# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឯកសារជំនួយ

# ការអប់រំកុមារពិការសតិបញ្ញា



រៀបរៀងដោយ ក្រសួងអប់រំ យុវជន និងកីឡា

ឆ្នាំ២០១៨

# បុព្វកថា

ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពត្រង់ចំណុចទី៤ ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សាផ្តោតសំខាន់លើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋានដែលជានាសមធម៌នៃការចូលរៀនរបស់កុមារគ្រប់ប្រភេទ។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំចងក្រងឯកសារជំនួយគ្រូបង្រៀនស្តីពី « **ការអប់រំកុមារពិការសតិបញ្ញា** » ដើម្បីលើកកម្ពស់គុណភាព សមត្ថភាពគ្រូបង្រៀន។ ឯកសារនេះមានគោលបំណងផ្តល់ចំណេះដឹងដល់លោកគ្រូអ្នកគ្រូលើផ្នែកទ្រឹស្តីផ្សារភ្ជាប់ទៅនឹងការប្រតិបត្តិ ដែលមានខ្លឹមសារ និងវិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងកុមារពិការសតិបញ្ញា រួមចំណែកលើកកម្ពស់គុណភាពបង្រៀន និងរៀន នៅតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនឱ្យកាន់តែប្រសើរឡើង។

ស្របពេលនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់មន្ត្រីពាក់ព័ន្ធមកពីដៃគូអភិវឌ្ឍរួមមានអង្គការសង្គ្រោះកុមារ អង្គការសាលារៀនទន្សាយ អង្គការជំនួយនៃក្តីសង្ឃឹមសម្រាប់សហគមន៍និងអង្គការពាក់ព័ន្ធផ្សេងទៀតដែលបានខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តក្នុងការកសាងឯកសារជំនួយគ្រូបង្រៀនស្តីពី « **ការអប់រំកុមារពិការសតិបញ្ញា** »នេះ ដើម្បីបំពេញឱ្យបាននូវសិទ្ធិក្នុងការទទួលបានការអប់រំសម្រាប់អ្នកសិក្សាដែលមានតម្រូវការអប់រំពិសេស។

ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់ឯកសារជំនួយគ្រូបង្រៀនសម្រាប់ជាមូលដ្ឋានជួយដល់កុមារពិការសតិបញ្ញា ដើម្បីរួមចំណែកសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ថ្ងៃព្រហស្បតិ៍ ៧ រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ឯកសារជំនួយគ្រូបង្រៀនស្តីពី«ការអប់រំកុមារពិការសតិបញ្ញា»ត្រូវបានរៀបចំឡើងដោយក្រសួងអប់រំ យុវជននិងកីឡា រួមមាននាយកដ្ឋានអប់រំពិសេស នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដោយសហការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធនិងអ្នកជំនួយការបច្ចេកទេស។

ឯកសារនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងឱ្យលោកគ្រូ អ្នកគ្រូទទួលបាននូវចំណេះដឹងទូទៅពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ លក្ខណៈតម្រូវការនិងវិធីសាស្ត្រក្នុងការជួយជំរុញការសិក្សារបស់កុមារពិការសតិបញ្ញាធ្វើឱ្យមានការរីកចម្រើនកាន់តែប្រសើរឡើង។ ម្យ៉ាងទៀតឯកសារនេះក៏បានបង្ហាញពីមធ្យោបាយនិងវិធីជួយរបស់គ្រូទៅដល់សិស្សពិការសតិបញ្ញានៅក្នុងថ្នាក់រៀន ឱ្យមានឱកាសចូលរួមក្នុងការសិក្សាជាមួយនឹងវិធីងាយៗដូចជា ល្បែងសិក្សា ដោយការអនុវត្តផ្ទាល់ដើម្បីធានាបានការអប់រំសម្រាប់អ្នកសិក្សាដែលមានតម្រូវការអប់រំពិសេសឱ្យទទួលបានជោគជ័យ។

ឯកសារជំនួយគ្រូបង្រៀនស្តីពី «ការអប់រំកុមារពិការសតិបញ្ញា» បានផ្តល់ព័ត៌មានជាមូលដ្ឋានដែលទាក់ទងនឹងកុមារពិការសតិបញ្ញា សម្រាប់ជួយឱ្យគ្រូទទួលបានចំណេះដឹងដើម្បីយកចិត្តទុកដាក់ដល់សិស្សពិការដូចសិស្សដទៃប្រកបដោយសមធម៌។

ឯកសារដែលក្រុមការងារបានរៀបចំឡើង រួមមានសៀវភៅអត្ថបទសម្រាប់អានស្តីពីការសិក្សាស្រាវជ្រាវចំនួន១២ប្រធានបទ សៀវភៅសម្រាប់គ្រូសម្របសម្រួល និង ឯកសារប្រតិបត្តិ(tool kits) សម្រាប់គ្រូបង្រៀនមេរៀនភាសាខ្មែរថ្នាក់ទី១ ដែលមានលំនាំនៃការបង្រៀន និងកិច្ចតែងការបង្រៀន សំបូរដោយបច្ចេកទេស និងសម្ភារសម្រាប់ជួយកុមារគ្រប់ប្រភេទ រៀននៅក្នុងថ្នាក់បរិយាបន្ន។ សៀវភៅអត្ថបទសម្រាប់អានមានចំនួន១២ប្រធានបទ ចំណែកសៀវភៅសម្រាប់អ្នកសម្របសម្រួល និងឯកសារប្រតិបត្តិសម្រាប់គ្រូបង្រៀន មិនទាន់បានគ្រប់ប្រធានបទនៅឡើយទេ។ ផ្អែកលើឯកសារគោលទាំង១២ប្រធានបទនេះ ក្រុមការងារបច្ចេកទេស កំពុងនិងបន្ត ផលិត tool kits ជាច្រើនទៀត ដើម្បីជួយដល់គ្រូបង្រៀននៅក្នុងថ្នាក់ នឹងចេញផ្សាយនាពេលឆាប់ៗខាងមុខ។

ក្រុមការងារយើងខ្ញុំនឹងរង់ចាំទទួលមតិយោបល់កែលម្អប្រកបដោយន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូទាំងអស់ដោយក្តីសោមនស្សរីករាយដើម្បីរួមចំណែកអភិវឌ្ឍវិស័យអប់រំ។

**ក្រុមការងាររចនាក្រងឯកសារ**

# មាតិកា


មេរៀនទី១ ........ 1

ដំណាក់កាលលូតលាស់របស់កុមារ  អាយុរបស់កុមារ ផ្អែកលើការលូតលាស់តាមដំណាក់កាល និងអាយុរបស់កុមារ ផ្អែកលើកាលូតលាស់ផ្នែកសង្គម ........ 1

១.១.វត្ថុបំណង ........ 1

១.៦.ការលូតលាស់តាមអាយុ៖ ........ 7

១.៧.ការវាស់វែងលើការលូតលាស់៖ ........ 7

១.៨.ការលូតលាស់ផ្នែកទំនាក់ទំនងសង្គមទៅតាមកម្រិតអាយុ ........ 7

១.៩.ការវាស់វែងពីការលូតលាស់ផ្នែកសង្គម៖ ........ 7

មេរៀនទី២ ........ 8

ការណែនាំអំពីពិការភាព ........ 8

២.១.វត្ថុបំណង ........ 8

២.២.និយមន័យ ........ 8

២.៣. ចំណាត់ថ្នាក់ពិការភាព ........ 8

ការរៀបចំកម្រងសំណួរ  ពាក់ព័ន្ធនឹងតម្រូវការរបស់កុមារដោយបង្កើតឡើងដើម្បីធ្វើការប្រៀបធៀបទៅនឹងទិន្នន័យកុមារជាលក្ខណៈអន្តរជាតិ Washington Group បានបង្កើតក្រុមការងារក្នុងឆ្នាំ២០០៩ ដែលដឹកនាំដោយការិយាល័យស្ថិតិជាតិនៃប្រទេសអ៊ីតាលី។ UNICEF បានចូលរួមនៅក្នុងក្រុមការងារនេះក្នុងឆ្នាំ២០១១។ ........ 12

២.៤. ម៉ូឌុលស្ដីពីសម្បទាកុមារ (អាយុពី ២ ដល់៤ឆ្នាំ) ........ 16

២.៥.ម៉ូឌុលស្ដីពីសម្បទាកុមារ (អាយុ ៥ ទៅ១៧ឆ្នាំ) ........ 20

មេរៀនទី៣ ........ 27

ខ្សោយបញ្ញា  ពិបាកក្នុងការសិក្សាមុខវិជ្ជា និងអូទីសឹម ........ 27

៣.១.វត្ថុបំណង ........ 27

៣.២.ខ្សោយបញ្ញា ..... 27
៣.១.២.ការចាត់ចំណាត់ថ្នាក់ ..... 28
៣.១.៣.លក្ខណៈសម្គាល់៖ ..... 31
៣.១.៤.មូលហេតុ៖ ..... 32
៣.១.៥.ការការពារ៖ ..... 34
៣.១.៦.ការវាស់ពីកម្រិតបញ្ញា (IQ)៖ ..... 36
៣.២.ការលំបាកក្នុងការសិក្សាមុខវិជ្ជា ..... 37
៣.២.១. និយមន័យ៖ ..... 37
៣.២.២. មូលហេតុ៖ ..... 41
៣.២.៣. វិធីបង្ការ៖ ..... 42
៣.៣.ភាពខុសប្រក្រតីនៃបណ្តុំអូទីសឹម (ASD) ..... 43
៣.៣.១.និយមន័យ៖ ..... 44
៣.៣.២.មូលហេតុរបស់ ASD៖ ..... 45
៣.៣.៣.សញ្ញាសម្គាល់ផ្សេងៗរបស់ ASD៖ ..... 46
៣.៣.៤.ការវាយតម្លៃពី ASD៖ ..... 47
៣.៣.៥.ការព្យាបាល ASD៖ ..... 48
មេរៀនទី៤ ..... 49
ពិការដោនស៊ីនដ្រូម និង ពិការចលករខួរក្បាល ..... 49
វត្ថុបំណង៖ ..... 49
៤.១.ដោនស៊ីនដ្រូម ..... 49
៤.១-១.និយមន័យ៖ ..... 49
៤.១.២.រោគសញ្ញា៖ ..... 50
៤.១.៣.ដើមហេតុ ហ្សែនរបស់ពិការដោនស៊ីនដ្រូម៖ ..... 51
៤.១.៤.កត្តាប្រឈម ..... 52
៤.១.៥.ការធ្វើតេស្តដើម្បីពិនិត្យ មើលក្នុងពេលកំពុងមានផ្ទៃពោះ៖ ..... 55
៤.១.៦.ការធ្វើតេស្តរោគវិនិច្ឆ័យក្នុងពេលមានផ្ទៃពោះ៖ ..... 56

៤.១.៧.តេស្តរោគវិនិច្ឆ័យចំពោះទារកទើបនឹងកើត៖ 57
៤.១.៨.ការព្យាបាល៖ 57
៤.២.ពិការចលករខួរក្បាល 58
៤.២.១.និយមន័យ៖ 58
៤.២.២ លក្ខណៈ 58
៤.២.៣.សញ្ញាដំបូង៖ 60
៤.២.៤.មូលហេតុ៖ 61
៤.២.៥.កត្តាហានិភ័យ៖ 63
៤.២.៦.ការចាត់ចំណាត់ថ្នាក់៖ 65
៤.២.៧ ការធ្វើរោគវិនិច្ឆ័យ៖ 70
៤.២.៨.ការព្យាបាល៖ 71
មេរៀនទី ៥ 83
ការរៀបចំក្រុមកុមារពិការ 83
វត្ថុបំណង៖ 83
៥.១. ការរៀបចំកុមារតាមក្រុម៖ 83
៥.២. កម្រិតអាយុ៖ 83
៥.៣. អាយុនៃការលូតលាស់របស់ខួរក្បាល៖ 83
មេរៀនទី៦ 85
កម្មវិធីសិក្សា និង បញ្ជីវាយតម្លៃសម្បទារបស់កុមារ 85
៦.១.វត្ថុបំណង៖ 85
៦.២.កម្មវិធីសិក្សា៖ 85
៦.៣.បញ្ជីវាយតម្លៃសម្បទាកុមារ ៖ 85
៦.៣.១.មត្តេយ្យសិក្សា 85
សកម្មភាពផ្ទាល់ខ្លួន ឬសកម្មភាពរស់នៅប្រចាំថ្ងៃ 86
សកម្មភាពសង្គម 86

សកម្មភាពការងារ......90
សកម្មភាពកំសាន្ត......90
៦.៣.២.ក្រុម៖ បឋមសិក្សា ១......90
សកម្មភាពផ្ទាល់ខ្លួនសម្រាប់ការរស់នៅប្រចាំថ្ងៃ......91
សង្គម......91
ការសិក្សា......93
សកម្មភាពការងារ......96
សកម្មភាពកំសាន្ត......96
៦.៣.៣. ក្រុម៖ បឋមសិក្សា ២......98
សកម្មភាពផ្ទាល់ខ្លួន ឬ សកម្មភាពសម្រាប់ការរស់នៅប្រចាំថ្ងៃ......98
ការធ្វើកិច្ចការផ្សេងៗ......102
សកម្មភាពកំសាន្ត......104
៦.៣.៤.ក្រុម៖ ថ្នាក់បឋមសិក្សា – III......105
មេរៀនទី៧......110
វិធីសាស្ត្របង្រៀន......110
វត្ថុបំណង៖......110
វិធីសាស្ត្របង្រៀនកុមារមានបញ្ហាខ្សោយបញ្ញា៖......110
វិធីសាស្ត្រផ្សេងៗសម្រាប់បង្រៀនកុមារពិការ......115
ឧទាហរណ៍មួយចំនួនក្នុងការបង្រៀនកុមារពិការ......118
មេរៀនទី៨......187
ផែនការអប់រំសម្រាប់កុមារម្នាក់ៗ......187
វត្ថុបំណង៖......187
៨.១. សេចក្តីផ្តើម ៖......187
៨.២. ធាតុផ្សំរបស់ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖......187
៨.៣. ទម្រង់គំរូរបស់ផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖......190

សេចក្តីណែនាំសម្រាប់ការបំពេញផ្នែក "ក" ..... 192
ការណែនាំសម្រាប់ការបំពេញផ្នែក "ខ" ..... 193
ផ្នែក ក ..... 195
ផ្នែក ខ ..... 196
ផ្នែក ខ ..... 197
មេរៀនទី ៩ ..... 199
កិច្ចតែងការបង្រៀនសម្រាប់ការបង្រៀនជាក្រុម ..... 199
ទម្រង់កិច្ចតែងការបង្រៀន៖ ..... 199
ទម្រង់គំរូ ..... 200
កិច្ចតែងការបង្រៀនសម្រាប់ការបង្រៀនជាក្រុម ..... 200
មេរៀនទី១០ ..... 203
ការគ្រប់គ្រងថ្នាក់រៀន ..... 203
វត្ថុបំណង៖ ..... 203
១០.១ និយមន័យ៖ ..... 203
១០.២ បច្ចេកទេសក្នុងការគ្រប់គ្រងថ្នាក់រៀន៖ ..... 204
មេរៀនទី១១ ..... 211
ការគ្រប់គ្រងអាកប្បកិរិយា ..... 211
និយមន័យ៖ ..... 211
ការគ្រប់គ្រងវិបត្តិអាកប្បកិរិយា៖ ..... 212
បច្ចេកទេសសម្រាប់ការកាត់បន្ថយវិបត្តិអាកប្បកិរិយា៖ ..... 215
វិធីសម្រាប់កាត់បន្ថយវិបត្តិអាកប្បកិរិយា៖ ..... 220
មេរៀនទី១២ ..... 224
វិធីក្នុងការវាយតម្លៃ និងការឱ្យសិស្សឡើងថ្នាក់ ..... 224
វិធីនៃការវាយតម្លៃ៖ ..... 224

លក្ខណៈវិនិច្ឆ័យសម្រាប់ឱ្យសិស្សឡើងថ្នាក់៖ ..... **225**

ឯកសារឧបសម្ព័ន្ធ ..... 228

**១. សេចក្តីណែនាំ សម្រាប់គ្រូសម្របសម្រួល**

- *ផែនការសម្រាប់បណ្តុះបណ្តាល*
- *កិច្ចតែងការសម្រាប់បណ្តុះបណ្តាល*

**២. លំហូរ វិធី គន្លឹះ និងល្បិចបង្រៀនបំណិនអំណានភាសាខ្មែរ**

- *ឯកសារជំនួយសម្រាប់គ្រូ ក្នុងការបង្រៀនបំណិនអំណានភាសាខ្មែរ នៅបឋមសិក្សា ពិសេសថ្នាក់ទី១*

៣. ឯកសារប្រេតិបត្តិ

*សម្រាប់បង្រៀនមេរៀនភាសាខ្មែរ ថ្នាក់ទី១ មានចំនួន១០មេរៀន*

# មេរៀនទី១

# ដំណាក់កាលលូតលាស់របស់កុមារ  អាយុរបស់កុមារ ផ្អែកលើការលូតលាស់តាមដំណាក់កាល និងអាយុរបស់កុមារ ផ្អែកលើកាលូតលាស់ផ្នែកសង្គម

## ១.១.វត្ថុបំណង

វត្ថុបំណងរបស់មេរៀននេះ  គឺដើម្បីសិក្សាស្វែងយល់អំពីនិយមន័យ  ដំណាក់កាលលូតលាស់របស់កុមារ  អាយុរបស់កុមារ ផ្អែកលើការលូតលាស់តាមដំណាក់កាល និងអាយុរបស់កុមារ ផ្អែកលើកការលូតលាស់ផ្នែកសង្គម។

## ១.២.សេចក្តីផ្តើម

ការសិក្សាស្វែងយល់ពីរបៀបដែលកុមារលូតលាស់ អាចជួយឱ្យយើងកំណត់នូវបញ្ហាដែលអាចកើតមានចំពោះកុមារ។  វាក៏អាចជួយឱ្យយើង  តម្រង់ទិសទៅរកបំណិនសមស្របដែលកុមារអាចរៀនសូត្របានទៅតាមអាយុជាក់លាក់របស់ពួកគេ។  យើងប្រើប្រាស់ដំណាក់កាលនៃការលូតលាស់  ដើម្បីសិក្សាពីការរីកចម្រើនទូទៅរបស់កុមារ។

## ១.៣.និយមន័យ និងគោលបំណងនៃដំណាក់កាលលូតលាស់របស់កុមារ

ដំណាក់កាលនៃការលូតលាស់គឺជាសញ្ញាសម្គាល់នៃការវិវឌ្ឍ ឬការលូតលាស់ផ្នែករាងកាយ ឬអាកប្បកិរិយា( សតិបញ្ញា )របស់ទារក   និងកុមារ។   ដំណាក់កាលទាំងនេះផ្តល់នូវព័ត៌មានសំខាន់ៗទាក់ទងនឹងការលូតលាស់របស់កុមារពីព្រោះដំណាក់កាលនីមួយៗមានភាពខុសគ្នា    ទៅតាមកម្រិតអាយុ ។ ឧទាហរណ៍ ការក្រឡាប់ ការវារ ឬលូន ការដើរ និងការនិយាយ ជាទូទៅត្រូវបានគេចាត់ទុកថាជាដំណាក់កាលនៃការលូតលាស់ដ៏សំខាន់នៅក្នុងប្រទេសជាច្រើនដើម្បីកំណត់ថា    បើសិនទារកកំពុងរីកលូតលាស់ ឬកំពុងវិវឌ្ឍដូចកុមារទូទៅ។

**ចំណុចសំខាន់ៗចំនួន៣ ដែលត្រូវចងចាំទាក់ទងនឹងដំណាក់កាលនៃការលូតលាស់មាន៖**

- ទារកភាគច្រើនចេះក្រឡាប់នៅពេលដែលគេមានអាយុប្រមាណ៣ខែ    និងចាប់ផ្តើមដើរនៅពេលដែលគេមានអាយុប្រមាណ១២ខែ។  ប្រទេស  និងវប្បធម៌ជាច្រើនកំណត់យកអាកប្បកិរិយាទាំងនេះថាជាដំណាក់កាលនៃការលូតលាស់ ។ នេះមិនមែនមានន័យថា ទារកម្នាក់នឹងចេះក្រឡាប់នៅថ្ងៃដែលគេគ្រប់អាយុ៣ខែ  ឬចាប់ផ្តើមដើរនៅថ្ងៃដែលគេមានអាយុ  គ្រប់មួយ

ឆ្នាំនោះទេ វាគ្រាន់តែជាការប៉ាន់ស្មានគ្រួសៗពីពេលវេលាដែលកុមារចាប់ផ្ដើម មានអាកប្បកិរិយាទាំងនេះប៉ុណ្ណោះ។

- ដំណាក់កាលនៃការលូតលាស់អាចមានលក្ខណៈខុសគ្នាទៅតាមវប្បធម៌ផ្សេងគ្នា។ឧទាហរណ៍ ទំនៀមទម្លាប់ វប្បធម៌មួយចំនួននៅសហរដ្ឋអាមេរិកមានជំនឿថា ការញញឹមដំបូង ជាដំណាក់កាលនៃការលូតលាស់ដ៏សំខាន់មួយរបស់ទារក។ ប្រជាជនកម្ពុជាជឿថា ទារកដែលមានអាយុ ០១ខែ ជាដំណាក់កាលនៃការលូតលាស់ដ៏សំខាន់មួយ ហើយមានការរៀបចំពិធីបង្កក់កូន ។
- ដំណាក់កាលនៃការលូតលាស់ កើតមានទៅតាមអាយុខុសៗគ្នារបស់កុមារ ហើយអាស្រ័យទៅតាមទម្លាប់នៃការចិញ្ចឹមបីបាច់ ។ ឧទាហរណ៍ នៅក្នុងប្រទេសលោកខាងលិចភាគច្រើន កុមារនៅចន្លោះអាយុ២ ឬ៣ឆ្នាំ យល់ដឹងនៅពេលដែលពួកគេត្រូវការទៅបង្គន់ ចំណែកឯប្រទេសមួយចំនួននៅអាស៊ី កុមារយល់ដឹងតាំងពីនៅវ័យក្មេងជាងនេះ ពោលគឺនៅអាយុ០១ឆ្នាំ ឬត្រឹមតែអាយុ០៦ខែ។ ទាំងនេះដោយសារម្ដាយនៅទ្វីបអាស៊ីភាគច្រើន បង្រៀនកូនពីរបៀបគ្រប់គ្រងការបត់ជើងតូច (នោម) តាំងតែពីនៅតូច ច្រើនជាងម្ដាយនៅប្រទេសលោកខាងលិចដែលប្រើខោទឹកនោមនៅពេលកូនមានអាយុ០១ឆ្នាំ ឬត្រឹមតែអាយុ០៦ខែ។

ចំណេះដឹងស្ដីពីដំណាក់កាលនៃការលូតលាស់ធ្វើឱ្យគ្រូបង្រៀន និងឪពុកម្ដាយមានសមត្ថភាពក្នុងការៈ

- យល់ដឹងថាកុមារបាន និងកំពុងលូតលាស់តាមដំណាក់កាលជាធម្មតា
- រំពឹងទុកមុនពីអ្វីដែលកុមារមានសមត្ថភាពក្នុងការធ្វើ ឬរៀនសូត្រនៅពេលបន្ទាប់ទៀត
- ជំរុញឱ្យមានការរីកចម្រើនរបស់កុមារស្របតាមអាយុរបស់គេ ។

**លំហាត់ទី១**

**តើដំណាក់កាលនៃការលូតលាស់ណាខ្លះរបស់កុមារដែលសំខាន់នៅក្នុងសង្គមរបស់អ្នក?**

ចូរគិតពីទារក និងកុមារនៅក្នុងគ្រួសារ និងសហគមន៍របស់អ្នក។ តើអាកប្បកិរិយាអ្វីដែលទារកធ្វើឱ្យអ្នករំភើប និងរីករាយ? តើមានការលូតលាស់ផ្នែករាងកាយណាខ្លះ ដែលអ្នកកត់សម្គាល់ឃើញថា កុមារកំពុងរីកលូតលាស់ដូចកុមារផ្សេងទៀតនៅក្នុងគ្រួសារ ឬសហគមន៍របស់អ្នកដែរ? តើលោក លោកស្រីមានរៀបចំពិធីបង្កក់ ឬពិធីសាសនាផ្សេងៗដើម្បីបង្ហាញនូវដំណាក់កាលជាក់លាក់នៃលូតលាស់នានារបស់កុមារា និងកុមារី ដែរឬទេ?

## ១.៤.ផ្នែកផ្សេងៗនៃការលូតលាស់របស់កុមារះ

គេអាចចាត់ថ្នាក់ដំណាក់កាលនៃការលូតលាស់របស់កុមារទៅតាមផ្នែក ឬវិស័យរួមមាន ការលូតលាស់ផ្នែករាងកាយ យល់ដឹង ការលូតលាស់ផ្នែកអារម្មណ៍ និងការលូតលាស់ផ្នែកសង្គម ។

**ក.ការលូតលាស់ផ្នែកកាយសម្បទាះ** ការលូតលាស់នេះរាប់បញ្ចូលទាំងការកើនទម្ងន់ និងការលូតកម្ពស់ ការផ្លាស់ប្តូររូបរាងកាយ និងការលូតលាស់បំណិនចលនា។ ចលនាមាន២ប្រភេទ គឺចលនាតូច ទាក់ទងនឹងចលនាដៃ ដូចជា សមត្ថភាពចាប់កាន់ស្លាបព្រា ឬខ្មៅដៃ និងផ្នែកចលនាធំ ទាក់ទងនឹងរាងកាយទាំងមូល ដូចជាការលោត ឬការឡើងជាដើម ។

**ខ.ការលូតលាស់ផ្នែកបញ្ញាះ** ចំណុចនេះរាប់បញ្ចូលទាំងការលូតលាស់ផ្នែកសតិបញ្ញា និងភាសា ការកើនឡើងនូវសមត្ថភាពក្នុងការចងចាំ និងសមត្ថភាពក្នុងការផ្តល់ហេតុផល ។ កុមារដែលដល់វ័យចូលរៀន ពួកគេរៀនពីរបៀបអាន សរសេរ និងការគណនា។

**គ.ការលូតលាស់ផ្នែកអារម្មណ៍ និង សង្គមះ** ចំណុចនេះរាប់បញ្ចូលទាំងការលូតលាស់បុគ្គលិកលក្ខណៈ និងម្ចាស់ការលើខ្លួនឯង សមត្ថភាពក្នុងការរាប់អានមិត្តភក្តិ និងការយល់ពីបញ្ហាផ្នែកសីលធម៌ ដូចជាដឹងពីអត្ថន័យនៃការនិយាយកុហកជាដើម។



រូបភាពនេះបង្ហាញពីរបៀបនៃការយល់របស់កុមារពីការប្រែប្រួលរបស់ពិភពលោកទៅតាមការរីកលូតលាស់របស់គេ។

## ១.៥.ដំណាក់កាលនៃការលូតលាស់របស់កុមារនៅកម្រិតបឋមសិក្សា

ដំណាក់កាលដំបូង ទារកត្រូវការអ្នកមើលថែ កាលណាធំឡើង ពួកគេរៀនពីជំនាញផ្សេងៗដើម្បីជួយខ្លួនឯង។ នៅអាយុ៦ឆ្នាំ កុមារអាចធ្វើកិច្ចការផ្សេងៗដោយខ្លួនឯង ដូចជា ការស្លៀកពាក់ លេងបាល់ យកវត្ថុផ្សេងៗ និងចេះស្វាគមន៍ភ្ញៀវ។ នៅសាលារៀន ពួកគេចាប់ផ្តើមរាប់អានមិត្តភក្តិ

ក្រៅពីសមាជិកគ្រួសារ។ ជំនាញផ្នែករាងកាយ ផ្នែកសង្គម និងផ្នែកផ្លូវចិត្ត មានការលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងដំណាក់កាលនេះ។



រូបភាពនេះ អាចពណ៌នាអំពីជំនាញ និងអាកប្បកិរិយាមួយចំនួនរបស់កុមារនៅសាលារៀន។

**ការលូតលាស់ផ្នែករាងកាយ បញ្ញា អារម្មណ៍ និងទំនាក់ទំនងសង្គមរបស់កុមារដែលចូលរៀន**

- **ទំនាក់ទំនងសង្គម និងអារម្មណ៍៖**
  - ស្វាគមន៍មនុស្សចាស់បានយ៉ាងត្រឹមត្រូវ
  - លេងជាមួយក្មេងផ្សេងទៀតដោយមានការសហការណ៍គ្នាល្អ (ឧទាហរណ៍ គោរពតាមក្បួននៃការ លេងល្បែង)
  - អាចរម្ងាប់អារម្មណ៍របស់ខ្លួនបាននៅពេលដែលពួកគេមិនសប្បាយចិត្ត ឬអន់ចិត្ត
  - សុំអភ័យទោសនៅពេលដែលពួកគេធ្វើអ្វីមួយខុស ឧទាហរណ៍ មិនគោរពតាមច្បាប់
  - យល់នៅពេលដែលអ្នកដទៃនិយាយកុហកពួកគេ
  - សុំការអនុញ្ញាតិមុនពេលយករបស់អ្វីមួយដែលជាកម្មសិទ្ធិរបស់អ្នកដទៃ
  - ដឹង(យល់)ពីអារម្មណ៍ផ្ទាល់របស់ខ្លួន
  - ដឹង(យល់)ពីអារម្មណ៍របស់អ្នកផ្សេងទៀត
- **ផ្នែកបញ្ញា៖**
  - និយាយដោយប្រើប្រាស់ប្រយោគពេញលេញ
  - អនុវត្តតាមការណែនាំយ៉ាងហោចណាស់ក៏3ជំហានដែរ
  - តម្រៀបរូបភាពតាមលំដាប់បានយ៉ាងហោចណាស់ក៏3ផ្ទាំងដែរដើម្បីរៀបរាប់ពីសាច់រឿងមួយ
  - រាប់(អាន)តួអក្សរ
  - កាន់សៀវភៅរឿងបានត្រឹមត្រូវ (មិនបញ្ច្រាស)
  - សម្គាល់(ចំណាំ)អ្វីដែលដូចគ្នា និងខុសគ្នា(ឧទាហរណ៍ តូច និងធំ ក្រាស និងស្តើង)

- យល់ពីការណែនាំពីទីតាំង ឬលំហ[ទំហំ] ( ឧទាហរណ៍ នៅលើ នៅក្រោម នៅក្នុង នៅក្រៅ នៅខាងឆ្វេង នៅខាងស្តាំ )
- រាប់លេខពីលេខ1ដល់លេខ10
- ស្គាល់ពណ៌នៅពេលគេបង្ហាញ ( ឧទាហរណ៍ ក្រហម ស ខ្មៅ ខៀវ )
- ស្គាល់រូបធរណីមាត្រ ( ឧទាហរណ៍ រង្វង់ ការ៉េ ត្រីកោណ ផ្កាយ រូបបេះដូង )
- យល់ពីពេលវេលានៃថ្ងៃ (ពេលព្រឹក ពេលរសៀល ថ្ងៃនេះ ថ្ងៃស្អែក)
- អាចប្រាប់ឈ្មោះថ្ងៃក្នុងសប្តាហ៍ ( ឧទាហរណ៍ ថ្ងៃនេះជាថ្ងៃ ...)

➢ **ផ្នែករាងកាយ៖**

**ចលនាធំ**

- អាចញ៉ាំ ស្លៀកពាក់ ទៅបង្គន់ ឬបន្ទប់ទឹកដោយខ្លួនឯង
- ដើរ ឬរត់បានយ៉ាងងាយស្រួល
- បោះ និងចាប់បាល់
- ឡើង និងចុះជណ្តើរម្តងមួយកាំៗ
- លោតជើងពីរ លោតជើងម្ខាង
- អាចទាត់ និងត្រេះបាល់

**ចលនាតូច**

- កាន់ខ្មៅដៃបានត្រឹមត្រូវ ( កាន់ដោយប្រើម្រាមដៃ៣ [tripod grasp] )
- កាន់ចង្កឹះបានត្រឹមត្រូវ ( កាន់ដោយប្រើម្រាមដៃ២ [pincer grasp] )
- អាចបើកគម្របដបទឹក
- ប្រើប្រាស់កន្ត្រៃ
- ហែកក្រដាស

➢ **ភាពយឺតយ៉ាវ តាមដំណាក់កាលនៃការលូតលាស់៖**

កុមារមួយចំនួនអាចចំណាយពេលយូរជាងកុមារធម្មតាតាមដំណាក់កាលនៃការលូតលាស់ ។ មានន័យថា កុមារមានការយឺតយ៉ាវចំពោះការលូតលាស់ផ្នែកបញ្ញា រាងកាយ សង្គម ឬក៏ទាំងបីផ្នែកនេះតែម្តង។ ឧទាហរណ៍ រឿន សាយ៉ាណា ជាសិស្សដែលមានអាយុ៨ឆ្នាំ រៀននៅថ្នាក់អប់រំ បរិយាបន្ន នៅសាលាបឋមសិក្សាជ្រៃ ក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង ដែលគាំទ្រដោយអង្គការជនពិការអន្តរជាតិ។



សាយ៉ាណាជាកុមារ ដោនស៊ីនដ្រូម (Down's syndrome) ហើយមានភាពយឺតយ៉ាវផ្នែកបញ្ញា ធ្វើឱ្យមានការលំបាកក្នុងការរៀនសូត្រជាងមិត្តរួមថ្នាក់។ គាត់ពុំមានភាពយឺតយ៉ាវណាមួយទាក់ទងនឹងការលូតលាស់ផ្នែករាងកាយទេ ហើយអាចលេងល្បែងផ្សេងៗជាមួយមិត្តរួមថ្នាក់បាន។ ទោះបីជាគាត់ពិបាកធ្វើតាមការណែនាំនៃការលេងល្បែង និងការប្តូរវេនគ្នាក៏ដោយ។ ដូច្នេះ អ្នកគ្រូ ហាស ស៊ីនឹម ជាអ្នកបង្រៀន សាយ៉ាណា បានធ្វើការផ្លាស់ប្តូរវិធីបង្រៀនមួយចំនួនៈ

- អនុញ្ញាតឱ្យគាត់ពាក់អាវរងារនៅក្នុងថ្នាក់ ដើម្បីឱ្យ សាយ៉ាណា មានអារម្មណ៍កក់ក្តៅ។
- ឱ្យ សាយ៉ាណា អង្គុយនៅខាងក្រោយ ដើម្បីឱ្យគ្រូរបស់គាត់អាចធ្វើការដាច់ដោយឡែកជាមួយគាត់ ប៉ុន្តែក្រោយមកអ្នកគ្រូបានប្តូរកន្លែងអង្គុយ (ខាងមុខ ជិតសិស្សពូកែ) ដើម្បីតាមដានការរីកចម្រើនជាប់ជាប្រចាំ ។
- ដាក់កិច្ចការងាយៗដូចជារាប់លេខពីលេខ១រហូតដល់លេខ១០ ខណៈពេលមិត្តរួមថ្នាក់រាប់ដល់លេខ១០០ ។
- ហៅគាត់ឱ្យមកសរសេរចម្លើយនៅលើក្តារខៀនដូចសិស្សផ្សេងៗទៀតដែរ ដោយប្រើប្រាស់ក្តារខៀនមួយចំណែកដែលទុកសម្រាប់គាត់។ នៅពេលគាត់ធ្វើកិច្ចការរបស់គាត់ចប់ អ្នកគ្រូឱ្យមិត្តរួមថ្នាក់ទះដៃដើម្បីលើកទឹកចិត្តដល់ សាយ៉ាណា ។
- ណែនាំមិត្តរួមថ្នាក់មិនឱ្យបង្អាប់ ឬសើចចំអក នៅពេល សាយ៉ាណា មានកំហុសណាមួយ ។

គ្រូបង្រៀនរបស់សាយ៉ាណាមានប្រសាសន៍ថាៈ «មានសិស្ស ដោនស៊ីនដ្រូមDown's syndrome មិនមែនជារឿងងាយស្រួលទេ ពីព្រោះគាត់មិនអាចរៀនជាមួយសិស្សផ្សេងៗទៀតបានគ្រប់ពេល។ ប៉ុន្តែខ្ញុំដឹងថា វាជាភារកិច្ចរបស់ខ្ញុំក្នុងការបង្រៀនកុមារទាំងអស់។ ដូច្នេះខ្ញុំត្រូវផ្លាស់ប្តូរការបង្រៀនពីរ ឬបីចំណុចរបស់ខ្ញុំ ដែលខ្ញុំអាចជួយគាត់បាន។ ខ្ញុំបានទទួលការបំប៉ន ពីអង្គការជនពិការអន្តរជាតិ ពីវិធីនៃការបង្រៀន និងផ្លាស់ប្តូរវិធីដែលមានលក្ខណៈសាមញ្ញ ដើម្បីជួយសិស្សទាំងអស់គ្នា។

## ១.៦.ការលូតលាស់តាមអាយុ៖

ការលូតលាស់តាមអាយុគឺជាការវាស់វែងនូវសមិទ្ធផលមួយ ដែលគេបង្ហាញទៅតាមលំដាប់នៃអាយុរបស់កុមារដទៃទៀត ពីកម្រិតដែលអាចធ្វើបាន។ វាក៏បង្ហាញពីការរីកចម្រើនពេញលក្ខណៈរបស់កុមារដែលបញ្ជាក់ទៅតាមអាយុ ហើយត្រូវបានកំណត់តាមរយៈរង្វាស់ស្តង់ដា ដូចជាទំហំ និងខ្នាតនៃដងខ្លួន តាមរយៈការធ្វើសកម្មភាព ផ្នែកសង្គម និងចិត្តសាស្ត្រ ផ្នែកចលនា និង ការធ្វើតេស្តផ្នែកខួរក្បាល និងភាពឈ្លាសវៃ។

## ១.៧.ការវាស់វែងលើការលូតលាស់៖

ការវាស់វែងលើការលូតលាស់ គឺបង្ហាញជាតួលេខនូវកម្រិតនៃការលូតលាស់របស់កុមារម្នាក់ដែលគេបានវាស់វែងតាមរយៈការចែកអាយុនៃការលូតលាស់ ជាមួយនឹងលំដាប់អាយុ រួចគុណនឹង ១០០ (អាយុនៃការលូតលាស់ឬលំដាប់អាយុ×១០០)។

## ១.៨.ការលូតលាស់ផ្នែកទំនាក់ទំនងសង្គមទៅតាមកម្រិតអាយុ

ការលូតលាស់ផ្នែកទំនាក់ទំនងសង្គមទៅតាមកម្រិតអាយុ គឺជាការប៉ាន់ស្មានមួយពីលទ្ធភាពរបស់មនុស្សម្នាក់នៅក្នុងស្ថានភាពសង្គមដែលទាក់ទងនឹងស្តង់ដាទូទៅ។ ចំពោះកុមារតូច ការលូតលាស់ផ្នែកទំនាក់ទំនងសង្គមទៅតាមកម្រិតអាយុ ជាទូទៅត្រូវបានគេកំណត់តាមរយៈការសម្ភាសឪពុក ម្តាយ និងមនុស្សពេញវ័យ ផ្សេងទៀតដើម្បីដាក់ពិន្ទុ។ ការលូតលាស់ផ្នែកទំនាក់ទំនងសង្គមទៅតាមកម្រិតអាយុគឺត្រូវបានកំណត់តាមរយៈកម្រិតនៃអាកប្បកិរិយាដែលមានការផ្លាស់ប្តូរ។

## ១.៩.ការវាស់វែងពីការលូតលាស់ផ្នែកសង្គម៖

ការវាស់វែងពីការលូតលាស់ផ្នែកសង្គម គឺជាការបង្ហាញជាតួលេខនូវកម្រិតនៃការលូតលាស់ផ្នែកសង្គមរបស់កុមារ ដូចដែលគេបានវាស់វែងតាមរយៈការចែកអាយុនៃការលូតលាស់ផ្នែកសង្គមជាមួយនឹងលំដាប់អាយុ រួចគុណនឹង១០០(អាយុនៃការលូតលាស់ផ្នែកសង្គមឬលំដាប់អាយុ×១០០)។

# មេរៀនទី២

# ការណែនាំអំពីពិការភាព

## ២.១.ទស្សបំណាង

សិក្សាស្វែងយល់អំពីនិយមន័យ ចំណាត់ថ្នាក់នៃពិការភាព និងគោលគំនិតនៃម៉ូឌុលសម្បទារបស់កុមារ។

### ២.២.និយមន័យ

សំដៅទៅលើជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬ សតិបញ្ញា បណ្ដាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃ ។ ពិការភាពមានដូចជាពិការ ឬពិបាកផ្នែករាងកាយ មើល ស្ដាប់ សតិបញ្ញា ផ្លូវចិត្ត និង ប្រភេទពិការផ្សេងៗទៀត ។

### ២.៣. ចំណាត់ថ្នាក់ពិការភាព

ពិការភាពមានច្រើនប្រភេទរួមទាំងការពិបាកផ្នែករាងកាយ និងផ្លូវចិត្តដែលអាចរាំងស្ទះ ឬចុះខ្សោយសមត្ថភាពរបស់មនុស្សម្នាក់ៗក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន។

គេអាចបែងចែកពិការភាពទៅតាមប្រភេទដូចខាងក្រោម៖

| ប្រភេទពិការ | ផ្នែក | ការពណ៌នា |
|---|---|---|
| 1.ពិការកាយសម្បទា និងពិបាកក្នុងការធ្វើចលនា | • ពិការចលករខួក្បាល (CP)<br>• ខូចទ្រង់ទ្រាយអវយវៈ<br>• បាត់បង់អវយវៈ (ឧទាហរណ៍ ដោយសារគ្រោះថ្នាក់) | • កុមារដែលមានពិការភាពផ្នែករាងកាយ និងពិបាកធ្វើចលនាជាទូទៅពុំមានតម្រូវការរៀនសូត្រពិសេសដាច់ដោយឡែកទេ ពួកគេគ្រាន់តែត្រូវការមធ្យោបាយសម្រាប់ទៅសាលារៀន ថ្នាក់រៀន (និងអាចត្រូវការឧបករណ៍ជំនួយផ្សេងៗដើម្បីជួយពួកគេក្នុងការអាន សរសេរ ឬផ្លាស់ទី)។<br>• កុមារ CP មួយចំនួនមានការពិបាកក្នុងការនិយាយ ឬជំងឺរមួលសារពាង្គកាយ ឬផ្នែកវិញ្ញាណ ប៉ុន្តែត្រូវការវាយតម្លៃឱ្យបានត្រឹមត្រូវជាមុនសិន។ |
| 2.ពិបាកក្នុងការមើល | • ខ្សោយគំហើញ (មើលឃើញមិនច្បាស់) | • ជាទូទៅគេជួយកុមារដែលខ្សោយគំហើញ ក្នុងកម្រិតទាប ឬមធ្យមបានតាមរយៈ ការផ្ដល់វ៉ែនតា រៀបចំទីកន្លែងអង្គុយក្នុងថ្នាក់រៀនឱ្យបានសមស្រប |

| | | |
|---|---|---|
| | • ងងឹតទាំងស្រុង (មើលមិនឃើញទាល់តែសោះ) | ឬផ្តល់ឯកសារដែលបោះពុម្ពជាអក្សរធំៗ ...។ |
| 3.ពិបាកក្នុងការនិយាយនិងការស្តាប់ (វិញ្ញាណ) | • ពិបាកក្នុងការស្តាប់កម្រិតស្រាល<br>• ពិបាកស្តាប់កម្រិតមធ្យម<br>• ថ្លង់ និងឬគ<br>• ពិបាកក្នុងការនិយាយឬការប្រាស្រ័យទាក់ទង | • ជាទូទៅសិស្សនៅក្នុងសាលារៀន មានការពិបាកក្នុងការស្តាប់ កម្រិតស្រាលច្រើនជាងអ្នកដែលពិបាកក្នុងការស្តាប់កម្រិតធ្ងន់ ។ រៀបចំកន្លែងអង្គុយឱ្យបានសមស្រប ប្រើប្រាស់ឧបករណ៍ជំនួយក្នុងការស្តាប់ សម្ភារឧបទ្ទេស និង ប្រើកាយវិការអាចជួយដល់កុមារដែលមានបញ្ហាស្តាប់កម្រិតស្រាល ។ |
| 4.ពិបាកផ្នែកសង្គម - អារម្មណ៍ | • បញ្ហាថប់បារម្ភ<br>• បញ្ហាអាកប្បកិរិយា | • ការរៀនសូត្ររបស់កុមារទទួលរងផលប៉ះ ពាល់ជាអវិជ្ជមានដោយសារអារម្មណ៍នៃការព្រួយចិត្តឬភាពភ័យខ្លាច(ទាក់ទងនឹង បញ្ហារបស់បុគ្គល ឬសាលារៀន)។<br>• ជារឿយៗកុមារបង្ហាញអាកប្បកិរិយា ឬអារម្មណ៍មិនសមស្រប ក្នុងកាលៈទេសៈធម្មតា (ឧទាហរណ៍ កុមារដើរចេញពីកន្លែងអង្គុយ រំខានមិត្តភក្តិ វាយអ្នកដទៃ មិនស្តាប់គ្រូបង្រៀន បំផ្លាញទ្រព្យសម្បត្តិ មិនឆ្លើយតបនឹងការកែតម្រូវរបស់គ្រូបង្រៀន កុមារអាចផ្ទង់អារម្មណ៍បានយ៉ាងច្រើន ៦០%នៃរយៈពេលបំពេញកិច្ចការ)។ |
| 5.ខ្សោយបញ្ញា ឬការលូតលាស់យឺត | • ដោនស៊ីនដ្រូម<br>• ការលូតលាស់យឺត | • ខ្សោយបញ្ញាប៉ះពាល់គ្រប់ផ្នែកទាំងអស់នៃការលូតលាស់របស់កុមារ។ កុមារមានការលូតលាស់យឺតផ្នែករាងកាយ ការនិយាយស្តី ការថែទាំខ្លួន និងបំណិនក្នុងការរៀនសូត្រ ។ ពួកគេមានកម្រិតពិន្ទុបញ្ញា(IQ)ក្រោមមធ្យម ប៉ុន្តែពួកគេមិនមានជំងឺផ្លូវចិត្តទេ ។ នៅពេលមានការគាំទ្រដល់កុមារដែលមានការលូតលាស់យឺត អាចទទួលបាននូវកម្រិតពិន្ទុបញ្ញា(IQ) ធម្មតាខ្លះដែរ បើប្រៀបធៀបនឹងកុមារធម្មតាដែលមានវ័យដំណាលគ្នា ។ |

| | | |
|---|---|---|
| | | • ក្នុងចំណោមកុមារខ្សោយបញ្ញាទាំងអស់មាន៨៥% ជាកុមារខ្សោយបញ្ញាកម្រិតស្រាល ។<br>កម្រិតស្រាល៖កម្រិតពិន្ទុបញ្ញា(IQ)ពី៥០ទៅ៧០ មានការលូតលាស់យឺតជាងកុមារទូទៅនៅគ្រប់ផ្នែកទាំងអស់ ប៉ុន្តែផ្នែករាងកាយមានភាពប្រក្រតី។កុមារមានសមត្ថភាពរៀនពីបំណិនជីវិតយ៉ាងស្ទាត់ជំនាញ អាចទទួលបានបំណិនក្នុងការអាន និង បំណិន គណិតវិទ្យារហូតដល់ថ្នាក់ទី៣ ដល់ថ្នាក់ទី៦ និងមានសមត្ថភាពចូលរួមក្នុងសកម្មភាពសង្គម និង សកម្មភាពប្រចាំថ្ងៃ។<br>កម្រិតមធ្យម៖ កម្រិតពិន្ទុបញ្ញា(IQ) ពី៣៥ ដល់៤៩ មានការលូតលាស់យឺតគួរឱ្យកត់សម្គាល់(ការនិយាយ បំណិនចលនា...) មានសមត្ថភាពទំនាក់ទំនងក្នុងកម្រិតងាយៗ យល់ដឹងបំណិនមូលដ្ឋានផ្នែកសុខភាព សុវត្ថិភាព ការថែទាំខ្លួន និងអាចធ្វើដំណើរបានជិតៗទៅកន្លែងដែលធ្លាប់ស្គាល់ដោយខ្លួនឯង។ |
| 6.បញ្ហាដំណើរការប្រព័ន្ធប្រសាទ | • ពិបាកផ្ទង់អារម្មណ៍និងសកម្មជ្រុល<br>• អូទីស៊ឹម(Autism Spectrum Disorder) | • ចូរចាំថា កុមារជាច្រើនមិនអាចអង្គុយនៅស្ងៀមបានយូរ ក្នុងការបំពេញកិច្ចការ ផ្សេងៗរហូតចប់ ឬរៀបចំផែនការជាមុនបានទេ។ ចំណុចនេះមិនមែនមានន័យថាពួកគេពិការឡើយ។<br>• កុមារអូទីស៊ឹម(ASD)ពិបាកចងមិត្ត ចូលចិត្តនៅតែឯង និងពិបាកយល់ពីអារម្មណ៍អ្នកដទៃ ។ ពិបាកក្នុងការផ្លាស់ប្តូរទម្លាប់ប្រចាំថ្ងៃ ដែលជះឥទ្ធិពលអវិជ្ជមានចំពោះអាកប្បកិរិយារបស់កុមារ។ កុមារអូទីស៊ឹម(ASD)មួយចំនួនមានកម្រិតពិន្ទុបញ្ញា (IQ)ខ្ពស់ចំពោះផ្នែកណាមួយជាក់លាក់ ។ |
| 7.ពិបាកក្នុងការសិក្សាមុខវិជ្ជា | • ពិបាកអាន (Dyslexia)<br>• ពិបាកគណនាលេខ | • ពិបាកក្នុងការសិក្សាមុខវិជ្ជាគឺជាភាពខ្សោយចំពោះបំណិនជាក់លាក់ណាមួយក្នុងការសិក្សា ឧទាហរណ៍ ការអាន ការសរសេរ ឬគណិតវិទ្យា រីឯបញ្ហាខ្សោយបញ្ញាមានផលប៉ះពាល់គ្រប់មុខវិជ្ជានៃ |

| | | |
|---|---|---|
| | (Dyscalculia)<br>• ពិបាកសរសេរ (Dysgraphia) | ការសិក្សា ។ |
| 8. ពិការផ្សេងៗ | • ជំងឺប្រកាច់<br>• ឆ្វែបមាត់<br>• ជើងខ្វេរ... | • ជំងឺប្រកាច់មិនមែនបណ្តាលមកពីជំនឿសាសនា វប្បធម៌ ឬសង្គមនោះទេ ហើយជំងឺនេះអាចព្យាបាលដោយការប្រើថ្នាំ ។<br>• មាត់ឆែប ឬជើងខ្វេរអាចស្តារនីតិសម្បទាបានតាមរយៈឧបករណ៍ជំនួយ និង ការវះកាត់ ។ |

**កំណត់សម្គាល់៖**

1. កុំសន្មតថា កុមារមានពិការភាពផ្សេងថែមទៀត លើកលែងតែមានការវាយតម្លៃត្រឹមត្រូវពីអ្នកមានជំនាញប៉ុណ្ណោះ ។
2. កុមារអាចធ្លាប់ជួបបញ្ហាទំនាក់ទំនងសង្គម និងមនោសញ្ចេតនា ឬក៏អាចជួបបញ្ហាអាកប្បកិរិយាដែលបណ្តាលមកពីភាពតក់ស្លុតអ្វីមួយ (ឧទាហរណ៍ អំពើហិង្សា មានសមាជិកក្នុងគ្រួសារស្លាប់)។ ទាំងនេះមិនមែនជាពិការភាពទេ ។
3. ៩០%នៃពិការភាពមិនអាចមើលឃើញទេ ភាគច្រើនពិការកម្រិតស្រាល ឬមធ្យមប៉ុណ្ណោះ មិនមែនកម្រិតធ្ងន់ធ្ងរទេ ។
4. កុមារមានប្រភេទពិការដូចគ្នា មិនជួបបញ្ហាដូចគ្នាទេ ជាទូទៅពួកគេមានតម្រូវការគាំទ្រផ្សេងៗគ្នា។
5. កុមារដែលទទួលបានឧបករណ៍ជំនួយ ដើម្បីជួយឱ្យពួកគេរៀនបានដូចមិត្តភក្តិរបស់គេ មិនគួរដាក់ងារថាជាកុមារមាន«តម្រូវការពិសេស»នោះទេ។
6. កុមារប្រហែលជាមានតម្រូវការដំបូងនៃចំណាត់ថ្នាក់ ឬប្រភេទណាមួយ ដែលមានឥទ្ធិពលទៅលើផ្នែកដទៃទៀតក្នុងកម្រិតណាមួយ។ តម្រូវការខ្លះមានទំនាក់ទំនងគ្នា និងមានផលប្រយោជន៍ ដើម្បីឆ្លុះបញ្ចាំងទៅលើតម្រូវការរបស់កុមារទាំងមូល។
7. ពាក្យថា «ជំងឺផ្លូវចិត្ត» ត្រូវបានប្រើប្រាស់នៅពេលដែលមនុស្សមានសុខភាពល្អវិវត្តទៅជាមានជំងឺ ដែលប៉ះពាល់ដល់ទឹកមុខ អារម្មណ៍ និងអាកប្បកិរិយារបស់គេ។ គេអាចជាសះស្បើយឡើងវិញ ក្នុងករណីដែលមានការព្យាបាលដ៏ត្រឹមត្រូវ។

**យោងទៅតាមម៉ូឌុលក្រុមWashington ឬ របស់UNICEF ស្ដីពីសម្បទារបស់កុមារៈ**

កម្រមានការស្រាវជ្រាវ និងមានទិន្នន័យស្ដីពីពិការភាពរបស់កុមារ ដែលធ្វើឱ្យរាំងស្ទះដល់ប្រសិទ្ធភាពក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីនានា។

អនុសញ្ញាស្ដីពីសិទ្ធិជនពិការនៃអង្គការសហប្រជាជាតិឆ្នាំ២០០៦ បានទទួលស្គាល់ថា «កុមារមានពិការភាពផ្នែករាងកាយ ផ្លូវចិត្ត សតិបញ្ញា ឬវិញ្ញាណ» មានសិទ្ធិ និងសេរីភាពដូចគ្នានិងកុមារដទៃទៀត។ អនុសញ្ញានេះបន្តទៀតថាៈ «គ្រប់សកម្មភាពទាំងអស់ដែលទាក់ទងនឹងឧត្ដមប្រយោជន៍របស់កុមារ ត្រូវយកមកពិចារណាជាអាទិភាព» និង «កុមារពិការមានសិទ្ធិបញ្ចេញមតិយោបល់ដោយសេរីនូវរាល់បញ្ហាដែលប៉ះពាល់ដល់ពួកគេ»។

ការរើសអើងចំពោះកុមារមានពិការភាព បណ្ដាលឱ្យកាត់បន្ថយការទទួលបានសេវាសង្គមជាមូលដ្ឋាន ជាពិសេសសេវាអប់រំ និងកង្វះការទទួលស្គាល់ជាទូទៅ។

ការដោះស្រាយការរើសអើង និងការលើកកំពស់បែបបរិយាបន្ន គឺជាបញ្ហាមួយដែលទាក់ទងគ្រប់វិស័យទាំងអស់។ វាអាចជោគជ័យបានតាមរយៈការទទួលបានព័ត៌មាន ការស្វែងរកការគាំទ្រ ការពង្រឹងគោលនយោបាយ ព្រមទាំងការសម្របសម្រួល ដើម្បីទទួលបានសេវាកម្មផ្សេងៗ ការស្ដាប់ និងពិចារណាមតិយោបល់របស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ វានៅតែជាឧបសគ្គ ដោយសារខ្វះទិន្នន័យកុមារពិការ ដែលគួរឱ្យទុកចិត្ត។ ទាំងនេះដោយសារតែការខ្វះការសិក្សាស្រាវជ្រាវ និងការប្រមូលទិន្នន័យពីកុមារមានពិការភាព ជាពិសេសនៅបណ្ដាប្រទេសកំពុងអភិវឌ្ឍ ហើយទំនងជាមានបញ្ហាថែមទៀតដោយសារការឱ្យនិយមន័យអំពីពិការភាពមានភាពខុសគ្នាទៅតាមប្រទេសនីមួយៗ។ បច្ចុប្បន្ននេះ មិនមានទិន្នន័យពីពិការភាពជាសាកលដែលអាចជឿជាក់បានអំពីកុមារទេ ទោះបីជាបាន និងកំពុងមានការខិតខំប្រឹងប្រែងនានា ក្នុងការកែលម្អស្ថានភាពតាមរយៈការប្រើប្រាស់និយមន័យ ចំណាត់ថ្នាក់ និងវិធីសាស្ត្រក្នុងការកំណត់អត្តសញ្ញាណដែលបានឯកភាពជាសាកលក៏ដោយ។

ការរៀបចំកម្រងសំណួរ ពាក់ព័ន្ធនឹងតម្រូវការរបស់កុមារដោយបង្កើតឡើងដើម្បីធ្វើការប្រៀបធៀបទៅនឹងទិន្នន័យកុមារជាលក្ខណៈអន្តរជាតិ Washington Group បានបង្កើតក្រុមការងារក្នុងឆ្នាំ២០០៩ ដែលដឹកនាំដោយការិយាល័យស្ថិតិជាតិនៃប្រទេសអ៊ីតាលី។ UNICEF បានចូលរួមនៅក្នុងក្រុមការងារនេះក្នុងឆ្នាំ២០១១។

សកម្មភាពចម្បងជាអាទិភាពនៃក្រុមនេះ គឺការរៀបចំនូវកម្រងសំណួរខ្លីៗដើម្បីឆ្លុះបញ្ចាំងពីផ្នត់គំនិតនាពេលបច្ចុប្បន្នទៅលើសម្បទារបស់កុមារ សម្រាប់បញ្ចូលទៅក្នុងការធ្វើជំរឿន និងអង្កេត។ ម៉ូឌុលថ្មី ប្រើប្រាស់ឯកសារពី "International Classification of Functioning, Disability and

Health-Children & Youth (ICF-CY) (ICF-CY)″ ដែលជាក្របខណ្ឌការងាររបស់អង្គការសុខភាពពិភពលោក សម្រាប់វាស់វែងពីពិការភាព។

ទិន្នន័យជាសាកលស្តីពីកុមារពិការ ជាទូទៅមិនអាចប្រៀបធៀបគ្នាបានទេ ដោយសារតែការមានឧបករណ៍ វិធីសាស្រ្ត និងនិយមន័យពិការភាពខុសៗគ្នា។ UNICEF និង Washington Group បានបង្កើតឧបករណ៍ថ្មីមួយស្តីពីសម្បទារបស់កុមារ និងពិការភាព ដើម្បីធ្វើឱ្យទិន្នន័យ អាចប្រៀបធៀបគ្នាបានពីប្រទេសមួយទៅប្រទេសមួយ។

The International Classification of Functioning, Disability and Health (ICF) គឺជាការចាត់ថ្នាក់ផ្នែកសុខភាពនៃសម្បទា និងពិការភាព។ ICF បានទទួលការយល់ព្រមពីរដ្ឋដែលជាសមាជិកទាំងអស់របស់WHOចំនួន១៩១ នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ នៅក្នុងអង្គសន្និបាតសុខភាពពិភពលោកលើកទី៥៤។ ការអនុម័តនេះ ស្របតាមការខិតខំប្រឹងប្រែងក្នុងការកែសម្រួលជាអន្តរជាតិអស់រយៈពេល៩ឆ្នាំ ដោយមានការសម្របសម្រួលពី WHO។ WHO ផ្តួចផ្តើមធ្វើចំណាត់ថ្នាក់លើផលប៉ះពាល់នៃជំងឺនានា The International Classification of Impairments, Disabilities, and Handicaps (ICIDH) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨០។

ការចាត់ចំណាត់ថ្នាក់របស់ICF បំពេញបន្ថែមទៅលើ International Classification of Diseases (ICD) របស់ WHO ដែលបានកែសម្រួលលើកទី១០ (បោះពុម្ពនៅឆ្នាំ២០១៦) ដែលមានព័ត៌មានផ្សេងៗស្តីពីការធ្វើរោគវិនិច្ឆ័យ និងលក្ខខណ្ឌសុខភាព ប៉ុន្តែមិនមានព័ត៌មានស្តីពីស្ថានភាពសម្បទាទេ។ ហេតុដូច្នេះហើយ ICD និងICF រួមគ្នាបង្កើតចំណាត់ថ្នាក់ស្នូលចំពោះ WHO Family of International Classifications (WHO-FIC)។

ម៉ូឌុលអំពីសម្បទាកុមាររបស់ Washington Group ឬUNICEF ដែលបានបញ្ចប់នៅក្នុងឆ្នាំ២០១៦ គ្របដណ្តប់លើកុមារដែលមានអាយុពី២ ដល់ ១៧ឆ្នាំ និងវាយតម្លៃពីការលំបាកនៃសម្បទាក្នុងផ្នែកផ្សេងៗ រួមមាន ការស្តាប់ គំហើញ ទំនាក់ទំនង ការយល់ដឹង ការសិក្សា ការផ្លាស់ទី និងអារម្មណ៍នានា។ ដើម្បីធ្វើការឆ្លុះបញ្ចាំងឱ្យបានកាន់តែប្រសើរឡើងនូវផលលំបាកនៃសម្បទា នៃផ្នែកផ្សេងៗត្រូវបានគេវាយតម្លៃដោយប្រៀបធៀបជាមួយនឹងកម្រិតរង្វាស់មួយ។ គោលបំណង គឺដើម្បីកំណត់ពីចំនួនចម្រុះនៃកុមារដែលមានហានិភ័យខ្ពស់ជាងកុមារផ្សេងទៀតដែលមានអាយុដំណាលគ្នា ឬសម្រាប់កុមារដែលឆ្លងកាត់បទពិសោធន៍ក្នុងការចូលរួមមិនបានពេញលេញក្នុងបរិកាសមិនសមស្រប។ កម្រងសំណួរដែលបានបង្កើតឡើង ដើម្បីប្រើប្រាស់ក្នុងការធ្វើជំរឿន និងអង្កេតតាមខ្នងផ្ទះនៅថ្នាក់ជាតិ លើសពីនេះទៀត គេបានធ្វើការអង្កេត និងជំរឿនជាមួយឪពុកម្តាយ ឬអ្នកថែរក្សាដោយផ្ទាល់។

ម៉ូឌុលនេះ បានឆ្លងកាត់ការត្រួតពិនិត្យបន្ថែមពីអ្នកជំនាញ និងបានធ្វើតេស្តសាកល្បងនៅតាមបណ្តាប្រទេសមួយចំនួន ដើម្បីកំណត់ពីគុណភាពរបស់សំណួរដែលគេត្រូវសួរ និងបញ្ជាក់ពីការយល់ដឹងផ្នែកវប្បធម៌ពីអ្នកឆ្លើយតប។ ម៉ូឌុលនេះត្រូវបានសហការទៅក្នុងវដ្តចុងក្រោយរបស់ Multiple Indicator Cluster Surveys (MICS) និង ត្រូវបានគេអនុវត្តនៅតាមប្រទេសមួយចំនួន ដែលជាផ្នែកមួយរបស់ MICS6។

## ប្រវត្តិ

ទិន្នន័យជាសាកលស្តីពីកុមារពិការ ជាទូទៅមិនអាចប្រៀបធៀបគ្នាបានទេ ដោយសារតែមានឧបករណ៍ វិធីសាស្ត្រ និងនិយមន័យពិការភាពខុសៗគ្នា។ UNICEF និង Washington Group បានបង្កើតឧបករណ៍ថ្មីមួយស្តីពីសម្បទារបស់កុមារ និងពិការភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ។

## ហេតុផល និងគោលការណ៍សម្រាប់សំណួរស្តីពីសម្បទារបស់កុមារ

កម្រងសំណួរ អាចកំណត់អត្តសញ្ញាណកុមារជាច្រើនដែលមានការលំបាកផ្នែកសម្បទា។ Washington Group បានធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីវាស់វែងលើសម្បទារបស់កុមារឈានទៅពង្រឹង និងពង្រីកបន្ថែម ដោយផ្អែកតាមការកំណត់អត្តសញ្ញាណ និងឆ្លើយតបនូវរាល់ទិដ្ឋភាពដែលទាក់ទងនឹងការលូតលាស់របស់កុមារ ដែលកន្លងមកមិនទាន់បានឆ្លើយតប។

ហេតុដូច្នេះហើយ ទើប Washington Group សហការជាមួយ UNICEF បានរៀបចំកម្រងសំណួរសម្រាប់ធ្វើការអង្កេតលើការកំណត់អត្តសញ្ញាណកុមារពិការ។

ម៉ូឌុលស្តីពីសម្បទារបស់កុមារ អាចត្រូវបានគេប្រើប្រាស់ជាសមាសភាគមួយនៃការអង្កេតពីចំនួនប្រជាជនថ្នាក់ជាតិ ឬជាការបំពេញបន្ថែមទៅលើការអង្កេតលើប្រធានបទដ៏មានសារសំខាន់ជាក់លាក់ណាមួយ។ ដូចគ្នានេះដែរ កម្រងសំណួរផ្សេងៗទៀតរបស់ Washington Group ក៏ឱ្យនិយមន័យថាពិការភាពជាការលំបាកក្នុងការអនុវត្តសកម្មភាពនានាជាមូលដ្ឋាន។ ការងារនេះត្រូវបានលើកឡើងដោយផ្អែកតាមកម្រងសំណួរពីមុនៗរបស់ Washington Group សម្រាប់មនុស្សពេញវ័យ។

ម៉ូឌុលអំពីសម្បទារបស់កុមារត្រូវបានរៀបចំសម្រាប់ធ្វើកិច្ចការដូចខាងក្រោម៖

- **ការពង្រីកផ្នែកសម្បទាកុមារ៖** ការបែងចែកនូវប្រភេទពិការមានភាពខុសគ្នាសម្រាប់កុមារបើប្រៀបធៀបទៅនឹងមនុស្សពេញវ័យ។ ចំពោះមនុស្សពេញវ័យ បញ្ហាសំខាន់ៗមាន វិញ្ញាណ ការផ្លាស់ទី និងការមើលថែខ្លួនឯង ជាពិសេសនៅពេលដែលគេមានអាយុកាន់តែច្រើន។ ចំពោះ

កុមារវិញ ការលំបាកចម្បងៗ គឺទាក់ទងទៅនឹងបញ្ហាសម្បទា អាកប្បកិរិយា និងផលប៉ះពាល់ផ្សេងៗ។

- **ការដាក់បញ្ចូលនូវកម្រិតក្រុមអាយុពេញលេញ៖** ក្រុមអាយុពី២ដល់១៧ឆ្នាំ។ តាមរយៈការសិក្សាអង្កេតពីចំនួនប្រជាជន ក្រុមការងារបានសម្រេចចិត្តថា ម៉ូឌុលនេះមិនអាចប្រើប្រាស់ចំពោះកុមារអាយុក្រោម២ឆ្នាំទេ។ កម្រងសំណួរផ្សេងៗគ្នាដែលបានបង្កើតឡើង សម្រាប់កុមារដែលមានអាយុពី ២ ទៅ៤ឆ្នាំ និងពីអាយុពី ៥ទៅ១៧ឆ្នាំ។
- **ការទទួលស្គាល់ពីកម្រិតនៃពិការភាព៖** ចម្លើយនៃចំណាត់ថ្នាក់នៃពិការភាពត្រូវបានគេតាក់តែងឡើងដើម្បីឆ្លើយតបជាបន្តបន្ទាប់ទៅនឹងការលំបាកផ្នែកសម្បទាជាមួយនឹងសមត្ថភាពក្នុងការកំណត់ឱ្យបានសមស្របពីភាពដាច់ដោយឡែកពីគ្នា ដែលផ្អែកទៅតាមតម្រូវការនានាលើការប្រមូលទិន្នន័យពីពិការភាព។
- **ការកំណត់អត្តសញ្ញាណពីការលំបាកដែលស្របទៅនឹងកម្រិតអាយុ៖** ដើម្បីជាភស្តុតាង និងផ្តោតលើអ្នកឆ្លើយតបអំពីមុខងារសម្បទារបស់កូនខ្លួនផ្ទាល់ សម្រាប់តំណាងឱ្យក្រុមកុមារផ្សេងទៀតនៅទីកន្លែងដែលសមស្រប សំណួរផ្សេងៗត្រូវបានគេចងក្រងជាប្រយោគ៖«ដោយប្រៀបធៀបទៅនឹងកុមារមានអាយុដំណាលគ្នា...» ។
- **ការពឹងផ្អែកទៅលើអ្នកឆ្លើយតបជាតំណាង៖** ដោយផ្អែកទៅលើវិធីសាស្ត្រក្នុងការអនុវត្តវិធីអង្កេតជាស្តង់ដា ត្រូវគិតពីក្រមសីលធម៌ក្នុងការសម្ភាសជាមួយកុមារ និងកុមារតូចៗមិនអាចមានសមត្ថភាពឆ្លើយនឹងសំណួរទាំងអស់បាន ក្រុមបានសម្រេចចិត្តតាក់តែងកម្រងសំណួរផ្សេងៗសម្រាប់ឪពុកម្តាយ ឬអ្នកថែទាំកុមារ។
- **ការរក្សាទំហៀបជាអន្តរជាតិ៖** គោលបំណងនៃកម្រងសំណួរគឺផ្តល់ទិន្នន័យដែលអាចប្រៀបធៀបបានក្នុងចំណោមបណ្តាជាតិសាសនានា។
- **ការអនុវត្តហ្មត់ចត់តាមស្តង់ដាអភិវឌ្ឍ៖** កម្រងសំណួរត្រូវបានតាក់តែងឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញផ្សេងៗ។ កម្រងសំណួរនេះ មានការចូលរួមពីសំណាក់អ្នកឯកទេសខាងស្ថិតិ ពេទ្យឯកទេសកុមារ អ្នកចិត្តសាស្ត្រ អ្នកឯកទេសព្យាបាលការបញ្ចេញសំឡេង ។ល។ បន្ទាប់មក សំណួរទាំងអស់នោះមានសក្តានុពល តាមរយៈការយល់ដឹង និងការធ្វើតេស្តសាកល្បងជាក់ស្តែង ស្របតាមនីតិវិធីដែលបង្កើតដោយ Washington Group ។

## វិធីសាស្ត្រ

UNICEF និងWG បានបង្កើតម៉ូឌុលនៃការអង្កេតដែលជារបាយការណ៍របស់ឪពុកម្តាយដើម្បីកំណត់អត្តសញ្ញាណកុមារមានអាយុពី០២ទៅ១៧ឆ្នាំ ដែលមានការលំបាកផ្នែកសម្បទានៅក្នុងការសិក្សាអង្កេតលើប្រជាជន តាមរយៈការពិនិត្យមើលឯកសារដែលមានស្រាប់ ការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងការធ្វើតេស្តលើការយល់ដឹង ។ ការធ្វើតេស្តជាក់ស្តែងនៅតាមមូលដ្ឋានលើសេចក្តីព្រាងម៉ូឌុល ត្រូវបានធ្វើឡើងនៅក្នុងប្រទេសកាមេរ៉ូន និងឥណ្ឌា ដោយប្រើប្រាស់ការសិក្សាអង្កេតលើប្រជាជន។ ការកំណត់លើសម្បទានៅក្នុងផ្នែកទាំង១៤ និងដាក់ពិន្ទុដូចជា «មិនមានការលំបាក» «មានការលំបាកមួយចំនួន» «មានការលំបាកច្រើន» និង «មិនអាចធ្វើបានទាំងអស់» ។

## ២.៤. ម៉ូឌុលស្តីពីសម្បទាកុមារ (អាយុពី ២ ដល់៤ឆ្នាំ)

| សម្បទាកុមារ (អាយុ 2-4 ឆ្នាំ) | | |
|---|---|---|
| 1.ខ្ញុំចង់សួរលោក លោកស្រីនូវសំណួរ មួយចំនួនពីការលំបាក ដែលកូនរបស់អ្នកបានឬទេ ?<br><br>តើ(ឈ្មោះ)ពាក់វ៉ែនតាឬទេ ? | ពាក់ ………………………………1<br>មិនពាក់ ……………………………2 | បើ2 រំលងទៅសំណួរ3 |
| 2.តើនៅពេលពាក់វ៉ែនតា (ឈ្មោះ)មានការលំបាកក្នុងការមើលដែរឬទេ ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ………………1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់………..4 | បើ1 រំលងទៅសំណួរ4<br>បើ2 រំលងទៅសំណួរ4<br>បើ3 រំលងទៅសំណួរ4<br>បើ4 រំលងទៅសំណួរ4 |
| 3.តើ(ឈ្មោះ)មានការលំបាកក្នុងការ មើលដែរឬទេ ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើ | មិនមានការលំបាក ………………1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់………..4 | |

| | | |
|---|---|---|
| បានទាំងអស់ ។ | | |
| 4.តើ(ឈ្មោះ)ប្រើឧបករណ៍ជំនួយសម្រាប់ស្តាប់ដែរឬទេ? | ប្រើ ……………………………..1<br>មិនប្រើ …………………………..2 | |
| 5.នៅពេលប្រើឧបករណ៍ជំនួយស្តាប់ តើ(ឈ្មោះ)មានការលំបាកក្នុងការស្តាប់សំឡេងដែរឬទេ? ដូចជាសំឡេងមនុស្សនិយាយ ឬសំឡេងភ្លេង...។<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់.…......…4 | បើ1 រំលងទៅសំណួរ6<br>បើ2 រំលងទៅសំណួរ6<br>បើ3 រំលងទៅសំណួរ6<br>បើ4 រំលងទៅសំណួរ6 |
| 6.តើ(ឈ្មោះ)មានការលំបាកក្នុងការស្តាប់សំឡេងដែរឬទេ? ដូចជាសំឡេងមនុស្សនិយាយ ឬសំឡេងភ្លេង.... ។<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់.…......…4 | |
| 7.តើ (ឈ្មោះ) មានប្រើប្រាស់ ឬទទួលឧបករណ៍ជំនួយសម្រាប់ដើរដែរ ឬទេ? | មាន ……………………………1<br>មិនមាន ………………………..2 | បើ2រំលងទៅសំណួរ10 |
| 8.បើគ្មានឧបករណ៍ជំនួយទេ តើ(ឈ្មោះ) មានការលំបាកក្នុងការដើរ ដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖ (ឈ្មោះ) មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មានការលំបាកមួយចំនួន.……...2<br>មានការលំបាកច្រើន ….……….3<br>មិនអាចធ្វើអ្វីបានទាំងអស់ ……4 | |
| 9.បើមានឧបករណ៍ជំនួយ តើ(ឈ្មោះ) មានការលំបាកក្នុងការដើរដែរ ឬទេ ? | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2 | បើ1 រំលងទៅសំណួរ11 |

| | | |
|---|---|---|
| លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់………..4 | បើ2 រំលងទៅសំណួរ11<br>បើ3 រំលងទៅសំណួរ11<br>បើ4 រំលងទៅសំណួរ11 |
| 10.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានការលំបាកក្នុងការដើរដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់………..4 | |
| 11.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ)មានការលំបាកក្នុងចាប់កាន់វត្ថុ តូចៗដែរឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់………..4 | |
| 12.បើប្រៀបធៀបជាមួយនឹងកុមារ ដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានកាលំបាកក្នុងការយល់ដឹងពីអ្វីដែល លោកលោកស្រីនិយាយដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់………..4 | |
| 13.នៅពេល(ឈ្មោះ)និយាយ តើលោក | មិនមានការលំបាក ……………..1 | |

| | | |
|---|---|---|
| លោកស្រីមានការលំបាកក្នុងការយល់ដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មានការលំបាកមួយចំនួន .........2<br>មានការលំបាកច្រើន ……………..3<br>មិនអាចធ្វើបានទាំងអស់……….4 | |
| 14.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានការលំបាកក្នុងការរៀនពីអ្វីផ្សេងៗ ដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ………………1<br>មានការលំបាកមួយចំនួន .........2<br>មានការលំបាកច្រើន ……………..3<br>មិនអាចធ្វើបានទាំងអស់……….4 | |
| 15.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានការលំបាកក្នុងការលេងដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ………………1<br>មានការលំបាកមួយចំនួន .........2<br>មានការលំបាកច្រើន ……………..3<br>មិនអាចធ្វើបានទាំងអស់……….4 | |
| 16.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) ទាត់ ធាក់ ខាំ វាយកុមារ ឬមនុស្សពេញវ័យ កម្រិតណា?<br><br>លោកលោកស្រីអាចនិយាយថា៖ (ឈ្មោះ) មិនមានទាំងអស់ ដូចឬតិចជាង ច្រើន ច្រើនជាងកុមារដទៃឬ? | មិនមានទាំងអស់ ………………1<br>ដូច ឬតិចជាង………………….2<br>ច្រើន ……………………………3<br>ច្រើនជាង ……………………..4 | |

**២.៥.ម៉ូឌុលស្ដីពីសម្បទាកុមារ (អាយុ ៥ ទៅ១៧ឆ្នាំ)**

| សម្បទាកុមារ (អាយុ៥ ទៅ១៧ឆ្នាំ) | | |
|---|---|---|
| 1.ខ្ញុំសុំសួរសំណួរលោក លោកស្រីមួយចំនួនពីការលំបាករបស់កូនអ្នក។<br><br>តើ(ឈ្មោះ)ពាក់វ៉ែនតា ឬដាក់កញ្ចក់ប្លាស្ទិកក្នុងភ្នែកដែរ ឬទេ? | ពាក់ឬដាក់ …………………………1<br>មិនពាក់ឬដាក់ ……………………2 | បើ2 រំលងទៅសំណួរ3 |
| 2.នៅពេលពាក់វ៉ែនតា ឬដាក់កញ្ចក់ប្លាស្ទិកនៅក្នុងភ្នែក តើ(ឈ្មោះ)មានការ លំបាកក្នុងការមើលដែរ ឬទេ?<br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………….1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………..3<br>មិនអាចធ្វើបានទាំងអស់…......…..4 | បើ1 រំលងទៅសំណួរ4<br>បើ2 រំលងទៅសំណួរ4<br>បើ3 រំលងទៅសំណួរ4<br>បើ4 រំលងទៅសំណួរ4 |
| 3.តើ(ឈ្មោះ)មានការលំបាកក្នុងការ មើលដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………….1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………..3<br>មិនអាចធ្វើបានទាំងអស់…......…..4 | |
| 4.តើ(ឈ្មោះ)មានឧបករណ៍ជំនួយក្នុងការស្ដាប់ដែរ ឬទេ? | មាន ......................................1<br>មិនមាន ……………………......……2 | បើ2 រំលងទៅសំណួរ6 |
| 5.នៅពេលប្រើប្រាស់ឧបករណ៍ជំនួយក្នុងការស្ដាប់ តើ(ឈ្មោះ)មានការលំបាកក្នុងការស្ដាប់ឮសំឡេងនានាដែរ ឬទេ? ដូចជាសំឡេងមនុស្ស ឬភ្លេង? | មិនមានការលំបាក ……………….1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………..3<br>មិនអាចធ្វើបានទាំងអស់…......…..4 | បើ1 រំលងទៅសំណួរ7<br>បើ2 រំលងទៅសំណួរ7 |

| | | |
|---|---|---|
| លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | | បើ3 រំលងទៅសំណួរ7<br>បើ4 រំលងទៅសំណួរ7 |
| 6.តើ(ឈ្មោះ)មានការលំបាកក្នុងការស្តាប់សំឡេងដែរ ឬទេ? ដូចជាសំឡេងមនុស្ស ឬ ភ្លេង?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……….4 | |
| 7.តើ(ឈ្មោះ)ប្រើឧបករណ៍ ឬទទួលបានឧបករណ៍ជំនួយសម្រាប់ដើរដែរ ឬទេ? | មាន .....................................1<br>មិនមាន ................................2 | បើ2 រំលងទៅសំណួរ12 |
| 8.បើគ្មានឧបករណ៍ជំនួយទេ តើ(ឈ្មោះ) មានការលំបាកក្នុងការដើរចម្ងាយ១០០ម៉ែត្រនៅលើដីរាបស្មើដែរឬទេ?ចម្ងាយនេះគឺប្រហែលនឹងប្រវែងតារាងបាល់ទាត់ ។<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……….4 | បើ3 រំលងទៅសំណួរ10<br>បើ4 រំលងទៅសំណួរ10 |
| 9.បើគ្មានឧបករណ៍ជំនួយទេ តើ(ឈ្មោះ) មានការលំបាកក្នុងការដើរចម្ងាយ៥០០ម៉ែត្រនៅលើដីរាបស្មើដែរឬទេ? ចម្ងាយនោះប្រហែលនឹងប្រវែងតារាងបាល់ទាត់ចំនួន៥ដង ។<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……….4 | |

| | | |
|---|---|---|
| 10.បើមានឧបករណ៍ជំនួយ តើ(ឈ្មោះ) មានការលំបាកក្នុងការដើរចម្ងាយ១០០ ម៉ែត្រនៅលើដីរាបស្មើដែរឬទេ?ចម្ងាយនេះ គឺប្រហែលនឹងប្រវែងតារាងបាល់ទាត់ ។<br><br>លោក លោកស្រីអាចនិយាយថាៈ(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់…........4 | បើ3 រំលងទៅសំណួរ11<br>បើ4 រំលងទៅសំណួរ11 |
| 11.បើគ្មានឧបករណ៍ជំនួយទេតើ(ឈ្មោះ) មានការលំបាកក្នុងការដើរចម្ងាយ៥០០ ម៉ែត្រនៅលើដីរាបស្មើដែរឬទេ?ចម្ងាយនេះប្រហែលនឹងប្រវែងតារាងបាល់ទាត់ចំនួន៥ដង ។<br><br>លោក លោកស្រីអាចនិយាយថាៈ(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់…........4 | បើ1 រំលងទៅសំណួ14 |
| 12.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានការលំបាកក្នុងការដើរចម្ងាយ១០០ម៉ែត្រនៅលើដីរាបស្មើដែរ ឬទេ? ចម្ងាយនេះគឺប្រហែលនឹងប្រវែងតារាងបាល់ទាត់ ។<br><br>លោក លោកស្រីអាចនិយាយថាៈ(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់…........4 | បើ3 រំលងទៅសំណួរ14<br>បើ4 រំលងទៅសំណួរ14 |

| | | |
|---|---|---|
| 13.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានការលំបាកក្នុងការដើរចម្ងាយ៥០០ម៉ែត្រនៅលើដីរាបស្មើដែរឬទេ? ចម្ងាយនោះប្រហែលនឹងប្រវែងតារាងបាល់ទាត់ចំនួន ៥ដង ។<br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……..…4 | |
| 14.តើ(ឈ្មោះ)មានការលំបាកក្នុងការថែទាំខ្លួនឯង ដូចជាការញ៉ាំអាហារឬការស្លៀកពាក់ដោយខ្លួនឯងដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……..…4 | |
| 15.នៅពេលដែល(ឈ្មោះ)និយាយតើគាត់មានការលំបាកដោយសារអ្នកនៅក្នុងផ្ទះស្តាប់មិនបាន ឬមិនយល់ដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……..…4 | |

| | | |
|---|---|---|
| 16.នៅពេលដែល(ឈ្មោះ)និយាយ តើគាត់មានការលំបាកដោយសារអ្នកដែលមិនមែនជាសមាជិកគ្រួសារស្តាប់មិនបាន ឬមិនយល់ដែរឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……..….4 | |
| 17.បើប្រៀបធៀបជាមួយនឹងកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានការលំបាកក្នុងការរៀនសូត្រពីអ្វីផ្សេងៗទៀតដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……..….4 | |
| 18.បើប្រៀបធៀបជាមួយនឹងកុមារ ដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ) មានការលំបាកក្នុងការចងចាំនូវអ្វីផ្សេងៗទៀតដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់……..….4 | |

| | | |
|---|---|---|
| 19.តើ(ឈ្មោះ)មានការលំបាកក្នុងការផ្ទង់អារម្មណ៍ទៅលើសកម្មភាពអ្វីមួយដែលគាត់ចូលចិត្តធ្វើដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់…......…4 | |
| 20.តើ(ឈ្មោះ)មានការលំបាកក្នុងការទទួលយកនូវការផ្លាស់ប្តូរនានាចំពោះសកម្មភាពប្រចាំថ្ងៃរបស់គាត់ដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់…......…4 | |
| 21.បើប្រៀបធៀបជាមួយកុមារដែលមានអាយុដំណាលគ្នា តើ(ឈ្មោះ)មានការលំបាកក្នុងការគ្រប់គ្រងអាកប្បកិរិយារបស់ខ្លួនគាត់ដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់…......…4 | |
| 22.តើ(ឈ្មោះ)មានការលំបាកក្នុងការរាប់អានមិត្តភក្តិដែរ ឬទេ?<br><br>លោក លោកស្រីអាចនិយាយថា៖(ឈ្មោះ) មិនមានការលំបាក មានការលំបាកមួយចំនួន មានការលំបាកច្រើន ឬមិនអាចធ្វើបានទាំងអស់ ។ | មិនមានការលំបាក ……………..1<br>មានការលំបាកមួយចំនួន ..........2<br>មានការលំបាកច្រើន ……………3<br>មិនអាចធ្វើបានទាំងអស់…......…4 | |

| | | |
|---|---|---|
| 23.តើ(ឈ្មោះ)ហាក់ដូចជាមានអារម្មណ៍ មួម៉ៅ ភ័យខ្លាច ឬព្រួយបារម្ភញឹកញាប់កម្រិតណា?<br><br>លោក លោកស្រីអាចនិយាយថា៖ រៀងរាល់ថ្ងៃ រៀងរាល់សប្តាហ៍ រៀងរាល់ខែ ពីរបីដងក្នុងមួយឆ្នាំ ឬមិនដែលសោះ? | <br><br><br>រៀងរាល់ថ្ងៃ ……………………….1<br>រៀងរាល់សប្តាហ៍ ……………….…2<br>រៀងរាល់ខែ …………………….….3<br>ពីរបីដងក្នុងមួយឆ្នាំ ……………...4<br>មិនដែលសោះ …………………...5 | |
| 24.តើ(ឈ្មោះ)ហាក់ដូចជាមានអារម្មណ៍ ស្រងូតស្រងាត់ ឬបាក់ទឹកចិត្ត ញឹកញាប់កម្រិតណា?<br><br>លោក លោកស្រីអាចនិយាយថា៖ រៀងរាល់ថ្ងៃ រៀងរាល់សប្តាហ៍ រៀងរាល់ខែ ពីរបីដងក្នុងមួយឆ្នាំ ឬមិនដែលសោះ? | <br><br><br>រៀងរាល់ថ្ងៃ ……………………….1<br>រៀងរាល់សប្តាហ៍ ……………….…2<br>រៀងរាល់ខែ …………………….….3<br>ពីរបីដងក្នុងមួយឆ្នាំ ……………...4<br>មិនដែលសោះ …………………...5 | |

# មេរៀនទី៣
# ខ្សោយបញ្ញា ពិបាកក្នុងការសិក្សាមុខវិជ្ជា និងអូទីសឹម

## ៣.១.វត្ថុបំណង

ដើម្បីសិក្សាស្វែងយល់ពីនិយមន័យ លក្ខណៈ និងមូលហេតុ ខ្សោយបញ្ញា ពិបាកក្នុងការសិក្សាមុខវិជ្ជា និងអូទីសឹម។

## ៣.២.ខ្សោយបញ្ញា

### ៣.២.១.និយមន័យ

ខ្សោយបញ្ញាសំដៅដល់មនុស្សទាំងឡាយណាដែលមានសម្បទាបញ្ញា (Intellectual Functioning) និងអាកប្បកិរិយា មិនពេញលេញ នាំឱ្យប៉ះពាល់ដល់បំណិនទំនាក់ទំនងសង្គម និងសកម្មភាពប្រចាំថ្ងៃជាច្រើន។ វាអាចកើតឡើងមុនពេលអាយុ១៨ ឆ្នាំ។

សម្បទាបញ្ញា(Intellectual functioning)សំដៅទៅលើសមត្ថភាពបញ្ញាស្មារតីទូទៅដូចជាការរៀនសូត្រ ការលើកហេតុផល ការដោះស្រាយបញ្ហា ។ល។ វិធីមួយក្នុងការវាស់បញ្ញាគេ ធ្វើតេស្តដោយប្រើឧបករណ៍IQ (Intellectual Quotient) ។ ជាទូទៅបើលទ្ធផលពិន្ទុតេស្ត IQ បានដល់៧០ ឬ ត្រឹមតែ ៧៥ពិន្ទុ បង្ហាញថា សម្បទាបញ្ញាមានកម្រិត (មិនពេញលេញ)។

ការប្រែប្រួលផ្នែកអាកប្បកិរិយាគឺជាការប្រមូលផ្តុំនូវបំណិនផ្សេងៗដែលទាក់ទងនឹងគោលគំនិតសង្គម និងការប្រតិបត្តិដែលមនុស្សត្រូវរៀនសូត្រ និងអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់គេ។

- **បំណិនក្នុងការបង្កើតគំនិត៖** គោលគំនិតទាក់ទងនឹង ភាសា អក្សរសាស្ត្រ លុយកាក់ ពេលវេលា និង ការតម្រង់ទិសដោយខ្លួនឯង។
- **បំណិនសង្គម៖** បំណិនអន្តរបុគ្គល និងការទទួលខុសត្រូវផ្នែកសង្គម ការឱ្យតម្លៃលើខ្លួនឯង (ពោលគឺមានបម្រុងប្រយ័ត្នតិច) ការដោះស្រាយបញ្ហាសង្គម និងសមត្ថភាពក្នុងការអនុវត្ត ឬគោរពច្បាប់ ដោយចៀសវាងក្លាយខ្លួនទៅជាជនរងគ្រោះ។
- **បំណិនប្រតិបត្តិ៖** សកម្មភាពទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ(ការមើលថែខ្លួនឯង) ការថែរក្សាសុខភាព ការធ្វើដំណើរ ការដឹកជញ្ជូន ការរៀបចំកម្មវិធី សកម្មភាពប្រចាំថ្ងៃ សុវត្ថិភាព ការប្រើប្រាស់លុយកាក់ ការប្រើប្រាស់ទូរស័ព្ទ។
- តេស្តស្តង់ដារក៏អាចកំណត់បាននូវកម្រិតនៃអាកប្បកិរិយាសម្របខ្លួន។

**អាយុនៃការចាប់ផ្តើម**

លក្ខខណ្ឌនេះគឺជាពិការភាពដែលទាក់ទងនឹងការលូតលាស់មួយក្នុងចំណោមការលូតលាស់ជាច្រើន គឺមានភស្តុតាងស្តីពីពិការភាពក្នុងអំឡុងពេលកំពុងរីកលូតលាស់ ដែលគេអាចកត់សម្គាល់នៅមុន អាយុ ១៨ ឆ្នាំ។

**ការគិតគូរពិចារណាបន្ថែម**

ប៉ុន្តែនៅក្នុងនិយមន័យ ឬការវាយតម្លៃខ្សោយបញ្ញា សមាគមសហរដ្ឋអាមេរិក ស្តីពីពិការភាព និងការលូតលាស់យឺត សង្កត់ធ្ងន់ថាកត្តាផ្សេងៗបន្ថែមទៀតត្រូវតែគិតគូរពិចារណាដូចជាស្ថានភាពបរិយាកាសទូទៅនៅក្នុងសហគមន៍ និងវប្បធម៌ជាលក្ខណៈបុគ្គល។ អ្នកជំនាញគួរពិចារណាលើការប្រើប្រាស់ភាសា និងវប្បធម៌ផ្សេងៗគ្នាជាមធ្យោបាយក្នុងការប្រាស្រ័យទាក់ទងគ្នា ដូចជា សម្តែងកាយវិការ និងអាកប្បកិរិយា។

នៅទីបញ្ចប់ ការវាយតម្លៃក៏ត្រូវសន្និដ្ឋានថាមានកម្រិតផ្សេងៗគ្នាចំពោះបុគ្គលម្នាក់ៗតែងតែកើតឡើងព្រមគ្នាជាមួយនឹងចំណុចខ្លាំង ហើយកម្រិតនៃមុខងារក្នុងជីវិតរបស់មនុស្សម្នាក់នឹងមានការកែលម្អ ប្រសិនបើគេផ្តល់ការគាំទ្រជាលក្ខណៈបុគ្គលសមស្របសម្រាប់រយៈពេលមួយដែលមាននិរន្តភាព។ ផ្អែកលើមូលដ្ឋាននៃការវាយតម្លៃពហុវិស័យតែមួយប៉ុណ្ណោះ ដែលអ្នកជំនាញអាចកំណត់ថា តើបុគ្គលម្នាក់ខ្សោយបញ្ញានិងត្រូវរៀបចំផែនការសម្រាប់ម្នាក់ៗដើម្បីគាំទ្រគាត់។

**៣.១.២.ការចាត់ចំណាត់ថ្នាក់**

អ្នកឯកទេសបែងចែកការខ្សោយបញ្ញាទៅជា៤កម្រិត៖ កម្រិតស្រាល មធ្យម ធ្ងន់ និងកម្រិតធ្ងន់ធ្ងរបំផុត។ កម្រិតនៃការខ្សោយបញ្ញាមួយមានភាពខុសគ្នាដាច់ស្រឡះ។ ឯកសាររោគវិនិច្ឆ័យ និងស្ថិតិនៃសុខភាពផ្លូវចិត្ត (Diagnostic and Statistical Manual of Mental Disorder, 5th Edition) ផ្តោតការយកចិត្តទុកដាក់បានតិចតួចទៅលើកម្រិតខ្សោយបញ្ញា(ពោលគឺពិន្ទុIQ) តែគេយកចិត្តទុកដាក់ច្រើនទៅលើចំនួននៃពិការភាព និងតម្រូវការអន្តរាគមន៍។

ពេលដែលពិន្ទុIQនៅតែជាប់ទាក់ទង និងមានសារៈសំខាន់ក្នុងការវាយតម្លៃនៃកម្រិតខ្សោយបញ្ញា ឯកសារថ្មីពីរោគវិនិច្ឆ័យ(DSM-V)ស្ថិតិនៃសុខភាពផ្លូវចិត្តបានបន្ថែមនូវកម្រិតនៃលក្ខណៈវិនិច្ឆ័យ (ខ្សោយបញ្ញា៖ មូលហេតុ និងលក្ខណៈសម្គាល់)។ អ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តត្រូវតែគិតគូរពិចារណាពីសមត្ថភាព ឬភាពទន់ខ្សោយរបស់មនុស្សនៅក្នុងបំណិនទាំង៣៖ បំណិនយល់ដឹង សង្គម និងបំណិនប្រតិបត្តិប្រចាំថ្ងៃ។

ចំណុចលម្អិតផ្នែកនីមួយៗមានដូចខាងក្រោម៖

## ខ្សោយបញ្ញាកម្រិតស្រាល

- ពិន្ទុ IQ ពី៥០-៧០
- មានភាពយឺតយ៉ាវជាងកុមារទូទៅនៅគ្រប់ផ្នែកទាំងអស់នៃការលូតលាស់
- លក្ខណៈផ្នែករាងកាយមិនមានភាពខុសធម្មតាទេ
- មានសមត្ថភាពក្នុងការរៀនពីបំណិនជីវិតដោយការអនុវត្តផ្ទាល់
- អាចទទួលបានបំណិនក្នុងការអាន និងគណិតវិទ្យាកម្រិតថ្នាក់ទី ៣-៦
- មានសមត្ថភាពក្នុងការចូលរួមសង្គម
- មានសមត្ថភាពប្រតិបត្តិសម្រាប់ជីវិតប្រចាំថ្ងៃ
- ជនខ្សោយបញ្ញាប្រមាណជា៨៥% ស្ថិតក្នុងប្រភេទពិការភាពកម្រិតស្រាល ហើយពួកគេជាច្រើនអាចសម្រេចបានជោគជ័យក្នុងការសិក្សា។ ពួកគេអាចចេះអាន ប៉ុន្តែមានការលំបាកក្នុងការយល់ដឹងពីអ្វីដែលគេអាន នេះគឺជាឧទាហរណ៍មួយរបស់កុមារខ្សោយបញ្ញាកម្រិតស្រាលម្នាក់។

## ខ្សោយបញ្ញាកម្រិតមធ្យម

- ពិន្ទុ IQ ពី៣៥-៤៩
- ភាពយឺតយ៉ាវក្នុងការលូតលាស់គួរឱ្យកត់សម្គាល់ (ពោលគឺការនិយាយស្ដី និងបំណិនចលនា)
- អាចមានសញ្ញានៃការលំបាកផ្នែករាងកាយ (ពោលគឺអណ្ដាតក្រាស់)
- អាចប្រាស្រ័យទាក់ទងក្នុងកម្រិតដំបូងក្នុងលក្ខណៈងាយៗ
- មានសមត្ថភាពរៀនពីបំណិនផ្នែកសុខភាព និងសុវត្ថិភាពជាមូលដ្ឋាន
- មានលទ្ធភាពមើលថែខ្លួនឯងបាន
- អាចធ្វើដំណើរតែម្នាក់ឯងបានទៅកន្លែងជិតៗ កន្លែងដែលធ្លាប់ស្គាល់
- ជនខ្សោយបញ្ញាកម្រិតមធ្យមមានបំណិនក្នុងការប្រាស្រ័យទាក់ទងបានខ្លះ ប៉ុន្តែមិនអាចប្រាស្រ័យទាក់ទងក្នុងលក្ខណៈស្មុគស្មាញបានទេ។ ពួកគេមានការលំបាកចំពោះស្ថានភាពសង្គម និងមានបញ្ហាក្នុងការយល់ពីព្រឹត្តិការណ៍ និងវិនិច្ឆ័យកិច្ចការសង្គម។ ពួកគេអាចមើលថែខ្លួនឯងបាន ប៉ុន្តែត្រូវការការណែនាំ និងការគាំទ្រច្រើនជាងមនុស្សធម្មតា។ ពួកគេជាច្រើនអាចរស់នៅដោយម្ចាស់ការបាន ប៉ុន្តែពេលខ្លះពួកគេមួយចំនួននៅតែត្រូវការការគាំទ្រពីក្រុមគ្រួសារ ឬអ្នកនៅជាមួយ។ ១០% នៃកុមារខ្សោយបញ្ញា គឺស្ថិតក្នុងកម្រិតមធ្យម។

## ខ្សោយបញ្ញាកម្រិតធ្ងន់

- ពិន្ទុ IQ ពី២០-៣៤
- ការគិតពិចារណាមានការលូតលាស់យឺតយ៉ាវ
- យល់ពីការនិយាយស្ដី ប៉ុន្ដែមានលទ្ធភាពតិចតួចក្នុងការប្រាស្រ័យទាក់ទង
- មានសមត្ថភាពរៀនពីសកម្មភាពទម្លាប់ប្រចាំថ្ងៃ
- អាចរៀនមើលថែខ្លួនឯងដែលមានលក្ខណៈងាយៗ
- ត្រូវការមើលថែដោយផ្ទាល់ពីសង្គម
- តាមរយៈការធ្វើរោគវិនិច្ឆ័យ មានតែមនុស្សប្រមាណតែ៣% ឬ៤%ប៉ុណ្ណោះ ដែលស្ថិតក្នុងខ្សោយបញ្ញាកម្រិតធ្ងន់។ អ្នកទាំងនេះអាចប្រាស្រ័យទាក់ទងគ្នាក្នុងកម្រិតដំបូង។ ពួកគេមិនអាចអនុវត្តសកម្មភាពមើលថែខ្លួនឯងដោយម្ចាស់ការបានទេ ហើយពួកគេត្រូវការថែទាំ និងការគាំទ្រប្រចាំថ្ងៃ។ ភាគច្រើនអ្នកដែលស្ថិតនៅក្នុងការខ្សោយបញ្ញាកម្រិតនេះ មិនអាចរស់នៅបានដោយជោគជ័យក្នុងជីវិតម្ចាស់ការបានទេ ហើយពួកគេចាំបាច់ត្រូវរស់នៅក្នុងមណ្ឌលប្រមូលផ្តុំ។

## ខ្សោយបញ្ញាកម្រិតធ្ងន់ធ្ងរ

- ពិន្ទុ IQ ទាបជាង២០
- មានភាពយឺតយ៉ាវខ្លាំងក្នុងការលូតលាស់គ្រប់ផ្នែកទាំងអស់
- រាងកាយ និងបញ្ញាមានភាពមិនប្រក្រតីតាំងពីកំណើត
- តម្រូវឱ្យមានការថែទាំយ៉ាងដិតដល់
- តម្រូវឱ្យមានអ្នកមើលថែលើសកម្មភាពប្រចាំថ្ងៃនិងសកម្មភាពមើលថែខ្លួនឯង
- មិនអាចមានលទ្ធភាពរស់នៅដោយម្ចាស់ការទេ
- ជនខ្សោយបញ្ញាធ្ងន់ធ្ងរត្រូវការគាំទ្រ និងថែរក្សាទាំងយប់ថ្ងៃ។ ពួកគេពឹងផ្អែកលើអ្នកដទៃទាំងស្រុងក្នុងការរស់នៅប្រចាំថ្ងៃ ហើយសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងមានកម្រិតទាបបំផុត។ ជាទូទៅ ជនប្រភេទនេះពិបាកធ្វើចលនាជាខ្លាំង ហើយប្រមាណជា១-២%ស្ថិតនៅក្នុងការខ្សោយបញ្ញាកម្រិតធ្ងន់ធ្ងរ ។

យោងតាDSM-Vថ្មី ទោះបីជានរណាម្នាក់មានការលំបាកផ្នែកសង្គមធ្ងន់ធ្ងរ(ឧទាហរណ៍ធ្ងន់ធ្ងរខ្លាំងរហូត ដល់ពួកគេស្ថិតនៅក្នុងប្រភេទពិការភាពកម្រិតមធ្យម)ក៏ដោយ ក៏គេចាត់ទុកពួកគាត់ស្ថិតនៅក្នុងប្រភេទ ពិការកម្រិតមធ្យមដែរ ដោយសារពួកគាត់មានពិន្ទុIQរហូតដល់80 ឬ85។ ដូច្នេះការផ្លាស់ប្តូរនានានៅក្នុង DSM-V តម្រូវឱ្យអ្នកមានវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្តវាយតម្លៃពីកម្រិតនៃ

ភាពទន់ខ្សោយតាមរយៈការវាស់ ពិន្ទុ IQ និងដោយមានការប្រៀបធៀបជាមួយនឹងសមត្ថភាពរបស់មនុស្សក្នុងការអនុវត្តសកម្មភាពក្នុងជីវិតប្រចាំថ្ងៃ។

### ៣.១.៣.លក្ខណៈសម្គាល់៖

កុមារដែលមានការលំបាកផ្នែកបញ្ញាភាគច្រើនស្ថិតនៅក្នុងកម្រិតមធ្យមដោយមានពិន្ទុ IQ ពី 50-70។ ចំពោះកុមារជាច្រើនក្នុងចំណោមកុមារទាំងនេះ ពុំមានមូលហេតុដែលគេដឹងឮជាក់លាក់ទាក់ទងនឹងភាពយឺតយ៉ាវនៃការលូតលាស់របស់ពួកគេទេ។

លក្ខណៈទាំងពីរនេះ មានកម្រិតដែលមានលក្ខណៈខុសៗគ្នានិងដូចគ្នាជាច្រើន ដោយកុមារខ្សោយបញ្ញាទាំងអស់មានកម្រិតផ្នែក សម្បទាផ្នែកបញ្ញា និង ការផ្លាស់ប្តូរអាកប្បកិរិយា។ ភាពមានកម្រិតផ្នែកសម្បទា ផ្នែកបញ្ញា ជាទូទៅរួមមានការលំបាកក្នុងការរំលឹកឡើងវិញពីការចងចាំ ការបំពេញកិច្ចការផ្សេងៗ និងការអនុវត្តសកម្មភាព ផ្សេងៗមានលក្ខណៈទូទៅ ហើយកុមារទាំងនេះអាចបង្ហាញនូវទំនោរមួយទៅរកការមានកំលាំងចិត្តទាប និងបាត់បង់ក្តីសង្ឃឹមក្នុងការរៀនសូត្រ។ ចំណុចបញ្ហាទាក់ទងនឹងការផ្លាស់ប្តូរផ្នែកអាកប្បកិរិយាអាចរាប់បញ្ចូលទាំងការលំបាកទាក់ទងនឹងបំណិនផ្នែកគោលគំនិត បំណិនផ្នែកសង្គម និងបំណិនក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ។ កុមារខ្សោយបញ្ញាក៏មានការលំបាកចំពោះបំណិន ក្នុងការសម្រេចចិត្តខ្លួនឯង រាប់បញ្ចូលទាំង ការប្រើប្រាស់ជម្រើស ការដោះស្រាយបញ្ហា និងការកំណត់គោលដៅ។

កុមារដែលគេធ្វើរោគវិនិច្ឆ័យឃើញថាមានការលំបាកផ្នែកបញ្ញាក្នុងកម្រិតស្រាលបង្ហាញពីភាពយឺតយ៉ាវផ្នែកបំណិនយល់ដឹង សង្គម និងអាកប្បកិរិយាសម្របខ្លួន នៅក្នុងថ្នាក់រៀនធម្មតា។ នៅក្នុងស្ថានភាពផ្សេងទៀត កុមារទាំងនេះមានសមត្ថភាពទាំងផ្នែកសង្គម និងផ្នែកវិជ្ជាជីវៈ។ នៅក្នុងជីវិតពេញវ័យរបស់ខ្លួន មនុស្សទាំងនេះអាចមានភាពម្ចាស់ការ និងអាចសម្របខ្លួន បានយ៉ាងល្អទៅនឹងស្ថានភាពផ្សេងៗដែលនៅក្រៅសាលារៀនលើកលែងតែការសិក្សា ដែលតម្រូវឱ្យមានការយល់ដឹងខ្ពស់។ ផ្អែកលើការវាយតម្លៃពីសាលារៀន កុមាប្រភេទនេះត្រូវបានគេបង្ហាញថា «ពួកគេមិនសូវឆ្លាតក្នុងរយៈពេល៦ម៉ោងនៅសាលារៀន(six-hours intellectual impairment)» ដែលឆ្លុះឱ្យឃើញពីពេលវេលា ដែលសិស្សស្ថិតនៅក្នុងថ្នាក់រៀនពិតប្រាកដ ហើយទំនងជាពិបាកក្នុងការសិក្សា។

## ឥទ្ធិពលលើការរៀនសូត្រៈ

នៅពេលមានការគាំទ្របានត្រឹមត្រូវ សិស្សខ្សោយបញ្ញាអាចសម្រេចបាននូវគុណភាពជីវិតប្រសើរសម្រាប់ផ្នែកផ្សេងៗជាច្រើន។សាលាត្រូវតែធ្វើការកែសម្រួលកម្មវិធីសិក្សា និងណែនាំតាមលក្ខណៈស្តង់ដារ ដោយប្រុងប្រយ័ត្ននៅពេលចាំបាច់ដើម្បីជួយសិស្សទាំងនេះឱ្យសម្រេចបាននូវការសិក្សា និងផ្នែកសម្បទាផ្សេងៗទៀត ដូចជាការរស់នៅដោយម្ចាស់ការលើខ្លួនឯង។ ពេលដែលសិស្សទាំងនេះមានកម្រិត នៃអាកប្បកិរិយាសម្របខ្លួន ។ ការសិក្សាពីសង្គមដើម្បីសម្រេចបាននូវភាពម្ចាស់ការ និងការពឹងផ្អែកលើខ្លួនឯងគឺជាគោលដៅចម្បងរាល់យុទ្ធសាស្ត្រនៃការបង្រៀនទាំងអស់ដែលគេអនុវត្តជាមួយសិស្សខ្សោយបញ្ញា។

ទោះជាយ៉ាងណាក៏ដោយ កុមារដែលខ្សោយបញ្ញាធ្ងន់ធ្ងរមិនមានសមត្ថភាពផ្នែកបញ្ញាដើម្បី «តាមទាន់»មិត្តភក្តិរបស់ខ្លួនទេចំពោះការសិក្សា។ ជាការពិតណាស់កុមារប្រហែលកាន់តែនៅដាច់ឆ្ងាយថែមទៀតនៅពេលដែលគេមានអាយុកាន់តែច្រើន ប្រសិនបើ សាលាពុំបានអនុវត្តការគាំទ្រលើការរៀនសូត្រឱ្យបានត្រឹមត្រូវ។ ទោះបីជាមានកម្មវិធីល្អ មួយក៏ដោយ គំលាតផ្នែកបញ្ញានិងការរៀនសូត្ររវាងសិស្សទាំងនេះ និងសម្បទាទូទៅរបស់មិត្តភក្តិ គេតែងតែរីកធំឡើងទៅតាមអាយុ។ កុមារដែលមានភាពយឺតយ៉ាវក្នុងការលូតលាស់នឹងរៀនសូត្រចេះដឹង និងយល់ពីកិច្ចការផ្សេងៗបានតិចជាង និងយឺតជាងកុមារធម្មតា ហើយការលូតលាស់ផ្នែកបញ្ញា តែងតែ ជួបការលំបាកជានិច្ច។ ទោះជាយ៉ាងណាក៏ដោយ កុមារខ្សោយបញ្ញានឹងបន្តការ រៀនសូត្រ និងយល់ពីទិដ្ឋភាពមួយចំនួនរបស់ពិភពលោក ប៉ុន្តែ ការរីកលូតលាស់ផ្នែកបញ្ញានេះមានភាពពេញលេញតិចតួចហើយវានៅតែមានគំលាតដដែលចំពោះមូលដ្ឋាននៃចំណេះដឹងរបស់សិស្ស។ ដោយសារការសិក្សាថ្មីៗត្រូវបានគេចម្រាញ់តាមរយៈបរិបទផ្នែកផ្លូវចិត្តរបស់កុមារតូចក្នុងចំណោមកុមារដែលមានភាព យឺតយ៉ាវក្នុងការលូតលាស់គុណភាពពីអ្វីដែលគេបានរៀន និងរបៀបដែលគេអនុវត្តវានឹងមានភាពខុស គ្នាពីអ្វីដែលកុមារធម្មតាកំពុងលូតលាស់។

## ៣.១.៤.មូលហេតុៈ

ពិការខ្សោយបញ្ញាអាចបណ្តាលមកពីលក្ខខណ្ឌណាមួយដែលធ្វើឱ្យការលូតលាស់របស់ខួរក្បាលជួបការលំបាកមុនពេលសម្រាល ក្នុងពេលសម្រាល និងក្នុងវ័យកុមារភាព។ មូលហេតុជាច្រើនត្រូវបានគេរកឃើញ ប៉ុន្តែក្នុងចំណោមកុមារប្រមាណជា មួយភាគបី នៃកុមារដែលទទួលរងផលប៉ះពាល់ គេនៅតែមិនទាន់ដឹងពីមូលហេតុច្បាស់លាស់នៅឡើយ។ ប្រភេទពិការខ្សោយបញ្ញាចំនួនបី សំខាន់ៗមាន Down syndrome សំណុំបញ្ហាជាតិអាល់កុលដែលប៉ះពាល់ដល់ទារកនៅក្នុងផ្ទៃដោយសារម្តាយសេពគ្រឿងស្រវឹង( Fetal Alcohol Spectrum Disorder [FASD]) និងជំងឺហ្សែន (ច្រើនមានពីកំណើត)[Fragile X syndrome]។ គេអាចបែងចែកមូលហេតុនានាដូចខាងក្រោមៈ

- កត្តាដំណារពូជ-លក្ខខណ្ឌទាំងនេះបណ្តាលមកពីភាពមិនប្រក្រតីរបស់ហ្សែនដែលមានពីឪពុកម្តាយ ដំណើរខុសប្រក្រតីនៅពេលហ្សែនប្រមូលផ្តុំគ្នា ឬបណ្តាលមកពីបញ្ហាផ្សេងៗទៀតរបស់ហ្សែនដែលបង្កឡើងក្នុងពេលមានផ្ទៃពោះដោយសារការឆ្លងរោគ ការថតកាំរស្មីXច្រើនពេក និង កត្តាផ្សេងៗទៀត។ មានជំងឺហ្សែនជាច្រើនដែលទាក់ទងនឹងពិការខ្សោយបញ្ញា ។ ឧទាហរណ៍មួយចំនួនរួមមានជំងឺដែលបង្កពីប៉ារាស៊ីតឈ្មោះតុក្សូប្លាស្មា ដែលជាបញ្ហាតែមួយគត់របស់ហ្សែន។ ដោយសារការបាត់បង់ ឬការចុះខ្សោយរបស់អង់ហ្ស៊ីមមួយ កុមារដែលមានជំងឺPKUមិនអាចដំណើរការ(កែច្នៃ)ផ្នែកមួយរបស់ប្រូតេអ៊ីនដែលគេហៅថា phe- nylalanine បានទេ។ បើពុំមានការព្យាបាលទេ phenylalanineនឹងប្រមូលផ្តុំគ្នានៅក្នុងឈាម ហើយបណ្តាលឱ្យមានពិការខ្សោយបញ្ញា។ Down syndrome គឺជាឧទាហរណ៍មួយនៃ បញ្ហារបស់ក្រូម៉ូហ្សូម។ បញ្ហាក្រូម៉ូហ្សូមកើតមានឡើងមិនទៀងទាត់ ហើយកើតឡើងដោយសារ មានក្រូម៉ូហ្សូមច្រើនពេក ឬតិចពេក ឬដោយសារការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ក្រូម៉ូហ្សូម។ ជំងឺ ហ្សែនគឺជាបញ្ហារបស់ហ្សែនតែមួយគត់ដែលមាននៅក្នុងក្រូម៉ូហ្សូម X ហើយគឺជាការនាំទៅរកមូលហេតុនៃពិការខ្សោយបញ្ញាតពូជ។
- បញ្ហាក្នុងពេលមានផ្ទៃពោះ៖ ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនពីសំណាក់ម្តាយដែលកំពុង ពរពោះអាចបង្កឱ្យមានពិការខ្សោយបញ្ញា។ ។ ការស្រាវជ្រាវក្នុងពេល ថ្មីៗនេះបានរកឃើញនូវការជាប់ទាក់ទងគ្នាចំពោះហានិភ័យបណ្តាលឱ្យខ្សោយបញ្ញារួមមាន ជំងឺខ្វះអាហាររូបត្ថម្ភ ការពុលដោយសារ បរិស្ថានជាក់លាក់ និងជំងឺផ្សេងៗរបស់ម្តាយក្នុងពេលមានផ្ទៃពោះ ដូចជាជំងឺម្យ៉ាងដែលបណ្តាល មកពីកាឆ្លងប៉ារាស៊ីតរបស់សត្វ(toxoplasmosis) ជំងឺវីរុសដែលអាចបង្កឱ្យមានភាពមិនប្រក្រតី ពីកំណើតលើទារក(cytomegalovirus) រោគកញ្ជ្រិលស្រាលឬស្អូច(គ្រោះថ្នាក់ដល់ទារក ក្នុងផ្ទៃបើម្តាយកើតជំងឺនេះ[rubella]) និងជំងឺស្វាយ (កាមរោគ)។
- បញ្ហាក្នុងពេលសម្រាល៖ ការសម្រាលមុនពេលកំណត់ ឬទារកកើតមកមិនគ្រប់គីឡូអាចបណ្តាល ឱ្យមានបញ្ហាធ្ងន់ធ្ងរដូចជាការរំខានដល់ដំណើរការសំខាន់ៗដែលទាក់ទងនឹងការលូតលាស់របស់ ខួរក្បាលនៅដំណាក់កាលដំបូង។ ការលំបាកផ្សេងៗក្នុងអំឡុងពេលដំណើរការសម្រាល ដូចជា ការថប់ដង្ហើម(ខ្វះអុកស៊ីសែន)មួយរយៈ ឬការរងរបួសក្នុងពេលសម្រាលអាចបណ្តាលឱ្យមាន ពិការខ្សោយបញ្ញា។
- បញ្ហាក្រោយពេលសម្រាល៖ ជំងឺផ្សេងៗក្នុងវ័យកុមារដូចជាជំងឺក្អកមាន់ អុតស្វាយ កញ្ជ្រិល និង ជំងឺដែលបង្កឱ្យរលាកស្រោមខួរនោះ(ក្លាយជារោគដែលបណ្តាលមកពីបាក់តេរីដែលបង្កឱ្យរលាក ស្រោមខួរប្រភេទ B [hib] ដែលមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើកុមារនៅអាយុ5ឆ្នាំដំបូង)ដែល បណ្តាលឱ្យកើតមេរោគរលាកស្រោមខួរ(meningitis) និងជំងឺរលាកស្រោមខួរ(encephalitis) អាចធ្វើឱ្យខូចខួរក្បាល។ ការមានរបួសស្នាមផ្សេងៗដូចជាការប៉ះទង្គិចក្បាល(a blow to the head) ឬការឈ្លក់ទឹក(near drowning) ការពុលសារធាតុសំណ

បារ៉ែត និងផ្នែកបរិស្ថានផ្សេង ទៀតអាចបណ្តាលឱ្យខូចទាំងស្រុងដល់ប្រព័ន្ធខួរក្បាល និងសរសៃប្រសាទ។

- ភាពក្រីក្រ និងការអត់អាហារៈ កុមារដែលធំលូតលាស់នៅក្នុងភាពក្រីក្រគឺស្ថិតនៅក្នុងហានិភ័យ កាន់តែខ្ពស់ចំពោះជំងឺខ្វះអាហាររូបត្ថម្ភ ជំងឺក្នុងវ័យកុមារ ប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ដល់ សុខភាពដែលមាននៅក្នុងបរិស្ថាន ហើយជាទូទៅពុំទទួលបានការថែរក្សាសុខភាពគ្រប់គ្រាន់ទេ។ កត្តាទាំងអស់នេះបង្កើននូវហានិភ័យចំពោះពិការខ្សោយបញ្ញា។ កុមារដែលស្ថិតនៅក្នុង តំបន់ជួបការលំបាកក៏ប្រហែលជាពុំទទួលបានការអប់រំ និងការអភិវឌ្ឍដែលបង្កើននូវបទពិសោធន៍ ផ្សេងៗដូចដែលគេផ្តល់ឱ្យកុមារផ្សេងទៀត។

## ៣.១.៥.ការការពារៈ

- មូលហេតុជាក់លាក់នានានៃពិការខ្សោយបញ្ញាអាចទប់ស្កាត់បាន។ មូលហេតុទូទៅបំផុត ក្នុងចំណោមមូលហេតុទាំងអស់នេះគឺរោគសញ្ញាដែលកើតចេញពីគ្រឿងស្រវឹងដែលធ្វើឱ្យប៉ះពាល់ទារកក្នុងផ្ទៃ(fetal alcohol syndrome)។ ស្ត្រីមានផ្ទៃពោះមិនត្រូវផឹកគ្រឿងស្រវឹងទេ។ ការទទួល បានការថែរក្សាគភ៌ត្រឹមត្រូវ ការទទួលបានថ្នាំវីតាមីនពេលមានគភ៌ និងទទួលបានការចាក់ថ្នាំ បង្ការប្រឆាំងនឹងជំងឺឆ្លងមួយចំនួនក៏អាចកាត់បន្ថយ ពិការខ្សោយបញ្ញាដែរ។
- ចំពោះគ្រួសារនានាដែលមានប្រវត្តិទាក់ទងនឹងបញ្ហាហ្សែន គួរផ្តល់អនុសាសន៍ឱ្យ ពិសោធន៍ហ្សែនមុនពេលសម្រេចចិត្តមានផ្ទៃពោះ(ចាប់កំណើត)។
- ការពិសោធន៍ជាក់លាក់ ដូចជាការពិនិត្យដោយស្តាប់សំលេងចលនា(ultrasound) និងការពិសោធន៍ទឹកភ្លោះ(amniocentesis)ក៏អាចធ្វើបានដែរក្នុងពេលកំពុងមានផ្ទៃពោះដើម្បីរកមើល បញ្ហានានាដែលទាក់ទងនឹងពិការខ្សោយបញ្ញា។ ទោះបីជាការពិសោធន៍ទាំងនេះអាចរកឃើញនូវបញ្ហានានាមុនពេលសម្រាលក៏ដោយ ក៏គេមិនអាចកែតម្រូវអ្វីបានដែរ។
- ការធ្វើអន្តរាគមន៍ផ្សេងៗទៀតកាត់បន្ថយពិការខ្សោយបញ្ញា។ ការលប់បំបាត់នូវ សារជាតុសំណនៅក្នុងបរិស្ថានអាចកាត់បន្ថយការខូចខួរក្បាលក្នុងចំណោមកុមារ។ ការធ្វើអន្តរាគមន៍របៀបការពារដូចជាកន្លែងអង្គុយដែលមានសុវត្ថិភាពសម្រាប់កុមារ និងពាក់មួកសុវត្ថិភាពសម្រាប់ជិះ កង់ឬម៉ូតូកាត់បន្ថយនូវការប៉ះទង្គិចក្បាល។ កម្មវិធីអន្តរាគមន៍ភ្លាមៗសម្រាប់ទារក និងកុមារដែលទើប តែចេះដើរដែលមានហានិភ័យខ្ពស់បានបង្ហាញឱ្យឃើញនូវប្រសិទ្ធភាពជាវិជ្ជមានទៅលើសម្បទា (functioning)ផ្នែកបញ្ញា។ ចុងក្រោយ ការថែរក្សាគភ៌ឱ្យបានពេញលេញតាំងតែពីដំបូង និង វិធានការការពារផ្សេងៗមុននិងក្នុងពេលមានផ្ទៃពោះបង្កើនឱកាសរបស់ស្ត្រីក្នុងការទប់ស្កាត់ពិការខ្សោយបញ្ញា។ការបន្ថែមរបបអាហារដែលមានសារជាតុអាស៊ីតហ្វូលីក(....)ដែលគេទទួលទានមុនពេល និងក្នុងពេលមានផ្ទៃពោះកាត់បន្ថយនូវហានិភ័យនៃខូចសរសៃប្រសាទ។ ស្ត្រីដែលមានជំងឺphenylketonuria(PKU)(បញ្ហារបស់ហ្សែនកើតឡើងដោយសារកង្វះអង់ស៊ីម)គួរត្រូវបានគេប្រឹក្សាយោបល់ឱ្យតមអាហារphenylalanine

សម្រាប់រយៈពេល3ខែមុនពេល មានផ្ទៃពោះដើម្បីទប់ស្កាត់ពិការខ្សោយបញ្ញាចំពោះទារករបស់ខ្លួន។

- សុខភាពរបស់ទារកម្នាក់ អាចពឹងផ្អែកទៅលើម្តាយមានសុខភាពល្អកម្រិតណានៅមុនពេលមានផ្ទៃពោះ។ យកល្អ ស្ត្រីគួរទៅពិនិត្យសុខភាពទូទៅរយៈពេល 6 ខែមុនពេល មានផ្ទៃពោះរួមមាន៖
    - ➢ ការធ្វើបច្ចុប្បន្នភាពការចាក់ថ្នាំបង្ការ
    - ➢ ការពិនិត្យមើលឡើងវិញនូវការប្រើប្រាស់ថ្នាំផ្សេងៗ
    - ➢ ការពិនិត្យមើលឡើងវិញនូវរបបអាហារ និងការបន្ថែមវីតាមីន រួមទាំងអាស៊ីតហ្វូលីកដែរ
    - ➢ ការគិតគូរពីការប្រឹក្សាយោបល់ទាក់ទងនឹងហ្សែន
    - ➢ ការឈប់ទទួលទានគ្រឿងស្រវឹង បារី គ្រឿងញៀនដែលវិជ្ជបណ្ឌិតមិនអនុញ្ញាតិ។
- ការថែរក្សាគត៌ក្នុងពេល មានផ្ទៃពោះ ស្ត្រីអាចការពារទារកក្នុងផ្ទៃដែលកំពុងលូតលាស់បានតាមរយៈ៖
    - ➢ ការសម្រាក និងការទទួលទានដំណេកឱ្យបានគ្រប់គ្រាន់
    - ➢ ទទួលទានអាហារដែលមានសារជាតុចិញ្ចឹមច្រើន
    - ➢ ចៀសវាងការទទួលទានគ្រឿងស្រវឹង បារី និងគ្រឿងញៀន
    - ➢ គេចចេញពីមនុស្សដែលមានជំងឺ
    - ➢ ដាក់ខ្សែក្រវ៉ាត់ពេលអង្គុយក្នុងឡាន និង
    - ➢ មិនលើករបស់អ្វីដែលធ្ងន់។
- ត្រូវពិចារណាពីការប្រឹក្សាយោបល់ទាក់ទងនឹងហ្សែនប្រសិនបើ៖
    - ➢ កុមារអាចមានតំណរពូជទាក់ទងនឹងបញ្ហារបស់ហ្សែនឬក្រូម៉ូហ្សូមដោយសារលក្ខណៈជាក់លាក់មួយនៅក្នុងគ្រួសារ
    - ➢ ការផ្តល់កំណើតពីមុនមករបស់ឪពុកម្តាយទាំងសងខាងដែលធ្វើឱ្យកូនមានបញ្ហាមួយទាក់ ទងនឹងហ្សែន ពិការខ្សោយបញ្ញាដែលមិនអាចពន្យល់បាន ឬការចុះខ្សោយចំពោះការលូតលាស់របស់ទារកក្នុងផ្ទៃ(birth defect)។
    - ➢ ម្តាយធ្លាប់បានពន្លូតកូន 2 ដង ឬច្រើនជាងនេះ ឬទារកបានស្លាប់ក្នុងវ័យជាកូនង៉ែត
    - ➢ ម្តាយមានអាយុ 35 ឆ្នាំ ឬលើសពីនេះ
    - ➢ ដៃគូរណាមួយជាពូជសាសន៍ ឬក្រុមជនជាតិភាគតិចដែលមានឧប្បត្តិហេតុខ្ពស់ទាក់ទង នឹងលក្ខខណ្ឌហ្សែន ឬដៃគូដែលជាប់សាច់ឈាមនឹងគ្នា។
- ពិការខ្សោយបញ្ញាអាចការពារបាននៅក្នុងវ័យកុមារភាពតាមរយៈការដឹងពីមូលហេតុ និង ចាត់វិធាននានាដើម្បីធ្វើឱ្យកុមារមានសុវត្ថិភាព និងសុខភាពល្អ។ វិធានការទាំងនេះរួមមាន៖
    - ➢ ការចាក់ថ្នាំបង្ការនៅក្នុងវ័យកុមារភាពដើម្បីការពារកុមារកុំឱ្យមានជំងឺយ៉ាងហោចណាស់ចំនួន 6 មុខដែរដែលអាចធ្វើឱ្យខូចខួរក្បាលរបស់កុមារ។ ជំងឺទាំងនេះរួមមានជំងឺ កញ្ជ្រិល ក្រឡទែន ក្អកមាន់(ក្អកម្ហបៗ) រលាកស្រោមខួរ អុត(អុតស្វាយ) និង

លោក ស្ងួត។

- ការការពារកុំឱ្យមានរបួសដើម្បីចៀសវាងការខូចខួរក្បាល ដូចជាការប្រើប្រាស់មួកសុវត្ថិភាពសម្រាប់ជិះកង់ និងកន្លែងអង្គុយដែលមានសុវត្ថិភាព ព្រមទាំងដាក់ខ្សែក្រវ៉ាត់ពេល ជិះរថយន្ត ការការពារការឈ្លក់ទឹក ការការពារការធ្លាក់ និងការការពារកុមារពីការក្រឡុក ខ្លាំងៗ។
- ការពិនិត្យមើលក្រោយពីការសម្រាលភ្លាមៗដើម្បីរកមើលនូវលក្ខណៈផ្សេងៗរបស់ហ្សែន ដែលអាចព្យាបាលបាន។
- កាត់បន្ថយឧប្បត្តិហេតុនៃរោគសញ្ញារលាកខួរក្បាលដែលបណ្តាលមកពីការឱ្យថ្នាំដែលមានសារជាតុ salicylate(aspirin) ផ្ទុយទៅវិញគេត្រូវប្រើថ្នាំដែលមានសារជាតុ aceta- minophen (ដូចជាTylenol)ជំនួសវិញដើម្បីកាត់បន្ថយការខូចខួរក្បាលដែលបណ្តាល មកពីរោគសញ្ញារលាកខួរក្បាល។
- កាត់បន្ថយការប្រឈមនឹងការបំពុលដោយសារជាតុសំណ បារ៉ត និងសារជាតុផ្សេងទៀត នៅក្នុងបរិស្ថានដែលគេដឹងឮថាធ្វើឱ្យខូចខួរក្បាល។
- ការពារកុមារពីផលិតផលដែលមានជាតិពុលផ្សេងៗនៅផ្ទះ។

### ៣.១.៦.ការវាស់ពីកម្រិតបញ្ញា (IQ)៖

ការវាស់ពីកម្រិតបញ្ញា(IQ)គឺជាពិន្ទុសរុបមួយដែលបានមកពីការធ្វើតេស្តស្តង់ដាជាច្រើនដែលគេរៀបចំ ឡើងដើម្បីវាយតម្លៃពីបញ្ញារបស់មនុស្ស។ អក្សរកាត់ «IQ» ត្រូវបានបង្កើតឡើងដោយអ្នកចិត្តវិទ្យា ម្នាក់ឈ្មោះ William Stern ដែលពាក្យអាឡឺម៉ង់ហៅថា Intelligenzquotient ជាពាក្យរបស់គាត់សម្រាប់ ប្រើក្នុងវិធីសាស្ត្រនៃការដាក់ពិន្ទុ សម្រាប់ការធ្វើតេស្តបញ្ញានៅសាកលវិទ្យាល័យ Wroclaw ដែលគាត់ បានគាំទ្រនៅក្នុងសៀវភៅរបស់គាត់នៅក្នុងឆ្នាំ 1912។

តាមប្រវត្តិ IQគឺជាពិន្ទុមួយដែលគេទទួលបាន ដោយការចែកពិន្ទុអាយុនៃការលូតលាស់ខួរក្បាលរបស់មនុស្សម្នាក់ ដែលគេទទួលបានតាមរយៈការធ្វើតេស្តបញ្ញា ជាមួយនឹងអាយុជាក់ស្តែងរបស់មនុស្សម្នាក់ (អាយុទាំងពីរ នេះត្រូវបានគេបង្ហាញជាឆ្នាំ និងខែ)។ ផលធៀបនៃលទ្ធផលគឺត្រូវគុណនឹង100ដើម្បីទទួលបានពិន្ទុIQ។ នៅពេលដែលការធ្វើតេស្តIQបច្ចុប្បន្ន ត្រូវបានគេរៀបចំឡើង ពិន្ទុដើមនៅចំណុចកណ្តាលរបស់សំណាក ដែលជាបទដ្ឋាន ត្រូវបានគេកំណត់ថាជាពិន្ទុIQចំនួន100 ហើយពិន្ទុនានា នៃការប្រែប្រួលតាមស្តង់ដារ(SD)នីមួយៗ ចុះឬឡើង ត្រូវបានគេកំណត់ថាជាពិន្ទុIQ ចំនួន15ច្រើនជាង ឬតិចជាង ទោះបីជាវិធីនេះមិនមានអនុវត្តនៅសម័យដើមក៏ដោយ។ បើអនុវត្តតាមការគណនាបែបនេះ មានមនុស្សប្រមាណ ជាពីរភាគបី ទទួលបានពិន្ទុIQ រវាង85 និង115។ មនុស្សប្រមាណជា5%មានពិន្ទុលើសពី125 និង5%មានពិន្ទុក្រោម75។

ពិន្ទុដែលបានមកពីការធ្វើតេស្តបញ្ញាគឺជាការប៉ាន់ស្មានពីបញ្ញាដោយសារមានការវាស់វែងជាក់លាក់ នានា (ឧទាហរណ៍ ចំងាយ ម៉ាស)មិនអាចសម្រេចបានទេបើគិតពីលក្ខណៈអរូបីយ៍នៃគោលគំនិតរបស់ «បញ្ញា»។ លទ្ធផលពិន្ទុIQ មានទំនាក់ទំនង ជាមួយកត្តានានាដូចជាជំងឺ ការស្លាប់ ស្ថានភាពសង្គម របស់ឪពុកម្តាយ និងទៅតាមកម្រិតដ៏សំខាន់នៃពិន្ទុ IQ របស់ឪពុកម្តាយផ្នែកជីវសាស្ត្រ។ គេបានកំពុងសិក្សាពីតំណពូជន៍ផ្នែកសមត្ថភាពបញ្ញារបស់មនុស្ស អស់រយៈពេលជិតមួយសតវត្សទៅហើយ ប៉ុន្តែនៅតែមានការពិភាក្សាដេញដោលគ្នា អំពីសារៈសំខាន់នៃការវាយតម្លៃពីតំណពូជ និងរបៀបដែលកូនបានទទួលមរតកពីឪពុកម្តាយ។

ពិន្ទុ IQ ត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំការងារអប់រំ វាយតម្លៃអំពីពិការខ្សោយបញ្ញា និងវាយតម្លៃពេលដាក់ពាក្យសុំបម្រើការងារ។ សូម្បីតែនៅពេលដែលសិស្សទទួលបានពិន្ទុរបស់ខ្លួនប្រសើរជាងមុន នៅក្នុងការធ្វើតេស្តស្តង់ដារក៏ដោយ ក៏ពួកគេមិនមែនមានសមត្ថភាពផ្នែកបញ្ញារបស់ខ្លួនប្រសើរជានិច្ចនោះទេ ដូចជាការចងចាំ ការយកចិត្តទុកដាក់ និងល្បឿន។ នៅក្នុងបរិបទនៃការស្រាវជ្រាវ គេចាត់ទុកវាជាកត្តាកំណត់( predictor )ក្នុងការបំពេញការងារ និងប្រាក់ចំណូល។

## ៣.២.ការលំបាកក្នុងការសិក្សាមុខវិជ្ជា

### ៣.២.១. និយមន័យៈ

ការលំបាកក្នុងការសិក្សាមុខវិជ្ជា គឺជាបញ្ហាមួយផ្នែកនៃប្រព័ន្ធប្រសាទរបស់មនុស្ស។ ក្នុងន័យសាមញ្ញ បញ្ហានេះកើតឡើង ដោយសារតែ ប្រព័ន្ធខួរក្បាលរបស់មនុស្សម្នាក់«បានចងភ្ជាប់គ្នា» ដែលខុសប្លែក ពីមនុស្សម្នាក់ទៀត។ កុមារដែលមានការលំបាកក្នុងការសិក្សា អាចឆ្លាតដូចមិត្តភក្តិរបស់គេ ឬអាចឆ្លាតជាងមិត្តភក្តិរបស់គេទៀតផង។ ទោះយ៉ាងនេះក្តី ពួកគេអាចមានការលំបាកក្នុងការអានសរសេរ ប្រកប ពន្យល់ហេតុផល រម្លឹកឡើងវិញ ឬរៀបចំព័ត៌មានសម្រាប់បង្ហាញ ប្រសិនបើឱ្យពួកគេធ្វើកិច្ចការដោយខ្លួនឯង ឬប្រសិនបើគ្រូ បង្រៀនពួកគេតាមរបៀបបុរាណ។

ការលំបាកក្នុងការសិក្សាមិនអាចព្យាបាល ឬកែតម្រូវបានទេ វាគឺជាបញ្ហាពេញមួយជីវិត។ ទោះជាយ៉ាង ណាក៏ដោយ បើមានការគាំទ្រ និងអន្តរាគមន៍ត្រឹមត្រូវ កុមារដែលមានការលំបាកក្នុងការសិក្សា អាចទទួលជោគជ័យក្នុងការសិក្សាដែរ ហើយអាចបន្តជោគជ័យ ដល់អាជីព នៅក្នុងជីវិតរបស់ពួកគេបន្តទៀត។

យើងអាចជួយកុមារមានការលំបាកក្នុងការសិក្សា ឱ្យទទួលបានលទ្ធផលជោគជ័យ តាមរយៈការលើកទឹកចិត្តដល់ចំណុចខ្លាំងរបស់គាត់ ដឹងពីចំណុចខ្សោយរបស់គាត់ យល់ពីប្រព័ន្ធអប់រំ ធ្វើការជាមួយអ្នកដែលមានជំនាញជួយគាត់ និងសិក្សាពីវិធីដើម្បីដោះស្រាយការលំបាករបស់គាត់។

## មិនមែនមនុស្សឆ្លាតទាំងអស់គិតដូចគ្នានោះទេ៖

តើលោកឬលោកស្រីដឹងទេថា Albert Einstein មិនចេះអានអក្សររហូតដល់គាត់មានអាយុ៩ឆ្នាំ? លោក Walt Disney ឧត្តមសេនីយ George Patton និងអតីតអនុប្រធានាធិបតីសហរដ្ឋអាមេរិកលោក Nelson Rockefeller មានការលំបាកក្នុងការអានអក្សរពេញមួយជីវិតរបស់ពួកគាត់។ Whoopi Goldberg និង Charles Schwab ព្រមទាំងអ្នកផ្សេងជាច្រើនទៀត មានការលំបាកក្នុងការសិក្សា ដែលមិនប៉ះពាល់ដល់ ជោគជ័យ នៅក្នុងជីវិតរបស់ពួកគាត់នោះទេ។

## ការពិតមួយចំនួន អំពីការលំបាកក្នុងការសិក្សា៖

- តាមស្ថិតិរបស់វិទ្យាស្ថានជាតិសុខភាព ប្រជាជនសហរដ្ឋអាមេរិកចំនួន១៥% ឬម្នាក់ក្នុងចំណោម៧នាក់ មានសញ្ញាមួយចំនួន ទាក់ទងនឹងការលំបាកក្នុងការសិក្សា។
- ការលំបាកនៅក្នុងមូលដ្ឋានគ្រឹះនៃការអាន និងបំណិននៃការប្រើប្រាស់ភាសា មានកើតឡើងច្រើនជាទូទៅ នៅក្នុងការលំបាកក្នុងការសិក្សា។ សិស្សមានចំនួនច្រើនរហូតដល់៨០% ដែលមានការលំបាកក្នុងការសិក្សា មានបញ្ហាក្នុងការអានអក្សរ។
- ការលំបាកក្នុងការសិក្សាតែងកើតមានឡើងនៅក្នុងគ្រួសារ។
- គេមិនត្រូវយល់ច្រឡំចំពោះការលំបាកក្នុងការសិក្សា ជាមួយពិការភាពផ្សេងៗទៀតទេ ដូចជាអូទីសឹម ខ្សោយសតិបញ្ញា ថ្លង់ ខ្វាក់ និងបញ្ហាអាកប្បកិរិយា។ ពុំមានលក្ខខណ្ឌណាមួយក្នុងចំណោមពិការទាំងនេះ ដែលជាកាលំបាកក្នុងការសិក្សាទេ។ ជាងនេះទៅទៀត គេមិនត្រូវច្រឡំការលំបាកក្នុងការសិក្សា ជាមួយនឹងការខ្វះឱកាសក្នុងការសិក្សាទេ ដូចជាការផ្លាស់ប្ដូរសាលារៀនជាញឹកញាប់ ឬអវត្តមានពីការសិក្សាជាដើម។ កុមារដែលកំពុងរៀនភាសាអង់គ្លេសក៏មិនចាំបាច់មានការលំបាកក្នុងការសិក្សាដែរ។
- បញ្ហាក្នុងការផ្ដោតអារម្មណ៍ ដូចជាពិបាកផ្ចង់អារម្មណ៍និងសកម្មជ្រុល(ADHD) និងការលំបាកក្នុងការសិក្សា តែងកើតមានក្នុងពេលជាមួយគ្នា ប៉ុន្តែបញ្ហាទាំងពីរមិនដូចគ្នាទេ។

## ការលំបាកទូទៅ ក្នុងការសិក្សាមុខវិជ្ជា៖

- លំបាកក្នុងការអាន(Dyslexia)៖ ការលំបាកក្នុងការអាន គឺជាការលំបាកផ្នែកភាសា ដែលមនុស្សម្នាក់ពិបាកយល់អំពីពាក្យដែលគេសរសេរ។ គេក៏អាចហៅវាថា ជាការលំបាកក្នុងការអាន ឬបញ្ហាក្នុងការអាន។
- លំបាកក្នុងការគណនា(Dyscalculia)៖ លំបាកក្នុងការគណនា គឺជាការលំបាកផ្នែកគណិតវិទ្យា ដែលមនុស្សម្នាក់ ជួបប្រទះក្នុងការដោះស្រាយបញ្ហាលេខគណិត និងយល់ពីគោលគំនិតផ្នែកគណិតវិទ្យា។

- លំបាកក្នុងការសរសេរ(Dysgraphia)៖ លំបាកក្នុងការសរសេរ គឺជាការលំបាកមួយ ដែលមនុស្សម្នាក់មាន ក្នុងការសរសេរឱ្យទៅជាទម្រង់អក្សរ ឬសរសេរអក្សរ នៅកន្លែងដែលគេបានកំណត់។
- បញ្ហាក្នុងការស្តាប់និងមើល៖ គឺជាបញ្ហាផ្នែកវិញ្ញាណទទួល ដែលមនុស្សម្នាក់មានការលំបាកក្នុងការយល់ ភាសា ទោះបីជាគាត់ស្តាប់លឺ និងមើលឃើញធម្មតាក៏ដោយ។
- ការលំបាកក្នុងការសិក្សាដោយសារការមិនយល់ភាសាកាយវិការ(Nonverbal learning disabilities)៖ ការលំបាកក្នុងការសិក្សាដោយសារការមិនយល់ពីភាសាកាយវិការ គឺជាបញ្ហាផ្នែកប្រព័ន្ធប្រសាទ ដែលកើតមាននៅខួរក្បាលផ្នែកខាងស្តាំ និងបណ្តាលឱ្យមានបញ្ហាផ្សេងៗទាក់ទងនឹងទំហំចក្ខុវិញ្ញាណការយល់ដោយអារម្មណ៍ ការរៀបចំ ការថ្លឹងថ្លែង និងដំណើរការតាមមុខងាររបស់សរីរាង្គ។

## សញ្ញាសម្គាល់ទូទៅនៃការលំបាកក្នុងការសិក្សាមុខវិជ្ជា៖

ព័ត៌មានល្អស្តីពីការលំបាកក្នុងការសិក្សា គឺថា ក្រុមអ្នកវិទ្យាសាស្ត្រកំពុងសិក្សាស្រាវជ្រាវថែមទៀតរាល់ថ្ងៃ អំពីប្រធានបទនេះ ហើយការស្រាវជ្រាវនេះ នឹងផ្តល់នូវក្តីសង្ឃឹម ព្រមទាំងវិធីមួយចំនួន។

ប្រសិនបើឪពុកម្តាយ គ្រូបង្រៀន និងអ្នកមានវិជ្ជាជីវៈផ្សេងទៀត រកឃើញនូវការលំបាកក្នុងការសិក្សា របស់កុមារតាំងពីគាត់នៅវ័យដំបូង ហើយជួយគាត់បានត្រឹមត្រូវ វាអាចផ្តល់ឱ្យកុមារនូវឱកាសមួយ ក្នុងការអភិវឌ្ឍជំនាញដែលគេត្រូវការដើម្បីនាំទៅរកជីវិតប្រកបដោយភាពជោគជ័យ និងផលិតភាព។ ការសិក្សាមួយក្នុងពេលថ្មីៗនេះរបស់វិទ្យាស្ថានជាតិសុខភាពនៅ Bethesda ក្នុងរដ្ឋ Maryland សហរដ្ឋអាមេរិកបង្ហាញថា សិស្សតូចៗចំនួន 67% ដែលស្ថិតក្នុងហានិភ័យចំពោះការលំបាកក្នុងការអានបានក្លាយជាអ្នកចេះអានមធ្យម ឬលើមធ្យមបន្ទាប់ពីទទួលបានជំនួយនៅថ្នាក់ទាបៗ។

ជាទូទៅឪពុកម្តាយគឺជាមនុស្សដំបូងដែលកត់សម្គាល់ឃើញថា«មានអ្វីមួយដែលហាក់ដូចជាខុសធម្មតា»។ ប្រសិនបើលោកឬលោកស្រីដឹងពីសញ្ញាសម្គាល់ទូទៅនៃការលំបាកក្នុងការសិក្សា លោកឬលោកស្រីនឹងមាន លទ្ធភាពដឹងពីបញ្ហាប្រឈមតាំងពីដំបូង។ ចំណុចខាងក្រោមនេះគឺជាបញ្ជីពិនិត្យផ្ទៀងផ្ទាត់ពីលក្ខណៈដែលអាចចង្អុលបង្ហាញពីការលំបាកមួយក្នុងការសិក្សា។ ពីមួយថ្ងៃទៅមួយថ្ងៃ មនុស្សភាគច្រើនមើលឃើញសញ្ញាឱ្យដឹងជាមុនមួយឬច្រើនក្នុងចំណោមសញ្ញាទាំងនេះ ចំពោះកូនរបស់ខ្លួន។ ចំណុចនេះគឺជារឿងធម្មតា។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើលោកឬលោកស្រីមើលឃើញលក្ខណៈសម្គាល់ ជាច្រើន ដែលអូសបន្លាយពេលដ៏យូរជាមួយកូនលោកអ្នក ចូរគិតពីលទ្ធភាពនៃការលំបាកមួយក្នុងការសិក្សា។

**កុមារស្ថិតក្នុងវ័យកុមារតូច ឬមត្តេយ្យសិក្សា៖**

- ចាប់ផ្តើមនិយាយ ក្នុងវ័យយឺតជាងកុមារភាគច្រើន
- មានបញ្ហាក្នុងការបញ្ចេញសំឡេង
- ការរីកចម្រើនផ្នែកវាក្យសព្ទ(ពាក្យ)យឺតជាទូទៅមិនមានសមត្ថភាពរកឃើញពាក្យដែលត្រឹមត្រូវ
- ពិបាករកពាក្យចុងជួន
- បញ្ហាក្នុងការរៀនលេខ អក្ខរក្រម ឈ្មោះថ្ងៃក្នុងសប្តាហ៍ ពណ៌ រូបធរណីមាត្រ
- សកម្មជ្រុល និងងាយបែកអារម្មណ៍
- ពិបាកក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិ
- ពិបាកក្នុងការអនុវត្តន៍តាមការណែនាំ ឬសកម្មភាពប្រចាំថ្ងៃដដែលៗ
- មានភាពយឺតយ៉ាវក្នុងការលូតលាស់បំណិនផ្នែកចលនាតូច ។

**កុមារពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី៤៖**

- មានភាពយឺតយ៉ាវក្នុងការរៀនពីទំនាក់ទំនងរវាងអក្សរ និងសំឡេង
- យល់ច្រឡំចំពោះពាក្យសាមញ្ញៗ ដូចជា រត់ ញ៉ាំ ចង់ ជាដើម
- មានកំហុសក្នុងការអាន និងប្រកបជាប់ជាប្រចាំ ដោយរាប់បញ្ចូលទាំង អក្សរបញ្ច្រាសគ្នា ដូចជា «ល» និង «ហ» ឬ លេខ «៦» និង «៨» អក្សរមួយផ្កាប់មួយផ្ងា ដូចជា អក្សរ «យ» និង លេខ«៣» អក្សរឆ្លាស់គ្នា ដូចជា «កំណត់ និង តំណក់» ឬ «កត់ និង តក់» និងពាក្យជំនួសគ្នា ដូចជា «ស្រី និង ស្ត្រី» ជាដើម។
- ផ្លាស់ប្តូរលំដាប់លេខរៀង និងច្រឡំសញ្ញាគណិតវិទ្យា ដូចជា «+, -, x, ឬ, = »
- មានភាពយឺតយ៉ាវ ក្នុងការចងចាំហេតុការណ៍នានា
- ការរៀនបំណិនថ្មីមានភាពយឺតយ៉ាវ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការទន្ទេញ
- ធ្វើអ្វីតាមចិត្តនឹកឃើញ ពិបាកក្នុងការរៀបចំផែនការ
- កាន់ខ្មៅដៃដោយគ្មានលំនឹង
- មានបញ្ហាក្នុងការរៀនពីពេលវេលា
- ពិបាកក្នុងសម្របសម្រួលចលនាខ្លួនប្រាណ និងឧស្សាហរណ៍មានឧប្បទ្វវហេតុ ។

**កុមារពីថ្នាក់ទី៥–៨៖**

- អានពាក្យបញ្ច្រាសអក្សរ មិនតាមលំដាប់លំដោយ ឧទាហរណ៍ «កំណត់ និង តំណក់»
- យឺតយ៉ាវក្នុងការរៀន បុព្វបទ និងបច្ច័យ របស់ពាក្យ ឬសគល់នៃពាក្យ និងវិធីផ្សេងៗក្នុងការប្រកបអក្សរ

- មិនចង់អានអក្សរឮខ្លាំងៗ
- មានការលំបាកក្នុងការធ្វើចំណោទ
- ពិបាកក្នុងការសរសេរដោយដៃ
- មានភាពច្រិមច្រុម  ចូលចិត្តក្ដាប់ដៃ ឬកាន់ខ្មៅដៃយ៉ាងណែន
- មិនចង់ធ្វើកិច្ចការសំណេរ ដែលគ្រូដាក់ឱ្យ
- យឺតយ៉ាវ ឬខ្សោយ ក្នុងការចងចាំ និងរំលឹកហេតុការណ៍នានា
- ពិបាកក្នុងការចងមិត្តភាព
- ពិបាកក្នុងការយល់ពីភាសាកាយវិការ និងការសម្ដែងទឹកមុខ ។

**សិស្សវិទ្យាល័យ និងមនុស្សពេញវ័យ៖**

- ចេះតែប្រកប និងសរសេរខុស ជាញឹកញាប់គ្រាន់តែពាក្យមួយ បែជាប្រកបបានច្រើនយ៉ាង
- គេចមិនចង់ ធ្វើកិច្ចការអំណាន និងសំណេរ
- ពិបាកក្នុងការសង្ខេបខ្លឹមសារ
- ពិបាកឆ្លើយសំណួរបើក
- បំណិនក្នុងការចងចាំខ្សោយ
- ពិបាកក្នុងការសម្របខ្លួនទៅតាមបរិយាកាសថ្មី
- ធ្វើកិច្ចការយឺតៗ
- ខ្សោយក្នុងការយល់ពីគោលគំនិតបែបអរូបិយ
- មានការផ្ដោតតិចតួចទៅលើចំណុចលម្អិត ឬជួនកាលយកចិត្តទុកដាក់ខ្លាំងពេកទៅលើចំណុចលម្អិតនោះ
- អានព័ត៌មានខុស ។

### ៣.២.២. មូលហេតុ៖

អ្នកស្រាវជ្រាវពុំបានដឹងពិតប្រាកដពី មូលហេតុដែលបណ្ដាលឱ្យមានការលំបាកក្នុងការសិក្សាទេ ប៉ុន្តែវាហាក់ដូចជាទាក់ទងទៅនឹងភាពខុសគ្នានៃសំណុំខួរក្បាល។ ភាពខុសគ្នាទាំងនេះមានចាប់តាំងពីកំណើត ហើយតែងមានលក្ខណៈដំណរពូជ។ ដើម្បីលើកកម្ពស់ការយល់ដឹងពីការលំបាកក្នុងការសិក្សា អ្នកស្រាវជ្រាវកំពុងសិក្សាពីផ្នែកផ្សេងៗរបស់ខួរក្បាល និងពីរបៀបដែលផ្នែកទាំងនោះដំណើរការ។ ក្រុមអ្នកវិទ្យាសាស្ត្ររកឃើញថា ការលំបាកក្នុងការសិក្សាគឺមានជាប់ទាក់ទងនឹងផ្នែកផ្សេងៗរបស់ខួរក្បាលដែលពាក់ព័ន្ធផ្នែកភាសា ហើយបានប្រើប្រាស់ នូវវិធីផ្សេងៗ ផលិតរូបភាពខាងក្នុងរបស់មនុស្ស ដើម្បីបង្ហាញថាខួរក្បាល របស់អ្នកដែលមានការលំបាកក្នុងការអានអក្សរ លូតលាស់ និងដំណើរការខុសពីខួរក្បាលធម្មតា។

ពេលខ្លះ កត្តាមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់ទារកក្នុងផ្ទៃ ដូចជាការទទួលទានគ្រឿងស្រវឹង ឬការប្រើប្រាស់គ្រឿងញៀនអាចបណ្តាលឱ្យមានការលំបាកក្នុងការសិក្សា។ កត្តាផ្សេងៗទៀត ក្នុងបរិស្ថានរបស់ កុមារអាចដើរតួនាទីដ៏សំខាន់មួយដែរ។ កត្តាទាំងនេះរួមមានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ និងការប្រឈម នឹងសារធាតុពុលផ្សេងៗដូចជាសារធាតុសំណនៅក្នុងទឹក ឬថ្នាំលាប។ ជាងនេះទៅទៀត កុមារដែលមិនទទួលបានការគាំទ្រដំបូង ដែលចាំបាច់សម្រាប់លើកស្ទួយនូវការលូតលាស់ផ្នែកសតិបញ្ញារបស់គេ អាចបង្ហាញឱ្យឃើញនូវសញ្ញាផ្សេងៗនៃការលំបាកក្នុងការសិក្សានៅពេលពួកគេចាប់ផ្តើមចូលរៀន។

ពេលខ្លះមនុស្សម្នាក់អាចវិវឌ្ឍទៅជាមនុស្សដែលមានការលំបាកក្នុងការសិក្សានៅក្នុងជីវិតនៅពេលក្រោយ។ មូលហេតុដែលអាចកើតមានចំពោះករណីដូចនេះរួមមានការបាត់ការចងចាំ ឬរបួសដែលធ្វើឱ្យប៉ះ ទង្គិចដល់ខួរក្បាល។

ដោយពុំមាននរណាម្នាក់ដឹងឱ្យបានច្បាស់ថាតើមូលហេតុអ្វីដែលបណ្តាលឱ្យមានការលំបាកក្នុងការសិក្សានៅឡើយ អ្នកដែលមានវិជ្ជាជីវៈផ្នែកសុខភាពខួរក្បាលបញ្ជាក់ថា វាមិនអាចជួយអ្វីបានទេក្នុងការពិនិត្យមើលទៅក្រោយវិញដើម្បីរកមើលហេតុផលផ្សេងៗដែលអាចកើតមាន។ ទោះបីមានកិច្ចការជាច្រើនទាក់ទងនឹងវិស័យនេះក៏ដោយ ការកំណត់ពីមូលហេតុឱ្យបានច្បាស់លាស់មានការលំបាក ហើយការខិតខំប្រឹងប្រែងក្នុងការធ្វើដូច្នេះនៅតែបន្ត (Hardman, Drew និង Egan, 2003)។ វាអាចជាកត្តាតាងមួយបន្ទាប់ពីអានជំពូកនេះ វាទំនងជាមានមូលហេតុជាច្រើនចំពោះការលំបាកក្នុងការសិក្សា ហើយនៅក្នុងករណីមួយចំនួន ប្រភេទជាក់លាក់នៃការលំបាកក្នុងការសិក្សាអាចមានមូលហេតុច្រើនយ៉ាង។ គ្រូបង្រៀនចាំបាច់ត្រូវ ទទួលស្គាល់ថាវាពុំមានមូលហេតុច្បាស់លាស់ទេពីអ្វីដែលបណ្តាលឱ្យមានការលំបាកក្នុងការសិក្សា ហើយមិនត្រូវធ្វើការសន្មតពីសិស្សដែលខ្លួនបង្រៀនទេ(Deutsch-Smith, 2004)។

ហេតុដូច្នេះហើយ ឪពុកម្តាយ និងគ្រូបង្រៀនត្រូវសម្របខ្លួនទៅតាមវិធីសាស្ត្រនានាដែលបានមកពីប្រភពផ្សេងៗ និងស្វែងរកដំបូន្មានពីអ្នកដែលមានវិជ្ជាជីវៈនៅក្នុងវិស័យនេះ។ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបន្តស្វែងរកមធ្យោបាយនានា ដើម្បីដោះស្រាយ និងជំនះលើការលំបាកនានាឱ្យមានប្រសិទ្ធភាព។

### ៣.២.៣. វិធីបង្ការ

- ការទប់ស្កាត់ជាទូទៅត្រូវបានគេរៀបរាប់ថាជាដំណាក់កាលទី1 ទី2 ឬទី3 អាស្រ័យទៅលើពេលវេលា និងមូលហេតុនៃវិធានការការពារដែលគេអនុវត្ត។ ការទប់ស្កាត់ការលំបាកក្នុងការសិក្សាអាចពាក់ព័ន្ធ នឹងដំណាក់កាលទាំង3ប្រភេទនេះ។

- ការទប់ស្កាត់បឋមមានន័យថាការពារកុំឱ្យមានពិការភាពកើតឡើងតាំងតែពីដំបូង។ ការទប់ស្កាត់បឋមនូវការលំបាកក្នុងការសិក្សាអាចពាក់ព័ន្ធនឹងការកាត់បន្ថយឱកាសនានាដែលធ្វើឱ្យរបួសដល់ខួរក្បាល បង្កើនជំនាញរបស់គ្រូបង្រៀនក្នុងការបង្រៀនសិស្ស និងការគ្រប់គ្រងអាកប្ប កិរិយា ឬបង្រៀនឪពុកម្តាយពីបំណិនក្នុងការចិញ្ចឹមបីបាច់កូន។ ដើម្បីឱ្យការទប់ស្កាត់បឋមដំណើរការបាន វិធីសាស្ត្រត្រូវមានគោលបំណងកាត់បន្ថយ ឬការលុបបំបាត់មូលហេតុ (នានា)នៃការលំបាកក្នុងការសិក្សាមុខវិជ្ជា ឬការទប់ស្កាត់នឹងកត្តាទូទៅ។

ឧទាហរណ៍ វាយឺតពេលទៅហើយក្នុងការអនុវត្តវិធានការទប់ស្កាត់បឋមលើការលំបាកនានាដែលបានកំណត់ ក្នុងថ្នាក់មតេយ្យសិក្សាពីគ្រូបង្រៀនរបស់Jamal។ បន្ទាប់ពីមានបញ្ហាផ្សេងៗកើតឡើង វាយឺតពេលហើយក្នុងការអនុវត្តវិធានការទប់ស្កាត់បឋម។

យើងសូមទាញការប្រុងប្រយ័ត្ន ទោះបីជាវិធានការទប់ស្កាត់បឋមត្រូវបានគេអនុវត្តក៏ដោយ រួមមានការបង្រៀនល្អក៏ដោយ ក៏ការលំបាកក្នុងការសិក្សាអាចនឹងកើតមានដែរ។ ការទប់ស្កាត់បឋមអាច កាត់បន្ថយចំនួនកុមារដែលមានការលំបាកក្នុងការសិក្សាឬបន្ថយភាពធ្ងន់ធ្ងរនៃការលំបាកនានា ប៉ុន្តែវានឹងមិនអាចលុបបំបាត់បាននូវការលំបាកក្នុងការសិក្សាទេ(ការលើកឡើងដូចគ្នានេះ អាចត្រូវបានគេធ្វើឡើង ទាក់ទងនឹងការទប់ស្កាត់បឋម នូវប្រភេទណាមួយនៃពិការភាព។ សូមមើល Kauffman, 1999, 2003)។ ដូច្នេះ ការទប់ស្កាត់បឋមមានសារៈសំខាន់ណាស់ក្នុងការរក្សាអត្រាប្រេវ៉ាឡង់នៃការលំបាកក្នុងការសិក្សាឱ្យនៅកម្រិតទាបតាមដែលអាចធ្វើទៅ បាន។ ទោះជាយ៉ាងណាក៏ដោយ វាគឺជាកំហុសមួយដែលសន្មត ថាវាអាចនឹងកាត់បន្ថយអត្រាប្រេវ៉ាឡង់ឱ្យនៅក្នុងកម្រិតសូន្យ។

## ៣.៣.ភាពខុសប្រក្រតីនៃបណ្តុំអូទីសឹម (ASD)

ភាពខុសប្រក្រតីនៃបណ្តុំអូទីសឹម (ASD) មានអត្ថន័យថ្មីមួយទៀតនៅក្នុងការបោះពុម្ពផ្សាយលើកទី5នៃសៀវភៅមេរៀនស្តីពីការធ្វើរោគវិនិច្ឆ័យ និងម៉ូឌុលស្តីពីស្ថិតិនៃបញ្ហារបស់ខួរក្បាល(DSM-V)។ សមាគមគ្រូពេទ្យផ្នែកចិត្តវិទ្យារបស់អាមេរិកដែល ទទួលខុសត្រូវលើការរៀបចំDSMថ្មីជឿជាក់ថាការផ្លាស់ប្តូរនូវលក្ខណៈសម្រាប់ការធ្វើរោគវិនិច្ឆ័យ ផ្តល់នូវមធ្យោបាយមួយដែលកាន់តែត្រឹមត្រូវ និងមានប្រយោជន៍សម្រាប់ការវិនិច្ឆ័យរោគរបស់មនុស្សដែល មានបញ្ហាទាក់ទងនឹងអូទីសឹម។

ស្ថិតក្រោមDSM-IVកន្លងមក មនុស្សអាចទទួលបានការធ្វើរោគវិនិច្ឆ័យមួយក្នុងចំណោមចំនួន ៤ដាច់ពីគ្នា៖

- អូទីសឹម
- បញ្ហារបស់ប្រភេទអូទីសឹមកម្រិតស្រាល(Asperger)
- បញ្ហានៃភាពចុះខ្សោយក្នុងវ័យកុមារភាព(childhood disintegrative disorder)

- បញ្ហានៃការលូតលាស់ទូទៅ តែមិនជាក់លាក់(Pervasive developmental disorder not otherwise specified [PDD-NOS])

យោងតាមការស្រាវជ្រាវ ក្រុមគ្រូពេទ្យផ្នែកពិនិត្យព្យាបាលពុំបានអនុវត្តតាមការធ្វើរោគវិនិច្ឆ័យទាំងនេះឱ្យ មានភាពស៊ីសង្វាក់គ្នានៅក្នុងកម្មវិធីពិនិត្យ និងព្យាបាលរបស់ខ្លួនទេ។ DSM-V ដកចេញនូវបញ្ហាទាំង៤នេះឱ្យនៅ ក្រោមលក្ខខណ្ឌដាច់ដោយឡែកពីគ្នា ហើយដាក់ពួកវានៅក្រោមចង្កោមASD។

ទោះបីជាបញ្ហានៃការលូតលាស់ទូទៅទាំង៤នេះហាក់ដូចជាស្ថិតនៅក្រោមបណ្តុំអូទីសឹមក៏ដោយ ក៏នរណា ម្នាក់ដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យពីមុនមកដោយប្រើប្រាស់វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រទាំងនេះ ត្រូវបន្តឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់ ADS នៅក្នុង DSM-Vដដែល។

## ៣.៣.១.និយមន័យៈ

ពាក្យ ASD សំដៅលើបញ្ហាជាច្រើនដែលគេចាត់ចំណាត់ថ្នាក់ជាបញ្ហានៃការលូតលាស់ទូទៅ(PDD)នៅក្នុង DSM-V។ និយមន័យរបស់ASDត្រូវបានគេកែសម្រួលដើម្បីឆ្លុះបញ្ចាំងទៅនឹងការរីកចម្រើនសំខាន់ៗនៅ ក្នុងការស្រាវជ្រាវចាប់តាំងពីលក្ខណៈវិនិច្ឆ័យរបស់DSM-IVត្រូវបានគេបោះពុម្ពផ្សាយនៅក្នុងឆ្នាំ1994។ អូទីសឹមតំណាងឱ្យចំណុចស្នូលរបស់ASD។ បើយោងតាមគេហទំព័រនិយាយពីអូទីសឹម(Autism ) អូទីសឹមត្រូវបានគេកំណត់តាមរយៈ «ការលំបាកជាប់ជាប្រចាំក្នុងការប្រាស្រ័យទាក់ទងផ្នែកសង្គម និង អន្តរកម្មក្នុងសង្គមក្នុងបរិបទជាច្រើន»។ បុគ្គលអូទីសឹមម្នាក់ៗបង្ហាញនូវការលំបាកដូចខាងក្រោមៈ

- ការលំបាកផ្នែកទំនាក់ទំនងសង្គម និងអារម្មណ៍ដែលមានចាប់ផ្តើមពីវិធីសាស្ត្រក្នុងផ្នែកទំនាក់ទំនងសង្គមដែលខុស ធម្មតា និងការខកខានក្នុងការចូលរួមក្នុងការសន្ទនាគ្នាទៅវិញទៅមករហូតដល់ការចុះថយនូវការ ចែករំលែកនូវការចាប់អារម្មណ៍ និងទឹកចិត្ត ក៏ដូចជាការខកខានក្នុងការឆ្លើយតបទៅនឹង សញ្ញា និងអន្តរកម្មសង្គម។
- ពិបាកក្នុងការប្រើប្រាស់ និងយល់ពីការប្រាស្រ័យទាក់ទងដោយកាយវិការដែលគេប្រើប្រាស់នៅ ក្នុងការទំនាក់ទំនង(អន្តរកម្ម)សង្គម ដូចជាពុំមានលទ្ធភាពធ្វើការទាក់ទងដោយប្រើក្រសែភ្នែក និងភាពខុសប្រក្រតីចំពោះភាសាកាយវិការ។ កុមារទាំងនេះក៏មានការលំបាកក្នុងការយល់ពីការ ប្រើប្រាស់កាយវិការ ហើយតាមធម្មតាមានការខ្វះខាតទាំងស្រុងចំពោះការសម្តែង(បង្ហាញ)ទឹក មុខ។
- ពិបាកក្នុងការបង្កើត និងរក្សាទំនាក់ទំនងសង្គម។

បុគ្គលម្នាក់ៗដែលមានជំងឺអូទីសឹមក៏បង្ហាញឱ្យឃើញនូវទម្រង់នៃអាកប្បកិរិយា ចំណាប់អារម្មណ៍ និង សកម្មភាពដដែលៗ និងមានដែនកំណត់ដែរ ដូចជា៖

- ការធ្វើសកម្មភាពដដែលៗ ឬប្រើប្រាស់វត្ថុ ឬនិយាយពាក្យដដែលៗ
- ចចេសដោយធ្វើកិច្ចការដដែលជាប្រចាំដោយពុំមានការបត់បែន បង្ហាញនូវទម្រង់នៃអាកប្បកិរិយា ដែលធ្វើតាមទម្លាប់ ឬអាកប្បកិរិយាដែលមិនមានការនិយាយស្តី។
- ការចាប់អារម្មណ៍មានកម្រិត(restricted) ធ្វើដដែលៗ(fixated)
- ឆាប់រំភើបខ្លាំង ឬមិនរំភើបទាល់តែសោះទៅនឹងការប្រែប្រួលបរិស្ថានជុំវិញដូចជា កំដៅ ពន្លឺ សំឡេង និងចំណីអាហារ(textured) ។

ចំណុចទាំងអស់នេះបង្ហាញឱ្យឃើញនូវលក្ខណៈទូទៅរបស់រោគសញ្ញាASD។ រោគសញ្ញាអាចមានចាប់ពី កម្រិតស្រាលរហូតដល់កម្រិតធ្ងន់ធ្ងរទៅតាមបណ្តុំអូទីសឹម។ ភាពធ្ងន់ធ្ងរតម្រូវឱ្យមានការធ្វើអន្តរាគមន៍ និង ការព្យាបាលទៅតាមដំបូន្មានរបស់គ្រូពេទ្យ។

ភាពខុសប្រក្រតីរបស់រោគសញ្ញាអូទីសឹមកម្រិតស្រាល(Asperger)មានទំនាក់ទនងយ៉ាងជិតស្និតទៅនឹង អូទីសឹមធម្មតានៅពេលវាក្លាយទៅជារោគសញ្ញា(symptom) និងជាមូលហេតុ។ អ្នកជំងឺអូទីសឹមប្រភេទ នេះ ដែលកាលពីមុនគេហៅថារោគសញ្ញាអូទីសឹមកម្រិតស្រាល ពុំមានភាពយឺតយ៉ាវគួរឱ្យកត់សម្គាល់ ចំពោះការអភិវឌ្ឍផ្នែកភាសាដូចអ្នកដែលមានជំងឺអូទីសឹមក្នុងកម្រិតធ្ងន់ធ្ងរនោះទេ។

អ្នកទាំងឡាយណាដែលមានស្ថានភាពចុះខ្សោយបញ្ញាក្នុងវ័យកុមារភាពប៉ុន្តែមានការលូតលាស់ធម្មតា ហើយបង្ហាញនូវបំណិនក្នុងការប្រាស្រ័យទាក់ទងជាពាក្យសម្តី ឬ កាយវិការសមស្របតាមកម្រិតអាយុ ក៏ដូចជាបំណិតផ្នែកចលនា ផ្នែកសង្គម និងការថែរក្សាខ្លួនឯង សមស្របដែរ។ ក្នុងចន្លោះអាយុពី2-10ឆ្នាំ អ្នកដែលមានជំងឺអូទីសឹមប្រភេទនេះ បាត់បង់បំណិនស្ទើរតែទាំងស្រុងទាក់ទងនឹងការលូតលាស់យ៉ាងហោចណាស់ក៏2ផ្នែកដែរ។

កុមារដែលមានជំងឺអូទីសឹមដែលពីមុនគេហៅថាPDD-NOSមានការលំបាកធ្ងន់ធ្ងរ ជាទូទៅទាក់ ទងនឹងអន្តរកម្មក្នុងសង្គមទៅវិញទៅមក ឬបំណិនក្នុងការប្រាស្រ័យទាក់ទងជាពាក្យសម្តី និងកាយវិការ ហើយបង្ហាញឱ្យឃើញនូវអាកប្បកិរិយាបែបបុរេនិច្ឆ័យទាក់ទងនឹងអូទីសឹម ប៉ុន្តែមិនត្រូវនឹងលក្ខណៈវិនិច្ឆ័យចំពោះបញ្ហានៃការលូតលាស់ទាំងមូលជាក់លាក់ទេ។

## ៣.៣.២.មូលហេតុរបស់ ASD៖

អ្នកជំនាញពុំមានការយល់ដឹងច្បាស់លាស់ទេពីមូលហេតុផ្សេងៗរបស់ASD ប៉ុន្តែអ្នកវិទ្យាសាស្ត្រជឿជាក់ថា ហ្សែន និងបរិស្ថានដើរតួនាទីដ៏សំខាន់មួយ។ ការសិក្សាស្រាវជ្រាវនានាបានរក

ឃើញនូវហ្សែនមួយចំនួន ដែលទាក់ទងនឹងASD ហើយបានរកឃើញនូវភាពខុសគ្នានានានៅក្នុងរចនាសម្ព័ន្ធខួរក្បាលរបស់អ្នកដែល មានបញ្ហា។ ការសិក្សាមួយចំនួនលើកឡើងថា បុគ្គលនានាដែលមាន ASDមានកម្រិតសារធាតុគីមីដែល បញ្ជូនរំញោចសរសៃប្រសាទពីកោសិកាសរសៃប្រសាទមួយទៅមួយ(neurotransmitter) សារធាតុម្យ៉ាង ដែលបញ្ចេញប្លាកែតនៅពេលជាលិកាមានរបួស (serotonin)មិនគ្រប់គ្រាន់នៅក្នុងខួរក្បាលទេ។ ភាពខុស ប្រក្រតីទាំងនេះអាចកើតមានឡើងដោយសារមានការបន្ទុចបង្អាក់ការលូតលាស់របស់ខួរក្បាល តាមធម្មតា ក្នុងរយៈពេលដ៏សំខាន់មួយនៃការលូតលាស់របស់ទារកក្នុងផ្ទៃ។ នៅពេលដែលការរកឃើញទាំងនេះមាន លក្ខណៈគួរឱ្យចាប់អារម្មណ៍ អ្នកវិទ្យាសាស្ត្រនៅមានពេលវេលាវែងឆ្ងាយទៅទៀតមុនពេលដែលពួកគេ អាចចង្អុលបង្ហាញពីមូលហេតុជាក់លាក់នានារបស់ ASD។

### ៣.៣.៣.សញ្ញាសម្គាល់ផ្សេងៗរបស់ ASD៖

សញ្ញាសម្គាល់ផ្សេងៗរបស់ASDមានភាពខុសគ្នាទៅតាមបុគ្គលម្នាក់ៗ ហើយភាពធ្ងន់ធ្ងររបស់វាក៏ដូច្នេះ ដែរ។ ចំណុចនេះអាចធ្វើឱ្យមានសញ្ញាសម្គាល់ផ្សេងៗវិវឌ្ឍន៍ទៅមុខដោយគ្មានការចាប់អារម្មណ៍ ជា ពិសេសចំពោះកុមារដែលមានជំងឺអូទីសឹមក្នុងកម្រិតស្រាល។ ក្នុងករណីមួយចំនួន វាមានសារៈសំខាន់ ណាស់ក្នុងការកត់សម្គាល់ថា រោគសញ្ញាផ្សេងៗអាចចុះខ្សោយទៅតាមពេលវេលា ប៉ុន្តែការសិក្សានានា បង្ហាញថាជាង 70% របស់មនុស្សពេញវ័យដែលមានជំងឺអូទីសឹមគឺនៅតែពឹងផ្អែកទៅលើគ្រួសាររបស់គេ និងត្រូវការជំនួយក្នុងការបំពេញកិច្ចការក្នុងជីវិតប្រចាំថ្ងៃជាមូលដ្ឋាន។ វាមានសារៈសំខាន់ណាស់ដែល មនុស្សពេញវ័យទាំងនេះបន្តទទួលជំនួយដែលមានគុណភាព និងការគាំទ្រពីគ្រួសារ។ កាលណាបុគ្គល ម្នាក់ទទួលបានការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវតាំងពីដំបូង លទ្ធផលក្នុងពេលអនាគតរបស់គេកាន់តែប្រសើរ។ ប្រសិនបើកុមារម្នាក់បង្ហាញថាមានសញ្ញាសម្គាល់ណាមួយដូចខាងក្រោម កុមារនោះអាចមាន ជំងឺអូទីសឹម៖

- ពុំមានការស្រែក ឬ«និយាយដូចក្មេងធម្មតា»នៅត្រឹមអាយុ12ខែ
- ពុំអាចនិយាយបានមួយម៉ាត់នៅអាយុ16ខែ ឬឃ្លាដែលមាន2ពាក្យនៅអាយុនៅ24ខែ
- មិនឆ្លើយតបទៅនឹងការហៅឈ្មោះនៅអាយុ1ឆ្នាំ
- ការបាត់បង់យ៉ាងឆាប់រហ័សនូវភាសាដែលទទួលបាន ឬបំណិនផ្នែកសង្គម
- មានទំនាក់ទំនងដោយប្រើក្រសែភ្នែកខ្សោយ
- តម្រៀបជាជួរ ឬរៀបចំរបស់ក្មេងលេង ឬវត្ថុផ្សេងទៀតច្រើនហួសហេតុ។
- មិនញញឹមតបវិញទេនៅពេលដែលគេញញឹមដាក់
- សមត្ថភាពថយចុះក្នុងការអាប់អាន និងរក្សាមិត្តភាព
- ពិបាកក្នុងការសន្ទនាធម្មតាជាមួយអ្នកផ្សេងទៀត

- ពុំចេះលេងតាមរបៀបធ្វើពុត(ធ្វើត្រាប់) និងការលេងរបៀបស្រមើស្រមៃទាក់ទងនឹងសង្គមទេ (ឧទាហរណ៍ ការលេងធ្វើជាផ្ទះ ធ្វើជាវេជ្ជបណ្ឌិត)
- ប្រើប្រាស់ភាសាដដែលៗ ឬខុសពីធម្មតា
- មានទម្រង់នៃការចាប់អារម្មណ៍តិចចំពោះអ្វីមួយដែលធំទូលាយ (Narrow patterns of interest that are excessive)
- ផ្តោតអារម្មណ៍តែរឿងអ្វីមួយឬវត្ថុជាក់លាក់ច្រើនហួសហេតុ
- រឹងរូសហួសហេតុពេកក្នុងការផ្លាស់ប្តូរនូវកិច្ចការប្រចាំថ្ងៃ ។

ក្រុមគ្រូពេទ្យទូទៅ(physician) និងគ្រូពេទ្យផ្នែកព្យាបាល(clinician)នឹងប្រើប្រាស់បញ្ជីសំណួរមួយ ឬ ឧបករណ៍ផ្សេងទៀតដើម្បីប្រមូលព័ត៌មានពីទម្រង់នៃការលូតលាស់ និងអាកប្បកិរិយារបស់កុមារ។

### ៣.៣.៤.ការវាយតម្លៃពី ASD៖

គ្រូពេទ្យផ្នែកព្យាបាលដូចជាចិត្តវិទូ ឬគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្តនឹងធ្វើការវាយតម្លៃពីកុមារម្នាក់ដែល មានជំងឺអូទីសឹមដើម្បីកំណត់ថាតើកុមារនោះបង្ហាញរោគសញ្ញាASD ឬអ្វីផ្សេងទៀត។ DSN-5ទាមទាររោគសញ្ញាផ្សេងៗកើតមានតាំងពីក្នុងវ័យកុមារភាពដំបូងម្ល៉េះទោះបីគេមិនអាចកត់សម្គាល់ឃើញវាហូត ទាល់តែពេលក្រោយមកទៀតក៏ដោយ។

ដើម្បីទទួលបានការធ្វើរោគវិនិច្ឆ័យមួយពីASD បុគ្គលនានាត្រូវតែមានលក្ខណៈឆ្លើយតបទៅនឹងលក្ខខណ្ឌ ទាំងអស់ក្នុងចំណោមលក្ខណៈវិនិច្ឆ័យខាងក្រោមដែលលំបាកក្នុងការប្រាស្រ័យទាក់ទង និងអន្តរកម្មក្នុងសង្គមទៅតាមបរិយាកាសផ្សេងៗ៖

- ពិបាកចូលរួមក្នុងអន្តរកម្មសង្គម ឬការរំជួលចិត្តផ្នែកសង្គម៖ បុគ្គលម្នាក់នឹងមានបញ្ហាផ្សេងៗក្នុង ការបង្កើត និងរក្សាការទាក់ទងគ្នាទៅវិញទៅមកតាមធម្មតាដែលគេតម្រូវឱ្យមានក្នុងការសន្ទនាគ្នា ទៅវិញទៅមកជាមួយអ្នកផ្សេងទៀត។
- ការលំបាកជាប់ជាប្រចាំក្នុងទំនាក់ទំនងក្នុងសង្គម៖ កុមារមិនមានការចាប់អារម្មណ៍ណាមួយចំពោះអ្នកផ្សេងទេ ហើយមិនមានសមត្ថភាព លេងល្បែងរបៀបធ្វើពុត(ធ្វើត្រាប់តាម)អ្វីមួយ និងសកម្មភាពដែលស្របនឹងអាយុត្រឹម ត្រូវផ្សេងទៀតដែរ។ កុមារពុំមានលទ្ធភាពក្នុងការសម្របខ្លួនទៅតាមការផ្លាស់ប្តូរផ្សេងៗ ទៅតាមបរិបទ និងតម្រូវការសង្គមដែរ។
- លំបាកក្នុងការទំនាក់ទំនងដោយប្រើភាសាកាយវិការ៖ កុមារអាចមានបញ្ហាក្នុងការបង្កើត និងរក្សា ទំនាក់ទំនងដោយប្រើក្រសែភ្នែក ពុំយល់ ឬឆ្លើយតបទៅនឹងភាសា កាយវិការបានទេដូចជារបៀបឈរ អង្គុយ ការសម្តែងទឹកមុខ ការលើកដាក់សំឡេង និងសញ្ញាផ្សេងៗទៀត។

បុគ្គលនានាត្រូវតែមានលក្ខណៈវិនិច្ឆ័យទៅនឹងរោគសញ្ញាចំនួន២ ក្នុងចំណោមរោគសញ្ញាចំនួន ៤ ដែលទាក់ទងនឹងចំណុចខាងក្រោម ៖

- ការនិយាយស្ដី ចលនារាងកាយ ឬការប្រើប្រាស់វត្ថុផ្សេងៗដដែលៗ (ពោលគឺ តម្រៀបវត្ថុក្មេងលេងជាជួរ)
- ពិបាកផ្លាស់ប្ដូរ អាកប្បកិរិយា ពាក្យសំដី និងកាយវិការ ហើយមានភាពចចេស និងសកម្មភាពប្រចាំថ្ងៃដដែលៗ។
- មានការផ្ដោតអារម្មណ៍ខ្លាំងទៅលើអ្វីមួយ
- មានការរំជួលចិត្តខ្លាំងពេក ឬតិចពេកទៅនឹងបរិស្ថានជុំវិញ (ពោលគឺ ការប្រែប្រួលអាកាសធាតុ អាហារ[textured] សំឡេង)។

**ការធ្វើរោគវិនិច្ឆ័យ** ASD៖

ការវាយតម្លៃពីជំងឺអូទីសឹមតម្រូវឱ្យមានកិច្ចសហការរបស់អ្នកមានវិជ្ជាជីវៈជា ច្រើន៖ អ្នកចិត្តវិទ្យា គ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត គ្រូពេទ្យផ្នែកសរសៃប្រសាទ អ្នកឯកទេសព្យាបាល ការបញ្ចេញសំឡេង និងអ្នកផ្សេងៗទៀត។ អ្នកមានវិជ្ជាជីវៈទាំងនោះនឹងត្រួតពិនិត្យមើលប្រព័ន្ធប្រសាទ យ៉ាងល្អិតល្អន់ ក៏ដូចជាការធ្វើតេស្តមើលពីបញ្ញា និងភាសាដែរ។ ពួកគេរកឃើញនូវភាពធ្ងន់ធ្ងររបស់ជំងឺអូទីសឹមដែលនឹងអនុញ្ញាតឱ្យពួកគាត់រៀបចំផែនការសម្រាប់ព្យាបាល និងអន្តរាគមន៍មួយប្រកបដោយប្រសិទ្ធភាពដោយផ្អែកលើតម្រូវការជាលក្ខណៈបុគ្គលរបស់កុមារម្នាក់ៗ។

**៣.៣.៥.ការព្យាបាល** ASD៖

ខណៈដែលពុំមានការព្យាបាលASDឱ្យជាសះស្បើយ(cure)បាន មានវិធីព្យាបាល(treatment) និងការ ធ្វើអន្តរាគមន៍ផ្សេងៗដែលអាចកាត់បន្ថយរោគសញ្ញាជាក់លាក់ និងនាំទៅរកការរីកចម្រើន។ គ្រូ ពេទ្យផ្នែកព្យាបាលនឹងរៀបចំផែនការមួយសម្រាប់ព្យាបាល និងអន្តរាគមន៍ដោយផ្អែកលើតម្រូវការជា លក្ខណៈបុគ្គលរបស់កុមារ និងភាពធ្ងន់ធ្ងររបស់ASD។ ការព្យាបាល និងអន្តរាគមន៍អាចរួមមាន៖

- អន្តរាគមន៍ផ្នែកអប់រំ និងអាកប្បកិរិយា
- ការប្រើប្រាស់ថ្នាំ (ព្យាបាលការព្រួយបារម្ភ ការបាក់ទឹកចិត្ត បញ្ហាផ្នែកខួរក្បាល ដែលធ្វើឱ្យមនុស្សម្នាក់ធ្វើរឿងដដែលៗ[obsessive-compulsive disborder (OCD)] និងរោគ សញ្ញាផ្សេងៗទៀតដែលទាក់ទងនឹងជំងឺអូទីសឹម)
- អន្តរាគមន៍ទាក់ទងនឹងការព្យាបាលផ្សេងៗទៀត ។

# មេរៀនទី៤
# ពិការដោនស៊ីនដ្រូម និង ពិការចលករខួរក្បាល

## វត្ថុបំណង៖

ដើម្បីយល់ដឹង និងសិក្សពីនិយមន័យ លក្ខណៈមូលហេតុរបស់ដោនស៊ីនដ្រូម និងពិការចលករខួរក្បាល។

## ៤.១.ដោនស៊ីនដ្រូម

### ៤.១-១.និយមន័យ៖

ដោនស៊ីនដ្រូម គឺជាបញ្ហាមួយរបស់ហ្សែនដែលកើតឡើងនៅពេលដែលមានការបែងចែកកោសិកាខុសប្រក្រតី ដែលបណ្តាលឱ្យមានការចម្លងក្រូម៉ូសូម ២១ ពេញលេញឬមួយចំណែក។ អង្គធាតុរបស់ហ្សែន លើសនេះធ្វើឱ្យមានការផ្លាស់ប្តូរការលូតលាស់ និងលក្ខណៈផ្នែករាងកាយរបស់ ដោនស៊ីនដ្រូម ។

ខ្លួនប្រាណរបស់យើងកកើតឡើងពីកោសិការាប់លាន។ នៅក្នុងកោសិកានីមួយៗមានក្រូម៉ូសូមចំនួន៤៦។DNAនៅក្នុងក្រូម៉ូសូមរបស់យើងកំណត់ពីរបៀបដែលយើងលូតលាស់។ ដោនស៊ីនដ្រូមកើតឡើងនៅពេលដែលមាន ក្រូម៉ូសូមលើសមួយ។ អ្នកដែលមានពិការដោនស៊ីនដ្រូម មានក្រូម៉ូសូមចំនួន ៤៧ ក្នុងកោសិកានានារបស់ពួកគេ ជំនួសឱ្យការមានក្រូម៉ូសូមចំនួន៤៦។ ពួកគេមានក្រូម៉ូសូម២១លើសចំនួន១ ដែលនេះជាមូលហេតុដែលពេលខ្លះគេស្គាល់ដោនស៊ីនដ្រូម ថាជា trisomy 21 (លក្ខណៈដែលអ្នកជំងឺមានក្រូម៉ូសូមចំនួន៣ជំនួសឱ្យ១គូ)ដែរ។

ទោះបីជាយើងដឹងពីរបៀបដែលដោនស៊ីនដ្រូម កើតឡើងក៏ដោយ យើងនៅតែមិនទាន់ដឹងនៅឡើយថាហេតុអ្វី បានជាវាកើតឡើង។ ដោនស៊ីនដ្រូម កើតឡើងតាំងពីពេលចាប់កំណើត កើតឡើងនៅគ្រប់ជាតិសាសន៍ និងក្រុមសង្គមទាំងអស់និងចំពោះឪពុកម្តាយគ្រប់វ័យ។ វាមិនមែនជាកំហុសរបស់នរណាម្នាក់ទេ។ ពុំមានការព្យាបាល ណាឱ្យជាសះស្បើយឡើយ ហើយវាក៏មិនបាត់ទៅណាដែរ។

ដោនស៊ីនដ្រូម មានលក្ខណៈខុសគ្នាទាក់ទងនឹងភាពធ្ងន់ធ្ងរក្នុងចំណោមបុគ្គលនានាដែលបណ្តាលឱ្យមានពិការ ភាពខ្សោយសតិបញ្ញា និងភាពយឺតយ៉ាវក្នុងការលូតលាស់ពេញមួយជីវិត។ វាគឺជាបញ្ហាផ្នែកក្រូម៉ូសូមរបស់ហ្សែនទូទៅបំផុត និងជាដើមហេតុនៃ ការខ្សោយ បញ្ញាសម្រាប់កុមារ។ ជាទូទៅវាក៏បណ្តាលឱ្យមានភាពខុស ប្រក្រតីផ្នែកវេជ្ជសាស្ត្រផងដែរ ដោយរាប់បញ្ចូលទាំងបញ្ហារបស់បេះដូង និងក្រពះពោះវៀន(gastrointestinal)ផងដែរ។

ការយល់ដឹងកាន់តែប្រសើរពីដោនស៊ីនដ្រូម និងការធ្វើអន្តរាគមន៍ពីដំបូងអាចបង្កើនគុណភាពជីវិតរបស់កុមារ និងមនុស្សពេញវ័យដែលមានបញ្ហានេះបានយ៉ាងច្រើន និងជួយពួកគេឱ្យរស់នៅក្នុងជីវិតប្រកបដោយភាពពេញចិត្ត។

## ៤.១.២.រោគសញ្ញា៖

ពិការដោនស៊ីនដ្រូម គឺជាបញ្ហាផ្នែកសតិបញ្ញានិងការលូតលាស់របស់ពួកគេអាចមានកម្រិតស្រាល មធ្យម ឬធ្ងន់ធ្ងរ។ មនុស្សមួយចំនួនមានសុខភាពល្អខណៈដែលអ្នកផ្សេងទៀតមានបញ្ហា សុខភាពគួរឱ្យកត់ សម្គាល់ ដូចជាជំងឺខ្សោយបេះដូងធ្ងន់ធ្ងរ។

កុមារ និងមនុស្សពេញវ័យដែលមានពិការដោនស៊ីនដ្រូម មានលក្ខណៈទម្រង់មុខខុសៗគ្នា។ ទោះបីជាមនុស្សទាំងអស់ដែលមានពិការដោនស៊ីនដ្រូម ពុំមានលក្ខណៈដូចគ្នាក៏ដោយក្នុង ចំណោមលក្ខណៈជាច្រើនរួមមាន៖

- មុខរាបស្មើ
- ក្បាលតូច
- កខ្លី
- អណ្តាតលៀន
- ត្របកភ្នែកខើចឡើងលើ (ដំបៅប្រេះត្របកភ្នែក)
- ត្រចៀកមានរូបរាងខុស ធម្មតា ឬតូច
- សាច់ដុំខ្សោយ
- ដៃខ្លី ធំដោយមានគន្លាក់តែមួយគត់នៅលើប្រអប់ដៃ
- ម្រាមដៃខ្លីហើយមានដៃ និងជើងតូចៗ
- មានភាពបត់បែនច្រើនហួសប្រមាណ
- កន្ទួលពណ៌សតូចៗនៅក្នុងភ្នែក (ប្រស្រីភ្នែក)ដែលគេហៅថាកន្ទួល
- កម្ពស់ទាប

ទារកដែលមានពិការដោនស៊ីនដ្រូម អាចមានទំហំខ្លួនធំមធ្យមប៉ុន្តែជាទូទៅពួកគេធំលូតលាស់យឺត ហើយនៅ តែមាន កម្ពស់ទាបជាងកុមារដទៃទៀតដែលមានអាយុដំណាលគ្នា។

## ការខ្សោយបញ្ញា៖

កុមារភាគច្រើនដែលមានពិការដោនស៊ីនដ្រូម មានការលំបាកផ្នែកបញ្ញាពីកម្រិតទាបទៅមធ្យម។ការលូតលាស់ ផ្នែកភាសាមានភាពយឺតយ៉ាវ ហើយការចងចាំទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែងត្រូវទទួលរងផលប៉ះពាល់។

## ពេលដែលត្រូវទៅជួបគ្រូពេទ្យ៖

កុមារដែលមានពិការដោនស៊ីនដ្រូម ជាទូទៅត្រូវបានគេធ្វើរោគវិនិច្ឆ័យនៅមុនឬក្រោយពេលសម្រាល។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើមានសំណួរណាមួយទាក់ទងនឹងការមានផ្ទៃពោះ ឬការលូតលាស់ និងវិវឌ្ឍន៍របស់កូនលោកឬលោកស្រី សូមអញ្ជើញទៅពិភាក្សាជាមួយគ្រូពេទ្យរបស់យើង។

## ៤.១.៣.ដើមហេតុ ហ្សែនរបស់ពិការដោនស៊ីនដ្រូម៖

កោសិការបស់មនុស្សជាទូទៅមានក្រូម៉ូសូមចំនួន ២៣គូ។ ក្រូម៉ូសូមមួយក្នុងក្រូម៉ូសូមមួយគូៗគឺមួយបាន មកពីឪពុកនិងមួយទៀតបានមកពីម្ដាយ។

ដោនស៊ីនដ្រូម គឺជាលទ្ធផលនានានៅពេលដែលការបែងចែកកោសិកាខុសប្រក្រតីដែលទាក់ទងនឹងក្រូម៉ូសូម២១ កើតឡើង។ភាពមិនប្រក្រតីនៃការបែងចែកកោសិកាទាំងនេះបណ្ដាលឱ្យក្រូម៉ូសូម២១មានចំនួនលើសមួយ។ អង្គធាតុរបស់ហ្សែនដែលលើសនេះគឺជាអ្នកបង្កឱ្យមានទ្រង់ទ្រាយ និងលក្ខណៈ នៃការលូតលាស់របស់ដោនស៊ីនដ្រូម។ការប្រែប្រួលណាមួយក្នុងចំណោមនៃការប្រែប្រួលរបស់ហ្សែន ទាំងបីអាចបណ្ដាលឱ្យពិការដោនស៊ីនដ្រូម៖

- ទ្រីសូមី ទី២១ - ប្រហែលជា៩៥%នៃពិការដោនស៊ីនដ្រូម គឺបណ្ដាលមកពី trisomy 21 ពោលគឺមនុស្សម្នាក់មានការចម្លង ក្រូម៉ូសូម២១ចំនួន៣ជំនួសឱ្យការចម្លងក្រូម៉ូសូមជាទូទៅដែលមានចំនួន២នៅគ្រប់កោសិកាទាំងអស់។ចំណុចនេះគឺបណ្ដាលមកពីការបែងចែកកោសិកាខុសប្រក្រតី ក្នុងអំឡុងពេលនៃការលូតលាស់ កោសិកាមេជីវិតឬកោសិកាស៊ុត(egg cell)។
- ដោនស៊ីនដ្រូម ដែលកើតចេញពីការផ្គុំគ្នារបស់កោសិកាតូច (Mosaic Down syndrome) - នៅក្នុងទម្រង់ដ៏កម្ររបស់ដោនស៊ីនដ្រូម ប្រភេទនេះមនុស្សម្នាក់មានកោសិកាមួយចំនួនប៉ុណ្ណោះ ដែលមានការចម្លងក្រូម៉ូសូម២១លើសចំនួន១។កោសិកាតូចៗដែលផ្គុំគ្នា (mosaic) ធម្មតា និងខុសប្រក្រតី នេះគឺបណ្ដាលមកពីការបែងចែកកោសិកាខុសប្រក្រតីបន្ទាប់ពីការបង្កកំណើត(ការរួមបញ្ចូលគ្នារវាងអូវ៉ុល និងស្ពែម៉ាតូសូអ៊ីត)។
- ដោនស៊ីនដ្រូម ដែលកើតចេញពីការបំលែងក្រូម៉ូសូម(translocation) -ដោនស៊ីនដ្រូម ក៏អាចកើត មានដែរនៅពេលដែលផ្នែកមួយរបស់ក្រូម៉ូសូមទី២១បានតភ្ជាប់(បំប្លែងក្រូម៉ូសូម) ជាមួយក្រូម៉ូសូមមួយផ្សេងទៀតមុនពេលឬក្នុងពេលបង្កកំណើត។កុមារទាំងនេះមានការចម្លង

ក្រូម៉ូសូមទី២១ធម្មតាចំនួន២ ប៉ុន្តែពួកគេក៏មានអង្គធាតុហ្សែនបន្ថែមពីក្រូម៉ូសូមទី២១ ដែលតភ្ជាប់ជាមួយក្រូម៉ូសូមមួយផ្សេងទៀតដែរ។

ពុំមានការយល់ដឹងពីកត្តាផ្នែក អាកប្បកិរិយា ឬបរិស្ថានដែលបណ្តាលឱ្យមាន ដោនស៊ីនដ្រូម ទេ។

## តើវាជាតំណពូជឬ?

ភាគច្រើននៃពិការដោនស៊ីនដ្រូម មិនមែនជាជំងឺតពូជទេ។ វាកើតឡើងដោយសារកំហុសក្នុងការបែងចែកកោសិកាក្នុងអំឡុងពេលនៃការលូតលាស់ដំបូងរបស់ទារកក្នុងផ្ទៃ។

ដោនស៊ីនដ្រូមដែលកើតចេញពីការបំលែងក្រូម៉ូសូមអាចចម្លងពីឪពុកឬម្តាយទៅកូន។ ទោះជាយ៉ាងណា ក៏ដោយមានកុមារប្រហែល៣% ទៅ ៤%ដែលមានពិការដោនស៊ីនដ្រូម មានការ បំលែងក្រូម៉ូសូមហើយមានតែ មួយចំនួនប៉ុណ្ណោះក្នុងចំណោមពួកគេដែលឆ្លងពីឪពុក ឬម្តាយរបស់ពួកគេ។

នៅពេលដែលការ បំលែងក្រូម៉ូសូមដែលមានតុល្យភាពចម្លងរួចហើយ ឪពុកឬម្តាយ មាន អង្គធាតុហ្សែនដែលមានការរៀបចំឡើងវិញមួយចំនួនដែលបានមកពីក្រូម៉ូសូម២១នៅលើក្រូម៉ូសូមមួយផ្សេងទៀត ប៉ុន្តែមិនមានអង្គជាតិហ្សែនលើសទេ។ ចំណុចនេះមានន័យថា ពួកគាត់មិនមានសញ្ញា ឬរោគសញ្ញាដោនស៊ីនដ្រូមទេ ប៉ុន្តែអាចចម្លងការ បំប្លែងក្រូម៉ូស្សូមដែលពុំមានតុល្យភាពទៅឱ្យកូនបានដែលធ្វើឱ្យកូនកើតជំងឺដោនស៊ីនដ្រូម ។

## ៤.១.៤.កត្តាប្រឈម

ឪពុកម្តាយមួយចំនួនមានហានិភ័យខ្ពស់ក្នុងការមានកូនដែលកើតពិការដោនស៊ីនដ្រូម ។ កត្តាហានិភ័យរួមមាន៖

- អាយុម្តាយកាន់តែចាស់ -ឱកាសរបស់ស្ត្រីក្នុងការផ្តល់កំណើតដល់កូនដែលមានពិការដោនស៊ីនដ្រូម ដោយសារមានអាយុកាន់តែច្រើន ពីព្រោះអូវុលដែលកាន់តែចាស់មានហានិភ័យកាន់តែខ្ពស់មួយចំពោះ ការបែងចែកក្រូម៉ូសូមមិនត្រឹមត្រូវ។ ហានិភ័យរបស់ស្ត្រីចំពោះការពពោះកូនដែលមានពិការដោនស៊ីនដ្រូម មានការកើនឡើងបន្ទាប់ពីស្ត្រីមានអាយុ ៣៥ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយកុមារភាគច្រើន ដែលមានពិការដោនស៊ីនដ្រូម កើតពីម្តាយដែលមានអាយុក្រោម ៣៥ ឆ្នាំដោយសារតែស្ត្រី វ័យក្មេងមានកូនច្រើន ។
- អ្នកផ្ទុកនូវការបំលែងហ្សែនដែលនាំឱ្យកើតដោនស៊ីនដ្រូម -ទាំងបុរសនិងស្ត្រីអាច ចម្លងការ បំលែងហ្សែនដែលបង្កឱ្យមានដោនស៊ីនដ្រូម ទៅឱ្យកូនរបស់ខ្លួនបាន។
- កូនម្នាក់ដែលមានដោនស៊ីនដ្រូម ឪពុកម្តាយដែលមានកូនមួយមានដោនស៊ីនដ្រូម និងឪពុកម្តាយដែលមាន ការបំលែង ក្រូម៉ូសូមដោយខ្លួនឯងគឺមានហានិភ័យដែលការកើនឡើង ខ្ពស់

ចំពោះការមានកូនម្នាក់ទៀតដែលមានដោនស៊ីនដ្រូម ។ អ្នកប្រឹក្សាយោបល់ផ្នែកហ្សែនអាចជួយឪពុកម្តាយក្នុងការវាយតម្លៃហានិភ័យនៃការមានកូនទី២ ដែលមានដោនស៊ីនដ្រូមបាន។

## ផលវិបាកៈ

អ្នកដែលមានពិការដោនស៊ីនដ្រូម អាចមានផលវិបាកជាច្រើនដែលផលវិបាកមួយចំនួនក្នុងចំណោមផលវិបាក ទាំងនោះកើតមានឡើងកាន់តែច្បាស់នៅពេលដែលពួកគេមានអាយុកាន់តែច្រើន។ ផលវិបាកទាំងនេះរួមមានៈ

- ជំងឺបេះដូងៈកុមារប្រមាណជាពាក់កណ្តាលដែលមានពិការដោនស៊ីនដ្រូម កើតមកដោយមានប្រភេទជំងឺបេះដូងពីកំណើតមួយចំនួន។ បញ្ហាបេះដូងទាំងនេះអាចមានការគំរាមកំហែងដល់អាយុ ជីវិតហើយអាចតម្រូវឱ្យមានការវះកាត់ភ្លាមៗតាំងតែពីវ័យទារក។
- ជំងឺក្រពះ&ពោះវៀន (GI) - ភាពខុសប្រក្រតីរបស់ GI កើតមានចំពោះកុមារមួយចំនួនដែលមានពិការដោនស៊ីនដ្រូម ហើយអាចរាប់បញ្ចូលទាំងភាពខុសប្រក្រតីរបស់ពោះវៀន បំពង់អាហារ បំពង់ខ្យល់ និងទ្វារលាមក។ ហានិភ័យនៃការវិវត្តបញ្ហាផ្នែករំលាយអាហារដូចជាការស្ទះGI ធ្លល់ ក្តៅចុងដង្ហើម (ការប្រាលរសក្រពះឬឧស្ម័នពីក្រពះមកតាមបំពង់អាហារ [gastroesophageal reflux]) ឬជំងឺទាក់ទងនឹងការរំលាយអាហារ(celiac disease)អាចកើនឡើង។
- បញ្ហាចុះខ្សោយរបស់ភាពស៊ាំ(immune disorders) ដោយសារភាពខុសប្រក្រតីនៃប្រព័ន្ធភាព ស៊ាំរបស់ពួកគេអ្នកដែលមានពិការដោនស៊ីនដ្រូម មានហានិភ័យកើនឡើងចំពោះបញ្ហានៃការលូតលាស់ភាពស៊ាំជាស្វ័យប្រវត្តិ(autoimmunity) ទម្រង់មួយចំនួននៃជំងឺមហារីកនិងជំងឺឆ្លង ផ្សេងៗដូចជាជំងឺរលាកសួតជាដើម។
- ការបាត់ដង្ហើមនៅពេលដេក (sleep apnea) - ដោយសារតែជាលិកាលោង(ភ្នាសស្តើងៗ) និងការផ្លាស់ប្តូរ គ្រោងឆ្អឹងដែលនាំឱ្យស្ទះផ្លូវដង្ហើមរបស់ពួកគេកុមារនិងមនុស្សពេញវ័យដែលមានពិការដោនស៊ីនដ្រូម មានហានិភ័យខ្ពស់នៃការបាត់ដង្ហើម(ដោយស្ទះ)នៅពេលគេង។
- ភាពជាត់ខ្លាំង(obesity) - អ្នកដែលមានពិការដោនស៊ីនដ្រូម មាន ទំនោរទៅរកការជាត់លើសទម្ងន់ខ្លាំងបើប្រៀបធៀបទៅនឹងមនុស្សទូទៅ។
- បញ្ហាឆ្អឹងខ្នង មនុស្សមួយចំនួនដែលមានពិការដោនស៊ីនដ្រូម អាចមានឆ្អឹងកងកចំនួន២ នៅផ្នែកខាងលើមិនរត់ត្រង់ជួរគ្នា(ជ្រួសគ្នា)[មានភាពមិនរឹងមាំនៃឆ្អឹងកងក(atlantoaxial instability)]។ លក្ខខណ្ឌ នេះធ្វើឱ្យពួកគេស្ថិតក្នុងហានិភ័យនៃការរងរបួសធ្ងន់ធ្ងរដល់ខួរឆ្អឹងខ្នង(spinal cord)ដោយសារកវែងពេក (overexte-nsion of the neck)។
- រោគមហារីកឈាម កុមារតូចៗដែលមានពិការដោនស៊ីនដ្រូម មានហានិភ័យកើនឡើងចំពោះការកើត ជំងឺមហារីកឈាម។

- ជំងឺវង្វេងស្មារតី(dementia) អ្នកដែលមានពិការដោនស៊ីនដ្រូម មានហានិភ័យខ្ពស់ក្នុងការកើតជំងឺ វង្វេងស្មារតី ពោលគឺជាសញ្ញានិងរោគសញ្ញាដែលអាចចាប់ផ្តើមនៅជុំវិញអាយុ ៥០ ឆ្នាំ។ការមានពិការដោនស៊ីនដ្រូម ក៏បង្កើនហានិភ័យនៃការវិវត្តរបស់ជំងឺវង្វេងវង្វាន់នៅពេលចាស់(Alzheimer's)ផងដែរ។
- បញ្ហាផ្សេងៗទៀតដោនស៊ីនដ្រូម អាចមានការជាប់ទាក់ទងផងដែរជាមួយនឹងស្ថានភាពសុខភាពផ្សេង ទៀតដែលរួមមានបញ្ហាក្រពេញបញ្ចេញអ័រម៉ូន(endocrine)បញ្ហាធ្មេញ ការប្រកាច់[seizure] ជំងឺ ឆ្លងទៅត្រចៀក ព្រមទាំងបញ្ហាសោតវិញ្ញាណ និងចក្ខុវិញ្ញាណ។

ចំពោះអ្នកដែលមានពិការដោនស៊ីនដ្រូម ការទទួលបានការថែទាំសុខភាពជាទៀងទាត់និងការព្យាបាលបញ្ហាផ្សេងៗនៅពេលដែលចាំបាច់អាចជួយថែរក្សាបាននូវរបៀបរស់នៅមួយប្រកបដោយសុខភាពល្អ។

**អាយុកាលមធ្យម** (life expectancy)៖

អាយុកាលនៃការរស់នៅ បានកើនឡើងយ៉ាងខ្លាំងចំពោះអ្នកដែលមានពិការដោនស៊ីនដ្រូម ។ បច្ចុប្បន្ននេះអ្នកដែលមានពិការដោនស៊ីនដ្រូម អាចរំពឹងថានឹងរស់នៅរហូតដល់អាយុជាង៦០ឆ្នាំ អាស្រ័យលើភាពរឹងមាំនៃបញ្ហាសុខភាព។

## ការធ្វើរោគវិនិច្ឆ័យ៖

មហាវិទ្យាល័យសម្ភព និងរោគស្ត្រីរបស់អាមេរិកផ្តល់អនុសាសន៍ចំពោះការផ្តល់ឱ្យនូវជម្រើសនៃការធ្វើតេស្តដើម្បី ពិនិត្យមើល និងការធ្វើតេស្តពីរោគវិនិច្ឆ័យចំពោះពិការដោនស៊ីនដ្រូម ដល់ស្ត្រីដែលមានផ្ទៃពោះទាំងអស់ ដោយមិនគិតពីអាយុ។

- ការធ្វើតេស្តពិនិត្យមើលអាចបង្ហាញពីលទ្ធភាព ឬឱកាសនានាដែលថាម្តាយម្នាក់កំពុងពពោះកូនដែលមានពិការដោនស៊ីនដ្រូម។ ប៉ុន្តែការធ្វើតេស្តទាំងនេះមិនអាចប្រាប់ឱ្យប្រាកដឬធ្វើរោគវិនិច្ឆ័យឃើញថាទារកមានពិការដោនស៊ីនដ្រូម ឬអត់ទេ។
- ការធ្វើតេស្តរោគវិនិច្ឆ័យអាចកំណត់ឬធ្វើរោគវិនិច្ឆ័យលើទារកដែលមានពិការដោនស៊ីនដ្រូម ដែរឬអត់។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចពិភាក្សាពីប្រភេទនៃការធ្វើតេស្ត វិជ្ជមាននិង អវិជ្ជមាន ផលប្រយោជន៍ និងហានិភ័យ ព្រមទាំងអត្ថន័យនៃលទ្ធផលរបស់អ្នកបាន។ ប្រសិនបើសមស្រប អ្នកផ្តល់សេវារបស់អ្នកអាចផ្តល់អនុសាសន៍ឱ្យអ្នកពិភាក្សាជាមួយអ្នកប្រឹក្សាយោបល់ពីហ្សែនបាន។

## ៤.១.៥.ការធ្វើតេស្តដើម្បីពិនិត្យ មើលក្នុងពេលកំពុងមានផ្ទៃពោះ

ការពិនិត្យមើលពីពិការដោនស៊ីនដ្រូម ត្រូវបានគេផ្តល់ឱ្យជាផ្នែកមួយនៃការថែទាំគភ៌មុនពេលសម្រាល ជាប្រចាំ។ ទោះបីជាការធ្វើតេស្ត ដើម្បីពិនិត្យមើលអាចកំណត់ពីហានិភ័យរបស់អ្នកតែប៉ុណ្ណោះចំពោះការពរពោះកូនដែលមានពិការដោនស៊ីនដ្រូម ក៏ដោយ ក៏ការធ្វើតេស្តនេះអាចជួយអ្នកឱ្យធ្វើការ សម្រេចចិត្តអំពីការធ្វើតេស្ត រោគវិនិច្ឆ័យជាក់លាក់ច្រើនថែមទៀត។

ការធ្វើតេស្តដើម្បីពិនិត្យផ្សេងៗរួមមានការធ្វើតេស្តរួមគ្នានៅក្នុងរយៈពេល៣ខែដំបូង និងការធ្វើតេស្តដើម្បីពិនិត្យបែបសមាហរណកម្ម ។

**ការធ្វើតេស្តរួមគ្នាក្នុងរយៈពេល៣ខែ ដំបូង៖**

ការធ្វើតេស្តរួមគ្នាក្នុងរយៈពេល ៣ខែ ដំបូង ដែលគេធ្វើឡើងជា ២ ជំហានរួមមាន៖

- តេស្តឈាម ការធ្វើតេស្តឈាមនេះវាស់ពីកម្រិតនៃប្រូតេអ៊ីនPAPP-A របស់ប្លាស្មាដែលទាក់ទងនឹង ការមានផ្ទៃ ពោះPAPP-A( Pregnancy-associated plasma protein-A ) និងអ័រម៉ូននៃការមានផ្ទៃពោះដែលគេស្គាល់ថា ជាអ័រម៉ូនដែលក្មោចក្រពេញគេទពេលពេញវ័យនៃភ្នាសរបស់មនុស្ស (human chorionic gonadotropin [HCG])។ កម្រិតនៃភាពខុសប្រក្រតីរបស់ PAPP-A និងHCG អាចបង្ហាញពីបញ្ហាមួយរបស់ទារក។
- ការធ្វើតេស្តមើលពីកំហាប់ ខួរកញ្ចឹងក( Nuchaltranslucency test)ក្នុងកំឡុងពេល ធ្វើតេស្តរបៀបនេះការពិនិត្យដោយការស្តាប់ សំឡេងចលនារបស់សរីរាង្គនៅក្នុងខ្លួន( ultrasound )ត្រូវបានគេប្រើដើម្បីវាស់ពីផ្នែកជាក់លាក់នៃ ករបស់កូនអ្នកពីខាងក្រោយ។ ការធ្វើដូចនេះត្រូវបានគេស្គាល់ថាជា ការធ្វើតេស្តដើម្បី ពិនិត្យមើលពីកំហាប់ខួរកញ្ចឹងក។ នៅពេលបង្ហាញវត្តមាននៃភាពមិនប្រក្រតី សារធាតុរាវច្រើនជាងធម្មតាទំនងជាប្រមូលផ្តុំគ្នាបានក្នុងជាលិកាកនេះ។

ដោយប្រើអាយុរបស់អ្នក ព្រមទាំងលទ្ធផលនៃការធ្វើតេស្តឈាម និងultrasound គ្រូពេទ្យ ឬអ្នកប្រឹក្សាយោបល់ ផ្នែកហ្សែនរបស់អ្នកអាចវាយតម្លៃបានពីហានិភ័យរបស់អ្នកចំពោះការមានកូនដែលមានពិការដោនស៊ីនដ្រូម ។

**ការធ្វើតេស្តរួមគ្នា៖**

ការធ្វើតេស្តរួមគ្នាត្រូវបានធ្វើឡើងជា២ផ្នែកក្នុងរយៈពេល៣ខែដំបូង និងក្នុងរយៈពេល៣ខែលើកទី២នៃ ការមានផ្ទៃពោះ។ លទ្ធផលនានាត្រូវបានគេរួមបញ្ចូលគ្នា ដើម្បីប៉ាន់ស្មាន ពីហានិភ័យដែលទារករបស់អ្នកមានពិការដោនស៊ីនដ្រូម ។

- រយៈពេល៣ខែដំបូង៖ ផ្នែកទីមួយរួមមានការធ្វើតេស្តឈាមដើម្បីវាស់ពី PAPP-A និង ultrasoundដើម្បីវាស់ ពី កំហាប់ខួរកញ្ចឹងក។

- រយៈពេល៣ខែទី២៖ ការពិនិត្យឈាមរបស់ម្តាយ(quad screen)វាស់ពីកម្រិតឈាមរបស់អ្នកទៅលើ សារជាតុចំនួន ៤ ដែលទាក់ទងនឹងការមានផ្ទៃពោះ៖ ប្រូតេអ៊ីនម្យ៉ាងដែលគេរកឃើញក្នុងទឹកដោះ(alpha fetoprotein), estriol, HCG និង inhibin A. ។

## ៤.១.៦.ការធ្វើតេស្តរោគវិនិច្ឆ័យក្នុងពេលមានផ្ទៃពោះ៖

ប្រសិនបើលទ្ធផលតេស្តដើម្បីពិនិត្យមើលរបស់អ្នកមានភាពវិជ្ជមាន ឬបង្កឱ្យមានការព្រួយបារម្ភ ឬអ្នកមានហានិភ័យខ្ពស់ក្នុងការមានកូនដែលមានពិការដោនស៊ីនដ្រូម អ្នកអាចពិចារណាពីការធ្វើតេស្តបន្ថែមទៀតដើម្បីបញ្ជាក់ពីរោគវិនិច្ឆ័យ។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចជួយអ្នកឱ្យថ្លឹងថ្លែងពីគុណសម្បត្តិ និងគុណវិបត្តិ នៃការធ្វើតេស្តទាំងនេះ។ការធ្វើតេស្តរោគវិនិច្ឆ័យដែលអាចកំណត់ពីពិការដោនស៊ីនដ្រូមបានរួមមាន៖

- ការធ្វើសំណាកសរសៃឆ្មារក្នុងសុក[Chorionic villus sampling (CVS)]-នៅក្នុងការធ្វើCVS គេយកកោសិកា ផ្សេងៗចេញពីសុកហើយគេប្រើវាដើម្បីវិភាគក្រូម៉ូសូមរបស់គភ៌។ តាមធម្មតាគេធ្វើតេស្តរបៀបនេះនៅ ក្នុងរយៈពេល ៣ ខែដំបូង ពោល គឺរវាងសប្តាហ៍ទី ១០ និងទី ១៣ នៃការមានផ្ទៃពោះ។ ហានិភ័យនៃ ការបាត់បង់ការមានផ្ទៃពោះ(រលូតកូន) ដោយសារ CVS មាន កម្រិតទាប បំផុត។
- ការបោះភ្នាសទឹកភ្លោះក្នុងអំឡុងពេលមានផ្ទៃពោះដោយប្រើម្ជុលឬសឺរ៉ាំង(Amniocentesis) - សំណាកមួយរបស់ទឹកភ្លោះដែលនៅព័ទ្ធជុំវិញទារកត្រូវបានបូមយកដោយប្រើម្ជុលដែលគេស៊កចូលទៅក្នុងស្បូនរបស់ម្តាយ។ បន្ទាប់មកគេប្រើសំណាកនេះដើម្បីវិភាគក្រូម៉ូសូមរបស់គភ៌។ តាមធម្មតាវេជ្ជបណ្ឌិតធ្វើតេស្តនេះនៅក្នុងអំឡុងពេល៣ខែទី២ បន្ទាប់ពីការមានផ្ទៃពោះបានរយៈពេល១៥សប្តាហ៍។ ការធ្វើតេស្ត នេះក៏មានហានិភ័យនៃការរលូតកូនទាបដែរ។

ការធ្វើរោគវិនិច្ឆ័យទៅលើហ្សែនមុនពេលផ្សាំ (preimplantation) គឺជាជម្រើសមួយសម្រាប់ដៃគូដែលកំពុងធ្វើការបង្កកំណើតនៅក្រៅស្បូន(in vitro fertilization)ដែលមានហានិភ័យខ្ពស់ក្នុងការចម្លងលក្ខខណ្ឌរបស់ ហ្សែនដាក់លាក់។ អំប្រ៊ីយ៉ុង(ទារកដែលទើបចាប់កំណើត)ត្រូវបានគេធ្វើតេស្តរកមើលភាពខុសប្រក្រតីរបស់ហ្សែន មុនពេលគេផ្សាំនៅក្នុងស្បូន។

## ៤.១.៧.តេស្តរោគវិនិច្ឆ័យចំពោះទារកទើបនឹងកើត៖

បន្ទាប់ពីសម្រាលរួច ការវិភាគរោគសញ្ញាដំបូងដើម្បីមើលពីជំងឺDown syndrome ជាទូទៅមានមូលដ្ឋានលើការពិនិត្យមើលរូបរាងកាយរបស់ទារក។ ប៉ុន្តែគេអាចរកឃើញលក្ខណៈពិសេសដែលទាក់ទងនឹងដោនស៊ីនដ្រូម ក្នុងចំណោមទារកដែលមិនមានពិការដោនស៊ីនដ្រូមដែរ។ ដូច្នេះអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចទំនងសុំឱ្យមានការធ្វើតេស្តមួយដែលគេហៅថាkaryotypក្រូម៉ូសូមដើម្បីបញ្ជាក់ពីរោគវិនិច្ឆ័យ។ដោយប្រើសំណាកឈាម ការធ្វើតេស្តនេះវិភាគលើក្រូម៉ូសូមរបស់កូនអ្នក។ ប្រសិនបើមានក្រូម៉ូសូមទី២១លើសនៅគ្រប់ ឬនៅក្នុងកោសិកាមួយចំនួនក្តី រោគសញ្ញាគឺជាពិការដោនស៊ីនដ្រូមហើយ។

## ៤.១.៨.ការព្យាបាល៖

អន្តរាគមន៍ពីដំបូងសម្រាប់ទារក និងកុមារដែលមានពិការដោនស៊ីនដ្រូម អាចធ្វើឱ្យមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងក្នុងការកែលម្អគុណភាពជីវិតរបស់ពួកគេ។ដោយសារកុមារម្នាក់ៗដែលមានពិការដោនស៊ីនដ្រូម មានលក្ខណៈពិសេសដាច់ដោយឡែកមួយ ការព្យាបាលត្រូវពឹងផ្អែកលើតម្រូវការរបស់បុគ្គលម្នាក់ៗ។ ម្យ៉ាងទៀត ដំណាក់កាលផ្សេងៗនៅក្នុងជីវិតក៏អាចត្រូវការសេវាកម្មផ្សេងៗគ្នាដែរ។

### ការថែទាំរបស់ក្រុមការងារ៖

ប្រសិនបើកូនរបស់លោកអ្នកមានពិការដោនស៊ីនដ្រូម ត្រូវពឹងផ្អែកលើក្រុមការងារ របស់អ្នកឯកទេសដែលអាចផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រ និងជួយកូនរបស់លោកអ្នកឱ្យអភិវឌ្ឍនូវបំណិននានាឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។ ដោយផ្អែកលើតំរូវការជាក់លាក់របស់កូនក្រុមរបស់អ្នកអាចបញ្ចូលរួមគ្នានូវជំនាញដូចខាងក្រោម៖

- គ្រូពេទ្យឯកទេសផ្នែកកុមារទទួលបន្ទុកការថែទាំបឋមដើម្បីសម្របសម្រួល និងផ្តល់ការថែទាំកុមារប្រចាំថ្ងៃ
- គ្រូពេទ្យឯកទេសបេះដូងរបស់កុមារ
- គ្រូពេទ្យឯកទេសក្រពះពោះវៀនរបស់កុមារ
- គ្រូពេទ្យឯកទេសខាងអ័រម៉ូនរបស់កុមារ
- គ្រូពេទ្យឯកទេសផ្នែកការលូតលាស់របស់កុមារ
- គ្រូពេទ្យឯកទេសខាងប្រសាទសាស្ត្ររបស់កុមារ
- គ្រូពេទ្យឯកទេសផ្នែកត្រចៀកច្រមុះ និងបំពង់ក (ENT) របស់កុមារ
- គ្រូពេទ្យភ្នែករបស់កុមារ (គ្រូពេទ្យឯកទេសខាងភ្នែក)
- អ្នកជំនាញខាងសោតទស្សន៍

- អ្នកជំនាញផ្នែកបញ្ចេញសំឡេង
- អ្នកព្យាបាលដោយចលនា
- អ្នកព្យាបាលដោយឱ្យអ្នកជំងឺធ្វើសកម្មភាពការងារប្រចាំថ្ងៃផ្សេងៗ

លោកអ្នកចាំបាច់ត្រូវធ្វើការសម្រេចចិត្តសំខាន់ៗពីការព្យាបាល និងការអប់រំកូន។ រៀបចំក្រុមការងាររបស់អ្នកផ្តល់សេវាថែទាំសុខភាព គ្រូបង្រៀន និងអ្នកព្យាបាលដែលទុកចិត្ត។អ្នក មានវិជ្ជាជីវៈទាំងនេះអាចជួយវាយតម្លៃធនធាននៅក្នុងតំបន់ និងពន្យល់ពីកម្មវិធីរបស់រដ្ឋនិងសហព័ន្ធសម្រាប់កុមារនិងមនុស្សពេញវ័យដែលមានពិការភាព។

# ៤.២.ពិការចលករខួរក្បាល

## ៤.២.១.និយមន័យ៖

ពិការចលករខួរក្បាលសំដៅទៅលើបណ្តុំបញ្ហានៃបញ្ហាប្រព័ន្ធប្រសាទដែលកើតឡើង លើទារកឬកុមារតូចៗហើយប៉ះពាល់ជាអចិន្ត្រៃយ៍ទៅលើចលនារបស់រាងកាយហើយពិការភាពចលករខួរក្បាល(CP)ដែលសម្រួលចលនាសាច់ដុំបង្កឡើងដោយសារការខូចខាត ឬភាពខុសប្រក្រតីនៅក្នុងខួរក្បាលដែលកំពុងលូតលាស់រំខានដល់សមត្ថភាពខួរក្បាលក្នុងការគ្រប់គ្រងចលនា និងក្នុងការរក្សានូវឥរិយាបថ និងតុល្យភាព។ ខួរក្បាលសំដៅទៅលើសំណុំខួរក្បាល ពាក្យថាស្ពឹកមានន័យថាការបាត់បង់ឬការលំបាកផ្នែកមុខងារនៃចលនា( motor function )។ជំងឺពិការចលករខួរក្បាលប៉ះពាល់ដល់តំបន់នៃចលនា( motor area )នៃស្រទាប់ខាងក្រៅរបស់ខួរក្បាល( ដែលគេហៅថាស្រទាប់ខាងក្រៅរបស់ខួរក្បាល[cerebral cortex] ) ជាផ្នែកមួយរបស់ខួរក្បាលដែលបញ្ជាចលនាសាច់ដុំ។

ក្នុងករណីមួយចំនួនផ្នែកខួរក្បាលដែលគ្រប់គ្រងផ្នែកចលនាពុំមានការលូតលាស់ជាប្រក្រតីទេក្នុងកំឡុងពេលនៃការលូតលាស់របស់គភ៌។ ចំណែកករណីផ្សេងទៀត ការខូចខាតនេះគឺជាផលវិបាកនៃការរងរបួសដល់ខួរក្បាលនៅមុនពេល អំឡុងពេល ឬក្រោយ ពេលសម្រាល។ ទោះក្នុងករណីណាក៏ដោយការខូចខាតនេះមិនអាចព្យាបាល បានទេករណីទាំងនេះនឹងមានជារៀងរហូត។

## ៤.២.២ លក្ខណៈ:

កុមារដែលមានពិការចលករខួរក្បាលបង្ហាញឱ្យឃើញតាមរយៈរោគសញ្ញាខុសៗគ្នាយ៉ាងច្រើនដែលរួមមាន៖

- ខ្វះការ សម្របសម្រួលផ្នែកចលនាសាច់ដុំនៅពេលធ្វើចលនាដោយមានឆន្ទៈ ( ឈ្មោះប្រភេទនៃចលនា[ataxia] )

- សាច់ដុំរឹងឬតឹង និងមានរ៉េផ្លិចខ្លាំងពេក ឬលើស (សាច់ដុំកន្ត្រាក់រឹង)
- ភាពទន់ខ្សោយនៅដៃ ឬជើងមួយចំហៀង ឬទាំងពីរ
- ដើរដោយប្រើម្រាមជើង ដើរឱនៗ (ទ្រឹមទ្រោមៗ) ឬដើររបៀបខ្វែងជើងគ្នាដូចកន្ត្រៃ
- ការប្រែប្រួលនៅក្នុង តូនីសសាច់ដុំ ទាំងរឹងពេកឬ ទន់ពេក
- ហៀរទឹកមាត់ច្រើន ពិបាកលេប ឬនិយាយ
- ចលនាញ័រញ្ញួយញ៉ឹកញាប់ ឬម្តងម្កាល
- យឺតយ៉ាង ក្នុងការបញ្ជាចលនា
- លំបាកក្នុងការធ្វើ ចលនា ជាក់លាក់ដូចជាការសរសេរ ឬបិទឡេវអាវ។

រោគសញ្ញារបស់ពិការចលករខួរក្បាល មានភាពខុសគ្នាទៅតាមប្រភេទ និងភាពធ្ងន់ធ្ងរ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ហើយអាចផ្លាស់ប្តូរបុគ្គលម្នាក់ៗតាមពេលវេលា។ រោគសញ្ញាអាចប្រែប្រួលយ៉ាងខ្លាំងក្នុងចំណោមបុគ្គលម្នាក់ៗ ដោយអាស្រ័យទៅលើកម្រិតរបួសផ្នែកណាមួយនៃខួរក្បាល។ មនុស្សទាំងអស់ដែលមានជំងឺពិការចលករខួរក្បាលមានបញ្ហាទាក់ទងនឹងការធ្វើចលនា និងកាយវិការ ហើយពួកគេខ្លះក៏មានកម្រិត ខ្សោយសតិបញ្ញា ជំងឺប្រកាច់ ព្រមទាំងកាយវិញ្ញាណ និងញាណដែលខុសប្រក្រតី ក៏ដូចជាភាពខុសប្រក្រតីផ្នែកសុខភាព(medical disorders)មួយចំនួនដែរ។ អ្នកពិការចលករខួរក្បាលក៏អាចមានការលំបាកក្នុងការមើល ឬការស្តាប់ ព្រមទាំងភាសា និងបញ្ហានិយាយដែរ។

ពិការចលករខួរក្បាលគឺជាមូលហេតុចម្បងដែលធ្វើឱ្យកុមារមានពិការភាព ប៉ុន្តែវាមិនបណ្តាលឱ្យមានពិការភាពយ៉ាងជ្រាលជ្រៅធ្ងន់ធ្ងរជានិច្ចនោះទេខណៈដែលកុមារម្នាក់ដែលមានជំងឺCPធ្ងន់ធ្ងរមិនអាចដើរបាន និងត្រូវការថែរក្សាយ៉ាងជិតដល់ពេញមួយជីវិត ចំណែកកុមារម្នាក់ទៀតដែលមានCP កម្រិតស្រាល អាចមានការលំបាកតិចតួច ហើយមិនត្រូវការជំនួយពិសេសទេ។ បញ្ហានេះមិនមានការវិវឌ្ឍន៍ទៅ មុខ មានន័យថាវានឹងមិនមានសភាពធ្ងន់ធ្ងរទៅៗតាមពេលវេលាទេ។ ទោះជាយ៉ាងណាក៏ដោយនៅពេលដែលកុមារមានអាយុកាន់តែច្រើន រោគសញ្ញាជាក់លាក់មួយចំនួនអាចលេចជារូបរាងកាន់តែច្បាស់ ឬកាន់តែចុះខ្សោយ។ ការសិក្សាមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលសម្រាប់គ្រប់គ្រងនិងទប់ស្កាត់ជំងឺបានបង្ហាញថាអត្រាទូទៅ(ប្រេវ៉ាឡង់)នៃជំងឺពិការចលករខួរក្បាលមាន៣,៣នាក់ក្នុងចំណោមទារក ១.០០០នាក់ដែលបានកើតមក។

មិនមានការព្យាបាលឱ្យជាសះស្បើយសម្រាប់ជំងឺពិការចលករខួរក្បាលទេ ប៉ុន្តែការព្យាបាលដោយការគាំទ្រ ការប្រើប្រាស់ថ្នាំ និងការវះកាត់អាចជួយអ្នកជំងឺជាច្រើនឱ្យបង្កើននូវបំណិនចលនា និងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងជាមួយពិភពលោកនេះបាន។

## ៤.២.៣.សញ្ញាដំបូង៖

ជាទូទៅរោគសញ្ញារបស់ជំងឺពិការចលករខួរក្បាលលេចឡើងនៅរយៈពេលប៉ុន្មានខែដំបូងនៃជីវិតទោះបីជាការធ្វើរោគវិនិច្ឆ័យជាក់លាក់អាចត្រូវបានគេពន្យារពេលរហូតដល់អាយុ២ឆ្នាំ ឬបន្ទាប់ពីនោះក៏ដោយ។ ទារកដែលមានពិការចលករខួរក្បាល ជារឿយៗមានភាពយឺតយ៉ាវក្នុងការលូតលាស់តាមរយៈនេះ ពួកគេមានភាពយឺតយ៉ាវក្នុងការសម្រេចបាន នូវដំណាក់កាលនៃការលូតលាស់ ដូចជាការរៀនក្រឡាប់ អង្គុយ វារ ឬដើរ។ ទារកមួយចំនួនដែលមានពិការចលករខួរក្បាលមានកម្លាំងកន្ត្រាក់របស់សាច់ដុំខុសប្រក្រតី។ កម្លាំងកន្ត្រាក់របស់សាច់ដុំចុះខ្សោយ(ការថយចុះនូវភាពរឹងមាំនៅផ្នែកណាមួយនៃរាងកាយ[hypotonia])អាចធ្វើឱ្យពួកគេមើល ទៅហាក់ដូចជាទន់ជ្រាយ។ កម្លាំងកន្ត្រាក់របស់សាច់ដុំឡើងខ្លាំង(ភាពរឹងកើនឡើងហើយមានការកន្ត្រាក់សាច់ដុំ[hypertonia])អាចធ្វើឱ្យពួកគេហាក់ដូចជាឡើងរឹងឬមិនអាចកម្រើកបាន។ ក្នុងករណីមួយចំនួន ដំណាក់កាលដំបូងរបស់hypotonia នឹងវិវត្តទៅជាhypertoniaបន្ទាប់ពីរយៈ ពេល ២ខែ ទៅ ៣ខែដំបូងនៃជីវិត។ កុមារដែលមាន ពិការចលករខួរក្បាលមានឥរិយាបថខុសធម្មតា ឬចូលចិត្តប្រើតែចំហៀងណាមួយនៃដងខ្លួននៅពេលពួកគេឈោង វារ ឬផ្លាស់ទី។ វាមានសារៈសំខាន់ណាស់ក្នុងការកត់សម្គាល់កុមារមួយចំនួនដែលមិនមានពិការចលករខួរក្បាលក៏អាចមានសញ្ញាមួយចំនួនក្នុងចំណោមសញ្ញាទាំងនេះដែរ។

**សញ្ញាព្រមានខ្លះៗ៖**

ក្នុងវ័យជាទារកដែលមានអាយុតិចជាង ៦ ខែ៖

- ក្បាលរបស់គេកម្រើកយឺតៗនៅពេលដែលលើកគេឡើងខណៈដែលកំពុងដេកផ្ងារ
- គាត់មានរាងកាយឡើងរឹង(feel stiff)
- គាត់មានរាងកាយឡើងទន់ (feel floppy)
- នៅពេលលើកឡើងជើងរបស់គាត់រឹង ហើយដាក់ខ្វែងគ្នា ឬដាក់ដូចកន្ត្រៃ

ក្នុងវ័យទារកដែលមានអាយុលើសពី ៦ ខែ៖

- គេមិនក្រឡាប់ទេ ទោះទៅខាងណាក៏ដោយ
- គេមិនអាចយកដៃរបស់ខ្លួនមកដាក់ផ្គុំគ្នាបានទេ
- គេមានការលំបាកក្នុងការដាក់ដៃរបស់គេនៅក្នុងមាត់
- គេឈោងចាប់យកអ្វីមួយតែដៃម្ខាងប៉ុណ្ណោះ ចំណែកឯដៃម្ខាងទៀតក្ដាប់ជាប់

ក្នុងវ័យទារកដែលមានអាយុលើសពី10ខែ៖

- វារឬលូនតែមួយចំហៀងខ្លួន ដោយរុញដៃនិងជើងរបស់គេតែម្ខាង ហើយអូសដៃនិងជើងម្ខាងទៀត
- គេមិនអាចឈរតោងអ្វីមួយបានទេ ។

## ៤.២.៤.មូលហេតុ៖

ពិការចលករខួរក្បាលគឺបណ្ដាលមកពីការលូតលាស់ខុសប្រក្រតី នៃផ្នែកណាមួយរបស់ខួរក្បាលឬដោយសារការខូចផ្នែកខ្លះនៃខួរក្បាលដែលគ្រប់គ្រងចលនា។ ការខូចខាតនេះអាចកើតឡើងនៅមុនពេល អំឡុងពេលឬ ក្រោយពេលសម្រាលភ្លាមៗ។ កុមារភាគច្រើនមានជំងឺពិការចលករខួរក្បាលពីកំណើត (ពោលគឺពួកគេកើត មកមានជំងឺនេះតែម្ដង) ទោះបីជាគេប្រហែលជាមិនអាចរកឃើញរហូតរយៈពេលប៉ុន្មានខែ ឬឆ្នាំក្រោយមកក៏ដោយ។ កុមារមួយចំនួនតូចកើតជំងឺពិការចលករខួរក្បាលដែលមានន័យថា ភាពខុសប្រក្រតីចាប់ផ្ដើមបន្ទាប់ពីប្រសូត្រហើយ។ មូលហេតុមួយចំនួននៃការកើតជំងឺពិការចលករខួរក្បាលរួមមាន ការខូចខួរក្បាលក្នុងរយៈពេល២ខែ ទៅ៣ខែ ឬ២ខែ ទៅ៣ឆ្នាំដំបូងនៃជីវិត ការឆ្លងមេរោគក្នុងខួរក្បាលដូចជា ជំងឺរលាកស្រោមខួរដោយសារបាក់តេរី ឬជំងឺរលាកខួរក្បាលដោយសារវីរុស បញ្ហាដោយសារការហូរឈាមទៅខួរក្បាល ឬការរងរបួសក្បាល ដោយសារការគ្រោះថ្នាក់ ដួលម៉ូតូ ធ្លាក់ ឬការរំលោភបំពានលើកុមារ។

ក្នុងករណីជាច្រើនមូលហេតុនៃជំងឺពិការចលករខួរក្បាលមិនត្រូវបានគេដឹងទេ។មូលហេតុដែលអាចបង្កឱ្យមានជំងឺ នេះរួមមាន ឧទាហរណ៍ភាពខុសប្រក្រតីរបស់ហ្សែន ការខូចរូបរាងរបស់ខួរក្បាលពីកំណើត ការឆ្លងមេរោគពីម្ដាយ ឬគ្រុនក្ដៅឬការរងរបួសរបស់ទារកក្នុងផ្ទៃជាដើម។ប្រភេទនៃការខូចខួរក្បាលដូចខាងក្រោមអាចបង្កឱ្យមានរោគសញ្ញាដែលបង្ហាញពីលក្ខណៈរបស់វា៖

ការខូចរូបធាតុពណ៌សរបស់ខួរក្បាល (periventricular leukomalacia ឬ PVL)៖រូបធាតុពណ៌សរបស់ខួរក្បាលគឺជាអ្នកទទួលខុសត្រូវសម្រាប់ការបញ្ជូនសញ្ញានៅក្នុងខួរក្បាល និងទៅផ្នែកផ្សេងៗទៀតនៃរាងកាយ។ការខូចខាត ដែលបណ្ដាលពី PVL មើលទៅដូចជារន្ធតូចៗនៅក្នុងរូបធាតុពណ៌សនៃខួរក្បាលរបស់ទារក។ ការខូះខាតជាលិកាទាំងនេះនៅក្នុងខួរក្បាលរំខានដល់ការបញ្ជូនសញ្ញាជាប្រក្រតី។ អ្នកស្រាវជ្រាវបានរកឃើញរយៈពេលនៃភាពងាយរងគ្រោះជាជម្រើសមួយ(selective vulnerability)ចំពោះការលូតលាស់ខួរក្បាលរបស់ទារកក្នុងផ្ទៃក្នុងចន្លោះពេល រវាង ២៦ និង ៣៤ សប្ដាហ៍នៃការមានគភ៌ ដែលក្នុងនោះអង្គធាតុពណ៌ស គឺងាយនឹងទទួលរងនូវការវាយប្រហារនិង របួសណាស់។

ការលូតលាស់ខុសប្រក្រតីរបស់ខួរក្បាល (ការលូតលាស់ខុសធម្មតា[dysgenesis]របស់ខួរក្បាល)៖ការរំខានណាមួយដល់ដំណើរការនៃការលូតលាស់ធម្មតារបស់ខួរក្បាលក្នុងអំឡុងពេលនៃការលូតលាស់របស់គត់អាចបណ្តាលឱ្យខូចរូបរាងខួរក្បាលដែលរារាំងដល់ការបញ្ជូនសញ្ញារបស់ខួរក្បាល។ការផ្លាស់ប្តូរហ្សែនដែលគ្រប់គ្រងការលូតលាស់ខួរក្បាលក្នុងរយៈពេលដំបូងអាចធ្វើឱ្យខួរក្បាលមិនរីកលូតលាស់តាមធម្មតា។ ការឆ្លងរោគ ជំងឺគ្រុនក្តៅ ការប៉ះទង្គិច ឬ លក្ខខណ្ឌដទៃទៀតដែលបង្កឱ្យស្ថានភាពសុខភាពចុះខ្សោយនៅក្នុងស្បូនក៏អាចធ្វើឱ្យប្រព័ន្ធសរសៃប្រសាទរបស់ទារកដែលមិនទាន់កើតស្ថិតក្នុងហានិភ័យដែរ។

ការហូរឈាមនៅក្នុងខួរក្បាល (ការហូរឈាមក្នុងលលាដ៍ក្បាល)៖ ការរហូរឈាមនៅក្នុងខួរក្បាលពីសរសៃឈាមដែលស្ទះឬខូច តាមធម្មតាត្រូវបានបង្កឡើងដោយជំងឺដាច់សរសៃឈាមក្នុងខួរក្បាលរបស់ទារកក្នុងផ្ទៃ។ ទារកខ្លះទទួលរងនូវជំងឺដាច់សរសៃឈាមក្នុងខួរក្បាលក្នុងពេលដែលគេស្ថិតនៅក្នុងស្បូនម្ល៉េះដោយសារតែការកកឈាមនៅក្នុងសុកដែលរាំងស្ទះលំហូររបស់ឈាមនៅក្នុងខួរក្បាល។ ប្រភេទផ្សេងទៀតនៃជំងឺដាច់សរសៃឈាមក្នុងខួរក្បាលរបស់ទារកក្នុងផ្ទៃ គឺបណ្តាលមកពីសរសៃឈាមក្នុងខួរក្បាលខុសទម្រង់ ឬខ្សោយឬដោយសារការកកឈាមខុសប្រក្រតី។ សម្ពាធឈាមឡើងខ្ពស់របស់ម្តាយ(ជំងឺលើសឈាម)គឺបញ្ហាផ្នែកសុខភាពទូទៅមួយក្នុងអំឡុងពេលមានផ្ទៃពោះហើយវាកាន់តែទូទៅថែមទៀតចំពោះទារកដែលមានជំងឺដាច់សរសៃឈាមក្នុងខួរក្បាលតាំងពីនៅក្នុងផ្ទៃ ។ ជំងឺឆ្លងរបស់ម្តាយជាពិសេសជំងឺរលាកផ្លឹងត្រគាកក៏បង្ហាញឱ្យឃើញនូវការកើនឡើងហានិភ័យនៃជំងឺដាច់សរសៃឈាមក្នុងខួរក្បាលរបស់ទារកក្នុងផ្ទៃដែរ។

ការខ្វះអុកស៊ីសែនធ្ងន់ធ្ងរនៅក្នុងខួរក្បាល៖ការថប់ដង្ហើម(Asphyxia) ការខ្វះខាតអុកស៊ីសែននៅក្នុងខួរក្បាលដែលបណ្តាលមកពីការរំខានដល់ការដកដង្ហើម ឬការផ្តល់អុកស៊ីសែនតិចតួចគឺជារឿងធម្មតាសម្រាប់រយៈពេលខ្លីរបស់ទារកដោយសារតែភាពតានតឹងក្នុងពេលឈឺពោះសម្រាល និងពេលសម្រាល។ ប្រសិនបើការផ្តល់អុកស៊ីសែនត្រូវកាត់ផ្តាច់ឬថយចុះសម្រាប់រយៈពេលវែងទារកអាចមានការវិវត្តនូវប្រភេទនៃការខូចខួរក្បាលមួយដែល គេហៅថា hypoxic-ischemic encephalopathy ដែលបំផ្លាញជាលិកានៅស្រទាប់ខាងក្រៅរបស់ខួរក្បាលដែលគ្រប់គ្រង ចលនានិងផ្នែកផ្សេងៗទៀតរបស់ខួរក្បាល។ ការបំផ្លាញប្រភេទនេះក៏អាចបណ្តាលមកពីសម្ពាធឈាមទាបក្នុងកម្រិតធ្ងន់ធ្ងររបស់ម្តាយ ការដាច់រហែកស្បូន ការដាច់សុកឬបញ្ហាទាក់ទងនឹងទងសុក(ផ្ចិត) ឬការប៉ះទង្គិចធ្ងន់ធ្ងរ ត្រង់ក្បាលក្នុងពេលឈឺពោះសម្រាល និងពេលសម្រាល។

## ៤.២.៥.កត្តាហានិភ័យ៖

មានស្ថានភាពសុខភាព ឬព្រឹត្តិការណ៍មួយចំនួនដែលអាចកើតមានឡើងក្នុងអំឡុងពេលមានផ្ទៃពោះនិងការសម្រាលកូនដែលអាចបង្កើនហានិភ័យរបស់ទារកដែលកើតមកមានជំងឺពិការចលករខួរក្បាល។ ហានិភ័យទាំងនេះរួមមាន៖

កូនកើតមកមានទម្ងន់តិចនិងកើតមិនគ្រប់ខែ៖ ទារកកើតមិនគ្រប់ខែ(កើតតិចជាងរយៈពេល ៣៧ សប្តាហ៍នៃការមានផ្ទៃពោះ) ហើយទារកដែលកើតមកមានទម្ងន់ តិចជាង៥.៥ផោនមានហានិភ័យក្នុងការវិវត្តទៅរកជំងឺពិការចលករខួរក្បាលខ្ពស់ជាងទារកដែលកើតគ្រប់ខែ និងមានទំងន់ធ្ងន់ជាង។ ទារកតូចៗដែលកើតមកមុនពេលកំណត់ លឿនពេកមានហានិភ័យជាពិសេស។

ការសម្រាលកូន ច្រើន៖ កូនភ្លោះ កូនកើតម្តង៣នាក់ និងកើតបានច្រើនជាងនេះមានហានិភ័យខ្ពស់ក្នុងការ កើតជំងឺពិការចលករខួរក្បាលទោះបីជាទារកកើតមកគ្រប់ខែក៏ដោយ។ការស្លាប់កូនម្នាក់ក្នុងចំណោមកូនភ្លោះ ឬកូនកើតម្តងបីនាក់កាន់តែមានហានិភ័យខ្ពស់ថែមទៀត។

ការឆ្លងជំងឺផ្សេងៗក្នុងពេលមានផ្ទៃពោះ៖ ការឆ្លងជំងឺផ្សេងដូចជា toxoplasmosis រោគកញ្ជ្រិលស្រាល វីរុសដែលអាចបង្កឱ្យមានភាពមិនប្រក្រតីពីកំណើតទារក(cytomegalovirus)និងជំងឺរើម (herpes) អាចឆ្លងទៅលើស្បូន និងសុក។ ការរលាកដែលបណ្តាលមកពីការឆ្លងមេរោគអាចបណ្តាលឱ្យខូច ប្រព័ន្ធសរសៃប្រសាទដែលកំពុងលូតលាស់របស់ទារកដែលមិនទាន់កើត។ ជំងឺគ្រុនក្តៅរបស់ម្តាយក្នុងពេលមាន ផ្ទៃពោះឬក្នុងពេលសម្រាលកូនអាចបណ្តាល ឱ្យមានការរលាកបែបនេះដែរ។

ប្រភេទឈាមមិនត្រូវគ្នារវាងម្តាយនិងកូន៖ ភាពមិនត្រូវគ្នារបស់ Rh គឺជាលក្ខខណ្ឌមួយដែលកើតមានឡើង នៅពេលដែលប្រភេទឈាម Rh មួយរបស់ម្តាយ (វិជ្ជមានក្តី ឬអវិជ្ជមានក្តី) ខុសពីប្រភេទឈាមទារករបស់ខ្លួន។ ប្រព័ន្ធរបស់ម្តាយមិនទទួលយកប្រភេទឈាមខុសគ្នារបស់ទារកហើយរាងកាយរបស់ម្តាយនឹងចាប់ផ្តើមបង្កើតអង្គបដិបក្ខដែលនឹងវាយប្រហារនិង សម្លាប់កោសិកាឈាមរបស់ទារកដែលអាចបណ្តាលឱ្យខូចខួរក្បាល។

ការប្រឈមនឹងសារជាតុពុលផ្សេងៗ៖ម្តាយដែលប្រឈមនឹងសារជាតុពុលផ្សេងៗក្នុងអំឡុងពេលមានផ្ទៃពោះដូចជាបារ៉ែតmethylមានហានិភ័យខ្ពស់ក្នុងការមានទារកដែលមានជំងឺពិការចលករខួរក្បាល។

ម្ដាយដែលមានភាពមិនប្រក្រតីនៅក្រពេញទីរ៉ូអ៊ីត ពិការខ្សោយសតិបញ្ញា មានប្រូតេអ៊ីនលើស នៅក្នុងទឹកនោមឬប្រកាច់៖ ម្ដាយដែលមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ ទំនងជាមានលទ្ធភាពតិចតួចក្នុងការមានកូនដែលមានជំងឺ CP។

វាក៏មានលក្ខខណ្ឌផ្នែកសុខភាពដែរក្នុងពេលឈឺពោះ ការសម្រាលនិងបន្ទាប់ពីការសម្រាលភ្លាមៗកំហុសដែលជាសញ្ញាព្រមានសម្រាប់ការកើនឡើងនៃហានិភ័យរបស់ជំងឺCP។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើននៃកុមារទាំងនេះនឹងមិនវិវត្តទៅជាជំងឺ CP ទេ។ សញ្ញាព្រមានរួមមាន៖

ការសម្រាលបញ្ច្រាសជើង៖ ទារកដែលមានជំងឺពិការចលករខួរក្បាលទំនងជាកើតមកបញ្ច្រាសជើងច្រើន (ជើង ចេញមកមុន) ជំនួសឱ្យការសម្រាលដែលក្បាលចេញមកមុននៅពេលចាប់ផ្ដើមសម្រាល។ ទារកដែលខ្សោយខុសពីធម្មតាតាំងតែពីនៅជាទារកក្នុងផ្ទៃទំនងជាកើតមកក្នុងស្ថានភាពបញ្ច្រាសជើង។

ការឈឺពោះសម្រាល និងការសម្រាលដែលមានលក្ខណៈស្មុគ្រស្មាញ៖ ទារកដែលមានបញ្ហាសរសៃ ឈាម ឬបញ្ហាផ្លូវដង្ហើម អំឡុងពេលឈឺពោះសម្រាល និងពេលសម្រាលកូនប្រហែលជាអាចទទួលរងផលប៉ះពាល់រួចហើយចំពោះការខូចខួរក្បាលឬខួរក្បាលខុសប្រក្រតី។

ទារកកើតមកទំហំតូចប្រៀបធៀបនឹងអាយុនៃការសម្រាល (Small for gestational age)៖ ទារកដែល កើតមកមានទំហំតូចជាងបើប្រៀបធៀបនឹងទម្ងន់ពិតប្រាកដទៅតាមអាយុនៃការសម្រាលមាន ហានិភ័យខ្ពស់ក្នុងការកើត ជំងឺពិការចលករខួរក្បាលដោយសារតែកត្តា ដែលរារាំងពួកគេមិនឱ្យលូតលាស់តាមធម្មជាតិនៅក្នុងស្បូន។

ពិន្ទុApgar សម្រាប់វិនិច្ឆ័យសុខភាពទារកដែលទើបនឹងកើតទាប៖ ពិន្ទុ Apgar គឺជាការកំណត់អត្រាជាលេខដែលឆ្លុះបញ្ចាំងពីសុខភាពរាងកាយរបស់ទារកដែលទើបនឹងកើត។ វេជ្ជបណ្ឌិតដាក់ពិន្ទុទៅតាមពេលវេលាពីចង្វាក់ បេះដូង ការដកដង្ហើម ការកន្ត្រាក់សាច់ដុំរញ្ជោចឬរផ្លិច(reflect) និងពណ៌ស្បែកក្នុងរយៈពេលប៉ុន្មាននាទីដំបូងបន្ទាប់ពីសម្រាល។ ពិន្ទុទាបមួយនៅក្នុងរយៈពេលពី ១០នាទី ទៅ២០នាទីបន្ទាប់ពីសម្រាលត្រូវបានគេចាត់ទុកទូទៅថា ជាសញ្ញាដ៏សំខាន់នៃបញ្ហាដែលមានសក្ដានុពលដូចជាពិការចលករខួរក្បាល ។

ជំងឺខាន់លឿង៖ទារកទើបនឹងកើតជាង ៥០% កើតជំងឺខាន់លឿង (ស្បែកឡើងពណ៌លឿង ឬភ្នែកពណ៌ស) បន្ទាប់ពីសម្រាលនៅពេលដែលទឹកប្រម៉ាត់ពណ៌ក្រហម សារធាតុមួយដែលគេប្រទះឃើញនៅក្នុងទឹកប្រមាត់កកើត លឿនជាងថ្លើមរបស់គេអាចបំបែកខ្លួនរបស់វា និងរីករាលដាលពេញ

រាងកាយ។ជំងឺខាន់លឿងក្នុងកម្រិតធ្ងន់ធ្ងរ ដែលមិនអាចព្យាបាលបាន អាចសម្លាប់កោសិកាក្នុងខួរក្បាលនិងអាចបណ្តាលឱ្យថ្លង់និងមានពិការចលករខួរក្បាល។

**ការប្រកាច់៖** ទារកដែលមានជំងឺប្រកាច់ប្រឈមនឹងហានិភ័យខ្ពស់កើតពិការចលករខួរក្បាលក្នុងវ័យកុមារភាពនៅពេលគេធ្វើ រោគវិនិច្ឆ័យនៅពេលក្រោយ។

**តើពិការចលករខួរក្បាលអាចបង្ការបានដែរឬទេ?**

ពិការចលករខួរក្បាលដែលទាក់ទងនឹងភាពមិនប្រក្រតីរបស់ហ្សែន មិនអាចការពារបានទេ ប៉ុន្តែហានិភ័យ២ ទៅ៣ក្នុង ចំណោមហានិភ័យនានា សម្រាប់ជំងឺពិការចលករខួរក្បាលពីកំណើតអាចគ្រប់គ្រង ឬជៀសវាងបាន។ ឧទាហរណ៍ជំងឺកញ្ជ្រិលស្រាល ឬកញ្ជ្រិលអាឡឺម៉ង់អាចការពារបានប្រសិនបើស្ត្រីបានចាក់វ៉ាក់សាំងការពារជំងឺនេះមុនពេលមានផ្ទៃពោះ។ ភាពមិនខុសគ្នារបស់ Rhក៏អាចគ្រប់គ្រងបាននៅមុនពេលមានផ្ទៃពោះដែរ។ ជំងឺពិការចលករខួរក្បាលដែលកើតមានជារឿយៗដោយសាររបួសក្បាលអាចការពារបានដោយប្រើយុទ្ធសាស្ត្រដែលមានសុវត្ថិភាពទូទៅ ដូចជាការប្រើខ្សែក្រវាត់ពេលជិះរថយន្តសម្រាប់ទារក និងកុមារដែលទើបតែចេះដើរ។

## ៤.២.៦.ការចាត់ចំណាត់ថ្នាក់៖

គេកំណត់ទម្រង់ជាក់លាក់នៃជំងឺពិការចលករខួរក្បាលទៅតាមវិសាលភាពប្រភេទ និងទីតាំងនៃភាពមិនប្រក្រតីរបស់កុមារ។ វេជ្ជបណ្ឌិតចាត់ចំណាត់ថ្នាក់ពិការចលករខួរក្បាល អាស្រ័យទៅតាមប្រភេទនៃបញ្ហាកាយវិការដែលទាក់ទងនឹង ការកន្ត្រាក់ (សាច់ដុំរឹង) athetoid(ចលនានៃការសរសេរ) ឬataxic(តុល្យភាពនិងការសម្របសម្រួលខ្សោយ) គួបផ្សំនឹងរោគសញ្ញាបន្ថែមណាមួយដូចជាភាពទន់ខ្សោយ (រោគស្ពឹក) ឬខ្វិន(plegia)។ ឧទាហរណ៍ ស្ពឹកមួយចំហៀង [hemiparesis (hemi =ពាក់កណ្តាល)] បង្ហាញថារាងកាយមួយចំហៀងខ្លួនមានភាពទន់ខ្សោយ។ ខ្វិនដៃជើង [Quadriplegia (quad = បួន)]មានន័យថាអវយវៈទាំង ៤ ទទួលរងផលប៉ះពាល់។

ពិការចលករខួរក្បាលប្រភេទស្ប៉ាស់ឬមានសាច់ដុំរឹង គឺជាទូទៅមានច្រើនបំផុត ។ មនុស្សមានសាច់ដុំរឹងនិងចលនាទ្រេតទ្រោត។ ទម្រង់នៃជំងឺពិការចលករខួរក្បាលប្រភេទស្ប៉ាស់ឬមានសាច់ដុំរឹងរួមមាន៖

- ខ្វិនមួយចំហៀងខ្លួន (Hemiplegia)ឬស្ពឹកមួយចំហៀងខ្លួន(hemiparesis)ជាទូទៅប៉ះពាល់ដៃនិងប្រអប់ដៃមួយចំហៀង ប៉ុន្តែវាក៏អាចរាប់បញ្ចូលទាំងជើងផងដែរ។ ជាទូទៅកុមារដែលមានជំងឺខ្វិនមួយចំហៀងខ្លួន ដើរយឺត និងប្រើម្រាមជើងដោយសារតែសរសៃកែងជើង

ឡើងតឹង។ ដៃ និងជើងដែលទទួលរងផលប៉ះពាល់តាមធម្មតាខ្លីជាង និងតូចជាងម្ខាងទៀត។ កុមារមួយចំនួននឹងលូតលាស់ដោយមានខ្នងកោង ខុសប្រក្រតី(scoliosisឬវៀចឆ្អឹងខ្នង)។ កុមារដែលមានជំងឺខ្វិចមួយចំហៀងខ្លួន(hemiplegia)ក៏អាចមានជំងឺប្រកាច់ដែរ។ការនិយាយស្ដីមានភាពយឺតយ៉ាវ ហើយប្រហែលជាមានសមត្ថភាពបំផុត ប៉ុន្តែសតិបញ្ញាជាទូទៅមានលក្ខណៈធម្មតា។

- ជំងឺខ្វិចទាំងសងខាងឬស្ពឹកទាំងសងខាង (Spastic diplegiaឬdiparesis) ពាក់ព័ន្ធនឹងការរឹងសាច់ដុំដែលភាគច្រើនកើតមាននៅលើជើងទាំងពីរ និងមានផលប៉ះពាល់តិចតួចទៅលើដៃ និងមុខទោះបីជាប្រអប់ដៃអាចមានលក្ខណៈខុសពីធម្មតាក៏ដោយ។ ការរំញោច ទងសាច់ដុំ(Tendon)នៅលើជើងមានភាពខ្លាំងជ្រុល។ ម្រាមជើងទាញឡើងលើនៅពេល បាតជើងមានចលនា។ ភាពរឹងនៃសាច់ដុំជើងជាក់លាក់ធ្វើឱ្យជើងមានចលនាដៃដែលមានលក្ខណៈដូចកន្ត្រៃ(scissor)។ កុមារអាចត្រូវការជើងជ្រែងឬឈើច្រត់។ សតិបញ្ញា និងបំណិនផ្នែកភាសាជាទូទៅមានលក្ខណៈធម្មតា។
- ជំងឺខ្វិចអវយវៈទាំង៤ឬស្ពឹកអវយវៈទាំង៤ គឺជាទម្រង់ធ្ងន់ធ្ងរបំផុតនៃជំងឺពិការចលករខួរក្បាល ហើយជាញឹកញាប់ពាក់ព័ន្ធនឹងពិការភាពខ្សោយបញ្ញាពីកម្រិតមធ្យមទៅធ្ងន់ធ្ងរ។ ជំងឺនេះបណ្ដាលមកពីការខូចខួរក្បាលធ្ងន់ធ្ងរ ឬទម្រង់ខួរក្បាលខុសប្រក្រតីគួរឱ្យកត់សម្គាល់ជារឿយៗ កុមារមានសាច់ដុំរឹងធ្ងន់ធ្ងរនៅលើអវយវៈរបស់ពួកគេ ប៉ុន្តែមាន កទន់។ ពួកកគេកម្រមានលទ្ធភាពដើរបានណាស់។ ការនិយាយ ស្ដីនិងការយល់មានការលំបាក។ ការប្រកាច់មានលក្ខណៈញឹកញាប់ និងពិបាកគ្រប់គ្រង។

**ជំងឺពិការចលករខួរក្បាលប្រភេទ** dyskinetic (រួមមាន **ក.** ប្រភេទ athetoid ដែលពិបាកចលនាដៃជើង(ករណីខ្លះពិបាកចលនាអណ្ដាត) ឈរនិងអង្គុយ **ខ.** ប្រភេទ choreoathetoid ដែលពិបាកចលនាដៃជើង និង **គ.** ប្រភេទ dystonic ដែលពិបាកនិងយឺតក្នុងការធ្វើចលនា ដងខ្លួនទាំងមូល ដូចជាដៃ ជើង ដងខ្លួន មាត់និងអណ្ដាត..)៖ គេចាត់ទុកជំងឺនេះទៅតាម ភាពយឺតយ៉ាវឬចលនាប្រអប់ដៃ ឬជើងមានលក្ខណៈកន្ត្រាក់ៗ។ ភាពសកម្មខ្លាំងរបស់សាច់ដុំនៅលើមុខនិងអណ្ដាតធ្វើ ឱ្យកុមារមួយ ចំនួនញាក់មុខញាក់មាត់ឬហៀរទឹកមាត់។ ពួកគេពិបាកក្នុងការអង្គុយឱ្យត្រង់ខ្លួនឬដើរ។ កុមារខ្លះមានបញ្ហាក្នុងការស្ដាប់ គ្រប់គ្រងការដកដង្ហើមឬការសម្រួលចលនាសាច់ដុំដែលគេត្រូវការសម្រាប់និយាយ។សតិបញ្ញាកម្រទទួលរងផលប៉ះពាល់ណាស់ចំពោះទម្រង់នៃជំងឺពិការចលករខួរក្បាលរបៀបនេះ។

**ជំងឺចលករពិការខួរក្បាលប្រភេទ** Ataxic៖ ប៉ះពាល់ដល់តុល្យភាពនិងការយល់ដឹងស៊ីជម្រៅ។ កុមារដែលមានជំងឺCPដោយសារយឺតសរសៃតែងមានការសម្រួលសរសៃខ្សោយ និងដើរមិននឹងដោយមានដំណើរ ទ្រេតទ្រោត(wide-based gait)។ ពួកគេមានការ លំបាកក្នុងការធ្វើចលនាឱ្យបានរហ័ស

ហ្មួន ឬច្បាស់លាស់ដូចជាការសរសេរឬការដាក់ឡេវអាវឬលំបាកក្នុងការគ្រប់គ្រងចលនាដោយស្ម័គ្រចិត្តដូចជាការឈោងយកសៀវភៅជាដើម។

**ប្រភេទចម្រុះ៖** ពិការចលករខួរក្បាលសំដៅទៅលើរោគសញ្ញាដែលមិនមែនជាប់ទាក់ទងនឹងប្រភេទណាមួយនៃជំងឺCPតែមួយមុខនោះទេ ប៉ុន្តែទាក់ទងនឹងប្រភេទចម្រុះរបស់ជំងឺនេះ។ឧទាហរណ៍ កុមារដែលមានជំងឺCPច្រើនប្រភេទអាចមានសាច់ដុំមួយចំនួនឡើងតឹងខ្លាំងជ្រុល ចំណែកឯកុមារផ្សេងទៀតមានសាច់ដុំទន់ជ្រាយខ្លាំងដែលបង្កើតឱ្យមានភាពលាយឡំគ្នាមួយរវាងសាច់ដុំរឹង និងទន់ជ្រាយ។

### តើមានលក្ខខណ្ឌអ្វីទៀតដែលទាក់ទងនឹងជំងឺពិការចលករខួរក្បាល?

**ខ្សោយបញ្ញា៖** ប្រហែល ៣០% ទៅ ៥០%នៃអ្នកដែលមានពិការចលករខួរក្បាល នឹងមានការលំបាកផ្នែកសតិបញ្ញា។ ការលំបាកផ្នែកខួរក្បាលមានលក្ខណៈទូទៅក្នុងចំណោមអ្នកដែលមានជំងឺខូចអវយវៈទាំងអស់ច្រើនជាងអ្នកដែលមានជំងឺពិការចលករខួរក្បាលផ្នែកផ្សេងទៀត។

**ជំងឺប្រកាច់៖** កុមារចំនួនពាក់កណ្តាលនៃកុមារដែលមានពិការចលករខួរក្បាលទាំងអស់មានការប្រកាច់មួយឬច្រើន ប្រភេទ។កុមារដែលមានជំងឺពិការចលករខួរក្បាលនិងជំងឺឆ្កួតជ្រូកហាក់ដូចជាមានជំងឺពិការខ្សោយសតិបញ្ញាច្រើន។

**ភាពធំធាត់ និងលូតលាស់យឺត៖** កុមារដែលមានពិការចលករខួរក្បាល ពីកម្រិតមធ្យមទៅធ្ងន់ធ្ងរជាពិសេសអ្នកដែលមានជំងឺ ស្ពឹកអវយវៈទាំងអស់តែងមានការធំធាត់ និងលូតលាស់យឺតយ៉ាវ។ចំពោះទារក ភាពយឺតយ៉ាវនេះជាទូទៅមាន ការឡើង ទម្ងន់តិចតួចពេក។ចំពោះកុមារតូចៗ វាអាចលេចចេញនូវភាពក្រិនខុសប្រក្រតី ហើយចំពោះ អ្នកដែល មានវ័យជំទង់វិញ វាអាចលេចឡើងរួមគ្នានូវភាពក្រិននិងការខ្វះការលូតលាស់ផ្នែកសរីរៈភេទ។ សាច់ដុំនិង អវយវៈដែលទទួលរងផលប៉ះពាល់ដោយសារពិការចលករខួរក្បាល មានទំហំតូចជាងសាច់ដុំ និងអវយវៈធម្មតា ជាពិសេស ចំពោះកុមារដែលមានជំងឺខូចមួយចំហៀងខ្លួនដែលអវយវៈនៅខាងផ្នែកដែលរងផលប៉ះពាល់របស់រាងកាយអាចនឹងមិន លូតលាស់លឿនឬលូតវែងដូចអវយវៈនៅផ្នែកមួយចំហៀងទៀតនៃដងខ្លួនដែលមានលក្ខណៈធម្មតាទេ។

**ខូចទ្រង់ទ្រាយឆ្អឹងខ្នង និង រលាកសន្លាក់** (Spinal deformities and osteoarthritis)៖ ការខូចទ្រង់ទ្រាយឆ្អឹងខ្នងពោលគឺខ្នងកោង(scoliosis) ខ្នងគម(ឆ្អឹងកងខ្នងវៀចទៅក្រោយ [kyphosis]) និងខ្នងវៀចទៅមុខ(អែន[lordosis]) មានទំនាក់ទំនងជាមួយជំងឺCP។ ការខូចទ្រង់ទ្រាយឆ្អឹងខ្នងអាច

ធ្វើឱ្យការអង្គុយឈរនិងដើរមានការលំបាកនិងបណ្តាលឱ្យឈឺឆ្អឹងខ្នងរ៉ាំរ៉ៃ។ ការសង្កត់ និងភាពបញ្ច្រាសគ្នារបស់សន្លាក់អាចបណ្តាលឱ្យមានជំងឺពុកឆ្អឹង[osteoporosis] (ការបំបែកឆ្អឹងខ្ចីក្នុង សន្លាក់ និងការរីកធំរបស់ឆ្អឹង)។

**ពិបាកមើល៖** កុមារជាច្រើនដែលមានពិការចលករខួរក្បាលមានភ្នែកស្រលៀង ដែលគេហៅថា«ភ្នែកកែក» ការទុកមិនព្រមព្យាបាលអាចនាំឱ្យខ្សោយភ្នែកមួយចំហៀង ហើយអាចរំខានដល់សមត្ថភាពក្នុងការវិនិច្ឆ័យរយៈចម្ងាយ។ កុមារមួយចំនួនដែលមានពិការចលករខួរក្បាលមានការលំបាកក្នុងការយល់និងរៀបចំព័ត៌មានដែលគេមើលឃើញ។ កុមារផ្សេងទៀតអាចមើលឃើញព្រាលៗ ឬងងឹងស្លុបដែលធ្វើឱ្យព្រិលភ្នែកមួយចំហៀង ឬទាំងពីរតែម្តង។

**ការស្តាប់មិនឮ៖** ការលំបាកក្នុងការស្តាប់ក៏មានលក្ខណៈទូទៅក្នុងចំណោមអ្នកដែលមានពិការចលករខួរក្បាល ច្រើន ជាងមនុស្សទូទៅដែរ។កុមារខ្លះមានការបាត់បង់ការស្តាប់មួយផ្នែកឬទាំងស្រុងតែម្តង ជាពិសេសដោយសារតែការមានជំងឺខាន់លឿងឬការខ្វះអុកស៊ីសែនក្នុងខួរក្បាលកំពុងលូតលាស់។

**បញ្ហាទាក់ទងនឹងការនិយាយ និងប្រើភាសា៖** បញ្ហាក្នុងការនិយាយ និងប្រើភាសាដូចជាពិបាកបង្កើតពាក្យនិង និយាយឱ្យបានច្បាស់ កើតមានឡើង ច្រើនជាងមួយភាគបី នៃអ្នកដែលមានពិការចលករខួរក្បាល។ ការនិយាយបានតិចតួចធ្វើឱ្យមានការលំបាកដល់ការប្រាស្រ័យទាក់ទង ហើយជារឿយៗត្រូវបានគេបកស្រាយថាជាសញ្ញានៃការលំបាកផ្នែកបញ្ញាដែលអាចធ្វើឱ្យកុមារដែលមានពិការចលករខួរក្បាលបាក់ទឹកចិត្តយ៉ាងខ្លាំង ជាពិសេសចំពោះអ្នកជំងឺភាគច្រើនដែលមានសតិបញ្ញាមធ្យម ឬលើសពីមធ្យម ។

**ការហៀរទឹកមាត់៖** អ្នកដែលមានពិការចលករខួរក្បាលមួយចំនួនហៀរទឹកមាត់ ដោយសារការគ្រប់គ្រងសាច់ដុំ នៅត្រង់បំពង់ក មាត់ និងអណ្តាតខ្សោយ។

**ការហូរទឹកនោមដោយមិនដឹងខ្លួន** (incontinence)**៖** ភាពស្មុគស្មាញមួយទៀតដែលអាចកើតមានចំពោះអ្នកពិការចលករខួរក្បាល គឺការហូរទឹកនោមដោយមិនដឹងខ្លួនដោយសារការគ្រប់គ្រងសាច់ដុំខ្សោយដែលធ្វើឱ្យផ្លោកនោមបិទមិនជិត។

**ភាពខុសប្រក្រតីផ្នែកញ្ញាណ** (ពិបាកប្រើប្រាស់ ឬដឹងដោយញាណទាំង៥)៖ មនុស្សមួយចំនួនដែលមានពិការចលករខួរក្បាលទទួលរងការឈឺចាប់ឬមានការលំបាកក្នុងការស្ទាបដោយប្រើវិញ្ញាណធម្មតាដូចជាការប៉ះជាដើម។

**ការលំបាកក្នុងការសិក្សាមុខវិជ្ជា៖** កុមារដែលមានពិការចលករខួរក្បាល ប្រហែលជាមានការលំបាកចំពោះដំណើរការនៃការវិភាគប្រភេទព័ត៌មានជាក់លាក់ស្តីពីទំហំ និងសោតវិញ្ញាណ។ ការខូចខួរក្បាលអាចប៉ះពាល់ដល់ការលូតលាស់សម្បទា (functioning)ផ្នែកភាសានិងសតិបញ្ញា។

**ការឆ្លងរោគ និងជំងឺរយៈពេលយូរអង្វែង៖** មនុស្សពេញវ័យជាច្រើនដែលមានពិការចលករខួរក្បាលមានហានិភ័យខ្ពស់ចំពោះការកើតជំងឺបេះដូង សួតនិងជំងឺរលាកសួត (ជាញឹកញាប់បណ្តាលមកពីការស្រូបកំទេចអាហារចូលទៅក្នុងសួត) ច្រើនជាងអ្នកទាំងឡាយណាដែលមិនមានបញ្ហានៃជំងឺនេះ។

**ការកន្ត្រាក់សាច់ដុំឡើងតឹងជាអចិន្ត្រៃយ៍៖** សាច់ដុំអាចស្ថិតនៅទីកន្លែងនានាដែលខុសប្រក្រតីហើយដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ត្រូវបានគេហៅថាការកន្ត្រាក់សាច់ដុំឡើងតឹង ជាអចិន្ត្រៃយ៍ដែលបង្កើនឱ្យមានការកន្ត្រាក់នូវសាច់ ដុំ និងការជ្រួសគ្នារបស់សន្លាក់សម្រាប់អ្នកដែលមានពិការចលករខួរក្បាល។

**ជំងឺខ្វះអាហាររូបត្ថម្ភ៖** ការលំបាកក្នុងការលេបការជញ្ជក់ ឬការជញ្ជក់ចំណីអាហារអាចធ្វើឱ្យអ្នកពិការចលករខួរក្បាល ជាច្រើនមានការលំបាកក្នុងការទទួលបានអាហាររូបត្ថម្ភត្រឹមត្រូវ ក៏ដូចជាការឡើង ឬការរក្សាទម្ងន់ដែរ ជាពិសេសទារក។

**បញ្ហាធ្មេញ៖** កុមារជាច្រើនដែលមានពិការចលករខួរក្បាល មួយចំនួនកើតជំងឺអញ្ចាញធ្មេញ និងប្រហោងធ្មេញដោយសារតែខ្វះអនាម័យធ្មេញ។ការព្យាបាលដោយប្រើថ្នាំមួយចំនួនដូចជាឱសថទប់ស្កាត់ជំងឺប្រកាច់ អាចធ្វើឱ្យបញ្ហាទាំងនេះកាន់តែមានភាពធ្ងន់ធ្ងរថែមទៀត។

**ភាពអសកម្ម៖**បង្ហាញឱ្យឃើញកាន់តែច្បាស់ចំពោះកុមារដែលមានពិការចលករខួរក្បាល ដោយសារតែប៉ះពាល់លើផ្នែកចលនារបស់ខួរក្បាលដែលបង្កើត និងគ្រប់គ្រងចលនាដោយឯកឯង។ ខណៈដែលកុមារ ដែលមានពិការចលករខួរក្បាលអាចបង្ហាញឱ្យឃើញនូវចំណាយថាមពលកើនឡើងក្នុងពេលធ្វើសកម្មភាពសម្រាប់ការរស់នៅប្រចាំថ្ងៃការលំបាកផ្នែកចលនាធ្វើឱ្យពួកគេមានការលំបាកក្នុងការចូល

រួមលេងកីឡា និងសកម្មភាពដទៃទៀតក្នុងកម្រិតមួយដែលមានកំលាំងគ្រប់គ្រាន់ដើម្បីបង្កើត និងរក្សាចំណុចខ្លាំង និងភាពសមស្រប។ ភាពអសកម្មរបស់មនុស្សពេញវ័យដែលមានពិការភាពរបៀបនេះបង្ហាញឱ្យឃើញនូវភាពធ្ងន់ធ្ងររបស់ជំងឺនេះកាន់តែកើនឡើង និងធ្លាក់ចុះចំពោះសុខភាពនិងសុខុមាលភាពទូទៅ។

## ៤.២.៧ ការធ្វើរោគវិនិច្ឆ័យ៖

កុមារភាគច្រើនដែលមានជំងឺចលករខួរក្បាលត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញក្នុងអំឡុងពេលមានអាយុ ២ ឆ្នាំដំបូងនៃជីវិត។ ប៉ុន្តែប្រសិនបើរោគសញ្ញារបស់កុមារមានកម្រិតស្រាលវាអាចមានការលំបាកសម្រាប់វេជ្ជបណ្ឌិតក្នុងការធ្វើរោគវិនិច្ឆ័យមុនគេអាយុ ៤ ឬ ៥ ឆ្នាំ។

គ្រូពេទ្យនឹងចេញវេជ្ជបញ្ជាឱ្យធ្វើតេស្ត ជាស៊េរីមួយដើម្បីវាយតម្លៃពីបំណិនចលនារបស់កុមារ។ ក្នុងអំឡុងពេលពិនិត្យជំងឺជាមួយគ្រូពេទ្យជាប្រចាំ គ្រូពេទ្យនឹងពិនិត្យមើលពីការលូតលាស់ ការធំធាត់ កំលាំងកន្ត្រាក់ របស់សាច់ដុំ ការគ្រប់គ្រងចលនាដែលស្របតាមអាយុ សោតវិញ្ញាណ និងចក្ខុវិញ្ញាណ និងការសម្រួល ក្នុងគោលបំណងដក ចេញនូវបញ្ហាផ្សេងៗដែលអាចបង្កឱ្យមានរោគសញ្ញាស្រដៀងគ្នា។ ទោះបីជារោគសញ្ញាអាចប្រែប្រួលទៅតាមពេលវេលាក៏ដោយជំងឺCPមិនមានការវិវឌ្ឍទេ។ ប្រសិនបើកុមារនៅតែបន្តបាត់បង់បំណិនចលនាបញ្ហាទំនងបណ្តាលមកពីលក្ខខណ្ឌផ្សេងទៀតជាជាងជំងឺCP ដែលមានដូចជាជំងឺហ្សែនឬជំងឺសាច់ដុំ បញ្ហានៃការបំលែង អាហារទៅជាថាមពល ឬការពកសាច់នៅក្នុងប្រព័ន្ធ ប្រសាទជាដើម។

- ការពិនិត្យសរីរៈនៅក្នុងលលាដ៍(Cranial)ដោយការស្តាប់សំឡេងចលនា៖ ប្រើរលកសំឡេងហ្វ្រេកង់ខ្ពស់ដើម្បីបង្កើតរូបភាពនៃខួរក្បាលរបស់ទារក។ គេប្រើវិធីនេះសម្រាប់ទារកដែលកើតមិនគ្រប់ខែមានហានិភ័យខ្ពស់ព្រោះវាមានភាពរំខានតិចបំផុតសម្រាប់បច្ចេកទេសនៃការថតរូបភាពទោះបីវាមិនទទួលបានជោគជ័យដូចការថតគ្រប់ជ្រុង(computed tomography) ឬការថតរូបភាពតាមរយៈសំឡេងញ័ររបស់ ម៉ាញ៉េទិចនៅពេលចាប់យកការផ្លាស់ប្តូររូបធាតុពណ៌សដែលជាប្រភេទជាលិកាខួរក្បាលដែលខូចខាតនៅក្នុងCP។
- ការថតសាច់ខួរក្បាល(CT)៖ ប្រើកាំរស្មីអ៊ិចដើម្បីបង្កើតរូបភាពដែលបង្ហាញពីរចនាសម្ព័ន្ធរបស់ខួរក្បាល និងផ្នែកនានាដែលខូច។

- ការថតរូបភាពតាមរយៈសំឡេងញ័ររបស់ម៉ាញ៉េទិច(MRI)៖ ប្រើកុំព្យូទ័រ ដែនម៉ាញ៉េទិច និងរលកវិទ្យុ ដើម្បីបង្កើតជារូបភាពនៃកាយវិភាគសរីរៈនៃជាលិកា និងរចនាសម្ព័ន្ធរបស់ខួរក្បាល។ MRI អាចបង្ហាញនូវ ទីតាំង និងប្រភេទនៃការខូចខាត ព្រមទាំងផ្តល់នូវកម្រិតព័ត៌មានលម្អិតជាងCT។

ការធ្វើតេស្តមួយផ្សេងទៀត គឺគំនូសកត់ត្រាសកម្មភាពខួរក្បាលដោយប្រើចរន្តអគ្គិសនី (electroencephalo- gram)ប្រើប្រាស់សេរីអេឡិចត្រូដ ដែលត្រូវបានគេបិត ឬបិទភ្ជាប់ជាបណ្តោះអាសន្នទៅស្បែកក្បាលដើម្បីរកមើលសកម្មភាពអគ្គិសនីនៅក្នុងខួរក្បាល។ ការផ្លាស់ប្តូរគំរូអគ្គិសនីធម្មតាអាចរកឃើញនូវជំងឺប្រកាច់។

បញ្ហានៃការរំលាយអាហារមួយចំនួនបន្លំខ្លួនជាពិការចលករខួរក្បាល។ ភាគច្រើននៃបញ្ហារំលាយអាហាររបស់កុមារមានភាពខុសប្រក្រតី និងរៀបចំទម្រង់នៃលក្ខណៈខួរក្បាលខុសដែលនឹងបង្ហាញនៅលើ MRI ។

ប្រភេទផ្សេងទៀតរបស់បញ្ហានានាក៏អាចធ្វើឱ្យគេយល់ច្រឡំថាជាពិការចលករខួរក្បាល ឬអាចបណ្តាលឱ្យមានប្រភេទពិការចលករខួរក្បាលជាក់លាក់ដែរ។ ឧទាហរណ៍បញ្ហានៃកំណកឈាម (ដែលរារាំងឈាមកុំឱ្យកកស្ទះ ឬធ្វើឱ្យឈាមកកហួសកម្រិត) អាចបណ្តាលឱ្យមានជំងឺដាច់សរសៃឈាមខួរក្បាលមុនពេលសម្រាលកូន ឬក្នុងពេលសំរាលកូនដែលធ្វើឱ្យខូចខួរក្បាល និងកាត់បន្ថយលក្ខណៈនៃរោគសញ្ញារបស់ពិការចលករខួរក្បាល ដែលជាទូទៅបំផុតគឺពិការចលករខួរក្បាល ប្រភេទ hemiparetic។ ការបញ្ជូនទៅគ្រូពេទ្យឯកទេសដូចជាគ្រូពេទ្យផ្លូវចិត្តកុមារ គ្រូពេទ្យកុមារអ្នកឯកទេសផ្នែកលូតលាស់របស់កុមារ គ្រូពេទ្យឯកទេសភ្នែក ឬគ្រូពេទ្យឯកទេសផ្នែកជម្ងឺត្រចៀកដើម្បីឱ្យមានការវិនិច្ឆ័យរោគសមស្រប និងជួយគ្រូពេទ្យ ឱ្យរៀបចំផែនការព្យាបាលជាក់លាក់មួយ។

## ៤.២.៨.ការព្យាបាលៈ

ពិការចលករខួរក្បាលមិនអាចព្យាបាលឱ្យជាបានទេ តែការព្យាបាលជារឿយៗកែលម្អសមត្ថភាពរបស់កុមារ។ កុមារជាច្រើនបន្តទទួលបានជីវិតជាមនុស្សពេញវ័យស្ទើរតែដូចធម្មតាប្រសិនបើពិការភាពរបស់ពួកគេត្រូវបានគ្រប់គ្រងត្រឹមត្រូវ។ ជាទូទៅការចាប់ផ្តើមការព្យាបាលកាន់តែរហ័សកុមារកាន់តែមានឱកាសប្រសើរឡើងក្នុងការជំនះលើពិការភាពនៃការលូតលាស់ឬការរៀនសូត្រពីមធ្យោបាយថ្មីៗដើម្បីអនុវត្តភារកិច្ចដែលពួកគេជួបប្រទះឱ្យបាន ជោគជ័យ។

ពុំមានការព្យាបាលតាមស្តង់ដារដែលដំណើរការសម្រាប់បុគ្គលម្នាក់ៗដែលមានពិការចលករខួរក្បាលនោះទេ។ នៅពេលគេធ្វើរោគវិនិច្ឆ័យហើយគេរកឃើញនូវប្រភេទរបស់ពិការចលករខួរក្បាល ក្រុមការងារមួយរបស់អ្នកឯកទេសខាង ថៃទាំ សុខភាពនឹងធ្វើការជាមួយកុមារ ព្រមទាំងឪពុកម្តាយរបស់ពួកគេដើម្បីកំណត់ពីភាពពីការលំបាកនិងតម្រូវការជាក់លាក់ ហើយបន្ទាប់មករៀបចំផែនការសមស្របមួយដែលដោះស្រាយនូវពិការភាពសំខាន់ៗដែលប៉ះពាល់ដល់គុណ ភាពជីវិតរបស់កុមារ។

**ការព្យាបាលដោយចលនា៖** តាមធម្មតាការព្យាបាលនេះ ចាប់ផ្តើមនៅក្នុងរយៈពេល២ឆ្នាំ-៣ឆ្នាំដំបូងនៃជីវិត ឬភ្លាមៗ បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យរួចហើយគឺជាគ្រឹះមួយនៃការព្យាបាលពិការចលករខួរក្បាល។ កម្រងនៃការអនុវត្តន៍ជាក់លាក់(ដូចជាកម្មវិធីការពារ ឬបណ្តុះបណ្តាលពីភាពរឹងមាំ) និងសកម្មភាពផ្សេងៗទៀតអាចរក្សា ឬពង្រឹងភាពរឹងមាំរបស់សាច់ដុំ តុល្យភាព និងបំណិនចលនា ព្រមទាំងទប់ស្កាត់ការកន្ត្រាក់សាច់ដុំឡើងតឹងជាអចិន្ត្រៃយ៍។ គេអាចប្រើឧបករណ៍ពិសេសសម្រាប់ទ្រឬអប (ឧបករណ៍ជំនួយសម្រាប់ទ្រឬអប[orthotics]) ដើម្បីកែលម្អការផ្លាស់ទី ឬពន្លាសាច់ ដុំដែលកន្ត្រាក់។

**ការព្យាបាលដោយឱ្យអ្នកជំងឺធ្វើសកម្មភាពផ្សេងៗ៖** ផ្តោតទៅលើការធ្វើឱ្យប្រសើរឡើង នូវដំណើរការរបស់រាងកាយផ្នែកខាងលើកែលម្អកាយវិការ និងការធ្វើឱ្យកុមារផ្លាស់ទីឱ្យបានច្រើនបំផុត។ អ្នកជំនាញខាងព្យាបាលដោយឱ្យអ្នកជំងឺធ្វើសកម្មភាពផ្សេងៗជួយបុគ្គលនានាឱ្យគិតរកមធ្យោបាយផ្សេងៗដើម្បីឆ្លើយតបនឹងសកម្មភាព ប្រចាំថ្ងៃដូចជាការស្លៀកពាក់ ទៅសាលារៀន និងចូលរួមក្នុងសកម្មភាពប្រចាំថ្ងៃ។

**ការព្យាបាលតាមរបៀបកំសាន្ត៖** លើកទឹកចិត្តឱ្យមានការចូលរួមក្នុងកម្មវិធីសិល្បៈនិងវប្បធម៌ កីឡា និងព្រឹត្តិការណ៍ផ្សេងៗទៀតដែលជួយដល់បុគ្គលម្នាក់ៗពង្រីកនូវបំណិននិងសមត្ថភាពផ្នែករាងកាយ និងបញ្ញា។ ឪពុក ម្តាយរបស់កុមារដែលចូលរួមក្នុងការព្យាបាលបែបកំសាន្តជាទូទៅកត់សម្គាល់ពីភាពប្រសើរឡើងមួយចំពោះការនិយាយ ការឱ្យតម្លៃលើខ្លួនឯង និងសុខុមាលភាពផ្លូវចិត្តរបស់កូនខ្លួន។

**ការព្យាបាលនៃការបញ្ចេញសំឡេង៖** អាចបង្កើនសមត្ថភាពរបស់កុមារក្នុងការនិយាយឱ្យកាន់តែច្បាស់ ជួយក្នុងការធ្វើចលនាសាច់ដុំបំពង់ក(swallowing disorders) និងរៀនពីវិធីសាស្ត្រថ្មីៗក្នុងការប្រាស្រ័យទាក់ទង ពោលគឺ ដោយប្រើភាសាសញ្ញា និងឬឧបករណ៍ជំនួយក្នុងការទំនាក់ទំនងពិសេស ដូចជាកុំព្យូទ័រដែលមានឧបករណ៍សំយោគសំឡេង ឬបន្ទះក្តារពិសេសដែលមានរូបសញ្ញាសំគាល់វត្ថុ និងសកម្មភាពប្រើប្រាស់ប្រចាំថ្ងៃដែលកុមារអាចចង្អុល ដើម្បីបង្ហាញពីការចង់បានរបស់គេ។

ការព្យាបាលចំពោះបញ្ហាទាក់ទងនឹងការញ៉ាំ និងហៀរទឹកមាត់៖ កុមារដែលមានពិការចលករខួរក្បាលមានការពិបាកក្នុងការញ៉ាំ ផឹកដោយសារពួកគេមានការគ្រប់គ្រងតិចតួចទៅលើសាច់ដុំនានាដែលបញ្ជាទៅលើចលនាមាត់ ថ្គាម និងអណ្តាតរបស់ពួកគេ។ ពួកគេក៏មានហានិភ័យដែរចំពោះការដកដង្ហើម ដោយស្រូបយកកំទេចអាហារ ឬសារធាតុរាវចូលទៅក្នុងសួតក៏ដូចជាចំពោះ ជំងឺខ្វះអាហាររូបត្ថម្ភ ការឆ្លងមេរោគទៅ សួត និងជំងឺសួតជាប់ជាលំដាប់ដែរ។

**ការព្យាបាលដោយប្រើថ្នាំ៖** ការប្រើថ្នាំសម្រាប់លេប ដូចជា diazepam, baclofen, dantrolene sodium និង tizanidine ត្រូវបានគេប្រើជា ធម្មតានៅដំណាក់កាលដំបូងនៃការព្យាបាលដើម្បីធ្វើឱ្យសាច់ដុំដែលរឹង ដែលកន្ត្រាក់ ឬឈឺ ។ ឱសថមួយចំនួនមានផលប៉ះពាល់ខ្លះៗបន្ទាប់ពីប្រើរួចដូចជាធ្វើឱ្យងងុយដេក(drowsiness) ការផ្លាស់ប្តូរសម្ពាធឈាមនិងហានិភ័យនៃ ការខូចថ្លើមដែលតម្រូវឱ្យមានការត្រួតពិនិត្យជាបន្តបន្ទាប់។ ឱសថសម្រាប់លេបមានលក្ខណៈសមស្របបំផុតសម្រាប់កុមារដែលត្រូវការការកាត់បន្ថយនូវការកន្ត្រាក់សាច់ដុំក្នុងកម្រិតស្រាលប៉ុណ្ណោះ ឬអ្នកដែលមានការកន្ត្រាក់សាច់ដុំគ្រប់កន្លែង។

- ឱសថ Botulinum toxin(BT-A) ដែលគេប្រើសម្រាប់ចាក់នៅកន្លែងណាមួយជាក់លាក់នៃរាងកាយ នៅសហរដ្ឋអាមេរិកបានក្លាយទៅជាការព្យាបាលជាលក្ខណៈស្តង់ដាសម្រាប់ការឈឺសាច់ដុំដោយសារការកម្រើកឥតឈប់ឈរចំពោះកុមារដែលមានបញ្ហាចលនាកន្ត្រាក់សាច់ដុំ ដូចជាCP។ BT-A បន្ធូរសាច់ដុំដែលកន្ត្រាក់តាមរយៈការធ្វើឱ្យកោសិកាសរសៃប្រសាទកុំឱ្យមានសកម្មភាពលើសាច់ដុំខ្លាំងពេក។ ប្រសិទ្ធិភាព នៃការបន្ថយនៃការចាក់ថ្នាំ BT-A មានរយៈពេលប្រហែល ៣ ខែ។ ផលវិបាកដែលគេមិនចង់បានមានកម្រិតទាប និងមានរយៈពេលខ្លីដោយមានការឈឺចាប់នៅពេលចាក់ថ្នាំនោះ ហើយជួនកាលមានរោគសញ្ញាដូច ជាជំងឺគ្រុនផ្តាសាយកម្រិតស្រាលអញ្ចឹង។ ការចាក់ថ្នាំ BT-A មានប្រសិទ្ធភាពបំផុតនៅពេលដែលគេអនុវត្តតាមកម្មវិធីរយៈពេលវែងដោយរួមទាំងការព្យាបាលផ្នែករាងកាយ និងការអបធ្មឹង។ ការចាក់ថ្នាំ BT-A មានប្រសិទ្ធភាពបំផុតសម្រាប់កុមារដែលមានការគ្រប់គ្រងមួយចំនួនលើចលនារបស់ពួកគេ និងមានចំនួនសាច់ ដុំដែលត្រូវព្យាបាលតិចដែលពុំមានសាច់ដុំណាមួយក្នុងចំណោមសាច់ដុំទាំងនោះជាប់គាំង ឬឡើងរឹឡើងរឹង។

**ការវះកាត់៖**

វះកាត់ឆ្អឹង ជារឿយៗត្រូវបានគេផ្តល់អនុសាសន៍នៅពេលដែលការកន្ត្រាក់ និងភាពឡើងរឹងនៃសាច់ដុំធ្វើឱ្យ មានសភាពធ្ងន់ធ្ងរដែលធ្វើការដើរ និងការផ្លាស់ទីមានការលំបាក ឬឈឺចាប់។ សម្រាប់

មនុស្សជាច្រើនដែលមានពិការចលករខួរក្បាល ការធ្វើអោយប្រសើរឡើងនូវរូបរាងនៃរបៀបដែលពួកគេដើរ ពោលគឺដំណើររបស់ពួកគេ ក៏មានសារៈសំខាន់ដែរ។

គ្រូពេទ្យវះកាត់អាចពន្លាសាច់ដុំ និងសរសៃពួរដែលមានប្រវែងខ្លី ដែលការនេះអាចជួយកែលម្អការផ្លាស់ទី និង កាត់បន្ថយការឈឺចាប់។ ការវះកាត់ ទងសាច់ដុំ(Tendon) អាចជួយកាត់បន្ថយរោគសញ្ញារបស់កុមារមួយចំនួនដែលមានពិការចលករខួរក្បាល ប៉ុន្តែវាអាចមានផលវិបាកជាអវិជ្ជមានរយៈពេលវែង។ ការវះកាត់ ឆ្អឹងអាចធ្វើទៅបានតាមពេល វេលាដែលសមស្របទៅនឹងអាយុរបស់កុមារ និងកម្រិតនៃការលូតលាស់ផ្នែកចលនា។ ការវះកាត់ក៏អាចកែសម្រួល ឬកែលម្អបានច្រើនការខូចទ្រង់ទ្រាយឆ្អឹងខ្នងចំពោះអ្នកដែលមានពិការចលករខួរក្បាល។

**វះកាត់ដើម្បីកាត់សរសៃប្រសាទចោល** (Selective dorsal rhizotomy: SDR) គឺជារបៀបនៃការវះកាត់មួយដែលគេណែនាំសម្រាប់ករណីនៃការកន្ត្រាក់ធ្ងន់ធ្ងរនៅពេលដែលការព្យាបាលតាមធម្មតាទាំងអស់ ពោលគឺការព្យាបាលផ្នែករាងកាយ ការប្រើឱសថសម្រាប់លេប និងការធ្វើឱ្យសាច់ដុំរលា (intrathecal Baclofen) ទាំងអស់ ទទួលបរាជ័យក្នុងការបន្ថយការកន្ត្រាក់ ឬការឈឺចាប់រ៉ាំរ៉ៃ។ គ្រូពេទ្យវះកាត់កំណត់ទីកន្លែង និងកាត់ផ្តាច់សរសៃ ប្រសាទដែលកន្ត្រាក់ខ្លាំងពេកឱ្យនៅដាច់ដោយឡែកនៅផ្នែកខាងក្រោយនៃឆ្អឹងកងខ្នង។ គេប្រើប្រាស់SDRទូទៅ បំផុតដើម្បីសម្រាលសាច់ដុំ និងបន្ថយការឈឺចាប់រ៉ាំរ៉ៃទាំងនៅអវយវៈផ្នែកខាងលើ ឬផ្នែកខាងក្រោម ឬទាំង២តែម្តង។ ជួនកាលវាក៏ត្រូវបានគេប្រើដើម្បីកែតម្រូវប្លោកនោមដែលកន្ត្រាក់ខ្លាំងពេកដែរ។ ផលវិបាកប្រកបដោយ សក្តានុពលភាពរួមមានការបាត់បង់ផ្នែកវិញ្ញាណ ស្ពឹក ឬការមានអារម្មណ៍មិនស្រួលនៅផ្នែកអវយវៈដែលផ្តល់សញ្ញាដោយសរសៃប្រសាទដែលកាត់ចេញ។

**ឧបករណ៍ជំនួយៈ** ឧបករណ៍ជំនួយដូចជា កម្មវិធីកុំព្យូទ័រ ការសំយោគសំឡេង និងសៀវភៅរូបភាពអាចជួយ បុគ្គលមួយចំនួនដែលមានពិការចលករខួរក្បាល ឱ្យកែលម្អបំណិន នៃការប្រាស្រ័យទាក់ទងបានយ៉ាងច្រើន។ ឧបករណ៍ផ្សេងទៀត ដែលនៅជុំវិញផ្ទះ ឬកន្លែងធ្វើការធ្វើឱ្យកាន់តែមានភាពងាយស្រួលសម្រាប់អ្នកដែលមានពិការចលករខួរក្បាល ក្នុងការសម្របខ្លួន ទៅតាមសកម្មភាពនៃការរស់នៅប្រចាំថ្ងៃ។

ឧបករណ៍សម្រាប់អប(Orthotic) ជួយសម្រួលសាច់ដុំដែលបាត់តុល្យភាព និងបង្កើនការផ្លាស់ទីដោយម្ចាស់ការ។ រណបសម្រាប់ទប់(braces និង splints) ប្រើកម្លាំងពីខាងក្រៅដើម្បី កែតម្រូវភាពខុស ប្រក្រតីរបស់សាច់ដុំ និងបង្កើនកាយសម្បទាផ្សេងៗដូចជាអង្គុយ ឬដើរ។ orthotics ផ្សេងទៀតជួយពន្លាសាច់ដុំ ឬទីតាំងរបស់សន្លាក់។ រណប ឧបករណ៍សម្រាប់ ទ្រាប់(wedge) កៅអី

ពិសេស និងឧបករណ៍ជំនួយផ្សេងៗទៀតអាចជួយអ្នកជំងឺឱ្យអង្គុយបានដោយស្រួល និងធ្វើឱ្យពួកគេកាន់តែមានភាពងាយស្រួលក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃ។ រទេះរុញ ឈើច្រត់មានកង់ និងម៉ូតូតូចៗអាចជួយអ្នកដែលមិនអាចផ្លាស់ទីដោយខ្លួនឯងបាន។ ឧបករណ៍ជំនួយសម្រាប់មើល រួមមានវ៉ែនតា កែវពង្រីក និងសៀវភៅដែលមានអក្សរធំៗ និងtypeface កុំព្យូទ័រ។ អ្នកដែលមានជំងឺCP មួយចំនួនអាចត្រូវការការវះកាត់ដើម្បីកែតម្រូវបញ្ហាចក្ខុវិញ្ញាណ។ ឧបករណ៍ជំនួយ សម្រាប់ស្តាប់ និងឧបករណ៍បំពងសំឡេងអាចជួយអ្នកជំងឺឱ្យស្តាប់ឮកាន់តែច្បាស់។

**ការព្យាបាលបន្ថែម និងតាមបែបផ្សេងទៀត៖** កុមារ និងមនុស្សវ័យជំទង់ជាច្រើនដែលមានពិការចលករខួរក្បាល ប្រើប្រាស់ការព្យាបាលបន្ថែម ឬតាមបែបផ្សេងទៀត។ ការសាកល្បងព្យាបាលដោយមានការត្រួតពិនិត្យដែលពាក់ព័ន្ធនឹងទម្រង់នៃការព្យាបាលមួយចំនួនពុំមានលក្ខណៈប្រាកដប្រជា ឬមិនបង្ហាញពីអត្ថប្រយោជន៍ទេ ហើយការព្យាបាលនោះមិនត្រូវបានគេទទួលយកសម្រាប់ការប្រតិបត្តិការ ព្យាបាលដែលគេបានកំណត់ទេ។ ទោះបីមានរបាយការណ៍ខ្លីៗស្តីពីអត្ថប្រយោជន៍ខ្លះៗចំពោះកុមារមួយចំនួនដែល មានពិការចលករខួរក្បាលក៏ដោយ ការព្យាបាលទាំងនេះមិនត្រូវបានអនុម័តយល់ព្រមពីរដ្ឋបាលទទួលបន្ទុកចំណីអាហារ និងឱសថរបស់អាមេរិកសម្រាប់ការព្យាបាលពិការចលករខួរក្បាលទេ។ ការព្យាបាលបែបនេះរួមទាំងការព្យាបាលដោយបញ្ចូលអុកស៊ីសែនខ្ពស់ (hyperbaric oxygen therapy) ការស្លៀកសម្លៀកបំពាក់ពិសេសក្នុងពេលបណ្តុះបណ្តាលពីការហាត់ប្រាណដើម្បីឱ្យមានភាពស៊ាំ ទម្រង់ជាក់លាក់នៃព្យាបាលដោយប្រើចរន្តអគ្គិសនី ការជួយកុមារក្នុងការធ្វើ ចលនាជាក់លាក់ជាច្រើនដងក្នុងមួយថ្ងៃ និងយុទ្ធសាស្ត្រនៃការរៀនសូត្រដែលគេរៀបចំជាលក្ខណៈឯកទេស។ ដូចគ្នានេះដែរ ការផ្តល់អាហារបំប៉នបន្ថែម រួមទាំងផលិតផលរុក្ខជាតិអាចមានទំនាក់ទំនងជាមួយផលិតផលផ្សេងៗទៀត ឬឱសថដែលកុមារដែលមានពិការចលករខួរក្បាល អាចនឹងលេប ឬមានផលវិបាកដែលគេមិនបានដឹងចំពោះខ្លួនគេផ្ទាល់។ ក្រុមគ្រួសារដែលមានកូនកើតពិការចលករខួរក្បាល ត្រូវតែពិភាក្សាពីការព្យាបាលទាំងអស់ជាមួយគ្រូពេទ្យរបស់ខ្លួន។

**ការព្យាបាលកោសិការបស់ដាលិកា៖** គេកំពុងអង្កេតដោយសារវាជាការព្យាបាលជំងឺពិការចលករខួរក្បាលមួយដែរ ប៉ុន្តែគេត្រូវការស្រាវជ្រាវនៅដំណាក់ដំបូងៗ និងការសាកល្បងព្យាបាលជាទ្រង់ទ្រាយធំដើម្បី សិក្សាមើលថាតើការព្យាបាលកោសិកាដាលិកាមានសុវត្ថិភាព និងមានប្រសិទ្ធភាពចំពោះមនុស្សដែរឬទេ។ កោសិកាដាលិកាមានសមត្ថភាពក្លាយជាប្រភេទកោសិកាផ្សេងទៀតនៅក្នុងរាងកាយ។ ក្រុមអ្នកវិទ្យាសាស្ត្រសង្ឃឹមថាកោសិការបស់ ដាលិកាអាចជួសជុលសរសៃប្រសាទខូច និងដាលិកាខួរក្បាល

បាន។ ការសិក្សានៅសហរដ្ឋអាមេរិកកំពុងពិនិត្យ មើលពីសុវត្ថិភាព និងភាពធន់នៃការចាក់បញ្ចូលកោសិកានៃដាលិការបស់ឈាមទៅក្នុងទងផ្ចិតចំពោះកុមារដែលមានពិការចលករខួរក្បាល។

**តើមានវិធីព្យាបាលដទៃទៀតដែលទាក់ទងនឹងការមានជំងឺចលករខួរក្បាលដែរ ឬទេ?**

**ជំងឺប្រកាច់៖** កុមារពិការខ្សោយបញ្ញា និងពិការចលករខួរក្បាលជាច្រើនក៏មានជំងឺប្រកាច់ដែរ។ ជាទូទៅការចេញ វេជ្ជបញ្ជាឱ្យប្រើថ្នាំគឺផ្អែកលើប្រភេទនៃការប្រកាច់ដែលបុគ្គលម្នាក់ៗធ្លាប់ឆ្លងកាត់ ព្រោះគ្មានថ្នាំណាអាចគ្រប់គ្រងការប្រកាច់លក្ខណៈបានទេ។ បុគ្គលមួយចំនួនអាចត្រូវការថ្នាំផ្សំពីរ ឬច្រើនដើម្បីឱ្យការគ្រប់គ្រងការប្រកាច់ មានភាពល្អប្រសើរ។

**ការនោមដោយមិនដឹងខ្លួន៖** ការព្យាបាលផ្នែកវេជ្ជសាស្ត្ររួមមាន ការហាត់ប្រាណពិសេស biofeedback ការប្រើថ្នាំតាមវេជ្ជបញ្ជា ការវះកាត់ ឬការដាក់ឧបករណ៍ជំនួយតាមរយៈការវះកាត់ដើម្បីដាក់ជំនួស ឬជំនួយសាច់ដុំ។

**ជំងឺពុកឆ្អឹង៖** កុមារដែលមានពិការចលករខួរក្បាលដែលមិនអាចដើរប្រឈមនឹងការវិវត្តចុះខ្សោយនៃដង់ស៊ីតេឆ្អឹង(osteopenia) ដែលធ្វើឱ្យពួកគេងាយនឹងបាក់ឆ្អឹង។ នៅក្នុងការសិក្សាមួយពីជនជាតិអាមេរិកដែលមានវ័យចំណាស់ដែលវិទ្យាស្ថានសុខភាពជាតិ (NIH) បានផ្តល់មូលនិធិឱ្យឱ្យក្រុមឱសថដែលគេហៅថាbisphosphonates ដែលFDA បានអនុម័តឱ្យប្រើប្រាស់ដើម្បីព្យាបាលការបាត់បង់សារជាតុរ៉ែសម្រាប់អ្នកជំងឺដែលវ័យចំណាស់ ក៏ហាក់ដូចជា បង្កើនដង់ស៊ីតេរ៉ែក្នុងឆ្អឹងដែរ។ វេជ្ជបណ្ឌិតអាចជ្រើសរើសយកឱសថប្រភេទនេះដើម្បីការពារ កុមារកុំឱ្យមានជំងឺពុក ឆ្អឹង។

**ការឈឺចាប់៖** ការឈឺចាប់អាចជាបញ្ហាមួយសម្រាប់អ្នកដែលមានពិការចលករខួរក្បាល ដោយសារការកន្ត្រាក់សាច់ដុំ និង ដោយសារភាពតានតឹង និងការដេកតែទៅលើផ្នែកមួយចំនួននៃរាងកាយដែលបណ្តាលមកពីភាពមិនប្រក្រតីរបស់សាច់ដុំ។ បុគ្គលមួយចំនួនក៏អាចមានការកន្ត្រាក់សាច់ដុំខ្លាំងៗជាញឹកញាប់ដែលគេមិនអាចដឹងមុន ឬទទួលបាន ថ្នាំជាមុន។ ថ្នាំ Diazepam អាចកាត់បន្ថយការឈឺចាប់ដែលបណ្តាលមកពីការកន្ត្រាក់សាច់ដុំហើយ gabapentin ត្រូវបានគេប្រើដោយជោគជ័យដើម្បីបន្ថយភាពធ្ងន់ធ្ងរ និងភាពញឹកញាប់នៃការកន្ត្រាក់សាច់ដុំខ្លាំងដែលបណ្តាលឱ្យមានការឈឺចាប់។ ការចាក់ថ្នាំ Botulinum toxin ក៏បង្ហាញឱ្យឃើញនូវការបន្ថយការកន្ត្រាក់សាច់ដុំ និងការឈឺចាប់។ Intrathecal baclofen បានបង្ហាញលទ្ធផលល្អក្នុងការកាត់បន្ថយការឈឺចាប់។ កុមារ និងមនុស្សពេញវ័យមួយចំនួនអាចបន្ថយការឈឺចាប់បានដោយការធ្វើអន្តរាគមន៍ដោយពុំមានប្រើថ្នាំ ដូចជាការ

បន្លប់ការឈឺចាប់(distraction) ការបណ្តុះបណ្តាលការសំរាកលម្ហែ(បន្ធូរអារម្មណ៍) biofeedback និងការព្យាបាលដោយការគក់ច្របាច់ ឬម៉ាស្សា។

តើមនុស្សពេញវ័យដែលមានជំងឺចលករខួរក្បាលប្រឈមនឹងបញ្ហាសុខភាពទេ?

**ចាស់មុនអាយុ៖** ភាគច្រើននៃអ្នកជំងឺដែលមានពិការចលករខួរក្បាល នឹងមានបទពិសោធន៍មួយចំពោះការចាស់ជាងអាយុនៅពេលដែលពួកគេឈានដល់អាយុ ៤០ ឆ្នាំ ដោយសារតែភាពតានតឹងបន្ថែម និងភាពមិនអាចកម្រើកបានដោយសារជំងឺនៅលើខ្លួនរបស់គេ។ ភាពយឺតយ៉ាវនៃការលូតលាស់ដែលជារឿយៗគួបផ្សំនឹងពិការចលករខួរក្បាលផងនោះ បានធ្វើឱ្យប្រព័ន្ធ សរីរាង្គមួយចំនួនពុំមានការលូតលាស់ និងមានសកម្មភាពពេញលេញទេ។ ជាលទ្ធផល ប្រព័ន្ធសរីរាង្គ ដូចជាប្រព័ន្ធ និងសរសៃឈាមបេះដូង(បេះដូង សរសៃឈាមវ៉ែន និងសរសៃឈាមអារទែ) និងប្រព័ន្ធដង្ហើម(សួត)ត្រូវតែធ្វើការយ៉ាងខ្លាំង ហើយធ្វើឱ្យពួកគេចាស់ជាងអាយុ។

**បញ្ហាមុខងារនៅកន្លែងធ្វើការ៖** បញ្ហាប្រឈមប្រចាំថ្ងៃនៅកន្លែងធ្វើការកើនឡើងនៅពេលដែលបុគ្គលពិការចលករខួរក្បាល ដែលជាអ្នកធ្វើការឈានដល់អាយុពាក់កណ្តាលវ័យ។ បុគ្គលមួយចំនួននឹងមានលទ្ធភាពបន្តធ្វើការងារបាន ដោយមានការកែសម្រួលមួយចំនួនដូចជា ការផ្លាស់ប្តូរកម្មវិធីធ្វើការ មានឧបករណ៍ជំនួយ ឬមានម៉ោងសម្រាក ញឹកញាប់។

**ជំងឺធ្លាក់ទឹកចិត្ត៖** បញ្ហាសុខភាពផ្លូវចិត្តក៏អាចជាការព្រួយបារម្ភដែរនៅពេលដែលអ្នកមានជំងឺពិការចលករខួរក្បាល មានវ័យកាន់តែចាស់។ អត្រាជំងឺធ្លាក់ទឹកចិត្តមានចំនួនខ្ពស់ជាងពី ៣ ទៅ ៤ ដងចំពោះជនពិការនានាដូចជា ជន ពិការចលករខួរក្បាលជាដើម។ វាហាក់ដូចជាមិនទាក់ទងទៅនឹងភាពធ្ងន់ធ្ងរនៃពិការភាពរបស់ពួកគេទេ ប៉ុន្តែវាអាស្រ័យលើរបៀបដែលពួកគេដោះស្រាយការលំបាកនោះបានល្អកម្រិតណា។ ទំហំនៃការគាំទ្រផ្នែកផ្លូវចិត្តដែលនរណាម្នាក់ មានបញ្ជាក់ពីកម្រិតនៃភាពជោគជ័យល្អកម្រិតណារបស់អ្នកនោះក្នុងការដោះស្រាយការខកចិត្ត និង ភាពតានតឹង ហើយថាតើពួកគេមានទស្សនវិស័យសុទិដ្ឋិនិយមអំពីអនាគត ឬអត់ ទាំងអស់នេះសុទ្ធតែមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាពផ្លូវចិត្ត។

**រោគសញ្ញាក្រោមមានការលំបាក៖** រោគសញ្ញានេះត្រូវបានគេកត់សម្គាល់តាមរយៈការរួមផ្សំនៃការឈឺចាប់ ភាពអស់កម្លាំង និងភាពទន់ខ្សោយដោយសារភាពមិនប្រក្រតីរបស់សាច់ដុំ ការខូចទ្រង់ទ្រាយឆ្អឹង រោគសញ្ញានៃការធ្វើការច្រើនហួសហេតុ(ជួនកាលគេហៅថាការរងរបួសដោយចលនាដដែលៗ) និងជំងឺរលាកសន្លាក់។ ការអស់កម្លាំងគឺ ជាបញ្ហាប្រឈមមួយដោយសារបុគ្គលដែលមានពិការចលករ

ខួរក្បាល អាចប្រើថាមពលរហូតដល់ទៅ ៣ ទៅ ៥ ដងនៅពេលពួកគេដើរ និងផ្លាស់ទីបើប្រៀបធៀបទៅនឹងមនុស្សធម្មតា។

**ជំងឺរលាកឆ្អឹងសន្លាក់ និងជំងឺរលាកសន្លាក់(Osteoarthritis and degenerative arthritis)៖** ភាពខុសប្រក្រតីរបស់ Musculoskeletal ដែលប្រហែលជាមិនបានបង្កើតឡើងនូវផាសុខភាពកាលពីវ័យកុមារអាចបណ្តាលឱ្យមានការឈឺចាប់ក្នុងពេលពេញវ័យ។ ឧទាហរណ៍ទំនាក់ទំនងខុសប្រក្រតីរវាងផ្ទៃសន្លាក់ និងភាពជាប់ណែនរបស់សន្លាក់អាចនាំឱ្យមានជំងឺរលាកសន្លាក់ឆ្អឹង និងជំងឺរលាកសន្លាក់យ៉ាងឆាប់រហ័ស។ បុគ្គលដែលមានពិការចលករខួរក្បាល អាច មានកំលាំងតិច និងការមានកម្រិតចំពោះការធ្វើចលនា ដែលធ្វើឱ្យពួកគេមានហានិភ័យក្នុងការប្រើប្រាស់រោគសញ្ញាហួសប្រមាណ និងការគាំងប្រព័ន្ធប្រសាទ(nerve entrapments)។

**ការឈឺចាប់៖** បុគ្គលដែលមានពិការចលករខួរក្បាល អាចមានការឈឺចាប់ដែលអាចមានលក្ខណៈស្រួចស្រាវ (ជាធម្មតាកើត ឡើងភ្លាមៗ និងមានរយៈពេលខ្លី) ឬរ៉ាំរ៉ៃហើយគេជួបប្រទះជាទូទៅបំផុតនោះនៅត្រង់ត្រគាក ជង្គង់ កជើង និងខ្នងផ្នែកខាងលើ និងខាងក្រោម។ អ្នកដែលមានពិការចលករខួរក្បាល ដែលធ្វើឱ្យកន្ត្រាក់សាច់ដុំអាចមានការឈឺចាប់ច្រើនកន្លែង និងឈឺចាប់ខ្លាំងជាងអ្នកដែលមានជំងឺពិការចលករខួរក្បាលប្រភេទផ្សេងទៀត។ ការព្យាបាលតាមរយៈការបង្ការក្នុងគោលបំណងកែតម្រូវភាពមិនប្រក្រតីរបស់គ្រោងឆ្អឹង និងសាច់ដុំភ្លាមៗនៅក្នុងជីវិតអាចជួយទប់ស្កាត់ការកើនឡើងនូវភាពតានតឹង និងភាពមិនអាចកម្រើកដែលកាន់តែធ្ងន់ធ្ងរដែលបណ្តាលអោយមានការឈឺចាប់។ ត្រគាកជ្រួសគ្នាដែលអាចបណ្តាលអោយមានការឈឺចាប់ជាពិសេសនោះអាចកែតម្រូវបានតាមរយៈការវះកាត់។

**ស្ថានភាពសុខភាពផ្សេងទៀត៖** មនុស្សពេញវ័យមានអត្រាស្ថានភាពសុខភាពអត្រាធម្មតាខ្ពស់ជាងស្ថានភាពសុខ ភាពរបស់អ្នកផ្សេងទៀត បន្ទាប់ពីជំងឺពិការចលករខួរក្បាលរបស់ពួកគេ ដូចជាជំងឺលើសឈាម ការហូរនោមដោយមិនដឹងខ្លួន ផ្លោកនោមមិនដំណើរការល្អ និងពិបាកក្នុងការលេបអាហារ។ ការវៀចឆ្អឹងខ្នង(Scoliosis) ទំនងជារីកចម្រើនឬវិវត្តបន្ទាប់ពីភាពពេញវ័យនៅពេលឆ្អឹងបានលូតលាស់ពេញរូបរាង និងទំហំចុងក្រោយរបស់វា។ អ្នកដែលមានពិការចលករខួរក្បាល ក៏មានការកើនឡើងនៃការបាក់ឆ្អឹងដែរ ដោយកើតឡើងញឹកញាប់បំផុតក្នុងកំឡុងពេលនៃការព្យាបាលដោយចលនា។

តើការស្រាវជ្រាវបាន និងកំពុងធ្វើអ្វីខ្លះ?

វិទ្យាស្ថានជាតិនៃបញ្ហាសរសៃប្រសាទ និងជំងឺដាច់សរសៃឈាមក្នុងខួរក្បាល (NINDS), Bethesda, រដ្ឋMaryland សហរដ្ឋអាមេរិកដែលជាផ្នែកមួយរបស់វិទ្យាស្ថានជាតិសុខភាព (NIH) គឺជាអ្នកផ្តល់មូលនិធិនាំមុខគេសម្រាប់ការ ស្រាវជ្រាវជាមូលដ្ឋាន ព្យាបាល និងបកប្រែលើបញ្ហាប្រព័ន្ធខួរក្បាល និងសរសៃប្រសាទថ្នាក់ជាតិ។ ទីភ្នាក់ងារ NIH មួយទៀតគឺវិទ្យាស្ថានជាតិសុខភាពកុមារ និងការអភិវឌ្ឍមនុស្ស (EHNN) របស់ Eunice Kennedy Shriver ក៏ធ្វើការស្រាវជ្រាវ និងគាំទ្រដល់ការស្រាវជ្រាវអំពីជំងឺពិការចលករខួរក្បាលដែរ។

ភាគច្រើននៃអ្វីដែលយើងបានដឹងអំពីពិការចលករខួរក្បាល បានមកពីការស្រាវជ្រាវដែលឧបត្ថម្ភដោយ NINDS ដោយរាប់បញ្ចូលទាំងការកំណត់អត្តសញ្ញាណនៃមូលហេតុថ្មី និងកត្តាហានិភ័យនៃពិការចលករខួរក្បាល ការរកឃើញថ្នាំដើម្បីគ្រប់គ្រងសាច់ដុំរឹង និងកន្ត្រាក់ព្រមទាំងវិធីសាស្ត្រច្បាស់លាស់បន្ថែមទៀតក្នុងការផ្តល់ថ្នាំទាំងនោះ កំណត់នូវបច្ចេកទេសវះកាត់ចម្រាញ់ដើម្បីកែតម្រូវភាពមិនប្រក្រតីនៃសាច់ដុំ និងឆ្អឹង និងការយល់ដឹងកាន់តែច្រើនអំពីរបៀប និងមូលហេតុនៃការខូចខួរក្បាលនៅដំណាក់កាលសំខាន់នៃការវិវត្តរបស់ទារកក្នុងផ្ទៃដែលធ្វើឱ្យកើតពិការចលករខួរក្បាល។

អ្នកវិទ្យាសាស្ត្រជាច្រើនគិតថាចំនួនកុមារយ៉ាងច្រើនមានពិការចលករខួរក្បាលដោយសារតែភាពខុសទ្រង់ទ្រាយតាំងពីដំបូងនៃការលូតលាស់របស់ខួរក្បាល។ ពួកគេកំពុងពិនិត្យមើលពីរបៀបដែលneurons(កោសិកាសរសៃប្រសាទ)នៅក្នុង ខួរក្បាលបានធ្វើឯកទេសកម្ម(specialize) និងរៀបចំទំនាក់ទំនងត្រឹមត្រូវជាមួយកោសិកាផ្សេងទៀតរបស់ខួរក្បាល យ៉ាងណាខ្លះ ហើយពួកគេកំពុងស្វែងរកមធ្យោបាយដើម្បីទប់ស្កាត់កត្តាដែលបង្អាក់នូវដំណើរការធម្មតានៃការលូតលាស់របស់ខួរក្បាល។

តំណពូជពេលខ្លះទទួលខុសត្រូវចំពោះការរៀបចំមិនត្រូវ និងភាពមិនប្រក្រតីរបស់ខួរក្បាលដែលបណ្តាលឱ្យមានជំងឺពិការចលករខួរក្បាល។ អ្នកវិទ្យាសាស្ត្រកំពុងស្វែងរកហ្សែនដែលទទួលខុសត្រូវចំពោះភាពមិនធម្មតាទាំងនេះដោយប្រមូលសំណាកDNAពីអ្នកដែលមានជំងឺចលករខួរក្បាល និងក្រុមគ្រួសាររបស់ពួកគេហើយប្រើបច្ចេកទេសពិនិត្យហ្សែនដើម្បីរកមើលទំនាក់ទំនងរវាងហ្សែននីមួយៗ និងប្រភេទមិនប្រក្រតីជាក់លាក់ជាពិសេសហ្សែនទាំងឡាយណាដែលទាក់ទងនឹងដំណើរការចំពោះខួរក្បាលដែលកំពុងលូតលាស់ដែលតាមរយៈនោះកោសិកាសរសៃប្រសាទដែលផ្លាស់ទីពីកន្លែងដែលពួកវាកើតទៅកន្លែងដែលវាត្រូវនៅនៅក្នុងសៀគ្វីរបស់សរសៃប្រសាទ(ដែលគេហៅថាការផ្លាស់ប្តូរប្រព័ន្ធសរសៃប្រសាទ)។

អ្នកវិទ្យាសាស្ត្រកំពុងពិនិត្យមើលព្រឹត្តការណ៍នៃខួរក្បាលរបស់ទារកទើបនឹងកើតដូចជាការហូរឈាម ជំងឺប្រកាច់ និងបញ្ហានៃការដកដង្ហើម និងបញ្ហានៃការចរាចរដែលអាចបណ្តាលឱ្យមានការបញ្ចេញសារធាតុគីមីខុសប្រក្រតី ការនេះបណ្តាលឱ្យមានការខូចខាត ហើម និងបណ្តាលអោយមានជំងឺពិការចលករខួរក្បាល។ ឧទាហរណ៍ការស្រាវជ្រាវបានបង្ហាញថាការហូរឈាមក្នុងខួរក្បាលបញ្ចេញនូវជាតិពុល glutamate ដែលជាសារធាតុគីមីដែល ជួយឱ្យសរសៃប្រសាទទាក់ទងគ្នា។ ទោះជាយ៉ាងណាក៏ដោយ ជាតិពុល glutamate ច្រើនពេកនឹងសម្លាប់សរសៃប្រសាទ។ តាមរយៈការសិក្សាពីរបៀបដែលសារធាតុគីមីក្នុងខួរក្បាលដែលតាមធម្មតាមានប្រយោជន៍ក្លាយទៅជាសារធាតុដ៏គ្រោះថ្នាក់ អ្នកវិទ្យាសាស្ត្រនឹងមានឱកាសផលិតឱសថថ្មីដើម្បីទប់ស្កាត់ផលប៉ះពាល់របស់វា។

អ្នកស្រាវជ្រាវកំពុងប្រើបច្ចេកទេសថតរូប និងការធ្វើតេស្តសរសៃប្រសាទ( neurobehavioral) ដើម្បីព្យាករណ៍ថា តើទារកដែលកើតមិនគ្រប់ខែទាំងនោះនឹងមានកើតជំងឺពិការចលករខួរក្បាលដែរ ឬទេ។ ប្រសិនបើបច្ចេកទេសនៃការពិនិត្យទាំងនេះទទួលបានជោគជ័យ គ្រូពេទ្យនឹងមានលទ្ធភាពកំណត់ទារកដែលមានហានិភ័យក្នុងការមានជំងឺCPតាំងពីមុនពេលកើត។

ការខូចអង្គធាតុបញ្ញាពណ៌សperiventricular ដែលជាមូលហេតុទូទៅបំផុតរបស់ពិការចលករខួរក្បាល ត្រូវបានគេកត់សម្គាល់ តាមរយៈការស្លាប់នៃអង្គធាតុពណ៌សនៅជុំវិញថតបេះដូងផ្នែកខាងក្រោយដែលបំពេញដោយសារធាតុរាវនៅក្នុងខួរក្បាល។ តំបន់របស់ periventricular មានផ្ទុកសរសៃតូចៗរបស់សរសៃប្រសាទដែលនាំសារពីខួរក្បាលទៅសាច់ដុំរបស់រាងកាយ។ ក្រុមអ្នកស្រាវជ្រាវដែលឧបត្ថម្ភដោយ NINDS កំពុងសង្ឃឹមថានឹងបង្កើតបានយុទ្ធសាស្ត្របង្ការការខូចអង្គធាតុពណ៌ស។ ឧទាហរណ៍អ្នកស្រាវជ្រាវកំពុងពិនិត្យមើលតួនាទីរបស់ខួរក្បាលដែលពាក់ព័ន្ធនឹងការបង្កើត គំរូ novel mouse មួយ និងការព្យាបាលដោយផ្អែកលើកោសិកាចំពោះការរងរបួសរបស់អង្គធាតុពណ៌សក្នុងពេលសម្រាល។ អ្នកស្រាវជ្រាវដែលទទួលបានមូលនិធិពី NINDS កំពុងសិក្សាពីសារធាតុគីមីមួយដែលគេរកឃើញ ជាទូទៅនៅក្នុងរាងកាយដែលគេហៅថា erythropoietin ដើម្បីពិនិត្យមើលថាតើវាបន្ថយហានិភ័យនៃជំងឺCPចំពោះទារកដែលកើតមិនគ្រប់ខែ ឬទេ។

អ្នកវិទ្យាសាស្ត្រដែលទទួលមូលនិធិពី NIHបន្តពិនិត្យមើលវិធីព្យាបាលថ្មី និងវិធីសាស្ត្រថ្មីៗដើម្បីប្រើប្រាស់ជម្រើស ដែលមានស្រាប់សម្រាប់ព្យាបាលអ្នកពិការចលករខួរក្បាល ដែលរួមមាន៖

**ព្យាបាលដោយការស្តារសម្បទារាងកាយ** (Constraint-induced therapy: CIT)៖ គឺជាការព្យាបាលពិការចលករខួរក្បាលដែលអាចជោគជ័យ។ ជារួម CITជាប់ទាក់ទង នឹងការទប់អវយវៈដែលរឹងមាំ (ដូចជាដៃ«ល្អ»មួយចំហៀងសម្រាប់មនុស្សម្នាក់ដែលរងផលប៉ះពាល់ដោយជំងឺដាច់សរសៃឈាមក្នុងខួរ

ក្បាល) ដោយការរុំ និងបង្ខំចិត្តប្រើដៃដែលទន់ធ្វើចលនា ឱ្យបានខ្លាំងក្លាជារៀងរាល់ថ្ងៃក្នុងរយៈពេលមួយ សប្តាហ៍។ ការសិក្សាមួយពីការព្យាបាលដែលត្រូវបានឧបត្ថម្ភដោយNICHDកំពុងពិនិត្យមើលការប្រើប្រាស់កម្រិតនៃការផ្តល់ថ្នាំខុសគ្នាសម្រាប់ការបណ្តុះបណ្តាលប្រចាំថ្ងៃដោយប្រើប្រាស់ការរុំ រុំពេញម៉ោងមិនឱ្យមានចលនាប្រៀបធៀបនឹងការដាក់រណបទប់ពាក់កណ្តាលពេលដើម្បីពង្រឹង រាងកាយផ្នែកខាងលើរបស់កុមារដែលទន់ទាំងសងខាង។ ការរកឃើញនានាតាមរយៈនៃការសិក្សានេះនឹងបង្កើតស្តង់ដាសម្រាប់ការប្រតិបត្តិដោយផ្អែកលើភស្តុតាងដើម្បីកែលម្អសមត្ថភាពផ្នែកចលនារបស់សរសៃប្រសាទ(neuromotor)ពេញមួយជីវិតសម្រាប់បុគ្គលដែលមានពិការចលករខួរក្បាល ។

**ការជម្រុញចលនាសាច់ដុំដោយប្រើចរន្តអគ្គិសនី Functional electrical stimulation (FES)៖** ការព្យាបាលដោយប្រើចរន្តអគ្គិសនីកម្រិតទាបដើម្បីរំញោចចលនាសាច់ដុំ និងស្តារចលនាដែលមានប្រយោជន៍ឡើងវិញ ដូចជាការឈរឬការបោះជំហានទៅមុខគឺជាវិធីដ៏មានប្រសិទ្ធភាពមួយដើម្បីកំណត់គោលដៅ និងពង្រឹងការកន្ត្រាក់សាច់ដុំ។ ក្រុមអ្នកស្រាវជ្រាវកំពុងវាយតម្លៃថាតើ FES-assisted stationary cycling អាចជួយបង្កើន កាយសម្បទា និងកំលាំងសាច់ដុំដែលខ្សោយជាទូទៅសម្រាប់មនុស្សវ័យជំទង់បានកម្រិតណា។ លទ្ធផលនៃការសិក្សារបស់ NICHD នេះនឹងនាំឱ្យមានការច្នៃប្រឌិតសម្រាប់ការព្យាបាលដែលសំដៅលើកកម្ពស់សម្បទាlocomotorរបស់កុមារដែលមានពិការចលករខួរក្បាល។

ឱសថ Botulinum toxin ដែលគេត្រូវបានចាក់នៅកន្លែងជាក់លាក់របស់រាងកាយបានក្លាយទៅជាស្តង់ដាមួយនៃការព្យាបាលសម្រាប់កុមារដែលមានបញ្ហាចលនា ដោយសារការកន្ត្រាក់សាច់ដុំដូចជាពិការចលករខួរក្បាល។ ការសិក្សាថ្មីៗទៅ លើសត្វបានបង្ហាញថា Botoxធ្វើឱ្យប៉ះពាល់ឆ្អឹង ប៉ុន្តែមិនមានការសិក្សាអំពីផលវិបាករបស់វាទៅលើឆ្អឹងមនុស្សទេ។ ការស្រាវជ្រាវដទៃទៀតបានបង្ហាញថាការព្យាបាលដោយរំញ័រអាំងតង់ស៊ីតេទាបអាចជួយកែលម្អរចនាសម្ព័ន្ធឆ្អឹង នៅលើឆ្អឹងជើងខាងក្រោមបំផុតរបស់កុមារដែលមានពិការចលករខួរក្បាល។ នៅក្នុងការស្រាវជ្រាវពីវិធីព្យាបាលថ្មីមួយដែលរៀបចំឡើងដោយNICHD ក្រុមអ្នកស្រាវជ្រាវកំពុងកំណត់ពីប្រសិទ្ធភាពនៃការព្យាបាលដោយប្រើថ្នាំ Botox ព្រមជាមួយគ្នានឹងការព្យាបាលរំញោចប្រចាំថ្ងៃលើទំហំឆ្អឹង និងរចនាសម្ព័ន្ធឆ្អឹងសម្រាប់កុមារដែលមានការកន្ត្រាក់សាច់ដុំដោយសារពិការចលករខួរក្បាល ។

**ជំងឺដែលបណ្តាលមកពីការចុះប្រព័ន្ធកម្តៅ( Systemic hypothermia)** - ឱសថដែលគ្រប់គ្រងការធ្វើឱ្យសីតុណ្ហភាពស្នូលក្នុងខ្លួនចុះត្រជាក់ទំនងជាការពារខួរក្បាល និងបន្ថយអត្រានៃការស្លាប់ ព្រមទាំងពិការភាព ដោយសារជំងឺមួយចំនួន និងការរងរបួសខួរក្បាល។ ការស្រាវជ្រាវពីមុនបានបង្ហាញថា ការបន្ថយកម្តៅអាចមានប្រសិទ្ធភាពក្នុងការព្យាបាលរោគសញ្ញាប្រព័ន្ធប្រសាទរបស់ទារកដែលកើតគ្រប់ខែ ឬកើតមិនគ្រប់ខែ តិចជាងមួយខែដែលត្រូវបានគេសន្មតថាមានជំងឺ ខ្វះអុកស៊ីសែនក្នុងខួរក្បាល hypoxic-ischemia (HIE, ការរបួសខួរក្បាលដោយសារការធ្លាក់ចុះការផ្គត់ផ្គង់ អុកស៊ីសែនទៅរាងកាយក្នុងកម្រិតធ្ងន់ធ្ងរ) ដែលអាចបណ្តាលឱ្យកើតជំងឺ CPប្រភេទ quatriplegic (ជំងឺពិការដៃជើងទាំងបួនទាំងស្រុង) ដោយមានឬពុំមានបញ្ហាចលនា។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកំណត់យុទ្ធសាស្ត្រនៃការបញ្ចុះកំដៅឱ្យមានប្រសិទ្ធភាពបំផុតអ្នកស្រាវជ្រាវដែលទទួលបានការគាំទ្រមូលនិធិពី NICHD កំពុងសិក្សាពីការព្យាបាលការបញ្ចុះកំដៅខុសៗគ្នាដើម្បីកែលម្អឱកាសនៃការរស់រានមានជីវិត និងលទ្ធផលនៃការលូតលាស់ប្រព័ន្ធប្រសាទនៅអាយុពី១៨ទៅ២២ខែក្រោយពេលព្យាបាលចំពោះទារកដែលមានរោគសញ្ញាផ្នែកប្រព័ន្ធប្រសាទដែលគេសម្មតថា HIE។ អ្នកស្រាវជ្រាវផ្សេងទៀតកំពុងពិនិត្យមើលថាតើការព្យាបាលរួមគ្នាដោយការប្រើប្រាស់ hypothermia និងrecombinant erythropoietin (អ័រម៉ូនដែលជំរុញការលូតលាស់របស់កោសិកាឈាមក្រហមថ្មី និងបង្កើនកម្រិតអុកស៊ីហ្សែននៅក្នុងឈាម)មានប្រសិទ្ធភាពជាងការព្យាបាលតែមួយមុខណាមួយក្នុងការព្យាបាលជំងឺទាក់ទងនឹងការលូតលាស់ខាងប្រព័ន្ធ ប្រសាទចំពោះគំរូរបស់សត្វដែលទាក់ទងនឹងការខ្វះអុកស៊ីសែនមុនពេល អំឡុងពេល ឬបន្ទាប់ពីកើតភ្លាមៗ។

នៅពេលអ្នកស្រាវជ្រាវបន្តស្វែងយល់ពីការព្យាបាលថ្មីសម្រាប់ជំងឺពិការចលករខួរក្បាល និងដើម្បីពង្រីកចំណេះដឹងរបស់យើងចំពោះការលូតលាស់របស់ខួរក្បាលយើងអាចរំពឹងថានឹងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការថែទាំកុមារដែលមានជំងឺពិការចលករខួរក្បាល និងជំងឺផ្សេងៗជាច្រើនទៀតដែលកើតមាននៅពេលទើបនឹងកើត។

# មេរៀនទី ៥

# ការរៀបចំក្រុមកុមារពិការ

## វត្ថុបំណង៖

- ដើម្បីរៀបចំកុមារពិការជាក្រុមទៅតាមកម្រិតអាយុ និងអាយុនៃការលូតលាស់របស់ខួរក្បាល នៅសាលាមត្តេយ្យសិក្សា និងបឋមសិក្សា។

## ៥.១. ការរៀបចំកុមារតាមក្រុម៖

ដោយផ្អែកតាមកម្រិតអាយុ និងអាយុនៃការលូតលាស់ខួរក្បាលរបស់កុមារពិការជាពិសេសកុមារខ្សោយបញ្ញាគេអាចរៀបចំកុមារទៅជាក្រុមនៅសាលាមត្តេយ្យសិក្សា និងបឋមសិក្សាដូចខាងក្រោម៖

| ល.រ | កម្រិតសិក្សា | កម្រិតអាយុ | កម្រិតនៃការលូតលាស់ខួរក្បាល |
|---|---|---|---|
| ១. | មត្តេយ្យ | ៣ ឆ្នាំទៅ ៦ ឆ្នាំ | ក្រោម ៥ ឆ្នាំ |
| ២. | បឋមសិក្សាកម្រិត១ | ៦ ឆ្នាំទៅ ១០ ឆ្នាំ | ៥ ឆ្នាំទៅ ៧ ឆ្នាំ |
| ៣. | បឋមសិក្សា កម្រិត២ | ១០ ឆ្នាំទៅ ១៣ ឆ្នាំ | ៧ ឆ្នាំទៅ ៩ ឆ្នាំ |
| ៣. | បឋមសិក្សាកម្រិត៣ | ១៣ ឆ្នាំទៅ ១៦ ឆ្នាំ | លើសពី ៩ ឆ្នាំ |

## ៥.២. កម្រិតអាយុ៖

កម្រិតអាយុ គឺជាអាយុរបស់មនុស្សម្នាក់ដែលគេវាស់ជាថ្ងៃ ខែនិងឆ្នាំចាប់តាំងពីថ្ងៃកើត។

## ៥.៣. អាយុនៃការលូតលាស់របស់ខួរក្បាល៖

អាយុនៃការលូតលាស់របស់ខួរក្បាល គឺជាការវាស់វែងមួយដោយប្រើប្រាស់ការធ្វើតេស្តផ្នែកចិត្តសាស្ត្រ ដែលបង្ហាញលទ្ធផលផ្នែកខួរក្បាលរបស់បុគ្គលម្នាក់ជាចំនួនឆ្នាំដែលកុមារមិនពិការម្នាក់ចំណាយពេលដើម្បីសម្រេចបានលទ្ធផលដូចគ្នា។

ឧបមា បើយើងសង្កេតមើលក្រុមកុមារដែលមានអាយុ១២ឆ្នាំ យើងអាចកត់សម្គាល់ឃើញ កុមារមានភាពខុសៗគ្នាទោះបីជាពួកគេមានអាយុដំណាលគ្នាក៏ដោយ។ កុមារខ្លះមានសាច់ដុំធំៗខ្លះមានរាង

ខ្ពស់ហើយស្គម ខ្លះមានការលូតលាស់យ៉ាងឆាប់រហ័ស និងខ្លះទៀតមិនទាន់លូតលាស់ដូចកុមារដទៃទៀតនៅឡើយទេ។ ចំណែកឯកម្លាំងកាយ សមត្ថភាព និងលក្ខណៈរាងកាយក៏ខុសគ្នាដែរ។

ដូច្នេះតើអាយុនៃការលូតលាស់របស់ខួរក្បាលមានយ៉ាងដូចម្តេច? មានន័យថាអាយុនៃការលូតលាស់របស់ខួរក្បាលជាកម្រិតអាយុនៃសមត្ថភាពផ្នែកខួរក្បាលរបស់បុគ្គលម្នាក់ អាស្រ័យទៅលើអាយុដែលបុគ្គលម្នាក់ត្រូវចំណាយពេលក្នុងការអភិវឌ្ឍខួរក្បាលទាន់កម្រិតដូចគ្នា។ ជាទូទៅអាយុនៃការលូតលាស់របស់ខួរក្បាលត្រូវបានគេវាស់តាមរយៈការធ្វើតេស្តស្តង់ដាបញ្ញា។ ឧទាហរណ៍ឯកសារ Stanford-Binet ស្តីពីកម្រិតនៃបញ្ញា បានគណនាពីអាយុនៃការលូតលាស់របស់ខួរក្បាលដោយផ្អែកលើថាតើកុមារម្នាក់អនុវត្តការធ្វើតេស្តបានល្អកម្រិតណា។

# មេរៀនទី៦

# កម្មវិធីសិក្សា និង បញ្ជីវាយតម្លៃសម្បទារបស់កុមារ

## ៦.១.វត្ថុបំណង៖

វត្ថុបំណងរបស់មេរៀននេះគឺ៖

- ប្រើប្រាស់កម្មវិធីសិក្សាទូទៅក្នុងការបង្រៀនកុមារពិការនៅក្នុងថ្នាក់អប់រំបរិយាប័ន្ន ។
- រៀបចំបង្កើតបញ្ជីវាយតម្លៃសម្បទារបស់កុមារពិការ ដើម្បីបង្រៀនកុមារពិការ នៅសាលារៀនអប់រំពិសេស។

## ៦.២.កម្មវិធីសិក្សា៖

កុមារពិការអាចរៀនជាមួយមិត្តរួមថ្នាក់បាន លុះត្រាតែគ្រូមានការសម្របសម្រួល និងកែលម្អកម្មវិធីសិក្សាទូទៅដែលមានស្រាប់ដ៏សមស្រប (នៃក្រសួងអប់រំ យុវជន និងកីឡា) នៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា។ ទន្ទឹមនឹងនេះ យើងប្រើបញ្ជីវាយតម្លៃសម្បទាកុមារពិការ ចំពោះកុមារនៅតាមសាលារៀនអប់រំពិសេស។

## ៦.៣.បញ្ជីវាយតម្លៃសម្បទាកុមារ ៖

| ល.រ | សកម្មភាព | បាទឬចាស់ | ទេ | ផ្សេងៗ |
|---|---|---|---|---|
| | សកម្មភាពផ្ទាល់ខ្លួន ឬសកម្មភាពរស់នៅប្រចាំថ្ងៃ | | | |
| ១ | ទំពា និងលេបអាហាររឹង (គោក) នៅពេលគេដាក់ទៅក្នុងមាត់របស់កុមារ។ | | | |
| | | | | |

### ៦.៣.១.មត្តេយ្យសិក្សា

| មត្តេយ្យសិក្សា | |
|---|---|
| ផ្នែក និងលេខរៀង | សកម្មភាព |

## សកម្មភាពផ្ទាល់ខ្លួន ឬសកម្មភាពរស់នៅប្រចាំថ្ងៃ

១. ទំពា និងលេបអាហាររឹង (គោក) នៅពេលគេដាក់ទៅក្នុងមាត់របស់កុមារ។

២. កាន់កែវ ឬពែងផឹកទឹក ឬទឹកដោះគោ ឬទឹកផ្លែឈើ។

៣. ទទួលទានអាហារដោយដៃខ្លួនឯង នៅពេលដែលគេស្រូបអាហារឱ្យ។

៤. អង្គុយបត់ជើង ឬអង្គុយចោងហោងលើចានបង្គន់សម្រាប់កុមារ ដើម្បីបត់ជើងតូច ឬបត់ជើងធំ។

៥. និយាយប្រាប់ ឬធ្វើកាយវិការ កាលណាពួកគេត្រូវការទៅបង្គន់។

៦. ស្រាតខោពេលចូលបង្គន់។

៧. ដុសធ្មេញដោយប្រើច្រាស ឬម្រាមដៃដោយមានដាក់ថ្នាំដុសធ្មេញ។

៨. ធ្វើតាមការណែនាំនៅពេលគេងូតទឹកឱ្យ - លាដៃ ឬ លាជើង ។

៩. ដោះសម្លៀកបំពាក់(រួមទាំងសម្លៀកបំពាក់ខាងក្នុង) នៅពេលគ្មានឡេវ។

១០. ស្លៀកខោក្នុង។

១១. ប្រើកូនកន្សែងជូតសម្អាតច្រមុះ។

១២. លាងសម្អាតដៃមុនពេលញ៉ាំចំណីអាហារ ឬពេលចេញពីបង្គន់ ឬពេលដេកខ្វក់។

១៣. ជូតខ្លួនឱ្យស្អាតបន្ទាប់ពីងូតទឹករួច។

១៤. បកសំបកផ្លែឈើ ដូចជាក្រូច ឬចេកមុនពេលទទួលទាន។

១៥. ទទួលទានអាហារនឹងចានសមស្រប ដូចជា នំប៉័ង ដំណាប់ បាយ និងសម្លការី នំបញ្ចុក។

១៦. កិនឬក្រឡុក និងទទួលទានអាហារដោយខ្លួនឯងដោយពុំមានកំពប់។

១៧. ជូតដៃ និងជូតមាត់បន្ទាប់ពីលាងដៃ និងលាងមាត់រួច។

១៨. ពាក់ស្បែកជើងផ្ទាត់។

១៩. ពាក់ស្បែកជើង ដែលពុំមានខ្សែ ឬទំពក់។

## សកម្មភាពសង្គម

១. ងាក ឬក្រឡេកមើលមនុស្សដែលដើរចុះឡើងក្បែរខ្លួន ឬនៅក្នុងបន្ទប់។

២. ឆ្លើយតបពេលគេហៅឈ្មោះរបស់គាត់ ដោយឈប់ធ្វើសកម្មភាពសិន ឬសម្លឹងមើលទៅរកអ្នកដែលហៅគាត់។

៣. នៅពេលអ្នកស្គាល់ហៅគាត់ឱ្យទៅជិត គាត់នឹងមក ។

៤. នៅពេលមានអ្នកញញឹមដាក់ គាត់នឹងញញឹមតបវិញ ។

៥. លេងជាមួយកុមារ២នាក់ទៀត ដោយមានកិច្ចសហការគ្នាល្អ ។

៦. រង់ចាំវេនរបស់ខ្លួននៅក្នុងថ្នាក់រៀន កន្លែងក្មេងលេង បន្ទប់ញ៉ាំអាហារ។

៧. ចែករំលែកសម្ភាររបស់ខ្លួន (ខ្មៅដៃ សៀវភៅ តុក្កតា ចំណីអាហារ...) នៅពេលដែលមិត្ត

រួមថ្នាក់សុំ។
៨. ស្វាគមន៍គ្រូបង្រៀន ឬមនុស្សចាស់ជាងខ្លួន នៅក្នុងសាលារៀន ឬនៅផ្ទះ។
៩. ចេះបែងចែករវាងមនុស្សចម្លែក និងអ្នកដែលធ្លាប់ស្គាល់។
១០. បង្ហាញកំហឹង ឬការមិនសប្បាយចិត្តតាមរយៈការបញ្ចេញសម្លេង (ស្រែក កាយវិការ គ្រហឹម...)ជាជាងការយំ។
១១. ឈប់ធ្វើសកម្មភាពមួយរយៈខ្លី នៅពេលដែលគេនិយាយថា «ទេ»។
១២. ប្រើសម្លេង កាយវិការ សកម្មភាពដើម្បីហៅមនុស្សម្នាក់ ឬឱ្យអ្នកដទៃចាប់អារម្មណ៍មកលើខ្លួន។
១៣.ឆ្លើយតបនឹងពាក្យពេជន៍ផ្សេងៗបានត្រឹមត្រូវ ដោយប្រើកាយវិការជាមួយដូចជា មក ឡើងលើ ទៅ លាហើយ ។ល។
១៤. ប្រើកាយវិការដូចជា គ្រវីក្បាលសម្រាប់ "ការបដិសេធ" ងក់ក្បាលសម្រាប់ "ការយល់ព្រម" ធ្វើដៃ ជាសញ្ញាសម្រាប់ពាក្យ " មក គេង លា..."។
១៥.ធ្វើតាមការស្នើសុំជាពាក្យសំដីសាមញ្ញៗ ដោយមានកាយវិការជាមួយផង ដូចជា «ឱ្យ» «ខ្ញុំនឹងយក» (ការឆ្លើយតបអាចជាកាយវិការ ឬជាពាក្យសម្ដី)។
១៦. អាចនិយាយបានដូចជា "ម៉ាក់ ម៉ាក់" "តា តា" "បង" ។ល។
១៧. ធ្វើតាមការបញ្ជាងាយៗដោយពុំមានកាយវិការដូចជា "យកបាល់មក" "ដាក់វាចុះ" ...។
១៨.ឆ្លើយសំណួរដូចជា"តើឡានបើកទៅមុខដូចម្ដេចដែរ?""តើយន្តហោះ ហោះដូចម្ដេចដែរ?" "តើកូនលាបម្សៅលើមុខ ដូចម្ដេចដែរ?"
១៩. សំគាល់មនុស្សនានាដោយចង្អុល ឬប្រាប់ឈ្មោះទៅតាមការស្នើសុំ (ឧ.ពូ មីង បងស្រី បងប្រុស ។ល។)។
២០. សួររកវត្ថុផ្សេងៗដែលគេចង់បាន ដោយប្រើកាយវិការ ឬដោយពាក្យសម្ដី។
២១. ប្រាប់ឈ្មោះរបស់ខ្លួននៅពេលគេសួរ។
២២. ធ្វើកាយវិការ ឬនិយាយបានត្រឹមត្រូវ ដូចជាពាក្យ អរុណសួរស្ដី ជម្រាបសួរ សាធុ...។

**ការសិក្សា**

១.ចង្អុល ឬបង្ហាញផ្នែកផ្សេងៗរបស់ដងខ្លួន (ក្បាល ច្រមុះ ភ្នែក ត្រចៀក ដៃ ជើង) នៅពេលដែលគេសួរ។
២.ប្រាប់ឈ្មោះផ្នែកផ្សេងៗនៃរាងកាយ នៅពេលដែលយើងចង្អុល។
៣.ចង្អុលវត្ថុសាមញ្ញៗចំនួន១០មុខដែលកុមារធ្លាប់ស្គាល់នៅផ្ទះរបស់ខ្លួន (ឧ. អង្ករ បន្លែ នំប៉ុង ភ្លើង កង្ហា កន្ទេល តុ កៅអី សំលៀកបំពាក់ ។ល។) នៅពេលដែលគេសួរ។
៤.ប្រាប់ផ្ទាល់មាត់ពីឈ្មោះវត្ថុចំនួន១០ នៅពេលដែលគេបង្ហាញ ឬនៅពេលដែលគេចង់បាន។
៥.កាន់ខ្មៅដៃ ហើយគូសវាស។

៦.ប្រើខ្មៅដៃពណ៌ដើម្បីផាត់ពណ៌លើដ្យាក្រាមដែលគេផ្តល់ឱ្យ។
៧.ផ្គូនលើដ្យាក្រាម ដែលបានផ្តល់ឱ្យ។
៨.ភ្ជាប់ចំណុចដៅមួយទៅចំណុចដៅមួយទៀត ដើម្បីបង្កើតបានជារូបភាពផ្សេងៗ។
៩.ចម្លងតួលេខ ឬដ្យាក្រាមដែលគេផ្តល់ឱ្យ។
១០.ដាក់វត្ថុផ្សេងៗជាក្រុមទៅតាមពណ៌ (ក្រហម បៃតង ខៀវ លឿង)នៅពេលគេផ្តល់វត្ថុមានពណ៌ខុសៗគ្នា។
១១.ដាក់វត្ថុផ្សេងៗជាក្រុមទៅតាមទំហំ (ធំ និងតូច វែងនិងខ្លី)។
១២.ផ្តល់វត្ថុ ឬរូបភាពផ្សេងៗដែលមានពណ៌ដូចគ្នា នៅពេលយើងស្នើសុំ។
១៣.ប្រាប់ឈ្មោះពណ៌នានា (ក្រហម បៃតង ខៀវ លឿង)។
១៤.ចង្អុលវត្ថុនានាដែលមានទំហំធំ-តូច វែង-ខ្លី ទៅតាមការស្នើសុំ។
១៥.ប្រាប់ពីទំហំវត្ថុនានា (ធំ-តូច វែង-ខ្លី)។
១៦.ចង្អុលទៅបណ្តុំវត្ថុផ្សេងៗ ដើម្បីបង្ហាញពីចំនួនច្រើន ឬតិច។
១៧.ប្រាប់ពីបណ្តុំវត្ថុនានា ដែលមានចំនួនច្រើន ឬតិច។
១៨.ចង្អុលទៅធុងដែលមានវត្ថុរឹង ឬរាវ ដើម្បីបង្ហាញថាពេញ ឬពុំមានអ្វីទេនៅក្នុងធុងនោះ។
១៩.ប្រាប់នៅពេលគេបង្ហាញធុងដែលមានទឹកពេញ ឬធុងទទេ មានឬពុំមានវត្ថុរឹង ឬវត្ថុរាវ។
២០.រាប់លេខរហូតដល់លេខ៥។
២១.រាប់និងឱ្យវត្ថុផ្សេងៗរហូតដល់ចំនួន៥ នៅពេលគេមិនបានសុំតាមលំដាប់លំដោយ។
២២.រាប់និងឱ្យវត្ថុផ្សេងៗ រហូតដល់ចំនួន១០ នៅពេលគេមិនបានសុំតាមលំដាប់លំដោយ។
២៣.បង្ហាញតម្លៃជាលេខ និងទីកន្លែង នៅពេលដែលគេពុំបានសួរទៅតាមលំដាប់លំដោយ។
២៤.រាប់ចំនួនរហូតដល់៥ នៅពេលដែលគេពុំបានសួរទៅតាមលំដាប់លំដោយ។
២៥.សរសេរលេខតាមលំដាប់លំដោយរហូតដល់ចំនួន ៥ ។
២៦.សរសេរលេខរហូតដល់លេខ៥ នៅពេលដែលគេហៅឱ្យសរសេរតាមអានមិនតាមលំដាប់លំដោយ ។
២៧.ចង្អុលព្យញ្ជនៈនៅក្នុងពាក្យដែលមានបីព្យាង្គ (ភាសាខ្មែរ ឬភាសាអង់គ្លេស) នៅលើតារាង ដោយគេពុំបានសួរតាមលំដាប់លំដោយ។
២៨.ប្រាប់ឈ្មោះព្យញ្ជនៈនៅក្នុងពាក្យដែលមាន៣ព្យាង្គ នៅពេលដែលគេពុំបានសួរទៅតាមលំដាប់លំដោយ។
២៩.សរសេរព្យញ្ជនៈនៅពេលគេហៅសរសេរតាមអាន (ពាក្យ ដែលមាន ៣ព្យាង្គក្នុងករណីដែលគេបង្រៀនពាក្យតាមរយៈការបង្ហាញ)។
៣០.អាចកំណត់បានរវាងនាឡិការ ព្យួរជញ្ជាំង ឬនាឡិកាដៃ។
៣១.ប្រាប់ ឬចង្អុលទៅនាឡិកា នៅពេលគេសួរពីទីកន្លែងសម្រាប់ដាក់នាឡិកាព្យួរជញ្ជាំង ឬនាឡិកាដៃ។

៣២.ប្រាប់ពីលក្ខណៈខុសគ្នារវាងក្រដាសប្រាក់ និងវត្ថុផ្សេងៗ។
៣៣.ប្រាប់ ឬចង្អុលនៅពេលដែលគេសួរពីការប្រើប្រាស់លុយ។
៣៤.រៀបលុយរៀល ពី១០០រៀល ទៅ ៥០០រៀល ឬ លុយដុល្លាពី១ដុល្លា ទៅ ៥ដុល្លានៅពេលដែលគេផ្តល់ឱ្យ។
៣៥.ឱ្យលុយរៀល ពី១០០រៀល ទៅ ៥០០រៀល ឬ លុយដុល្លាពី១ដុល្លា ទៅ ៥ដុល្លា នៅពេលដែលគេសុំ។
៣៦.ចង្អុល ឬប្រាប់ពីលុយរៀល ពី១០០រៀល ទៅ៥០០រៀល ឬលុយដុល្លាពី១ដុល្លា ទៅ ៥ដុល្លា នៅពេលដែលបង្ហាញលុយទាំងនោះ។
៣៧.អាចរាប់ នឹងឱ្យលុយរៀល ពី១០០រៀល ទៅ៥០០រៀល ឬ លុយដុល្លាពី១ដុល្លា ទៅ ៥ដុល្លានៅពេលដែលគេសុំ។
៣៨.ចង្អុលរូបភាពរបស់សត្វផ្សេងៗ យ៉ាងហោចណាស់ឱ្យបានចំនួន៥នៅពេលដែលគេសួរ។
៣៩.ប្រាប់ឈ្មោះសត្វយ៉ាងហោចណាស់ចំនួន៥ នៅពេលដែលគេបង្ហាញរូបភាព។
៤០.ចង្អុលរូបភាពផ្លែឈើយ៉ាងហោចណាស់ចំនួន៥ នៅពេលដែលគេសួរ។
៤១.ប្រាប់ឈ្មោះផ្លែឈើយ៉ាងហោចណាស់ចំនួន ៥ នៅពេលដែលគេបង្ហាញរូបភាព។
៤២.ប្រាប់ ឬចង្អុលទៅសម្លៀកបំពាក់ (អាវក្រៅ ខោខ្លី អាវ អាវយឺត) ដែលគេស្លៀកពាក់ នៅពេលគេសួរ។
៤៣.ប្រើពាក្យ ឬកាយវិការសម្រាប់ « ឥឡូវ និងពេលក្រោយ» នៅពេលចាំបាច់។
៤៤.កំណត់ ឬប្រាប់ឈ្មោះពីមធ្យោបាយធ្វើដំណើរនានា (កង់ ម៉ូតូឌុប រ៉ឺម៉កកង់បី ឡាន រទេះភ្លើង យន្តហោះ ...)។

| |
|---|
| **សកម្មភាពការងារ**<br>១. ប្រើប្រាស់អំបោសបោសធូលីដើម្បីសម្អាតគ្រឿងសង្ហារឹមនៅក្នុងថ្នាក់រៀន និងផ្ទះ។<br>២. លាងសម្អាតកែវ និងចាន មុនពេលនិងក្រោយពេលទទួលទានអាហារ។<br>៣. ជូតសម្អាតកែវ និងចាននឹងក្រណាត់បន្ទាប់ពីលាងសម្អាតរួច ។<br>៤. បត់សម្លៀកបំពាក់តូចៗ (ដូចជាកន្សែងដៃ ខោទ្រនាប់)។ |
| **សកម្មភាពកំសាន្ត**<br>**នៅក្នុងផ្ទះ៖**<br>១. មើលការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍<br>២. រាំ ទះដៃ គោះចើៗទៅតាមចង្វាក់ភ្លេងក្នុងវិទ្យុ ឬទូរទស្សន៍<br>៣. លេងល្បែងផ្គុំប្លង់ ផ្គុំគ្នា និងរើ(បំបែក)ចេញពីគ្នា<br>៤. ផាត់ពណ៌ដោយប្រើខ្មៅដៃ ឬខ្មៅដៃពណ៌<br>៥. លេងល្បែងសម្តែងតួដូចជាគ្រូបង្រៀន ជាម្តាយ ជាឪពុក បងប្រុសស្រីទៅសាលារៀន ឬមើលថៃផ្ទះសម្បែង។<br>៦.រៀបចំរបស់របរផ្សេងៗផ្ទាល់ខ្លួនទៅតាមកន្លែងរបស់វាឱ្យបានត្រឹមត្រូវនៅក្នុងបន្ទប់មួយដែលគេផ្តល់ឱ្យ។<br>៧. មើលរូបភាពនៅក្នុងទស្សនាវដ្តីដោយពុំហែកសៀវភៅនោះចោល។<br>**នៅក្រៅផ្ទះ៖**<br>១. លេងបាល់<br>២. លេងល្បែងរត់ដេញចាប់ រត់ប្រណាំងគ្នា ដើរត្រាប់តាមសត្វទា លោតកង្កែប ។ល។<br>៣. ហាត់ប្រាណដើរឡើងភ្នំ (jungle gym) ។ល។<br>៤. លេងជីខ្សាច់<br>៥. លេងទឹក<br>៦. លេងល្បែងបិទពួន ល្បែងបោះដំឡូងក្តៅ ល្បែងរាំជណ្តើមកៅអី ។ល។<br>៧. លេងនៅលើកន្លែងរអិល<br>៨. យោលទោង |

## ៦.៣.២.ក្រុមៈ បឋមសិក្សា ១

| ក្រុមៈ បឋមសិក្សា -១ | |
|---|---|
| ផ្នែក និងលេខរៀង | សកម្មភាព |

**សកម្មភាពផ្ទាល់ខ្លួនសម្រាប់ការរស់នៅប្រចាំថ្ងៃ**

១. ដើរដោយខ្លួនឯងចម្ងាយប្រមាណ ៣ម៉ែត្រដើម្បីទៅយកវត្ថុអ្វីមួយ។
២.ឡើង និងចុះជណ្តើរដោយដាក់ជើងទាំង២នៅលើកាំជណ្តើរនីមួយៗដោយពុំមានអ្នកជួយ។
៣. ចាក់សោបើកទ្វារ ឬដកគន្លឹះទ្វារដើម្បីបើកទ្វារនៅពេលគេចង់ចូល ឬចេញទៅក្រៅបន្ទប់។
៥. លាងសម្អាតខ្លួនបន្ទាប់ពីបន្ទោបង់រួច។
៦. កាច់ ឬ ចុចទឹក ឬចាក់ទឹកបង្គន់បន្ទាប់ពីបន្ទោបង់រួច។
៧.ស្លៀកសម្លៀកបំពាក់ ដោយរួមទាំងខោ ឬអាវក្នុង (ប្រហែលមិនភ្ជាប់ឡេវ ឬទំពក់ ទេ)
៨. ស្លៀកសម្លៀកបំពាក់៖ ក) រូត ខ) កិបឡេវ គ) ដាក់ឡេវ ឃ) ថ្ពក់ឡេវ
៩. ដោះសម្លៀកបំពាក់៖ ក) រូត ខ) ដោះឡេវ
១០. ញ៉ាំអាហារអស់ដោយខ្លួនឯងដោយពុំមានកំពប់
១១.សុំ ឬចង្អុលម្ហូបអាហារ (ឧ. បាយ និងសម្លការី នំបញ្ចុក)នៅពេលគេចង់ញ៉ាំថែមទៀត។
១២. រៀបចំអាហារថ្ងៃត្រង់ និងពេលល្ងាចទាំងនៅលើតុ និងលើកម្រាល។
១៣. ចាក់ ទឹកចេញពីកំសៀវ ឬត្រងទឹកពីក្បាលរ៉ូប៊ីណេដើម្បីផឹកនៅពេលដែលគេស្រេកទឹក
១៤. យកទឹកឱ្យអ្នកផ្សេងទៀត
១៥.លាងសម្អាតដៃមុនពេលញ៉ាំអាហារសម្រន់ ឬចំណីអាហារផ្សេងៗ ឬបន្ទាប់ពីចេញពីបង្គន់ ឬនៅពេលដែលដៃកខ្វក់។
១៦. លុបលាងមុខដោយទឹកថ្នាំសម្រាប់លាងសម្អាតមុខ ឬ សាប៊ូលាងមុខ និងទឹក
១៧. ជូតសម្អាតដៃ និងមុខដោយកន្សែងពោះគោបន្ទាប់ពីលាងសម្អាតហើយ។
១៨. សម្អាតច្រមុះជាមួយនឹងកន្សែងដៃ ឬក្រដាសអនាម័យនៅពេលដែលចាំបាច់។
១៩. ប្រើប្រាស់សាប៊ូដុះ ឬ ទឹកថ្នាំដុសខ្លួនដើម្បីសម្អាតខ្លួននៅពេលងូតទឹក។
២០. លាបម្សៅ ឬលាបឡេនៅលើមុខ។
២១. សិតសក់ និងចងសក់ដោយប្រើកៅស៊ូកងបន្ទាប់ពីត្រដោះសក់ដែលជំពាក់រួចហើយ(ក្នុងករណីជាក្មេងស្រី)។

**សង្គម**

១.ផ្តល់ឱ្យមានជម្រើសមួយ រវាងសកម្មភាព២ ឬវត្ថុ២។
២. ធ្វើសកម្មភាពទៅតាមការស្នើសុំរបស់គ្រូបង្រៀន និងឪពុកម្តាយ។
៣. សុំការអនុញ្ញាតិដើម្បីលេងតុក្កតា ឬសម្ភារផ្សេងៗដែលមិនមែនជារបស់ខ្លួន។
៤. ចូលរួមនៅក្នុងការលេងល្បែងជាក្រុមដែលមានកុមារលេងចំនួន៤-៥នាក់។
៥. រង់ចាំវេនរបស់ខ្លួននៅក្នុងពេលកំពុងលេងល្បែង។
៦. ចែកសម្ភារគ្នាលេងនៅពេលលេងល្បែងជាក្រុម។

៧. រក្សានូវឥរិយាបទសមរម្យនៅពេលចូលរួមក្នុងកម្មវិធីសង្គមផ្សេងៗ។
៨.ថែរក្សាសម្ភារផ្ទាល់ខ្លួនរបស់គាត់នៅសាលារៀន( ឧ.កាបូបដាក់សៀវភៅ ប្រអប់ដាក់អាហារថ្ងៃត្រង់ ប្រអប់ដាក់ ខ្មៅដៃ)។
៩. ការពារ ឬ ស្វែងរកជំនួយនៅពេលមានរបួសស្នាម ឬមានការរំខានពីអ្នកដទៃទៀត។
១០. ដឹងថាអ្នកនិយាយកំពុងខឹង ធុញទ្រាន់ ក្រៀមក្រំ រីករាយ ។ល។
១១. ប្រាប់ឈ្មោះផ្នែកផ្សេងៗរបស់រាងកាយនៅពេលគេចង្អុល។
១២. ប្រើប្រាស់ពាក្យផ្សំ ឬកាយវិការដើម្បីបញ្ជាក់ពីតម្រូវការ ឬបំណងប្រាថ្នារបស់ខ្លួន។
១៣. ឆ្លើយ(ដោយការនិយាយ ឬ កាយវិការ)នឹងសំណួរផ្សេងៗដូចជា «នេះជារបស់នរណា?» ដោយកុមារចង្អុលមក ខ្លួនរបស់គាត់ ឬនរណាម្នាក់បានយ៉ាងត្រឹមត្រូវ។
១៤. អនុវត្តតាមការណែនាំ ឬបញ្ជាចំនួន២បន្តបន្ទាប់គ្នា។
១៥. រៀបរាប់ឈ្មោះសមាជិកគ្រួសារដូចជា បង ឬប្អូនប្រុស បង ឬប្អូនស្រី ម្ដាយមីង ឬម្ដាយធំ ឪពុកធំ ឬឪពុកមា។
១៦. ប្រើប្រាស់ឃ្លាដែលមាន២-៣ព្យាង្គដើម្បីប្រាប់ព័ត៌មាន (ប្រសិនបើកាយវិការធ្វើឱ្យខ្លួនយល់ if non-verbal make self understood by guestures)។
១៧. សុំឱ្យគេជួយ(ជាពាក្យសំដី ឬកាយវិការ)សម្រាប់តម្រូវការផ្ទាល់ខ្លួន។
១៨. ធ្វើតាមសារផ្សេងដោយមានអាយតនិបាត(ឈ្នាប់)ផ្សេងៗដូចជា នៅខាងក្រោម នៅខាងក្រោយ នៅខាងមុខ (ឧទាហរណ៍ ដាក់កាបូបនៅខាងមុខក្មេងប្រុសនោះ)។
១៩. ប្រើប្រាស់ពាក្យទាក់ទងនឹងយេនឌ័រត្រឹមត្រូវនៅពេលគេសួរ។ តើប្អូន (ឬចង្អុលទៅកុមារម្នាក់)ជាកុមារា ឬកុមារី?
២០.អាចរៀបរាប់ឈ្មោះទម្រង់ពហុវចនៈ។ ឧ. កៅអីច្រើន ខ្មៅដៃច្រើន សៀវភៅច្រើន។
២១. អាចអនុវត្តតាមការណែនាំផ្សេងៗដើម្បីធ្វើកិច្ចការមួយដោយពុំមានផ្ដល់គន្លឹះ ឬសញ្ញា។

**ការសិក្សា**

១. អានស្រៈទាំងអស់ (ជាភាសាអង់គ្លេស ឬភាសាខ្មែរ) នៅពេលដែលគេបង្ហាញនៅលើតារាង ឬ សៀវភៅ។(ពាក្យដែល សរសេរនៅលើប្រអប់សម្រាប់បង្រៀន)។
២. អានពាក្យ (បន្លែ ផ្លែឈើ គ្រឿងសង្ហារឹម សត្វផ្សេងៗ) (ប្រហែល ១០ពាក្យ)។
៣.អានពាក្យដែលមាន២-៣ព្យាង្គដោយពុំមានបង្ហាញរូបភាពជាជំនួយ(ប្រហែល១០ពាក្យ)។
៤. អានឈ្មោះរបស់ខ្លួន
៥. អានឈ្មោះរបស់មិត្តភក្តិរបស់ខ្លួននៅក្នុងថ្នាក់។
៦. ប្រាប់ស្លាកសញ្ញាចំនួន៤ទាក់ទងនឹងការធ្វើដំណើរដោយខ្លួនឯង(ឯករាជ្យ)។
៧. សរសេរឈ្មោះរបស់ខ្លួន។
៨. សរសេរពាក្យដែលជាឈ្មោះ (បន្លែ ផ្លែឈើ គ្រឿងសង្ហារឹម សត្វ សម្លៀកបំពាក់)។
៩. ប្រាប់ពីតួនាទីនៃសរីរាង្គដែលទាក់ទងនឹងវិញ្ញាណ។
១០. រាប់ និងផ្តល់វត្ថុផ្សេងៗរហូតដល់១០មុខ ពេលដែលគេពុំបានសួរតាមលំដាប់លំដោយ។
១១. បង្ហាញនូវចំនួនរហូតដល់១០ នៅពេលដែលគេពុំបានសួរតាមលំដាប់លំដោយ។
១២. រាប់ចំនួនរហូតដល់លេខ១០ នៅពេលគេពុំបានសួរតាមលំដាប់លំដោយ។
១៣. សរសេរលេខរហូតដល់លេខ១០ នៅពេលគេហៅឱ្យសរសេរតាមអានចោះៗ។
១៤. សរសេរលេខរហូតដល់លេខ ១០ ទៅតាមលំដាប់លំដោយយ៉ាងត្រឹមត្រូវ។
១៥. សរសេរលេខដែលបាត់ដែលនៅពីខាងមុខ និងខាងក្រោយរហូតដល់លេខ១០។
១៦. ធ្វើលេខបូកងាយៗពីវត្ថុផ្សេងៗត្រឹមចំនួន១០(ដោយពុំចាំបាច់សរសេរលើក្រដាស)។
១៧.ធ្វើលេខបូកងាយៗពីវត្ថុផ្សេងត្រឹមចំនួន១០នៅលើក្រដាស ដោយមានប្រើសញ្ញាធូត ។
១៨. ផ្តល់ឱ្យចំនួនពិតប្រាកដរបស់វត្ថុនានារហូតដល់២០ នៅពេលដែលគេសួរ។
១៩. បន្ថែមចំនួនពីចំនួន១១ រហូតដល់២០( ឧទាហរណ៍ ១១= ១០ & ១)។
២០. ចង្អុលលេខរហូតដល់លេខ២០ នៅពេលគេសួរតាមលំដាប់លំដោយ។
២១. រៀបរាប់ចំនួនលេខរហូតដល់លេខ ២០ នៅពេលគេពុំបានសួរតាមលំដាប់លំដោយ។
២២. សរសេរលេខរហូតដល់លេខ២០ នៅពេលដែលគេហៅឱ្យសរសេរតាមអាន។
២៣. សរសេរលេខរហូតដល់លេខ២០តាមលំដាប់លំដោយ។
២៤. សរសេរលេខដែលបាត់នៅពីមុខ និងពីក្រោយលេខ១៩។
២៥. រាប់លេខម្តង១០រហូតដល់លេខ១០០ (១០ ២០ ៣០ ៤០.......១០០)។
២៦. ដាក់លេខ១០ៗដើម្បីឱ្យបានលេខ ១០ ២០ ៣០ ៤០ .......១០០)។
២៧. បញ្ចូល(ភ្ជាប់)ពេលវេលាជាមួយនឹងសកម្មភាពប្រចាំថ្ងៃ។

២៨. ប្រាប់ ឬ បង្ហាញនៅលើប្រតិទិន ឬ តារាងឈ្មោះនៃថ្ងៃ នៅពេលដែលគេសួរថា តើថ្ងៃនេះជាថ្ងៃអ្វី តើថ្ងៃស្អែកជា ថ្ងៃអ្វី ហើយតើថ្ងៃម្សិលមិញជាថ្ងៃអ្វី។

២៩. ប្រាប់ ឬធ្វើកាយវិការពីអ្វីដែលគេបានធ្វើពីព្រលឹមរហូតដល់ពេលចូលគេងតាមលំដាប់លំដោយ។

៣០. ប្រាប់អាយុរបស់ខ្លួន នៅពេលដែលគេសួរ។

៣១. ប្រាប់ ឬធ្វើកាយវិការពីចំនួនថ្ងៃក្នុងមួយសប្តាហ៍។

៣២. ប្រាប់ពីចំនួនខែក្នុងមួយឆ្នាំ។

៣៣. បង្ហាញពីកាលបរិច្ឆេទនៅលើប្រតិទិន។

៣៤. ផ្លាស់ប្តូរកាលបរិច្ឆេទ និងខែនៅលើប្រតិទិន។

៣៥. ប្រាប់ពីតួនាទីរបស់ទ្រនិចនាឡិកាវែង និងខ្លីនៅលើនាឡិកា នៅពេលដែលគេសួរ។

៣៦. បង្ហាញម៉ោងនៅលើនាឡិកាជាចំនួនម៉ោងគត់ នៅពេលដែលគេសួរ។

៣៧. ប្រាប់ម៉ោងពីចំនួនម៉ោងគត់ដោយមើលនាឡិការព្យួរជញ្ជាំង ឬនាឡិកាដៃ។

៣៨. បង្ហាញម៉ោងជាចំនួនកន្លះម៉ោងនៅលើនាឡិកា (ម៉ោង ៦:៣០ ម៉ោង ៧:៣០)។

៣៩. ប្រាប់ម៉ោងជាចំនួនកន្លះម៉ោង[៣០នាទី] (ម៉ោង ៣:៣០ ម៉ោង ៤:៣០)ដោយមើលនាឡិការព្យួរជញ្ជាំង ឬ នាឡិកាដៃ។

៤០. រៀបចំខ្លួនរួចរាល់ដើម្បីមកសាលារៀនឱ្យទាន់ពេលវេលា។

៤១. ស្គាល់ក្រដាសប្រាក់រៀល ១០០ ៥០០ ១០០០រៀល ឬប្រាក់ដុល្លា ពី១ដុល្លា ៥ដុល្លា ១០ដុល្លា។

៤២. រាប់ក្រដាសប្រាក់រៀល១០០រៀល ឱ្យបាន ៨០០រៀល ១០០០រៀល ២០០០រៀល ។ល។ ឬប្រាក់១ដុល្លាដើម្បីឱ្យបានចំនួន៨ដុល្លា ១០ដុល្លា ២០ដុល្លា ។ល។

៤៣. ដាក់ក្រដាសប្រាក់១០០០រៀល ឱ្យបាន ២០០០ ៣០០០ ៤០០០ ៥០០០រៀល ឬប្រាក់ដុល្លា១០ដុល្លាមួយដុំៗដើម្បីឱ្យបានចំនួន២០ដុល្លា ៣០ដុល្លា ៤០ដុល្លា ៥០ដុល្លា ... ១០០ ដុល្លា។

៤៤. អាប់លុយសម្រាប់ក្រដាស់១០០០រៀល ដោយប្រើ ក្រដាស់៥០០រៀល (៥០០+៥០០) ឬ១០ដុល្លាដោយប្រើប្រាស់ក្រដាស៥ដុល្លា (៥+៥)។

៤៥. អាប់ជាលុយដែលមានក្រដាស់៥០០ ១០០០ ២០០០រៀល ដោយប្រើក្រដាស ៥០០ និង១០០០រៀល ឬអាប់លុយរហូតដល់១០ដុល្លា ២០ដុល្លា ៥០ដុល្លាដោយប្រើប្រាស់ក្រដាសប្រាក់៥ ដុល្លា និង១០ដុល្លាបញ្ចូលគ្នា។

៤៦. ប្រាប់ពីឈ្មោះក្រដាសប្រាក់រៀល ឬដុល្លា។

| |
|---|
| ៤៧. ប្រាប់អំពីចំនួនទឹកប៉ុន្មានពែង ឬកែវទឹក ចំនួនអង្គរដែលគេត្រូវការដើម្បីដាក់ទៅក្នុងសម្ភារផ្ទះបាយដែលគេផ្តល់ឱ្យ។<br>៤៨. វាស់បរិមាណទឹកជាពែងដែលគេត្រូវការសម្រាប់ធុងតែ ឬ កាហ្វេ។<br>៤៩. ប្រាប់ឪពុកម្តាយ ឬសមាជិកគ្រួសាររបស់គេ នៅពេលគេមានអារម្មណ៍មិនស្រួលខ្លួន។<br>៥០. ប្រាប់ពីមធ្យោបាយធ្វើដំណើរផ្សេងៗ (កង់ ស៊ីក្លូ ម៉ូតូឌុប រ៉ឺម៉កកង់៣ រថយន្ត រថយន្តក្រុង រថភ្លើង យន្តហោះ)។<br>៥១. រៀបរាប់ឈ្មោះមធ្យោបាយធ្វើដំណើរផ្សេងៗ។<br>៥២. ឡើងជិះ ឬចុះពីមធ្យោបាយធ្វើដំណើរណាមួយនៅពេលដែលវាឈប់។ |

**សកម្មភាពការងារ**

១.បោសធូលីលើគ្រឿងសង្ហារឹម និងវត្ថុផ្សេងៗទៀតនៅក្នុងផ្ទះដោយប្រើប្រាស់អំបោសដែលធ្វើពីក្រណាត់។

២. ដាក់បន្លែទៅតាមប្រភេទរបស់វា និងដាក់វានៅតាមធ្នើរ ឬប្រអប់នីមួយៗនៅក្នុងទូទឹកកក។

៣. រៀបចំចាន និងកែវទឹកបានត្រឹមត្រូវនៅលើតុអាហារ ឬកម្រាលសម្រាប់អាហារពេលព្រឹក ឬ ពេលថ្ងៃត្រង់ ឬពេលល្ងាចនៅពេលដែលគេបានប្រាប់។

៤. លាងចាន និងកែវទឹកបន្ទាប់ពីទទួលទានអាហារ ឬអាហារសម្រន់រួច។

៥. បកសំបកបន្លែដូចជា សណ្តែក ខ្ទឹមបារាំង ដំឡូងស្វោរ ។ល។ នៅពេលដែលពុំមានកាំបិត ឬ ប្រដាប់ចិត។

៦.គ្រងទឹកពីក្បាលរ៉ូប៊ីណេដោយប្រើធុងយួរតូចៗនៅពេលដែលចាំបាច់ ឬនៅពេលសមាជិកគ្រួសារប្រើ។

៧. ដាក់សម្ភារផ្ទះបាយគរគ្នាបន្ទាប់ពីលាងសម្អាតរួច។

៨. រៀបចំអាហារសម្រន់ ឬម្ហូបអាហារផ្សេងៗដាក់ក្នុងចានសម្រាប់សមាជិកគ្រួសារ។

៩. បេះស្លឹកបន្លែពីបន្លែដែលគេទទួលទានស្លឹក។

១០.ជួយធ្វើការម្តាយ ឬឪពុក ឬបងប្អូននៅក្នុងផ្ទះបាយដោយជួយយករបស់របរសម្រាប់ដាំស្ល រ ដូចជាបន្លែ ឬគ្រឿងផ្សំ វាល់ទឹកសម្រាប់ឆុងតែ ឬកាហ្វេ នៅពេលគេប្រាប់។

**សកម្មភាពកំសាន្ត**

**នៅក្នុងផ្ទះ៖**

១. លេងល្បែងសាមញ្ញៗដូចជា ល្បែងឡើងឋានសួគ៌ឬល្បែងដើរសេះជាមួយកុមារ ២-៣នាក់ (មានក្បួនដាក់លាក់តែ ២ប៉ុណ្ណោះ)។

២. មើលកម្មវិធីក្នុងទូរទស្សន៍ពី១៥-៣០នាទី។

៣. រៀបចំប្លង់ឱ្យត្រូវតាមគំរូដែលគេផ្តល់ឱ្យ(៣-៨ចំណែក)។

៤. គូររូបភាពសាមញ្ញ និងផាត់ពណ៌។

៥. កាត់ និងបិតរូបភាពពីទស្សនាវដ្តីចាស់ៗដើម្បីធ្វើជាសៀវភៅរូបភាព ឬការងារសិល្បៈបិតរូប(នៅពេលដែលគេជួយកាត់)។

៦. ប្រមូលក្រដាសពណ៌ស្អិត(sticker)។

៧. ល្បែងប្រមូល(ស្លាកសញ្ញា) ឬផ្គុំរូបភាព។

៨. មើលរូបភាពក្នុងសៀវភៅ ឬសៀវភៅរឿងកំប្លែង។

៩. រៀបចំបន្ទប់ដោយដាក់របស់របរផ្សេងៗនៅតាមកន្លែងនីមួយៗរបស់វា។

១០. ឱ្យចំណីអាហារ និងថែទាំសត្វចិញ្ចឹម(នៅក្រោមការគ្រប់គ្រង)។

**ខាងក្រៅបន្ទប់**

១.លេងល្បែងហុច ឬបោះបាល់ និងចាប់បាល់។

២. បង្ហោះខ្លែង លេងកូនឃ្លី។

៣. លេងល្បែង ដូចជាលេងបាត់ពួន។

៤. ស្រោចដំណាំ ។

៥. ដើរលេងទៅខាងក្រៅ ឬទៅលេងផ្ទះមិត្តភក្តិនៅទីកន្លែងដែលរស់នៅជាមួយគ្នា។

៦. លេងបោះបាល់ចូលក្នុងកន្ត្រក។

៧. ឡើងរបារ ដើមឈើ ឬឡើងអ្វីមួយដែលស្រដៀងនេះ។

៨. លេងល្បែងលោតរំលងដោយមានក្បួនត្រឹមត្រូវ។

៩. ដើរផ្សារទិញឥវ៉ាន់ជាមួយមនុស្សចាស់។

១០. ចេញក្រៅទៅទទួលទាននៅភោជនីយដ្ឋាន ឬពាងល្ខោនជាមួយមនុស្សចាស់។

## ៦.៣.៣. ក្រុមៈ បឋមសិក្សា ២

| ក្រុមៈ បឋមសិក្សា ២ | |
|---|---|
| ផ្នែក និងលេខរៀង | សកម្មភាព |

**សកម្មភាពផ្ទាល់ខ្លួន ឬ សកម្មភាពសម្រាប់ការរស់នៅប្រចាំថ្ងៃ**

១. បត់ក្រដាសជា ៤ ចំណែក (ប៉ុនសៀវភៅសរសេរ)។

២. បត់ក្រដាសឱ្យត្រូវនឹងស្រោមសំបុត្រ និងបិទស្រោមសំបុត្រ។

៣. ប្រើប្រាស់បន្ទប់ទឹកដោយខ្លួនឯងនៅពេលដែលចាំបាច់ដោយពុំមាននរណាជួយ។

៤. ងូតទឹក (រាប់បញ្ចូលទាំងការដុសសាប៊ូ ដុសសម្អាតខ្លួន និងជូតខ្លួនដោយកន្សែងពោះគោ) បិទទ្វារ បន្ទប់ទឹកដោយខ្លួនឯង។

៥. សិតសក់

៦. សិតសក់ និងចងសក់ដោយប្រើកៅស៊ូ។

៧. ក្រងសក់ និងចងសក់ដោយប្រើកៅស៊ូ។

៨. លាបម្សៅឬឡេឬក្រែមនៅលើមុខ។

៩. ស្លៀកពាក់សម្លៀកបំពាក់ស្អាតបាត។

១០. ជ្រើសរើសសម្លៀកបំពាក់សមស្របទៅតាមអាកាសធាតុ។

១១. ស្លៀកពាក់ និងសម្អិតសម្អាងយ៉ាងស្អាតបាតនៅពេលចេញទៅក្រៅ។

១២. ដាក់សម្លៀកបំពាក់ដែលកខ្វក់សម្រាប់បោកគក់។

១៣.លាងសម្អាតប្រអប់សម្រាប់ដាក់អាហារ ចាន កែវ និងស្លាបព្រាដោយខ្លួនឯងនៅពេលទទួលទានរួច។

១៤. ប្រាប់សមាជិកគ្រួសារនៅពេលមានភ្ញៀវមកលេង។

១៥. ស្គាល់ខ្លួនឯងនៅក្នុងចំណោមក្មេងប្រុស ឬក្នុងចំណោមក្មេងស្រី។

១៦. ប្រាប់ថាខ្លួនគាត់ស្ថិតនៅក្នុងក្រុមណា។

**សកម្មភាពសង្គម**

១. សុំឱ្យគេហុចចានដែលខ្លួនចង់បាននៅពេលកំពុងទទួលទានអាហារដោយការគួរសម។

២. ដើរទៅហាងលក់ទំនិញ ឬទៅកន្លែងក្មេងលេង ឬផ្ទះរបស់មិត្តភក្តិក្នុងចំងាយ១គីឡូម៉ែត្រ និងត្រឡប់មកវិញ។

៣.ទិញវត្ថុចំនួន២មុខដែលគេសរសេរនៅលើស្លាក ពីហាងនៅក្បែរផ្ទះរបស់ខ្លួន(ប្រហែលជាមិនដឹងពី ចំនួនទេ)។

| |
|---|
| ៤. ណែនាំខ្លួនរបស់គេឱ្យនរណាម្នាក់ដែលមកលេងផ្ទះរបស់គេស្គាល់នៅពេលដែលចាំបាច់។<br>៥. ស្វាគមន៍ និងសុំឱ្យបងប្អូន ឬសមាជិកគ្រួសាររបស់មិត្តភក្តិអង្គុយលេងនៅពេលដែលពួកគេមកលេងផ្ទះ របស់ខ្លួន។<br>៦. អានសេចក្តីណែនាំដែលគេសរសេរនៅតាមផ្លូវ និងធ្វើតាមការណែនាំនោះ។<br>៧. អានស្លាកសញ្ញាផ្សេងៗ<br>៨. អានស្លាកតម្លៃទំនិញផ្សេងៗ(៤៨០០០រៀល ទៅ ៥១០០០រៀល ឬ ១០,២០ដុល្លារ ១១,២៥ដុល្លារ)។<br>៩. ទិញសម្ភារការិយាល័យពីហាងបានត្រឹមត្រូវនៅពេលដែលគេប្រាប់។<br>១០. ប្រាប់ ឬធ្វើកាយវិការដែលបង្ហាញថាគាត់ត្រូវការលុយសម្រាប់ជិះកង់ ស៊ីក្លូ ម៉ូតូឌុប រ៉ឺម៉កកង់បី ឡាន ឡានក្រុង រថភ្លើង យន្តហោះ។<br>១១. ចង្អុលឬប្រាប់ពីវត្ថុផ្សេងៗដែលគេជ្រើសរើសនៅក្នុងភោជនីយដ្ឋាន។<br>១២. ក្នុងពេលមានការសន្ទនា សួរសំណួរផ្សេងៗដែលពាក់ព័ន្ធ។<br>១៣. ចាំព័ត៌មាន ឬសារផ្សេងៗ ហើយប្រាប់ព័ត៌មាន ឬសារទាំងនោះបានត្រឹមត្រូវទៅឱ្យអ្នកដែលពាក់ព័ន្ធ(ជាពាក្យសំដី ឬកាយវិការ)<br>១៤. រៀបរាប់ពី២-៣ឃ្លាពីព្រឹត្តិការណ៍កន្លងមកដោយមិនពន្យាពេល (ប្រសិនបើធ្វើកាយវិការត្រូវធ្វើឱ្យងាយយល់តាមរយៈកាយវិការ និងសកម្មភាព)។<br>១៥. ធ្វើតាមការណែនាំជាពាក្យសំដីដើម្បីធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយនៅក្នុងអគារ។<br>១៦. ព្យាយាមបង្ហាញពីគំនិតផ្សេងៗដល់អ្នកដទៃ ឬរៀបរាប់ពីឧប្បត្តិហេតុនានាដោយខ្លួនឯង។<br>១៧. ប្រើប្រាស់កិរិយាស័ព្ទទាក់ទងនឹងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលបានត្រឹមត្រូវ។<br>១៨. និយាយឬសម្តែងកាយវិការច្បាស់ ឱ្យអ្នកដែលមិនស្គាល់ បានយល់។ |
| **ការរៀនសូត្រ**<br>១.អានឈ្មោះបន្លែ ផ្លែឈើ គ្រឿងផ្សំ គ្រាប់ធញ្ញជាតិសំលៀកបំពាក់។ល។<br>២.អានឈ្មោះថ្ងៃប្រចាំសប្តាហ៍។<br>៣.អានឈ្មោះខែ។<br>៤.ធ្វើលេខបូកងាយៗ(មួយខ្ទង់)ទោះបីគេសរសេរបញ្ឈរ ឬផ្តេក(២+៣)ក៏ដោយ។<br>៥.ធ្វើលេខដកងាយៗ(មួយខ្ទង់)។<br>៦.ធ្វើលេខបូក២ខ្ទង់ដោយពុំមានត្រាទុក។<br>៧.ធ្វើលេខដក២ខ្ទង់ដោយពុំមានខ្ចី(ត្រាទុក)។<br>៨.មានលទ្ធភាពភ្ជាប់ការគណនាផ្សេងៗទៅនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ។ |

៩.សរសេរឈ្មោះបន្លែ ផ្លែឈើ សម្លៀកបំពាក់ គ្រឿងផ្សំ ធញ្ញជាតិយ៉ាងហោចណាស់ចំនួន៥មុខ។
១០. សរសេរឈ្មោះថ្ងៃនៅពេលសរសេរតាមអាន។
១១. សរសេរឈ្មោះខែនៅពេលសរសេរតាមអាន។
១២. សរសេរឃ្លាដែលមាន២ព្យាង្គនៅពេលសរសេរតាមអាន។
១៣. សរសេរកាលបរិច្ឆេទ ខែ និងឆ្នាំនៅក្នុងសៀវភៅឬក្ដារឈ្នួនរបស់គេ
១៤. សរសេរកាលបរិច្ឆេទ ខែ និងឆ្នាំនៅពេលសរសេរលិខិតសុំច្បាប់សម្រាកឬមូលប្បទានប័ត្រ
១៥. ប្រាប់ ឬធ្វើកាយវិការថាតើថ្ងៃនេះជាថ្ងៃអ្វី។
១៦. ប្រាប់ម៉ោងនៅពេលទ្រនិចនាឡិការវែងចង្អុលលេខ៣ លេខ៦ លេខ៩ លេខ១២
១៧. ប្រាប់ម៉ោងជានាទី ដោយប្រាប់ជាចំនួន៥នាទីម្ដង។
១៨. រាប់ក្រដាសប្រាក់ដល់១០០០០រៀល ឬ ពី០១ ដុល្លារហូតដល់១០ដុល្លារ
១៩. អាប់លុយជា១០០រៀលពីលុយ៥០០ ឬ១០០០រៀល និង ១ដុល្លារសម្រាប់ក្រដាស៥ដុល្លារ និង១០ដុល្លារ
២០. បង់ថ្លៃវិក័យបត្ររហូតដល់១០០០០រៀល ដោយប្រើក្រដាស៥០០រៀល និង ១០០០ រៀល ឬ១០ដុល្លារដោយប្រើក្រដាស ១ដុល្លារ និង៥ដុល្លារ។
២១. រៀបក្រដាសប្រាក់(១០០រៀល ២០០រៀល) ឱ្យបាន១០០០រៀល ឬលុយដុល្លា (១ដុល្លារ៥ដុល្លារ)ដើម្បីឱ្យបាន១០ដុល្លារ។
២២. ឱ្យលុយរហូតដល់១០០០០រៀល ដោយរៀបជាក្រុម៥០០រៀល ឬ ឱ្យរហូតដល់១០ ដុល្លារដោយដាក់លុយជាក្រុម៥ដុល្លារ ពីក្រដាសប្រាក់លាយគ្នា។
២៣. ដាក់លុយដុំៗ(១០០០រៀល ២០០០រៀល ៥០០០រៀល ) ដើម្បីអាប់ ដូចជា១៣០០ រៀល ២១០០រៀល ៣២០០រៀល) ឬ(១ដុល្លារ ៥ដុល្លារ ១០ដុល្លារដើម្បីអាប់ដូចជាចំនួន ១៦ដុល្លារ ២១ដុល្លារ ៣២ដុល្លារ
២៤. អាប់លុយរហូតដល់៥០០០រៀល ឬ ៥ដុល្លារ។
២៥. អាប់លុយរហូតដល់១០០០០រៀល ឬ១០ដុល្លារ។
២៦. អាប់លុយរហូតដល់២០០០០រៀល ឬ ២០ដុល្លារ។
២៧. សរសេរចំនួនដែលធំជាង៤០០០រៀលដោយមានសញ្ញាក្បៀស។
២៨. ធ្វើលេខបូកដែលមានត្រាទុក (៣ជួរ ឬច្រើនជាងនេះដែលមាន២ខ្ទង់)។
២៩. ធ្វើលេខដកដែលមានខ្ចី[តម្លើងឬត្រាទុក](២ខ្ទង់ឬ៣ខ្ទង់)។
៣០. កំណត់ ឬដាក់ឈ្មោះចំណុះ១លីត្រឬ១គីឡូក្រាម។ វាស់ពាង ឬថ្លឹងដុំថ្ម។
៣១. ប្រាប់ពីផលប្រយោជន៍របស់ជញ្ជីង។

៣២. ប្តឹងបន្លែ និងធញ្ញជាតិទំងន់១គីឡូក្រាម។
៣៣. កំណាត់ឈ្មោះ ឬដាក់ឈ្មោះម៉ែត្របន្ទាត់ ឬម៉ែត្រសំពត់។

**ការធ្វើកិច្ចការផ្សេងៗ**

១. ឡើងជណ្ដើរដើម្បីសម្អាត ឬបោសធូលីលើផ្ទះ ឬលាបថ្នាំជញ្ជាំង។

២. ជូតសម្អាតសម្ភារផ្ទះបាយ ដោយប្រើក្រណាត់ស្អាត។

៣. បោសសម្អាតកម្រាលដោយប្រើអំបោសដែលមានដង។

៤. ទទួលទានអាហារដោយពុំមានហៅគេឱ្យជួយ។

៥. រើសយករបស់របរផ្សេងនៅផ្សារទំនើបទៅតាមការសរសេរ ឬបញ្ជីរូបភាព ហើយយករបស់របរទាំងនោះ ទៅកាន់កន្លែងគិតលុយ។

៦. អានវិក្កយបត្រ បណ្ណទូទាត់ទំនិញ

៧. សរសេរកំណត់ហេតុខ្លីៗ បញ្ជីរាយនាមមុខទំនិញនៅពេលគេហៅសរសេរតាមអាន

៨. អានឬសរសេរសារនៅក្នុងទូរស័ព្ទ

៩. ទៅផ្សារ ឬហាងនានាដើម្បីទិញម្ហូបអាហារផ្សេងៗ។

១០. ចាក់រូបផ្កាដោយប្រើអំបោះ និងម្ជុល។

១១. លាងអង្ករ និង ធញ្ញជាតិផ្សេងៗទៀត

១២. ឆុងតែ ឬកាហ្វេ ឬរៀបចំទឹកផ្លែឈើ

១៣. រៀបចំអាហារសម្រន់ងាយៗដូចជានំប៉ុងសាំងវិច ពងទាចៀន អាហារគ្រាម ស្ករគ្រាប់។

១៤. ចិតបន្លែជាបំណែកតូចៗ។

១៥. ចិតសំបកដំឡូង ត្រសក់ និងបន្លែផ្សេងៗទៀតនៅពេលគេមានតម្រូវការ។

១៦. រៀបចំសម្លបន្លែ ឬ សម្លនំបញ្ចុក។

១៧. បង្កាត់ភ្លើង ចង្ក្រានឧស្ម័ន ឬ ធ្យូង ឬ ឧស្ម័នស្ងួត ដោយខ្លួនឯង

១៨. រៀបចំអាហារពេលព្រឹកសម្រាប់សមាជិកគ្រួសារ។

១៩. រៀបចំចាន ស្លាបព្រានៅលើតុបាយមុនពេលញ៉ាំអាហារថ្ងៃត្រង់ ឬអាហារពេលល្ងាច។

២០. រៀបចំសម្អាតតុបាយក្រោយពេលទទួលទានអាហាររួចហើយ។

២១. បោសសម្អាតធូលីលើគ្រឿងសង្ហារឹម ទូចាន និងសម្ភារផ្សេងៗទៀតដោយប្រើអំបោសបោសធូលី។

២២. ជូតសម្អាតកម្រាលដោយប្រើក្រណាត់កន្ទបសើម។

២៣. លាងសម្អាតសម្ភារផ្ទះបាយ និងទុកដាក់សម្ភារទាំងនោះទៅតាមកន្លែងនីមួយៗ។

២៤. ជម្រះសម្លៀកបំពាក់សម្រាប់ហាលនៅលើស្នូបន្ទាប់ពីបោកគក់ហើយ។

២៥. បត់សម្លៀកបំពាក់បន្ទាប់ពីហាលរួច និងដាក់វានៅក្នុងទូខោអាវ។

២៦. មូរកន្ទេល ឬកម្រាលពូក ហើយដាក់វានៅតាមកន្លែងដែលត្រឹមត្រូវ។

២៧. រៀបចំកន្លែងគេងដោយខ្លួនឯង។

២៨. លាងអង្ករ និងបន្លែនៅពេលគេប្រាប់។

២៩. រៀបចំតុបតែងស្លឹកឈើ ផ្កាភ្ញីនៅមាត់ច្រក ឬបន្ទប់ក្នុងឱកាសបុណ្យទាន និងពិធីសង្គមផ្សេងៗ។

៣០. រៀបចំតុបតែងផ្កានៅក្នុងថូផ្កា។

៣១. ទៅកាន់ចំណតរថយន្ត ឬម៉ូតូកង់បី ឬគោយន្ត បានត្រឹមត្រូវដើម្បីធ្វើដំណើរទៅកាន់កន្លែងមួយដែល គេប្រាប់នៅតាមផ្លូវដែលគេធ្លាប់ទៅ។

៣២. សំគាល់ ឬចំណាំរថយន្តក្រុង ឬម៉ូតូកង់បី ឬគោយន្តដើម្បីធ្វើដំណើរទៅកាន់គោលដៅរបស់ខ្លួន។

៣៣. បង់ថ្លៃឡានក្រុង ឬម៉ូតូកង់បី ឬគោយន្ត ត្រឹមត្រូវ។

៣៤. រកកន្លែងអង្គុយ ឬសុំកន្លែងគេអង្គុយនៅពេលកំពុងធ្វើដំណើរនៅលើរថយន្តក្រុង ឬផ្ដល់កន្លែងអង្គុយរបស់ខ្លួនទៅឱ្យមនុស្សចាស់។

៣៥. ចុះពីរថយន្តក្រុង ឬរថយន្តឈ្នួល ឬម៉ូតូកង់បី ឬគោយន្តនៅចំណតដែលត្រូវចុះបានត្រឹមត្រូវ។

**សកម្មភាពកំសាន្ត**

**នៅក្នុងផ្ទះ៖**

១. មើលទូរទស្សន៍រឿងភាគ និងតាមដានសាច់រឿងតាមលំដាប់លំដោយ។

២. លេងល្បែងផ្សេងៗដូចជា Ludo ឬ chinese checkers សត្វពស់ និងឡើងជណ្តើរ។

៣. ជ្រើសរើសកាសែត ឬថាសចម្រៀង ឬប៉ុស្តិ៍វិទ្យុ និងបើកម៉ាស៊ីនចាក់ចម្រៀង ឬវិទ្យុដោយខ្លួនឯង។

៤. លេងឧបករណ៍តន្ត្រី ឬច្រៀងចម្រៀង។

៥. រាំ ឬទះដៃ ឬគោះជើងតាមចង្វាក់ភ្លេង(ឬបង្ហាញសញ្ញានៃភាពរីករាយពេលស្តាប់តន្ត្រី)។

៦. រៀបចំផ្កាដាក់ក្នុងថូ។

៧. មើលថែសត្វចិញ្ចឹម។

៨. ធ្វើសកម្មភាពផ្សេងៗ (ធ្វើកូនក្រមុំក្មេងលេង រៀបចំបណ្ណស្វាគមន៍ កាត់រូបភាពផ្សេងៗនៅលើក្រដាស ការងារដេរប៉ាក់)។

**នៅក្រៅផ្ទះ៖**

១.ធ្វើដំណើរកំសាន្តនៅខាងក្រៅដោយមានរៀបចំចម្អិនម្ហូបអាហារជាមួយគ្រួសារ ឬមិត្តភក្តិ (៣-៤)នាក់។

២.ចូលរួមនៅក្នុងការថែទាំរុក្ខជាតិ និងសួនច្បារ។

៣.ទៅក្រៅដើម្បីមើលភាពយន្តជាមួយសមាជិកគ្រួសារម្នាក់ ឬច្រើននាក់។

៤.លេងល្បែងផ្សេងៗដែលមានប្រើកីឡាវាយកូនបាល់(Racquet) ឬល្បែងបោះ(ទាត់)បាល់ផ្សេងៗទៀតដែលមានក្បួនត្រឹមត្រូវ។

៥.ហែលទឹកដោយមានការត្រួតពិនិត្យ។

៦.ជិះសេះដោយមានការត្រួតពិនិត្យ។

៧.ចេញទៅលើលេងនៅខាងក្រៅ(ដោយមានគេទៅជាមួយ)។

៨.ចូលរួមក្នុងការប្រមូលផ្តុំក្នុងសង្គមដែលមិត្តភក្តិ និងបងប្អូនបានរៀបចំ(មានគេទៅជាមួយ)។

## ៦.៣.៤.ក្រុមៈ ថ្នាក់បឋមសិក្សា – III

| ក្រុមៈ ថ្នាក់បឋមសិក្សា – III | |
|---|---|
| ផ្នែក និងលេខរៀង | សកម្មភាព |

**សកម្មភាពផ្ទាល់ខ្លួន ឬជីវិតរស់នៅប្រចាំថ្ងៃ**

១. ដាក់ ឬដេរឡេវអាវ។

២. ដេរសម្លៀកបំពាក់របស់ខ្លួនដោយប្រើម៉ាស៊ីនដេរ។

៣. នៅពេលដែលចាំបាច់យួរទឹកក្នុងធុងដែលមានចំណុះមធ្យម។

៤. កក់សក់នឹងសាប៊ូកក់សក់ និងសាប៊ូដុះខ្លួន ឬសាប៊ូម្សៅ។

៥. កោរពុកមាត់ដើម្បីឱ្យមើលទៅឃើញស្អាត(បុរស) ឬរៀបចំខ្លួនពេលមករដូវ(ស្ត្រី)។

៦. បោកគក់សំលៀកបំពាក់របស់ខ្លួនជាមួយនឹងសាប៊ូដុំ ឬសាប៊ូម្សៅ។

៧. អ៊ុតសម្លៀកបំពាក់ផ្ទាល់របស់ខ្លួន។

៨. ប្រើប្រេងក្រអូប ឬបង់រំរបួសប្រសិនបើចាំបាច់។

៩. ប្រាប់ ឬធ្វើកាយវិការពីជំងឺ និងការឈឺចាប់ភ្លាមៗដើម្បីទទួលបានជំនួយ។

១០. ធ្វើតាមការណែនាំរបស់គ្រូពេទ្យដោយពុំចាំបាច់គេរំលឹកក្នុងពេលមានជំងឺ។

១១. រៀបចំខ្លួនឱ្យបានស្អាតបាត និងត្រឹមត្រូវសម្រាប់ឱកាសផ្សេងៗ។

១២. ប្រើប្រាស់ទូរស័ព្ទ ឬទូរស័ព្ទដៃនៅពេលដែលចាំបាច់។

**សកម្មភាពសង្គម**

១.ជិះកង់ ឬដើរទៅណាមកណាដោយខ្លួនឯងសម្រាប់រយៈចំងាយ ១គីឡូម៉ែត្រពីផ្ទះ។

២. ជួយផ្លាស់ប្តូរទីកន្លែងគ្រឿងសង្ហារឹមធុនៗនៅក្នុងផ្ទះ ឬកន្លែងធ្វើការ។

៣. រកបង្គន់អនាម័យដោយខ្លួនឯង ដោយសួរគេដើម្បីរកបង្គន់នៅកន្លែងថ្មី(ដូចជាផ្ទះបងប្អូន ផ្ទះមិត្តភក្តិ ភោជនីយដ្ឋាន រោងភាពយន្ត ផ្សារទំនើប)។

៤. បញ្ជាទិញម្ហូបអាហារ(កុម្មង់)ម្ហូបអាហារដោយខ្លួនឯងនៅក្នុងភោជនីយដ្ឋាន។

៥. ឈរជាជួរ (ដើម្បីរង់ចាំទិញសំបុត្រ ឬសម្ភារនានានៅក្នុងផ្សារទំនើប)។

៦. សួររកទិសដៅនៅពេលដែលចាំបាច់។

៧. ចូលរួមជាមួយអ្នកដែលមានអាយុស្របាលៗគ្នា នៅក្នុងសកម្មភាពសង្គម ឬសាសនាដោយពុំចាំបាច់ឱ្យមានការចាប់អាម្មណ៍ដែលមិនចាំបាច់។

៨. បញ្ជាក់ពីការព្រួយបារម្ភនៅពេលមានបញ្ហា និងស្វែងរកជំនួយ។

៩. ការពារខ្លួននៅពេលមានការរំខាន ឬការកេងប្រវ័ញ្ចពីអ្នកផ្សេងទៀត។

១០. អាន ឬមើលសញ្ញាសំគាល់សំខាន់ៗដើម្បីធ្វើការងារឱ្យបានសម្រេច។

| |
|---|
| ១១. ជ្រើសរើស ទិញ ចុះហត្ថលេខា និងផ្ញើកាតឬបណ្ណទៅឱ្យមនុស្សសំខាន់ៗនៅពេលចូលឆ្នាំ និងឱកាសផ្សេងៗទៀត។<br>១២. រក្សាការណាត់ជួប។<br>១៣. ប្រាប់ពេលវេលានៅពេលគេសួរ។<br>១៤. ទៅរោងកុន ឈរបន្តគ្នាជាជួរ និងទិញសំបុត្រសម្រាប់មើលកុន។<br>១៥. ទទួលទូរស័ព្ទ និងឆ្លើយតប ឬផ្តល់ព័ត៌មានទៅឱ្យអ្នកផ្សេងនៅពេលគេប្រាប់ឱ្យធ្វើ។<br>១៦. ប្រាប់ឈ្មោះទីក្រុង ឬ ខេត្ត ឬ ស្រុក ឬ ភូមិដែលគេកំពុងរស់នៅ។ |
| **ការសិក្សា**<br>១. អានឃ្លាដែលមាន២ពាក្យ។<br>២. អានឃ្លាសាមញ្ញៗ។<br>៣. ធ្វើលេខបូកដែលមាន២ខ្ទង់ ដោយមានត្រាទុក។<br>៤. ធ្វើលេខដកដែលមាន២ខ្ទង់ ដោយមានខ្ចី(ត្រាទុក)។<br>៥. ចេះ(ស្គាល់) អំពីតារាងទី៥។ Aware of table 5<br>៦. ប្រើប្រាស់តារាងទី៥សម្រាប់គោលបំណងនៃពេលវេលា ឬលុយកាក់<br>៧. សរសេរឃ្លាសាមញ្ញ នៅពេលគេប្រាប់។<br>៨. រៀបចំបញ្ជីមុខទំនិញផ្សេងៗដើម្បីទៅទិញនៅតាមហាងនានា។<br>៩. ចម្លងអត្ថបទមួយកថាខណ្ឌ(៥-៦ឃ្លា)ដោយមានសញ្ញាខណ្ឌ។<br>១០. សរសេរលិខិតមួយច្បាប់។<br>១១. កំណត់ពេលវេលានៅលើនាឡិកា។<br>១២. ទិញរបស់របរផ្សេងៗដែលមានតម្លៃរហូតដល់៥ដុល្លារ។<br>១៣. អាប់លុយដែលមានទឹកប្រាក់រហូតដល់៥ដុល្លារ។<br>១៤. អាប់លុយដែលមានទឹកប្រាក់រហូតដល់១០ដុល្លារ។<br>១៥. អាប់លុយដែលមានទឹកប្រាក់រហូតដល់២០ដុល្លារ។<br>១៦. ទិញរបស់របរផ្សេងៗដែលមានតម្លៃរហូតដល់១.០០០រៀល។<br>១៧. អាប់លុយដែលមានទឹកប្រាក់រហូតដល់៥០០រៀល។<br>១៨. អាប់លុយដែលមានទឹកប្រាក់រហូតដល់១.០០០រៀល។<br>១៩. កំណត់ ឬប្រាប់ការថ្លឹងទំងន់ដុំថ្មដែលមានទំង់២គីឡូក្រាម ៥គីឡូក្រាម ១០គីឡូក្រាម។<br>២០. ថ្លឹងរបស់របរផ្សេងៗដូចជាស្រូវ ធញ្ញជាតិ បន្លែទម្ងន់ ២គីឡូក្រាម ៥គីឡូក្រាម ១០គីឡូក្រាម<br>២១. សំគាល់ដុំថ្មដែលមាន ទម្ងន់១ ឬ២គីឡូក្រាម ១ ឬ៤គីឡូក្រាម។ |

| |
|---|
| ២២. ថ្លឹងអង្ករ គ្រាប់ធញ្ញជាតិ បន្លែដែលមានទម្ងន់១ ឬ២គីឡូក្រាម ១ ឬ៤គីឡូក្រាម។<br>២៣. វាស់ក្រណាត់ជាម៉ែត្រ។<br>២៤. បូកតម្លៃបន្ថែមទៅលើបណ្ណទូទាត់ចំណាយរហូតដល់៥ដុល្លារ។<br>២៥. បូកតម្លៃបន្ថែមទៅលើបណ្ណទូទាត់ចំណាយរហូតដល់១០ដុល្លារ។<br>២៦. បង់វិក្កយបត្ររហូតដល់២០ដុល្លារនៅក្នុងទម្រង់ណាមួយដែលមានក្រដាសប្រាក់១ដុល្លារ ៥ដុល្លារ និង ១០ដុល្លារ។<br>២៧. បង់វិក្កយបត្ររហូតដល់៥០ដុល្លារនៅក្នុងទម្រង់ណាមួយដែលមានក្រដាសប្រាក់១ដុល្លារ ៥ដុល្លារ ១០ដុល្លារ និង២០ដុល្លារ។<br>២៨. បន្ថែមតម្លៃទៅលើប័ណ្ណទូទាត់ចំណាយរហូតដល់៥០០រៀល។<br>២៩. បន្ថែមតម្លៃទៅលើបណ្ណទូទាត់ចំណាយរហូតដល់១.០០០រៀល។<br>៣០. បង់វិក្កយបត្រដែលមានតម្លៃរហូតដល់ទៅ១.០០០រៀលនៅក្នុងទម្រង់ណាមួយដែលមានក្រដាសប្រាក់១០០ រៀល និង៥០០រៀល។<br>៣១. បង្ហាញផ្នែកនានានៃរាងកាយដូចជាសួត បេះដូង ក្រលៀននៅលើរូបរាងរបស់មនុស្ស ឬកន្លែលដែលសមស្របនៅលើរាងកាយ។<br>៣២. រៀបរាប់ដោយប្រើពាក្យសាមញ្ញៗពីតួនាទីរបស់សួត បេះដូង ក្រលៀន និងសរសៃឈាម។<br>៣៣. ប្រាប់ឈ្មោះព្រះមហាក្សត្រ ឬ នាយករដ្ឋមន្ត្រីរបស់ប្រទេសកម្ពុជា។<br>៣៤. ប្រាប់ឈ្មោះប្រទេស ខេត្តផ្ទាល់របស់នរណាម្នាក់.<br>៣៥. ប្រាប់ ឬ បង្ហាញពីប្រភពទឹកខុសៗគ្នា។<br>៣៦. ប្រាប់ ឬ បង្ហាញពីប្រភពផលិតផលទឹកដោះគោ ឬ ប្រេងឆា។<br>៣៧. ប្រាប់ ឬបង្ហាញពីផលប្រយោជន៍នៃការសម្លាប់មេរោគ។ |
| **សកម្មភាពការងារ**<br>១. សម្អាតសម្ភារផ្ទះបាយជាមួយនឹងសាប៊ូម្សៅ និងសាប៊ូទឹក( សាប៊ូលាងចាន )។<br>២. ជូតកម្រាលដោយក្រណាត់សើម។<br>៣. ទុកដាក់អង្ករ និងធញ្ញជាតិនៅក្នុងធុងដាច់ដោយឡែកបន្ទាប់ពីទិញមក។<br>៤. ចិតបន្លែឱ្យបានត្រឹមត្រូវសម្រាប់មុខម្ហូបខុសៗគ្នា។<br>៥. រៀបចំធុងតែ ឬកាហ្វេ ឬទឹកផ្លែឈើ។<br>៦. ចេះប្រើចង្ក្រានប្រេងកាត ឬចង្ក្រានហ្គាស។<br>៧. ចេះប្រើប្រាស់ឧបករណ៍ផ្ទះបាយ (ដូចជាប្រដាប់ចិត ប្រដាប់បក កាំបិតចិតសំបក ប្រដាប់កោសដូង ប្រដាប់កិនចំណីអាហារ [blander] ម៉ាស៊ីនក្រឡុក)។ |

| |
|---|
| ៨. រៀបចំនំសាំងវិច ពងទាចៀន(អូមឺឡែត) អាហារស្រួយ ស្ករគ្រាប់។<br>៩. រៀបចំបាយ បបរ នំបញ្ចុក។<br>១០. រៀបចំចាន ចានទាប ។ល។ នៅលើតុបាយ។<br>១១. បោកគក់សម្លៀកបំពាក់ជាមួយសាប៊ូដុំ ឬសាប៊ូម្សៅ។<br>១២. បត់សម្លៀកបំពាក់ និងដាក់គរគ្នានៅក្នុងទូ។<br>១៣. រៀបចំគ្រែសម្រាប់គេង។<br>១៤. ទិញបន្លែ និងសម្ភារប្រើប្រាស់ក្នុងផ្ទះផ្សេងៗទៀតពីហាងដែលនៅជិតផ្ទះ។<br>១៥. រៀបចំខ្លួនឱ្យបានរួចរាល់ដើម្បីទៅធ្វើការងារឱ្យទាន់ពេលវេលា។<br>១៦. រៀបរាប់ពីមធ្យោបាយធ្វើដំណើរផ្សេងៗ។<br>១៧. ទិញសំបុត្រពីកន្លែងលក់សំបុត្រ។<br>១៨. បំពេញព័ត៌មានផ្ទាល់ខ្លួននៅក្នុងពាក្យសុំ (ឧទាហរណ៍ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន ឈ្មោះឪពុក ភេទ ភាសានិយាយ)។<br>១៩.ប្រើទម្រង់ធនាគារនៅក្រោមការត្រួតពិនិត្យរបស់អាណាព្យាបាល នៅពេលដែលចាំបាច់។<br>២០. បំពេញទម្រង់សម្រាប់កក់សំបុត្រយន្តហោះ។<br>២១. មើលថែសមាជិកគ្រួសារពេលដែលគេមានជំងឺនៅពេលដែលគេសុំ។<br>២២. អនុវត្តការសង្គ្រោះបឋមងាយៗ (រំបង់ លាបប្រេងកូឡានៅកន្លែងដែលឈឺ) |
| **សកម្មភាពកំសាន្ត**<br>**នៅក្នុងផ្ទះ៖**<br>១. បង្ហាញការចាប់អារម្មណ៍ទៅលើការគូររូប និងការផាត់ពណ៌<br>២. លេងល្បែងការ៉ុម carom ល្បែងបៀ និងល្បែង Chinese checkers។<br>៣. ស្តាប់បទចម្រៀងដែលបានជ្រើសរើសនៅក្នុងកាសែត ឬCDឬជ្រើសរើសស្ថានីយ៍វិទ្យុដែលគេផ្តល់ឱ្យនៅពេល ណាមួយ ឬជ្រើសរើសកម្មវិធីទូរទស្សន៍ដែលសមស្របដោយខ្លួនឯង។<br>៤. ចូលរួមនៅក្នុងការរៀបចំតុបតែងលម្អផ្ទះសម្រាប់ពិធីបុណ្យ ឬជប់លៀង ឬឱកាសពិសេសនានា។<br>៥. ស្លៀកពាក់ និងផាត់មុខ ឬសកម្មភាពណាមួយដើម្បីរក្សាសម្រស់ឱ្យស្អាត។<br>៦. រៀបចំបាច់ផ្កាដោយមានផ្កាស្រស់ ឬផ្កាសិប្បនិមិត្ត (ផ្កាជ័រ ឬផ្កាក្រដាស)។<br>៧. ចំណាយពេលវេលាជាមួយមិត្តភក្តិដើម្បីជជែកពីឧប្បត្តិហេតុផ្សេងៗក្នុងសង្គម។<br>៨. ចូលរួមក្នុងការរៀបចំរូបតុក្កតា បណ្ណស្វាគមន៍ និងសកម្មភាពមុខរបរណាមួយ។<br>៩. ចូលរួមនៅក្នុងការងារដេរប៉ាក់ ការប៉ាក់ឱន ការចាក់(សម្លៀកបំពាក់) ។ល។<br>១០. ជ្រើសរើសរូបថតកីឡាករ តារាភាពយន្ត តែមឬកំណត់ត្រា ដែលពេញចិត្ត និងរៀបចំរូបទាំងនោះនៅ |

ក្នុង សៀវភៅរូបថត។

**ក្រៅផ្ទះ៖**

១. ឡើងភ្នំ ឬដំណើរបោះតង់

២. ជិះកង់ទៅលេងមិត្តភក្តិ ឬបងប្អូន ឬធ្វើដំណើរតាមរថយន្តក្រុងដើម្បីទៅលេងពួកគេក្នុងចំងាយ៣គីឡូម៉ែត្រ។

៣. ចូលរួមមើលការប្រគុំតន្ត្រី ឬទៅមើលការសម្តែងសិល្បៈ ឬភាពយន្ត។

៤. បង្ហោះខ្លែង ឬលេងបោះអង្គុញ ឬល្បែងលោតឈូសជើងម្ខាង។

៥. មើលថៃវុក្ខជាតិ - សួនច្បារ។

៦. អភិវឌ្ឍ ឬបង្ហាញការចាប់អារម្មណ៍ចំពោះជំនាញបោកចំបាប់ ដូចជាយូដូ ការ៉ាត់តេ តៃក្វាន់ដូរ ។ល។ ឬ និង ហាត់រាំ ឬលេងតន្ត្រី។

៧. ចេញទៅញ៉ាំអាហារនៅតាមភោជនីយដ្ឋានជាមួយមិត្តភក្តិ។

៨. លេងល្បែងដែលមានប្រើរ៉ាកែត (វាយសី វាយកូនបាល់នៅលើតុ វាយកូនបាល់នៅលើស្មៅ ។ល។)

៩. លេងបាល់ដែលមានក្បួនច្បាប់ត្រឹមត្រូវ (បាល់បោះ បាល់ទាត់ ។ល។)។

១០. ហែលទឹកដោយខ្លួនឯង។

១១. ជិះសេះដោយខ្លួនឯង។

# មេរៀនទី៧

# វិធីសាស្ត្របង្រៀន

## វត្ថុបំណង៖

- ដើម្បីយល់និងរៀនសូត្រពីវិធីផ្សេងៗក្នុងការបង្រៀន។
- ដើម្បីបង្រៀនកុមារពិការនៅថ្នាក់មត្តេយ្យសិក្សានិងបឋមសិក្សា។

## វិធីសាស្ត្របង្រៀនកុមារមានបញ្ហាខ្សោយបញ្ញា៖

វិធីសាស្ត្របង្រៀនកុមារខ្សោយបញ្ញាមានសារៈសំខាន់ណាស់ ទោះបីវាមានការលំបាកចំពោះបរិស្ថាននៃការរៀនសូត្រក៏ដោយ ក៏កុមារមានបញ្ហាខ្សោយបញ្ញាអាចរៀនចេះ ព្រមទាំងមានសមត្ថភាពទទួលបាននិងប្រើប្រាស់ព័ត៌មានថ្មីៗផងដែរ។ មានវិធីសាស្ត្របង្រៀនតាមបែបបរិយាបន្នជាច្រើនដែលអាចជួយកុមារទាំងអស់ឱ្យរៀនបានចេះដឹង និងមានវិធីសាស្ត្របង្រៀនជាក់លាក់មួយចំនួនដែលមានប្រយោជន៍សម្រាប់បង្រៀនសិស្សដែលមានបញ្ហាខ្សោយបញ្ញា ដូចជា៖

1. បង្ហាញអំពីខ្លឹមសារសំខាន់ៗតាមលំដាប់លំដោយនៃមេរៀនដែលត្រូវរៀន និងបង្រៀនដោយបញ្ជាក់ពីគោលគំនិតសំខាន់ និងផ្តល់ឱកាសសម្រាប់ការអនុវត្តន៍ជាក់ស្តែងនូវជំនាញ និងគោលគំនិតថ្មីៗ។
2. ផ្តល់ឯកសារ ឬមេរៀនឱ្យបានច្បាស់លាស់មុនពេលចាប់ផ្តើមបង្រៀនដើម្បីឱ្យពួកគេបានអានជាមុន។
3. ផ្តល់ឯកសារ ឬមេរៀនជាផ្នែកៗ និងណែនាំដល់សិស្ស ពីរបៀបអានឯកសារ ឬមេរៀនគន្លឹះឱ្យបានស៊ីជម្រៅ ប្រសើរជាងឱ្យពួកគេសិក្សាឯកសារ ឬមេរៀនទូទៅច្រើន។
4. គ្រូត្រូវណែនាំសិស្សឱ្យបានច្បាស់ តាមលំដាប់លំដោយ ទាំងការនិយាយពន្យល់ ការសរសេរ និងការអនុវត្ត ។ ឧទាហរណ៍ ពេលធ្វើលំហាត់ ធ្វើពិសោធន៍ឬប្រើប្រាស់កុំព្យូទ័រ ។
5. សិស្សអាចរៀនបានច្រើន និងទទួលបានលទ្ធផលកាន់តែល្អ ប្រសិនបើមានការប្រើប្រាស់បច្ចេកវិទ្យាជំនួយ។
6. ប្រើប្រាស់ការពិពណ៌នាជាពាក្យសម្តីឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីបន្ថែមទៅលើខ្លឹមសារឯកសារ ឬមេរៀននានាដែលបានបង្ហាញនៅលើក្តារខៀន ឬផ្ទាំងរូបភាព។
7. ប្រើភាសាដែលមានលក្ខណៈខ្លី ច្បាស់ និងងាយយល់។
8. ពង្រឹងការរៀនសូត្រ ដោយប្រើប្រាស់ឧទាហរណ៍ជាក់ស្តែង និងផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ។

9. បង្ហាញព័ត៌មានទៅតាមទម្រង់ផ្សេងៗដូចជាឯកសារ សន្លឹកកិច្ចការ ផ្ទាំងរូបភាព វីដេអូ ដើម្បីឱ្យឆ្លើយតបទៅនឹងរបៀបនៃការរៀនខុសៗគ្នារបស់កុមារ។
10. ប្រើប្រាស់វិធីបង្រៀនផ្សេងៗ ដើម្បីឱ្យសិស្សទទួលបានព័ត៌មានដោយមិនចាំបាច់តែតាមរយៈការអានតែមួយមុខប៉ុណ្ណោះ។ ចូរប្រើប្រាស់ តារាង ដ្យាក្រាម បញ្ជីក្រាប គោលគំនិតជាដើម សម្រាប់បង្ហាញខ្លឹមសារមេរៀនដល់សិស្ស។
11. រៀបចំដ្យាក្រាមឱ្យមានរបៀបរៀបរយ និងប្រើប្រាស់ពណ៌ដែលសមស្របដើម្បីបង្ហាញពីភាពខុសគ្នា និងបញ្ជាក់ពីចំណុចសំខាន់ៗ។
12. ត្រូវប្រាកដថា មានបញ្ជីពាក្យបច្ចេកទេសដែលសិស្សចាំបាច់ត្រូវរៀនមុនពេលបង្រៀន។
13. គ្រូត្រូវមានកំណត់ត្រា និងផែនការជួយសិស្សទាំងឡាយដែលមានបញ្ហាក្នុងការសរសេរ ការស្តាប់ និងការផ្ទង់អារម្មណ៍។
14. សិស្សអាចចាប់បានខ្លឹមសារមេរៀនត្រឹមត្រូវតាមលំដាប់លំដោយ ប្រសិនបើពួកគេបានអាន និងសិក្សាមេរៀននោះ លើសពី១ដង។
15. បញ្ជាក់សារឡើងវិញចំពោះឃ្លា និងការណែនាំសំខាន់ៗក្នុងពេលបង្រៀន ។
16. ការបង្រៀនជាលក្ខណៈបុគ្គលមានសារៈសំខាន់ រួមទាំងមិត្តអប់រំមិត្តផងដែរ ។
17. សិស្សអាចផ្តល់ចម្លើយតាមរយៈពាក្យសម្តីជាជាងជាលាយលក្ខណ៍អក្សរ សម្រាប់កិច្ចការសំណេររបស់ពួកគេ ។
18. ការណែនាំជាលក្ខណៈបុគ្គលមានប្រយោជន៍សម្រាប់សិស្សខ្សោយបញ្ញាអំពីការប្រើឧបករណ៍ក្នុងមន្ទីរពិសោធន៍ឬកុំព្យូទ័រ ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់កុមារ។

## វិធីសាស្ត្របង្រៀនកុមារពិបាកសិក្សាមុខវិជ្ជា

មានវិធីសាស្រ្តបង្រៀនជាច្រើនដែលអាចជួយកុមារទាំងអស់ឱ្យរៀនសូត្របានចេះដឹង ប៉ុន្តែមានវិធីសាស្ត្រជាក់លាក់មួយចំនួនដែលមានប្រយោជន៍សម្រាប់បង្រៀនសិស្សពិបាកសិក្សាមុខវិជ្ជា៖

1. ចែកជូនឯកសារ ឬមេរៀនសម្រាប់អានឱ្យបានច្បាស់លាស់មុនពេលចាប់ផ្តើមបង្រៀន ដើម្បីឱ្យសិស្សបានអានជាមុន។ ផ្តល់ការណែនាំដល់សិស្សអាននូវចំណុចសំខាន់ៗនៃឯកសារ ឬមេរៀនប្រសើរជាជាងការអានអត្ថបទទាំងស្រុង។
2. គ្រូត្រូវណែនាំ ឬពន្យល់សិស្សឱ្យបានច្បាស់អំពីនីតិវិធី និងជំហាននីមួយៗ តាមរយៈការនិយាយ និងការសរសេរ។ ឧទាហរណ៍ ពេលធ្វើលំហាត់នៅក្នុងបន្ទប់ពិសោធន៍ ឬធ្វើកិច្ចការនៅក្នុងកុំព្យូទ័រជាដើម ។
3. សិស្សអាចទទួលផលប្រយោជន៍ច្រើនពីការប្រើប្រាស់បច្ចេកវិទ្យាជំនួយ។

4. ប្រើប្រាស់ការពិពណ៌នាជាពាក្យសម្តីឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីបំពេញបន្ថែមទៅលើខ្លឹមសារឯកសារ ឬមេរៀនដែលបានបង្ហាញនៅលើក្តារខៀន ឬផ្ទាំងរូបភាព។ សិស្សលំបាកក្នុងការសិក្សាមុខវិជ្ជា តែងចូលចិត្តរៀនតាមរយៈការស្តាប់។
5. បង្ហាញព័ត៌មានទៅតាមទម្រង់ផ្សេងៗដូចជាឯកសារ សន្លឹកកិច្ចការ ផ្ទាំងរូបភាព វីដេអូ ដើម្បីឱ្យឆ្លើយតបទៅនឹងរបៀបនៃការរៀនខុសៗគ្នារបស់កុមារ។
6. ប្រើប្រាស់វិធីបង្រៀនផ្សេងៗ ដើម្បីឱ្យសិស្សទទួលបានព័ត៌មានដោយមិនចាំបាច់តែតាមរយៈការអានតែមួយមុខប៉ុណ្ណោះ។ ចូរប្រើប្រាស់ តារាង ដ្យាក្រាម បញ្ជីក្រាប គោលគំនិតជាដើម សម្រាប់បង្ហាញខ្លឹមសារមេរៀនដល់សិស្ស។
7. រៀបចំដ្យាក្រាមឱ្យមានរបៀបរៀបរយ និងប្រើប្រាស់ពណ៌ដែលសមស្របដើម្បីបង្ហាញពីភាពខុសគ្នា និងបញ្ជាក់ពីចំណុចសំខាន់ៗ។
8. ត្រូវប្រាកដថា មានបញ្ជីពាក្យបច្ចេកទេសដែលសិស្សចាំបាច់ត្រូវរៀនមុនពេលបង្រៀន។
9. គ្រូត្រូវមានកំណត់ត្រា និងផែនការជួយសិស្សទាំងឡាយដែលមានបញ្ហាក្នុងការសរសេរ ការស្តាប់ និងការផ្ចង់អារម្មណ៍។
10. សិស្សអាចចាប់បានខ្លឹមសារមេរៀនត្រឹមត្រូវតាមលំដាប់លំដោយ ប្រសិនបើពួកគេបានអាន និងសិក្សាមេរៀននោះ លើសពី១ដង។
11. ការពន្យល់សារឡើងវិញមានសារៈសំខាន់ណាស់សម្រាប់សិស្សពិបាកសិក្សាមុខវិជ្ជា។ គ្រូបង្រៀនត្រូវតែរំលឹក និងណែនាំសារឡើងវិញចំពោះចំណុចសំខាន់ៗតាមមធ្យោបាយផ្សេងទៀត ។
12. សិស្សពិបាកក្នុងការសិក្សាមុខវិជ្ជានឹងទទួលបានផលប្រយោជន៍ពីការពិភាក្សាទៅលើការគ្រប់គ្រងពេលវេលា និងការរៀបចំដោះស្រាយបញ្ហាផ្សេងៗ ។ ការពិភាក្សាទាំងនេះ ត្រូវបញ្ចូលទៅក្នុងសកម្មភាពពិភាក្សាដៃគូ ។
13. បង្រៀនបំប៉នបន្ថែម ជាតម្រូវការចាំបាច់របស់កុមារពិបាកក្នុងការសិក្សាមុខវិជ្ជា ។
14. សិស្សពិបាកក្នុងការសិក្សាមុខវិជ្ជាអាចផ្តល់ចម្លើយតាមរយៈពាក្យសម្តីជាជាងលាយលក្ខណ៍អក្សរ សម្រាប់កិច្ចការសំណេររបស់ពួកគេ ។
15. កុំធ្វើឱ្យសិស្សមានការបារម្ភពីការធ្វើខុសឆ្គង ការសួរសំណួរ ឬការធ្វើកិច្ចការ ជាដើម។
16. ការណែនាំជាលក្ខណៈបុគ្គលមានប្រយោជន៍សម្រាប់សិស្សពិបាកសិក្សាមុខវិជ្ជាអំពីការប្រើឧបករណ៍ក្នុងមន្ទីរពិសោធន៍ឬកុំព្យូទ័រ ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់កុមារ។

## វិធីសាស្ត្របង្រៀនកុមារអូទីសឹម

1. កុមារអូទីសឹមត្រូវការធ្វើកិច្ចការដែលជាទម្លាប់ដដែលៗ និងមានរបៀបរៀបរយតាមលំដាប់លំដោយ៖ កិច្ចការដែលជាទម្លាប់ដដែលៗ និងមានរបៀបរៀបរយតាមលំដាប់លំដោយ ប្រៀបបីដូចជាកញ្ចក់មួយសម្រាប់កុមារអូទីសឹមដែលមានបញ្ហាខ្សោយគំហើញ ឬវាប្រៀបបីដូចជាឧបករណ៍ជំនួយស្តាប់សម្រាប់កុមារអូទីសឹមដែលមានបញ្ហាខ្សោយក្នុងការស្តាប់។ វាមានសារៈ

សំខាន់ណាស់នៅពេលដែលបរិស្ថានសិក្សានិងរបៀបបង្រៀនមានការរៀបចំនិងស៊ីសង្វាក់គ្នាល្អ ធ្វើឱ្យការសិក្សារបស់កុមារកាន់តែប្រសើរ។

2. *ការរៀបចំតាមលំដាប់លំដោយនៃ "ពេលវេលា" សម្រាប់កុមារអូទីសឹម៖* កាលវិភាគប្រចាំថ្ងៃគឺជាឧបករណ៍មួយសម្រាប់ការរៀបចំ «ពេលវេលា» សម្រាប់កុមារអូទីសឹម។ គ្រូបង្រៀនត្រូវមានកាលវិភាគប្រចាំថ្ងៃរបស់ខ្លួននៅលើក្ដារខៀន ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់ទេសម្រាប់ជួយកុមារអូទីសឹម។ កុមារទាំងនេះភាគច្រើនទាមទារឱ្យមានកម្មវិធីប្រចាំថ្ងៃផ្ទាល់ខ្លួនដោយមានលក្ខណៈលម្អិត។ ជាទូទៅពួកគាត់ត្រូវការកាលវិភាគខ្លីៗសម្រាប់រយៈពេលជាក់លាក់។
3. *ការរៀបចំ "ទីកន្លែង" សម្រាប់កុមារអូទីសឹម៖* កុមារអូទីសឹមអាចរៀនបានប្រសើរនៅក្នុងថ្នាក់ដែលមានការរៀបចំតុបតែង កំណត់ទីកន្លែងឱ្យបានច្បាស់លាស់ដោយបិទសញ្ញាសម្គាល់នៅលើគ្រឿងសង្ហារឹម សម្ភារ និងកម្រាល។ គ្រូត្រូវរៀបចំឱ្យមានកន្លែងសម្រាប់សិស្សធ្វើកិច្ចការបុគ្គល ដៃគូ និងក្រុម។ គ្រូបង្រៀនត្រូវរៀបចំកិច្ចការសិស្សដាក់តាមប្រភេទ និងទីកន្លែងដាច់ពីគ្នាចំពោះកិច្ចដែលត្រូវធ្វើ និងកិច្ចការដែលបានធ្វើរួចហើយ។
4. *ការរៀបចំកុមារអូទីសឹមឱ្យផ្លាស់ប្ដូរទម្លាប់ប្រចាំថ្ងៃ៖* ទោះបីជាការរៀបចំថ្នាក់រៀនភាគច្រើនពុំមានការផ្លាស់ប្ដូរក៏ដោយ ក៏ប៉ុន្តែកកាលវិភាគត្រូវតែមានការផ្លាស់ប្ដូរជានិច្ច។ គ្រូត្រូវគិតពីព្រឹត្តិការណ៍ទាំងអស់ដែលអាចកើតមាន ហើយដែលអាចប៉ះពាល់ទៅលើសកម្មភាពប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន។ ឧទាហរណ៍៖ ការប្រមូលផ្ដុំគ្នា និងការប្រកាសអាសន្នពេលមានអគ្គីភ័យ វាតែងតែបង្កឱ្យមានភាពភ័យខ្លាចសម្រាប់កុមារអូទីសឹម។ ការប្រើប្រាស់កាលវិភាគប្រចាំថ្ងៃឬការបង្កើតជាសាច់រឿងនិទានបែបសង្គម អាចមានប្រយោជន៍ក្នុងការកាត់បន្ថយភាពភ័យខ្លាចរបស់កុមារអូទីសឹម។
5. *កុមារអូទីសឹមមានការលំបាកក្នុងការយល់ភាសា៖* ការលំបាកផ្នែកភាសាគឺជាសញ្ញាសំគាល់របស់កុមារអូទីសឹម។ កុមារអូទីសឹមមានការលំបាកក្នុងការយល់ពាក្យពេចន៍ដែលវែង។ ចូរផ្ដល់ការណែនាំមួយ ឬពីរចំណុចម្ដងច្បាស់ៗ និងសាមញ្ញ។ ជាការលំបាកខ្លាំងណាស់សម្រាប់កុមារអូទីសឹម បើសិនជាគ្រូផ្ដល់ការណែនាំច្រើនក្នុងពេលតែមួយដល់គាត់ដូចជា៖ «យកសៀវភៅគណិតវិទ្យារបស់ប្អូនចេញពីលើតុ បើកទំព័រទី៥៩ ធ្វើលំហាត់ចំនួន១០ដំបូង ហើយចូរចាំថាត្រូវសរសេរឈ្មោះរបស់ប្អូននៅលើក្រដាស បន្ទាប់មកដាក់វានៅក្នុងកន្ត្រក»ជាដើម។ ជាធម្មតាបរិមាណព័ត៌មានដែលគេអាចវិភាគបានមានលក្ខណៈខុសគ្នាពីកុមារម្នាក់ទៅកុមារម្នាក់ទៀត ប៉ុន្តែចូរចងចាំថាកុមារអូទីសឹមមានការលំបាកក្នុងការវិភាគភាសានិយាយ។
6. *កុមារអូទីសឹមប្រើចក្ខុវិញ្ញាណក្នុងការយល់ភាសា៖* ទោះបីជាផ្នែកភាសារបស់ខួរក្បាលទទួលរងផលប៉ះពាល់ក៏ដោយ ក៏ផ្នែកចក្ខុវិញ្ញាណនៅធម្មតា ឬមានករណីជាច្រើនអាចមានការលូតលាស់ល្អទៀតផង។ កុមារអូទីសឹមវិភាគព័ត៌មានតាមរយៈចក្ខុវិញ្ញាណបានល្អប្រសើរជាងតាមការនិយាយផ្ទាល់មាត់។ ខ្លឹមសារព័ត៌មានត្រូវអមជាមួយការបង្ហាញដោយរូបភាព។

7. *កុមារអូទីសឹមមានការលំបាកក្នុងការយល់ភាសាសញ្ញា៖* គ្រូបង្រៀនត្រូវដឹងពីការអនុញ្ញាត ឬមិនអនុញ្ញាតនៅពេលដែលថ្នាក់រៀនមានការឡូឡាខ្លាំងពេក។ ចូរចាំថាសិស្សអូទីសឹមទំនងជាមិនយល់ទេ អំពីការក្រឡេកមើលរបស់គ្រូបង្រៀនក្នុងន័យថាគ្រូបង្រៀនចង់ឱ្យសិស្សនៅក្នុងថ្នាក់រក្សាភាពស្ងៀមស្ងាត់។ ក្នុងពេលដែលសិស្សផ្សេងៗទៀតយល់យ៉ាងឆាប់រហ័សដោយឈប់ជជែកគ្នា ក្នុងខណៈដែលកុមារអូទីសឹមនៅតែបន្តជជែកគ្នា ហើយពេលនោះពួកគេនឹងមានការងឿងឆ្ងល់ថាហេតុអ្វីបានជាពួកគេមានបញ្ហា។ គ្រូបង្រៀនចាំបាច់ត្រូវនិយាយត្រង់ៗប្រាប់កុមារនោះពីអ្វីដែលអ្នកចង់ឱ្យគេធ្វើ ឧទាហរណ៍ "ធីតាឈប់ជជែកគ្នា" ។
8. *កុមារអូទីសឹមមានការពិបាកក្នុងយល់ទំនាក់ទំនងសង្គមមនុស្ស៖* កុមារអូទីសឹមមានការលំបាកយល់ពីគំនិតរបស់មនុស្សម្នាក់ផ្សេងទៀត។ ពួកគេប្រហែលជាមិនយល់ថា តើយោបល់ឬសកម្មភាពរបស់គេមានផលប៉ះពាល់ទៅលើអារម្មណ៍របស់អ្នកដទៃយ៉ាងដូចម្តេចទេ។ ត្រូវបង្រៀនបំណិនផ្នែកសង្គមដល់កុមារពិការអូទីសឹម ដូចជា៖ ការស្វាគមន៍ ប្តូរវេនរង់ចាំ និងការចែករំលែកគំនិតយោបល់ជាដើម ។
9. *កុមារអូទីសឹមជាទូទៅគឺជាអ្នកគោរពច្បាប់ទម្លាប់៖* សិស្សអូទីសឹមដែលមានសម្បទាខ្ពស់ ជាធម្មតាត្រូវបានគេដឹងថាជានគរបាលនៅក្នុងថ្នាក់រៀន។ នៅពេលដែលបង្កើតបានច្បាប់ណាមួយ គេតែងតែអនុវត្តតាមច្បាប់នោះជារឿយៗ ហើយប្រសិនបើមិត្តរួមថ្នាក់ណាមួយមិនអនុវត្តតាមច្បាប់ វាតែងតែបង្កឱ្យមានភាពតានតឹងសម្រាប់កុមារអូទីសឹម។ ចំណុចនេះតែងបង្កឱ្យមានជម្លោះជាមួយមិត្តភក្តិ ដោយសារសិស្សរួមថ្នាក់យល់ឃើញថាកុមារអូទីសឹមជាមនុស្សពូកែទូលពិត (និយាយរអេចរអូច ឬរាយការណ៍)។
10. *កុមារអូទីសឹមជាច្រើនមានបញ្ហាទាក់ទងនឹងញាណ៖* កុមារអូទីសឹមជាច្រើនឆាប់មានរំញោចទាក់ទងនឹងការប៉ះ ការមើល ឬការស្តាប់សំឡេង ឬការបញ្ចូលគ្នានូវផ្នែកមួយចំនួនក្នុងផ្នែកទាំងពីរនេះឬទាំងអស់តែម្តង។ ពួកគេប្រហែលជាឆាប់មានរំញោច (លើសញ្ញាណ) ចំពោះពន្លឺនៅក្នុងបន្ទប់រៀន ឬកន្លែងផ្សេងៗនៅក្នុងសាលារៀន។ ញាណដែលទាក់ទងនឹងបញ្ហាខាងលើ អាចមានលក្ខណៈធ្ងន់ធ្ងរខ្លាំងដែលបណ្តាលឱ្យកុមារគេចចេញពីស្ថានភាពទាំងនោះឬអាចនឹងបង្កឱ្យមានអាកប្បកិរិយាមិនល្អកាន់តែខ្លាំងឡើងថែមទៀត។ ការព្យាបាលដោយឱ្យកុមារអូទីសឹមធ្វើសកម្មភាពនៅក្នុងសាលារៀនអាចមានប្រយោជន៍ក្នុងការកំណត់ពីគន្លឹះនានាដែលទាក់ទងនឹងញាណរបស់ពួកគេ។ ឪពុកម្តាយរបស់កុមារក៏អាចផ្តល់នូវព័ត៌មានសំខាន់ៗ ថាតើកូនរបស់ខ្លួនមានការយល់ឃើញដូចម្តេចចំពោះបរិស្ថានជាក់លាក់នានា។
11. *កុមារអូទីសឹមផ្តោតលើចំណុចលម្អិតជាជាងចំណុចរួម៖* កុមារអូទីសឹមមានទំនោរផ្តោតទៅលើចំណុចលម្អិតជាក់លាក់ជាជាងទៅលើរូបភាពធំទូលាយ។ ឧទាហរណ៍៖ ការពិភាក្សាពីគំនិតសំខាន់ៗរបស់សាច់រឿង វាមានការលំបាកសម្រាប់កុមារប្រភេទនេះ។ ពួកគេអាចផ្តោតទៅលើចំណុចលម្អិតៗដែលមិនទាក់ទងទៅនឹងសាច់រឿងជំនួសវិញ។ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យឯកសារណែនាំផ្សេងៗមានលក្ខណៈសាមញ្ញ។ ឧទាហរណ៍៖ នៅពេលបង្រៀនអក្សរ

ឬពាក្យ គឺគ្រាន់តែប្រើបណ្ណអក្សរ ឬបណ្ណពាក្យធម្មតាដោយមិនចាំបាច់មានស៊ុំក្បាច់ក្បូរ រចនាព័ទ្ធជុំវិញនោះទេ។

12. *កុមារអូទីសឹមមានការលំបាកយ៉ាងខ្លាំងក្នុងការវិភាគព័ត៌មានទូទៅ៖* បំណិនក្នុងការរៀនសូត្រនៅក្នុងស្ថានភាពមួយ មិនទំនងជាអាចអនុវត្តនៅកន្លែងមួយផ្សេងទៀតបានទេ។ គ្រូបង្រៀនត្រូវបង្រៀនបំណិនឱ្យបានច្រើន ដែលអាចយកទៅអនុវត្តបាននៅកន្លែងជាច្រើន និងជាមួយមនុស្សផ្សេងៗគ្នាជាច្រើន ដូចជាបំណិនសង្គម ភាសា និងការសិក្សា។
13. *កុមារអូទីសឹមគឺជាអ្នកគិតត្រង់ៗ៖* ភាសាប្រៀបធៀបដូចជា "ភ្លៀងដូចគេចាក់ទឹក" គឺមិនអាចស្តាប់យល់ទេសម្រាប់កុមារអូទីសឹម។ គ្រូបង្រៀនចាំបាច់ត្រូវបង្រៀនកុមារពីន័យត្រង់ៗរបស់ប្រយោគនានាដែលមិត្តរួមថ្នាក់ និងគ្រូបង្រៀនប្រើប្រាស់ជាទូទៅដូចជា "ភ្លៀងដូចគេចាក់ទឹក" ទៅជា "ភ្លៀងខ្លាំង" វិញ។
14. *កុមារអូទីសឹមជាទូទៅគឺជាជនរងគ្រោះពីការសម្លុតធ្វើបាបពីកុមារដទៃ៖* កុមារអូទីសឹមគឺជាគោលដៅសម្រាប់ការសម្លុតធ្វើបាបពីកុមារដទៃដើម្បីជាការសើចសប្បាយ។ មនុស្សពេញវ័យចាំបាច់ត្រូវដឹងពីបញ្ហារបស់កុមារអូទីសឹម។ ការអប់រំមិត្តរួមថ្នាក់ពីអូទីសឹមនិងពន្យល់ពីមូលហេតុនៃអាកប្បកិរិយានានា មានប្រយោជន៍ក្នុងការជួយកុមារអូទីសឹម។
15. *កុមារអូទីសឹមគឺជាកុមារដែលមានលក្ខណៈពិសេស និងអស្ចារ្យ៖* កុមារអូទីសឹមគឺជាប្រភេទកុមារតែមួយគត់ដែលគិត និងយល់ឃើញថាពិភពលោកមានលក្ខណៈដាច់ដោយឡែកជាងកុមារភាគច្រើន។

## វិធីសាស្ត្រផ្សេងៗសម្រាប់បង្រៀនកុមារពិការ

កុមារពិការម្នាក់ៗមានភាពខុសៗគ្នា ហើយត្រូវការការបង្រៀនជាលក្ខណៈបុគ្គលផ្សេងៗគ្នា។ មានគោលការណ៍គ្រឹះមួយចំនួនដែលត្រូវចងចាំក្នុងចិត្តជាប់ជានិច្ច ក្នុងពេលផ្តល់បំណិនណាមួយដល់កុមារ។

### គ្រូបង្រៀនត្រូវចងចាំពីគោលការណ៍គ្រឹះទាំង៤ដូចខាងក្រោម៖

1. *ពីងាយទៅពិបាក៖* ការចាប់ផ្តើមពីជំហានមួយដែលនាំកុមារឆ្ពោះទៅរកភាពជោគជ័យ គឺការលើកទឹកចិត្តឱ្យកុមារខំប្រឹងរៀនបន្ថែមទៀត។ គ្រូបង្រៀនត្រូវជៀសវាងការកំណត់គោលដៅខ្ពស់ពេកសម្រាប់កុមារ។ នៅពេលដែលកុមាររៀនពីជំហានសាមញ្ញៗ ហើយគេត្រូវណែនាំពីជំហានដែលមានលក្ខណៈស្មុគស្មាញ ឬពិបាកៗ បន្តិចម្តងៗ។ ឧទាហរណ៍ នៅពេលបង្រៀនពីរបៀបដុសធ្មេញ គេត្រូវចាប់ផ្តើមពីធ្មេញមុខហើយបន្តយឺតៗទៅធ្មេញនៅផ្នែកម្ខាងទៀត និងបន្ទាប់មកទៅធ្មេញផ្នែកខាងក្នុង។

2. *ពីអ្វីដែលដឹងទៅអ្វីដែលមិនធ្លាប់ដឹង៖* ចំណេះដឹងមានស្រាប់របស់កុមារជាចំណុចចាប់ផ្តើមសម្រាប់ការបង្រៀនបំណិនផ្សេងៗ។ ឧទាហរណ៍ គ្រូបង្រៀនត្រូវបង្រៀនកុមារឱ្យអានពាក្យ "ឆ្កែ" គេត្រូវចាប់ផ្តើមដោយការសម្គាល់រូបភាពរបស់សត្វ"ឆ្កែ" ដោយផ្គូផ្គងជាមួយពាក្យ"ឆ្កែ" ហើយបន្ទាប់មកឱ្យកុមាររកពាក្យដែលសរសេរថា"ឆ្កែ" ដោយធ្វើការជ្រើសរើសក្នុងចំណោមពាក្យពីរ និងច្រើនជាងពីរ។
3. *ពីរូបីទៅអរូបី៖* កុមារពិការមានការលំបាកក្នុងការធ្វើតាមគោលគំនិតអរូបី។ ការបង្រៀនត្រូវមានឧទាហរណ៍ជាក់ស្តែងអមជាមួយ ។ ឧទាហរណ៍ ដើម្បីឱ្យកុមារយល់ពីគោលគំនិតរបស់"ថ្ងៃអាទិត្យ" ដែលមានលក្ខណៈអរូបី សូមភ្ជាប់វាជាមួយសកម្មភាពផ្សេងៗដែលគេធ្វើនៅថ្ងៃអាទិត្យដូចជា "ប៉ាមិនទៅធ្វើការទេ" "ដូច្នេះកូនក៏នឹងមិនចាំបាច់ទៅសាលារៀនដែរ"។
4. *ពីចំណុចរួមទៅជាចំណុចជាក់លាក់៖* គោលគំនិតនៃការបង្រៀន គ្រូបង្រៀនត្រូវតែណែនាំជារួមសិន។ ឧទាហរណ៍ មុនពេលបង្រៀនពីផ្នែកផ្សេងៗនៃរាងកាយរបស់មនុស្ស គ្រូបង្រៀនត្រូវណែនាំពីរាងកាយទាំងមូលជាមុនសិន "នេះគឺជាមនុស្ស" "នេះគឺជាភ្នែករបស់គាត់" ។ល។ ដូចគ្នានេះដែរ គ្រូបង្រៀនត្រូវតែបង្ហាញពាក្យទាំងមូលសិន មុនពេលបង្ហាញអក្សរផ្សេងៗដែលផ្សំបានជាពាក្យដែលត្រូវបង្រៀន (ករណីបង្រៀនអំពី វាក្យសព្ទ ការញែកព្យាង្គ និងសូររបស់ពាក្យ)។

## ដំណាក់កាលនៃការរៀនសូត្រ៖

1. *ការទទួលបានចំណេះដឹង៖* នេះគឺជាដំណាក់កាលដែលកុមាររៀនសូត្រកិច្ចការមួយ។ ដើម្បីទទួលបានជោគជ័យ គេត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការរៀបចំ ខ្លឹមសារ កិច្ចការ និងបរិស្ថានសិក្សា ក្នុងរបៀបជារចនាសម្ព័ន្ធ។ ឧទាហរណ៍ ប្រសិនបើគ្រូបង្រៀនកំពុងបង្រៀនកុមារម្នាក់ពីបំណិនក្នុងការប្រើប្រាស់បង្គន់ ក្នុងដំណាក់កាលនៃការទទួលបានចំណេះដឹងនេះ បង្គន់និងពាក្យគន្លឹះដែលគេប្រើត្រូវតែដូចគ្នា ហើយផ្សារភ្ជាប់ជាមួយនឹងសកម្មភាពដូចជា ការក្រោកពីគ្រែ ឬញ៉ាំទឹកដោះគោ មុនពេលទៅបង្គន់ជាដើម។ ចំណុចនេះអាចជួយកុមារទទួលបានជោគជ័យក្នុងការទទួលបានចំណេះដឹងទាំងនេះ។
2. *ការថែរក្សាបំណិន៖* នៅពេលដែលគេមើលឃើញថាកុមារមានសមត្ថភាពអនុវត្តកិច្ចការដែលគ្រូបានបង្រៀន ហើយកុមារអនុវត្តត្រឹមត្រូវជាប់ជាប្រចាំបាន៨០ភាគរយ យើងហៅចំណុចនេះថាជាការថែរក្សាបំណិន។
3. *ការប្រើប្រាស់បំណិនជាទូទៅ៖* នេះគឺជាដំណាក់កាលដែលកុមារមានសមត្ថភាពអាចអនុវត្តជំនាញបានត្រឹមត្រូវនៅក្នុងស្ថានភាពណាមួយដែលគ្រូបង្រៀនផ្តល់ឱ្យ។ នោះគឺសមត្ថភាពក្នុងការផ្ទេរនូវអ្វីដែលគេបានទទួល និងថែរក្សាចំណេះដឹងនៅក្នុងស្ថានភាពមួយទៅស្ថានភាពមួយផ្សេងៗទៀតដែលមានលក្ខណៈស្រដៀងគ្នា។ ប្រសិនបើយើងយកឧទាហរណ៍ដូចគ្នាទាក់ទងនឹងការបណ្តុះបណ្តាលពីការប្រើប្រាស់បង្គន់ នៅពេលដែលកុមារអាចប្រើប្រាស់បង្គន់ជាក់

លាក់មួយបានត្រឹមត្រូវស្មើរតែគ្រប់ពេលវេលា ដូច្នេះ កុមារនោះត្រូវការការបណ្តុះបណ្តាលពីការប្រើប្រាស់បង្គន់ផ្សេងៗទៀត ឧទាហរណ៍បង្គន់នៅតាមទីសាធារណៈ ការយល់ដឹងពីពាក្យផ្សេងៗទៀតដែលគេប្រើប្រាស់សម្រាប់បង្គន់។ ប្រសិនបើកុមារនោះអាចធ្វើដូច្នេះបានដោយជោគជ័យ យើងអាចនិយាយបានថាបំណិននេះអាចយកទៅប្រើប្រាស់បានជាទូទៅហើយ ។

**ការជំរុញលើកទឹកចិត្តៈ**

ការជំរុញលើកទឹកចិត្ត គឺជាចំណុចសំខាន់ជាងគេបំផុតមួយចំពោះការបណ្តុះជំនាញណាមួយដែលបានផ្តល់រង្វាន់សមស្របចំពោះកុមារសម្រាប់ការព្យាយាមដែលកុមារទាំងនោះធ្វើបានជោគជ័យ។ រង្វាន់ទាំងនេះអាចមានជាស្នាមញញឹម ឬអង្អែលស្មាថ្មមៗ រហូតដល់ការជូនរង្វាន់ធំដល់កុមារអាស្រ័យទៅលើស្ថានភាពជាក់ស្តែង។ កុមារម្នាក់ដែលគេស្នើសុំឱ្យក្រោកឈរឡើង ហើយទៅបិទទ្វារត្រូវបានគេសរសើរថា"ល្អ" ឬ"ញញឹមដាក់"សម្រាប់លើកទឹកចិត្តចំពោះគាត់ដែលធ្វើតាមការណែនាំ។ កុមារម្នាក់ផ្សេងទៀត បានច្របាច់ទឹកផ្លែឈើមួយកែវដោយខ្លួនឯងទៅតាមការណែនាំនៃការបណ្តុះបណ្តាល អាចទទួលបានទឹកផ្លែឈើនោះជារង្វាន់។

**វិធីបង្រៀនៈ** មានវិធីជាច្រើនដែលគេប្រើប្រាស់ជាទូទៅសម្រាប់ការបង្រៀនមានដូចជា ការជួយតម្រង់អាកប្បកិរិយា ការណែនាំ ការធ្វើគំរូ ការបំបែកកិច្ចការតាមលំដាប់លំដោយ និងការបន្ថយការជួយ។ ថ្វីបើពាក្យខាងលើហាក់ដូចជាមានលក្ខណៈបច្ចេកទេស ក៏យើងទាំងអស់គ្នាបានប្រើប្រាស់ពាក្យទាំងនេះនៅក្នុងជីវិតប្រចាំថ្ងៃនៅពេលដែលយើងបង្រៀន។

1. *ការជួយតម្រង់អាកប្បកិរិយាៈ* វិធីនេះមានន័យថាជាការផ្តល់ការលើកទឹកចិត្តដល់កុមារចំពោះអាកប្បកិរិយាមួយ ដើម្បីឆ្ពោះទៅរកអាកប្បកិរិយាដែលយើងចង់បាន។ ដូច្នេះប្រសិនបើយើងចង់ឱ្យកុមារម្នាក់មានឥរិយាបថសុំទឹក នោះយើងត្រូវជួយគេដោយព្យាយាមនិយាយពាក្យខាងដើមថា"ទឹ"។ បន្តិចម្តងៗ យើងអាចជួយកុមារនោះ ដោយអាចឱ្យគាត់និយាយបានជាចុងក្រោយថា "ទឹក"។
2. *ការណែនាំៈ* គឺជាការជួយយ៉ាងសាមញ្ញដល់កុមារក្នុងកម្រិតផ្សេងៗដោយផ្អែកលើចំណេះដឹង ឬសមត្ថភាពមានស្រាប់របស់កុមារ។ ការជួយតម្រង់ផ្នែកអវយវៈ ឧទាហរណ៍ ការជួយកាន់ដៃជើងរបស់គាត់ ដាក់ស្តែងដូចជា ចាប់ដៃកុមារឱ្យកាន់ម្ហូប ឬឱ្យចាប់ម្ហូបដាក់មាត់របស់គាត់ ។ ឧទាហរណ៍ម៉្យាងទៀត ដោយប្រាប់កុមារឱ្យចាប់ម្ហូបនឹងដៃ ឬដោយប្រាប់ឱ្យគាត់ដាក់ម្ហូបក្នុងមាត់។
3. *ការធ្វើគំរូៈ* គឺជាការជំរុញតាមរយៈការបង្ហាញគំរូឱ្យមើល នៅពេលដែលកុមារកំពុងមើលការបង្ហាញនូវសកម្មភាពនៃកិច្ចការដែលគេចង់បាន ដើម្បីឱ្យកុមារធ្វើតាមគឺជាការផ្តល់គំរូ។ ឧទាហរណ៍ៈ គ្រូដុសធ្មេញរបស់ខ្លួនឯងផ្ទាល់ឱ្យកុមារមើលបន្ទាប់មកឱ្យកុមារនោះធ្វើតាម ។ កុមាររៀនសូត្របានយ៉ាងឆាប់រហ័សប្រសិនបើអ្នកធ្វើគំរូឱ្យកុមារមើល។ ការបង្រៀនបំណិន

មួយនេះគ្រូអាចជ្រើសរើសមិត្តភក្តិរបស់គេធ្វើជាគំរូ។វិធីទាំងនេះគឺជារបៀបបង្រៀនដែលមានប្រសិទ្ធភាពបំផុត។

4. *ការបំបែកកិច្ចការតាមលំដាប់លំដោយ៖* មានន័យថាជាការបំបែកកិច្ចការមួយឱ្យទៅជាកិច្ចការតូចៗតាមលំដាប់លំដោយពីដើមដល់ចប់។ យើងអាចបង្រៀនដំណាក់កាលដំបូងមុន ឬចាប់ផ្តើមដំណាក់កាលចុងក្រោយមុន ប៉ុន្តែដាច់ៗពីគ្នា។ ឧទាហរណ៍ ការងូតទឹក មានកិច្ចការតូចៗដូចជា ចាក់ទឹក ដុះសាប៊ូ ចាក់ទឹករហូតជ្រះសាប៊ូ ជូតសម្អាតខ្លួនជាមួយនឹងកន្សែង ។ល។ កុមារត្រូវការបំណិននៅគ្រប់ដំណាក់កាលនៃភារកិច្ចតូចៗ ។
5. ការកាត់បន្ថយការជួយ៖ គឺជាវិធីកាត់បន្ថយក្នុងការជួយដល់កុមារ រហូតដល់កុមារអាចធ្វើកិច្ចការដោយភាពម្ចាស់ការ។

## ឧទាហរណ៍មួយចំនួនក្នុងការបង្រៀនកុមារពិការ

**ពិបាកក្នុងការស្តាប់៖ សញ្ញានិងលក្ខណៈសម្គាល់**

- មានការលំបាកក្នុងការវិភាគ និងចងចាំភាសាទាក់ទងទៅនឹងកិច្ចការនានា ប៉ុន្តែមិនមានបញ្ហាក្នុងការបកស្រាយ ឬរំឭកឡើងវិញនូវសូរសំឡេងដែលមិនមែនជាពាក្យសំដីនៅក្នុងបរិស្ថានជុំវិញខ្លួន ដូចជាសំលេងដូរតន្ត្រី ។ល។
- អាចវិភាគពីការគិត និងគំនិតផ្សេងៗយឺតៗ និងមានការលំបាកក្នុងការពន្យល់ពីការគិត និងគំនិតទាំងនោះ។
- ប្រកប និងបញ្ចេញសំឡេងមិនត្រឹមត្រូវ ឬប្រឡំចំពោះពាក្យដែលមានសូរស្រដៀងគ្នា។ (ត្រីនិងស្រី ស្រូតនិងច្រូត សាច់និងសាច ជិតនិងចិត ជាដើម)។
- អាចយល់ច្រឡំ ឬយល់ខុសចំពោះភាសាប្រៀបធៀប ការលេងពាក្យពេចន៍ និងពាក្យកំប្លុកកំប្លែង បកស្រាយពាក្យតាមន័យត្រង់ៗ។
- ឆាប់បែកអារម្មណ៍នៅពេលមានសំឡេង ឬមានការនិយាយឡូឡានៅជុំវិញខ្លួន។
- មានការពិបាកក្នុងការផ្ចង់អារម្មណ៍ឱ្យបានយូរ ឬពិបាកក្នុងការចងចាំចំពោះបទបង្ហាញ ឬការបង្រៀនផ្ទាល់មាត់។
- អាចបកស្រាយខុស ឬមានការលំបាកក្នុងការចងចាំចំពោះការណែនាំជាពាក្យសំដី។ ពិបាកក្នុងការអនុវត្តតាមការណែនាំដែលមានលក្ខណៈបន្តបន្ទាប់គ្នា។
- ពិបាកយល់ចំពោះប្រយោគដែលមានលក្ខណៈស្មុគស្មាញ ឬការនិយាយញាប់។
- ជាមនុស្សដែល«មិនអើពើ»ជាមួយអ្នកដទៃ ជាពិសេសនៅពេលដែលកុមារស្លុងអារម្មណ៍នឹងអ្វីមួយ។
- និយាយថា «អ្វី(ស្អីគេ)?»ជាញឹកញាប់បំផុត សូម្បីតែគេស្តាប់ឮនូវអ្វីដែលបាននិយាយច្រើនដងក៏ដោយ។

| ដំណោះស្រាយចំពោះកុមារពិបាកក្នុងការស្តាប់៖<br><br>• ប្រើការបង្ហាញ (រូបភាព សញ្ញា...)ច្រើនជាងការពន្យល់។<br>• បំពេញបន្ថែមទៅលើញាណដែលពុំមានការខូចខាតឱ្យបានច្រើនថែមទៀត (ប្រើប្រាស់អក្សរ សញ្ញា ឯកសារ ឬកាយវិការដែលអាចមើលឃើញច្បាស់)។<br>• ទុកពេលឱ្យបានច្រើន ពេលដាក់កិច្ចការអ្វីមួយឱ្យធ្វើ រួចអាចសួរនាំគាត់ថា «រួចរាល់ហើយឬនៅ?»។<br>• រៀបរៀងពាក្យឡើងវិញ ឬជួយពន្យល់បកស្រាយឡើងវិញ ចំពោះការណែនាំជាពាក្យសម្តី ឬជាលាយលក្ខណ៍អក្សរ មុនៗ ដែលអាចធ្វើឱ្យមានការច្រឡំ។<br>• បង្រៀនពាក្យជាលក្ខណៈអរូបី ឫសគល់នៃពាក្យ សទិសន័យ ឬពាក្យផ្ទុយ។<br>• ញែកឱ្យដាច់ពីគ្នារវាងការលើកដាក់សំឡេង និងសូរសំឡេង ផ្លាស់ប្តូរល្បឿនក្នុងការនិយាយ សង្កត់ ឬបញ្ជាក់ពាក្យសំខាន់ៗ។<br>• សួរសំណួរជាក់លាក់នៅពេលបង្រៀន ដើម្បីស្វែងយល់ថា តើពួកគេពិតជាយល់មែនឬទេ?<br>• ទុកពេលឱ្យពួកគេ៥-៦ វិនាទីដើម្បីឆ្លើយតប "ពេលវេលាសម្រាប់គិត"។<br>• ទម្លាប់ឱ្យសិស្ស និយាយប្រាប់ពីគោលគំនិត វាក្យស័ព្ទ និងវិធាននៃការប្រើប្រាស់ភាសាជាដើម។ | |
|---|---|
| **ពិបាកក្នុងការស្តាប់(APD)**<br>ឧទាហរណ៍សកម្មភាពផ្សេងៗទៀត | |
| សញ្ញា និងលក្ខណៈសម្គាល់ | យុទ្ធសាស្ត្រ បច្ចេកទេស សកម្មភាព និងសម្ភារ |
| • បកស្រាយខុស ឬពិបាកចងចាំការណែនាំផ្ទាល់មាត់។ ពិបាកធ្វើតាមការណែនាំដែលមានលក្ខណៈបន្តបន្ទាប់គ្នា។ | **សកម្មភាពទី១៖**<br>**ការណែនាំសម្រាប់ជួយកុមារពិបាកក្នុងការស្តាប់**<br>កុមារនឹងមានសមត្ថភាពអាច៖<br>➢ អនុវត្តតាមការណែនាំផ្ទាល់មាត់<br>➢ អនុវត្តតាមដោយប្រុងប្រយ័ត្នចំពោះការណែនាំតាមលំដាប់លំដោយ។<br><br>**ការណែនាំរបស់គ្រូបង្រៀន៖**<br>**ជំហានទី១៖** ឱ្យសិស្សធ្វើសកម្មភាពមួយ ដោយណែនាំសិស្សឱ្យប្រើការស្រមើស្រមៃរបស់ខ្លួនទៅជារូបភាពមួយនៅ |

| | |
|---|---|
| | ក្នុងចិត្តរបស់ពួកគេអំពីសកម្មភាពនោះ ដើម្បីឱ្យសិស្សនិយាយសារឡើងវិញនូវការណែនាំទៅគ្រូបង្រៀន។<br><br>**ជំហានទី២៖** គ្រូលើកម្រាមដៃមួយឡើងលើ នៅពេលប្រាប់ពីការណែនាំ ហើយសិស្សត្រូវលើកម្រាមដៃមួយឡើងលើនៅពេលដែលសិស្សនិយាយការណែនាំនោះសារឡើងវិញទៅគ្រូបង្រៀន។ បន្ទាប់មកសិស្សចាំបាច់ត្រូវធ្វើកម្មភាពមួយដែលគ្រូបង្រៀនប្រាប់ឱ្យធ្វើ។<br><br>**ជំហានទី៣៖** នៅថ្ងៃបន្ទាប់ អនុវត្តដំណើរការដូចគ្នាដោយមានការណែនាំចំនួន២។ គ្រូបង្រៀនផ្តល់ការណែនាំដល់សិស្ស ដោយលើកម្រាមដៃមួយឡើងលើសម្រាប់ការណែនាំទី១ និងលើកម្រាមដៃ២ឡើងលើសម្រាប់ការណែនាំទី២។ សិស្សគិតស្រមៃពីការណែនាំទាំង២ និងនិយាយឡើងវិញពីការណែនាំទាំងនោះ ដោយលើកម្រាមដៃ១ឡើងលើសម្រាប់ការណែនាំទី១ និងលើកម្រាមដៃ២ឡើងលើសម្រាប់សកម្មភាពទី២។ បន្ទាប់មកសិស្សធ្វើតាមការណែនាំទាំង២ដែលគ្រូបង្រៀនឱ្យធ្វើ។<br><br>**ជំហានទី៤៖** ថ្ងៃទី៣ ផ្តល់នូវការណែនាំចំនួន៣។ ថ្ងៃទី៤ ការណែនាំចំនួន៤ និងបន្ថែមទៀតនៅថ្ងៃបន្ទាប់។ ឈប់ធ្វើសកម្មភាពនៅពេលដែល សិស្សអាចធ្វើកិច្ចការ៧ឬ៨ តាមលំដាប់លំដោយបាន។ |
| • មានការលំបាកនៅក្នុងការវិភាគ និងចងចាំភាសាទាក់ទងទៅនឹងកិច្ចការនានា ប៉ុន្តែមិនមានបញ្ហាក្នុងការបកស្រាយ ឬរំឭកឡើងវិញនូវសូរសំឡេងដែលមិនមែនជាពាក្យសំដីនៅក្នុង បរិស្ថានជុំវិញខ្លួន ដូចជាសំលេងដូរតន្ត្រី ។ល។<br>• ប្រកប និងបញ្ចេញសំឡេងមិនត្រឹមត្រូវ ឬច្រឡំចំពោះពាក្យដែល | <u>**សកម្មភាពទី ២**</u><br><br><u>ការលេងល្បែងដូរតន្ត្រី៖ជាវិធីដ៏រីករាយមួយដើម្បីស្វែងយល់ពីសំឡេង និងចង្វាក់ភ្លេង</u><br><br>ក្មេងៗចូលចិត្តសំឡេងកងរំពង។ យើងមានធុងសំរាម (សម្ភារងាយៗដែលមានស្រាប់)។ ឱ្យធុងសំរាមចំនួន២ ឬច្រើនផ្សេងៗគ្នា ឱ្យកុមារបង្កើតសំឡេងតន្ត្រីដើម្បីឱ្យពួកគេស្វែងយល់ពីសំឡេង និងចង្វាក់។ វាជាគំនិតសាមញ្ញមួយ៖ |

មានសូរស្រដៀងគ្នា។ (ត្រីនិងស្រី ស្រួតនិងច្រូត សាច់និងសាច ជិតនិងចិត ជាដើម)។

- អាចយល់ច្រឡំ ឬយល់ខុសចំពោះភាសាប្រៀបធៀប ការលេងពាក្យពេចន៍ និងពាក្យកំប្លុកកំប្លែង។ បកស្រាយពាក្យតាមន័យត្រង់ៗ។
- មានការពិបាកក្នុងការផ្ចង់អារម្មណ៍ឱ្យបានយូរ ឬពិបាកក្នុងការចងចាំចំពោះបទបង្ហាញ ឬការបង្រៀនផ្ទាល់មាត់។
- ពិបាកយល់ចំពោះប្រយោគដែលមានលក្ខណៈស្មុគស្មាញ ឬការនិយាយញាប់។

ព្យួរធុងសំរាមនៅពិដាន(ឬមែកឈើ) និងឱ្យកុមារវាយ និងគោះដើម្បីស្វែងយល់ពីសំឡេងខុសៗគ្នា។ នៅពេលដែលគេព្យួរដេបរួចហើយ គំនិតនៃការលេងល្បែងគឺចេញមកដោយឯកឯង។ សូមព្យាយាមធ្វើដូចនេះនៅទីធ្លាក្នុងផ្ទះរបស់អ្នកឬសាលារៀន ហើយពិនិត្យមើលថាអ្វីដែលល្បែងទាំងនោះ ធ្វើឱ្យមានការទាក់ទាញអារម្មណ៍របស់អ្នក។




**មូលហេតុដែលកុមារត្រូវស្វែងយល់ពីសំឡេងនិងចង្វាក់៖**

**សិស្សនឹងមានសមត្ថភាពអាច៖**

➢ យល់ដឹងអំពីដំណើរការនៃការវិនិច្ឆ័យក្នុងការស្តាប់

➢ ធ្វើឱ្យកុមារដឹងថាមានប្រភេទនៃការលើកដាក់សំឡេងខុសៗគ្នា សង្កត់ឬបញ្ជាក់ពាក្យសំខាន់ៗ។ កម្រិតសំឡេង លំនាំ ស្វែងយល់ពីសំឡេងនិងចង្វាក់។

**សម្ភារផ្សេងៗសម្រាប់បង្កើតជាសំឡេងតន្ត្រីផ្ទាល់របស់កុមារដើម្បីឱ្យកុមារអាចស្វែងយល់ពីសំឡេងនិងចង្វាក់បាន៖**

- ដបប្លាស្ទិក
- ខ្សែ
- ដំបង (ចង្កឹះ)
- ជម្រើសៈសំឡីនិងស្កុតដើម្បីរុំធ្វើដំបងទៅជាប្រដាប់វាយស្គរ។

| | |
|---|---|
| |  |
| ពិបាកយល់ចំពោះប្រយោគដែលមានលក្ខណៈស្មុគស្មាញ ឬការនិយាយញាប់ | **<u>សកម្មភាពទី៣៖</u>**<br><u>ស្តាប់ដើម្បីយល់ន័យ</u><br>សិស្សនឹងមានសមត្ថភាពអាច៖<br>➢ អភិវឌ្ឍបំណិនក្នុងការស្តាប់<br>➢ បង្ហាញអារម្មណ៍ផ្ទាល់ខ្លួនតាមរយៈការសម្តែងសកម្មភាពនានា ដែលជាមធ្យោបាយ សម្រាប់ជួយឱ្យយល់អត្ថន័យ របស់សាច់រឿង។<br>**ធ្វើសកម្មភាពបង្ហាញ៖** ប្រាប់ឬអានរឿងឮៗ ហើយបន្ទាប់មកឱ្យសិស្សរបស់អ្នកសម្តែងតួ ឬបង្ហាញសាច់រឿង។ សកម្មភាពទាំងនេះ លើកទឹកចិត្តឱ្យកុមារស្តាប់ព័ត៌មានបានលម្អិត និងការស្តាប់បានរយៈពេលវែង។<br>**ស្តាប់រឿងតាមរយៈស៊ីឌី៖** នៅពេលដែលសិស្សរបស់អ្នក ស្តាប់រឿងចប់ ពួកគេត្រូវធ្វើត្រាប់ ឬសម្តែងតួតាមសាច់រឿងបើអាចធ្វើទៅបាន។ ប្រសិនបើករណីមិនអាចធ្វើបាន គឺគ្រាន់តែឱ្យពួកគេស្តាប់បានហើយ។ សៀវភៅរឿងមានសារៈសំខាន់២យ៉ាង ទី១វាប្រើពាក្យត្រង់ៗ និងទី២ធ្វើឱ្យកុមារមានភាពរីករាយ។ រឿងនេះមានសារៈប្រយោជន៍ដល់កុមារដែលពួកគេអាចពិភាក្សាទៅលើគ្រាមភាសា និងរបៀបដែលអ្នកស្តាប់នៅក្នុងកិច្ចសន្ទនាអាចយល់នូវអ្វីដែលពួកគេបាននិយាយ។<br>**តាមខ្ញុំឱ្យទាន់៖** គ្រូបង្រៀនអានឬប្រាប់រឿងដែលសិស្សធ្លាប់ដឹងច្បាស់។ ផ្លាស់ប្តូរខ្លឹមសារនៅត្រង់ចំណុចណាមួយក្នុង |

| | |
|---|---|
| | សាច់រឿង ដើម្បីពិនិត្យមើលថាតើពួកគេដឹងកំហុសនោះដែរឬទេ? ខ្លឹមសារដែលបានផ្លាស់ប្តូរនោះគឺជាសកម្មភាពមួយដែលតម្រូវឱ្យសិស្សមានការយកចិត្តទុកដាក់ដោយប្រើការស្តាប់ឱ្យបានច្រើន។ |
| | **សកម្មភាពទី៤៖**<br><br>**ល្បែងខ្នងទល់ខ្នង ត្រចៀកទល់ត្រចៀក និងការស្តាប់ភាសា៖**<br><br>ជ្រើសរើសកុមារមួយចំនួន ដើម្បីលេងកំសាន្តល្បែងផ្នែកភាសា និងការស្តាប់នេះ។ យើងតែងតែស្វែងរកវិធីក្នុងការបង្កើតបំណិនផ្នែកភាសា និងការស្តាប់ ដោយលេងល្បែងសាមញ្ញៗដែលបង្កប់ដោយបំណិននៅក្នុងនោះ។<br><br>ល្បែងនេះ វាមានប្រសិទ្ធភាពក្នុងការជួយកុមារឱ្យមានភាពប្រសើរទៅលើបំណិនស្តាប់។<br><br>សិស្សមានសមត្ថភាពអាច៖<br>• អនុវត្តតាមការណែនាំ<br>• អភិវឌ្ឍចលនាតូច (គូរគំនូរ និងកាត់)<br>• ការប្រាប់ទិសដៅ<br>• ស្គាល់ផ្នាក់<br>• បំណិនក្នុងការទំនាក់ទំនង<br>• ការយកចិត្តទុកដាក់<br>• ដំណើរការក្នុងការស្តាប់ ។<br><br>សម្ភារសម្រាប់លេងល្បែងខ្នងទល់ខ្នង ត្រចៀកទល់ត្រចៀក ការស្តាប់ភាសា៖<br>• ក្រដាស២សន្លឹក<br>• រូបធរណីមាត្រដែលមានពណ៌ខុសៗគ្នា<br>• កន្ត្រៃ<br>• ខ្មៅដៃពណ៌ ឬហ្វឺត។<br><br>សេចក្តីណែនាំសម្រាប់ការលេងល្បែងខ្នងទល់ខ្នង ត្រចៀក |

| | |
|---|---|
| | ទល់ត្រចៀក និងការស្ដាប់ភាសា៖<br><br>• ការលេងល្បែងនេះ អ្នកលេងត្រូវអង្គុយទល់ខ្នងដោយងាកមុខចេញពីគ្នា។<br>• ដាក់ក្រដាស១សន្លឹកលើដីនៅមុខអ្នកលេងម្នាក់ៗ និងរូបមួយចំនួន។ អ្នកលេងទីមួយដាក់រូបមួយនៅកន្លែងណាក៏បាននៅលើក្រដាស ហើយប្រាប់ទីតាំងឱ្យអ្នកលេងម្នាក់ទៀតដឹង។ ឧទាហរណ៍ ៉ដាក់រូបការ៉េពណ៌ក្រហមតូចមួយនៅជ្រុងខាងស្ដាំផ្នែកខាងលើ៉។<br>• ឥឡូវនេះគឺជាវេនរបស់អ្នកលេងម្នាក់ទៀតក្នុងការជ្រើសរើស និងផ្ដល់ការណែនាំ។ បន្ទាប់ពីប្ដូរវេនគ្នាបានពីរទៅបីវេនរួចមក អ្នកលេងប្រៀបធៀបស្នាដៃរបស់ពួកគេដើម្បីពិនិត្យមើលថាតើវាត្រឹមត្រូវកម្រិតណា។ ការពិនិត្យមើលពីរបៀបដែលកុមារធ្វើតាមការណែនាំ វានឹងផ្ដល់ព័ត៌មានសំខាន់ៗដល់អ្នក។ អ្នកអាចដឹងថាតើពួកគេយល់ ឬមានការលំបាកក្នុងដំណើរការនៃការស្ដាប់ពាក្យ ឃ្លា ការពិពណ៌នាពាក្យនីមួយៗ ឬការប្រាប់ទិសដៅ។ នេះគឺជាឧទាហរណ៍មួយដែលបង្ហាញថា កុមារមានការលំបាកទាក់ទងនឹងការប្រាប់ទិសដៅ។<br><br><br> |
| ប្រកប និងបញ្ចេញសំឡេងមិនត្រឹមត្រូវ ឬប្រឡំចំពោះពាក្យដែលមានសូរស្រដៀងគ្នា។ (ត្រីនិងស្រី ស្រួតនិងច្រូត សាច់និងសាច ជិតនិងចិត ជាដើម)។ | **សកម្មភាពទី៥**<br>**ល្បែងទី២ អំពីការមើល៖ តើមានអ្វីដែលបាត់?**<br>សិស្សមានសមត្ថភាពអាច៖<br>➢ កែលម្អនូវកម្រិតនៃការមើលឃើញតាមរយៈការមើលរបស់កុមារនូវចំណុចដែលមានភាពខុសគ្នា និងស្រដៀងគ្នា។<br><br>ហេតុអ្វីបានជាបំណិននេះមានសារៈសំខាន់? ព្រោះវាអាច |

| | |
|---|---|
| | ជួយដល់ការសរសេរ ការប្រកប ការអាន និងការយល់បានកាន់តែប្រសើរ។ កុមារត្រូវការមើលពីកំហុសផ្នែកអក្ខរាវិរុទ្ធរបស់ខ្លួន។ ពួកគេចាំបាច់ត្រូវដឹងថាពួកគេកំពុងអានពាក្យ «គេ»មិនមែន «កេរ» ទេ។<br><br>កុមារទី១ រៀបចំដុំតម្រៀប។ កុមារទី២សិក្សាពីដុំតម្រៀបនោះ មួយនាទី។<br><br>កុមារទី១ដដែល គ្របដុំតម្រៀបនោះ និងដកយកដុំតម្រៀប ១ដុំចេញ។ ធ្វើដូចនេះ រួចបន្តការធ្វើឱ្យកាន់តែលំបាកទៅៗ គេអាចដកមួយដុំឬច្រើនដុំ ឬបន្ថែមមួយដុំ ឬច្រើនដុំ។<br><br>បន្ទាប់មកបើកដុំតម្រៀប ហើយកុមារទី២ទាយថា តើដុំតម្រៀបណាដែលបានបាត់ ឬលើស?<br><br>ត្រូវធ្វើបែបនេះបន្តបន្ទាប់រួចប្តូរវេនគ្នា។ |

| ការពិបាកក្នុងការអាន ( dyslexia ) |
| --- |
| **ការពិបាកក្នុងការអាន៖ សញ្ញានិងលក្ខណៈសម្គាល់**<br>• ពិបាកក្នុងការទទួលព័ត៌មាននិងការយល់ដឹងអ្វីដែលពួកគេស្តាប់ឮ។<br>• ពួកគេអាចមានការពិបាកក្នុងការយល់ និងអនុវត្តតាម ប្រសិនបើនរណាម្នាក់ណែនាំឱ្យធ្វើអ្វីមួយដែលលឿន និងច្រើនក្នុងមួយពេល ឬពិបាកចងចាំកិច្ចការផ្សេងៗតាមលំដាប់លំដោយ។<br>• មើលអក្សរបញ្ច្រាស ដូចជា «ល» និង «ហ» ឬ លេខ «៦» និង «៨» ។<br>• កុមារដែលពិបាកក្នុងការអាន ក៏អាចអានបញ្ច្រាស់ផងដែរ (ពីស្តាំទៅឆ្វេង)។<br>• កុមារអាចមានការពិបាកក្នុងការមើល និងស្តាប់សូរ ចំពោះអក្សរ ឬពាក្យដែលស្រដៀងៗគ្នា។ ពួកគេក៏ពិបាកក្នុងយល់អំពីការដកឃ្លា និងអាចពិបាកក្នុងការបញ្ចេញសំឡេងចំពោះពាក្យដែលពួកគេមិនធ្លាប់ឮ។ |
| **ការលំបាកក្នុងការអាន៖ វិធីសាស្ត្រសម្រាប់ជួយអន្តរាគមន៍**<br>• គ្មានវិធីណាអាចស្តារ ឬព្យាបាលទៅលើផ្នែកខួរក្បាលរបស់កុមារដែលពិការក្នុងការអាននោះទេ។<br>• ការជួយបំប៉នផ្នែកអប់រំជាវិធីសម្រាប់ព្យាបាលដ៏សំខាន់ចំពោះកុមារពិបាកក្នុងការអាន។<br>• ការធ្វើតេស្តផ្នែកចិត្តសាស្ត្រអាចជួយគ្រូបង្រៀនកំណត់ពីផ្នែកផ្សេងៗដែលត្រូវជួយដល់កុមារ។<br>• គ្រូបង្រៀនអាចប្រើវិធីទាក់ទងនឹងការស្តាប់ ការមើល និងការប៉ះឬស្ទាប ដើម្បីបង្កើនបំណិនអំណានរបស់សិស្ស។ ការជួយសិស្សម្នាក់ៗឱ្យប្រើពហុវិញ្ញាណក្នុងការរៀន ឧទាហរណ៍ ដូចជា ស្តាប់មេរៀនតាមរយៈម៉ាញ៉េឬស៊ីឌី និងការប្រើម្រាមដៃស្ទាបលើរូបភាព ឬពាក្យដែលនិយាយ វាអាចជួយសិស្សក្នុងការវិភាគព័ត៌មាន។ វិធីសាស្ត្របង្រៀនដ៏សំខាន់បំផុតគឺការពន្យល់ឱ្យបានច្រើនដង ដោយប្រើប្រាស់វិធីសាស្ត្របង្រៀនពហុវិញ្ញាណទាំងនេះ។<br>• ប្រសិនបើកុមារមានការពិបាកក្នុងការអានធ្ងន់ធ្ងរ គ្រូបង្រៀនអាចប្រើវិធីដូចជា ការងារក្រុមតូច ក្រុមធំ ជារៀងរាល់សប្តាហ៍ ហើយធានាថា រាល់ការងារក្រុមទាំងនោះត្រូវតែមានដំណើរការយឺតៗ។ កុមារដែលមានការពិបាកក្នុងការអានធ្ងន់ធ្ងរ ទំនងជាមិនអាចអានបានល្អនោះទេ ហើយក៏ទំនងជាត្រូវការការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមិនតម្រូវឱ្យមានបំណិនក្នុងការអានច្រើនទេ។<br>• កុមារពិបាកក្នុងការអានកម្រិតស្រាល ជាទូទៅអាចទទួលបានជោគជ័យពីការរៀនហ្វឹកហាត់អាននៅក្នុងសាលារៀន។ |

| ការពិបាកក្នុងការអាន៖ ឧទាហរណ៍សកម្មភាពសម្រាប់ជួយ | |
|---|---|
| សញ្ញា និងលក្ខណៈសម្គាល់ | យុទ្ធសាស្រ្ត បច្ចេកទេស សកម្មភាព និងសម្ភារ |
| • លំបាកក្នុងការទទួលព័ត៌មាននិងការយល់ដឹងអ្វីដែលពួកគេស្តាប់ឮ។<br>• កុមារអាចមានការពិបាកក្នុងការមើល និងស្តាប់សូរ ចំពោះអក្សរ ឬពាក្យដែលស្រដៀងៗគ្នា។ ពួកគេក៏ពិបាកក្នុងយល់អំពីការដកឃ្លា និងអាចពិបាកក្នុងការបញ្ចេញសំឡេងចំពោះពាក្យដែលពួកគេមិនធ្លាប់ឮ។ | **ការពិបាកក្នុងការអាន៖**<br>**សកម្មភាពទី១៖**<br>**ចំណងជើងល្បែង៖**ល្បែងឡូតូដែលដាក់តួអក្សរផ្គុំគ្នា (Letter Blend Bingo)<br>**កម្រិតថ្នាក់៖** ថ្នាក់មត្តេយ្យ ថ្នាក់ទី១ និងថ្នាក់ទី២<br>**មុខវិជ្ជា៖** អំណាន ឬការស្គាល់សូរ<br>សិស្សមានសមត្ថភាពអាច៖<br>➢ សិស្សនឹងឮពាក្យផ្សេងៗដែលផ្សំជាមួយព្យញ្ជនៈនិងព្យញ្ជនៈ បានត្រឹមត្រូវទៅតាមអក្សរនៅលើកាត (bingo)មួយ។<br><br>កុមារពិបាកក្នុងការអាន មានការពិបាកក្នុងការវិភាគសំឡេង និងផ្ទុផ្គងអក្សរ ទៅនឹងសំឡេងដែលត្រូវគ្នារបស់ព្យញ្ជនៈ ឬស្រៈទាំងនោះ។ គេរកឃើញថា សកម្មភាពពហុវិញ្ញាណគឺជាវិធីដ៏មានប្រសិទ្ធភាព មួយនៃការបង្រៀនស្គាល់សូរ និងអានសូរ។<br><br>ជាការអនុវត្តជាក់ស្តែង ល្បែងឡូតូផ្គុំអក្សរឬពាក្យ គឺជាវិធីប្រកបដោយភាពសប្បាយរីករាយមួយ ដើម្បីជួយសិស្សក្នុងការស្តាប់ និងសម្គាល់ពីការផ្គុំគ្នារបស់ព្យញ្ជនៈ ។<br><br>វិធីនេះជួយកុមារឱ្យរៀនពីអក្សរដែលបានផ្គុំគ្នា តាមរយៈការប្រើវិញ្ញាណលើសពីមួយ។ វារាប់បញ្ចូលទាំងការមើលឃើញ តាមរយៈការមើលអក្សរនៅលើក្តារឡូតូ ហើយប្រសិនបើគេប្រើប្រាស់រូបភាព ចូរមើលរូបភាពទាំងនោះ។ មេរៀននេះរួមបញ្ចូលផ្នែកសោតវិញ្ញាណ ពីព្រោះពួកគេស្តាប់ឮពាក្យដែលគ្រូបង្រៀនហៅ។ វាក៏រួមបញ្ចូលផងដែរនូវការប៉ះតាមរយៈការឱ្យសិស្សសម្គាល់នូវអក្សរ នៅពេលដែលគេហៅអក្សរទាំងនោះ។ |

**កម្មវិធីសិក្សាស្តង់ដារ៖**

RF.1.2.បង្ហាញពីការយល់ដឹងចំពោះពាក្យ ព្យាង្គ និងសូរសំឡេង (មូលសព្ទ)ដែលបាននិយាយ

**ពេលវេលាដែលត្រូវការលេង៖** 30 នាទី

**ឯកសារ និងសម្ភារដែលត្រូវការ៖**

- សន្លឹកឬផ្ទាំងឡូតូ៖ ដែលមានក្រឡាចត្រង្គ ៤ឬ៥ កាត់ទទឹង និង ៤ឬ៥ចុះក្រោម ដោយមានដាក់អក្សរខ្លះ និងមិនដាក់អក្សរខ្លះ នៅក្នុងក្រឡានីមួយៗ។ សន្លឹកឬផ្ទាំងឡូតូនីមួយៗ ត្រូវមានលក្ខណៈខុសគ្នា។
- ហ្វឺត ឬខ្មៅដៃពណ៌
- បញ្ជីពាក្យដែលចាប់ផ្តើម ដោយការផ្គុំតួអក្សរ បណ្ណអក្សរ ឬរូបភាពរបស់ពាក្យ ដែលចាប់ផ្តើមជាមួយនឹងអក្សរដែលបានផ្គុំគ្នា ដូចជា «ស្រ ច្ប សម្ប កន្ល.... ជាដើម» ។

**សកម្មភាព៖**

គ្រូបង្រៀនអានពាក្យ និងបង្ហាញរូបភាពរបស់ពាក្យដែលចាប់ផ្តើមដោយការប្រកបផ្គុំតួអក្សរចូលគ្នា។ ការអានពាក្យឮៗនិងការបង្ហាញរូបភាពបង្កើននូវបទពិសោធន៍នៃការលេងល្បែងដែលប្រើប្រាស់ពហុវិញ្ញាណ។ សិស្សគូសចំណាំក្នុងក្រឡាការ៉េនៅលើក្តារឡូតូរបស់ពួកគេ ចំពោះតួអក្សរដែលត្រូវផ្គុំគ្នាឱ្យត្រូវតាមសំឡេងដើម។

ឧទាហរណ៍៖ ករណីពាក្យ "ស្រាប់" សិស្សដែលមានតួអក្សរផ្គុំចូលគ្នាដោយផ្តើមពី «ស្រ»នៅលើបណ្ណឡូតូរបស់ខ្លួន ត្រូវគូសចំណាំក្នុងក្រឡាការ៉េនោះ។ នៅពេលដែលគេហៅពាក្យនីមួយៗ សិស្សត្រូវគូសចំណាំក្នុងក្រឡាការ៉េដែលមានតួអក្សរផ្គុំនៅដើមដំបូងរបស់ពាក្យ។ នៅពេលសិស្សទទួលបានបន្ទាត់ត្រង់ ឬបន្ទាត់កែង ពួកគេមាន «ឡូតូ»។

គេអាចបន្តលេងល្បែងនេះបាន ដោយឱ្យសិស្សសាកល្បងគ្រប់ក្រឡានៅលើក្រដាស់ដែលខ្លួនបានបំពេញ ឬចាប់ផ្តើម

លេងសារជាថ្មីដោយប្រើប៊ិកហ្វឺតពណ៌ខុសគ្នា។

**វិធីផ្សេងទៀត៖**

- ប្រើសន្លឹកកិច្ចការដែលមានក្តារឡូតូទទេ ហើយឱ្យសិស្សសរសេរតួអក្សរផ្តុំគ្នានៅក្នុងក្រឡានីមួយៗ ដោយ ធ្វើឱ្យប្រាកដចំពោះការប្រើប្រាស់ការផ្តុំតួអក្សរនីមួយៗតែម្តងប៉ុណ្ណោះ (ប្រាប់សិស្សឱ្យដឹងថាពួកគេនឹងមិនប្រើប្រាស់ការផ្តុំតួអក្សរទាំងអស់ទេ)។ គ្រូអាចសរសេរតួអក្សរផ្តុំនានានៅខាងក្រោមសន្លឹកកិច្ចការសម្រាប់សិស្សក្នុងការប្រើជាឯកសារយោង។
- ប្រើក្រឡាចត្រង្គតូចៗដែលមានបួនការ៉េឡើងលើ និងបួនការ៉េទទឹង ហើយមានក្រឡាចត្រង្គចំនួន៤ក្នុងមួយទំព័រ ដែលអាចលេងល្បែងឡូតូចំនួន៤ដង។
- ប្រើអក្ខរក្រមទាំងមូល និងឱ្យសិស្សគូសចំណាំសំឡេងចាប់ផ្តើម ឬសំឡេងបញ្ចប់របស់ពាក្យមួយ។

គ្រូអាចផ្លាស់ប្តូរបណ្ណឡូតូ ដើម្បីឱ្យស្របគ្នាជាមួយមេរៀនបច្ចុប្បន្ន ឧទហរណ៍ ការរៀបចំក្តារឡូតូ សម្រាប់រៀនអំពីវាក្យសព្ទសាមញ្ញៗ រៀនអំពីពាក្យដែលបញ្ចប់ដោយព្យញ្ជនៈណាមួយ រៀនអំពីពណ៌ និងរៀនអំពីរូបរាងគំរូជាដើម។

**គន្លឹះ៖**

ចូរអ៊ុតបណ្ណឬផ្ទាំងឡូតូ ដើម្បីឱ្យគេអាចប្រើប្រាស់បានច្រើនដង។ ប្រើប្រាស់ប៊ិកហ្វឺតដែលអាចលុបជ្រះដើម្បីធ្វើឱ្យមានភាពងាយស្រួលក្នុងការលុបចំណុចដែលបានគូសចំណាំ។

តួអក្សរផ្តុំចូលគ្នា នៅដើមដំបូងរបស់ពាក្យ ដែលគេឃើញជាទូទៅមាន៖ ក្ង ខ្ព ល្ព ស្ត ស្ព ច្ប ស្រ ល្ប បន បន្ល គន្ល គន្ធ រង្វ ...ជាដើម។ គ្រូត្រូវបង្កើតវាឱ្យបានច្រើន។

បញ្ជីពាក្យ ដែលអាចកើតឡើងដោយការផ្តុំតួអក្សរ ទាំងនោះអាចមាន៖

ក្ងាន ខ្ពស់ ល្ពៅ ស្ពៅ ច្បាប់ ច្បាស់ ស្រាប់ ល្បិច បន្លែ

| | |
|---|---|
| | គន្លង គន្ទា វង្វង់....ជាដើម។ គ្រូត្រូវរៀបចំកិច្ចការនេះឱ្យសិស្សអនុវត្ត។<br><br>*គេហទំព័រដែលបង្កើតបណ្ណឡូតូ ដោយឥតគិតថ្លៃគឺ៖ Print-Bingo.com: www.print-bingo.com*<br>*គេហទំព័រដែលបង្កើតក្តារឡូតូ ដោយឥតគិតថ្លៃគឺ៖ www.saksena.net/partygames/bingo* |
| • មើលអក្សរបញ្ច្រាស ដូចជា «ល» និង «ហ» ឬ លេខ «៦» និង «៨»។<br>• ពិបាកក្នុងការទទួលព័ត៌មាននិងការយល់ដឹងអ្វីដែលពួកគេស្តាប់ឮ។<br>• ពួកគេអាចមានការពិបាកក្នុងការយល់ និងអនុវត្តតាម ប្រសិនបើនរណាម្នាក់ណែនាំឱ្យធ្វើអ្វីមួយដែលលឿន និងច្រើនក្នុងមួយពេល ឬពិបាកចងចាំកិច្ចការផ្សេងៗតាមលំដាប់លំដោយ។<br>• កុមារដែលពិបាកក្នុងការអាន ក៏អាចអានបញ្ច្រាស់ផងដែរ (ពីស្តាំទៅឆ្វេង)។ | **សកម្មភាពទី២៖** ជ្រុងអក្ខរវិញ្ញាណ (spelling station)<br>កុមារពិបាកក្នុងការអាន មានការពិបាកខ្លាំងក្នុងការយល់ពីលំដាប់របស់តួអក្សរនៅក្នុងពាក្យនីមួយៗដែលអាចនាំពួកគេឱ្យមើលឃើញអក្សរ «ល» ថាជា «ហ»ឬអាចឱ្យពួកគេរៀបចំពាក្យខុសពីលំដាប់លំដោយរបស់វា (ឧទាហរណ៍ ពាក្យ «រមនា» មើលទៅឃើញថាជាពាក្យ «មរនា»ទៅវិញ)។ ប្រសិនបើ អ្នកចង់ដឹងពីលក្ខណៈនៃអារម្មណ៍របស់កុមារពិបាកក្នុងការអាន *សូមមើលវីដេអូស្តីពីគំរូតាមរយៈគេហទំព័រខាងក្រោម៖* *https://youtu.be/tZ3MFFPvS3w*<br><br>ក្នុងគោលបំណងជួយសិស្សដែលពិបាកប្រកប ដោយសារតែមានបញ្ហាពិបាកក្នុងការអាន ស្ថាប័នឈ្មោះ Education Cornerបានបង្កើត ជ្រុងអក្ខរវិញ្ញាណ«spelling station» ដើម្បីផ្តល់ឱកាសដល់សិស្សថ្នាក់ទី ១-៣ ពង្រឹងនូវបំណិនអំណានរបស់ពួកគេតាមរយៈការមើល ការស្តាប់ និងការសរសេរដដែលៗ។<br><br>គ្រូបង្រៀនត្រូវអនុវត្តន៍របៀបនេះ ឱ្យបានច្រើនដងក្នុងមួយសប្តាហ៍ដើម្បីពង្រឹងការរៀនសូត្រ តាមរយៈការរៀនឡើងវិញដែលធ្វើឱ្យបំណិនរបស់គេកាន់តែមានភាពរឹងមាំ ដោយមធ្យោបាយដែលមានភាពរីករាយ និងការចូលរួម។<br><br>គំនិតផ្សេងៗសម្រាប់កិច្ចតែងការបង្រៀន៖<br>• អក្សរមានភ្ជាប់ដែកឆក់(lettermagnets)-ចូរប្រើអក្សរដែលមានភ្ជាប់ដែកឆក់នៅលើបន្ទះលោហៈ ដែល |

| | |
|---|---|
| | សិស្សអាចសរសេរ (ប្រកប)ពាក្យដែលគេផ្ដល់ឱ្យ។<br>• ពេលវេលាសម្រាប់លេងល្បែងផ្គុំរូប(puzzle time)-គ្រូគួររៀបចំសន្លឹកកិច្ចការ (តារាង) សម្រាប់លេងល្បែងផ្គុំពាក្យខ្វែង និងស្វែងរកពាក្យ ដើម្បីរៀនប្រកប ឬអានពាក្យ។ ចំណុចទាំងនេះជួយសិស្សឱ្យរៀនចេះពីការប្រកបតាមរយៈការស្គាល់ពាក្យ ដែលក្នុងពេលជាមួយគ្នានេះដែរ សិស្សបានចូលរួមជាប់ជានិច្ចតាមរយៈការលេងល្បែងសប្បាយៗ។<br>• ពាក្យចម្រុះពណ៌(colorful words)- សិស្សដែលមកមើលនៅជ្រុងនេះ នឹងសរសេរពាក្យរបស់ខ្លួនដោយប្រើប្រាស់ពណ៌ផ្សេងៗគ្នាសម្រាប់អក្សរនីមួយៗ។ ការប្រើប្រាស់ពណ៌ខុសៗគ្នាទាំងនេះ សិស្សអាចប្រើប្រាស់ភាពស៊ីសង្វាក់គ្នា ឬទំនាក់ទំនងគ្នា រវាងពណ៌ និងតួអក្សរដើម្បីរៀនតាមរយៈគេស្តខ្លីៗ ដែលត្រឹមត្រូវ។ សិស្សដែលស្ថិតនៅជ្រុងនេះ សួរគ្នាទៅវិញទៅមកពីការប្រកបពាក្យ។ សិស្សម្នាក់ត្រូវអានពាក្យខ្លាំងៗ ចំណែកឯសិស្សផ្សេងទៀតប្រកបអក្សរនឹងមាត់ ឬសរសេរពាក្យនៅលើក្រដាស។ វិធីនេះជួយសិស្សដែលមានការពិបាកក្នុងការប្រកបពាក្យ តាមរយៈ ការស្ដាប់ និងជាពាក្យសម្ដី។<br>• សិល្បៈរបស់អក្សរ(ទម្រង់អក្សរ)[word art]- ការប្រើខ្មៅដៃពណ៌ ប៊ិកហ្វឺត វត្ថុតូចៗដែលមានពន្លឺចាំងព្រាលៗ(glitter) និងវត្ថុសិល្បៈផ្សេងៗទៀត សិស្សសរសេរពាក្យនៅលើក្រដាសគំរូ បន្ទាប់មកតុបតែងពាក្យនោះ។ វិធីនេះជួយឱ្យសិស្សចងចាំការប្រកបពាក្យតាមរយៈផ្សារភ្ជាប់នឹងការមើល ជាមួយផ្នែកសិល្បៈដែលអាចបន្ថយផលប៉ះពាល់ ចំពោះកុមារពិបាកក្នុងការមើល។ |
| ពួកគេអាចមានការពិបាកក្នុងការៈ<br>1. យល់ឱ្យទាន់ តាមការណែនាំដែលលឿនរហ័ស ។<br>2. អនុវត្តតាមការណែនាំច្រើនជាងមួយ | **សកម្មភាពទី៣ៈ**<br>កិច្ចតែងការបង្រៀន"ដម្រាបសួរទន្សាយ Peter"<br>**វត្ថុបំណងៈ**បន្ទាប់ពីបានស្ដាប់(និងឬអាន) រឿងឈ្មោះទន្សាយPeter សិស្សនឹងធ្វើសកម្មភាពផ្សេងៗតាមសាច់រឿង |

| | |
|---|---|
| នៅក្នុងពេលតែមួយ។<br>3. ចងចាំព្រឹត្តិការណ៍ ឬដំណើររឿងតាមលំដាប់លំដោយ។ | និងសរសេរសំបុត្រមួយទៅឱ្យទន្សាយ Peter ។<br><br>**ចំណាំ៖** លោកអ្នកអាចចូលទៅរកព័ត៌មានផ្សេងៗ អំពីសាច់រឿងនេះ នៅលើគេហទំព័រដែលមានឈ្មោះថា *"Dear Peter Rabbit Letter Writing Lesson"* ដូចបានបញ្ជាក់នៅខាងក្រោមនៃគេហទំព័រនេះ។<br><br>• កំណត់ឈុតឆាកផ្សេងៗនៃសាច់រឿង<br>• កំណត់ផ្នែកផ្សេងៗនៃតួអង្គរបស់សាច់រឿង<br>• កំណត់ដំណើររឿងរបស់សាច់រឿង<br>• កំណត់បញ្ហា និងដំណោះស្រាយរបស់សាច់រឿង<br>• ប្រៀបធៀបភាពស្រដៀងគ្នា និងភាពខុសគ្នារវាងព្រឹត្តិការណ៍នានា នៅក្នុងរឿង និងព្រឹត្តិការណ៍នានានៅក្នុងជីវិត<br>• អនុវត្តបំណិននៃការគិតតាមបែបហេតុផល ដោយប្រាប់ពីភាពខុសគ្នារវាងការពិត និងការស្រមើស្រមៃក្នុងអត្ថបទ<br>• និពន្ធរឿងសាមញ្ញៗស្របនឹងគំនិត ឬព្រឹត្តិការណ៍សំខាន់មួយ ដោយមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ ព្រមទាំងសេចក្តីលម្អិត<br>• ចូលរួមក្នុងសកម្មភាព និងដំណើរការនៃការនិពន្ធជាក្រុម រួមទាំង ការប្រើវិធីនៃការសរសេរព្រាងជាមុនដែលមានដូចជាការរៀបចំបញ្ជីគំនិត ការបំផុសគំនិត និងការគូររូប ដើម្បីបង្កើតគំនិតសម្រាប់ការសរសេរ។<br>• និពន្ធសម្រាប់គោលបំណងផ្សេងៗជាច្រើន រួមទាំងការឆ្លើយតបតាមទម្រង់សាមញ្ញៗ ដែលមានដូចជាស្រោមសំបុត្រ ចុះបញ្ជី និងទិនានុប្បវត្តិ<br>• ចំណាំ៖ មេរៀននេះក៏អាចរកបានតាមរយៈគេហព័រខាងក្រោមនេះដែរ។ *http:ឬឬwww.digitalwish.comឬdwឬdigitalwishឬview_lesson_plans?id=4326*<br><br>សូមចូលទៅកាន់អាសយដ្ឋានខាងលើ ដើម្បីទទួលបានឯកសារជាច្រើនទៀត។ |

| | |
|---|---|
| | 1. ការរៀបចំប្រវត្តិ៖ ចែករំលែកគេហទំព័រនៃសកម្មភាពរបស់ទន្សាយPeter ដែលបានមកពី "Peter Rabbit Online" (សូម មើលURLខាងក្រោម) ចុចលើប៊ូតុងលេងល្បែង ចុចលើ«តួអង្គ» ដើម្បីពិភាក្សាពីតួអង្គក្នុងរឿង។<br><br>2. សាច់រឿង៖ អានរឿង "ទន្សាយឈ្មោះPeter" ជាមួយសិស្សតាមonline (សូមមើល URL ខាងក្រោម) ឬតាមរយៈការប្រើសៀវភៅ។ ពិភាក្សាពីផ្នែកព្រឹត្តិការណ៍ផ្សេងៗរបស់សាច់រឿង និងឱ្យសិស្សនិយាយសាច់រឿងឡើងវិញដោយប្រើពាក្យសម្ដីផ្ទាល់របស់ខ្លួន។ សួរសំណួរផ្សេងៗពីចំណុចលម្អិតរបស់សាច់រឿង។<br><br>3. ផ្នែកផ្សេងៗរបស់សាច់រឿង៖ ចូលទៅកាន់ផែនទីរបស់សាច់រឿង: អាន សរសេរ គិត និងឱ្យសិស្សក្នុងថ្នាក់ធ្វើការនៅលើផែនទី សាច់រឿងដែលមានផ្នែកផ្សេងៗរបស់សាច់រឿង។ (តួអង្គ ឈុតឬ ឆាក ជម្លោះ ដំណោះស្រាយ)ដែលមានlink ខាងក្រោម។<br><br>4. អ្នករៀបចំក្រាហ្វិច៖ លោកអ្នកអាចទាញយកទម្រង់ឯកសារជា MS Word ដែលមាននៅក្នុងគេហទំព័រសម្រាប់សិស្សបានដើម្បីបញ្ចូលសំណួរ ឬប្រយោគ ចំនួន៦ ផ្ញើរទៅឱ្យទន្សាយPeter។ ឯកសារជា MS Word អាចរកបាននៅលើគេហទំព័រ "*Dear Peter Rabbit Letter Writing Lesson*"។<br><br>5. ការសរសេរសំបុត្រ៖ នៅពេលដែលអ្នករៀបចំក្រាហ្វិកបានរៀបចំរួចរាល់ហើយ សិស្សនឹងវាយសំបុត្រទៅឱ្យទន្សាយPeter។ គ្រូបង្រៀនអាចប្រើគំរូមួយ ក្នុងចំណោមគំរូពីរ នៅលើ online។ |

| | |
|---|---|
| | • លិខិតដែលអាចបោះពុម្ពបានសម្រាប់ការសរសេរសេចក្ដីព្រាងត្រួសៗអាចរកបាននៅលើlink "*Dear Peter Rabbit Letter Writing Lesson*"។<br><br>• នៅពេលដែលគេសរសេរសេចក្ដីព្រាងត្រួសៗរួចហើយ សិស្សអាចប្រើប្រាស់ទម្រង់នៃការឆ្លើយឆ្លងណាមួយសម្រាប់សំណៅឯកសារអេឡិចត្រូនិក៖<br><br>**ក.** គំរូនៃការឆ្លើយឆ្លងជា MS Word៖ សិស្សវាយកាលបរិច្ឆេទ ការស្វាគមន៍ តួសេចក្ដីរបស់លិខិត និងការគោរព។ គំរូអាចរកបាននៅលើlinkមេរៀននៃការសរសេរលិខិត "Dear Peter Rabbit Letter"។<br><br>**ខ.** គំរូនៃការឆ្លើយឆ្លងជាPowerPoint៖ ទាញយកគំរូ Power Point អាចរកបាននៅលើlink មេរៀននៃការសរសេរលិខិត "Dear Peter Rabbit Letter"។<br><br>នៅពេលដែលគេទាញយកគំរូPowerPoint បានហើយ សូមចូលទៅកាន់កម្មវិធីបញ្ចាំងស្លាយនៅផ្នែកខាងលើ។ ចុចលើ "view show"។ ចូលទៅកាន់"advance the slide ឬចុចលើ ប៊ូតុង enter"។ កុមារ ឬគ្រូបង្រៀនអាចវាយសាច់រឿងរបស់ពួកគេនៅក្នុងប្រអប់ពណ៌ស។ បន្ទាប់មករក្សាទុក (save) Power Point នីមួយៗដោយមានឈ្មោះកុមារ ឬឈ្មោះថ្នាក់។ អនុវត្តការអានរួមគ្នានៅក្នុងថ្នាក់។<br><br>**គ.**ជម្រើសផ្សេងៗទៀត ដើម្បីសរសេរលិខិតដែលមានរបៀបរៀបរយ អាចរកបាននៅលើlink មេរៀន "Dear Peter Rabbit Letter Writing" ដូចខាងក្រោម៖<br>• *ReadWriteThink Friendly Letter Generator*<br>• *Study Zone Letter Interative*<br>• *Let's Write a Letter Interative*<br>• *ReadWriteThink Post Card Generator* |

| | |
|---|---|
| | 6. សិល្បៈ៖ សិស្សអាចបង្កើតម្ហូករូបទន្សាយ ឬគ្រឿងលម្អសម្រាប់ពាក់លើក្បាល។ គេហទំព័រមួយដែលអាចជួយបានគឺគេអាចរកបាននៅលើlinkមេរៀន "Dear Petter Rabbit Letter Writing"។<br><br>7. ការបង្ហាញសំបុត្រដល់សិស្សក្នុងថ្នាក់រៀន៖ សិស្សម្នាក់ៗនឹងបង្ហាញ ឬអានសំបុត្ររបស់ពួកគេឱ្យសិស្សនៅក្នុងថ្នាក់រៀនស្តាប់។ ចំណាំ៖សិស្សអាចពាក់ត្រចៀកទន្សាយរបស់គេនៅពេលអានសំបុត្ររបស់ខ្លួនផ្ញើទៅកាន់ទន្សាយ Peter។ ថតសាច់រឿងនានា ដោយប្រើម៉ាស៊ីនថតរូប។ ចែកឱ្យសិស្សក្នុងថ្នាក់មើលនៅពេលបញ្ចប់មេរៀន។<br><br>8. គេហទំព័រ ឬប្លុក(Webpageឬblog)៖ ជម្រើស៖ សម្រាប់អ្នកដែលមានគេហទំព័រ សិស្សអាចថតរូបគ្នាទៅវិញទៅមកដោយប្រើម៉ាស៊ីនថតរូបឌីជីថល ហើយគ្រូបង្រៀនអាចដាក់រូបថតសិស្ស នោះនៅក្នុងសំបុត្រដែលសិស្សនោះបានសរសេរ។ អ្នកអាចធ្វើដូចនេះនៅក្នុងប្លុកបានដែរ។ (សូមមើលឧទាហរណ៍ ដើម្បីចែករំលែកជាមួយសិស្ស)។ លិខិតរបស់លោកស្រីSadie ផ្ញើទៅកាន់Peter អាចរកបាននៅលើ Link មេរៀននៃការសរសេរសំបុត្រ "*Dear Peter Rabbit Letter*"។<br><br>9. គំនិតបន្ថែមទៀតសម្រាប់សកម្មភាពបុណ្យរំលឹកថ្ងៃដែលព្រះយេស៊ូគ្រិស្តរស់វិញ (Easter) អាចរកបាននៅលើគេហទំព័រ *Vermilion Parish Easter Holiday* នៅលើ Link មេរៀន "*Dear Peter Rabbit Letter Writing*"។<br><br>10. រឿងបន្ថែម៖ ប្រៀបធៀបរឿងប្រឌិត និងរឿងពិតរបស់សត្វទន្សាយ និងការរស់រានមានជីវិត។ រឿងពិតរបស់សត្វទន្សាយឈ្មោះBugsដែលរស់រានមានជីវិតពីខ្យល់ព្យុះ Hurricane Katrina អាចរកបាននៅលើLinkមេរៀន "*Dear Peter Rabbit Letter Writing*"។ |

| | |
|---|---|
| | គ្រូបង្រៀនអាចប្រើប្រាស់ការឆ្លើយឆ្លងគ្នាតាមរបៀប "ប្រៀបធៀបព័ត៌មានដូចគ្នានិងផ្ទុយគ្នា" តាមរយៈសាច់រឿងផ្សេងៗ ឬប្រើដ្យាក្រាម ដែលគេអាចរកបាននៅក្នុង Link មេរៀន "*Dear Peter Rabbit Letter Writing*"។ |
| **ករណីសិស្សពិបាក** ក្នុងការបែងចែកឱ្យដាច់ពីគ្នានូវតួអក្សរមួយចំនួនមានលក្ខណៈស្រដៀងគ្នា។<br>*ឧទាហរណ៍៖*<br>- ព្យញ្ជនៈ៖ ប ម ស ល ហ រ វ ...<br>- ស្រៈ៖ ា ោ ែ ា ោ...<br>- ព្យញ្ជនៈផ្សំជាមួយស្រៈ ដូចជា រនាំង របាំង នោស់ របស់ រមាស់ ... | **វិធីបង្រៀន៖**<br>➢ បង្ហាញអក្សរធំៗ ដែលមើលទៅស្រដៀងគ្នាដើម្បីជួយសិស្សឱ្យងាយស្រួលក្នុងការចំណាំព្យញ្ជនៈទាំងនោះ និងកំណត់ពីភាពខុសគ្នា។<br>➢ អានអក្សរឮៗច្បាស់ៗដោយចង្អុលទៅអក្សរ និងឱ្យសិស្សអានតាម។<br>➢ ឱ្យសិស្សគូរ(សរសេរអក្សរ)ប្រៀបធៀបគ្នា ហើយប្រាប់ពួកគេពីអក្សរដែលមានរូបស្រដៀងគ្នា និងខុសគ្នា។<br>➢ ឱ្យសិស្សរកមើលអក្សរ (ទាំងព្យញ្ជនៈ និងស្រៈ)នៅក្នុងអត្ថបទមួយ ហើយចង្អុល គូសរង្វង់ជុំវិញ គូសបន្ទាត់ពីក្រោម ឬចម្លងអក្សរនោះ។<br>➢ ប្រើឯកសារ និងសកម្មភាពផ្សេងៗគ្នាដើម្បីបង្រៀនពីគោលគំនិតទាំងនេះ។ |
| **ករណីសិស្សពិបាក** ក្នុងការបែងចែកឱ្យដាច់ពីគ្នា នូវតួអក្សរ តាមក្រុមសម្លេង<br>*ឧទាហរណ៍៖*<br>- ព្យញ្ជនៈពួក អ៊ះម និង ន | **វិធី និងល្បិចបង្រៀន៖**<br>**គោលបំណង៖**<br>១. នាំសិស្សឱ្យស្គាល់: សូរ និងតួអក្សរ<br>២. នាំសិស្សឱ្យស្គាល់: តួអក្សរ និងសូរ<br>៣. ចែកឱ្យដាច់: ទាំងតួអក្សរ និងសូរ<br>**វិធី៖** ភ្ជាប់ពី រូបី ទៅអរូបី (ឧទាហរណ៍ មុង និង នំ)<br>1. គូររូប ឬប្រើរូបមុង និងនំ សម្រាប់បិទលើក្ដាខៀន<br>2. ប្រើតួអក្សរ «ម» និង «ន» សម្រាប់បិទលើក្ដារខៀន<br>3. នាំសិស្សឱ្យផ្គូផ្គងរវាងតួអក្សរ "ម ជាមួយរូប មុង និងអក្សរ «ន» ជាមួយរូប នំ" (ដៃគូ និងក្រុម)<br>4. នាំសិស្សគូរ និងសរសេរអក្សរ «ម» និង «ន» (ដៃគូ និងក្រុម)<br>ក).ប្រើទម្រង់ចំណុចដាច់ៗ រួចគ្រូគូសភ្ជាប់ឱ្យមើល |

| | |
|---|---|
| | ខ).គ្រូគូរ ឬប្រើទម្រង់អក្សរចំណុចៗ ឱ្យសិស្សគូរជាអក្សរ (ម និង ន)<br>គ).គ្រូឱ្យសិស្សគូរជារាងអក្សរ ដោយគ្មានចំណុច ។<br>5. ផ្គូផ្គងរូប ជាមួយតួអក្សរ<br>ក).គ្រូត្រៀមរូបឱ្យបានច្រើន ដែលមានដូចជា មុង មូស មើម នំ ធុង សត្វទុង ទ្រុង ផ្លែមៀន<br>ខ).សិស្សផ្គូផ្គងរូបជាមួយតួអក្សរ (ជាដៃគូ និងក្រុម)<br>គ).សិស្សស្វែងរករូបណា ដែលមានតួអក្សរមិនមែន «ម» និង «ន» (ប្រកួតតាមក្រុម)។<br>6. ឱ្យសិស្សប្រាប់សូរ របស់តួអក្សរ «ម» និង «ន» របស់រូបភាពទាំងអស់ (កិច្ចការដៃគូ និងក្រុម)។ |
| **ករណីសិស្សពិបាក** ញែកសូរសំឡេងរបស់តួអក្សរ និងស្រៈ។<br>*ឧទាហរណ៍៖*<br>- សូរព្យញ្ជនៈ៖ ម ភ រ វ ល យ<br>- សូរស្រៈ៖ ា ៃ ោ ៅ<br>- សូរផ្សំ៖ កា កោ កៅ ចេ ចៃ<br>- សូរប្រកប៖ កប ចង គាត់<br>- សូរប្រកប៖ ក្ងាន ក្បាច់ | **វិធីបង្រៀន៖**<br>➢ ដើរទៅឈរនៅខាងមុខសិស្ស បង្ហាញអក្សរ និងអានអក្សរ ឱ្យបានច្បាស់ៗ។<br>➢ ចង្អុលអក្សរ និងឱ្យសិស្សអានអក្សរនោះម្តងមួយៗ ព្រមទាំងប្រាប់ពីសំឡេងខុសៗគ្នារបស់អក្សរទាំងនោះ។<br>➢ ឱ្យសិស្សអនុវត្តការអានជាក្រុម ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយមានជំនួយពីសិស្សពូកែ។<br>➢ អនុវត្តការបែងចែកសំឡេងរបស់ស្រៈ និងព្យញ្ជនៈ តាមរយៈការច្រៀង អានអត្ថបទ បង្ហាញរូបភាព។ល។ ហើយឱ្យសិស្សកំណត់សំឡេងរបស់អក្សរនីមួយៗនៅក្នុងអត្ថបទ។ ឧទាហរណ៍៖ ការបែងចែកសម្លេងតាមរយៈបទចម្រៀង ជាដើម។<br>• កខខិតខំសិក្សា គគាគិគីគឺកូនគីង្គក់<br>• ឃឃាកុំដេកទ្រមក់ងងើបកុំងក់កខគឃង។<br>➢ ចែកសិស្សជា២ក្រុម ដោយក្រុមទី១ច្រៀង ហើយទី២ស្តាប់ បន្ទាប់មកក្រុមទី២ច្រៀង និងក្រុមទី១ស្តាប់វិញម្តង។ នៅពេលបញ្ចប់ គ្រូសួរថា៖<br>• តើមានសម្លេងអក្សរ«ក»ចំនួនប៉ុន្មាននៅក្នុងបទ |

| | |
|---|---|
| | ចម្រៀង? (សរសេរចម្លើយនៅលើក្តារខ្នួន)<br>• គ្រូបញ្ជាក់ចម្លើយដោយសរសេរបទចម្រៀងនៅលើក្តារខៀន។ |
| | **វិធី និងល្បិច បង្រៀន៖**<br>**គោលបំណង៖**នាំសិស្សឱ្យស្គាល់: <u>សូររបស់តួអក្សរ និងស្រះ</u><br>**វិធី៖** ភ្ជាប់ពី រូបី ទៅអរូបី (ឧទាហរណ៍ ម យ រ វ ល)<br>ក. ទំនាក់ទំនងរវាងតួអក្សរ និងសូរ<br>1. គ្រូប្រាប់ពាក្យគំរូដល់សិស្ស (ឈ្មោះមនុស្ស ឈ្មោះវត្ថុ ឈ្មោះទីកន្លែង ឈ្មោះសត្វ)។ ឧទាហរណ៍ មង មួក មេឃ មុង លុយ វាល...) ដែលមានតួអក្សរខាងលើ ដោយភ្ជាប់សូររបស់តួអក្សរ ទៅនឹងឈ្មោះ។<br>2. គ្រូយកអក្សរចល័ត (តួអក្សរខាងលើ) មកផ្គូផ្គងជាមួយរូបភាព ដែលមានតួអក្សរខាងលើ ចំនួនមួយ ឬពីរ។ ឧទាហរណ៍<br>▪ ម–មង ម–មួក ម–មេឃ រ–រៀល រ–រុយ វ–វាល<br>3. សិស្សស្វែងរកពាក្យ ពីសៀវភៅ កាសែត ទស្សនាវដ្តី និងពីឈ្មោះមនុស្ស វត្ថុ ទីកន្លែង សត្វ ដែលមានសម្លេងតួអក្សរ ខាងលើ (ការងារដៃគូ និងការងារក្រុម) រួចរាយការណ៍ជាដៃគូ ដោយការសរសេរ និងអានបញ្ចេញសម្លេង យឺតៗ)<br>4. សិស្សផ្គូផ្គងរូបភាព ដែលមានសូររបស់តួអក្សរខាងលើជាមួយតួអក្សរដែលត្រូវ (ការងារដៃគូ និងក្រុម)។ ឧទាហរណ៍ មង មុង មួក មេឃ រុយ វាល លុយ យំ រោម វែក<br>5. សិស្សផ្គូផ្គងរូបភាព ជាមួយតួអក្សរចល័ត ដើម្បីបង្ហាញថា សូររបស់តួអក្សរនៅក្នុងរូបភាព មិនមែនជាសូរ របស់តួអក្សរ ម យ រ វ ល<br>ឧទាហរណ៍ ធុង ពោត ដេក ចេក គោ សោ ។ |
| **ករណីសិស្សពិបាក** ញែកសូរ ផ្សំសូរ និងប្រកបពាក្យថ្មីឱ្យបានត្រឹមត្រូវ<br>ឧទាហណ៍: | **វិធី និងល្បិចបង្រៀន៖**<br>**គោលបំណង៖** នាំសិស្សឱ្យចេះ:<br>១. <u>ស្គាល់តួអក្សរ និងសូររបស់តួអក្សរ</u> |

| | |
|---|---|
| - សុខ<br>- គុក<br>- ចាប | ២. ញែកសូររបស់ពាក្យ ( សូរដើម សូរបន្ទាប់ និងសូរចុង )<br>៣. ផ្សំសូររបស់ពាក្យ<br>៤. បញ្ចេញសម្លេងរបស់ពាក្យ។<br>**វិធី៖** ភ្ជាប់ពីរូបីទៅអរូបី ( ឧទាហរណ៍ ចាប )<br>1. គ្រូនាំយកពាក្យថ្មីមកសិក្សា ( ឧទាហរណ៍ បង្ហាញរូបចាប រួចសួរសិស្សថាជាអ្វី? ហៅថាអ្វី? បន្លឺសូរសម្លេងឃីតៗ)<br>2. គ្រូនាំសិស្សឱ្យស្គាល់តួអក្សរ និងសូររបស់វា ដោយញែកព្យាង្គ និងសូរ<br>➢ គ្រូសួរ៖ តើពាក្យ "ចាប" មានប៉ុន្មានព្យាង្គ?អ្វីខ្លះ?<br>➢ សិស្សពិភាក្សាដៃគូ១នាទី និងឆ្លើយតាមក្រុមថាមានមួយព្យាង្គគឺ"ចាប"<br>➢ គ្រូសួរ៖ តើពាក្យ"ចាប" មានសូរដើមរបស់ព្យញ្ជនៈអ្វី ? ចូរពិភាក្សាជាមួយដៃគូ<br>➢ សិស្សឆ្លើយថា មានសូរដើមរបស់ព្យញ្ជនៈ "ច"<br>➢ គ្រូដាក់កិច្ចការ៖ តើពាក្យនេះ មានព្យញ្ជនៈ និងស្រៈអ្វីខ្លះ? ចូររាប់ព្យញ្ជនៈ និងស្រៈទាំងអស់ដែលមាននៅក្នុងពាក្យនេះ<br>➢ សិស្សធ្វើការជាដៃគូ ឬក្រុម រួចបង្ហាញលទ្ធផលតាមក្រុម៖<br>▪ ចំនួនព្យញ្ជនៈមានពីរគឺ "ច និង ប"<br>▪ ចំនួនស្រៈមានមួយគឺ "ស្រៈា"<br>3. គ្រូនាំសិស្ស រកសូរដើម សូរបន្ទាប់ និងសូរចុង របស់ព្យាង្គ និងពាក្យ<br>➢ គ្រូដាក់កិច្ចការ៖ ចូរប្រាប់សូរដើម សូរបន្ទាប់ និងសូរចុង នៅក្នុងពាក្យ "ចាប"<br>➢ សិស្ស"ការងារដៃគូ"៖ ទុករយៈពេល១នាទី ឱ្យសិស្សសរសេរលើផ្ទាំងក្រដាស់តាមក្រុមៈ ចាប "ច"ជាសូដើម "ា"ជាសូរបន្ទាប់ និង "ប" ជាសូរចុង(**ល្បែងចងចាំសូរដើម សូរបន្ទាប់ និងសូរចុង**)<br>➢ គ្រូរៀបចំតួអក្សរ "ច ា ប" ឱ្យធំៗ ដើម្បីឱ្យសិស្សតាមក្រុមដែលមានគ្នា៣នាក់ លេងប្រណាំងគ្នា នៅមុខថ្នាក់រៀន។ |

| | |
|---|---|
| | **<u>វិធីលេង</u>៖**<br>a. កុមារ៣ក្រុម ចូលប្រកួតម្តងៗ ក្នុង១ក្រុមមានគ្នា៣នាក់ ដែលម្នាក់ៗកាន់តួអក្សរមួយរបស់ពាក្យ «ចាប» គឺ «ច»សូរដើម «ា»សូរបន្ទាប់ និង «ប»សូរចុង<br>b. គ្រូរៀបកុមារទាំង៣ក្រុម ដែលក្រុមនីមួយៗ ចាប់ដៃគ្នាជារង្វង់ ដោយទុកពេលឱ្យកុមារចាត់ចែងក្នុងក្រុមរៀងៗខ្លួន<br>c. គ្រូគូសបន្ទាត់លើស្មួនស្មៅ សម្រាប់ឱ្យសមាជិកតាមក្រុមនីមួយៗ រត់ទៅតម្រង់ជួរគ្នាដើម្បីបង្កើតជាពាក្យ ចាប នៅលើបន្ទាត់ទាំង៣<br>d. គ្រូស្រែកឱ្យកុមារទាំង៣ក្រុមចាប់ផ្តើម រត់ចូលក្នុងបន្ទាត់តាមក្រុមរៀងខ្លួន ដើម្បីបង្កើតជាពាក្យ "ចាប" ពីឆ្វេងទៅស្តាំ ដោយទុកពេលឱ្យកុមារ តាមរយៈការរាប់ចំនួន ១ ដល់ ៥។<br>e. ក្រុមណារៀបចំបានត្រឹមត្រូវ និងមុនគេ នឹង ទទួលបានជ័យជំនះ។<br>**សំគាល់៖** គ្រូត្រូវនាំសិស្សដែលពិបាកក្នុងការញែកសូរ ផ្សំសូរ និងប្រកបពាក្យថ្មី ចូលលេងឱ្យបានស្ទាត់។<br>4. គ្រូនាំសិស្សផ្សំសូរ និងតួអក្សរឱ្យទៅជាពាក្យ<br>➢ គ្រូដាក់កិច្ចការ៖<br>តើពាក្យ «ចាប» ប្អូនសរសេរអក្សរអ្វីខ្លះ?<br>តើពាក្យ «ចាប» ប្អូនប្រកបដូចម្តេចខ្លះ?<br>➢ សិស្សធ្វើការជាដៃគូ និងរាយការណ៍តាមតុ៖<br>ពាក្យ "ចាប" ខ្ញុំសរសេរ «ច ា និង ប»<br>ពាក្យ"ចាប" ខ្ញុំប្រកប «ច ា ចា និង ប ចាប»<br>5. គ្រូនាំសិស្សបន្លឺសូររបស់ពាក្យឱ្យបានត្រឹមត្រូវ<br>➢ គ្រូអានបន្លឺសូរ៥ដង ពីយឺត ទៅញាប់<br>➢ សិស្សអានតាមក្រុមធំ ៥ដង<br>➢ សិស្សអានជាដៃគូឱ្យគ្នាស្តាប់២ទៅ៥ដង។ |
| **ករណីសិស្សផ្សំសូរ និងប្រកបមិនបានត្រឹមត្រូវ៖** | ➢ បង្ហាញរូបភាព និងបណ្ណពាក្យដែលតំណាងឱ្យរូបភាព។<br>➢ ឱ្យសិស្សផ្សំអក្សរចល័តដើម្បីបង្កើតពាក្យមួយដែលមាន |

| | |
|---|---|
| *ឧទាហរណ៍៖*<br>- ផ្សំសូរ៖ តោ គោ ខោ<br>- ប្រកបសូរ៖ តោ គោ ខោ | ន័យដូចក្នុងរូបភាពដែលបានបង្ហាញ។<br>➢ អនុវត្តផ្សំសូរដោយប្ដូរព្យញ្ជនៈ ឬស្រៈ ដើម្បីឱ្យសិស្សយល់ពីការផ្លាស់ប្ដូរសូរ និងទីតាំងរបស់អក្សរផ្សំ។<br>➢ សរសេរពាក្យគំរូមួយនៅលើក្ដារខៀន ហើយឱ្យសិស្សអានពាក្យនោះ។<br>➢ លុបព្យញ្ជនៈ ឬស្រៈដើម ហើយរក្សាទុកព្យញ្ជនៈ ឬស្រៈដែលសិស្សត្រូវរៀន។<br>• ឧទាហរណ៍ទី១៖ គ្រូសរសេរ «តោ» ហើយឱ្យសិស្សអាន។ បន្ទាប់មក គ្រូលុប ឬជំនួសព្យញ្ជនៈ «ត» ដោយ «ខ និង គ» ... ហើយឱ្យសិស្សអាន<br>• កុមារហ្វឹកហាត់ជាដៃគូ ដោយម្នាក់ជាអ្នកសរសេរ ម្នាក់ទៀតជាអ្នកអានបញ្ចេញសូរ ។ |
| **ករណីសិស្សអានពាក្យ និងល្បះ មិនបានត្រឹមត្រូវ៖** | 1. អនុវត្តតាមវិធី និងល្បិចសម្រាប់ការបង្រៀនអំពី៖<br>➢ ការស្គាល់សូរ<br>➢ ការស្គាល់តួអក្សរ និងសូរ<br>➢ ការអានពាក្យ និងអានស្ទាត់<br>➢ រៀនវាក្យស័ព្ទ និងអានស្ទាត់<br>2. ឱ្យសិស្សអានម្ដងមួយពាក្យៗ ហើយបន្ទាប់មក២ ឬ៣ពាក្យម្ដង ក្រោយមកទៀតអានឃ្លាទាំងមូលតែម្ដង។ ឱ្យសិស្សដែលទទួលបានលទ្ធផលការសិក្សាល្អ ប្រាប់នូវពាក្យណាមួយដែលសិស្សដទៃមិនអាចអានរួច។<br>3. ឱ្យសិស្សអានឃ្លាទាំងមូលម្ដងទៀត។<br>4. បន្តធ្វើដូចនេះរហូតទាល់តែសិស្សអានចប់អត្ថបទទាំងមូល។ |
| ករណី សិស្សអានដោយពុំយល់ ន័យខ្លឹមសារ។ | ➢ ឱ្យសិស្សអានពាក្យ ឬឃ្លាដោយប្រើរូបភាព វត្ថុពិត ឬតាមរយៈការប្រៀបធៀប ឬការផ្ដល់ឧទាហរណ៍។<br>➢ ផ្ដល់រូបភាព ឬវត្ថុពិតដែលត្រូវនឹងបណ្ណពាក្យ។<br>➢ ដឹកនាំសិស្សឱ្យអានពាក្យតាមរយៈការប្រើរូបភាព។<br>➢ បន្ថែមរូបភាព និងបណ្ណពាក្យ៣ឬ៤ថែមទៀត ហើយឱ្យសិស្សផ្គូផ្គងរូបភាព ឬវត្ថុពិតជាមួយបណ្ណពាក្យ។ |

**គន្លឹះ វិធី និងល្បិច មួយចំនួនសម្រាប់ជួយសិស្ស រៀនអានយល់ន័យ៖**
**គោលបំណងធំ៖** សិស្សយល់ន័យរបស់ពាក្យ ឃ្លា ល្បះ ប្រយោគ កថាខណ្ឌ និងអត្ថបទទាំងស្រុង។
**គោលបំណងតូច៖** សិស្សមានសមត្ថភាពអាច៖

1. ផ្គូផ្គង ពាក្យ ឬឃ្លា ជាមួយរូបភាព (វិធីងាយៗ)
2. ជ្រើសរើសពាក្យ ឃ្លា ឬប្រយោគ ភ្ជាប់ជាមួយរូបភាព បំពេញក្នុងចន្លោះដែលបាត់ (វិធីងាយៗ)
3. ពិភាក្សារកចម្លើយ ដោយប្រើវិធីអាន ផ្អែកលើអត្ថបទ
4. រៀបលំដាប់ព្រឹត្តិការណ៍ ក្នុងរឿងតាមលំដាប់លំដោយត្រឹមត្រូវ ភ្ជាប់ជាមួយរូបភាព (វិធីមានលក្ខណៈលំបាក)
5. សង្ខេបអត្ថបទ ឬសាច់រឿងឡើងវិញ ភ្ជាប់ជាមួយរូបភាព (វិធីមានលក្ខណៈលំបាក)

***សំគាល់៖*** គ្រូគួរជ្រើសរើសវិធីងាយៗ នៅពេលអនុវត្តដំបូង រួចឈានទៅរកវិធីលំបាក

| វិធី | សកម្មភាព | |
|---|---|---|
| | សកម្មភាពគ្រូ | សកម្មភាពសិស្ស |
| ១.ផ្គូផ្គងពាក្យ ឬឃ្លាជាមួយរូបភាព<br>(រយៈពេល ៥នាទី) | 1. គ្រូចែកបណ្ណពាក្យ បណ្ណឃ្លា បណ្ណរូបភាព និងពន្យល់<br>2. គ្រូណែនាំសិស្សឱ្យកែកិច្ចការឆ្លាស់ក្រុមគ្នា<br>3. គ្រូបង្ហាញចម្លើយដែលត្រឹមត្រូវ | ការងារក្រុម៖<br>1. ផ្គូផ្គងបណ្ណពាក្យ បណ្ណឃ្លា និងបណ្ណរូបភាព ឱ្យសមស្រប ដាក់ក្នុងកូឡោនពីរដោយគូសសញ្ញា ព្រួញភ្ជាប់គ្នា<br>2. ផ្ទៀងផ្ទាត់ចម្លើយគ្នាទៅវិញទៅមក |
| ២.ជ្រើសរើសពាក្យ ឬឃ្លា បំពេញក្នុងចន្លោះដែលបាត់។<br>(រយៈពេល៥នាទី) | 1. គ្រូចែកអត្ថបទដែលបាត់ពាក្យ ឬឃ្លាមួយចំនួន<br>2. គ្រូចែកបណ្ណពាក្យ ឬឃ្លាដែលត្រូវប្រើសម្រាប់បំពេញក្នុងចន្លោះ (ត្រូវបង់លេខរៀង និងភ្ជាប់ជាមួយរូបភាព)<br>3. គ្រូណែនាំក្រុមធំ និងដើរជួយតាមក្រុមតូច<br>4. គ្រូបង្ហាញចម្លើយត្រឹមត្រូវ | ការងារដៃគូ៖<br>1. អានអត្ថបទ ដែលបាត់ពាក្យ ឬឃ្លា<br>2. អានពាក្យ ឬឃ្លា សម្រាប់បំពេញចន្លោះ<br>3. ជ្រើសរើសពាក្យ ឬឃ្លាយកទៅផ្គូផ្គង<br>4. ផ្លាស់ប្តូរ និងកែចម្លើយរវាងក្រុមពីរៗ |
| ៣.ពិភាក្សារកចម្លើយ ដោយប្រើវិធីអាន ផ្អែកលើ | 1. គ្រូសរសេរសំនួរមួយចំនួនលើក្តារខៀន | **១.ការងារបុគ្គល៖**<br>➢ ឡើងអានសំនួរមួយសំនួរម្នាក់ |

| | | |
|---|---|---|
| អត្ថបទ ។<br>(រយៈពេល ៥នាទី) | 2. គ្រូនាំសិស្សពិភាក្សាសំនួរ និង ពន្យល់សំនួរ<br>3. គ្រូណែនាំសិស្សឱ្យអានអត្ថបទ និង ដើរជួយកុមារដែលពិបាកក្នុងការអាន<br>4. គ្រូណែនាំសិស្សអំពីរបៀប "អាន ស្ទាត់" "អានលឿន" "អានឃើត" "អានទៅមុខ និងត្រឡប់ក្រោយ" ដើម្បីស្វែងរកព័ត៌មាន និងអត្ថន័យ របស់ពាក្យ ដោយប្រើម្រាមដៃ<br>5. គ្រូណែនាំសិស្ស អំពីរបៀបស្រង់ ចម្លើយ<br>6. គ្រូណែនាំសិស្ស ឱ្យប្រៀបធៀប ចម្លើយជាមួយដៃគូ<br>7. គ្រូនាំសិស្សទៅរកចម្លើយដែលត្រឹម ត្រូវ។ | **២.ការងារដៃគូ៖**<br>➢ ពិភាក្សាអត្ថន័យរបស់សំនួរ នីមួយ<br>**៣.ការងារបុគ្គល៖**<br>➢ យកអត្ថបទមក "អានស្ទាត់" "អានលឿន" "អានឃើត" "អានទៅមុខ និងត្រឡប់ ក្រោយ" ដើម្បីស្វែងរក ព័ត៌មាន និងអត្ថន័យរបស់ ពាក្យ ដោយប្រើម្រាមដៃគូស បន្ទាត់ពីក្រោមល្បះដែលអាច ជាចម្លើយរបស់សំនួរនីមួយៗ រួចបង់លេខ<br>**៤.ការងារដៃគូ៖**<br>➢ ប្រៀបធៀបចម្លើយជាមួយដៃគូ<br>➢ រាយការណ៍ចម្លើយជាលក្ខណៈ ដៃគូ។ |
| ៤. រៀបលំដាប់ព្រឹត្តិការណ៍ ក្នុងសាច់រឿង តាមលំដាប់ លំដោយត្រឹមត្រូវ ដោយ ភ្ជាប់ជាមួយរូបភាព។<br>(រយៈពេល ៥នាទី) | 1. បង្កើតបណ្ណល្បះ ទៅតាមលំដាប់ លំដោយ នៃព្រឹត្តការណ៍ក្នុងរឿង (គ្រូអាចប្រើសកម្មភាពប្រចាំថ្ងៃ របស់សិស្ស ឬអត្ថបទ និងភ្ជាប់ ជាមួយរូបភាព) ដោយដាក់អក្សរ « ក.ខ.គ.ឃ.ង» នៅខាងដើមបណ្ណ ល្បះនីមួយៗ<br>2. បិទបណ្ណល្បះលើក្ដារខៀន ឱ្យខុសពី លំដាប់ព្រឹត្តការណ៍ របស់សាច់រឿង<br>3. ដាក់កិច្ចការឱ្យសិស្សសិក្សាអត្ថន័យ របស់ល្បះនីមួយៗ ដើម្បីរៀបតាម ព្រឹត្តការណ៍របស់សាច់រឿង ដែល មានរូបភាព សម្រាប់ជួយកុមារ<br>4. ដើរជួយតាមក្រុម<br>5. បង្ហាញចម្លើយត្រឹមត្រូវដល់សិស្ស។ | **ការងារក្រុម៖**<br>1. សិក្សាន័យរបស់ល្បះនីមួយៗ<br>2. ពិភាក្សារៀបបណ្ណល្បះតាម លំដាប់លំដោយនៃព្រឹត្តការណ៍ សាច់រឿង<br>3. សរសេរលេខរៀង "១.២.៣ .៤.៥" ភ្ជាប់នៅខាងចុងនៃ បណ្ណល្បះនីមួយៗ<br>4. ក្រុមនីមួយៗបង្ហាញចម្លើយ នៅលើផ្ទាំងក្ដារខៀនក្រុម<br>5. ក្រុមនីមួយៗផ្លាស់ប្ដូរចម្លើយ គ្នាទៅវិញទៅមក ។ |

| | | |
|---|---|---|
| ៥. សង្ខេបអត្ថបទ ឬសាច់រឿងឡើងវិញ ដោយប្រើអត្ថបទ និងរូបភាព | 1. គ្រូរៀបចំសិស្ស៤នាក់ក្នុងមួយក្រុម<br>2. ណែនាំកិច្ចការៈ ឱ្យកុមារចែកគ្នាទទួលខុសត្រូវរៀបរាប់សាច់រឿងឡើងវិញ មួយឬពីរប្រយោគ ក្នុងសមាជិកម្នាក់<br>3. ដើរជួយក្រុម បែងចែកការងារ និងហ្វឹកហាត់<br>4. ណែនាំកុមារអំពីនីតិវិធីបង្ហាញលទ្ធផល<br>5. សម្របសម្រួលឱ្យសិស្សប្រកួតគ្នាសង្ខេបសាច់រឿង | ការងារក្រុមៈ<br>1. ចាត់ចែងគ្នាក្នុងក្រុមទទួលខុសត្រូវសង្ខេបសាច់រឿងតាមឃ្លា និងប្រយោគសម្រាប់ម្នាក់ៗ<br>2. សមាជិកក្នុងក្រុមសួរគ្នាឱ្យរៀបរាប់ឃ្លានិងប្រយោគរបស់ខ្លួន ឱ្យសមាជិកដទៃស្តាប់ (ហ្វឹកហាត់រហូតចាំ)<br>3. ចាប់ផ្តើមរៀបរាប់ សង្ខេបតាមក្រុម<br>ក.សង្ខេបតាមក្រុមៈ សិស្សក្នុងក្រុមនីមួយៗ និយាយសង្ខេបសាច់រឿងតគ្នាពីសមាជិកម្នាក់ទៅសមាជិកម្នាក់ទៀត ។<br>ខ.សង្ខេបឆ្លងក្រុមៈសិស្សម្នាក់ក្នុងក្រុម១ សង្ខេបឃ្លាទី១ សិស្សម្នាក់ទៀតក្នុងក្រុម២ រៀបរាប់សាច់រឿងបន្ត ដោយគ្រូ ជាអ្នកសម្របសម្រួល តាមឃ្លាល្បះ និងកាត់សេចក្តីថាត្រូវ ឬខុសបន្តរបៀបនេះរហូតដល់ចប់។ |

| ឧទាហរណ៍ស្តីពីសកម្មភាពនៃការលំបាកក្នុងការគណនា | |
|---|---|
| សញ្ញានិង លក្ខណៈសម្គាល់ | វិធីសាស្ត្រ បច្ចេកទេស សកម្មភាពនិងសម្ភារ |
| • បង្ហាញពីការលំបាកក្នុងការយល់ពីគោលគំនិតនៃតម្លៃតាមខ្នង់ និង បរិមាណបន្ទាត់លេខ តម្លៃ វិជ្ជមាន និងអវិជ្ជមាន ការត្រាទុក និងការខ្ចី<br>• មានការលំបាកក្នុងការរៀបចំព័ត៌មានឬសកម្មភាពតាមលំដាប់លំដោយ<br>• មានការលំបាកក្នុងការបំលែងភាសាទៅតាមដំណើរការ គណិតវិទ្យា | ការលំបាកក្នុងការគណនា៖សកម្មភាព<br><br>ល្បែងគណិតវិទ្យា៖<br><br>• **ល្បែងប្រើក្តារ** (board games) ជួយឱ្យកុមារអនុវត្តការផ្គូផ្គងចំណុចៗនៅលើគ្រាប់ឡុកឡាក់ ឬសំណុំនៃ វត្ថុផ្សេងៗដើម្បីធ្វើឱ្យចំនួនចន្លោះត្រឹមត្រូវក្នុងការផ្លាស់ទី។ ឧទាហរណ៍ ដូចជាល្បែង Candy Land សមស្របចំពោះល្បែងប្រភេទនេះ។<br>• Board books ក៏ឱ្យផ្គូផ្គងចំនួន និងវត្ថុ ។ កុមារត្រូវគូសភ្ជាប់ចំនួនដែលត្រូវទៅនឹងវត្ថុក្នុងសៀវភៅកិច្ចការ។<br>.<br>• **ល្បែងផ្គូផ្គង** ឱ្យកុមារតាមដានពីទីកន្លែងដែលពួកគេឃើញ វត្ថុនិងលំនាំគំរូផ្សេងៗ។ ល្បែង ដូមីណូ (Dominoes) ក៏ធ្វើឱ្យកុមារអនុវត្តការផ្គូផ្គងចំនួន និងវត្ថុផ្សេងៗផងដែរ។<br>• **ល្បែងអាថ៌កំបាំង** មានសំណួរចំនួន 20 ឬទាយតើអ្នកណា? ឱ្យកុមាររក្សាព័ត៌មានទុកក្នុងចិត្តដើម្បីប្រើជាវិធីសាស្ត្រក្នុងការស្វែងរកឬទៅរកចម្លើយដែលត្រឹមត្រូវ។<br><br>• **ល្បែងរៀបក្រឡាដើរតាមទីតាំង** ឱ្យកុមារស្វែងរកមធ្យោបាយដើម្បីផ្លាស់ប្តូរផ្នែកផ្សេងៗសម្រាប់ទប់ឬចាប់យកផ្នែកផ្សេងៗ ទៀត។ ល្បែងនេះរួមមានល្បែងផ្សេងៗដូចជាអុក។<br><br>• **ល្បែងគណនាលេខ** ពាក់ព័ន្ធនឹងការដកចេញ ការលុប ចេញ ឬការរៀបចំឡើងវិញនូវបំណែកផ្សេងៗដើម្បីឈ្នះ។ ល្បែង នេះរួមមានបាយខុម (mancala) និងល្បែងបៀរ ដូចជា Uno និង trash។<br><br>• **ល្បែងគ្រប់គ្រងធនធាន** ដូចជា Monopoly ឬ Carcassone ឱ្យកុមារ ឱ្យគិតពីចំនួនលុយ ឬធនធាន(ដូចជាទ្រព្យសម្បត្តិ) ដែលពួកគេមាន និងរបៀបដែលពួកគេអាចប្រើលុយ ធនធាន |

| | |
|---|---|
| | ទាំងនោះដើម្បី សម្រេចបានគោលដៅមួយ។ វីដេអូស្ដីពីការលំបាកក្នុងការគណនា៖<br>[https://sharemylesson.com/teaching-resource/dyscalculia-teaching-help-196309](https://sharemylesson.com/teaching-resource/dyscalculia-teaching-help-196309) |
| • មានការលំបាកក្នុងការយល់ និងធ្វើចំណោទ<br>• មានការលំបាកក្នុងការរៀបរាប់ព័ត៌មាន ឬព្រឹត្តិការណ៍នានាតាមលំដាប់លំដោយ<br>• បង្ហាញការលំបាកក្នុងការប្រើប្រាស់ជំហាននានាដែលពាក់ព័ន្ធនឹងការគណនាផ្នែកគណិតវិទ្យា | **សកម្មភាពទី5**<br>***ការបន្ថែមចំនួន ក្នុងការរាប់ចំនួនខ្ទង់រាយ***<br>ប្រើវិធីក្នុងការផ្ដុំរូបភាពផ្សេងៗ ដូចជាដុំដែលមានចំនួន10ជ្រុង ដើម្បីផ្ដុំរូបភាពដែលមើលឃើញ។ ការប្រើទម្រង់ដែលអាចកត់សម្គាល់បាន និងស៊ីសង្វាក់ ដោយផ្ដោតលើចំនួន 1, 2, 5 និង 10 ។ ឧទាហរណ៍៖<br><br>គេអាចបង្ហាញកុមារពីរបៀបដែល«បំណែក(chunking)»អាចជួយពួកគេឱ្យរៀនលេខលើសពីចំនួនមួយៗ។<br>***ការលំបាកក្នុងការរាប់ថយក្រោយ***<br>ការរាប់ថយក្រោយតម្រូវឱ្យមានការចងចាំមានដំណើរការដូច្នេះវាអាចមានការលំបាកចំពោះគ្រូបង្រៀន និង ឪពុកម្ដាយក្នុងការកត់សម្គាល់។ វាគឺជាមូលដ្ឋានក្នុងការដកលេខ។ ប្រើសម្ភារឧបទេសនិងរូបភាព។ វាគឺជា វិធីដ៏ល្អមួយសម្រាប់ការណែនាំ និងការប្រើពាក្យ «យកចេញ» និង «ដក»រួមទាំងសំណួរមួយ ក្នុងចំណោមសំណួរដែលចូលចិត្តប្រើ គឺ «តើវាធំជាង ឬតូចជាង?»<br>*ការយល់ដឹងតិចតួចអំពីចំនួន និងមិនមានសមត្ថភាពក្នុងការប៉ាន់ស្មាន។*<br>ជាថ្មីម្ដងទៀតវត្ថុដែលកំណត់នៅក្នុងលំនាំដែលអាចសម្គាល់បានដើម្បីការអភិវឌ្ឍបំណិននេះ។ ព្យាយាមប្រៀបធៀបវត្ថុដែលកំណត់ក្នុងលំនាំគំរូដោយវិធីរាប់រំលង។ "តើវាទំហំធំជាងឬតូចជាង»? សំណួរ |

នេះនឹងមានប្រយោជន៍ម្តងទៀត

*ការលំបាកក្នុងការយល់ពីតម្លៃលេខតាមខ្ទង់ និងក្បួនលេខនព្វន្ត។*

កុមារម្នាក់អាចរាប់ចំនួនរហូតដល់ដប់ ប៉ុន្តែការសរសេរចំនួនដប់ទៅជាលេខ១០ គឺជាកិច្ចការដែលមានលក្ខណៈពិបាកមួយក្នុងការយល់អំពីរបៀបដែលគេហៅចំនួននោះថា«ដប់»។ គេអាច បង្ហាញចំណុចនេះជាលំដាប់នៃការលូតលាស់ផ្នែកបញ្ញាដោយប្រើប្រាស់ដុំដែលមានចំនួនដប់ៗនៅលើប័ណ្ណតម្លៃតាមខ្ទង់មួយ ជាចំណុចចាប់ផ្តើម ហើយបន្ទាប់មកឱ្យកុមារប្រើសញ្ញា(ខ្ទង់)ដោយខ្លួនឯងផ្ទាល់។

ប្រមាណវិធីគុណ និងប្រមាណវិធីចែកជាមួយនឹងចំនួន 10, 100, 1000 ។ល។ អាចបង្ហាញតាមវិធីសាស្ត្រស្រដៀងគ្នា។

*ករណីកុមារពិបាកចាំចំនួនថេរ ប៉ុន្តែអាចយល់បានពីការគុណចំនួនពិត ដូចជា២ដង ៥ដង និង១០ដង*

គ្រប់ចំនួនថេរទាំងអស់សុទ្ធតែមានប្រយោជន៍ ហើយចំនួនថេរខ្លះមានប្រយោជន៍ជាងចំនួនថេរផ្សេងទៀត។ នោះជាប្រមាណវិធីសម្រាប់មនុស្សដែលចូលចិត្តរៀន និងរៀនបានល្អ ។

គេអាចបង្ហាញកុមារពីរបៀបភ្ជាប់លំនាំគំរូនានា (សញ្ញារបស់វា)ដើម្បីបង្ហាញពីប្រមាណវិធី បូកនិងដកចំនួន ពិត។ ឧទាហរណ៍




គោលការណ៍នេះ អាចត្រូវបានបំបែកទៅជាវិធីគុណ។ ការយល់ដឹងនឹងកើតមាន ក៏ដូចជាវិធីសាស្ត្រសម្រាប់ដំណើរការធ្វើប្រមាណវិធី។ គេភ្ជាប់ប្រមាណវិធីគុណទៅនឹងវិធីបូក ដូច្នេះគេអាចពន្យល់ និងបង្ហាញចំនួន ៧x៦ ទៅជាការបូកដដែលៗ នូវចំនួន6ចំនួន៧ដង គឺ ៦ + ៦ + ៦ + ៦+ ៦ + ៦ + ៦។ គេអាចគណនាម្យ៉ាងទៀត ដោយការបំបែកនិងផ្សំចូលគ្នាដូចជា ផ្សំលេខប្រាំមួយ «6» ចំនួន៥ដង (៦ + ៦ + ៦ + ៦ + ៦) និង (៦ + ៦) នោះគឺស្មើនឹង៥ x ៦ និង ២ x ៦ ដែលលទ្ធផលគឺ ៣០ + ១២ ដែលស្មើនឹង ៤២ ។

គេអាចអនុវត្តវិធីនេះសម្រាប់ឧទាហរណ៍ផ្សេងៗជាច្រើនទៀត ហើយវិធីនេះបង្រៀនកុមារអំពីប្រមាណវិធីគុណ និងវិធីដែលគេភ្ជាប់វាទៅនឹងប្រមាណវិធីបូក។ វាបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការគុណលេខនៅពេលដែលមានលក្ខណៈកាន់តែលំបាក។

### ល្បឿនយឺតៗនៃការធ្វើការ

មានកត្តារួមចំណែកមួយចំនួនដែលរួមបញ្ចូលគ្នាធ្វើឱ្យកុមារដែលមានការលំបាកក្នុងការគណនាមានភាពយឺតយ៉ាវក្នុងការដោះស្រាយបញ្ហាគណិតវិទ្យា ឧទាហរណ៍ការរំលឹកឡើងវិញនូវចំនួនពិត និងការរំលឹកឡើងវិញពីនិតិវិធីផ្សេងៗមានភាពយឺតយ៉ាវ និងមិនច្បាស់លាស់។ ដូច្នេះពួកគេមានឧទាហរណ៍តិចតួច និងទទួលបាន បទពិសោធន៍តិច។ ពួកគេកាន់តែមានការព្រួយបារម្ភឡើង ហើយធ្វើ ឱ្យស្ថានការណ៍កាន់តែអាក្រក់ទៅៗ។ ដូច្នេះពួកគេត្រូវការឧទាហរណ៍ តិចតួច ប៉ុន្តែត្រូវជ្រើសរើសដោយប្រុងប្រយ័ត្នដើម្បីផ្តល់នូវបទពិសោធន៍គ្រប់គ្រាន់សម្រាប់ការរៀនសូត្រ។

ការផ្តល់ចម្លើយគណិតវិទ្យាឱ្យបានឆាប់រហ័សគឺជាឧបសគ្គចំពោះកុមារ។ វិធីណាមួយក្នុងការកាត់បន្ថយការរំពឹងទុកនេះ(ជានិច្ចកាលមិនប្រាកដ) វាល្អសម្រាប់កុមារ។

### មានភាពខ្សោយបំណិនគិតផ្ទាល់មាត់

មានមនុស្សគិតថា មានបំណិនក្នុងការគិតលេខផ្ទាល់មាត់ ជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការរៀនគណិតវិទ្យា។ ខ្ញុំមិនឯកភាពចំពោះជំនឿនោះទេ។

បំណិនពីរដែលអ្នកត្រូវតែពូកែសម្រាប់ការគិតលេខ សម្រាប់ផ្ទាល់មាត់គឺការចងចាំក្នុងរយៈពេលខ្លី (ការចាំសំណួរ) និង ការចងចាំរយៈពេលយូរ។ កុមារដែលមានការលំបាកក្នុងការគណនាតែងមានការចងចាំរយៈពេលខ្លី និងបណ្តោះអាសន្ន។ ការសម្របសម្រួលដែលសមហេតុផលមួយ គឺត្រូវបង្ហាញសំណួរ មិនមែនគ្រាន់តែនិយាយពីសំនួរនោះទេ។ ការសម្រួលដែលសមហេតុផលមួយទៀតគឺការផ្តល់ពេលវេលាបន្ថែម 25%ទៀត ។

| | |
|---|---|
| | **ការងារគួរជៀសវាង**<br><br>ប្រសិនបើកុមារ (ឬមនុស្សពេញវ័យ)ម្នាក់គិតទុកមុនថា ពួកគេធ្វើកិច្ចការខុស ដូចនេះពួកគេនឹងស្ងាត់ស្ងៀម និងគេចវេះ ។ នេះគឺជាការភ័យខ្លាចមួយចំពោះការវាយតម្លៃអវិជ្ជមាន។ ពួកយើងភាគច្រើន មានបទពិសោធន៍បែបនេះ ចំពោះរឿងមួយចំនួន។ ប្រសិនបើ អ្នកមិនបរាជ័យ អ្នកក៏មិនព្យាយាមដែរ ។ ចំណុចនោះតម្រូវឱ្យមានការរៀបចំថ្នាក់រៀន និងផ្ទះ សម្រាប់ជួយកុមារដែលពុំទទួលបានជោគជ័យ បើពុំមានការបរាជ័យនោះទេ ក៏ពុំមានការបង្កើតនូវជំហានផ្សេងទៀតឆ្ពោះទៅរកភាពជោគជ័យជាបន្តបន្ទាប់ដែរ។<br><br>*ការព្រួយបារម្ភខ្ពស់ មានលក្ខណៈជាក់លាក់ចំពោះគណិតវិទ្យាៈ*<br><br>ការព្រួយបារម្ភអាចត្រូវបានសម្រួល។ វាកម្រកើតមានណាស់សម្រាប់សិស្សដែលជួបការលំបាកក្នុងការគិតលេខ។ មានការស្រាវជ្រាវគួរឱ្យជឿជាក់មួយបង្ហាញថាការព្រួយបារម្ភធ្វើឱ្យចុះខ្សោយដល់ ការចងចាំ ហើយវាកាត់បន្ថយសមត្ថភាពក្នុងការធ្វើលំហាត់គណិតវិទ្យា។ នៅក្នុងសាលារៀនរបស់ខ្ញុំយើងបានប្រើប្រាស់វិធីជំនួយបន្ថែម ដើម្បីជួយដោះស្រាយការភ័យខ្លាចចំពោះការបរាជ័យ ការព្រួយបារម្ភ និងការឱ្យតម្លៃខ្លួនឯងទាប។<br><br>***ការភ្លេចវិធាន និងរូបមន្តគណិតវិទ្យា។***<br><br>ប្រសិនបើការចងចាំមានរយៈពេលវែង សម្រាប់គណិតវិទ្យាមានការចុះខ្សោយ ដូច្នេះកុមារត្រូវការការគាំទ្រដើម្បីចងចាំរូបមន្តជាទូទៅមានលក្ខណៈលំបាកដែលយើងប្រើនៅក្នុងគណិតវិទ្យា។ វាគឺជាជំនួយដ៏ធំមួយប្រសិនបើកុមារយល់ពីអ្វីដែលគេកំពុងធ្វើនិងហេតុផលនៃការធ្វើនោះ។ ជំហាននានាត្រូវសមហេតុផល ហើយកិច្ចការទាំងមូលក៏ត្រូវសមហេតុផលដែរ។ ដោយសារគណិតវិទ្យាមានការអភិវឌ្ឍចំណុចនេះជាទូទៅនឹងតម្រូវឱ្យមានការយល់ដឹងច្បាស់លាស់ពីកិច្ចការជាមុន។ ដូច្នេះគេចាំបាច់ត្រូវកែសម្រួលវាម្តងហើយម្តងទៀត។ វាពុំមានប្រយោជន៍អ្វីទាំងអស់ក្នុងការនិយាយទៅកាន់កុមារម្នាក់ថា«ខ្ញុំបានប្រាប់ចំណុចនេះដល់ឯងចំនួនដប់ដងហើយ ឯងគួរតែចាំវា»។ ការប្រាប់ចំនួនដប់ដងដោយពុំមានការយល់គឺជាការខាតបង់ពេល វេ |

| | |
|---|---|
| | លា។ ប្រើសម្ភារផ្សេងៗ និងរូបភាព (រួមជាមួយនឹង និមិត្តសញ្ញានិង ខ្ទង់)ដើម្បីអភិវឌ្ឍការយល់ដឹង។ |
| សិស្សមិនស្គាល់តម្លៃលេខ<br>ឧទាហរណ៍៖<br>( ៨ = ........... ) | • បង្ហាញវត្ថុឬរូបភាពពិតចំនួន ៨ ហើយសួរ៖ តើមានវត្ថុ ឬរូបភាព ចំនួនប៉ុន្មាន?<br>• ឱ្យសិស្សរកវត្ថុចំនួន ៨ ។<br>• ឱ្យសិស្សរាប់ម្រាមដៃចំនួន ៨ ( ៥ និង ៨ )។<br>• សរសេរលេខ ៨ ឱ្យធំនៅលើក្តារខៀន ហើយប្រាប់សិស្សឱ្យ សរសេរតាម ដាក់នៅក្នុងសៀវភៅរបស់គេ។<br>• ឱ្យសិស្សសរសេរលេខ ៨ នៅក្នុងខ្យល់ដោយធ្វើតាមគ្រូបង្រៀន។<br>• ឱ្យសិស្សសរសេរលេខ៨នៅលើក្តារឆ្នួនរបស់គេឱ្យបានច្រើនដង<br>• ឱ្យសិស្សបំបែកចំនួន ៨ (ប្រើវត្ថុពិតដើម្បីជួយសិស្សឱ្យយល់ កាន់តែច្បាស់)<br>➢ ឧទាហរណ៍៖ ៨= ៧ + ១, ៨ = ៣ + ៣ + ២, ៨ = ៦ + ២, ៨ = ៤ + ២ + ២, ៨ = ៥ + ៣,៨ = ៥ + ២ + ១, ៨ = ៤ + ៤, ៨ = ៦ + ១ + ១,៨ = ៤ + ៣ + ១ ។ |
| សិស្សមិនចេះបូកលេខ ឬដក លេខ | • ប្រើវត្ថុឬរូបភាពពិតដើម្បីជំនួសលេខនៅក្នុងការគណនា។<br>• ផ្តល់ឱ្យសិស្សនូវចំណោទទាក់ទងនឹងការបូកលេខ ឬដកលេខ ហើយឱ្យសិស្សប្រើប្រាស់វត្ថុផ្សេងៗដើម្បីធ្វើការគណនា។<br>• ឱ្យសិស្សបន្តអនុវត្តរហូតទាល់តែគេយល់។<br>• រំឭកសិស្សថា៖<br>○ ការបូកលេខសំដៅទៅលើការដាក់បញ្ចូលគ្នានូវចំនួនមួយជាមួយ នឹងចំនួនមួយផ្សេងទៀត។<br>○ ការដកលេខសំដៅទៅលើការយកចំនួនមួយចេញពី ចំនួនសរុប មួយ។<br>➢ ឧទាហរណ៍ទី ១៖ ( ៣ + ២ = ៥ ) នារីមានខ្មៅដៃចំនួន ៣ ដើម ហើយប្អូនស្រីរបស់នាងមានខ្មៅដៃចំនួន២ដើម។ តើពួកគេ មាន ខ្មៅដៃសរុបចំនួនប៉ុន្មាន?<br>➢ ឧទាហរណ៍ទី ២៖ ( ៥-២ = ៣ ) សុខាមានផ្លែស្វាយចំនួន ៥ ផ្លែ ហើយគេឱ្យផ្លែស្វាយចំនួន ២ ផ្លែ ទៅមិត្តភក្តិរបស់គេ។ តើសុខានៅសល់ផ្លែស្វាយចំនួនប៉ុន្មានផ្លែ? |
| សិស្សមិនចេះរបៀបបូកឬដក លេខតាមតម្លៃខ្ទង់ (រាយ ដប់ | • ឱ្យក្រដាសដែលមានក្រឡាប្អូនៗជ្រុងទៅសិស្ស ហើយបង្ហាញ ពួកគេពីរបៀបធ្វើ៖ |

| | |
|---|---|
| រយ។ល។) | ○ សរសេរលេខតាមខ្ទង់នីមួយៗនៅក្នុងក្រឡាដោយឡែកៗពីគ្នា។<br>○ ដាក់លេខទៅតាមលំដាប់ឱ្យបានត្រឹមត្រូវ (ពីស្ដាំទៅឆ្វេងនិងពីលើចុះក្រោម)<br>○ បូកលេខ ឬដកលេខតាមខ្ទង់នីមួយៗពីស្ដាំទៅឆ្វេង<br>➢ ឧទាហរណ៍៖<br>រយ ដប់ រាយ     រយ ដប់ រាយ<br>1 5 8     1 5 8<br>+ 3 1     - 3 1<br>1 8 9     1 2 7<br>• ផ្ដល់លំហាត់ស្រដៀងគ្នាឱ្យសិស្សអនុវត្តបន្ត។ |
| សិស្សមិនអាចចាំតារាងមេគុណ | • ប្រើតារាងមួយដែលមានលេខ ១ ដល់ ១០០ សម្រាប់ឱ្យសិស្សរាប់ (សូត្រ)ជាចំនួន មេគុណ២ និង មេគុណ៥។ ធ្វើបែបនេះជារៀងរាល់ថ្ងៃ។<br>• ឱ្យសិស្សសូត្រមេគុណនៅក្នុងថ្នាក់ជារៀងរាល់ថ្ងៃ។ ប្រើតារាងមេគុណសម្រាប់ឱ្យសិស្សសូត្រតាម។<br>• ផ្ដល់តារាងមួយដែលមានតារាងមេគុណឱ្យសិស្សម្នាក់ៗ និងបង្ហាញពួកគេពីរបៀបសូត្រ(ប្រើប្រាស់វា)។<br>• អនុវត្តការគុណលេខនៅរាល់ពេលបង្រៀនគណិតវិទ្យាម្ដងៗ។ |
| សិស្សមិនចេះប្រមាណវិធីគុណ (របៀបគុណលេខ) | • ឱ្យក្រដាសដែលមានក្រឡាបួនៗជ្រុងទៅសិស្ស និងតារាងមេគុណ ហើយបង្ហាញរបៀបធ្វើ៖<br>○ សរសេរលេខផ្សេងៗតាមបន្ទាត់ឈរមួយ<br>○ ប្រើតារាងមេគុណដើម្បីរកចម្លើយ<br>○ ត្រាទុកចំពោះការគុណលេខដែលមាន ២ ខ្ទង់<br>➢ ឧទាហរណ៍៖<br>ដប់ រាយ    6<br>8     58<br>x 6     x 3<br>48     174 |
| សិស្សមិនចេះវិធីចែកលេខ | • ពន្យល់ថាការចែកលេខគឺជាដំណើរផ្ទុយគ្នានឹងការគុណលេខ |

| | |
|---|---|
| (ប្រមាណវិធីចែក) | និងប្រើវត្ថុពិតប្រាកដដើម្បីបង្ហាញរបៀបចែកលេខ។<br>➢ ឧទាហរណ៍៖ ប្រើល្បែងសិក្សាមួយនៃការចែកចំនួនសិស្សឱ្យ ទៅជាក្រុមតូចៗដែលមានចំនួនខុសៗគ្នា។<br>○ បង្ហាញរបៀបប្រើតារាងមេគុណដើម្បីរកចម្លើយ |
| សិស្សមិនចេះរបៀបកំណត់ដំណើរការដែលគេត្រូវការនៅក្នុង ការធ្វើចំណោទ | • បង្រៀនសិស្សឱ្យរកមើលពាក្យគន្លឹះសំខាន់ៗនៅក្នុងសេចក្តីណែនាំនៃចំណោទដែលបង្ហាញដំណើរការដែលគេត្រូវការ។<br>○ ចំពោះការបូកលេខ ពាក្យសំខាន់ៗគឺ «សរុប» ឬ«រួមទាំងអស់»<br>○ ចំពោះការដកលេខ ពាក្យសំខាន់ៗគឺ «ឱ្យ» ឬ «នៅសល់»<br>○ ចំពោះការគុណលេខ គំនិតសំខាន់ៗគឺ៖ ចំនួន*ដូចគ្នា*នៃរបស់អ្វីមួយនៅក្នុងរបស់*នីមួយៗ*។<br>➢ ឧទាហរណ៍ទី ១៖ សុខមានខ្មៅដៃចំនួន ១៥ និងសៅមានខ្មៅដៃចំនួន ៥។ តើសុខ និងសៅមានខ្មៅដៃសរុបចំនួនប៉ុន្មាន?<br>➢ ឧទាហរណ៍ទី ២៖ សុខមានខ្មៅដៃចំនួន ១៥ ដើម ។ គាត់ឱ្យខ្មៅដៃ ចំនួន ៥ ដើមទៅសៅ។ តើសុខនៅសល់ខ្មៅដៃប៉ុន្មានដើម?<br>➢ ឧទាហរណ៍ទី ៣៖ មានប្រអប់ចំនួន ៤។ ប្រអប់នីមួយៗមានដុំថ្មចំនួន ៧ ដុំ។តើចំនួនដុំថ្មសរុបទាំងអស់មានប៉ុន្មាន? |

| **លំបាកក្នុងការសរសេរ** |
|---|
| លំបាកក្នុងការសរសេរ៖ សញ្ញា និងលក្ខណៈសម្គាល់<br>• សិស្សអាចបង្ហាញពីភាពប៉ិនប្រសប់ក្នុងការនិយាយ ប៉ុន្តែបែជាខ្សោយក្នុងការសរសេរទៅវិញ។<br>• សញ្ញាវណ្ណយុត្តដែលពុំសូវប្រើ (ឬមិនប្រើតែម្តង)។ ការប្រកបមិនត្រឹមត្រូវ (ពេលខ្លះពាក្យដូចគ្នាប្រកបខុសគ្នា) ការសរសេរបញ្ច្រាសគ្នា សូរស្រដៀងគ្នា បាត់ព្យញ្ជនៈ កំហុសក្នុងការប្រើបច្ច័យទូទៅនៃពាក្យ។ មិនមានភាពប៉ិនប្រសប់ក្នុងការរៀបលំដាប់ពាក្យ។ ការបកស្រាយ(ឬយល់)សំណួរ និងបញ្ជីសំណួរខុស។ ការដាក់លេខរៀងមិនតាមលំដាប់លំដោយ និងសរសេរលេខបញ្ច្រាសគ្នា។<br>• សរសេរអក្សរមើលមិនយល់ (បើទោះបីជា គេផ្តល់ពេលវេលា និងការយកចិត្តទុកដាក់សមស្របដើម្បីធ្វើកិច្ចការនោះក៏ដោយ)។<br>• ភាពមិនស៊ីសង្វាក់គ្នា(ភាពស៊ីសង្វាក់គ្នា)៖ ការប្រឫកច្របល់គ្នាចំពោះអក្សរពុម្ព និងអក្សរដែលគេសរសេរជាប់គ្នាពេក ទំហំអក្សរមិនសមស្រប ឬទំហំតួអក្សរមិនទៀងទាត់ រូបរាងអក្សរ ឬការទ្រេតរបស់តួអក្សរជាដើម។<br>• ការសរសេរពាក្យ ឬអក្សរមិនបានចប់ចុងចប់ដើម ឬបាត់ពាក្យ។ |

- ពុំស៊ីសង្វាក់គ្នាចំពោះទីតាំងអក្សរនៅលើទំព័រតាមបន្ទាត់ និងរឹមទំព័រ ព្រមទាំងពុំស៊ីសង្វាក់គ្នាចំពោះចន្លោះរវាងពាក្យ និងអក្សរនានា។
- ការក្ដាប់កាន់យ៉ាងណែន ឬខុសពីធម្មតា ជាពិសេសការកាន់ឧបករណ៍សម្រាប់សរសេរនៅកៀកនឹងក្រដាស ឬដាក់មេដៃលើម្រាមដៃពីរ និងសរសេរដោយប្រើកដៃ។
- និយាយតែម្នាក់ឯងពេលកំពុងសរសេរ ឬសំឡឹងមើលដៃដែលកំពុងសរសេរដោយប្រុងប្រយ័ត្ន។
- ការចម្លង ឬសរសេរយឺត ឬដោយលំបាក - ទោះបីជាមានរបៀបរៀបរយ និងអាចអានរួចក៏ដោយ។

**ពិបាកក្នុងការសរសេរ៖ វិធីសាស្ត្រ**

- លើកទឹកចិត្តឱ្យសិស្សព្រៀង(គ្រោង)គំនិតរបស់ពួកគេ។ វាមានសារៈសំខាន់ណាស់ក្នុងការសរសេរគំនិតសំខាន់ៗលើក្រដាស ដោយពុំគិតទៅលើការប្រកប វណ្ណយុត្ត ។ល។
- ឱ្យសិស្សគូររូបភាពមួយដែលជាគំនិតសម្រាប់កថាខណ្ឌនីមួយៗ។
- ឱ្យសិស្សនិយាយតាមគំនិតរបស់ពួកគេ និងថតដាក់ក្នុងម៉ាស៊ីនថតសំឡេង ហើយបន្ទាប់មកឱ្យគេចាក់ស្ដាប់ និងសរសេរតាម។
- ឱ្យពួកគេអនុវត្តបំណិនក្នុងការចុចលើក្ដារពុម្ពអក្សរ(Keyboard)។ វាអាចមានការលំបាកពីដំបូង ប៉ុន្តែបន្ទាប់ពីពួកគេបានរៀនពីលំនាំ(ទម្រង់)នៃក្ដារចុចហើយ ការចុចអក្សរនឹងលឿនជាង និងច្បាស់ជាងការសរសេរដោយដៃ។
- ត្រូវមានកុំព្យូទ័រសម្រាប់សិស្សដែលពិបាកក្នុងការសរសេរ ដើម្បីឱ្យពួកគេរៀបចំព័ត៌មាន និងពិនិត្យមើលអក្ខរាវិរុទ្ធ។ ទោះបីជាបំណិនក្នុងការចុចក្ដារពុម្ពអក្សររបស់ពួកគេមិនល្អក៏ដោយ ក៏កុំព្យូទ័រអាចជួយផ្ដល់ព័ត៌មានលម្អិតបានផងដែរ។
- ឱ្យពួកគេបន្តអនុវត្តការសរសេរដោយដៃ។ វាជាពេលវេលាក្នុងជីវិតរបស់សិស្សដែលពួកគេត្រូវការដើម្បីអាចមានសមត្ថភាពក្នុងការសរសេរកិច្ចការផ្សេងៗ ហើយទំនងជាអាចចែករំលែកកិច្ចការទាំងនោះជាមួយអ្នកដទៃ។ វានឹងមានការរីកចម្រើនបន្តទៅទៀត ដរាបណាសិស្សនៅតែបន្តការសរសេរដោយដៃ។
- លើកទឹកចិត្តឱ្យសិស្សនិយាយឮៗ នៅពេលដែលពួកគេសរសេរ។ ធ្វើបែបនេះ វាអាចផ្ដល់នូវព័ត៌មានត្រឡប់ដ៏មានតម្លៃពីការស្ដាប់។
- ផ្ដល់ពេលវេលាឱ្យបានច្រើនសម្រាប់អនុវត្តកិច្ចការសរសេរ រួមមាន សរសេរកំណត់ត្រា ការចម្លង និងការធ្វើតេស្ដ។
- បង្ហាញគន្លឹះសំខាន់ៗជាមុនដល់សិស្សចំពោះកិច្ចការដែលត្រូវឱ្យសិស្សធ្វើ និងវាយតម្លៃជាបន្តបន្ទាប់ ដូចជា ការប្រឡង ការរៀនកុំព្យូទ័រ។ល។ ដើម្បីឱ្យពួកគេអាចដឹងជាមុនពីបញ្ហានានាដែលនឹងអាចកើតមានឡើង។
- អនុញ្ញាតឱ្យសិស្សចាប់ផ្ដើមកិច្ចការ ឬលំហាត់មុនសិស្សដទៃ។
- ដាក់បញ្ចូលពេលវេលាទៅក្នុងកាលវិភាគរបស់សិស្សឱ្យធ្វើជា«ជំនួយការបណ្ណាល័យ» ឬ «ជំនួយ

ការការិយាល័យ»ដែលវាអាចជាមធ្យោបាយមួយសម្រាប់ពួកគេក្នុងការទទួលបាននូវកិច្ចការសំណេរមុន ឬធ្វើសកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹងសម្ភារដែលគេត្រូវរៀន។

- ជំនួសការដែលឱ្យសិស្សសរសេរចម្លើយពេញលេញ សូមផ្ដល់កិច្ចការដែលមានលក្ខណៈផ្ដល់ជាគន្លឹះខ្លះៗ ឬចំណងជើងសំខាន់ៗ ដើម្បីឱ្យសិស្សអាចបំពេញព័ត៌មានលម្អិតនៅក្រោមចំណងជើងទាំងនោះ (ឬផ្ដល់ព័ត៌មានលម្អិត ហើយឱ្យសិស្សជាអ្នកដាក់ចំណងជើង)។
- អនុញ្ញាតឱ្យសិស្សនិយាយនូវកិច្ចការ ឬការធ្វើតេស្តមួយចំនួន (ឬផ្នែកខ្លះ)ឱ្យ«អ្នកកត់ត្រា» សរសេរ។ បណ្ដោះបណ្ដាល «អ្នកកត់ត្រា» ឱ្យសរសេរអ្វីដែលសិស្សនិយាយទៅតាមពាក្យសម្ដីរបស់គេ ហើយបន្ទាប់មកឱ្យសិស្សធ្វើការផ្លាស់ប្ដូរ(កែសម្រួល)ការសរសេរនោះដោយពុំមានជំនួយពី អ្នកកត់ត្រា។
- មិនគួរកំណត់ «ភាពមានរបៀបរៀបរយ» ឬ «អក្ខរាវិរុទ្ធ» (ឬទាំងពីរ)ជាលក្ខណៈវិនិច្ឆ័យនៃការដាក់ពិន្ទុសម្រាប់កិច្ចការមួយចំនួន ឬការរៀបចំកិច្ចការដែលគេត្រូវវាយតម្លៃនៅលើផ្នែកជាក់លាក់នៃដំណើរការសរសេរ។
- អនុញ្ញាត្តិឱ្យសិស្សប្រើអក្សរកាត់ក្នុងការសរសេរមួយចំនួន (ដូចជា bឬc សម្រាប់ពាក្យ ដោយសារតែ[because])។ ឱ្យសិស្សរៀបចំបញ្ជីអក្សរកាត់តាមលំដាប់នៅក្នុងសៀវភៅកត់ត្រា។ ចំណុចទាំងនេះនឹងមានប្រយោជន៍ច្រើនសម្រាប់ការកត់ត្រានៅពេលអនាគត។
- កាត់បន្ថយកិច្ចការដែលតម្រូវឱ្យមានការចម្លងច្រើន។ ឧទាហរណ៍នៅក្នុងគណិតវិទ្យា ចូរផ្ដល់នូវសន្លឹកកិច្ចការដែលមានចំណោទស្រាប់ ដោយមិនចាំបាច់ឱ្យសិស្សចម្លងចំណោទនោះ។
- បំបែកការសរសេរជាជំហានៗ ហើយបន្ទាប់មកបង្រៀនសិស្សឱ្យធ្វើដូចគ្នា។ បង្រៀនពីដំណាក់កាលផ្សេងៗក្នុងការសរសេរ (ការបំផុសគំនិត ព្រាង កែសម្រួល និងការអានឡើងវិញ។ល។)។ ពិចារណាការដាក់ពិន្ទុលើដំណាក់កាលទាំងនេះសូម្បីតែការធ្វើលំហាត់ជាលាយលក្ខណ៍អក្សរមួយចំនួន នៅក្នុង«ស្ថានភាពតែមួយ(one-sitting)»ក៏ដោយ ដើម្បីឱ្យគេអាចផ្ដល់ពិន្ទុនៅលើអត្ថបទខ្លីៗ និងនៅលើសេចក្ដីព្រាងត្រួសៗ ក៏ដូចជាកិច្ចការសម្រេចចុងក្រោយដែរ។
- នៅលើកុំព្យូទ័រ សិស្សអាចរៀបចំសេចក្ដីព្រាងត្រួសៗ ចម្លងវា និងបន្ទាប់មកកែតម្រូវវា ដើម្បីឱ្យគេអាចវាយតម្លៃទាំងសេចក្ដីព្រាងត្រួសៗ និងកិច្ចការសម្រេចចុងក្រោយដោយពុំចាំបាច់ការវាយ អត្ថបទបន្ថែម។
- លើកទឹកចិត្តឱ្យសិស្សប្រើកម្មវិធីកែអក្ខរាវិរុទ្ធ ហើយប្រសិនបើអាចធ្វើទៅបានសូមឱ្យអ្នកផ្សេងទៀតអានកិច្ចការរបស់គេដែរ។ គេផ្ដល់អនុសាសន៍ឱ្យប្រើកម្មវិធីកែអក្ខរាវិរុទ្ធជាសំឡេងជាពិសេសប្រសិនបើសិស្សមិនអាចស្គាល់ពីពាក្យដែលត្រូវ (តាមធម្មតារួមទាំងឧបករណ៍សម្រាប់ស្ដាប់សំលេង)។
- អនុញ្ញាតឱ្យសិស្សប្រើអក្សរដែលសរសេរជាប់គ្នា(cursive)ឬអក្សរសរសេរដោយដៃ(manuscript) មួយណាក៏បានដែលងាយអានបំផុត។
- លើកទឹកចិត្តសិស្សដែលរៀននៅថ្នាក់បឋមសិក្សាឱ្យប្រើក្រដាសដែលមានបន្ទាត់ដើម្បីសរសេរនៅ

លើបន្ទាត់នោះជានិច្ច។

- អនុញ្ញាតឱ្យសិស្សធំៗប្រើទំហំបន្ទាត់ទៅតាមជម្រើសរបស់ពួកគេ។ ត្រូវចងចាំក្នុងចិត្តថា សិស្ស ខ្លះសរសេរអក្សរតូចៗដើម្បីបិតបាំងភាពគ្មានសណ្តាប់ធ្នាប់ ឬអក្ខរាវិរុទ្ធរបស់គេ។
- អនុញ្ញាតឱ្យសិស្សប្រើក្រដាស់ ឬឧបករណ៍សរសេរដែលមានពណ៌ផ្សេងៗគ្នា។
- អនុញ្ញាតឱ្យសិស្សប្រើក្រដាសព្រាងសម្រាប់គណិតវិទ្យា ឬត្រឡប់ក្រដាសទៅបន្ទាត់ចំហៀងដើម្បីជួយតម្រឹមជួរនៃលេខ។
- អនុញ្ញាតឱ្យសិស្សប្រើឧបករណ៍សរសេរដែលមានភាពងាយស្រួលបំផុតសម្រាប់ពួកគេ។
- ប្រសិនបើការចម្លងមានការលំបាក ចូរឱ្យសិស្សធ្វើការកែតម្រូវមួយចំនួនជាជាងការចម្លងឡើងវិញទាំងស្រុង។
- ពិចារណាថាតើការប្រើកម្មវិធីថតសំឡេង(ស្គាល់សំឡេង)[speech recognition]នឹងមានប្រយោជន៍ឬទេ។ ប្រសិនបើសិស្ស និងគ្រូបង្រៀនមានឆន្ទៈក្នុងការចំណាយពេលវេលា និងការខិតខំប្រឹងប្រែងក្នុង«ការបណ្តុះបណ្តាល»កម្មវិធីsoftwareសម្រាប់ថតសំឡេងរបស់សិស្ស និងរៀនប្រើកម្មវិធីនោះ សិស្សអាចមានពេលវេលាទំនេរពីដំណើរការចលនានៃការសរសេរ ឬវាយអក្សរនៅលើក្តារពុម្ពអក្សរ។
- រៀបចំគម្រោងសរសេរតាមបែបសហការគ្នាដែលសិស្សផ្សេងៗទៀតអាចដើរតួនាទី«ជាអ្នកបំផុសគំនិត» «អ្នករៀបចំព័ត៌មាន «អ្នកសរសេរ» «អ្នកអានឡើងវិញ» និង«អ្នកបង្ហាញ»។
- ផ្តល់ការណែនាំបន្ថែមនិងប្រើប្រាស់ពេលវេលាការបរិច្ឆេទមួយដំណាក់ៗសម្រាប់កិច្ចការ ដែលមានរយៈពេលវែង។ ពិភាក្សាជាមួយសិស្សនិងឪពុកម្តាយពីលទ្ធភាពនៃការអនុវត្តតាមកាលបរិច្ឆេទដោយធ្វើការក្រោយម៉ោងសិក្សាជាមួយគ្រូបង្រៀនក្នុងករណីដែលថ្ងៃផុតកំណត់មកដល់ហើយកិច្ចការនេះមិនទាន់ត្រូវបានធ្វើនៅឡើយ។
- សរសេរណែនាំពីការសរសេរដោយដៃទៅក្នុងកាលវិភាគរបស់សិស្ស។ ព័ត៌មានលម្អិត និងកំរិត ឯករាជ្យភាពគឺអាស្រ័យទៅលើអាយុ និងឥរិយាបថរបស់សិស្ស ប៉ុន្តែសិស្សជាច្រើនចង់ឱ្យការ សរសេរដោយដៃកាន់តែស្អាត។
- ចូរចងចាំថាគេត្រូវពង្រឹងទម្លាប់នៃការសរសេរដោយដៃតាំងពីដំបូង។ មុនពេលចាប់ចូលរួមក្នុងការជំនះលើការកាន់ក្តាប់យ៉ាងណែនរបស់សិស្ស ឬថាតើពួកគេគួរសរសេរជាអក្សរជាប់គ្នា ឬអក្សរពុម្ពចូរពិចារណាថាតើការពង្រឹងការផ្លាស់ប្តូរទម្លាប់នឹងធ្វើឱ្យកិច្ចការនៃការសរសេរកាន់តែមានភាពងាយស្រួលសម្រាប់សិស្ស ឬថាតើនេះជាគឺជាឱកាសមួយសម្រាប់សិស្សក្នុងការធ្វើការជ្រើសរើសផ្ទាល់របស់ខ្លួនទេ។ ចូរប្រយ័ត្នប្រយែងចំពោះការមានបន្ទុកការងារច្រើន ដោយសារសិស្សមានកិច្ចការ និងវគ្គសិក្សាផ្សេងៗទៀត។
- បង្រៀនវិធីសរសេរដោយដៃតាមបែបផ្សេងទៀតដូចជា «ការសរសេរដោយគ្មានទឹកភ្នែក» (wrting without tears)។

- ដោយគ្រាន់តែសរសេរពាក្យ ឬឃ្លាគន្លឹះមួយសម្រាប់កថាខណ្ឌនីមួយៗហើយបន្ទាប់មកបំពេញព័ត៌មានលម្អិតនៅពេលក្រោយអាចមានប្រសិទ្ធភាព។
- គេត្រូវប្រើវិធីពហុវិញ្ញាណឱ្យបានច្រើនសម្រាប់ការបង្រៀនទាំងការសរសេរអក្សរដោយដៃនិងការសរសេរអក្សរជាប់គ្នា។ គេចាំបាច់ត្រូវអនុវត្តវិធីទាំងនេះឱ្យបានច្រើនដើម្បីឱ្យ អក្សរមានលក្ខណៈត្រឹមត្រូវស្វ័យប្រវត្តិមុនពេលឱ្យសិស្សប្រើប្រាស់បំណិននេះដើម្បីបញ្ចេញគំនិតរបស់គេ។
- ឱ្យសិស្សប្រើប្រាស់កម្មវិធីក្រាហ្វិកសម្រាប់មើល។ ឧទាហរណ៍ អ្នកអាចបង្កើតផែនទីគំនិត ដែលយើងអាចគូសវាស គំនិតសំខាន់ៗនៅកណ្ដាលនៃទំព័រ និងសរសេរបន្ថែមពត៌មាន នៅលើបន្ទាត់ក្រៅរង្វង់កណ្ដាល ដែលមើលទៅដូចគ្នានឹងដៃជើងរបស់សត្វពីងពាង ឬកាំកង់រទេះ។
- រៀបចំឯកសារ និងកិច្ចការផ្សេងៗទៅតាមជំហានជាលំដាប់លំដោយឱ្យបានត្រឹមត្រូវ។ មធ្យោបាយងាយស្រួលមួយដើម្បីចងចាំពីជំហានទាំងនេះគឺត្រូវគិតពីពាក្យ«POWER»។
- P - រៀបប្លង់ឯកសាររបស់អ្នក
- O - រៀបចំការគិត និងគំនិតរបស់អ្នក
- W - សរសេរសេចក្ដីព្រាងរបស់អ្នក
- E - កែសម្រួលកិច្ចការរបស់អ្នក
- R - កែតម្រូវការងាររបស់អ្នក រៀបចំសេចក្ដីព្រាងចុងក្រោយ
- ប្រសិនបើសិស្សអស់កម្លាំង ចូរឱ្យពួកគេសាកល្បងធ្វើសកម្មភាពដូចខាងក្រោម៖
    - រលាស់ដៃឱ្យបានលឿន ប៉ុន្តែមិនខ្លាំងៗទេ។
    - ត្រដុសបាតដៃទាំង2 ហើយផ្ដោតលើការមានអារម្មណ៍កក់ក្ដៅ។
    - ត្រដុសដៃនៅលើកំរាលជារាងរង្វង់(ឬប្រសិនបើស្លៀកសម្លៀកបំពាក់ដែលធ្វើពីក្រណាត់ទន់ៗ ចូរត្រដុសដៃស្រាលៗនៅលើភ្លៅក្បែរជង្គង់)
    - ប្រើមេដៃស្ដាំចាប់កាន់របស់ប្រើប្រាស់ញឹកញាប់ដើម្បីចុចលើចុងប៊ិកនៅពេលកំពុង កាន់ប៊ិកនៅក្នុងដៃនោះ។ ធ្វើដូច្នេះម្ដងទៀតដោយប្រើម្រាមដៃចង្អុល។
    - អនុវត្ត *ការអង្គុយដើបៗ(sitting pushups)* ដោយដាក់បាតដៃនីមួយៗនៅលើកៅអី និងដាក់ម្រាមដៃទៅខាងមុខ។សិស្សច្រត់ដៃលើកៅអីហើយលើកខ្លួនរបស់ពួកគេឱ្យ ផុតពីកៅអីបន្តិច។
- ឱ្យសិស្សថតជាសំលេងទុកនូវកិច្ចការ និងឬការធ្វើតេស្តផ្ទាល់មាត់សំខាន់ៗ ។
- ផ្ដល់អាទិភាពចំពោះកិច្ចការជាក់លាក់នានាក្នុងអំឡុងពេលធ្វើសកម្មភាពដែលមានលក្ខណៈស្មុគស្មាញ។ ឧទាហរណ៍សិស្សអាចផ្ដោតលើការប្រើពាក្យពិពណ៌នានៅក្នុងកិច្ចការមួយ ហើយនៅក្នុងកិច្ចការមួយទៀតផ្ដោតទៅលើការប្រើប្រយោគចម្រុះគ្នា។
- ពង្រឹងចំណុចវិជ្ជមាននៃការខិតខំរបស់សិស្ស។
- ត្រូវអត់ធ្មត់ចំពោះខ្លួនឯង។

### ឧទាហរណ៍ស្តីពីសកម្មភាពនៃការពិបាកក្នុងការសរសេរ dysgraphia

| សញ្ញានិងលក្ខណៈសម្គាល់ | វិធីសាស្រ្តបច្ចេកទេសសកម្មភាពនិងសម្ភារ |
|---|---|
| ការពិបាកក្នុងការសរសេរៈសញ្ញានិងលក្ខណៈសម្គាល់<br><br>• សិស្សអាចបង្ហាញពីភាពប៉ិនប្រសប់ក្នុងការនិយាយ ប៉ុន្តែបែជាខ្សោយក្នុងការសរសេរទៅវិញ។<br>• សញ្ញាវណ្ណយុត្តដែលពុំសូវប្រើ (ឬមិនប្រើតែម្តង)។ ការប្រកបមិនត្រឹមត្រូវ (ពេលខ្លះពាក្យដូចគ្នាប្រកបខុសគ្នា) ការសរសេរបញ្ច្រាសគ្នា សូរស្រដៀងគ្នា បាត់ព្យាង្គ កំហុសក្នុងការប្រើបច្ច័យទូទៅនៃពាក្យ។ មិនមានភាពប៉ិនប្រសប់ក្នុងការរៀបលំដាប់ពាក្យ។ ការបកស្រាយ(ឬយល់)សំណួរ និងបញ្ចីសំណួរខុស។ ការដាក់លេខរៀងមិនតាមលំដាប់លំដោយ និងសរសេរលេខបញ្ច្រាសគ្នា។<br>• សរសេរអក្សរមើលមិនយល់ (បើទោះបីជា គេផ្តល់ពេលវេលា និងការយកចិត្តទុកដាក់សមស្រប ដើម្បីធ្វើកិច្ចការនោះក៏ដោយ)។<br>• ការសរសេរពាក្យ ឬអក្សរមិនបានចប់ចុងចប់ដើម ឬបាត់ពាក្យ។ | ការពិបាកក្នុងការសរសេរៈ សកម្មភាព<br><br>បង្កើនការសម្របសម្រួលចលនាតូចៈ<br><br>ទាំងនេះគឺគ្រាន់តែជាសកម្មភាពពីរបីប៉ុណ្ណោះ ដែលអ្នកអាចសាកល្បងនៅសាលារៀនបាន ប៉ុន្តែមានសកម្មភាពជាច្រើនទៀត ដែលមានប្រយោជន៍សម្រាប់ការលូតលាស់របស់កុមារ។ សកម្មភាពផ្សេងៗដែលជួយសិស្សរបស់អ្នកឱ្យចូលចិត្តសរសេរ និងរៀនសូត្រតាំងពីដើមដំបូង គឺវានឹងនាំឱ្យទទួលបាននូវលទ្ធផលនៃការសិក្សាល្អ។<br><br>សកម្មភាពខាងក្រោម វានឹងជួយកុមារឱ្យមានការលូតលាស់កាន់តែប្រសើរឡើងលើការគ្រប់គ្រងចលនាតូចរបស់ដៃ។<br><br>• លេងជាមួយមេដែកតូចៗ (small fridge magnet)។ កុមារអាចរៀបចំមេដែកជាជួរ ជារង្វង់ ឬរាងផ្សេងៗទៀត។<br>• រៀបចំរូបរាងផ្សេងៗដោយប្រើឈើគូស។<br>• សង់អាគារដោយប្រើកាក់។<br>• គូររង្វង់តូចៗនៅលើក្រដាសមួយសន្លឹក បន្ទាប់មកឱ្យសិស្សយកដុំថ្មមួយដុំដាក់នៅក្នុងរង្វង់នីមួយៗ។<br>• ចាក់ទឹកចូលក្នុងធុងតូចៗ។<br>• លេងល្បែងចាប់ចង្កឹះ(ត្រេះ)(Pickup sticks) (អ្នកអាចយកនំបញ្ចុកអ៊ីតាលី(spaghetti) ឬមីសួមកលេងបាន)។ លើក មីសួ មួយដុំឡើង ហើយទម្លាក់វាចុះក្រោម។ មីសួ នឹងធ្លាក់មកគលើគ្នា។ ល្បែងនេះគឺត្រូវ រើសយកមីសួ មួយសរសៃម្តងៗ ដោយមិនត្រូវធ្វើឱ្យប៉ះ សរសៃ ផ្សេងទៀតទេ។<br>• រើសក្រដាសពណ៌តូចៗ និងបិទវាឱ្យទៅជាសកម្មភាពដ៏ប៉ិនប្រសប់ (craft activity)។ |

| | |
|---|---|
| | • បិតគ្រាប់ធុញ្ញជាតិ ឬគ្រាប់អង្គាំនៅលើទម្រង់នៃរូប ឬ រូបភាពសាមញ្ញមួយ។<br>• រៀបចំបំណែក Lego ដែលមានពណ៌តូចៗ ទៅតាម ពណ៌របស់វា។<br>• បិទស្លាក(stickers) ឬរូបផ្សេងៗនៅលើ ក្រដាស ដែលគេគូរជាគំនូររួចហើយ។ |
| • ភាពមិនស៊ីសង្វាក់គ្នា៖ ការប្របូក ប្របល់គ្នាចំពោះអក្សរពុម្ព និងអក្សរ ដែលគេសរសេរជាប់គ្នាពេក ទំហំអក្សរ មិនសមស្រប ឬទំហំតួអក្សរមិនទៀង ទាត់ រូបរាងអក្សរ ឬការទ្រេតរបស់តួ អក្សរជាដើម។ | • ការដេរប៉ាក់សាមញ្ញៗ- ប្រើម្ជុលធំមួយ និងគូរបន្ទាត់ នៅលើក្រណាត់ដើម្បីគូរតាម។<br>• រៀបចំគ្រាប់ពូជ គ្រាប់អង្គាំ ឬបំណែក Lego តូចៗជា បន្ទាត់ត្រង់។<br>• លាយគ្រាប់អង្ករនិងគ្រាប់អង្គាំ។ ឱ្យសិស្សរើសយក គ្រាប់អង្គាំ។<br>• ផ្ទេរអង្ករពីធុងមួយទៅធុងមួយទៀត។<br>• ធ្វើសកម្មភាពតាមលំដាប់លំដោយឱ្យចេញជា ចង្វាក់ នៃការគោះ ឧទាហរណ៍ ទះដៃពីរដង ហើយទះភ្លៅម្នាក់ ពីរដង។<br><br>**រូបរាងនិងទំហំទាំងអស់**<br><br>ជាពេលដ៏ល្អមួយដែលត្រូវចាប់ផ្តើមឱ្យ កូនរបស់អ្នកគូរ និង ផាត់ពណ៌ដោយប្រើខ្មៅដៃ ប៊ិក ខ្មៅដៃពណ៌ និងប៊ិកហ្វឺត សម្រាប់រូបនិងទំហំទាំងអស់។អ្នកអាចចាប់ផ្តើមដោយឱ្យ កូនរបស់អ្នកកាន់ប៊ិកហ្វឺតធំមួយដែលនឹងជួយ កូនឱ្យក្តាប់ កាន់បានល្អ ហើយបន្ទាប់មកជួយពួកគេ បន្តិចម្តងៗឱ្យកាន់ ខ្មៅដៃពណ៌តូចៗ។ វត្ថុកាន់តែតូចវាមានការលំបាកខ្លាំង សម្រាប់ពួកគេក្នុងការបញ្ជាសាច់ដុំទាំងនោះដើម្បីធ្វើឱ្យ ប្រសើរឡើងនូវបំណិនរបស់ពួកគេ។ |



**ល្បែង រៀបវត្ថុឱ្យត្រូវតាមក្រុមពណ៌** (Super Sorting Pie)
ខ្ញុំស្រលាញ់ Super Sorting Pie ពី ក្រុមហ៊ុន Amazon ហើយខ្ញុំប្រើប្រាស់វានៅក្នុងមជ្ឈមណ្ឌលរបស់ខ្ញុំគ្រប់ពេលវេលា ជាមួយកុមារដែលមករកខ្ញុំ ឱ្យជួយបង្រៀនសរសេរដោយដៃ។ សូមចងចាំថាផ្នែកដ៏សំខាន់មួយនៃរូបផ្តុំគឺមិនត្រឹមតែ ជួយឱ្យកូនរបស់អ្នកសរសេរ អក្សររបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយ ពួកគាត់ឱ្យកាន់ខ្មៅដៃបានត្រឹមត្រូវសម្រាប់ការសរសេរអក្សរដោយដៃឱ្យបានប្រសើរជាងមុន។ ពីដំបូង កុមារមានទំនោរក្នុងការចាប់កាន់ខ្មៅដៃ និងខ្មៅដៃពណ៌ដោយប្រើបាតដៃទាំងមូលរបស់គេ ដូចការកាន់កាំបិតអញ្ចឹង ប៉ុន្តែសកម្មភាពផ្សេងៗដែលធ្វើ ឱ្យពួកគេប្រើប្រាស់ចង្អុលដៃ និងមេដៃរបស់គេ នឹងពង្រឹងសាច់ដុំទាំងនោះសម្រាប់ការសរសេរ។ នោះជាមូលហេតុដែល Super Sorting Pie ដំណើរការបានយ៉ាងល្អដោយសារតែវាអនុញ្ញាតឱ្យកុមារចាប់កាន់ផ្លែឈើ ហើយដាក់វានៅក្នុងថាសដោយប្រើដង្កៀបចាប់។



**គ្រាប់អង្កាំ និងកាក់៖** សកម្មភាពចលនាតូច របស់កុមារក្នុងការប្រើប្រាស់គ្រាប់អង្កាំ កាក់ និង អក្សរ។ ចំណុចទាំងនេះគ្រាន់តែជាសកម្មភាពពីរបីប៉ុណ្ណោះដែលអ្នកអាចសាកល្បង

| | |
|---|---|
| | ធ្វើនៅផ្ទះបាន ប៉ុន្តែមានសកម្មភាពជាច្រើនដែលល្អសម្រាប់ការ លូតលាស់របស់កុមារ។ សកម្មភាព ដើម្បីជួយកូនរបស់អ្នកឱ្យស្រលាញ់ ការសរសេរនិងការរៀនសូត្រពីដំបូងតែងនាំទៅរកភាពជោគជ័យនៃការសិក្សា។<br> |
| • ការក្តាប់កាន់យ៉ាងណែន ឬខុសពីធម្មតា ជាពិសេសការកាន់ឧបករណ៍សម្រាប់សរសេរនៅកៀកនឹងក្រដាស ឬដាក់មេដៃលើម្រាមដៃពីរ និងសរសេរដោយប្រើកដៃ។<br>• សិស្សអាចបង្ហាញពីភាពប៉ិនប្រសប់ក្នុងការនិយាយ ប៉ុន្តែបែជាខ្សោយក្នុងការសរសេរទៅវិញ។<br>• ការសរសេរពាក្យ ឬអក្សរមិនបានចប់ចុងចប់ដើម ឬបាត់ពាក្យ។ | **ឧបករណ៍សម្រាប់កាន់ខ្មៅដៃ**<br>ឧបករណ៍សម្រាប់កាន់ខ្មៅដៃ មានទីតាំងសមរម្យសម្រាប់ដាក់មេដៃ ចង្អុលដៃ និងដៃកណ្តាលនៅលើខ្មៅដៃឱ្យបានត្រឹមត្រូវ។ ការចាប់យកខ្មៅដៃឱ្យបានត្រឹមត្រូវធ្វើឱ្យកូនរបស់អ្នកសរសេរអក្សរបានកាន់តែស្អាត និងឆាប់រហ័សដោយពុំធ្វើឱ្យសាច់ដុំដៃរបស់គេចុះខ្សោយឡើយ។ មានរបៀបកាន់ខ្មៅដៃជាច្រើន ដូច្នេះវាសំខាន់ណាស់ក្នុងការដឹងពីអ្វីដែលជាតម្រូវការជាក់លាក់នានារបស់កូន។ ឧទាហរណ៍ ប្រសិនបើនាងព័ទ្ធមេដៃរបស់នាងជុំវិញចង្អុលដៃរបស់នាង ។ ឧបករណ៍នេះ អាចធ្វើឱ្យវាមានភាពងាយស្រួលសម្រាប់ម្រាមដៃផ្សេងៗរបស់នាងស្ថិតក្នុងទីតាំងត្រឹមត្រូវ។<br><br>អ្នកអាចរកឧបករណ៍សម្រាប់ចាប់កាន់ខ្មៅដៃ នៅហាងលក់សម្ភារការិយាល័យ ប៉ុន្តែ ប្រដាប់ទាំងនោះប្រហែលជាមិនអាចទប់ម្រាមដៃ គ្រប់គ្រាន់សម្រាប់កុមារ ពិបាកក្នុងការសរសេរ នោះទេ។ ដើម្បីស្វែងរកប្រដាប់សម្រាប់ចាប់កាន់ខ្មៅដៃត្រឹមត្រូវឱ្យកូនរបស់អ្នកចាំបាច់ត្រូវរកមើលសៀវភៅវាយឈ្មោះអមដោយរូបភាព តាមប្រព័ន្ធអ៊ីនធឺណែតដោយ |

| | |
|---|---|
| | សំដៅទៅរកអ្នកព្យាបាលដោយធ្វើចលនា។<br><br>• ឱ្យសិស្សអនុវត្តឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ទាំងនៅក្នុងនិងក្រៅថ្នាក់រៀន ដូចជា បន្ទាត់ត្រង់ វង្វង់ និង បន្ទាត់កាច់ចុះ កាច់ឡើង ។<br>• ផ្តល់អក្សរគំរូមួយដែលមានសញ្ញាព្រួញ បង្ហាញទិស សម្រាប់ឱ្យសិស្សគូរឱ្យបានច្រើនដងតាមដែលអាចធ្វើទៅបានទាំងនៅក្នុងលំហ លើដី លើក្តារខៀន និងនៅក្នុងសៀវភៅរបស់ពួកគេ។<br>• នាំសិស្សឱ្យសរសេរក្រឡាចត្រង្គមួយជំហានម្តងៗ។<br>• ឱ្យសិស្សសរសេរនៅលើក្តារខៀន និងកែតម្រូវ<br>• ឱ្យសិស្សប្រើដុំថ្មតូចៗ គ្រាប់សណ្តែក ឬគ្រាប់ ពោត ដើម្បីរៀបជារូបអក្សរដែលពួកគេបាន រៀនហើយ ជាកិច្ចការផ្ទះ ឬនៅពេល ចេញលេង។ |
| សិស្សសរសេរពាក្យខុសច្រើន និងផ្តល់អត្ថន័យខុស (ចេះពាក្យតិចតួច) | • ឱ្យពួកគេរៀនពាក្យច្រើនថែមទៀត(ការសរសេរ ការអាន)<br>• ប្រើបណ្ណរូបភាព ឬ អក្សរ។<br>• ប្រើកាយវិការដើម្បីពន្យល់ពីអត្ថន័យរបស់ពាក្យ<br>• បង្រៀនពួកគេពីរបៀបសម្គាល់ពាក្យសទិសន័យ (ពាក្យដែលមានន័យដូចគ្នា) និងពាក្យសទិសសូរ (ពាក្យដែលមានសូរដូចគ្នា តែន័យខុសគ្នា)របស់ពាក្យនីមួយៗ ដើម្បីពង្រឹងវាក្យសព្ទរបស់សិស្ស។<br>• ឱ្យសិស្សលេងល្បែងរៀបពាក្យ និងពន្យល់ពី អត្ថន័យរបស់ពាក្យដែលគេទើបតែបង្កើតឡើង។ |
| សិស្សសរសេរឃ្លា ប្រយោគ និងអត្ថបទមិនបាន ល្អ (គំនិតរបស់ពួកគេពុំមានលក្ខណៈទូលំទូលាយ និង | • ឱ្យសិស្សអនុវត្តការបំពេញចន្លោះនៅក្នុងឃ្លាផ្សេងៗ<br>• ឱ្យសិស្សសរសេរឃ្លាខ្លីៗ (ប្រធាន កិរិយាសព្ទ និងកម្មបទ) ដោយពិពណ៌នាអំពីសកម្មភាព និងបរិស្ថានផ្សេ |

| | |
|---|---|
| ច្បាស់លាស់)។ | ងៗជុំវិញពួកគេ។<br>• ឱ្យសិស្សរៀបចំពាក្យឱ្យត្រូវតាមលំដាប់លំដោយដើម្បីបង្កើតឃ្លា និងប្រយោគ និងអាន ឃ្លាដែលមានលក្ខណៈពេញលេញ។<br>• ប្រើសំណួរដែលមានបីកម្រិត (ចងចាំ យល់ និង ការគិតស៊ីជម្រៅ) ហើយឱ្យសិស្សរៀបចំ ប្រយោគផ្សេងៗដើម្បីឆ្លើយសំណួរ។<br>• ជាញឹកញាប់ឱ្យសិស្សផ្តល់ហេតុផល សម្រាប់ចម្លើយនីមួយៗ។<br>• ជារឿយៗឱ្យសិស្សអានអត្ថបទដែលមានរូបភាព និងប្រយោគខ្លីៗហើយបន្ទាប់មកឱ្យពួក គេអានអត្ថបទដែលកាន់តែលំបាកនៅក្នុងកាសែត ទស្សនាវដ្តី.....។<br>• ធ្វើឱ្យសិស្សមានទម្លាប់ប្រើវចនានុក្រមដើម្បីឱ្យពួកគេមានសមត្ថភាពស្វែងរកពាក្យនិង អត្ថន័យរបស់ពាក្យទាំងនោះ។<br>• ផ្តល់ការកែតម្រូវយ៉ាងច្បាស់លាស់លើរាល់កិច្ចការទាំងអស់ដែលបានដាក់ឱ្យសិស្សធ្វើ និង កែតម្រូវចម្លើយខុសដែលសិស្ស បានផ្តល់ឱ្យភ្លាមៗ។ |

**អូទីសឹម (ASD)**

**អូទីសឹម៖ សញ្ញានិងលក្ខណៈសម្គាល់**

សញ្ញាសម្គាល់របស់អូទីសឹម៖

លក្ខណៈសំខាន់ៗរបស់ ASD គឺជាបញ្ហាទាក់ទងនឹងការប្រាស្រ័យទាក់ទង នឹងអន្តរកម្មក្នុងសង្គម។

សញ្ញាសម្គាល់របស់ ASD ចំពោះកុមារនៅមត្តេយ្យសិក្សា៖

**ភាសានិយាយ**

- មានភាពយឺតយ៉ាវក្នុងការលូតលាស់លើការនិយាយស្តី(ឧទាហរណ៍ និយាយបានតិចជាង50 ពាក្យផ្សេងៗគ្នាពេលមានអាយុ 2 ឆ្នាំ) ឬមិននិយាយអ្វីទាំងអស់តែម្តង
- ជាញឹកញាប់និយាយពាក្យ និងប្រយោគដដែលៗ
- សំដីដែលមានសំឡេងដដែលៗ ឬស្មើ
- ចូលចិត្តទំនាក់ទំនងដោយប្រើពាក្យតែមួយម៉ាត់ៗ បើទោះបីជាអាចនិយាយបានជាឃ្លាក៏ដោយ

**ឆ្លើយតបជាមួយអ្នកដទៃ**

- មិនឆ្លើយនៅពេលគេហៅចំឈ្មោះរបស់ខ្លួនទោះបីជាស្តាប់ឮធម្មតាក៏ដោយ
- មិនទទួលយកការថ្នាក់ថ្នមដែលឪពុកម្តាយឬអ្នកថែទាំផ្តល់ឱ្យ (ទោះបីជាពួកគេអាចផ្តួចផ្តើមឱ្យ មានការថ្នាក់ថ្នមដោយខ្លួនឯងក៏ដោយ)
- ប្រតិកម្មអវិជ្ជមានខុសពីធម្មតានៅពេលមាននរណាម្នាក់ស្នើសុំឱ្យគេធ្វើអ្វីមួយ។

**ធ្វើអន្តរកម្មជាមួយអ្នកដទៃ**

- មិនដឹងពីទីកន្លែងផ្ទាល់ខ្លួនរបស់អ្នកដទៃ ឬពុំមានភាពអត់ឱនចំពោះអ្នកដែលចូល មកកន្លែងរបស់គេផ្ទាល់
- ចាប់អារម្មណ៍តិចតួចក្នុងការទាក់ទងជាមួយអ្នកដទៃរួមទាំងកុមារដែលមានអាយុប្រហាក់ប្រហែលគ្នា
- មិនភាពរីករាយចំពោះស្ថានភាពផ្សេងៗដែលកុមារភាគច្រើនដែលមានអាយុដំណាលនឹងគេចូលចិត្តដូចជាពិធីខួបកំណើតជាដើម
- ចូលចិត្តលេងតែម្នាក់ឯងជាជាងការសុំឱ្យអ្នកដទៃលេងជាមួយ
- កម្រប្រើកាយវិការឬការបង្ហាញទឹកមុខនៅពេលប្រាស្រ័យទាក់ទងណាស់
- មិនមានការប្រើក្រសែភ្នែក

**អាកប្បកិរិយា**

- មានចលនាដដែលៗដូចជាការទះដៃ ងឹកងោកទៅមុខទៅក្រោយៗ ឬផ្ទាត់ម្រាមដៃរបស់ខ្លួន
- លេងប្រដាប់ក្មេងលេងតាមរបៀបដដែលៗនិងគ្មានភាពច្នៃប្រឌិត ដូចជាការតម្រៀបដុំតាមលំដាប់ទំហំឬពណ៌ជាជាងប្រើប្រាស់ដុំទាំងនោះដើម្បីសាងសង់រូបអ្វីមួយ។
- ចូលចិត្តមានទម្លាប់ប្រចាំថ្ងៃស្រដៀងៗគ្នា ហើយមានការខកចិត្តយ៉ាងខ្លាំងប្រសិនបើមានការផ្លាស់ប្តូរទម្លាប់ប្រចាំថ្ងៃនោះ
- ចូលចិត្ត ឬមិនចូលចិត្តខ្លាំងចំពោះម្ហូបអាហារមួយចំនួនដោយផ្អែកលើលក្ខណៈក្លិន ឬពណ៌របស់ម្ហូបអាហារ ដោយមិនផ្អែកលើរសជាតិរបស់ម្ហូបអាហារ
- មានការចាប់អារម្មណ៍ផ្នែកវិញ្ញាណខុសពីធម្មតា - ឧទាហរណ៍កុមារអូទីសឹម អាចហិត បើបប្រដាប់ក្មេងលេង វត្ថុផ្សេងៗ ឬមនុស្សមិនមានភាពសមរម្យ

**សញ្ញា និងលក្ខណៈសម្គាល់ របស់ អូទីសឹម ចំពោះកុមារដែលគ្រប់អាយុចូលរៀន**

**ភាសានិយាយ**

- មិនចូលចិត្តការប្រើភាសានិយាយ
- សំដីដែលមានសំឡេងដដែលៗ ឬស្មើ
- និយាយដោយប្រើប្រយោគមុនពេលរៀនជាជាងការដាក់បញ្ចូលគ្នានូវពាក្យនីមួយៗដើម្បីបង្កើត ឃ្លាថ្មីៗ
- និយាយតែឯង ជាជាងការសន្ទនាគ្នាទៅវិញទៅមក

**ការឆ្លើយតបជាមួយអ្នកដទៃ**

- ការទទួលយកសំដីរបស់មនុស្សដទៃក្នុងន័យត្រង់ៗតែម្តង និងមិនអាចយល់ពីពាក្យចំអក បញ្ឈឺចិត្ត ពាក្យប្រៀបធៀប ឬសំដីបញ្ចិតបញ្ចៀង
- មានប្រតិកម្មអវិជ្ជមានខុសពីធម្មតានៅពេលមាននរណាម្នាក់ស្នើសុំឱ្យគេធ្វើអ្វីមួយ

**ការធ្វើអន្តរកម្មជាមួយអ្នកដទៃ**

- មិនដឹងពីទីកន្លែងផ្ទាល់ខ្លួនរបស់អ្នកដទៃ ឬពុំមានភាពអត់ឱនចំពោះអ្នកដែលចូល មកកន្លែងរបស់គេផ្ទាល់
- មានការចាប់អារម្មណ៍តិចតួចក្នុងការទាក់ទងជាមួយអ្នកដទៃរួមទាំងកុមារដែលមានអាយុប្រហាក់ប្រហែលគ្នា ឬមានមិត្តភក្តិជិតស្និទ្ធពីរបីនាក់ប៉ុណ្ណោះ ទោះជាមានការព្យាយាមចងមិត្តភាពក៏ដោយ
- មិនយល់អំពីរបៀបដែលមនុស្សធ្វើអន្តរកម្មនៅក្នុងសង្គមជាទូទៅដូចជាការស្វាគមន៍អ្នកដទៃ ឬការជូនពរពួកគេពេលបែកគ្នា
- មិនមានសមត្ថភាពក្នុងការសម្រួលការលើកដាក់សំឡេង និងខ្លឹមសារនៃការនិយាយរបស់ខ្លួនឱ្យស្របនឹងស្ថានភាពសង្គមខុសៗគ្នាទេ-ឧទាហរណ៍ការនិយាយស្តីបែបផ្លូវការបំផុតនៅក្នុងពិធីជប់លៀងមួយ ហើយបន្ទាប់មកនិយាយទៅកាន់មនុស្សចម្លែកតាមរបៀបស្រដៀងគ្នានេះដែរ
- មិនមានភាពរីករាយចំពោះស្ថានភាព និងសកម្មភាពនានាដែលកុមារដែលមានអាយុដំណាលគ្នាភាគច្រើនសប្បាយរីករាយ
- កម្រប្រើកាយវិការឬការបង្ហាញទឹកមុខនៅពេលធ្វើការប្រាស្រ័យទាក់ទងណាស់
- មិនប្រើក្រសែភ្នែកក្នុងការប្រាស្រ័យទាក់ទង

**អាកប្បកិរិយា**

- មានចលនាដដែលៗដូចជាការទះដៃ ងឹកងោកទៅមុខទៅក្រោយៗ ឬផ្ទាត់ម្រាមដៃរបស់គេ
- លេងក្នុងលក្ខណៈដដែលៗ និងមិនមានភាពច្នៃប្រឌិត ជាញឹកញាប់ចូលចិត្តលេងជាមួយវត្ថុផ្សេងៗជាជាងលេងជាមួយមនុស្ស
- មានការវិវឌ្ឍនូវការចាប់អារម្មណ៍ជាក់លាក់ខ្ពស់មួយចំពោះប្រធានបទឬសកម្មភាពមួយ
- ចូលចិត្តមានទម្លាប់ប្រចាំថ្ងៃស្រដៀងៗគ្នា ហើយមានការខកចិត្តយ៉ាងខ្លាំងប្រសិនបើមានការផ្លាស់ប្តូរទម្លាប់ប្រចាំថ្ងៃនោះ
- ចូលចិត្ត ឬមិនចូលចិត្តខ្លាំងចំពោះម្ហូបអាហារមួយចំនួនដោយផ្អែកលើលក្ខណៈក្លិន ឬពណ៌របស់ម្ហូបអាហារ ដោយមិនផ្អែកលើរសជាតិរបស់ម្ហូបអាហារ
- មានការចាប់អារម្មណ៍ផ្នែកវិញ្ញាណខុសពីធម្មតា - ឧទាហរណ៍កុមារអូទីសឹម អាចហិត ឬមើលប្រដាប់ក្មេងលេងវត្ថុផ្សេងៗ ឬមនុស្សមិនមានភាពសមរម្យ

| ឧទាហរណ៍សកម្មភាពនៃអូទីសឹម | |
|---|---|
| សញ្ញានិង លក្ខណៈសម្គាល់ | យុទ្ធសាស្ត្រ បច្ចេកទេស សកម្មភាព និងសម្ភារ |
| • ចូលចិត្តទំនាក់ទំនងដោយប្រើពាក្យតែមួយម៉ាត់ៗ ទោះ មានសមត្ថភាពនិយាយជាឃ្លាក៏ដោយ<br>• មិនចូលចិត្តការប្រើភាសានិយាយ | អូទីសឹមៈ សកម្មភាព<br>សកម្មភាពទី 1៖<br>***ពណ៌ចម្រុះក្នុងដបៈ*** នេះគឺជាសកម្មភាពសាមញ្ញមួយដែលអាចជួយដល់ការលូតលាស់ផ្នែកបញ្ញាកូនរបស់លោកលោកស្រីដែលទើបនឹងចេះដើរ និងជួយឱ្យគេផ្តោតអារម្មណ៍បានល្អ។ ពណ៌ដែលធ្វើឱ្យចាប់អារម្មណ៍និងរាងដែលគួរឱ្យចាប់ចិត្តនៅក្នុងដបគឺច្បាស់ជាទាក់ទាញការយកចិត្តទុកដាក់របស់កូនលោក លោកស្រី។<br>ចូរធ្វើឱ្យប្រាកដថា វត្ថុនានាដែលមាននៅក្នុងដបមានពណ៌ចម្រុះតាមដែលអាចធ្វើទៅបាន។ ចូរឱ្យកូនរបស់លោក លោកស្រី ចូលរួមរើសវត្ថុផ្សេងៗ សម្រាប់ដាក់ក្នុងដប។<br>លោក លោកស្រីត្រូវការៈ<br>• ដបឬក្រឡដ័រទទេ<br>• ទឹក<br>• ទឹកស៊ីរ៉ូធ្វើពីពោត<br>• វត្ថុតាំងលម្អតូចតាចដូចជាឃ្នាបគាបសក់ គ្រាប់អង្កាំ ឡេវ ឬគ្រឿងចុច ។ល។<br>• គ្រាប់ដែលមានពន្លឺភ្លឺផ្លេកៗមួយកញ្ចប់<br>• ថ្នាំពណ៌ សម្រាប់ផាត់ផ្ទាំងអក្ខរក្រម<br>• ក្រដាសមួយសន្លឹក។<br>**សេចក្តីណែនាំៈ**<br>ចាប់ផ្តើមដោយឱ្យកូនរបស់លោក លោកស្រីសរសេរអក្សរពី ក ដល់ អ នៅលើក្រដាសមួយសន្លឹកនោះ។ ឥឡូវ ចូរចាប់ផ្តើមដាក់វត្ថុដែលបានរៀបរាប់ខាងលើចូលក្នុងដប។ ចាក់ទឹកពណ៌ចូលកន្លះដប ហើយចាក់ទឹកស៊ីរ៉ូពោតចូលកន្លះដបទៀត។ បិទគម្របដបឱ្យជិតដោយប្រើការ និងក្រឡុកវត្ថុក្នុងដបឱ្យបានសព្វល្អ។ ពេលរៀបចំរួចរាល់ហើយ ឱ្យកូនរបស់លោក លោកស្រីរកមើលអក្ខរក្រមទាំងអស់នៅក្នុងដបហើយយកអក្សរផ្សេងៗដែល កូនរបស់លោក លោកស្រីរកឃើញមកដាក់ |

| | |
|---|---|
| | លើសន្លឹកក្រដាស។ |
| • សម្ដីដែលមានសំឡេងដដែលៗ ឬស្ទើ | **សកម្មភាពទី 2**<br>***ការផាត់ពណ៌ ដោយប្រើដុំទឹកកកពណ៌*** (ice painting) ជាមួយនឹងការដាក់បន្ថែមការពិសោធន៍ផ្នែក វិទ្យាសាស្ត្រដ៏សប្បាយរីករាយបែបនេះ កូនរបស់លោកលោកស្រីនឹង មានការចង់ដឹងយ៉ាងខ្លាំង សកម្មភាពនេះនឹងជួយបង្កើនសមត្ថភាពរបស់កូនលោក លោកស្រីក្នុងការសម្គាល់និងបែងចែកពណ៌នានា។ វាក៏នឹងជួយលើកកម្ពស់បំណិន និងចំណេះដឹងក្នុងការសង្កេតរបស់គេ អំពីគោលគំនិតជាក់លាក់ផ្នែកវិទ្យាសាស្ត្រដែរ។<br>លោក លោកស្រីត្រូវមាន៖<br>• ថាសទឹកកក<br>• ថ្នាំពណ៌ សម្រាប់ផាត់បន្ទះឈើសំប៉ែតតូចៗឬ ក្រដាស<br>• ទឹក<br>• សន្លឹកដែកស្ដើងៗ (ដែលអាចបត់បាន)<br>**សេចក្ដីណែនាំ៖**<br>លាយថ្នាំពណ៌ដែលកូនរបស់លោក លោកស្រីចង់ប្រើជាមួយទឹកបន្តិច ហើយចាក់វាទៅក្នុងថតរបស់ថាសទឹកកក។ ដាក់បន្ទះឈើសំប៉ែតតូចៗ ទៅក្នុងថតនីមួយៗហើយប្រើសន្លឹកដែកស្ដែងៗ ដើម្បីគ្របពីលើថាស និងជួយទប់ឈើកុំឱ្យដួល។ ដាក់ថាសទៅក្នុងទូទឹកកកថ្មៗ និងទុកឱ្យវាកកក្នុងរយៈពេល ២-៣ ម៉ោង។ ឥឡូវនេះសូមយកដុំទឹកកក ដែលមានពណ៌ចេញ ហើយឱ្យកូនរបស់លោក លោកស្រីបង្វិលដុំទឹកកកនោះលេង និងបង្កើតទម្រង់ផ្សេងៗដោយប្រើដុំទឹកកកពណ៌ដែល មានរាងបួនជ្រុងនៅលើសន្លឹកក្រដាស។ |
| • មានការចាប់អារម្មណ៍តិចតួចក្នុងការធ្វើអន្តរកម្មជាមួយអ្នកដទៃរួមទាំងកុមារដែលមានអាយុស្រាបាលៗគ្នាឬមានមិត្តភក្ដិជិតស្និទ្ធតែពីរបីនាក់ប៉ុណ្ណោះ បើទោះបីជា | **សកម្មភាពទី 3៖**<br>***វត្ថុដែលអាចទទួលទានបាន*** តើអ្វីដែលល្អជាងខ្សែកដ៏ស្រស់ស្អាតដែលកូនរបស់លោក លោកស្រីមិនត្រឹមតែចូលចិត្តពាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលទានផងដែរ? សកម្មភាពនេះនឹងកែលម្អការសម្របសម្រួលដៃនិងភ្នែករបស់កូនលោក លោកស្រី ក៏ដូចជា បំណិនចលនាតូចរបស់គេដែរ។ |

| | |
|---|---|
| ព្យាយាមចងមិត្តភាពក៏ដោយ | លោក លោកស្រីត្រូវមានៈ<br>• ស្ករគ្រាប់រាងវែង<br>• ស្ករគ្រាប់ចម្រុះពណ៌ ឬគ្រាប់ធញ្ញជាតិដែលមានរន្ធនៅកណ្ដាល<br>**សេចក្តីណែនាំៈ**<br>ឱ្យស្ករគ្រាប់វែងទៅកូនរបស់លោក លោកស្រី ហើយឱ្យនាងចងស្ករគ្រាប់ឬគ្រាប់ធញ្ញជាតិជាប់ជាមួយស្ករគ្រាប់វែងៗនោះម្ដងមួយៗ។ នៅពេលចងស្ករគ្រាប់វែងជាមួយស្ករគ្រាប់ ឬគ្រាប់ធញ្ញជាតិរួចហើយ ចូរចងភ្ជាប់ចុងស្ករគ្រាប់វែងៗទាំងសងខាង។<br><br>**សកម្មភាពទី 4**<br>***ល្បែងផ្គូផ្គងៈ*** សកម្មភាពនេះគឺជាមធ្យោបាយដ៏រីករាយមួយដើម្បីលើកកម្ពស់ការរៀនសូត្រនិងសមត្ថភាពផ្នែកចលនារាងកាយរបស់កូនលោក លោកស្រី។ លោក លោកស្រីអាចកែសម្រួលសកម្មភាពបានដោយអាស្រ័យលើអ្វីដែលកូនរបស់លោក លោកស្រីកំពុងរៀន នៅសាលារៀន។<br>លោក លោកស្រីត្រូវមានៈ<br>• ឃ្នាបគាបខោអាវដែលមានពណ៌មួយកញ្ចប់<br>• លេខ អក្ខរក្រមផ្លែឈើឬបន្លែផ្ទាំងប្រកាស សម្រាប់បិទជាមួយនឹង ក្រដាសស្អិតសម្រាប់ផ្គូផ្គង។<br>**សេចក្តីណែនាំៈ**<br>នៅលើតុ ចូរដាក់ផ្ទាំងក្រដាសសម្រាប់បិទចំនួនពី ១០ទៅ១៥ ផ្ទាំងដែល មានរូបភាពផ្លែឈើ បន្លែ សត្វផ្សេងៗ ។ល។ ដាក់ស្លាកនៅលើឃ្នាប គាបខោអាវនីមួយៗឱ្យត្រូវនឹងរូបភាពនៅលើផ្ទាំងក្រដាស។ ឱ្យកូនរបស់លោក លោកស្រីគាបឃ្នាបខោអាវឱ្យត្រូវនឹងផ្ទាំងក្រដាសដែលជាគូនឹងគ្នា។<br>**សកម្មភាពទី 5**<br>*http://raisingchildren.net.au/articles/autism_spectrum_disorder_play ។ htmlhttp://raisingchildren.net.au/articles/rough_and_tumble_play.html* |

វីដេអូខ្លីនេះគឺនិយាយពីការលេងដណ្ដើមគ្នា(rough-and-tumble)គឺដូចជាការលេងដេញចាប់ និងបោកចំបាប់អញ្ចឹង។ ចំណុចទាំងនេះគឺជារឿងល្អសម្រាប់គ្រូបង្រៀន ឬឪពុកម្ដាយក្នុងការលេងជាមួយកូន របស់ខ្លួន។ លោក លោកស្រីអាចលេងសប្បាយជាមួយគ្នា និងពង្រឹង ចំណងទាក់ទងគ្នាក្នុងពេលតែមួយ។ ដូចជាការហាត់ប្រាណល្អមួយដែរ ការលេងដណ្ដើមគ្នាជួយកុមារឱ្យដឹងថាតើគេមានកម្លាំងកម្រិតណា។

លោក លោកស្រីត្រូវមានភាពទន់ភ្លន់(ថ្នម)ជានិច្ចជាមួយកុមារតូចៗ ដូច្នេះពួកគេពុំមានការឈឺចាប់ទេ។

**ការលេងដណ្ដើមគ្នា៖ អាយុនិងដំណាក់កាល**

**ទារក និងកុមារចេះដើរតេះតះ** ចូលចិត្តការធ្វើចលនាដែលបង្កឱ្យមានភាពសប្បាយ ដរាបណាពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព។ កុមារចេះដើរតេះតះ និងទារកចូលចិត្តឱ្យឪពុកម្ដាយរបស់គេដាក់គេលើជង្គង់របស់គាត់ និងអង្រួនតិចៗ ឬលើកគេឡើងឱ្យខ្ពស់។ វាជាការល្អបំផុតដែលត្រូវធ្វើថ្នមៗជាមួយកុមារតូចៗ ដើម្បីជៀសវាងការរងរបួសដោយចៃដន្យណាមួយ។

កុមារចេះដើរតេះតះចូលចិត្តលេងដេញចាប់ឬដេញប៉ះចាប់បង្វិលជុំវិញនិងរាំ។ ការលេងទាក់ទងនឹងសកម្មភាព ប្រភេទនេះដំណើរការល្អបំផុតនៅពេលដែលកុមារភ្ញាក់ដឹងខ្លួនស្រួល បួល និងមិនរំពឹងទុកថាត្រូវចូលគេងឬអង្គុយស្ងៀមនៅពេលណាមួយ ភ្លាមៗ។

**កុមាររៀននៅសាលាបឋមសិក្សា** គឺចូលចិត្តលេងដណ្ដើមគ្នាបំផុត។

| ការលំបាកក្នុងដំណើរនៃការស្តាប់ |
| --- |
| **លំបាកក្នុងការស្តាប់៖ សញ្ញា និងលក្ខណៈសម្គាល់**<br>• មានការលំបាកក្នុងការយល់អត្ថន័យរបស់ភាសានិយាយ<br>• ខ្សោយក្នុងការសរសេរ<br>• ពិបាកក្នុងការអានយល់ន័យ<br>• លំបាកក្នុងការបញ្ចេញគំនិតក្នុងទម្រង់ជាពាក្យសម្តី<br>• លំបាកក្នុងការដាក់ងារ ឬហៅឈ្មោះវត្ថុ<br>• ជារឿយៗមានការពិបាកចិត្ត ដោយសារមានអ្វីៗដែលត្រូវនិយាយច្រើន បែជាគ្មានវិធីនិយាយវាចេញមកបាន<br>• មានអារម្មណ៍ថាពាក្យនានាគឺ "ស្ថិតនៅខាងចុងៗមាត់របស់ខ្ញុំ"<br>• អាចរៀបរាប់ពីវត្ថុមួយ និងគូររូបវត្ថុនោះបាន ប៉ុន្តែមិនអាចគិតរកពាក្យ នោះនិយាយចេញមកបាន<br>• អាចមានការសៅហ្មងក្នុងចិត្ត ឬមានអារម្មណ៍ទុក្ខព្រួយ<br>• មានការលំបាកក្នុងការយល់រឿងកំប្លែង |
| **លំបាកក្នុងដំណើរការនៃការស្តាប់៖ វិធីសាស្ត្រ**<br>• និយាយយឺតៗ និងច្បាស់ៗ ហើយប្រើប្រយោគសាមញ្ញៗដើម្បីបញ្ជូនព័ត៌មាន<br>• បញ្ជូនទៅរកអ្នកឯកទេសខាងព្យាបាលការនិយាយ<br>• អនុញ្ញាតឱ្យប្រើឧបករណ៍ថតសំឡេងសម្រាប់កត់ត្រា<br>• សរសេរគោលគំនិតសំខាន់ៗនៅលើក្តារខៀន<br>• ផ្តល់ឱ្យមានអ្នកគាំទ្រម្នាក់ ឬដៃគូដើម្បីជួយ<br>• ប្រើបច្ចេកទេសភ្ជាប់ជាមួយរូបភាពជាជំនួយដល់ការស្តាប់ និងការយល់<br>• ប្រើតារាង (ក្រាហ្វិក) សម្រាប់កត់ត្រាខ្លឹមសារមេរៀននៅក្នុងម៉ោងសិក្សា ឬពីសៀវភៅអាន<br>• ប្រើប្រាស់សាច់រឿងជាការចាប់ផ្តើមក្នុងការសរសេរ និងធ្វើកិច្ចការដែលគ្រូដាក់ឱ្យ<br>• ប្រើការគូសជំនួយក្នុងការយល់ខ្លឹមសារ<br>• បង្កើតសំនួរលម្អិត និងប្រើវត្ថុរូបី ឬរូបភាព ជាជំនួយក្នុងការយល់ខ្លឹមសារ។ |

| ឧទាហរណ៍សម្រាប់សកម្មភាពការលំបាកក្នុងដំណើរការនៃការស្តាប់ | |
|---|---|
| **សញ្ញា និងលក្ខណៈសម្គាល់ជាក់លាក់** | **វិធីសាស្ត្រ បច្ចេកទេស សកម្មភាព និងសម្ភារ** |
| **លំបាកក្នុងដំណើរការនៃការស្តាប់៖**<br>**សញ្ញា និងលក្ខណៈសម្គាល់**<br>• មានការលំបាកក្នុងការយល់អត្ថន័យរបស់ភាសានិយាយ<br>• ពិបាកក្នុងការអានយល់ន័យ<br>• លំបាកក្នុងការបញ្ចេញគំនិតក្នុងទម្រង់ជាពាក្យសម្តី<br>• លំបាកក្នុងការដាក់ងារ ឬហៅឈ្មោះវត្ថុ<br>• អាចរៀបរាប់ពីវត្ថុមួយ និងគូររូបវត្ថុនោះបាន ប៉ុន្តែមិនអាចគិតរកពាក្យ នោះនិយាយចេញមកបាន | **លំបាកក្នុងដំណើរការនៃការស្តាប់**<br>**សកម្មភាពទី 1**<br>ពិបាកយល់ពីភាសា = ពិបាកប្រើភាសា<br>ភាសាគឺជាផ្នែកដ៏សំខាន់មួយក្នុងការទំនាក់ទំនង។ សកម្មភាពអភិវឌ្ឍបំណិនភាសារបស់កុមារ ដែលពិបាកស្តាប់ មានសារៈសំខាន់ណាស់ចំពោះការអប់រំឪពុកម្តាយដែលជួយចិញ្ចឹមបីបាច់ និង បង្រៀនកុមារដើម្បីឱ្យគេអាចទទួលបានបំណិនដែលគេត្រូវការសម្រាប់ដឹកនាំជីវិតឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។ ពុំមានវិធីសាស្ត្រណាមួយដើម្បីព្យាបាលការពិបាកស្តាប់នេះទេ ហើយជារឿយៗភាពជោគជ័យអាស្រ័យលើកុមារ ម្នាក់ៗ។ ល្បែង និងសកម្មភាពមួយចំនួនខាងក្រោមនេះ ត្រូវបានចងក្រងដើម្បីជួយកុមារពិបាកក្នុងការប្រើភាសា ឱ្យអភិវឌ្ឍបំណិនផ្នែកភាសា និងកសាងនូវទំនុកចិត្តចំពោះសមត្ថភាពរបស់គេក្នុងការប្រាស្រ័យទាក់ទងឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។<br><br><br>**ភ្លើងពណ៌ក្រហម ពណ៌បៃតង ជំនួយកិច្ចការផ្ទះ**<br>យកក្រដាសសមួយសន្លឹក ហើយគូររង្វង់ធំៗចំនួនបី។ ផាត់ |

| | |
|---|---|
| | ពណ៌ ក្រហមមួយ លឿងមួយ និងបៃតងមួយ។ នៅពេលណាដែល លោក លោកស្រីជួយកូនឱ្យធ្វើកិច្ចការសាលាដាក់ឱ្យធ្វើនៅផ្ទះ (ឬមានការសន្ទនាផ្សេងៗ) សូមលើកទឹកចិត្តគេឱ្យប្រើបណ្ណពណ៌ក្រហម ពណ៌បៃតងនេះ។ នៅពេលដែលកូនមានអារម្មណ៍ថា លោក លោកស្រីបានប្រើពាក្យពេចន៍ច្រើនហួសហេតុពេក ចូរចង្អុលទៅរកបណ្ណពណ៌ក្រហម។ នេះគឺជាសញ្ញារបស់លោកលោកស្រីដើម្បីឱ្យគេឈប់សម្រាកមួយរយៈខ្លី ហើយពិនិត្យមើលឡើងវិញពីចំណុចនានារហូតទាល់តែកូនមានអារម្មណ៍ថាគេត្រៀមខ្លួនរួច និងផ្ដល់ភ្លើងបៃតងឱ្យ លោក លោកស្រីបន្តកិច្ចការទៀត។ គេក៏អាចប្រើរង្វង់ដូចគ្នាខាងលើ តែពណ៌លឿង ដើម្បីកាត់បន្ថយភាសាពាក្យសម្ដីនឹងសម្របទៅតាមតម្រូវការរបស់កូន ។ |
| • លំបាកក្នុងការបញ្ចេញគំនិតតាមរយៈពាក្យសំដី<br>• លំបាកក្នុងការយល់ពីអត្ថន័យតាមរយៈការនិយាយ<br>• ពិបាកក្នុងការអានយល់ន័យ | **<u>សកម្មភាពទី 2</u>**<br>**<u>និយាយទល់មុខកញ្ចក់</u>**<br>កុមារដែលលំបាកក្នុងដំណើរការនៃការស្ដាប់ តែងមានការលំបាកថែមទៀតចំពោះការស្ដាប់អ្វីដែលគេស្ដាប់ នៅពេលដែលពួកគេបែរមុខចេញពីអ្នកនិយាយ។ សូមជួយកូនរបស់អ្នកឱ្យចេះប្រើក្រសែភ្នែកបន្ថែមពីលើការស្ដាប់ ពោលគឺបន្តការកសាងបំណិនផ្នែកចក្ខុវិញ្ញាណ ។ យកបញ្ជីពាក្យ មកប្រកបពាក្យ ឬសូត្រកំណាព្យខ្លីៗ។ អង្គុយទល់មុខកូន ហើយនិយាយម្ដងមួយពាក្យៗយឺតៗ និងលើកដាក់សំឡេងឱ្យមានការចាប់អារម្មណ៍ ហើយធ្វើមាត់ឱ្យត្រូវនឹងសំឡេង។ បន្ទាប់មកឱ្យកូនថាតាមអ្នក ពោលគឺមិនត្រឹមតែព្យាយាមធ្វើឱ្យត្រូវតាមពាក្យ និងរបៀបដែលអ្នកនិយាយពាក្យនោះទេ ប៉ុន្តែថែមទាំងបង្ហាញទឹកមុខទៀតផង។ សូមកុំភ័យ ទោះបីមើលទៅដូចជាឆ្គួតបន្តិចក្នុងការធ្វើដូច្នេះ ពោលគឺធ្វើជ្រួញច្រមុះ ឬជ្រួញចិញ្ចើមរបស់អ្នក ដើម្បីសង្កត់ន័យបន្ថែមទៀត។ លើកទឹកចិត្តឱ្យកូនរបស់លោក លោកស្រីមើលកញ្ចក់នៅពេលគេនិយាយដើម្បីជួយពង្រឹង ការយល់ដឹងភាសាកាយវិការ។ |

**<u>សកម្មភាពទី 3</u>**

**<u>ល្បែង៖ រៀបវ៉ាន់ ទៅលេងផ្ទះលោកយាយ</u>**

ល្បែងនេះជួយកុមារមានការលំបាកក្នុងដំណើរការនៃការស្ដាប់ឱ្យអនុវត្តបំណិនចងចាំដែលមានសារៈសំខាន់ចំពោះការប្រាស្រ័យទាក់ទង។ ចាប់ផ្ដើមលេងល្បែងដោយនិយាយថា៖

- ខ្ញុំទៅផ្ទះលោកយាយ ហើយនៅក្នុងវ៉ាលី ខ្ញុំបានរៀបចំ ________________________ ។
- បន្ទាប់មកដល់វេនកូនរបស់អ្នកនិយាយម្ដង ដោយនិយាយថា៖
- ខ្ញុំទៅផ្ទះលោកយាយ ហើយក្នុងវ៉ាលី ខ្ញុំបានរៀបចំ(វត្ថុដែលអ្នកបានរាយក្នុងបញ្ជី)និង______________។

គោលដៅគឺបន្តបង្កើតសាច់រឿងត្រឡប់ចុះត្រឡប់ឡើង និងមើលឃើញថាតើអ្នកអាចបន្ថែមអ្វីបានខ្លះទៀតនៅក្នុងបញ្ជី។ ត្រូវប្រាកដថា អ្នកលេងល្បែងនេះយឺតៗ។

<u>សកម្មភាពបន្ថែមទៀតដើម្បីអភិវឌ្ឍបំណិនភាសាចំពោះកុមារពិបាកប្រើភាសា។</u>

- សាកល្បងលេង<u>ល្បែងជំនួយស្ដាប់</u>មួយចំនួន ដែលយើងបានចែករំលែកកាលពីម្សិលមិញ។ ល្បែងទាំងនោះមានសារៈសំខាន់ណាស់សម្រាប់កុមារដែលមានសមត្ថភាព និងកុមារពិការប្រភេទផ្សេងៗ។ ការស្ដាប់គឺជាផ្នែកមួយដ៏សំខាន់នៃការអភិវឌ្ឍផ្នែកភាសា។




- ប្រើឧបករណ៍ថតសម្លេង និងថតសំឡេងដោយខ្លួនអ្នកផ្ទាល់ ពេលអ្នកកំពុងប្រាប់រឿងដែលកូនពេញចិត្ត ព្រមទាំងផ្ដល់ការណែនាំពីរបៀបធ្វើអ្វីមួយ ឬធ្វើអ្វីផ្សេងៗទៀតដែលកូនអ្នកចង់ស្ដាប់ម្ដងហើយ

| | |
|---|---|
| | ម្តងទៀត។<br>• គូររូបភាពតាមសូរអក្សរជាមួយកូនរបស់អ្នក។ ជ្រើសរើសសូរអក្សរគោលដៅ ដូចជា "ធ" ហើយបន្ទាប់មកស្វែងរកពាក្យដែលចាប់ផ្តើមដោយអក្សរនោះនៅក្នុងទស្សនាវដ្តី។ កាត់អក្សរទាំងនោះ ហើយបិទនៅក្នុងកម្រងរូបភាព។<br>• បន្ថែមសៀវភៅសំខាន់ៗមួយចំនួននៅក្នុងបន្ទប់ដាក់សៀវភៅរបស់អ្នក។ ជ្រើសរើសសៀវភៅដែលអ្នកពេញចិត្តចំនួន៣ក្បាល ដើម្បីស្វែងយល់ពីកុមារពិបាកក្នុងការស្តាប់ ដែលជួយលើកកម្ពស់បំណិនភាសារួមមាន៖<br><br>• The Listening Child និពន្ធដោយ Stephen Prescod<br>• When the Brain Can't Hear និពន្ធដោយ Teri James Bellis<br>• The Sound of Hope និពន្ធដោយ Lois Kam Heymann<br><br><br><br>www.listenlovelearn.com<br>ដំណើរការមិនតាមលំដាប់នៃការស្តាប់ អាចនាំឱ្យមានការប្រឈមជាច្រើនដល់គ្រួសារអ្នក។ កុមារត្រូវការរៀនដើម្បីយល់ពីភាសា និងអភិវឌ្ឍបំណិនក្នុងការប្រាស្រ័យទាក់ តាមរយៈសកម្មភាពផ្សេងៗ ព្រមទាំងឱកាសក្នុងការពង្រឹង និងការរៀនត្រូវតាមគោលបំណងជាក់លាក់។ នៅពេលយើងបន្ថែមល្បែងមួយចំនួន ចូរប្រើប្រាស់សកម្មភាពនានា ដែលអភិវឌ្ឍបំណិនក្នុងការស្តាប់ និងកសាងនូវចំណុចខ្លាំង |

| | |
|---|---|
| | ទាក់ទងបែបបទរៀនសូត្រដែលយើងកំពុងអនុវត្តជំហានតូចៗទាំងនោះក្នុងទិសដៅត្រឹមត្រូវ។ |
| • អាចរៀបរាប់ពីវត្ថុមួយ និងគូររូបវត្ថុនោះបាន ប៉ុន្តែមិនអាចគិតរកពាក្យ នោះនិយាយចេញមកបាន<br>• លំបាកក្នុងការដាក់ងារ ឬហៅឈ្មោះវត្ថុ | **សកម្មភាពទី ៥**<br>**បញ្ហាទាក់ទងនឹងដំណើរការផ្នែកចក្ខុវិញ្ញាណ**<br>សរីរាង្គវិញ្ញាណនៃប្រព័ន្ធចក្ខុវិញ្ញាណគឺភ្នែក។ ភ្នែក និងខួរក្បាល មានទំនាក់ទំនងគ្នា និងធ្វើការរួមគ្នាដើម្បីជួយយើងក្នុងការបកស្រាយអ្វីៗដែលនៅជុំវិញខ្លួនយើងដោយប្រើប្រាស់គំហើញ ឬអ្វីដែលយើងមើលឃើញ។ ចំណុចនេះកើតឡើងតាមរយៈការបកស្រាយរបស់កាំរស្មី។ កាំរស្មីឆ្លងកាត់ប្រព័ន្ធផ្សេងៗគ្នាជាច្រើនរបស់ភ្នែក ហើយដល់ស្រទាប់កោសិកាចក្ខុវិញ្ញាណនៅក្នុងខួរក្បាល។ នៅត្រង់ចំណុចនេះ វត្ថុត្រូវបានកំណត់ និងផ្តល់អត្ថន័យ។ ចំណុចនេះរួមបញ្ចូលទាំងព័ត៌មានលម្អិតទាក់ទងនឹងពណ៌ ទំហំសមាមាត្រទាំង៣ ទីកន្លែងដែលវត្ថុមួយស្ថិតនៅក្នុងលំហ ការចងចាំពីរូបភាព និងផ្តល់នូវបរិបទនៃរូបភាពនៅក្នុងបរិយាកាស។<br><br>**បញ្ហាទាក់ទងនឹងដំណើរការផ្នែកចក្ខុវិញ្ញាណ**<br>ចូរស្រមៃថាប្រព័ន្ធចក្ខុវិញ្ញាណគឺជាកង់របស់ទោចក្រយាន។ នៅកណ្តាលកង់គឺជាសមត្ថភាពក្នុងការមើលឃើញ។ កាំកង់ទាំងអស់ដែលចេញពីចំណុចកណ្តាលគឺជាទិដ្ឋភាពខុសៗគ្នាជាច្រើនរបស់គំហើញ រួមទាំងសមត្ថភាពក្នុងការសម្គាល់ភាពខុសគ្នានៃវត្ថុផ្សេងៗរបស់ចក្ខុវិញ្ញាណ ការមើលឃើញ ការចងចាំ ការរៀបចំទម្រង់ សមត្ថភាពផ្នែកចលនារបស់ចក្ខុវិញ្ញាណ។ល។ ប្រព័ន្ធចក្ខុវិញ្ញាណមានមុខងារជាច្រើនដែលជួយកូនរបស់យើងឱ្យមានការជំជាត់ រៀនសូត្រ និងលូតលាស់។ ប្រព័ន្ធទាំងអស់ នេះដើរតួនាទីសំខាន់រៀងៗខ្លួន។ តាមរយៈការយល់ឃើញពីដំណើរការរបស់វិញ្ញាណ បញ្ហាផ្សេងៗទាក់ទងនឹងញ្ញាណ របស់គំហើញអាចរាំងដល់សមត្ថភាពរបស់កុមារមួយចំនួន ក្នុងការចូលរួមឱ្យបានជោគជ័យ |

| | |
|---|---|
| | នៅក្នុងបរិយាកាសជុំវិញរបស់គេ។<br>កុមារអាចទទួលការរំខានច្រើនដោយសារគ្រឿងជុំរុញផ្នែកចក្ខុវិញ្ញាណដែលនៅជុំវិញគេ។ ពួកគេអាចទទួលការរំខានច្រើនលើសលុបដោយសារពណ៌ជាច្រើននៅក្នុងបន្ទប់ ផ្ទាំងរូបភាព ឬ គំនូរសិល្បៈនៅលើជញ្ជាំង និងការផ្លាស់ទីចុះឡើងរបស់អ្នកផ្សេងៗទៀតដែលនៅជុំវិញគេ។ ចលនារូបភាពនៅលើកញ្ចក់ ទូរទស្សន៍ទាក់ទាញចំណាប់អារម្មណ៍របស់គេ។ គេអាចមើលឃើញសកម្មភាពនៅខាងក្រៅបង្អួច ឬចង់រាប់ឥដ្ឋនៅលើកម្រាល ដែលមានពណ៌ និងលក្ខណៈខុសៗគ្នា។<br><br>**សកម្មភាពអាចមើលឃើញគួជាទីពេញចិត្តរបស់យើងសម្រាប់កុមារ**<br>កុមារភាគច្រើនមានការលូតលាស់ប្រព័ន្ធចក្ខុវិញ្ញាណយ៉ាងខ្លាំងតាមរយៈការចូលរួមក្នុងសកម្មភាពនៃការលេងកំសាន្តងាយៗ ដែលអនុញ្ញាតឱ្យមានការស្វែងយល់ផ្នែកចក្ខុវិញ្ញាណនៅក្នុងបរិយាកាសប្រចាំថ្ងៃរបស់ពួកគេ។ មានសកម្មភាព ឬល្បែង ជាច្រើនដែលអាចជួយលើកកម្ពស់ការលូតលាស់ប្រព័ន្ធចក្ខុវិញ្ញាណឱ្យមាន សុខភាពល្អ ដែលរួមមាន៖<br>▪ ខ្ញុំរកមើល<br>▪ ល្បែងផ្គុំរូបភាព<br>▪ ស្វែងរកពាក្យ និងប្រពលពាក្យ<br>▪ ស្វែងរកនិងរើសអេតចាយ |

| ការលំបាកក្នុងការយល់ដឹងតាមរយៈចក្ខុវិញ្ញាណ |
|---|
| **សញ្ញា និងលក្ខណៈសម្គាល់៖**<br>• អាចមើលឃើញបញ្ច្រាសៈ ក នឹង ត គ ភ ឬមើលឃើញត្រលប់ពីលើចុះក្រោម៖ ជនឹង ផ, ដ,ជ,ប,ថ និងមើលច្រឡំ ◌ានឹង. ◌េ◌ែ◌ៃ .ល ហ ។ លេខ ៦ នឹង ៩ .២ និង ៧<br>• មានការលំបាកក្នុងការដើរជុំវិញបរិវេណនានា<br>• ត្អូញត្អែរពីការឈឺ និងការរមាស់ភ្នែក ញីភ្នែក ពិបាកអានអក្សរព្រិលមិនច្បាស់<br>• ងាកក្បាលនៅពេលអានឆ្លងទំព័រ ឬកាន់ចំជ្រុងក្រដាស<br>• បិទភ្នែកម្ខាងពេលកំពុងធ្វើការ ឬស្ទាបខណៈពេលកំពុងអាន<br>• មិនអាចចម្លងអក្សរបានត្រឹមត្រូវ<br>• វង្វេងកន្លែងជាញឹកញាប់<br>• មិនចំណាំវត្ថុ ឬពាក្យមួយប្រសិនបើគេបង្ហាញតែផ្នែកណាមួយនៃវត្ថុ ឬ ពាក្យនោះ<br>• កាន់ខ្មៅដៃណែនពេក។ ជាញឹកញាប់ធ្វើឱ្យបាក់ចុងខ្មៅដៃ ឬខ្មៅដៃពណ៌។<br>• ពិបាកកាត់ ឬបិទ<br>• សរសេរអក្សរមិនត្រង់ជួរ អាចធ្វើឱ្យក្រដាសដែលសរសេររញ៉េរញ៉ៃ ដែលអាចមានទាំងអក្សរជាន់គ្នា ដកឃ្លាមិនទៀងទាត់ អក្សរមិនត្រង់បន្ទាត់ |
| **ការលំបាកក្នុងការយល់ដឹងតាមរយៈចក្ខុវិញ្ញាណ៖ យុទ្ធសាស្ត្រ**<br>• កុំដាក់ពិន្ទុចំពោះការសរសេរដោយដៃ<br>• អនុញ្ញាតឱ្យសិស្សសរសេរតាមអាននូវរឿងដែលមានលក្ខណៈច្នៃប្រឌិត<br>• ផ្តល់ជម្រើសផ្សេងទៀតឱ្យសិស្សសម្រាប់កិច្ចការទាក់ទងនឹងការសរសេរ<br>• សំណូមពរឱ្យប្រើខ្មៅដៃដែលមានដាក់ប្រដាប់កាន់ ខ្មៅដៃ និងប៊ិកដែលគេរៀបចំជាពិសេស<br>• អនុញ្ញាតឱ្យប្រើកុំព្យូទ័រ ឬកម្មវិធីវាយអត្ថបទ<br>• ដាក់កម្រិតកិច្ចការទាក់ទងនឹងការចម្លង<br>• ផ្តល់ឧបករណ៍តាមដាន៖ បន្ទាត់ អត្ថបទពីកំព្យូទ័រ<br>• ប្រើសៀវភៅដែលមានបោះពុម្ពអក្សរធំៗ<br>• គ្រោងនឹងទិញ ឬពិនិត្យមើលសៀវភៅដែលមានភ្ជាប់កាសែតអាត់សម្លេង<br>• ដកស្រង់បទពិសោធន៍ដោយប្រើប្រភេទក្រដាសខុសៗគ្នា៖ ក្រដាសពណ៌ ក្រាហ្វ ក្រដាសដែលមានស្នាមបន្ទាត់ជាក្រឡា |

ឧទាហរណ៍សកម្មភាព ទាក់ទងនឹងការលំបាកក្នុងការយល់ដឹងតាមរយៈចក្ខុវិញ្ញាណ៖

| **ការលំបាកក្នុងការយល់ដឹងតាមរយៈចក្ខុវិញ្ញាណ** | **យុទ្ធសាស្ត្រ បច្ចេកទេស សកម្មភាពនិងសម្ភារ** |
| --- | --- |
| ការលំបាកចំពោះការដឹងដោយវិញ្ញាណតាមរយៈចក្ខុវិញ្ញាណ/ការលំបាកផ្នែកចលនារបស់ចក្ខុវិញ្ញាណ៖ សញ្ញា និង លក្ខណៈសម្គាល់<br><br>• មិនចំណាំវត្ថុ/ពាក្យមួយ ប្រសិនបើគេបង្ហាញតែផ្នែកណាមួយនៃវត្ថុ / ពាក្យនោះប៉ុណ្ណោះ<br><br>• សរសេរអក្សរមិនត្រង់ជ្រុង (misaligns letter) អាចមានក្រដាសដែលសរសេរញ៉េរញ៉ៃ ដែលអាចមានទាំងអក្សរជាន់ គ្នា ដកឃ្លាមិនទៀងទាត់ អក្សរមិនត្រង់បន្ទាត់ | **សកម្មភាពទី 1**<br>**បំណិនក្នុងការចងចាំតាមរយៈគំហើញនៅក្នុងបន្ទប់រៀន**<br>**គន្លឹះងាយៗ៖** ការតម្រៀបអក្សរឱ្យចេញជាពាក្យ<br>ជ្រើសរើសពាក្យសម្រាប់ប្រកបមួយដែលសិស្សរបស់អ្នកបានរៀន និងចាំស្ទាត់ហើយ។ ច្របល់អក្សរបញ្ចូលគ្នា។ដោយផ្អែកលើអាយុរបស់សិស្ស ចូរបង្ហាញសិស្សក្នុងថ្នាក់នូវការតម្រៀបពាក្យមួយៗ ដែលមានតួអក្សរពី ៤ ទៅ ៧ តួអក្សរក្នុងមួយលើកៗ។<br><br>ចូរចងចាំថា ត្រូវចាប់ផ្ដើមពីពាក្យងាយៗសម្រាប់សិស្ស ហើយបន្ទាប់ឈានទៅរកពាក្យពិបាកៗ។<br><br>អ្នកអាចប្រើក្ដារខៀន ឬបណ្ណអក្សរឬបណ្ណដែលបានសរសេរពាក្យដែលត្រូវតម្រៀបទុកជាមុនរួចហើយសម្រាប់ការងារនេះ ប៉ុន្តែអនុញ្ញាតឱ្យសិស្សពិនិត្យមើលពាក្យដែលច្របល់ចូលគ្នានីមួយៗតែ ១វិនាទីប៉ុណ្ណោះក្នុង១អក្សរ។ ឧទាហរណ៍ បង្ហាញពួកគេ "**ប ា យ**" ឱ្យពួកគេមើលត្រឹមតែ៣វិនាទីប៉ុណ្ណោះ។ (អត្ថប្រយោជន៍៖ ប្រសិនបើកុមារមិនយកចិត្តទុកដាក់ទេពួកគេនឹងបាត់បង់ឱកាស!) សិស្សសរសេរអក្សរដែលច្របល់ចូលគ្នា បន្ទាប់មកពិនិត្យមើលថាតើពួកគេអាចសរសេរពាក្យមួយណា។<br>**វង្វាន់បន្ថែម៖** សម្រាប់កិច្ចការដែលកាន់តែលំបាក ចូររៀបចំកិច្ចការនេះឱ្យទៅជាភារកិច្ចនៃការចងចាំតាមរយៈសោតវិញ្ញាណ។<br>ជំនួសឱ្យការបង្ហាញតួអក្សរដល់សិស្ស ឱ្យពួកគេស្ដាប់គ្រូ អានឮៗវិញ (១អក្សរក្នុង១វិនាទី)។ ប្រសិនបើសិស្សរបស់អ្នកពូកែ អ្នកអាចឱ្យពួកគេរកនឹកតួអក្សរ និងតម្រៀបជាពាក្យនៅក្នុងចិត្តរបស់ពួកគេ។ សូមប្រុងប្រយ័ត្ន៖ ខ្ញុំសូមផ្ដល់អនុសាសន៍ឱ្យលោក លោក |

| | |
|---|---|
| | ស្រីធ្វើឱ្យប្រាកដថាសិស្សអាចធ្វើរបៀបនេះជាមួយពាក្យដែលមិនទាន់ច្របល់គ្នាជាមុនសិន។ ហើយលោក លោកស្រីក៏ត្រូវធ្វើ តេស្តខ្លួនឯងដែរ។ វាពិតជាធ្វើឱ្យកោសិកាខួរក្បាលទាំងនោះមានចលនា!<br><br><br>សកម្មភាពគំហើញសម្រាប់កុមារ អានត្រួសៗ<br><br> |

ពាក្យដែលគេឃើញញឹកញាប់នៅក្នុងល្បែង"<u>មានតែម្តាយម្នាក់គត់"</u> <u>(There's Just One Mommy)</u> - នៅក្នុងសកម្មភាពនេះសូមលើកទឹកចិត្តឱ្យកូនៗរបស់លោក លោកស្រីអានអក្សរនៅលើទំព័រត្រួសៗ។ ប្រាប់ពួកគេឱ្យទប់លំនឹងក្បាល(កុំឱ្យងាក) នៅពេលដែលពួកគេធ្វើចលនាភ្នែករកមើលអក្សរនិងពាក្យ។

<u>សកម្មភាពទី 2</u>



ល្បែងស្វែងរក និងតម្រៀបពណ៌ ដកស្រង់ចេញពី <u>កន្លែងដែលនាំឱ្យចម្រើនផ្នែកគំនិតច្នៃប្រឌិត (Where imagination Grows)</u>~ ការពិនិត្យរកមើលវត្ថុផ្សេងៗគឺជាវិធីល្អមួយដើម្បីអនុវត្តបំណិនចលនាផ្នែកចក្ខុ វិញ្ញាណ។

កិច្ចការដែលនាងត្រូវប្រឈម គឺការដាក់បន្ទះឈើនៅលើក្រដាស កាតុង ដែលមានបន្ទះឈើច្រើនជាង 2 បន្ទះ។

នៅពេលដែលក្រដាសកាតុងកាន់តែច្រើនឡើងៗ នាងត្រូវខំប្រឹងធ្វើការកាន់តែខ្លាំងដើម្បីកុំឱ្យម្រាមដៃ និងដៃរបស់នាងប៉ះបន្ទះឈើដែលនៅលើក្រដាសកាតុង។ ពេលខ្លះនាងមានការខកចិត្ត ដូច្នេះខ្ញុំត្រូវលើកទឹកចិត្តនាងឱ្យប្រើមេដៃនិងចង្អុលដៃរបស់នាងតែប៉ុណ្ណោះ ហើយម្រាមដៃផ្សេងទៀតត្រូវក្តាប់ឱ្យណែន។

| ការពិបាកផ្លង់អារម្មណ៍ និងសកម្មជ្រុល |
| --- |
| **សញ្ញា និងលក្ខណៈសម្គាល់៖**<br>• មិនអាចអង្គុយស្ងៀមបាន មានសកម្មភាពរវើកពេលអង្គុយ<br>• ឆាប់ធុញទ្រាន់ និងងាយទទួលការរំខាន<br>• មិនស្តាប់ ឬហាក់ដូចជាមិនទទួលបាននូវអ្វីដែលគេកំពុងនិយាយ<br>• លំបាកក្នុងការធ្វើតាម សូម្បីការណែនាំសាមញ្ញក៏ដោយ<br>• ស្តែងឱ្យឃើញនូវការចងចាំខ្សោយ<br>• ងាយបាត់បង់របស់របរផ្សេងៗ រួមទាំងកិច្ចការសាលារៀន និងរបស់របរផ្ទាល់ខ្លួន<br>• និយាយញាប់ ហើយនិយាយឥតឈប់<br>• លំបាកក្នុងការបំពេញកិច្ចការផ្សេងៗ<br>• មិនមានបំណិនក្នុងការរៀបចំឱ្យមានប្រសិទ្ធភាព<br>• ខ្វះភាពអត់ធ្មត់<br>• ជាទូទៅរពឹសខ្លាំង<br>• ការថប់អារម្មណ៍<br>• គេងមិនលក់<br>• ការប្រែប្រួលផ្នែកអារម្មណ៍ខ្លាំង និងញឹកញាប់<br>• បង្ហាញអារម្មណ៍មានលក្ខណៈខ្លាំងក្លា និងឆាប់រហ័ស<br>• មានភាពអត់ឱនតិចជាមួយមនុស្ស ស្ថានភាព និងបរិយាកាសជុំវិញខ្លួន<br>• ឆាប់មានកំហឹង<br>• ឆេវឆាវ<br>• ទំនាក់ទំនងផ្ទាល់ខ្លួនប្រែប្រួលជានិច្ច |

**មូលហេតុនៃសញ្ញា និងលក្ខណៈសម្គាល់៖**

- ការជក់បារី
- របបអាហារ និងសុខភាពពោះវៀន
- របួសខួរក្បាល
- តំណពូជ

**យុទ្ធសាស្ត្រ៖**

1. យល់ពីការលំបាកដែលសិស្សពិបាកផ្ទង់អារម្មណ៍ និងសកម្មជ្រុលហើយផ្តល់នូវបរិយាកាសក្នុងថ្នាក់រៀនមួយដែលមានរបៀបរៀបរយ សុវត្ថិភាព និងអាចព្យាករណ៍បាន។
2. បង្កើតឱ្យមានទំនាក់ទំនងល្អ និងសមរម្យជាមួយឪពុកម្តាយសិស្ស។ រៀនអំពីចំណុចខ្លាំង ចំណុចខ្សោយ ចំណាប់អារម្មណ៍ និងផលសម្រេចរបស់កូនៗគាត់នៅក្រៅសាលារៀន។ សួរពីវិធីសាស្ត្របង្រៀនអ្វីខ្លះដែលមានប្រសិទ្ធភាពបំផុតសម្រាប់កូនរបស់ពួកគាត់។ ទាក់ទងគាត់ជាញឹកញាប់ និងផ្ញើកំណត់ត្រាលើកទឹកចិត្តទៅផ្ទះរបស់គាត់។
3. សូមឆ្លៀតពេលនិយាយជាមួយសិស្សម្នាក់ៗ។ ត្រូវមានការគោរព និងបង្ហាញការចាប់អារម្មណ៍ចំពោះជោគជ័យរបស់គេនៅក្នុងសាលារៀនដោយសួរពួកគេពីរបៀបដែលគេរៀនបានល្អបំផុត។
4. សម្រេចចិត្តរួមគ្នាអំពីសញ្ញាឬលេខកូដមួយដែលគ្រូអាចប្រើដើម្បីរំឭកកុមារឱ្យយកចិត្តទុកដាក់លើកិច្ចការ។ ឧទាហរណ៍ ការប្រើក្រសែភ្នែកទាក់ទងគ្នានិងប៉ះស្លឹកត្រចៀករបស់គ្រូ ឬលើកវត្ថុជាក់លាក់អ្វីមួយឡើង ឬគ្រូអាចលើកម្រាមដៃមួយឬពីរឡើងលើ។
5. បង្កើតវិន័យក្នុងថ្នាក់រៀនឱ្យបានច្បាស់លាស់ និងខ្លីៗ។ ពិភាក្សាពីវិន័យនោះដោយផ្ទាល់មាត់ហើយបិទវានៅកន្លែងណាមួយដើម្បីងាយស្រួលរំឭកវាឡើងវិញ។ ពន្យល់អំពីផលវិបាកនៃការប្រព្រឹត្តិខុសដោយប្រើពាក្យពេចន៍ដែលអាចយល់បាន និងពង្រឹងវិន័យនោះឱ្យបានខ្ជាប់ខ្ជួន។ ចូរជៀសវាងការ តស៊ូរកអំណាច។
6. ប្រើប្រព័ន្ធដាក់ពិន្ទុ និមិត្តរូបផ្កាយឬវិធីសាស្ត្រផ្សេងៗទៀត ដើម្បីផ្តល់រង្វាន់អាកប្បកិរិយាដែលសមស្រប។
7. កត់សម្គាល់ និងផ្តល់ព័ត៌មានត្រឡប់ស្តីពីការរីកចម្រើនណាមួយចំពោះផ្នែកអាកប្បកិរិយា និងការសិក្សា។ ជៀសវាងការរិះគន់កុមារនៅចំពោះមុខអ្នកដទៃ។
8. ផ្តល់ការណែនាំក្នុងលក្ខណៈសាមញ្ញ និងជាក់ស្តែង។ រៀបចំសេចក្តីណែនាំ ភារកិច្ច និងកិច្ចការផ្សេងៗឱ្យមានលក្ខណៈសាមញ្ញ។ ឱ្យកុមារបញ្ចប់ជំហានមួយសិន មុននឹងណែនាំជំហានទី២។
9. បែងចែកមេរៀនទៅជាផ្នែកខ្លីៗ និងប្រើប្រាស់សម្ភារឧបទេសបង្រៀនដូចជាខ្សែភាពយន្ត ម៉ាស៊ីនថត ម៉ាស៊ីនចាក់សំឡេង កម្មវិធីកុំព្យូទ័រ និងការងារជាក្រុមតូចៗដើម្បីពង្រឹងការសិក្សារបស់កុមារ។
10. ផ្តល់ឱកាសឱ្យសិស្សពិបាកផ្ទង់អារម្មណ៍ និងសកម្មជ្រុល បង្ហាញបំណិន ទេពកោសល្យ និងសមត្ថភាពនៃភាពជាអ្នកដឹកនាំរបស់គេ។

11.រៀបចំសម្រាប់ការផ្លាស់ប្តូរតាមរយៈការផ្តល់សញ្ញានៅពេលការផ្លាស់ប្តូរមួយកើតឡើង។ ការប្រើតន្ត្រីអាចមានប្រយោជន៍។ សាកល្បងលេងភ្លេងបុរាណ ឬថតសម្លេងធម្មជាតិក្នុងពេលធ្វើការ។

12. ឱ្យសិស្សទាំងអស់ឈរ និងពត់ខ្លួន រត់មួយកន្លែង ឬធ្វើការហាត់ប្រាណ ឬចលនាសកម្មភាពនៅពេលចាំបាច់។

13. ក្រដាសដែលមានពណ៌លេខកូដសម្រាប់មុខវិជ្ជានីមួយៗ។ ប្រសិនបើមាន សូមប្រើក្រដាសពណ៌ដែលមានពណ៌ស ដាំដែង ឬខៀវខ្ចីសម្រាប់កិច្ចការដែលទាក់ទងនឹងការសរសេរ។

14. រៀបចំកាលវិភាគ គ្រោងបញ្ជី និងសៀវភៅកិច្ចការផ្ទះមួយដើម្បីជួយសិស្សឱ្យមានរបៀបរៀបរយក៏ដូចជាបង្កើនទំនាក់ទំនងផ្ទះ សាលារៀន។ បិទតារាងកាលវិភាគមួយច្បាប់នៅលើតុរបស់សិស្ស។

15. កែតម្រូវកិច្ចការផ្ទះដែលចាំបាច់ដើម្បីឱ្យស្របជាមួយសិស្សដែលទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុល។ ជៀសវាងកិច្ចការណាដែលធ្វើឱ្យរវល់ច្រើន និងដែលគេលែងត្រូវការ។

16. ណែនាំកុមារពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុលដែលមានវ័យជំទង់ផ្តិតស្នាមបាតដៃរបស់គេនៅផ្នែកខាងមុខ និងខាងក្រោយសឺមីសម្រាប់យកតាមខ្លួនគេទោះគេទៅទីណាក៏ដោយ។ ឱ្យពួកគេដាក់ដៃរបស់គេនៅលើសឺមីដែលមានស្នាមដៃដើម្បីជួយពួកគេឱ្យចងចាំក្នុងការដាក់ដៃរបស់គេដោយខ្លួនគេឯង។

17. ផ្អាកមួយភ្លែតមុនពេលសួរសំណួរ ឬសួរសំណួរមួយទៅកុមារដែលមិនយកចិត្តទុកដាក់ដើម្បីឱ្យពួកគេផ្តោតអារម្មណ៍។ ប្រើឈ្មោះ ឬការចាប់អារម្មណ៍របស់សិស្សក្នុងលក្ខណៈអព្យាក្រឹត្យក្នុងពេលពិភាក្សាគ្នា។

18. ដើរនៅជុំវិញបន្ទប់ ហើយទះស្មារបស់កុមារតិចៗ ឬបិទសម្គាល់ទំព័រសៀវភៅរបស់កុមារដែលគេកំពុងអានដើម្បីជួយគេឱ្យផ្តោតលើកិច្ចការដែលកំពុងធ្វើ។

19. ឱ្យកុមារពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុលអង្គុយក្បែរគ្រូ និងនៅកន្លែងដែលមានការរំខាន និងការជម្រុញតិចតួច ពោលគឺនៅក្បែរទ្វារ បង្អួច និងសិស្សដែលសកម្ម។ ឬឱ្យកុមារអង្គុយនៅជិតកន្លែងដាក់ប្រដាប់ខួងខ្មៅដៃ ហើយឱ្យកុមារនោះក្រោកឡើងទៅខួងខ្មៅដៃឱ្យបានញឹកញាប់តាមដែលគេត្រូវការ។

20. សំឡឹងរកមើលសញ្ញានៃការកើនឡើងនូវភាពតានតឹងចំពោះកុមារដែលសកម្មជ្រុល។ គ្រូប្រហែលជាចង់កាត់បន្ថយបន្ទុកការងារ ឬផ្តល់ឱកាសឱ្យកុមារបញ្ចេញថាមពលមួយចំនួន។ ឧទាហរណ៍ឱ្យសិស្សយក«សំបុត្រសំខាន់»មួយដែលដាក់ក្នុងស្រោមសំបុត្របិទជិតទៅជូនគ្រូបង្រៀនម្នាក់ទៀត ឬលេខារបស់សាលារៀនដែលយល់អំពីតម្រូវការរបស់កុមារក្នុងការផ្លាស់ទី(ធ្វើចលនា)។

21. ផ្តល់ឱកាសធ្វើសកម្មភាពរាងកាយ។ ជ្រើសរើសកុមារដែលសកម្មជ្រុលឱ្យចែកក្រដាស ឬធ្វើការងារផ្សេងៗទៀតនៅក្នុងថ្នាក់រៀនដែលអាចជួយគេឱ្យបញ្ចេញថាមពលដែលមិនបានប្រើប្រាស់ និងរួមចំណែកដល់អារម្មណ៍នៃការឱ្យតម្លៃខ្លួនរបស់គេ។

22. លើកទឹកចិត្តកុមារឱ្យប្រើបច្ចេកទេសស្វ័យត្រួតពិនិត្យដើម្បីជួយក្នុងការផ្តោតអារម្មណ៍។ ឧទាហរណ៍អនុញ្ញាតឱ្យគេត្រដុសក្រណាត់ បិទស្កុតមុខពីរ ឬវត្ថុផ្សេងៗដែលបិទជាប់នៅក្រោមតុរបស់គេ ឬ ឱ្យបាល់ទន់ៗឱ្យសិស្សនោះច្របាច់។
23. អនុញ្ញាតឱ្យសិស្សដែលចាញ់ពន្លឺ ពាក់របាំងការពារមុខ ឬមួក ក្នុងថ្នាក់រៀន។ បិទភ្លើងដែលនៅជិតបង្អួច ឬបន្ថយពន្លឺភ្លើងក្នុងបន្ទប់រៀន។
24. ត្រូវមានភាពបត់បែន និងអនុញ្ញាតឱ្យកុមារដែលពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុលក្រោកឈរឬអង្គុយចោងហោង លើកៅអីរបស់គេប្រសិនបើវាជួយសិស្សឱ្យបំពេញកិច្ចការបាន។ ឬឱ្យគេអង្គុយនៅលើកម្រាលឥដ្ឋជិតគ្រូឬនៅលើតុមូលធំមួយប្រសិនបើអាចជួយឱ្យកុមារនោះធ្វើការងារបាន។ ខ្នើយបញ្ចូលខ្យល់ ឬកង់សម្រាប់ហាត់ប្រាណនៅមួយកន្លែងស្ងាត់ៗដែលនៅជាប់នឹងតុក៏អាចប្រើបានដែរ។
25. រៀបតុពីរទល់មុខគ្នា ឬនៅចំហៀងគ្នាសម្រាប់សិស្សពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុលម្នាក់។ កុមារអាចផ្លាស់ទីទៅមុខទៅក្រោយបានដោយសេរី ឬសណ្តូកខ្លួនចន្លោះតុក៏បាន ឱ្យតែពួកគេនៅតែធ្វើកិច្ចការរបស់ខ្លួន និងស្ថិតក្នុងកន្លែងដែលគេបានកំណត់។
26. ផ្តល់បន្ទប់បួនជ្រុងមួយ ឬកន្លែងស្ងប់ស្ងាត់សម្រាប់សិស្សពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុល ប្រើប្រាស់នៅពេលមានសកម្មភាពច្រើនពេកនៅក្នុងថ្នាក់រៀន។
27. បើសិនជាចាំបាច់ត្រូវរៀបចំទីកន្លែងដាក់លាក់ដោយបិទស្កុតសម្គាល់ថានោះជាកន្លែងរបស់គេតែម្នាក់ឯងដែលគ្មាននរណាផ្សេងទៀតអាចចូលបាន។ នៅកន្លែងនោះសិស្សអាចក្រោកឈរ អង្គុយនៅលើកម្រាលឥដ្ឋ ឬដើរចុះឡើងដើម្បីបំពេញកិច្ចការរបស់គេ។ ទោះជាយ៉ាងណាក៏ដោយ កុមារនោះត្រូវរក្សាភាពស្ងៀមស្ងាត់ហើយនៅតែក្នុងកន្លែងនោះប៉ុណ្ណោះ រហូតទាល់តែមានការអនុញ្ញាតឱ្យចាកចេញ។
28. លើកទឹកចិត្តឱ្យមានការស្វែងយល់ពីអារម្មណ៍របស់អ្នកដទៃ ពេលកុមារធ្វើការទាក់ទងជាមួយមិត្តភក្តិ។ ប្រសិនបើគេខ្វះការយល់ដឹងផ្នែកសង្គម វាអាចមានប្រយោជន៍ក្នុងការនិយាយអ្វីមួយដូចជា «ម៉ារីមើលទៅមិនសប្បាយចិត្តនៅពេលដែលប្អូននិយាយរកនាង»។ តើមានវិធីអ្វីដែលគួរសមជាងនេះក្នុងការសុំអ្វីមួយពីគេ?» ប្រសិនបើសិស្សរំខានមិត្តភក្តិញឹកញាប់ សូមរំឭកកុមារឱ្យស្តាប់សិនមុននឹងនិយាយ។
29. ឱ្យសិស្សដែលមានអាយុច្រើន ឬឪពុកម្តាយស្ម័គ្រចិត្តធ្វើជាអ្នកបង្រៀនដល់សិស្សទាំងនេះ។
30. បង្កើតកិច្ចសហការជាមួយគ្រូអប់រំពិសេស អ្នកចិត្តវិទ្យារបស់សាលារៀន អ្នកប្រឹក្សាយោបល់របស់សាលារៀន អ្នកគ្រប់គ្រងរដ្ឋបាល និង អ្នកឯកទេសដទៃទៀតនៅក្នុងសាលារៀន បញ្ជាក់ពីទីកន្លែងល្អបំផុតសម្រាប់កុមារពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុល។

| ឧទាហរណ៍សកម្មភាពសម្រាប់កុមារពិបាកផ្ទង់អារម្មណ៍ និងសកម្មជ្រុល | |
|---|---|
| **សញ្ញា និងលក្ខណៈសម្គាល់** | **យុទ្ធសាស្ត្រ បច្ចេកទេស សកម្មភាព និងសម្ភារ** |
| ពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុល៖ សញ្ញា<br>• ឆាប់ធុញទ្រាន់ និង ងាយទទួលរងការរំខាន<br>• ស្តែងឱ្យឃើញពីការចងចាំខ្សោយ<br><br><br><br><br><br><br><br><br><br><br><br>• មានការលំបាកក្នុងការធ្វើតាម ទោះបី សេចក្តីណែនាំសាមញ្ញ ក៏ដោយ | **សកម្មភាព៖**<br>**សកម្មភាពទី 1៖**<br>**បណ្ណអក្សរ រូបភាព**<br>ជាសញ្ញាដ៏សំខាន់មួយរបស់កុមារពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុល កុមារមានសមត្ថភាពពិសេសក្នុងការចងចាំបានល្អ តែបានតិច។ ការចងចាំក្នុងរយៈពេលខ្លី គឺជាបញ្ហាទូទៅសម្រាប់អ្នកទាំងឡាយណាដែលទទួលរងផលប៉ះពាល់ពីការពិបាកផ្ចង់អារម្មណ៍ និងសកម្មជ្រុល។<br>កុមារមើលឃើញថាចំណុចផ្សេងៗដែលមិនជម្រុញឱ្យគេរំជួលចិត្តខ្លាំងគឺមានការលំបាកក្នុងការចងចាំជាងអ្វីដែលធ្វើឱ្យគេរំជួលចិត្ត។ ឧទាហរណ៍ដោយសារកុមារដែលមើលឃើញច្បាស់ ហើយមានបញ្ហាក្នុងការចងចាំឈ្មោះ ប៉ុន្តែប្រសិនបើគេឃើញមុខរបស់អ្នកណាម្នាក់ គេនឹងចងចាំរហូត ពោលគឺ ស្អិតដូចការអញ្ចឹង។<br><br>កុមារមិនបំភ្លេចឈ្មោះដោយចេតនាទេ។ ទោះបីជាឈ្មោះនោះមិនទាក់ទងនឹងមុខដោយផ្ទាល់ក៏ដោយ វាពិបាកក្នុងការឱ្យគត់សម្គាល់ឈ្មោះណាស់ ដែលរឹតតែធ្វើឱ្យពួកគេពិបាកក្នុងការចងចាំ។ ទោះជាយ៉ាងនេះក្តី មានវិធីជាច្រើនដើម្បីជំនះលើបញ្ហានេះ។<br><br>មេរៀនដែលជាគំនិតល្អឥតខ្ចោះមួយសម្រាប់អភិវឌ្ឍបំណិនក្នុងការចងចាំគឺ បណ្ណអក្សរ បណ្ណរូបភាព ជាពិសេសសម្រាប់ការរៀនពីគោលគំនិតសំខាន់ៗ ដូចជាតារាងមេលេខគុណជាដើម។<br>ឧទាហរណ៍ នៅពេលដែលត្រឡប់ពីសាលារៀនមកផ្ទះវិញ ម្តាយរបស់ខ្ញុំប្រើបបណ្ណអក្សរ បណ្ណរូបភាព ដើម្បីបង្រៀនខ្ញុំពីតារាងមេលេខគុណ ហើយរហូតមកដល់ពេលនេះ ខ្ញុំអាចប្រាប់បានយ៉ាង |

| | |
|---|---|
| | លឿនថា «៩ × ៦ គឺស្មើនឹង ៥៤» ដោយមិនចាំបាច់គិត។ វាជួយពង្រឹងជាប់ជាប្រចាំនូវគន្លឹះផ្នែកចក្ខុវិញ្ញាណក្នុងការគណនា បើមិនដូច្នោះទេ ការដោះស្រាយចំណោទគណិតវិទ្យាក្លាយទៅជាមេរៀនដែលគួរឱ្យធុញទ្រាន់។<br>វិធីសាស្ត្រនេះមិនត្រឹមតែអនុវត្តចំពោះចំណោទគណិតវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែគេក៏អាចប្រើវាដើម្បីទន្ទេញកាលបរិច្ឆេទប្រវត្តិសាស្ត្រ តួលេខ ប្រវត្តិសាស្ត្រ វាក្យសព្ទ និងការប្រកបដែរ។ |
| • ធាប់ធុញ និងងាយទទួលរងការរំខាន<br>• ជាទូទៅពឹសខ្លាំង | <u>**សកម្មភាពទី2**</u><br>**សកម្មភាពសំដែងតួះ**<br>កុមារមួយចំនួនគោះជើងរបស់គេបន្តើរៗ ម្រាមដៃនៅមិនស្ងៀម ទាញសំលៀកបំពាក់ចុះឡើង សម្លឹងសម្លក់រថយន្តដែលកំពុងបើកបរនៅខាងក្រៅ និងស្វែងរកលេសណាមួយដើម្បីចេញពីកន្លែងអង្គុយ។ ថាមពលទាំងអស់ដែលមិនបានបញ្ចេញចាំបាច់ត្រូវបង្ហាញឱ្យឃើញដោយប្រការណាមួយ ហើយដរាបណាកុមារអង្គុយនៅកន្លែងរបស់គេដែលអង្គុយរបស់ពួកគេ ត្រូវជំនះដើម្បីឱ្យទទួលបានផង។<br>គ្រូបង្រៀនអាចផ្លាស់ប្តូរចំណុចនេះបានដោយដាក់កិច្ចការដែលតម្រូវឱ្យមាន អន្តរកម្មជាមួយអ្នកដទៃ និងការផ្លាស់ប្តូរកន្លែងនៅជុំវិញបន្ទប់រៀនឱ្យកុមារធ្វើ។ ការយកចិត្តទុកដាក់ភ្លាមៗរបស់កុមារគឺនៅលើកិច្ចការដែលមានក្នុងដៃ ពីព្រោះកុមារកំពុងពេញចិត្តចំពោះកម្លាំងជម្រុញដែលពួកគេត្រូវការ។ សកម្មភាពសំដែងតួគឺជាមធ្យោបាយដ៏ប្រសើរមួយដើម្បីឱ្យសិស្ស ក្រោកឈរឡើង និងផ្លាស់ទីជុំវិញនៅក្នុងលក្ខណៈស្រដៀងគ្នាមួយខណៈដែលគេនៅតែកំពុងរៀនដដែល។ នៅក្នុងថ្នាក់ភាសា គេអាច ប្រើការសំដែងតួបែបនេះដោយឱ្យសិស្សធ្វើបទបង្ហាញពីសាច់រឿងដែលកំពុងរៀន នៅក្នុងថ្នាក់គណិតវិទ្យា ល្បែងធ្វើត្រាប់តាមដែលតម្រូវឱ្យសិស្សសំដែងតួជាអ្នកជំនួញទិញ និងលក់ទំនិញផ្សេងៗអាចបង្រៀនពីគោលគំនិតដែលស្មុគស្មាញបាន។<br>ប្រសិនបើមេរៀនមួយហាក់ដូចជាមានភាពធុញទ្រាន់និងសោះ |

| | |
|---|---|
| | កក្រោះ សម្រាប់លោកលោកស្រីក្នុងការបង្រៀន នោះវាមិនមានភាពទាក់ទាញសម្រាប់សិស្សរបស់គាត់ទេ ជាពិសេសមិនមានភាពទាក់ទាញសម្រាប់សិស្សពិបាកផ្ទង់អារម្មណ៍និងសកម្មជ្រុលរបស់គាត់ ហើយគ្រូគួរតែបន្ថែមចលនា( សកម្មភាព ) និងអន្តរកម្មមួយចំនួន។ |
| • ខ្វះភាពអត់ធ្មត់<br>• មានភាពអត់ឱនតិចតួចចំពោះមនុស្ស ស្ថានភាព និងអ្វីៗ ដែលនៅជុំវិញ | **សកម្មភាពទី ៣**<br>**ការជជែកវែកញែកក្នុងថ្នាក់រៀន៖**<br>សញ្ញារបស់កុមារពិបាកផ្ចង់អារម្មណ៍និងសកម្មជ្រុលមួយទៀតគឺជាទំនោរទៅរកការឆ្លើយសំណួរដោយពុំបានគិតមុនពេលគ្រូហៅឱ្យឆ្លើយ ឬមុនពេលគ្រូសួរសំណួរទៅទៀត ។<br>ខ្ញុំបាននិយាយមុននេះថា កិច្ចការដែលមានលក្ខណៈច្នៃប្រឌិតគឺជាឱកាសល្អឥតខ្ចោះសម្រាប់សិស្សពិបាកផ្ចង់អារម្មណ៍និងសកម្មជ្រុលបង្ហាញស្នាដៃ និងស្វែងរកការសរសើរដែលពួកគេបាត់បង់នៅក្នុងសកម្មភាពសិក្សាដែលមានលក្ខណៈតឹងរឹងខ្លាំង។ ទោះយ៉ាងណាក៏ដោយ គេត្រូវណែនាំពីរចនាសម្ព័ន្ធដើម្បីជួយសិស្ស ពិបាកផ្ចង់អារម្មណ៍និងសកម្មជ្រុល ឱ្យរៀន មិនត្រឹមតែត្រូវចាំដល់វេនរបស់ពួកគេនោះទេ ប៉ុន្តែត្រូវចំណាយពេលវេលារបស់ខ្លួន ចំពោះការសម្រេចចិត្ត និងចម្លើយរបស់ខ្លួនដែរ។<br><br>វិធីល្អឥតខ្ចោះក្នុងការ នាំយកសកម្មភាពបម្រុងទុកមុន និងកែលម្អចំណេះដឹង អំពីមុខវិជ្ជាជាក់លាក់ របស់សិស្សពិបាកផ្ចង់អារម្មណ៍និងសកម្មជ្រុល គឺការរៀបចំការពិភាក្សាវែកញែកនៅក្នុងថ្នាក់រៀន។ នៅក្នុងកិច្ចពិភាក្សាវែកញែកក្នុងថ្នាក់រៀន សិស្សទទួលបានឱកាសពិភាក្សាលើមុខវិជ្ជាផ្សេងៗនៅក្នុងថ្នាក់រៀន បន្ថែមពីគោលគំនិតរបស់មេរៀន ព្រមទាំង បណ្តុះនូវភាពអត់ធ្មត់ និងបំណិនក្នុងការគិតស៊ីជម្រៅ។ ក្នុងនាមជាគ្រូបង្រៀនម្នាក់ អ្នកត្រូវចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាវែកញែក ដើម្បីធ្វើអន្តរាគមន៍ មិនថាសិស្សនិយាយអ្វី ឬនិយាយរបៀបណា និងនិយាយពេលណានោះទេ។ |

# មេរៀនទី៨

# ផែនការអប់រំសម្រាប់កុមារម្នាក់ៗ

## ទិន្នន័យ៖

វត្ថុបំណងនៃផែនការអប់រំសម្រាប់កុមារម្នាក់ៗ គឺជាការពិពណ៌នាពីកម្រង វិធីសាស្ត្រក្នុងការដោះស្រាយតម្រូវការអប់រំជាក់លាក់របស់កុមារម្នាក់ៗ ។

## ៨.១. សេចក្តីផ្តើម ៖

ផែនការអប់រំ សម្រាប់កុមារម្នាក់ៗគឺជាផែនការ ឬកម្មវិធីជាលាយលក្ខណ៍អក្សរ ដែលក្រុមការងារអប់រំ នៅតាមសាលារៀនបានបង្កើតឡើង ដោយមានការផ្តល់ជាតុចូលពីឪពុកម្តាយផងដែរ ហើយផែនការនេះបញ្ជាក់នូវគោលបំណងផ្នែកសិក្សារៀនសូត្ររបស់សិស្ស និងវិធីសាស្ត្រដើម្បីសម្រេចគោលបំណង ទាំងនេះ។ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ គឺជាមធ្យោបាយសម្រាប់ដោះស្រាយបញ្ហាសិក្សារៀនសូត្រជាក់លាក់របស់កុមារម្នាក់ៗ និង ដាក់បញ្ចូលនូវគោលដៅអប់រំជាក់លាក់នានា។ ផែនការនេះគឺជាឯកសារពាក់ព័ន្ធនឹងកាតព្វកិច្ចផ្លូវច្បាប់។សាលារៀនត្រូវផ្តល់នូវអ្វីៗគ្រប់យ៉ាងដូចដែលខ្លួនបានសន្យានៅក្នុងផែនការនេះ។

ផែនការអប់រំសម្រាប់កុមារម្នាក់ៗ គឺជាមធ្យោបាយសម្រាប់កិច្ចខិតខំប្រឹងប្រែងរួមគ្នាដែលបានចងក្រងឡើងដោយក្រុមការងារ ទាំងអស់ដែលក្នុងនោះរួមមានគ្រូបង្រៀនផ្នែកអប់រំពិសេស អ្នកតំណាងមកពីក្រសួងអប់រំយុវជននិងកីឡា គ្រូបង្រៀនអប់រំចំណេះទូទៅ និងក្រុមអ្នកចិត្តវិទ្យា និង អ្នកជំនាញនានាដែលផ្តល់សេវាទាំងនេះ មានដូចជាអ្នកព្យាបាលខាងការបញ្ចេញសំឡេងជាដើម។

## ៨.២. ធាតុផ្សំរបស់ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖

ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការជាក់លាក់របស់កុមារ ម្នាក់ៗ។ ចំណុចនេះមានន័យថា ផែនការនីមួយៗមានលក្ខណៈខុសៗគ្នា។ ប៉ុន្តែបើតាមគោលការណ៍ គ្រប់ផែនការអប់រំសម្រាប់កុមារម្នាក់ៗទាំងអស់ត្រូវតែមានជាតុផ្សំដូចខាងក្រោម៖

- **កម្រិតនៃលទ្ធផលសិក្សារបស់កុមារបច្ចុប្បន្ន** ( PLOP)៖ នេះជាការពណ៌នាលម្អិតពីសមត្ថភាពជំនាញ ចំណុចខ្លាំង និងចំណុចខ្សោយរបស់កូនអ្នក។ វាគឺជាផ្នែកមួយនៃផែនការអប់រំសម្រាប់កុមារម្នាក់ៗ ដែលពន្យល់ពីបញ្ហានៃការរៀនសូត្រ និងផលប៉ះពាល់របស់កុមារទៅលើសមត្ថ

ភាពរបស់ពួកគេក្នុងការសិក្សានៅក្នុងកម្មវិធីអប់រំចំណេះទូទៅ។ PLOP រួមបញ្ចូលនូវព័ត៌មានលម្អិតស្ដីពីរបៀបដែលកុមារម្នាក់ៗដោះស្រាយលើមុខវិជ្ជាសិក្សា និងសកម្មភាពប្រចាំថ្ងៃ ឬសកម្មភាពតាមតួនាទីផ្សេងៗ ដូចជាការចូលរួមនៅក្នុងសង្គមជាដើម។

PLOP ត្រូវមានមូលដ្ឋានពីការសង្កេតរបស់គ្រូបង្រៀន និងទិន្នន័យជាក់ស្ដែង ដូចជាលទ្ធផលនៃការធ្វើតេស្តជាដើម។ វាមានសារៈសំខាន់ណាស់ដោយសារ PLOP មិនមែនជាឯកសារថេតចម្លងសាមញ្ញសម្រាប់ការប្រើប្រាស់ដដែលៗ ពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងផែនការអប់រំសម្រាប់កុមារ ម្នាក់ៗទេ។ ពីមួយឆ្នាំទៅមួយឆ្នាំសិស្សកាន់តែមានភាពរីកចម្រើន និងស្ទាត់ជំនាញលើបំណិន ផ្សេងៗ ការងារកាន់តែមានភាពប្រឈមច្រើនឡើង ដូច្នេះសមត្ថភាព និងតម្រូវការរបស់ពួកគេក៏មានការផ្លាស់ប្ដូរដែរ។

- **លទ្ធផលនៃការវាយតម្លៃ និងការធ្វើតេស្តកុមារៈ** លទ្ធផលនេះ គួររាប់បញ្ចូលនូវរាល់ការវាយតម្លៃពីគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់។

- **ការអប់រំពិសេស និងសេវាពាក់ព័ន្ធនានាដែលត្រូវផ្ដល់ឱ្យៈ** ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ពន្យល់ច្បាស់លាស់ពីប្រភេទនៃការគាំទ្រ និងសេវាកម្មនានាដែលកុមារនឹងទទួលបាន។ ឧទាហរណ៍ៈ ប្រសិនបើកុមារត្រូវទទួលបានការព្យាបាលដោយចលនា ផែនការនេះត្រូវបញ្ជាក់ថា តើកុមាររូបនេះនឹងទទួលបានការព្យាបាលរយៈពេលប៉ុន្មាននាទីក្នុងមួយសប្ដាហ៍។

- **ការសម្របសម្រួល និងការកែលម្អៈ** ចំណុចទាំងនេះជួយកុមារក្នុងការរៀនសូត្រតាមកម្មវិធីសិក្សា អប់រំចំណេះទូទៅ។ ការសម្របសម្រួល ជាការផ្លាស់ប្ដូរពីរបៀបដែលកុមារបង្ហាញនូវអ្វីដែលពួកគេបានសិក្សា។ វាអាចជួយកុមារឱ្យធ្វើកិច្ចការផ្សេងៗពាក់ព័ន្ធនឹងការរៀនសូត្ររបស់គេ។ ឧទាហរណ៍ៈ កុមារត្រូវបានផ្ដល់ម៉ោងបន្ថែមសម្រាប់ធ្វើតេស្ត។ ការកែលម្អ គឺជាការផ្លាស់ប្ដូរនូវវិធីសាស្ត្របង្រៀន ឬអ្វីដែលគេរំពឹងទុកពីសិស្ស។ ផែនការអប់រំសម្រាប់កុមារម្នាក់ៗមួយចំនួនត្រូវបានគេហៅថា «លក្ខណៈវិនិច្ឆ័យសម្រាប់ការឡើងថ្នាក់ដែលបានកែលម្អ»។ ការកំណត់នេះជាភាគរយនៃការរំពឹងទុកទៅលើកម្រិតថ្នាក់សិក្សាដែលសិស្សត្រូវបំពេញដើម្បីឡើងថ្នាក់។

- **ជំនួយ និងសេវាកម្មបន្ថែមៈ** ចំណុចទាំងនេះគឺជាការគាំទ្រដើម្បីជួយសិស្សឱ្យបានរៀននៅក្នុងសាលារៀនអប់រំចំណេះទូទៅ។ ជំនួយនិងសេវាកម្មបន្ថែមអាចរាប់បញ្ចូលនូវជំនួយក្នុងការបង្រៀនមួយទល់មួយ កំណត់ត្រានៅក្នុងថ្នាក់រៀនដែលគេបានបញ្ជាក់ ឧបករណ៍ និងបច្ចេកវិទ្យាជំនួយ ដូចជាកម្មវិធីកុំព្យូទ័រជាដើម។

- **គោលដៅសិក្សាប្រចាំឆ្នាំ៖** ចំណុចទាំងនេះត្រូវមានលក្ខណៈប្រាកដនិយម អាចសម្រេចបាន និងអាចវាស់វែងបាន។ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ រៀបរាប់អំពីបំណិនផ្នែកសិក្សា និងសកម្មភាពដែលក្រុមការងារអប់រំ គិតថា សិស្សអាចសម្រេចបាននៅដំណាច់ឆ្នាំសិក្សា។ គោលដៅសិក្សាប្រចាំឆ្នាំជួយកុមារឱ្យចូលរួមនៅសាលារៀនអប់រំចំណេះទូទៅ។ ប្រសិនបើកុមារពិការច្រើនប្រភេទឬធ្ងន់ធ្ងរ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ក៏ត្រូវមានគោលដៅសម្រាប់រយៈពេលខ្លីដែរ។ គោលដៅទាំងនេះមានឈ្មោះថាវត្ថុបំណង ឬខ្នាតគំរូ។

- ការពិពណ៌នាពីរបៀបវាស់វែងនិងរាយការណ៍ពីការរីកចម្រើនរបស់កុមារដល់អាណាព្យាបាល៖ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ត្រូវពន្យល់ពីរបៀបដែលសាលារៀនតាមដានការរីកចម្រើនរបស់សិស្សឆ្ពោះទៅរកការសម្រេចគោលដៅ ហើយវាក៏ត្រូវពិពណ៌នាពីរបៀបដែលសាលារៀនផ្សព្វផ្សាយ លទ្ធផលទាំងនោះជូនដល់ឪពុកម្តាយឬអាណាព្យាបាល។

  ឧទាហរណ៍៖ គោលដៅមួយអាចនឹងកំណត់ថា កុមារអាចអានអក្សរបាននៅពេលគេរៀនថ្នាក់ទី៣។ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ នឹងកំណត់ជាក់លាក់ពីរបៀបដែលគេនឹងតាមដានពេលគឺ ការវាយតម្លៃក្រៅផ្លូវការ និងជាផ្លូវការ ។ ជាញឹកញាប់លទ្ធផលទាំងនោះត្រូវបានគេរាយការណ៍ ជូនឪពុកម្តាយ ឬអាណាព្យាបាល ។ ប្រសិនបើរបាយការណ៍ឆមាសទី១បង្ហាញថា ការរីកចម្រើនរបស់កុមារមានភាពយឺតយ៉ាវ ឪពុកម្តាយ ឬអាណាព្យាបាល និងក្រុមការងារអប់រំ អាចពិភាក្សាស្វែងរកអន្តរាគមន៍ថ្មីបន្ថែមទៀត។

- **បរិយាកាសដែលមានឧបសគ្គតិចតួច៖** ជាការពន្យល់ថាតើកុមារត្រូវចូលរួមកម្រិតណានៅក្នុងសាលារៀនអប់រំចំណេះទូទៅ និងកម្មវិធីសិក្សាបន្ថែម។ គេតម្រូវឱ្យមានការចូលរួម ក្នុងកម្រិតពេញលេញបំផុតតាមដែលអាចធ្វើបានដែលគេហៅថាជាលក្ខខណ្ឌបរិយាកាសដែលមានឧបសគ្គតិចតួចបំផុត។

- **កាលបរិច្ឆេទបានកំណត់នៅក្នុងផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖** ត្រូវបញ្ជាក់ពីពេលវេលាដែលសេវាកម្មនានាត្រូវចាប់ផ្តើម ទីកន្លែង និងរយៈពេលដែលត្រូវផ្តល់សេវាកម្ម ទាំងនេះ។

- **ផែនការដែលមានរយៈពេលវែង៖** ផែនការនេះនឹងចាប់ផ្តើមនៅពេលកុមារឈានចូលដល់អាយុ១៦ឆ្នាំ។ ផែនការនេះរួមបញ្ចូលនូវសេវាកម្មនិងការគាំទ្រនានា ដើម្បីជួយសិស្សឱ្យបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យ និងសម្រេចគោលដៅសិក្សានៅឧត្តមសិក្សា។ ដូច្នេះដោយយោងទៅលើអាយុ និងស្ថានភាពរបស់កុមារ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ អាចនឹងរួមបញ្ចូលនូវផែនការសម្រាប់រយៈពេលវែងផងដែរ។

- **ការពង្រីកសេវាកម្មនៅក្នុងឆ្នាំសិក្សា៖** សិស្សមួយចំនួនទទួលបានការអប់រំបន្ថែម ដូចជានៅវិស្សមកាលតូច ឬម្តងម្កាលក្នុងរយៈពេលឈប់សម្រាករយៈពេលវែង ដូចជានៅវិស្សមកាលធំ។ ដូច្នេះដោយយោងទៅលើអាយុនិងស្ថានភាពរបស់កុមារ ផែនការអប់រំសម្រាប់កុមារម្នាក់ៗរបស់ពួកគេក៏អាចនឹងរួមបញ្ចូលនូវការពង្រីកសេវាកម្មក្នុងឆ្នាំសិក្សាដែរ។

ផែនការនេះមានបំណងពន្យល់ឱ្យបានលម្អិតពីរបៀបដែលគណៈគ្រប់គ្រងសាលារៀនត្រូវដោះស្រាយចំពោះការលំបាក ឬតម្រូវការនានាដែលគេបានរកឃើញនៅក្នុងរបាយការណ៍វាយតម្លៃ។ ផែនការនេះរាប់បញ្ចូលទាំងវិធីសាស្ត្រនិងកម្មវិធីដែលត្រូវផ្តល់ឱ្យកុមារ អ្នកផ្តល់សេវា និងទីកន្លែងដើម្បីរៀបចំផ្តល់ការអប់រំនៅក្នុងបរិយាសដែលមានឧបសគ្គតិចតួចបំផុត។

ជារឿយៗ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ត្រូវបានចងក្រងឡើងនៅមុនកិច្ចប្រជុំ ហើយត្រូវផ្តល់ជូនឪពុកម្តាយក្នុងរយៈពេលតិចបំផុតក៏មួយសប្តាហ៍មុនពេលប្រជុំ ដើម្បីឱ្យឪពុកម្តាយអាចស្នើសុំការផ្លាស់ប្តូរនានាណាមួយមុនពេលប្រជុំចាប់ផ្តើម។ នៅពេលប្រជុំ គេលើកទឹកចិត្តឱ្យក្រុមការងារអប់រំធ្វើការបញ្ជាក់បន្ថែម ឬដកចេញផ្នែកណាមួយនៃផែនការនេះ ដែលពួកគេយល់ឃើញថាចាំបាច់។

ផែនការអប់រំសម្រាប់កុមារម្នាក់ៗ នឹងផ្តោតទៅលើតែផ្នែកណាមួយដែលទទួលរងផលប៉ះពាល់ពីពិការភាពប៉ុណ្ណោះ។ ផែនការនេះនឹងផ្តល់ការយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស និងរៀបចំពេលវេលាសម្រាប់សិស្សឱ្យសម្រេចគោលដៅដែលបានកំណត់។ ផែនការនេះ ត្រូវឆ្លុះបញ្ចាំងនូវអ្វីដែលមិត្តរួមថ្នាក់របស់គាត់កំពុងសិក្សា ឱ្យបានច្រើនតាមដែលអាចធ្វើបាន ។ ផែនការអប់រំសម្រាប់កុមារម្នាក់ៗ កំណត់ពីការគាំទ្រ និងសេវាកម្មនានាដែលសិស្សត្រូវការ ដើម្បីទទួលជោគជ័យ។

## ៨.៣. ទម្រង់គំរូរបស់ផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖

មានទម្រង់គំរូជាច្រើនសម្រាប់ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ក៏ប៉ុន្តែផែនការអប់រំសម្រាប់កុមារម្នាក់ៗ ភាគច្រើនមានចំណុចមួយចំនួន ឬទាំងអស់ជាពិសេសតាមលំដាប់លំដោយទាំងនេះ៖

- **ផ្នែក ក**
  - ឈ្មោះ
  - ថ្ងៃខែឆ្នាំកំណើត
  - ភេទ
  - អាសយដ្ឋាន
  - ភាសាកំណើត ឬភាសា(ផ្សេងៗ)
  - ព័ត៌មានសំខាន់ៗ

- លក្ខខណ្ឌដែលពាក់ព័ន្ធ
- គោលដៅ
- បុគ្គលិកទទួលបន្ទុក

- **ផ្នែក ខ**
  - បំណិន
  - កម្រិតបច្ចុប្បន្នភាព ឬទិន្នន័យដើម
  - វត្ថុបំណង
  - តម្រូវការសម្ភារបង្រៀន
  - ដំណើរការបង្រៀន
  - ការវាយតម្លៃ
  - កំណត់សំគាល់

# ផែនការអប់រំសម្រាប់កុមារម្នាក់ៗ
# សៀវភៅណែនាំ

ការរៀបចំកម្មវិធីអប់រំសម្រាប់កុមារម្នាក់ៗជាក់លាក់ ដើម្បីឆ្លើយតបនឹងតម្រូវការផ្នែកអប់រំ និងការបណ្តុះ បណ្តាលរបស់កុមារម្នាក់ៗ។ កុមារពិការ២នាក់អាចមានសមត្ថភាព និងតម្រូវការមិនដូចគ្នា ហើយសិស្សខ្សោយសតិបញ្ញាភាគច្រើនត្រូវការសេវាកម្មផ្សេងៗលើសពីមួយ ដូចជាការអប់រំបរិយាប័ន្ន ការអប់រំពិសេស ការព្យាបាលការបញ្ចេញសម្លេង ព្រមទាំងការព្យាបាលសោតទស្សន៍ ចិត្តសាស្ត្រ សរីរាង្គ ការព្យាបាលចលនា និងការព្យាបាលដោយឱសថ។ វាមានសារៈសំខាន់ណាស់ ក្នុងការរៀបចំកម្មវិធីផ្តល់សេវាកម្មពេញលេញសម្រាប់កុមារម្នាក់ៗ ទៅតាមតម្រូវការរបស់ពួកគេដោយរាប់បញ្ចូលទាំងធាតុចូលសមស្របពីរបៀបបង្រៀនខុសៗគ្នា។ ការបង្កើតផែនការអប់រំសម្រាប់កុមារម្នាក់ៗ របៀបនេះគឺជាផ្នែកដ៏សំខាន់នៃដំណើរការនៃការព្យាបាលទៅតាមរោគវិនិច្ឆ័យ។

ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ចែកចេញជា២ផ្នែក ពោលគឺផ្នែក ក និងខ។ ផ្នែក ក ពណ៌នាពីព័ត៌មានទូទៅរបស់កុមារ អ្នកដែលផ្តួចផ្តើមបង្កើតកម្មវិធីនេះ និងគោលដៅរួមសម្រាប់កុមារ។ ផ្នែក ខ ពណ៌នាពីការបង្កើតកម្មវិធីជាក់លាក់នានាសម្រាប់បំណិន ឬអាកប្បកិរិយា។

## សេចក្តីណែនាំសម្រាប់ការបំពេញផ្នែក "ក"

1. **ឈ្មោះ៖** បំពេញនាមត្រកូល និងនាមខ្លួនរបស់សិស្ស
2. **កាលបរិច្ឆេទ (អាយុ)៖** បំពេញតាមឯកសារ
3. **ភេទ**
4. **អាសយដ្ឋាន៖** បំពេញអាសយដ្ឋានបច្ចុប្បន្ន
5. **ភាសាកំណើត ៖** វាមានសារៈសំខាន់ណាស់ដែលកុមារត្រូវប្រើភាសាមួយជាប្រចាំ ដូច្នេះត្រូវកត់ត្រាព័ត៌មានលម្អិតនៃភាសាកំណើតរបស់កុមារនោះ ក៏ដូចជាភាសាដទៃទៀតដែលកុមារនិយាយ។ សូមគូរវង្វង់លើភាសាកំណើត។
6. អត្តលេខចុះឈ្មោះចូលរៀន៖ បំពេញអត្តលេខចុះឈ្មោះចូលរៀននៅក្នុងសាលារៀន។
7. **កម្រិតថ្នាក់រៀនឬបញ្ជីឈ្មោះ៖** ប្រសិនបើជាសាលារៀនអប់រំពិសេសណាមួយ បែងចែកកុមារទៅតាមក្រុម ថ្នាក់រៀន ឬអក្ខរក្រមបញ្ជីឈ្មោះ។
8. **កាលបរិច្ឆេទក្នុងការរៀបចំ៖** ផែនការអប់រំសម្រាប់កុមារម្នាក់ៗ ជាទូទៅត្រូវបានធ្វើឡើងនៅថ្ងៃណាមួយជាក់លាក់ដែលក្រុមការងារជួបប្រជុំគ្នា និងធ្វើការសម្រេចទៅលើកម្មវិធីនេះសម្រាប់កុមារណាម្នាក់។ សូមចុះកាលបរិច្ឆេទនៃការជួបប្រជុំនេះ។
9. **លេខផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖** កុមារម្នាក់ៗនឹងមានលេខទៅតាមលំដាប់លំដោយ។ សូមចុះលេខផែនការនេះ។
10. ព័ត៌មានសំខាន់ៗស្តីពីកុមារពិការរួមមាន៖
    - កម្រិតនៃភាពយឺតយ៉ាវនៃការលូតលាស់
    - ស្ថានភាពពាក់ព័ន្ធនានា ដូចជាពិបាកក្នុងការមើល ស្តាប់ ឬ ការវះកាត់ ស្ថានភាពវេជ្ជសាស្ត្រជំងឺប្រកាច់ ការកន្ត្រាក់សាច់ដុំ (Hyperkinsesis) និងបញ្ហាអាកប្បកិរិយានានា
    - ប្រវត្តិគ្រួសាររបស់កុមារ
    - ចំណុចខ្លាំង និងចំណុចខ្សោយរបស់កុមារ
    - ការប្រើប្រាស់ឱសថ ប្រសិនបើមាន។
11. **គោលដៅ៖** បញ្ជាក់ពីគោលដៅទូទៅដែលបានកំណត់សម្រាប់កុមារបន្ទាប់ពីការវាយតម្លៃ និងអទិភាពតាមលំដាប់លំដោយ ប្រសិនបើមានគោលដៅលើសពីមួយ។
12. **ឈ្មោះអ្នកទទួលខុសត្រូវ៖** ឈ្មោះសមាជិកដែលទទួលខុសត្រូវចំពោះការអនុវត្ត និងការសម្របសម្រួល ផែនការអប់រំសម្រាប់កុមារម្នាក់ៗត្រូវបញ្ជាក់នៅទីនេះ។

## ការណែនាំសម្រាប់ការបំពេញផ្នែក "ខ"

ផ្នែក"ខ"មានកម្មវិធីជាក់លាក់របស់កុមារដែលមានការណែនាំច្បាស់លាស់ក្នុងការអនុវត្តកម្មវិធី។

13. **បំណិនឬសកម្មភាព៖** បញ្ជាក់នៅទីនេះដែរគឺបំណិនដែលកុមារពិការត្រូវទទួលកា របណ្តុះបណ្តាលដូចជាបំណិនទាក់ទងនឹងការញុំាអាហារ ការស្លៀកពាក់ ឬការសរសេរ ។ល។ ប្រសិនបើមានជាអាកប្បកិរិយាណាមួយដែលគេត្រូវបញ្ជាក់ សូមរៀបរាប់អាកប្បកិរិយានោះ ឧទាហរណ៍ ការបោកក្បាល រុកភ្នែក យោលខ្លួន ។ល។
14. **ទិន្នន័យបច្ចុប្បន្ន៖** សូមសរសេរដោយប្រើពាក្យទាក់ទងនឹងអាកប្បកិរិយានូវអ្វីដែលពិតប្រាកដដែលកុមារពិការអាចធ្វើបានចំពោះបំណិន ឬអាកប្បកិរិយាដែលគេផ្តល់ឱ្យ ឧទាហរណ៍៖ ប្រសិនបើបំណិននោះគឺការសិតសក់ កម្រិតបច្ចុប្បន្នភាពអាចមាន «ការចាប់កាន់ក្រាស់បានត្រឹមត្រូវ»។ ការដាក់ក្រាសនៅលើក្បាល ប៉ុន្តែមិនបានសិតសក់ទៅតាមទិសដៅសមស្របមួយទេ ។ មិនអាចសិតសក់ទៅមួយចំហៀងបានទេ។
15. ប្រសិនបើវាជាអាកប្បកិរិយា សូមលើកឡើងពីអ្វីដែលជំរុញឱ្យកើតមានអាកប្បកិរិយានេះ កម្រិត នៃរបៀបដែលកុមារពិការមានអាកប្បកិរិយាជាក់លាក់ និងរយៈពេលដែលគេមានអាកប្បកិរិយា នោះ។
16. **វត្ថុបំណង៖** បញ្ជាក់ដោយប្រើពាក្យពេជន៍ដែលទាក់ទងនឹងអាកប្បកិរិយា ពីអត្ថន័យរបស់វត្ថុបំណងនេះ បញ្ជាក់ពី

    (ក) លក្ខខណ្ឌ

    (ខ) អាកប្បកិរិយា

    (គ) កម្រិតនៃការធ្វើសកម្មភាព

    (ឃ) កាលបរិច្ឆេទដែលត្រូវបញ្ចប់។

    ដើម្បីធ្វើការបង្ហាញ សូមមើលឧទាហរណ៍នៅផ្នែកខាង ក្រោម។

    (ក) នៅពេលគេសួរ

    (ខ) កុមារ (ឈ្មោះរបស់កុមារ) ចង្អុលទៅកាន់រូបភាពផ្លែឈើដែលគេហៅឈ្មោះបានត្រឹមត្រូវ

    (គ) ត្រូវបាន ៨ លើកក្នុងចំណាម ១០ លើក

    (ឃ) និងក្នុងរយៈពេល ៣ ខែ។
17. **នីតិវិធី ៖** ផ្តល់នូវនីតិវិធីមួយជំហានម្តងៗ ដើម្បីសម្រេចបាននូវវត្ថុបំណងច្បាស់លាស់។ មិនត្រូវមានមហិច្ឆិតាខ្ពស់ពេកទេ។ ដំណាក់កាលនីមួយៗត្រូវតែជាក់លាក់ និងច្បាស់លាស់។ ចូរកុំភ្លេចការលើកទឹកចិត្ត ។
18. **សម្ភារដែលត្រូវការ៖** សរសេរសម្ភារដែលត្រូវការសម្រាប់អភិវឌ្ឍបំណិនជាក់លាក់ ឬសម្រាប់កែលម្អអាកប្បកិរិយា។

19. **ការវាយតម្លៃ៖** ទុកកូឡោនឱ្យនៅចំហ នៅពេលគេសរសេរផែនការអប់រំសម្រាប់កុមារម្នាក់ៗ បន្ទាប់ពីរយៈពេលមួយជាក់លាក់ ពោលគឺនៅពេលដែលគេវាយតម្លៃកុមារពីការរីកចម្រើន ឬបញ្ហាផ្សេងៗ បន្ទាប់មក បំពេញកូឡោននេះ ដោយកត់ត្រាពីការសង្កេត។ ការធ្វើដូចនេះនឹងបង្កើតបាននូវទិន្នន័យដើម ឬកម្រិតបច្ចុប្បន្នភាពសម្រាប់ឱ្យគេរៀបចំផែនការអប់រំសម្រាប់កុមារម្នាក់ៗបន្ត។

ដើម្បីកំណត់ពីការរីកចម្រើនរបស់កុមារ គេអាចចាត់ថ្នាក់ពីលេខ ១ដល់ ៧ ដូចខាងក្រោម៖

- ក្រោមទិន្នន័យដើម = 1
- ពុំមានការរីកចម្រើន = 2
- រីកចម្រើន 25% = 3
- រីកចម្រើន 50% = 4
- រីកចម្រើន 75% = 5
- រីកចម្រើន 90% = 6
- រីកចម្រើន 100% = 7

គូសរង្វង់លើលេខឱ្យបានត្រឹមត្រូវ។ ដើម្បីទទួលបានភាគរយនៃការរីកចម្រើន សូមធ្វើការវាស់វែងដោយ ប្រៀបធៀបទៅនឹងវត្ថុបំណង ចំនួនដងដែលកុមារអាចធ្វើបាន។ រកឱ្យឃើញភាគរយនៃពិន្ទុ។

ក្នុងទម្រង់នេះ គេអាចសរសេរពីការអភិវឌ្ឍផ្នែកបំណិនភាសា និងការនិយាយ សកម្មភាពក្នុងការរស់នៅប្រចាំថ្ងៃនិងការសិក្សារៀនសូត្រ ក៏ដូចជាអាកប្បកិរិយានានាដែលគេត្រូវកែលម្អ។ ដូច្នេះ ទម្រង់នេះគឺមានសារៈសំខាន់សម្រាប់អ្នកអប់រំពិសេស អ្នកព្យាបាលការបញ្ចេញសំឡេង អ្នកចិត្តសាស្រ្ត និងសរីរៈវិទ្យា។

20. **បញ្ហាដែលជួបប្រទះ ឬកំណត់សំគាល់៖** សរសេរនៅទីនេះឱ្យបានច្បាស់លាស់ អំពីបញ្ហាដែលបានជួបប្រទះ ខណៈដែលកំពុងអនុវត្តកម្មវិធីនេះ ដែលអាចមានភាពជាក់លាក់ចំពោះកុមារ និងស្ថានភាព។

## គំរូ
## ផែនការអប់រំសម្រាប់កុមារម្នាក់ៗ

### ផ្នែក ក

1. ឈ្មោះ៖ សំ សំបូរ
2. ថ្ងៃខែឆ្នាំកំណើត៖ (អាយុ)
3. ភេទ៖ ប្រុស
4. អាសយដ្ឋាន៖
5. ភាសាកំណើត៖ ភាសាខ្មែរ ប្រើប្រាស់ដោយកុមារខ្សោយសតិបញ្ញា
6. អត្តលេខចុះឈ្មោះ៖
7. ថ្នាក់រៀននិងបញ្ជីឈ្មោះ៖ បឋមសិក្សា១
8. កាលបរិច្ឆេទចុះក្នុងផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖
9. លេខផែនការអប់រំសម្រាប់កុមារម្នាក់ៗ៖ ០១+ ០២
10. ព័ត៌មានសំខាន់ៗ៖ ខ្សោយសតិបញ្ញាក្នុងកម្រិតធ្ងន់ធ្ងរអំពីកុមារ
11. លក្ខខណ្ឌដែលពាក់ព័ន្ធ៖ ការដើរខុសប្រក្រតី ការទទួលការព្យាបាលចលនា ព្រមទាំងការបញ្ជូន បើចាំបាច់
12. គោលដៅ៖ មានការរីកចម្រើនលើបំណិនចលនា
    - ងូតទឹកខ្លួនឯង
    - ដុសធ្មេញខ្លួនឯង
    - ការនិយាយ
    - ស្គាល់ពីលុយ និងពេលវេលា
13. បុគ្គលិកដែលទទួលបន្ទុកផែនការអប់រំសម្រាប់កុមារម្នាក់ៗ

កាលបរិច្ឆេទចាប់ផ្តើមកម្មវិធី៖..................
កាលបរិច្ឆេទការវាយតម្លៃ៖......................
បុគ្គលិកទទួលបន្ទុក៖ Leena

## ផ្នែក ខ

- **បំណិនៈ** ការដុសធ្មេញ (បំណិនជួយខ្លួនឯង)
  កម្រិតបច្ចុប្បន្នភាព ឬ កុមារធ្វើតាមការណែនាំសាមញ្ញៗ។ គេអាចកាន់ច្រាសដុះធ្មេញបានត្រឹមត្រូវ និង អាចបើកគម្របថ្នាំដុសធ្មេញបាន។ យកច្រាសដុះធ្មេញដាក់ក្នុងមាត់។

---

- **វត្ថុបំណងៈ** កុមារអាចដុសធ្មេញរបស់គេដោយប្រើប្រាស់ច្រាស និងថ្នាំដុសធ្មេញនៅពេលព្រឹកបន្ទាប់ពីក្រោកពីគេង និងពេលយប់ក្រោយញុំាអាហារពេលល្ងាចរួចបានត្រឹមត្រូវ ៨០% ក្នុងរយៈពេល ៣ ខែ។

---

- **សម្ភារដែលត្រូវការៈ** ថ្នាំដុសធ្មេញ ច្រាស ទឹក និងកញ្ចក់
- **ដំណើរការៈ**
  1. គេអាចបង្កើតលក្ខខណ្ឌលើកទឹកចិត្តសម្រាប់កុមារបានដោយផ្សារភ្ជាប់សកម្មភាពផ្សេងទៀតទៅ នឹងការដុសធ្មេញ ឧទាហរណ៍ «កុមារនឹងបានទឹកដោះគោញុំា បន្ទាប់ពីដុសធ្មេញរួច»។ ប្រសិនបើ អាចធ្វើបាន គេអាចសុំឱ្យមិត្តរួមថ្នាក់(បងប្អូនប្រុស ឬស្រី)ចូលរួមដុសធ្មេញជាមួយកុមារនោះ។
  2. ឈរពីក្រោយកុមារ ហើយចាប់កាន់ច្រាសជាមួយកុមារនៅពីមុខកញ្ចក់។ ដោយធ្វើជាគំរូក្នុងការដុសធ្មេញដុសតាមលំដាប់នៃធ្មេញមុខផ្នែកខាងលើ និងខាងក្រោម ធ្មេញខាងឆ្វេង និងខាងស្តាំ ដោយដាក់ធ្មេញខាងលើ និងខាងក្រោមជាប់គ្នា ហើយបន្ទាប់មកបើកមាត់ដុសធ្មេញលើ និងធ្មេញក្រោម។ កាត់បន្ថយការធ្វើជាគំរូបន្តិចម្តងៗ។ ការឱ្យមិត្តភក្តិ និងអ្នកធ្វើទៀតធ្វើជាគំរូនឹងពង្រឹងការរៀនសូត្របានយ៉ាងឆាប់រហ័ស។ សូមផ្តល់ការសរសើរ និងលើកទឹកចិត្តដល់កុមាររាល់ការព្យាយាមរបស់គេ។
  3. ឱ្យកុមារអោនទៅមុខបន្តិច និងប្រាប់កុមារឱ្យខ្ពុរមាត់ចេញ។ គេអាចធ្វើជាគំរូ និងបង្ហាញប្រាប់ជាក់ ស្តែងលើកដំបូងបាន ហើយក្រោយមកត្រូវបណ្តោយឱ្យកុមារធ្វើដោយខ្លួនឯងបន្តិចម្តងៗ។
  4. សូមកុំភ្លេចផ្តល់រង្វាន់លើកទឹកចិត្តដល់កុមាររាល់ការព្យាយាមរបស់គេ។

---

- **ការវាយតម្លៃ**
  1 2 3 4 5 6 7 (78% )

---

**សំគាល់ៈ** ពីរបីថ្ងៃបន្ទាប់មកកុមារបង្ហាញពីចំណាប់អារម្មណ៍ក្នុងការដុសធ្មេញរបស់គាត់បន្ទាប់ពីញុំាអាហាររួច។

# ផែនការអប់រំសម្រាប់កុមារម្នាក់ៗ

កាលបរិច្ឆេទចាប់ផ្ដើមកម្មវិធី៖..................
កាលបរិច្ឆេទការវាយតម្លៃ៖......................
បុគ្គលិកទទួលបន្ទុក៖ Leena

## ផ្នែក ខ

- **បំណិន៖** បំណិន តួនាទីនៃពាក្យ (ភាសាកាយវិការ និងការកំសាន្ត)
កម្រិតបច្ចុប្បន្ន ឬកុមារធ្វើតាមការណែនាំងាយៗ។ គេអាចនិយាយពាក្យពីរបីម៉ាត់ លេងបាល់ទាត់ និងមើលការប្រកួតបាល់ទាត់តាមទូរទស្សន៍។

---

- **វត្ថុបំណង៖** នៅពេលគេសួរ កុមារអាចហៅឈ្មោះសម្ភារផ្សេងៗដែលប្រើប្រាស់ក្នុងការលេងបាល់ទាត់ ដោយ ប្រាប់បានត្រឹមត្រូវចំនួន ៨០% ក្នុងរយៈពេល ៣ ខែ ។

---

- **សម្ភារដែលត្រូវការ៖** បាល់ទាត់ សំណាញ់ ស្បែកជើង ស្រោមជើង ខោអាវកីឡា និងទស្សនាវដ្ដីកីឡា ។ល។
- **ដំណើរការ៖**
  1. នាំកុមារទៅជិតតារាងបាល់ទាត់មុនពេលចាប់ផ្ដើមលេង និងសុំឱ្យពួកគេធ្វើការកត់សម្គាល់ និង ហៅឈ្មោះសម្ភារទាំងនោះ។ ដំបូងប្រាប់ពួកគេនូវឈ្មោះវត្ថុទាំងនោះ ហើយសុំឱ្យកុមារនិយាយ ឡើងវិញដោយបង្ហាញនូវសម្ភារទាំងនោះម្ដងមួយៗ។ និយាយប្រាប់ពួកគេ បន្ទាប់មកធ្វើសញ្ញាជា សំឡេង ហើយចាប់ផ្ដើមឱ្យកុមារហ្វឹកហាត់ដោយខ្លួនឯងបន្តិចម្ដងៗ។
  2. ក្នុងពេលសម្រាក ចូរបង្ហាញទស្សនាវដ្ដីកីឡាដែលមានពណ៌ និងណែនាំឈ្មោះសម្ភារផ្សេងៗ (បាល់ ....) ដែលគេប្រើសម្រាប់លេងបាល់ទាត់។
  3. នៅពេលលេង ឱ្យកុមារហុចសម្ភារទាំងនោះ និងផ្ដល់ឱកាសឱ្យកុមារប្រាប់ឈ្មោះវត្ថុទាំងនោះ។ ហើយសុំឱ្យកុមារនិយាយប្រាប់ពីអ្វីដែលពួកគេចង់បានដែរ។
  4. នៅពេលប្រមូលសម្ភារដាក់ក្នុងទីលាន ចូរឱ្យកុមារប្រាប់ឈ្មោះសម្ភារនោះម្ដងទៀត។
  5. ជម្រាបឪពុកម្ដាយឱ្យសួរឈ្មោះសម្ភារកីឡានីមួយៗនៅពេលកុមារមើលបាល់ទាត់តាមទូរទស្សន៍
  6. នៅក្នុងម៉ោងសិក្សាសិល្បៈ និងគំនូរ ត្រូវជួយកុមារឱ្យគូររូបបាល់ និងសុំឱ្យកុមារប្រាប់ឈ្មោះ។
  7. សូមកុំភ្លេចផ្ដល់រង្វាន់លើកទឹកចិត្តដល់កុមារសម្រាប់ការព្យាយាមម្ដងៗរបស់គេ។

- **ការវាយតម្លៃ**

  1 2 3 4 5 6 7 (៧៨% )

**សំគាល់៖** នៅពេលកុមារដេួលទៅលើដី និងមានរបួស ការហ្វឹកហាត់មានតែនៅផ្ទះប៉ុណ្ណោះសម្រាប់រយៈពេល ១០ ថ្ងៃ។

# មេរៀនទី ៩
# កិច្ចតែងការបង្រៀនសម្រាប់ការបង្រៀនជាក្រុម

**វត្ថុបំណង៖** វត្ថុបំណងរបស់ជំពូកនេះគឺដើម្បីយល់ និងរៀនសូត្រពីរបៀបរៀបចំ និងអនុវត្តកិច្ចតែងការ បង្រៀននៅសាលារៀនមត្តេយ្យសិក្សា និងបឋមសិក្សា។

## ៩.១. និយមន័យ៖

កិច្ចតែងការបង្រៀនគឺជាការពិពណ៌នាលម្អិតរបស់គ្រូបង្រៀនក្នុងការបង្រៀនមេរៀនមួយ។ កិច្ចតែងការបង្រៀន ប្រចាំថ្ងៃត្រូវបានគ្រូបង្រៀនរៀបចំឡើងដើម្បីណែនាំការរៀនសូត្រនៅក្នុងថ្នាក់។ ចំណុចលម្អិតនៅក្នុងកិច្ចតែងការបង្រៀននឹងមានភាពខុសគ្នាអាស្រ័យទៅលើការពេញចិត្តរបស់គ្រូបង្រៀន មុខវិជ្ជាដែលត្រូវបញ្ចូល និងតម្រូវការនានារបស់សិស្ស។ វាអាចមានតម្រូវការផ្សេងៗដែលគេតម្រូវឱ្យមាន តែមិនត្រូវបានគេដាក់បញ្ចូលទៅតាមប្រព័ន្ធ របស់សាលារៀនទាក់ទងនឹងកិច្ចតែងការបង្រៀននេះទេ។ កិច្ចតែងការបង្រៀនគឺជាការណែនាំសម្រាប់គ្រូបង្រៀន ដើម្បីបង្រៀនមេរៀនដាក់លាក់មួយ ហើយកិច្ចតែងការនេះមានបញ្ចូលនូវគោលបំណង(អ្វីដែលគេរំពឹងទុកថាសិស្សនឹងរៀន) របៀបដែលគេសម្រេចបាននូវគោលបំណង(វិធីសាស្ត្រ ដំណើរការ) និងមធ្យោបាយនៃការវាស់វែង ថាតើគេសម្រេចបានគោលបំណងនោះដោយរបៀបណា(ការប្រឡងឬតេស្ត សន្លឹកកិច្ចការជំនួយ កិច្ចការផ្ទះ ។ល។)។

## ទម្រង់កិច្ចតែងការបង្រៀន៖

ដោយមានទម្រង់ជាច្រើនសម្រាប់កិច្ចតែងការបង្រៀន កិច្ចតែងការបង្រៀនជាច្រើនមានចំណុចមួយចំនួន ឬគ្រប់ ចំណុចទាំងអស់ដែលមានរៀបចំតាមលំដាប់លំដោយដូចខាងក្រោម។

- ឈ្មោះសាលារៀន
- កាលបរិច្ឆេទ និងពេលវេលា
- ថ្នាក់ ឬ ឆ្នាំ
- ឈ្មោះគ្រូបង្រៀន
- ចំនួនសិស្ស
- លំដាប់អាយុ
- ផ្នែក

- កិច្ចការ ប្រធានបទ ឬ សកម្មភាព
- កម្រិតបច្ចុប្បន្ន
- វត្ថុបំណងជាក់លាក់
- សម្ភារដែលត្រូវប្រើ
- ការលើកទឹកចិត្ត
- សកម្មភាពរបស់គ្រូបង្រៀន
- សកម្មភាពរបស់សិស្ស
- ការវាយតម្លៃ
- កំណត់សំគាល់

## ទម្រង់គំរូ

## កិច្ចតែងការបង្រៀនសម្រាប់ការបង្រៀនជាក្រុម

ឈ្មោះសាលារៀន __________ ថ្នាក់ ____________ កាលបរិច្ឆេទ ____________

ឈ្មោះរបស់គ្រូបង្រៀន__________លំដាប់អាយុ __________ពេលវេលា_______ចំនួនកុមារ ______

**ចំណុច ឬ ផ្នែក៖** កម្មវិធីសិក្សា

**កិច្ចការ ប្រធានបទ សកម្មភាព៖** ការកំណត់ចំនួនតាមលេខរៀន ១ និង ២

**កម្រិតបច្ចុប្បន្ន**

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

**វត្ថុបំណងជាក់លាក់៖** នៅពេលគេសួរ ឬ សុំឱ្យប្រាប់ សិស្សដឹងចំនួនលេខ ១ និង លេខ២ ដោយសិស្ស ៨០% ឆ្លើយបានត្រឹមត្រូវក្នុងរយៈពេល ៣០ នាទី។

ឬ

**វត្ថុបំណងជាក់លាក់៖ បន្ទាប់ពីបង្រៀនបាន**៣០នាទី សិស្សចំនួន ៨០% នឹងមានសមត្ថភាពបំពេញ

កិច្ចការបានត្រឹមត្រូវ។

---

## ការរៀបចំថ្នាក់រៀន៖

**សម្ភារដែលត្រូវប្រើ៖** បណ្ណពាក្យ(លេខ) ឬរូបភាព(សម្រាប់បង្ហាញសិស្ស) ឈើដោតការ៉េម និងវត្ថុផ្សេងៗទៀត

**ការលើកទឹកចិត្ត៖** គ្រូបង្រៀននឹងជូនពរសិស្ស និងប្រាប់ពីសារៈសំខាន់នៃការរៀនលេខ។

| ល.រ | សកម្មភាពរបស់គ្រូបង្រៀន | សកម្មភាពរបស់សិស្ស |
|---|---|---|
| 1 | គ្រូបង្រៀននឹងបង្ហាញបណ្ណដែលមានលេខ ១ ឱ្យសិស្សមើល | សិស្សមើលបណ្ណ |
| 2 | គ្រូបង្រៀនបង្ហាញបណ្ណលេខ ហើយនិយាយថានេះ គឺលេខ | សិស្សនឹងមើលឃើញ |
| 3 | គ្រូបង្រៀនឱ្យសិស្សអាន(ថា)តាម | សិស្សនឹងអាន(ថា)តាម «លេខ |
| 4 | គ្រូបង្រៀនបង្ហាញបណ្ណដែលមានលេខ ២ | សិស្សនឹងឃើញ |
| 5 | គ្រូបង្រៀននឹងនិយាយថា នេះជាលេខ ២ | សិស្សនឹងសង្កេតមើល |
| 6 | គ្រូបង្រៀនឱ្យសិស្សអាច(ថា)តាម | សិស្សនឹងអាន(ថា)តាម «លេខ |
| 7. | គ្រូបង្រៀននឹងឱ្យបណ្ណលេខទៅសិស្ស | សិស្សនឹងទទួលយកបណ្ណលេខ |
| 8 | គ្រូបង្រៀនឱ្យសិស្សមើលអ្វីដែលគាត់កំពុងធ្វើ | សិស្សនឹងសង្កេតមើល |
| 9 | គ្រូបង្រៀនដាក់ឈើដោតការ៉េមចំនួន ៤ នៅលើតុ | សិស្សនឹងមើលទៅគ្រូបង្រៀន |
| 10 | គ្រូបង្រៀននឹងយកឈើសម្រាប់ដោតការ៉េមចំនួន ១ ដាក់នៅលើ | សិស្សនឹងមើលការបង្ហាញរបស់គ្រូបង្រៀន |
| 11 | គ្រូបង្រៀននឹងប្រាប់ពីតម្លៃរបស់លេខ១ | |
| 12 | គ្រូបង្រៀននឹងយកឈើសម្រាប់ដោតការ៉េមចំនួន ១ ដាក់នៅលើ | សិស្សនឹងមើលការបង្ហាញរបស់គ្រូបង្រៀន |
| 13 | គ្រូបង្រៀនដាក់ប៉េងប៉ោងមួយចំនួន | |
| 14 | គ្រូបង្រៀនឹងយកប៉េងប៉ោងចំនួន ២ ហើយនិយាយថា «នេះជាចំនួន២» | សិស្សស្តាប់ និងមើលសកម្មភាពរបស់គ្រូបង្រៀន គ្រូបង្រៀន |
| 15 | គ្រូបង្រៀននឹងដាក់បណ្ណដែលមានលេខ ២ នៅមុខសិស្សម្នាក់ៗ | សិស្សនឹងមើលឃើញ |
| 16 | គ្រូបង្រៀននឹងឱ្យសិស្សដាក់ប៉េងប៉ោងចំនួន ១ នៅលើបណ្ណដែល មានលេខ(២) | សិស្សនឹងធ្វើសកម្មភាព |
| 17. | គ្រូបង្រៀននឹងដាក់បណ្ណដែលមានលេខ ១ នៅមុខសិស្សម្នាក់ៗ | សិស្សនឹងមើលឃើញ |
| 18 | គ្រូបង្រៀននឹងឱ្យសិស្សដាក់ប៉េងប៉ោងចំនួន ២នៅលើបណ្ណដែល មានលេខ (២) | សិស្សនឹងអនុវត្តតាម |
| 19 | គ្រូបង្រៀននឹងអនុវត្តដោយប្រើវត្ថុផ្សេងៗគ្នា | សិស្សនឹងអនុវត្តលេខ ១ និងលេខ ២ដោយ ប្រើវត្ថុផ្សេងៗគ្នា |
| 20 | គ្រូបង្រៀននិងនិយាយថាល្អ និងទះដៃសម្រាប់ពួកគេ | សិស្សនិងនិយាយថាអរគុណ |

# មេរៀនទី១០

# ការគ្រប់គ្រងថ្នាក់រៀន

## ទត្ថុបំណង៖

ដើម្បីស្វែងយល់ និងសិក្សាពីរបៀបប្រើប្រាស់វិធីសាស្ត្រផ្សេងៗ នៃការគ្រប់គ្រងកុមារពិការនៅតាមមត្តេយ្យសិក្សា និងបឋមសិក្សា។

## ១០.១ និយមន័យ៖

ការគ្រប់គ្រងថ្នាក់រៀនសំដៅលើជំនាញ និងប្រើវិធី ផ្សេងៗជាច្រើនដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីរៀបចំ កុមារឱ្យមានសណ្តាប់ធ្នាប់ យកចិត្តទុកដាក់ ចូលរួមក្នុងសកម្មភាព និងទទួលបានលទ្ធផលល្អក្នុងថ្នាក់រៀន។ នៅពេលដែលការគ្រប់គ្រងថ្នាក់រៀនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនអាចកាត់បន្ថយរាល់សកម្មភាពដែលប៉ះពាល់ដល់ការសិក្សារបស់កុមារម្នាក់ៗ ឬកុមារទាំងអស់ ប៉ុន្តែបង្កើនជាអតិបរមាចំពោះអាកប្បកិរិយាដែលជួយសម្របសម្រួល ឬពង្រឹងការសិក្សា។ ជាទូទៅ គ្រូបង្រៀនដែលមានសមត្ថភាពក្នុងការបង្ហាញពីជំនាញដ៏ល្អក្នុងការគ្រប់គ្រងថ្នាក់រៀន ប៉ុន្តែគ្រូបង្រៀនដែលពុំមានបទពិសោធន៍ ឬការគ្រប់គ្រងថ្នាក់រៀន ពុំសូវមានប្រសិទ្ធភាព ធ្វើឱ្យថ្នាក់រៀនគ្មានសណ្តាប់ធ្នាប់ កុមារមិនចូលរួមក្នុងសកម្មភាព និងមិនយកចិត្ត ទុកដាក់ក្នុងការសិក្សា ។

ស្របពេលដែលមានការបកស្រាយពន្យល់នៅមានកម្រិត ឬផ្អែកតាមបែបប្រពៃណីស្តីពីការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធិភាពគឺផ្តោតទាំងស្រុងទៅលើ«ការគោរពតាមបទបញ្ញត្តនានា» រួមមាន ច្បាប់វិក្រឹតការ និងយុទ្ធសាស្ត្រនានាដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីឱ្យសិស្សអង្គុយនៅតាមកន្លែង ស្តាប់ការណែនាំ និងស្តាប់ដោយយកចិត្តទុកដាក់ ។ល។ ទស្សនៈដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងបានធ្វើបច្ចុប្បន្នភាពស្តីពីការគ្រប់គ្រងថ្នាក់រៀនផ្តោតទៅលើអ្វីគ្រប់យ៉ាងដែលគ្រូបង្រៀនប្រើដើម្បីសម្របសម្រួល ឬពង្រឹងការសិក្សារបស់កុមារដែលមានកត្តាមួយចំនួនដូចជា៖ អាកប្បកិរិយាវិជ្ជមាន ការសំដែងទឹកមុខរីករាយ ពាក្យសម្តីលើកទឹកចិត្ត និងការយកចិត្តដាក់ទៅលើកុមារស្មើៗគ្នា បរិយាកាសក្នុងថ្នាក់រៀន(ដូចជាការរៀបចំថ្នាក់រៀនដែលគួរឱ្យទាក់ទាញ ដោយតុបតែងសម្ភារសិក្សាដែលអាចជួយក្នុងសកម្មភាពសិក្សាផ្សេងៗ) ការរំពឹងទុក (គុណភាពកិច្ចការដែលគ្រូបង្រៀនរំពឹងថាកុមារនឹងសម្រេចបាន អាកប្បកិរិយាល្អជាមួយកុមារដទៃ ជាកិច្ចព្រមព្រៀង រវាងគ្រូបង្រៀន និងកុមារ) សម្ភារសិក្សា(ប្រភេទអត្ថបទ សម្ភារឧបទ្ទេស និងឯកសារដទៃទៀតដែលគ្រូបង្រៀនប្រើប្រាស់) ឬសកម្មភាពនានា (ប្រភេទសម្មភាពសិក្សា ដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីឱ្យកុមារចូលរួម ចាប់

អារម្មណ៍ និងមានជាសំនួរ)។ ដោយសារតែមេរៀន ដែលរៀបចំមិនបានល្អ សម្ភារសិក្សាមិនគួរឱ្យចាប់អារម្មណ៍ គ្មានការរំពឹងទុកច្បាស់លាស់អាចនឹងមិនទាក់ទាញចំណាប់អារម្មណ៍សិស្ស នាំឱ្យអាកប្បកិរិយាដែលមិនចង់បានកើនឡើង ឬថ្នាក់រៀនគ្មានសណ្តាប់ធ្នាប់ ចំណែកការគ្រប់គ្រងថ្នាក់រៀនទៀតសោត ក៏មិនអាចញែកចេញពីការសម្រេចចិត្តនានារបស់គ្រូបង្រៀន ។ នៅក្នុងទស្សនៈស្តីពីការគ្រប់គ្រងថ្នាក់រៀនបច្ចុប្បន្ន ការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន បានល្អគឺជារឿងពីរដាច់ដោយឡែកពីគ្នា។

## ១០.២ បច្ចេកទេសក្នុងការគ្រប់គ្រងថ្នាក់រៀនៈ

គ្រូបង្រៀនដែលមានសមត្ថភាព មានចំណាប់អារម្មណ៍ខ្លាំងក្នុងការបង្រៀនសិស្ស ។ ពួកគាត់ចង់ចំណាយពេលវេលារបស់ខ្លួនក្នុងការបង្រៀន មិនមែនគ្រាន់តែដោះស្រាយបញ្ហាថ្នាក់រៀនប៉ុណ្ណោះទេ ។ ខាងក្រោមនេះគឺជាបច្ចេកទេសក្នុងការរៀបចំថ្នាក់រៀនដែលអាចជួយគ្រូបង្រៀនដោះស្រាយរាល់បញ្ហាផ្សេងៗ ឬទប់ស្កាត់បញ្ហាមិនឱ្យកើតមានឡើងដើម្បីឱ្យពួកគាត់អាចចំណាយពេលទៅលើការងារបង្រៀន និងរៀនបាន ច្រើននៅក្នុងថ្នាក់រៀន។

### ១០.២.១ ភាពខុសគ្នារវាងកុមារា និងកុមារី

កុមារា និងកុមារីអាចនឹងមានទំនោរផ្នែកអាកប្បកិរិយាខុសប្លែកពីគ្នាដោយសារលក្ខណៈធម្មជាតិរបស់ពួកគេ ។ ទាំងនេះមិនមែនជាកត្តាកំណត់ឱ្យបានច្បាស់លាស់នោះឡើយ ប៉ុន្តែវាអាចជាទម្រង់ និងបែបផែន ផ្សេងៗគ្នា ។ ការពិភាក្សាទៅលើកត្តាសំខាន់ៗក្នុងប្រទេសកម្ពុជា និងមូលហេតុៈ

- កុមារាមានសកម្មភាពច្រើន ហើយចូលចិត្តដើរចុះឡើង - ចំណុចនេះហាក់ដូចជាធ្វើឱ្យពួកគេ « រពឹស »នៅពេលពួកគេធុញទ្រាន់ អស់កម្លាំង និងត្រូវការការផ្លាស់ប្តូរសកម្មភាព ឬត្រូវការសម្រាក។ ការសម្រាកគឺមិនចាំបាច់ចំណាយពេលយូរនោះទេប៉ុន្តែគ្រាន់តែជាសកម្មភាព ឬ ការលេងកំសាន្តរយៈពេលខ្លីដែលអាចឱ្យពួកគេមានពេលវេលា ក្នុងការផ្លាស់ប្តូរ និងប្រមូលអារម្មណ៍ឡើងវិញបានប៉ុណ្ណោះ។
- សកម្មភាពរបស់កុមារាអាចធ្វើឱ្យពួកគេសកម្មជាង ដែលជំរុញឱ្យពួកគេកាន់តែសប្បាយរីករាយ ប៉ុន្តែវាមិនមែនជាបំណងរបស់ពួកគេទេ។ ពួកគេអាចនឹងរត់បុកគ្នា ឬរត់ជាន់គ្នានៅពេលពួកគេប្រញ៉ាប់ធ្វើសកម្មភាពអ្វីមួយ។
- កុមារីមានទំនោរក្នុងការនិយាយស្តីច្រើនជាងកុមារា ហើយចង់ជជែកជាមួយមិត្តភក្តិរបស់ពួកគេនៅពេលដែលពួកគេជួបបញ្ហាអ្វីមួយ ។ វាមានន័យថាពួកគេត្រូវការចំណាយពេលយូរដើម្បី បញ្ចប់ការជជែកគ្នា ឬដើម្បីរក្សាភាពស្ងៀមស្ងាត់នៅពេលមួយសមរម្យ ។
- កុមារីអាចមានភាពទន់ជ្រាយ និងភ័យខ្លាចក្នុងការផ្លាស់ប្តូរយោបល់ និងការឆ្លើយសំនួរ

របស់គ្រូក្នុងថ្នាក់ ដូច្នេះពួកគេអាចមានឥរិយាបទស្ងប់ស្ងាត់ ហើយគេត្រូវការការលើកទឹកចិត្ត ក្នុងការចូលរួម សកម្មភាពឱ្យមានប្រសិទ្ធិភាព ។

- ការប្រើប្រាស់បង្គន់អនាម័យជាប្រចាំសម្រាប់កុមារី( ការការពារពេលកុមារនៅតូច និង ភាពខ្មាសអៀននៅពេលកុមារកាន់តែធំ )ចាំបាច់ត្រូវដោះស្រាយដោយប្រុងប្រយ័ត្ន និង សមស្របដើម្បីគាំទ្រដល់កុមារី ។

## ១០.២.២ និយមន័យនៃពាក្យ "វិន័យ"

គឺជាទស្សនៈដែលគេយល់ច្រឡំជាទូទៅថាជាការដាក់ទណ្ឌកម្ម ។ ការដាក់ទណ្ឌកម្មគឺជា «ការធ្វើឱ្យឈឺចាប់ ឬជាការដាក់ទោសចំពោះការប្រព្រឹត្តកំហុស» ហើយជាទូទៅទាក់ទងនឹងការដាក់ទោសធ្ងន់ធ្ងរ ឬផលវិបាកធ្ងន់ធ្ងរដែលបង្កឱ្យមានការភ័យខ្លាច និង ជាការបំពាន ។ ផ្ទុយទៅវិញ វិន័យគឺជា «ការបណ្តុះបណ្តាលដែលអាចកែប្រែ បំពាក់បំប៉ន ឬធ្វើឱ្យប្រសើរឡើងនូវបញ្ញាស្មារតី និងចរិតលក្ខណៈផ្នែកក្រមសីធម៌» ។ ពាក្យថា «Pupil: សិស្ស » កើតចេញមកពីពាក្យឡាតាំងដែលមានន័យថា សិស្សសាលា ។ ពាក្យវិន័យនេះកើតចេញមកពីពាក្យឡាតាំង«Disciplina»ដែល មានន័យថា «ការណែនាំ ការបង្រៀន ការរៀន និងចំណេះដឹង»

វិន័យគឺផ្តោតច្រើនទៅលើការអប់រំបណ្តុះបណ្តាលផ្នែកអាកប្បកិរិយាឱ្យបានសមរម្យ និងទៅតាមការរំពឹងទុក ។ វិន័យសំដៅទៅលើ "ការបង្រៀន" និង "ការទូន្មាន" ឬ "ការណែនាំ» ។ ដូច្នេះ វាគឺជាលំនាំមួយ ដែលមានទំនាក់ទំនងទៅនឹងការយល់ដឹង និងការរីកលូតលាស់ប្រកបដោយលទ្ធផលជាវិជ្ជមាន និងអវិជ្ជមាន។ វាអាចជួយកែប្រែសិស្សតាមរយៈការណែនាំជាគំរូ និងការទូន្មាន។

កុមារត្រូវដឹងថារាល់សកម្មភាពរបស់ពួកគេតែងតែទទួលបាននូវលទ្ធផលទាំងវិជ្ជមាន និង អវិជ្ជមាន ។ សកម្មភាព និងអាកប្បកិរិយារបស់របស់កុមារមានលទ្ធផលវិជ្ជមាន និងអវិជ្ជមាន អាស្រ័យទៅលើការប្រព្រឹត្ត។ ប្រសិនបើកុមារ ប្រព្រឹត្តខ្លួនឱ្យបានសមស្រប មានភាពអត់ធ្មត់ និងសុភាពរាបសារ នោះនឹងទទួលបានលទ្ធផលវិជ្ជមាន ប៉ុន្តែប្រសិនបើកុមារប្រព្រឹត្ត នូវអ្វីដែលមិនល្អ គ្មានភាពអត់ធ្មត់ និងរពឹស នោះពួកគេនឹងទទួលបានលទ្ធផលអវិជ្ជមានជាក់ជាមិនខាន។

## ១០.២.៣ ការផ្តល់ និងដករង្វាន់

ការផ្តល់រង្វាន់គឺជាផលប៉ះពាល់វិជ្ជមាន ដែលបានមកពីការប្រព្រឹត្តល្អ ចំណែកឯការដករង្វាន់គឺជាផលប៉ះពាល់អវិជ្ជមាន ឬការដាក់ពិន័យសម្រាប់ការប្រព្រឹត្តមិនល្អ ។ សិស្សអាចផ្តល់យោបល់សម្រាប់ប្រភេទរង្វាន់ និងការដករង្វាន់ណាខ្លះដែលពួកគេគិតថាសមរម្យ និង ជួយគ្រូបង្រៀនក្នុងការរៀបចំបង្កើតមធ្យោបាយផ្សេងៗដើម្បីធានាបាននូវផលវិបាក និងលទ្ធផល ដែលសមស្របទោះបីវាមានលក្ខណៈវិជ្ជមាន និងអវិជ្ជមានក៏ដោយ ។ នៅពេលគ្រូបង្កើតបទបញ្ញត្តិដោយមានការចូលរួមចែក

វែលែកមតិយោបល់ពីសិស្សសម្រាប់រង្វាន់លើកទឹកចិត្ត និងការដាក់ពិន័យ (គ្រូបង្រៀនមិនចាំបាច់ពិភាក្សាជាមួយសិស្សគ្រប់រឿងនោះទេ) ។

ការផ្តល់ «ជម្រើស» អាចជួយសិស្សឱ្យទទួលស្គាល់ថា ជាលទ្ធផលនៃការជ្រើសរើសល្អ ឬអាក្រក់ និងធ្វើឱ្យពួកគេមានទំនួលខុសត្រូវចំពោះអាកប្បកិរិយាដែលពួកគេបានប្រព្រឹត្ត ។

**សម្គាល់៖** ការផ្តល់រង្វាន់ និងការដករង្វាន់ ត្រូវមាន៖

- ភាពសមស្របតាមអាយុ និងភេទរបស់សិស្ស
- សុវត្ថិភាព
- សង្គតិភាព (ស៊ីសង្វាក់គ្នា)
- ផ្តោតទៅលើអាកប្បកិរិយា មិនមែនផ្តោតទៅលើកុមារនោះទេ

ការផ្តល់រង្វាន់ និងដករង្វាន់ត្រូវកម្រិតនៃការប្រព្រឹត្ត ដើម្បីធានាថា៖

ក) អាកប្បកិរិយាខុសឆ្គងតិចតួច ឬមានលក្ខណៈរំភើបមិនគួរដោះស្រាយក្នុងលក្ខណៈធ្ងន់ធ្ងរពេកទេ

ខ) កុមារអាចមានឱកាសកែខ្លួន និងមិនប្រព្រឹត្តិអ្វីដែលខុសឆ្គងធ្ងន់ធ្ងរនោះឡើយ

គ) គ្រូផ្តល់យោបល់ និងគាំទ្រ

ឃ) កុមារអាចទទួលស្គាល់ពីកម្រិតនៃការផ្តល់ និងការដករង្វាន់ អាស្រ័យទៅលើការប្រព្រឹត្តិរបស់ពួកគេ

## ១០.២.៤ ការទទួលស្គាល់ សុំអភ័យទោស សំណង និងការផ្សះផ្សា

ជាវិធីដែលត្រូវអនុវត្តដើម្បីជួយកុមារឱ្យទទួលស្គាល់ពីកំហុសឆ្គងរបស់ពួកគេ និងកែលម្អកំហុសឆ្គងទាំងនោះ ។ កុមារចាំបាច់ត្រូវយល់ថា សកម្មភាពរបស់ពួកគេតែងនាំមកនូវផលប៉ះពាល់ ហើយពួកគេជាអ្នកទទួលខុសត្រូវក្នុងការធានាថាពួកគេត្រូវរកឱ្យឃើញពីកំហុសឆ្គងទាំងនោះ និងត្រូវធ្វើយ៉ាងណាកែប្រែវាឱ្យបានសមស្រប ។ ការដឹកនាំកុមារឱ្យឆ្លងកាត់លំនាំទាំងនេះជួយដល់ពួកគេឱ្យទទួលខុសត្រូវចំពោះអាកប្បកិរិយារបស់ខ្លួន និងស្វែងយល់អំពីរបៀបក្នុងការដោះស្រាយទំនាស់ ក៏ដូចជាស្ថានការណ៍ និងទំនាក់ទំនងនានាដែលបានប្រេះឆា ។

វិធីនេះមានដូចខាងក្រោម៖

**ក) ការទទួលស្គាល់៖** ជាការជួយកុមារឱ្យទទួលស្គាល់កំហុសឆ្គងនៃអាកប្បកិរិយា ឬសកម្មភាពរបស់ពួកគេ ព្រមទាំងផលប៉ះពាល់ចំពោះអ្នកដទៃ ដឹងថាអ្វីដែលពួកគេបានធ្វើគឺមិនសមស្រប ដឹងពីមូលហេតុ និង គុណតម្លៃរបស់កុមារដទៃទៀត ។

**ខ) ការសុំអភ័យទោស៖** កុមារគប្បីចេះនិយាយពាក្យ«សុំទោស»ទៅកាន់កុមារដែលទទួលរងផលប៉ះពាល់ដោយសារសកម្មភាពរបស់ខ្លួន។ ពួកគេត្រូវការធ្វើការសុំទោសដោយផ្ទាល់។

**គ) សំណង៖** ជាការសងនូវអ្វីដែលបានបាត់បង់ ។ នៅពេលដែលកុមារម្នាក់បានសម្តែងចេញនូវអាកប្បកិរិយាអវិជ្ជមានដល់អ្នកដទៃ វាមានសារៈសំខាន់ណាស់ដែលពួកគេត្រូវចេះកែប្រែស្ថានភាព នេះឱ្យល្អឡើងវិញ ។ ពួកគេត្រូវដោះស្រាយបញ្ហា និងត្រូវសងការខូចខាតសម្រាប់ផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីអាកប្បកិរិយារបស់ពួកគេ ។ បើមិនធ្វើដូច្នេះទេ ការនិយាយពាក្យសុំទោស នឹងលែងមានន័យ ។

- ការដករង្វាន់ មិនមែនជាការដាក់ទណ្ឌកម្មនោះទេ តែវាជាការកែលម្អ ។ ឧទាហរណ៍៖ នៅក្នុងស្ថានភាពដែលកុមារបានវាយដំ ឬបង្កការឈឺចាប់ដល់កុមារដទៃទៀត ពេលនោះពួកគេត្រូវគិតថាត្រូវធ្វើអ្វីមួយដែលជាសំណងចំពោះសកម្មភាពដែលបង្កនោះ ។ អ្វីដែលគេត្រូវតែបស្នងមានដូចជា៖ ត្រូវដងទឹកជំនួស ប្រាប់ស្មាឱ្យកុមារនោះ ។ល។
- សំណងជាជំហានដ៏សំខាន់ដើម្បីឈានទៅរកការផ្សះផ្សាគ្នា និងជួយឱ្យមានការកសាងទំនុកចិត្តគ្នាឡើងវិញ ។ ចំណុចនេះបញ្ជាក់ឱ្យឃើញពីភាពស្មោះត្រង់ និងភាពច្បាស់លាស់នៃពាក្យថា "សុំទោស" ហើយផ្តល់ឱកាសក្នុងការ កសាងទំនាក់ទំនងសារជាថ្មីឡើងវិញ។

**ឃ) ការផ្សះផ្សា៖** ជាឱកាសសម្រាប់ឱ្យភាគីរងគ្រោះអាចទទួលយកបាន និង មានទំនុកចិត្តសារជាថ្មីឡើងវិញ។ ចំណុចនេះមិនមែនកើតមានគ្រប់ពេលនោះទេ ហើយអាចនឹងត្រូវចំណាយពេលវេលាច្រើន ប៉ុន្តែវាគឺជាគោលដៅចុងក្រោយរបស់គ្រូបង្រៀន ។ ទំនាក់ទំនងនេះត្រូវស្តារឡើងវិញឱ្យបានប្រសើរតាមដែលអាចធ្វើបាន ។

វិធីនេះត្រូវអនុវត្តលើកុមារជាលក្ខណៈបុគ្គល និងត្រូវធ្វើឡើងដាច់ដោយឡែក មិនមែននៅចំពោះមុខកុមារជាច្រើនទេ។ វិធីនេះ ពិតជាជួយដោះស្រាយនូវស្ថានភាពនៃការប្រឈមមុខដាក់គ្នាដោយចេតនា។ ប្រសិនបើកុមារនៅតែបន្ត បដិសេធមិនធ្វើតាមការផ្សះផ្សាទៀតនោះ វិធីនេះនឹងត្រូវពង្រឹងបន្ថែមទៀត។

នៅពេលកុមារចម្រើនវ័យ ឬស៊ាំនឹងវិធីនេះ អ្នកដែលរងគ្រោះអាចនឹងត្រូវបានស្នើឱ្យផ្តល់នូវសំណូមពរសម្រាប់«ការកែលម្អ»។ ប្រការនេះនឹងមាន ប្រសិទ្ធភាពសម្រាប់ការស្តារឡើងវិញនូវទំនុកចិត្ត ប៉ុន្តែត្រូវយកចិត្តទុកដាក់ដើម្បីធានាថា ការណ៍នេះមិនមែនជា«ការសងសឹក»ឬគំនុំគុំគួនទេ។

## ១០.២.៥ ប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយា៖

ជាទូទៅយើងត្រូវការ «ប្រព័ន្ធ» ដើម្បីគាំទ្រដល់ការផ្តល់រង្វាន់ និងការដករង្វាន់ដើម្បីឱ្យមានភាពសមស្របទៅតាមអាកប្បកិរិយារបស់កុមារ និងធានាថាយើងអាចផ្តល់រង្វាន់លើកទឹកចិត្ត មិនមែនត្រឹមតែជា«ការសរសើរ»នោះទេ។ ការលើកទឹកចិត្តសិស្ស ជួយពួកគេឱ្យរៀនធ្វើការងារផ្សេងៗដើម្បីសម្រេចគោលបំណង ។ ពួកគេអាចស្វែងយល់ពីអ្វីដែលត្រូវធ្វើ និង ដឹងអំពីសារសំខាន់នៃការប្រព្រឹត្តសមស្របដើម្បីទទួលបានរង្វាន់ ក៏ដូចជាការទទួលខុសត្រូវរបស់ពួកគេក្នុងការបំពេញការងារជាក្រុមតូច ក្រុមធំ ឬថ្នាក់រៀន ព្រមទាំងជួយឱ្យកុមារយល់ដឹងអំពីសមធម៌ ភាតរភាព និងយុត្តិធម៌ក្នុងការទទួលបានរង្វាន់ទាំងនោះ ។

ឧទាហរណ៍ពីប្រព័ន្ធក្នុងថ្នាក់រៀនទាំងមូលសម្រាប់ការតាមដានអាកប្បកិរិយាសិស្ស៖

- ពិន្ទុ ឬផ្កាយរង្វាន់ (រង្វាន់ផ្សេងៗគ្នា ទៅតាមកម្រិតអាយុ)
- រូបភាពដូចជាមុខញញឹម មុខសប្បាយចិត្ត និងពិន្ទុ (អាចយកមកប្រើប្រាស់ដូចខាងលើ ឬប្រើជាសញ្ញាក្រើនរំឭក)
- ការផ្តល់រង្វាន់ជាក្រុមធំ ក្រុមតូច និងពិន្ទុ ជួយដល់ការប្រកួតប្រជែងការងារក្រុមតូចក្រុមធំ ។

## ១០.២.៦ ការសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមានជាមុន៖

ការសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមាន ជាជំហានដំបូងមុនពេលដល់ដំណាក់កាលដករង្វាន់ និងដកពិន្ទុពីកុមារដែលមានអាកប្បកិរិយាដែលមិនសមរម្យ ។ ជាធម្មតា ពេលយើងឃើញអាកប្បកិរិយាមិនសមរម្យណាមួយ យើងត្រូវកែលម្អចំពោះអាកប្បកិរិយានោះឱ្យទាន់ពេលវេលា ។

កុមារគ្រប់រូបចង់ទទួលបានការលើកទឹកចិត្ត ឬទទួលបានការសរសើរ ដូច្នេះក្នុងស្ថានភាពដែលពិនិត្យឃើញថាមានអាកប្បកិរិយាមិនសមរម្យណាមួយកើតឡើង គ្រូត្រូវព្យាយាមសរសើរកុមារដែលមានអាកប្បកិរិយាល្អដែលនៅក្បែរ កុមារដែលមានអាកប្បកិរិយាមិនសមរម្យនោះ ។ នេះគឺជាការឆ្លុះបញ្ចាំងពីលក្ខណៈវិជ្ជមាន ហើយក្រើនរំឭកតាមបែបវិជ្ជមានទៅដល់កុមារម្នាក់នោះ ក៏ដូចជាសិស្សក្នុងថ្នាក់ទាំងមូលផងដែរដើម្បីឱ្យពួកគេមានអាកប្បកិរិយាវិជ្ជមាន ។ ឧទាហរណ៍៖ គ្រូនិយាយថា៖ « គង់ កូនអង្គុយបានល្អណាស់!» «លីន កូនស្តាប់បានល្អ ហើយ ការយកចិត្តទុកដាក់របស់កូនពិតជាល្អខ្លាំងណាស់»។ ភាគច្រើន កុមារដែលមានអាកប្បកិរិយាមិនសមរម្យក៏ចង់ទទួលបាននូវការចាប់អារម្មណ៍ និងការសរសើរពីគ្រូផងដែរ ប្រសិនបើគេស្តាប់ឮកុមារដទៃទៀតទទួលបានការសរសើរ ដូចនេះពួកគេនឹងកែប្រែអកប្បកិរិយា ឬសកម្មភាពរបស់ពួកគេ ។ គ្រូចាំបាច់ត្រូវផ្តល់ការសរសើរភ្លាមៗ

ដល់កុមារ ដែលមានអាកប្បកិរិយាត្រឹមត្រូវ។ ចំណុចនេះអាចមានប្រសិទ្ធភាព ជាពិសេសសម្រាប់កុមារដែលពួកគេមានចរិតចូលចិត្តប្រកួតប្រជែង។

## ១០.២.៧ កៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)៖

កៅអីសញ្ជឹងគិត គឺជាវិធានការមួយដើម្បីធ្វើឱ្យកុមារម្នាក់ៗមាន «ចិត្តស្ងប់» និងផ្តល់ពេលវេលាដើម្បីពិចារណាឡើងវិញ ហើយបញ្ឈប់ការប្រព្រឹត្តិមិនសមរម្យរបស់ពួកគេ កុំឱ្យកើតឡើងវិញ។ របៀបនៃការប្រើប្រាស់កៅអីសញ្ជឹងគិតមានសារៈសំខាន់ណាស់។ ដើម្បីឱ្យវិធានការនេះមានប្រសិទ្ធភាព និងសមស្របគ្រូត្រូវគិតថាការប្រើកៅអីសញ្ជឹងគិត៖

- មិនមែនជាការដាក់ពិន័យនោះទេ
- ផ្តោតលើ «ការគិត» និង «ការធ្វើចិត្តស្ងប់» ពោលគឺផ្តោតលើ «បច្ចេកទេសក្នុងការធ្វើឱ្យ ចិត្តស្ងប់»។
- ចំណាំ៖
    - មិនត្រូវដាក់ងារដល់កុមារ
    - ត្រូវចែកឱ្យដាច់រវាងអាកប្បកិរិយា និងកុមារ
    - ត្រូវផ្តល់ជម្រើសឱ្យកុមារ
    - ប្រើប្រាស់ការគិត ការឆ្លុះបញ្ចាំង និងទុកពេលវេលាកែលម្អអាកប្បកិរិយា
    - បង្រៀនពួកគេឱ្យចេះជ្រើសរើសដោយខ្លួនឯង

## ១០.២.៨ វិធីធ្វើឱ្យចិត្តស្ងប់៖

វិធីធ្វើឱ្យចិត្តស្ងប់គឺដូចគ្នានឹងល្បែងថាមពលដែរ ប៉ុន្តែការធ្វើឱ្យស្ងប់ចិត្តមានគោលដៅធ្វើឱ្យកុមារផ្តោតអារម្មណ៍ជាជាង ធ្វើឱ្យពួកគេមានភាពសកម្ម ។ វិធីនេះត្រូវបានគេប្រើប្រាស់បន្ទាប់ពីពេលចេញលេង ឬនៅពេលដែលពួកគេមានការរំភើបចិត្តចំពោះបញ្ហាអ្វីមួយ ឬជាពិសេសនៅពេលដែលកុមារបាត់បង់ម្ចាស់ការលើខ្លួនឯងដោយសារតែការរំភើបចិត្ត និងការរំខាន។ វិធីនេះមានដូចជា៖

- ការធ្វើសមាធិ
- ការរាប់យឺតៗដល់លេខ១០
- អោបដៃ
- ដកដង្ហើមចេញចូលឱ្យវែង
- ល្បែងសត្វតោដេក ឱ្យសិស្សដាក់ក្បាលលើតុ ហើយព្យាយាមនៅស្ងៀមមួយកន្លែងតាមដែលអាចធ្វើបាន (សត្វតោដេក) ហើយគ្រូដើរចុះឡើង អ្នកដែលនៅស្ងាត់ស្ងៀម

បានយូរជាងគេគឺជាអ្នកឈ្នះ។

- និទានរឿងឱ្យសិស្សស្តាប់

ប្រព័ន្ធនៃការគ្រប់គ្រងថ្នាក់រៀន ជាពិសេសសម្រាប់សិស្សមត្តេយ្យសិក្សា ឬបឋមសិក្សា ត្រូវអនុវត្តជាប្រចាំ ។ នៅពេលដែលគេបង្កើតបានជាមូលដ្ឋានគ្រឹះរឹងមាំហើយ ដំណើរការនេះគ្រាន់តែធ្វើជាការក្រើនរំឭកយូរៗម្តងប៉ុណ្ណោះ ។

# មេរៀនទី១១
# ការគ្រប់គ្រងអាកប្បកិរិយា

## វត្ថុបំណង៖

វត្ថុបំណងរបស់មេរៀននេះគឺដើម្បីស្វែងយល់ និងរៀនសូត្រពីរបៀបរៀបចំ និងអនុវត្តផែនការគ្រប់គ្រងវិបត្តិអាកប្បកិរិយា ដើម្បីគ្រប់គ្រងវិបត្តិអាកប្បកិរិយារបស់កុមារពិការនៅថ្នាក់មត្តេយ្យសិក្សា និងថ្នាក់បឋមសិក្សា។

## និយមន័យ៖

ដូចដែលបានរៀបរាប់នៅក្នុងការសិក្សាស្រាវជ្រាវ និងជំនាញខាងអក្សរសាស្ត្រ «វិបត្តិអាកប្បកិរិយា»គឺជា អាកប្បកិរិយាដែលបង្កឱ្យមានការខ្វល់ខ្វាយ រំខាន សំឡុត បង្កបញ្ហា និងឬគំរាមកំហែងដល់អ្នកដទៃ ដែលអាចបង្ហាញតាមរយៈរាងកាយ ពាក្យសម្ដី ការសរសេរ ឬសកម្មភាពជាក់លាក់នានារបស់សិស្ស។ ឧទាហរណ៍ខ្លះៗមានដូចខាងក្រោម៖

- អាកប្បកិរិយាដែលតែងតែមានការរំខានដល់បរិយាកាស ឬការគ្រប់គ្រងថ្នាក់រៀន
- ការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ទាក់ទងនឹងលទ្ធផលនៃការសិក្សា ឧទាហរណ៍ ការរៀបចំមិនបានល្អ ឬ មិនមានសង្គតិភាព
- ការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ចំពោះអាកប្បកិរិយា ឬរូបរាងកាយ
- ខ្សោយក្នុងការគិត (គំនិត) ពេលគឺទាំងការនិយាយ ឬទាំងការសរសេរ
- អាកប្បកិរិយាកាចសាហាវខ្លាំងពេកចំពោះអ្នកផ្សេងទៀត មិនអាចរៀបចំដែនកំណត់ ឬ មិនអាចផ្ដោតអារម្មណ៍ឡើងវិញ
- មិនសូវមានជំនាញក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងការដោះស្រាយបញ្ហា
- អាកប្បកិរិយាមិនសមរម្យ ចម្លែក ឬខុសពីធម្មតា
- មានការអត់ធ្មត់តិចតួចនៅពេលជួបប្រទះឧបសគ្គ(ការរារាំង)ផ្សេងៗ
- មានប្រតិកម្មជ្រុលហួសហេតុចំពោះកាលៈទេសៈផ្សេងៗ
- មិនងាយមានអារម្មណ៍ធម្មតាវិញ (បន្ទាប់ពីខឹង ភ័យ ។ល។)
- ការសរសេរ ឬការនិយាយដែលបង្កឱ្យមានអំពើហិង្សា ចូលចិត្តប្រើអំពើហិង្សា
- ការគំរាមកំហែងដោយសារការសរសេរ ឬការប្រើពាក្យសំដីដោយផ្ទាល់ ឬដោយប្រយោល (ចំពោះខ្លួនឯង ឬចំពោះអ្នកដទៃ)
- ពុំមានភាពអាណិតអាសូរ និងបារម្ភពីអ្នកដទៃ មិនអាចមើលថៃ(ខ្លួនឯង ឬអ្នកដទៃ)
- មិនអាចគ្រប់គ្រងកំហឹងបាន

- មានលក្ខណៈតក់ស្លុត តឹងតែង ឬធាប់យំ
- ការបង្ហាញគំនិតចង់ធ្វើអត្តឃាត ឬអារម្មណ៍អស់សង្ឃឹម។

## ការគ្រប់គ្រងវិបត្តិអាកប្បកិរិយាៈ

នៅក្នុងកម្មវិធីស្តីពីការគ្រប់គ្រងវិបត្តិអាកប្បកិរិយា "ការគ្រប់គ្រងអាកប្បកិរិយាដែលមិនចង់បាន" ត្រូវបានគេកំណត់និយមន័យយ៉ាងច្បាស់លាស់ ទិន្នន័យត្រូវបានគេប្រមូលនៅមុនពេល និងក្នុងពេលរៀបចំកម្មវិធីអន្តរាគមន៍ ការវាយតម្លៃ ពីការធ្វើអន្តរាគមន៍ត្រូវបានគេធ្វើឡើង ហើយក្នុងករណីដែលការធ្វើអន្តរាគមន៍មិនទទួលបានជោគជ័យ វិធីនៃការធ្វើអន្តរាគមន៍នឹងត្រូវបានគេកែសម្រួល។ ជំហានសំខាន់ៗចំនួន៥សម្រាប់អនុវត្ត កម្មវិធីគ្រប់គ្រងវិបត្តិអាកប្បកិរិយា។ ជំហានទាំងនោះមានៈ

1. *ការកំណត់ពីវិបត្តិអាកប្បកិរិយា*
2. *ការកំណត់ចំណុចដៅវិបត្តិអាកប្បកិរិយា*
3. *ការកត់ត្រាទុកពីអាកប្បកិរិយា*
4. *ការវិភាគមុខងារ*
5. *វិធីនៃការធ្វើអន្តរាគមន៍*

## ១. ការកំណត់ពីវិបត្តិអាកប្បកិរិយា

ឪពុកម្តាយ គ្រូបង្រៀន ឬអាណាព្យាបាលអាចត្អូញត្អែរពីអាកប្បកិរិយារបស់កុមារ។ ភារកិច្ចដំបូងរបស់អ្នកព្យាបាលចលនា គឺត្រូវរៀបចំបញ្ជីមួយស្តីពីវិបត្តិអាកប្បកិរិយាដែលកុមារពិការបានបង្ហាញ។ ការកំណត់នេះអាចធ្វើទៅបានតាមរយៈការប្រើប្រាស់បញ្ជីពិនិត្យផ្ទៀងផ្ទាត់ពីអាកប្បកិរិយា ឬការសង្កេតពីអាកប្បកិរិយា។

## ២. ការកំណត់គោលដៅ នៅក្នុងវិបត្តិអាកប្បកិរិយាៈ

ការកំណត់នេះពាក់ព័ន្ធនឹងជំហានចំនួន៣ដូចខាងក្រោមៈ

- វិបត្តិអាកប្បកិរិយា ត្រូវបានរកឃើញដោយកំណត់ការប្រើប្រាស់ពាក្យពេចន៍ដែលអាចសង្កេតបាន ជាវត្ថុបំណង និងអាចវាស់វែងបាន។
- រៀបចំកម្រិតនៃអាកប្បកិរិយាទៅតាមការបង្ហាញរបស់កុមារដោយផ្អែកទៅលើភាពធ្ងន់ធ្ងររបស់បញ្ហា និងតម្រូវការជាក់លាក់របស់កុមារ ឬអ្នកថែរក្សាម្នាក់។

➢ ការជ្រើសរើសចំណុចដៅ គោលដៅនៃការធ្វើអន្តរាគមន៍ត្រូវតែមានលក្ខណៈច្បាស់លាស់។ ដំបូង គេត្រូវជ្រើសរើសវិបត្តិអាកប្បកិរិយា ដែលគេត្រូវកំណត់ជាមុនសិន ហើយបន្ទាប់មកគេត្រូវកំណត់វាជាចំណុចដៅនៃអាកប្បកិរិយាដែលគេត្រូវកែលម្អ។ ការព្យាយាមគ្រប់គ្រងវិបត្តិអាកប្បកិរិយាទាំងអស់ក្នុងពេលតែមួយនឹងមិនអាចសម្រេចជោគជ័យទេ។ គេអាចដោះស្រាយវិបត្តិអាកប្បកិរិយាចំនួន២-៣ជាមុនសិនដោយយោងទៅលើកម្រិតនៃអាកប្បកិរិយាដែលបានកំណត់។

## ៣. ការកត់ត្រាទុកពីអាកប្បកិរិយា៖

ការកត់ត្រាទុកពីអាកប្បកិរិយាមានសារសំខាន់ណាស់ក្នុងការគ្រប់គ្រងវិបត្តិអាកប្បកិរិយា។ ការកត់ត្រាទុកនេះមានសារសំខាន់សម្រាប់ការត្រួតពិនិត្យមើលពីការផ្លាស់ប្តូរនានាចំពោះចំណុចដៅរបស់អាកប្បកិរិយា ក៏ដូចជាសម្រាប់ការវាយតម្លៃពីប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍ជាបន្តបន្ទាប់ដែរ។

ការកត់ត្រាទុកពីការសង្កេតត្រូវបានគេប្រើប្រាស់ជាទូទៅបំផុតសម្រាប់កុមារពិការ។ ប្រភេទនៃកំណត់ត្រាដែលបានសង្កេត ត្រូវបានគេប្រើប្រាស់ដោយផ្អែកទៅលើប្រភេទនៃអាកប្បកិរិយាដែលគេបានកត់ត្រាទុក។ ភាពញឹកញាប់របស់អាកប្បកិរិយាផ្សេងៗត្រូវកត់ត្រាទុកនៅក្នុងចន្លោះពេលជាក់លាក់។ ចំណុចលម្អិត នៃផ្នែកទាំងនេះមានដូចខាងក្រោម៖

➢ **ភាពញឹកញាប់៖** គេត្រូវរាប់ចំណុចដៅរបស់អាកប្បកិរិយារៀងរាល់ពេលដែលវាកើតឡើង។
➢ **រយៈពេល៖** គេត្រូវកត់ត្រាទុកនូវរយៈពេលរបស់ចំណុចដៅនៃអាកប្បកិរិយាជាវិនាទី នាទី ឬម៉ោង។ ឧទាហរណ៍ យំ ចំនួន៤ដង ឬកុមារកំពុងអង្គុយនៅក្នុងថ្នាក់រៀនរយៈពេល៩នាទី។
➢ **ការកត់ត្រាទុកពីចន្លោះពេលវេលា៖** គេត្រូវបែងចែករយៈពេលសរុបនៃការសង្កេតទៅតាមចន្លោះ ពេលវេលាស្មើៗគ្នា ហើយគេត្រូវកត់សម្គាល់ថាតើចំណុចដៅនៃអាកប្បកិរិយាបានកើតឡើងដែរឬទេនៅក្នុងចន្លោះនៃរយៈពេលនីមួយៗ។ ការធ្វើដូច្នេះផ្តល់នូវសូចនាករមួយសម្រាប់ភាពញឹកញាប់ និងរយៈពេលរបស់អាកប្បកិរិយាដែលគេបានសង្កេត ក៏ដូចជាលំដាប់លំដោយរបស់ព្រឹត្តិការណ៍នានាដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងវិធីសាស្ត្រនេះ ការកត់ត្រាទុកជាប្រចាំមានការលំបាក ហើយវិធានការជាក់លាក់សម្រាប់ភាពញឹកញាប់ និង រយៈពេលគឺមិនអាចធ្វើទៅបានទេ។
➢ **សំណាកពេលវេលា៖** ដោយសារការលំបាកទាក់ទងនឹងការកត់ត្រាទុកជាប្រចាំនូវទិន្នន័យមូលដ្ឋានសំណាកពេលវេលានៃចំណុចដៅរបស់អាកប្បកិរិយាត្រូវបានគេប្រើប្រាស់។ មធ្យោបាយមួយនៃការធ្វើសំណាកគឺត្រូវសង្កេតកុមារនៅចុងបញ្ចប់នៃចន្លោះពេលវេលាជាក់លាក់មួយ។ ចំណុចនេះនឹងពឹងផ្អែកទៅលើភាពញឹកញាប់នៃចំណុចដៅរបស់អាកប្បកិរិយាក៏ដូចជាពេលវេលា ដែលត្រូវចំណាយ។

## ៤. ការវិភាគមុខងារ

ទំនាក់ទំនងរវាងអាកប្បកិរិយា និង បរិយាកាសសង្គមដែលកើតឡើងដោយផ្ទាល់ត្រូវបានគេវិភាគ។ ការវិភាគពីមុខងារ កំណត់នូវចំណុចនានានៅក្នុងបរិយាកាសដែលបង្កឱ្យមានបញ្ហា ឬចំណុចនានាដែលបង្កើននូវវិបត្តិអាកប្បកិរិយាឱ្យកើតឡើងម្តងហើយម្តងទៀត។ សរុបសេចក្តីមកការវិភាគពីមុខងារទាក់ទងជាប្រព័ន្ធទៅនឹង កាលៈទេសៈ អាកប្បកិរិយា និង ផលវិបាក ដូចខាង ក្រោម៖

- កាលៈទេសៈឬព្រឹត្តិការណ៍នានាដែលកើតឡើងភ្លាមៗមុនពេលអាកប្បកិរិយា ឬបរិយាកាសនានាកើតមានឡើង។
- អាកប្បកិរិយា ភាពញឹកញាប់ រយៈពេល និងកម្រិតសកម្មភាពរបស់វា
- ផលវិបាក ឬព្រឹត្តិការណ៍ដែលកើតមានបន្ទាប់ពីអាកប្បកិរិយាជាក់លាក់។

## ៥. វិធីនៃការធ្វើអន្តរាគមន៍

បន្ទាប់ពីកត់ត្រាទុកនូវវិធានការផ្អែកទិន្នន័យមូលដ្ឋាន និងវិភាគពីកាលៈទេសៈ និងផលវិបាករបស់អាកប្បកិរិយារួចហើយ គេត្រូវរៀបចំផែនការសម្រាប់ការគ្រប់គ្រងអាកប្បកិរិយា។ វិធីនៃការព្យាបាលទាំងអស់ត្រូវពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរកាលៈទេសៈ ឬការផ្លាស់ប្តូរផលវិបាក។

ឧទាហរណ៍មួយនៃការផ្លាស់ប្តូរកាលៈទេសៈត្រូវបានគេបង្ហាញនៅក្នុងករណីរបស់តារា។ នៅពេលតារារំខាន មិត្តរួមថ្នាក់របស់គេតាមរយៈការក្តិចអ្នកដែលអង្គុយជិតគាត់នៅក្នុងថ្នាក់រៀន វិធីសាស្រ្តមួយក្នុងការផ្លាស់ប្តូរកាលៈទេសៈគឺត្រូវឱ្យតារាអង្គុយជិតគ្រូបង្រៀន ឬឱ្យគាត់អង្គុយតែម្នាក់ឯងដើម្បីកាត់បន្ថយអាកប្បកិរិយារបស់គាត់។

ឧទាហរណ៍មួយនៃការផ្លាស់ប្តូរផលវិបាកត្រូវបានគេបង្ហាញនៅក្នុងករណីរបស់តារា។ ពេលណាក៏ដោយដែលគេគប់វត្ថុផ្សេងៗក្នុងពេលដែលកំពុងខឹងខ្លាំង ម្តាយរបស់គាត់លួងលោមគាត់ភ្លាមៗ។ ផលវិបាកជាវិជ្ជមាននេះបណ្តាលមកពីការកើនឡើងនូវអាកប្បកិរិយាដែលពោរពេញដោយកំហឹងរបស់តារា។ នីតិវិធីនៃការគ្រប់គ្រងដែលគេប្រើប្រាស់ដើម្បីបញ្ឈប់អាកប្បកិរិយានេះទាក់ទងនឹងការផ្តល់ដំបូន្មានរបស់ម្តាយតារាក្នុងការធ្វើមិនអើពើពីកុមារ(បន្ថយផលវិបាកជាវិជ្ជមាននៃការយំរបស់កុមារ) ឬប្រើប្រាស់អន្តរាគមន៍ដែលបានកំណត់។

## បច្ចេកទេសសម្រាប់ការកាត់បន្ថយវិបត្តិអាកប្បកិរិយា៖

វិធីខាងក្រោមត្រូវបានគេមើលឃើញថាមានប្រយោជន៍ក្នុងការកាត់បន្ថយវិបត្តិអាកប្បកិរិយា។

- **រៀបចំរចនាសម្ព័ន្ធបរិយាកាសឡើងវិញ៖** ការកើតឡើងនូវអាកប្បកិរិយាណាមួយគឺជាផ្នែកមួយនៃកាលៈទេសៈបច្ចុប្បន្ន និងអតីតកាល។ ចំណុចនេះគេហៅថា«ការគ្រប់គ្រងទម្លាប់»។ ការគ្រប់គ្រងនេះគឺជាឧបករណ៍ដ៏មានសក្តានុពលមួយក្នុងការកាត់បន្ថយវិបត្តិអាកប្បកិរិយា។ ឧទាហរណ៍ ប្រសិនបើកុមារម្នាក់មានអារម្មណ៍មិនមូលនៅក្នុងថ្នាក់ ហើយកំពុងនិយាយជាមួយមិត្តភក្តិរបស់គេនៅក្នុងថ្នាក់ដោយចំណាយពេលតិចតួចទៅលើកិច្ចការងារដែលខ្លួនមានអាកប្បកិរិយាបែបនេះ អាចកាត់បន្ថយដោយឱ្យគាត់អង្គុយឆ្ងាយពីគេ ឬការដាក់របាំងជុំវិញកុមារនោះ។ ការធ្វើដូចនេះអាចកាត់បន្ថយកម្លាំងជំរុញនៃការមានអារម្មណ៍មិនមូលនៅក្នុងថ្នាក់រៀន។ ហេតុដូច្នេះហើយ ប្រសិនបើវាក្លាយទៅជាភស្តុតាងមួយនៅពេលធ្វើការវិភាគពីមុខងារថា ជាវិបត្តិអាកប្បកិរិយាកើតឡើងតែក្នុងបរិយាសកាសជាក់លាក់មួយប៉ុណ្ណោះ មិនមែនក្នុងបរិយាកាសផ្សេងៗទៀតទេ ពេលនោះការរៀបចំឡើងវិញនូវបរិយាកាសនោះនឹងកាត់បន្ថយនូវការកើតមាននូវចំណុចដៅរបស់អាកប្បកិរិយាដែលទំនងជាកើតមាន។ ការរៀបចំបរិយាកាសឡើងវិញចាំបាច់ត្រូវតែរួមបញ្ចូលជាមួយនឹងកម្មវិធីលើកទឹកចិត្តជាវិជ្ជមាននូវអាកប្បកិរិយាសមស្រប ព្រមទាំងដកចេញនូវរង្វាន់វិញ ប្រសិនបើវិបត្តិអាកប្បកិរិយាកើតឡើងនៅក្នុងបរិយាកាសថ្មីទៀត (ការផ្តល់រង្វាន់ខុសគ្នា)។

- **ការលុបបំបាត់៖** គេមានលទ្ធភាពក្នុងការកាត់បន្ថយភាពញឹកញាប់របស់អាកប្បកិរិយាមួយបានតាមរយៈការមិនបង្ហាញការផ្តល់រង្វាន់អាកប្បកិរិយាភ្លាមៗ។ ដំណើរការនេះគេហៅថាការលុបបំបាត់។ ឧទាហរណ៍ កុមារអាយុ៨ឆ្នាំម្នាក់តែងមានកំហឹងជាប់ជាប្រចាំដោយការគ្រហឹមខ្លាំងៗនៅពេលដែលគេសុំឱ្យ អានអក្សរ។ ទង្វើរបៀបនេះបណ្តាលឱ្យគ្រូបង្រៀនបោះបង់ចោលនូវការផ្តល់ភារកិច្ចនោះឱ្យគេ។ ការវិភាគពីដំណើរការលើកឡើងថា កំហឹងរបស់កុមារនោះកំពុងត្រូវបានពង្រឹងបន្ថែម(គ្រូបង្រៀនបោះបង់ភារកិច្ចនោះ)តាមរយៈការមិនអនុញ្ញាតឱ្យកុមាររួចផុតពីភារកិច្ចដែលគេមិនពេញចិត្តដោយការស្រែករបស់គេ។ វិធីលុបបំបាត់សម្រាប់កុមារនោះគឺពាក់ព័ន្ធទៅនឹងការមិនបង្ហាញវត្តមាននៃការផ្តល់រង្វាន់ទៅលើការគ្រហឹម ពោលគឺត្រូវបន្តភារកិច្ចក្នុងការអាន ទោះបីជាគាត់ខឹងក៏ដោយ។

- **វិធីនៃការធ្វើអន្តរាគមន៍ដែលមានដែនកំណត់ជាក់លាក់៖** ចំណុចនេះមានន័យថាគឺ ណែនាំពីផលវិបាកផ្សេងៗសម្រាប់អាកប្បកិរិយាមួយដែលកាត់បន្ថយភាពដែលអាចកើតមានឡើងនៅពេលអនាគត។ ក្នុងពេលធ្វើការវិភាគពីសកម្មភាព កម្លាំងជំរុញនៃការដាក់វិន័យសម្រាប់កុមារនៅក្នុងស្ថានភាពជាក់លាក់មួយចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់។ ប្រសិទ្ធភាពនេះអាច

ជាកស្តុតាងសម្រាប់ការប្រើប្រាស់ប៉ុណ្ណោះ។ នីតិវិធីនៃការដាក់ពិន័យគួរត្រូវបានគេពិនិត្យមើល ភ្លាមៗ និងជាប់ជាប្រចាំ បន្ទាប់ពីវិបត្តិអាកប្បកិរិយាកើតឡើង។ ប្រភេទនៃនីតិវិធីក្នុងការធ្វើ អន្តរាគមន៍ដែលមានដែនកំណត់ជាក់លាក់ជាទូទៅរួមមាន៖ ការផ្អាកសកម្មភាព( អស់ពេល) សងការខូចខាត ការឱ្យកែសម្រួលឡើងវិញ ការដាក់កម្រិត និងការមិនអនុញ្ញាត។

o **ការផ្អាកសកម្មភាព៖**

ចំណុចនេះមានន័យថាការផ្អាកសកម្មភាពពីការអនុវត្តបែបវិជ្ជមាន។ នៅពេលដែលវិបត្តិ អាកប្បកិរិយា មានសភាពគ្រោះថ្នាក់ ឬធ្វើឱ្យរបួសដល់ខ្លួនឯង នីតិវិធីនានាដូចជាការលុប បំបាត់មិនគប្បីប្រើឡើយ។ ដូច្នេះគេអាចប្រើប្រាស់នីតិវិធីនៃការដាក់វិន័យដូចជាការ បញ្ឈប់សកម្មភាពបាន។ គេអាចប្រើប្រាស់ការបញ្ឈប់សកម្មភាពតាមមធ្យោបាយផ្សេងៗ ជាច្រើន។ ប្រសិនបើការអនុវត្តបន្ថែមដែលពាក់ព័ន្ធនឹងការលើកសរសើរ ឬការចូលរួមក្នុង សង្គម ការបញ្ឈប់សកម្មភាពពាក់ព័ន្ធនឹងការនាំកុមារឱ្យចេញឆ្ងាយពីតុអាហារ ឬយកចាន អាហារចេញ។ គេអាចប្រើប្រាស់ការបញ្ឈប់សកម្មភាពនៅក្នុងស្ថានភាពណាមួយដែលការ ផ្តល់រង្វាន់ត្រូវបានគេផ្តល់ឱ្យ។ ការផ្តល់រង្វាន់ត្រូវបានគេដកចេញក្នុងពេលដែលមានវិបត្តិ អាកប្បកិរិយាកើតឡើង។

o **សំណងការខូចខាត៖**

គេប្រើប្រាស់នីតិវិធីនេះសម្រាប់កុមារជាលក្ខណៈបុគ្គល ដែលកំពុងចូលរួមនៅក្នុងកម្មវិធី សម្រាប់ការបង្រៀនពីការកែលម្អអាកប្បកិរិយា។ នៅពេលមានវិបត្តិអាកប្បកិរិយាកើត ឡើងចំនួនសញ្ញាជាក់លាក់ដូចជា ផ្កាយ ពិន្ទុ ត្រូវដកយកវិញពីកុមារម្នាក់ៗ ដែលបាន ទទួលរួចហើយ។ គេអាចប្រើប្រាស់នីតិវិធីនេះជាការដាក់វិន័យសម្រាប់មាន ការរំខាន ការ ប្រើប្រាស់ភាសាដែលមានលក្ខណៈរំលោភបំពាន ឬការមកថ្នាក់រៀនមិនទាន់ពេលវេលា។

o **ការកែតម្រូវឡើងវិញ៖**

ចំណុចនេះទាក់ទងនឹងនីតិវិធីចំនួន២ដាច់ពីគ្នា

១. ការសង

២. ការអនុវត្តបែបវិជ្ជមាន

សម្រាប់វិបត្តិអាកប្បកិរិយា គេអាចប្រើប្រាស់នីតិវិធីទាំង២នេះ ប៉ុន្តែចំពោះអាកប្បកិរិយា នៃកម្លាំងជំរុញដោយខ្លួនឯងមួយចំនួន គេអាចប្រើប្រាស់បានសម្រាប់តែការអនុវត្តបែប វិជ្ជមានប៉ុណ្ណោះ។ សំណងមានន័យថា ការស្តារឡើងវិញនូវការរំខានលើសពីលក្ខខណ្ឌ ធម្មតា ហើយការអនុវត្តបែបវិជ្ជមានពាក់ព័ន្ធនឹងការអនុវត្តនូវវិធីដែលសមស្របសម្រាប់ ការឆ្លើយតបទៅនឹងស្ថានភាពដែលកុមារម្នាក់ៗបានប្រព្រឹត្តខុសជាទូទៅ។ ឧទាហរណ៍ ប្រសិនបើកុមារម្នាក់ញ៉ាំមិនរើសមុខ សូម្បីតែសំរាមអ្វីដែលគេរើសបាននៅលើដី ការកែ

លម្អឡើងវិញនូវសំណងត្រូវពាក់ព័ន្ធនឹងការបន្ថែមពេលវេលាក្នុងការដុស ធ្មេញ លាងមាត់ និងលាងដៃជាមួយនឹងសាប៊ូ ឬថ្នាំសម្លាប់មេរោគ(រយៈពេល២០នាទី)នៅពេលណាក៏ដោយដែលអាកប្បកិរិយារបៀបនេះកើតឡើង។ ជាទូទៅ ការអនុវត្តបែបវិជ្ជមានដែលគេធ្វើឡើងបន្ទាប់ពីសំណងក្នុងការបន្ថែមពេលវេលា(ចំនួន២០នាទី)សម្រាប់មធ្យោបាយដែលសមស្របនានា ដើម្បីដោះស្រាយបញ្ហាសំរាម ដូចជាបោសសម្អាតសំរាម ជូតសម្អាតការបោះសំរាមចោលជាដើម ។ល។

**០ ការដាក់កម្រិតៈ**

ការដាក់កម្រិតផ្នែករាងកាយមានប្រសិទ្ធភាពក្នុងការកាត់បន្ថយអាកប្បកិរិយានានាដូចជាការ រំលោភបំពានផ្នែករាងកាយ និងការធ្វើឱ្យមានរបួសលើខ្លួនឯង។ ការដាក់កម្រិតនេះអាចមាន ភាពខុសគ្នាទៅតាមកុមារម្នាក់ៗដូចជាឱ្យកុមារអង្គុយនៅលើកៅអីមួយ សង្កត់ដៃកុមារចុះឱ្យជាប់ដើម្បីឱ្យកុមារនៅកន្លែងរបស់គាត់មួយរយៈពេលខ្លី ទប់ក្បាលរបស់កុមារឱ្យជាប់ដោយដៃទាំង២របស់គ្រូបណ្តុះបណ្តាល គាបក្បាលរបស់កុមារនឹងជង្គង់របស់គេឱ្យជាប់ ។ល។

**០ ការមិនអនុញ្ញាតៈ**

ជាទូទៅគេប្រើប្រាស់វិធីនេះតែនៅពេលណាដែលវិធីបង្រៀនផ្សេងៗទៀតទទួលបរាជ័យក្នុងការគ្រប់គ្រងវិបត្តិអាកប្បកិរិយា។ អាកប្បកិរិយាដែលមានការគម្រាមកំហែងដល់អាយុជីវិត ឬធ្វើឱ្យមានរបួសស្នាមលើខ្លួនឯងដូចជាការបោកក្បាលខ្លាំងៗ ការក្អួតចង្អោរជាប់ជាប្រចាំ និងការខាំត្រូវបានគេគ្រប់គ្រងដោយប្រើកម្លាំងជំរុញ។ គេត្រូវពិនិត្យមើលជាបន្ទាន់នូវកម្លាំង ជម្រុញ ( ថាមពលដែលប្រតិបត្តិ ការរន្ធត់តិចតួច) Faradic aversion (Battery operated mild shock) គឺជាការរៀបចំគ្រប់គ្រងលើអាកប្បកិរិយាដែលមិនចង់ឱ្យកើតឡើង។

កម្លាំងជំរុញផ្នែកសារធាតុគីមីមិនល្អដែលអាចកើតមានដូចជាក្លិនឈ្ងុលខ្លាំង(អាម៉ូញ៉ាក់) សារធាតុដែលមានរសជាតិជូរ ឬល្វីងអាចត្រូវបានគេបង្ហាញជាជាងការធ្វើឱ្យកុមារតូចៗមានភាពតក់ស្លុត។

ជាទូទៅ គេត្រូវប្រើប្រាស់វិធីនៃការធ្វើអន្តាគមន៍ដែលមានដែនកំណត់ទាំងអស់ដោយរួមបញ្ចូលគ្នាជាមួយកម្មវិធីអនុវត្តបន្ថែមខុសៗគ្នា សម្រាប់ការផ្តល់រង្វាន់ដល់វិបត្តិអាកប្បកិរិយាបច្ចុប្បន្ន។

➢ **ការផ្តល់រង្វាន់ផ្សេងទៀត៖**

កម្មវិធីផ្តល់រង្វាន់ខុសគ្នាទាក់ទងនឹងការផ្តល់រង្វាន់ជាវិជ្ជមានចំពោះការកើតឡើងនូវអាកប្ប-កិរិយាសមស្របដែលគេបានបញ្ជាក់ជាមុន អវត្តមានអាកប្បកិរិយាដែលចង់បានសម្រាប់រយៈពេលជាក់លាក់ ការកើតឡើងនូវអាកប្បកិរិយាដែលមិនស្របនឹងចំណុចដៅរបស់អាកប្បកិរិយាដែលគេត្រូវកាត់បន្ថយ និងការកើតឡើងនូវវិបត្តិអាកប្បកិរិយាមានកម្រិតទាបដែលត្រូវបានគេកត់ត្រាទុក។

ការផ្តល់រង្វាន់ផ្សេងៗគ្នានៃការកែលម្អអាកប្បកិរិយា ឬអាកប្បកិរិយាដែលចង់បាននៅពេលដែលការដាក់ពិន័យត្រូវបានគេអនុវត្តដើម្បីកាត់បន្ថយវិបត្តិអាកប្បកិរិយា។ បើមិនដូច្នេះទេវិបត្តិអាកប្បកិរិយានឹងនៅតែមានដដែល ដោយសារការខ្វះជំនាញក្នុងការកែលម្អអាកប្បកិរិយា និងបំណិនមានកម្រិត។

ការបង្ហាញករណីសិក្សា៖ ការគ្រប់គ្រងវិបត្តិអាកប្បកិរិយា

តារាគឺជាកុមារដែលមានអាយុ៩ឆ្នាំ។ គេបាននាំគាត់មកកាលពី១ឆ្នាំមុនដោយមានការត្អូញត្អែរមួយចំនួនទាក់ទងនឹងការមិនអាចទំពារអាហារបាន សម្លឹងមើលអ្វីដោយភាពសង្ស័យ និងមិនមានការប្រាស្រ័យទាក់ទងដោយក្រសែភ្នែក ដំណើរការនៃការគ្រប់គ្រងរបស់ពោះវៀនមិនបានល្អ មិនអាចញ៉ាំអាហារបានដោយខ្លួនឯង រពឹសខ្លាំង ស្រែកយំ មិនចុះសម្រុងជាមួយអ្នកផ្សេង។ ការវិវឌ្ឍការនិយាយស្ដីមានភាពយឺតយ៉ាវ និងមិនចេះសហការក្នុងសកម្មភាពណាមួយ។

តាមប្រវត្តិបង្ហាញថាតារាកើតមិនគ្រប់ខែទេ ការសម្រាលមិនតាមធម្មតា ហើយការវិវឌ្ឍតាមកម្រិត អាយុក៏មានភាពយឺតយ៉ាវដែរ។ ម្ដងម្កាល វាបង្ហាញពីបញ្ហាពោះវៀន និងប្លោកនោម ប្រសិនបើម្ដាយរបស់គេនៅជិត។ ការវិភាគផ្នែកចិត្តសាស្ត្រលម្អិតបង្ហាញថា កុមារនេះមានIQ ចំនួន២៣ ហើយការធ្វើរោគវិនិច្ឆ័យពីកម្រិតពិការភាពសតិបញ្ញាធ្ងន់ធ្ងរផ្នែកអូទីសឹមត្រូវបានគេធ្វើឡើង។ ចំពោះការវិភាគពីការអប់រំពិសេសវិញបង្ហាញថា តារាពឹងផ្អែកលើអ្នកដទៃទាំងស្រុងនៅគ្រប់សកម្មភាពទាំងអស់ ដោយរាប់បញ្ចូលទាំងបំណិនក្នុងការជួយខ្លួនឯង ហើយត្រូវបានគេដាក់ឱ្យនៅក្នុងក្រុមដែលត្រូវការការមើលថែឱ្យបានជិតដល់។ ការពិនិត្យផ្នែកវេជ្ជសាស្ត្រពុំបានបង្ហាញឱ្យ ឃើញនូវភាពធ្ងន់ធ្ងរណាមួយទេ ហើយគេក៏មិនអាចដឹងពីប្រភពជាក់លាក់ដែរ។

ផែនការគ្រប់គ្រងរួមមានការបណ្តុះបណ្តាលតារាពីបំណិនសម្រាប់ជួយខ្លួនឯង បំណិនផ្នែកភាសា បំណិនប្រាស្រ័យទាក់ទងក្នុងសង្គម និងការគ្រប់គ្រងវិបត្តិអាកប្បកិរិយា។ គេបានរៀបចំផែនការដោយបានផ្តល់អាទិភាពទៅលើការគ្រប់គ្រងវិបត្តិអាកប្បកិរិយាមុនពេលចាប់ផ្តើមកម្មវិធីអន្តរាគមន៍ផ្សេងៗទៀត ដើម្បីឱ្យកុមារនេះមានការសហការកាន់តែច្រើន និងឆ្លើយតបបានកាន់តែប្រសើរទៅនឹងការបណ្តុះបណ្តាល។

ការវាយតម្លៃពីអាកប្បកិរិយាលម្អិតមួយបង្ហាញថា កុមារនេះមានវិបត្តិអាកប្បកិរិយាដូចខាងក្រោម៖ រពឹសខ្លាំង ស្រែកគ្រហឹមខ្លាំង គេធ្វើឱ្យខឹង មិនចូលចិត្តកន្លែងថ្មី ខ្លាចមនុស្សចម្លែក យំជាប់ជាប្រចាំ និងឱបម្តាយរបស់គេជាប់ វាយអ្នកដែលនៅជុំវិញខ្លួននៅពេលដែលគេបង្ខំឱ្យវាធ្វើសកម្មភាពអ្វីមួយ និងបង្ហាញអារម្មណ៍មួម៉ៅ។

ពីដំបូង គេជ្រើសរើសយកចំណុចដៅអាកប្បកិរិយាចំនួន៣សម្រាប់ការគ្រប់គ្រងដែលមានដូចជាការយំខ្លាំងហួសហេតុ ការវាយគេ និងការកែលម្អប្រាស្រ័យទាក់ទងដោយប្រើក្រសែភ្នែក។ គេបានបង្រៀនឪពុកម្តាយឱ្យកត់ត្រាទុកពីទិន្នន័យដើមសម្រាប់ចំណុចដៅអាកប្បកិរិយានៅលើតារាងរចនាសម្ព័ន្ធមួយនៅឯផ្ទះដែលរាប់បញ្ចូលទាំងរយៈពេល និងភាពញឹកញាប់នៃចំណុចដៅរបស់អាកប្បកិរិយា។

ចំពោះការវិភាគពីសកម្មភាពវិញ គេរកឃើញថាតារាចូលចិត្តតន្ត្រី ការរ៉េម នំបីស្គីត និងការចេញទៅដើរលេង។ គេក៏បានរកឃើញដែរថា ទាំងឪពុក និងម្តាយរបស់តារាទម្រើសកូនខ្លាំងពេក និង ការពារកូនខ្លាំងពេក ហើយឪពុករបស់គេមិនបានដាក់ពិន័យកូនឱ្យបានខ្ជាប់ខ្ជួន។ គេរកឃើញ ថាឪពុកម្តាយរបស់តារាតែងតែធ្វើតាមការទាមទាររបស់គេនៅពេលណាដែលគេយំយូរ។

គេបានផ្តល់ដំបូន្មានដល់ឪពុកម្តាយឱ្យធ្វើមិនអើពើចំពោះកូននៅពេលណាដែលគេយំ និងស្រែក ហើយមិនឱ្យតាមការទាមទាររបស់គេ(លុបបំបាត់)។ គេក៏បានផ្តល់ដំបូន្មានដល់ឪពុកម្តាយផងដែរឱ្យមានភាពអត់ធ្មត់ នៅពេលណាដែលគាត់វាយគេ ឬដាក់ពិន័យវាតាមរយៈការដកហូតនូវការលើកទឹកចិត្តសម្រាប់គាត់(ផ្អាកសកម្មភាព)។ គេសុំឱ្យម្តាយរបស់តារាផ្តល់រង្វាន់ដល់តារាតាមរយៈការឱប ឬការថើប(ការអនុវត្តបន្ថែមបែបវិជ្ជមាន)នៅពេលណាដែលតារាព្យាយាម(ទោះបីមួយផ្នែកក៏ដោយ) មើលទៅម្តាយគាត់នៅពេលដែលគាត់ហៅ(ការសម្តែង)។

គេវាយតម្លៃតារាជាប់ជាប្រចាំតាមរយៈការកត់ត្រាទុកនូវភាពញឹកញាប់ និងរយៈពេលនៃ

ចំណុចដៅរបស់អាកប្បកិរិយា។ វាបង្ហាញឱ្យឃើញថា គាត់បានកាត់បន្ថយការយំបាន៥០% កាត់បន្ថយការវាយគេបាន៧៥% និងកែលម្អការប្រាស្រ័យទាក់ទងដោយប្រើក្រសែភ្នែកបាន ៥០%។ តាពត្រូវបន្តការគ្រប់គ្រងអាកប្បកិរិយា ហើយគេចាប់ផ្តើមកែលម្អការប្រាស្រ័យទាក់ទងរបស់គាត់(ការ និយាយ និងភាសា) ព្រមទាំងបំណិនក្នុងការជួយខ្លួនឯង។

## វិធីសម្រាប់កាត់បន្ថយវិបត្តិអាកប្បកិរិយា៖

គេបានរកឃើញថា វិធីខាងក្រោមនេះមានប្រយោជន៍ណាស់ក្នុងការបង្កើនអាកប្បកិរិយាវិជ្ជមាន។

### ការផ្តល់រង្វាន់៖

ជារឿយៗអាកប្បកិរិយាត្រូវបានកំណត់ដោយផលវិបាកផ្សេងៗរបស់វា។ យើងមានបំណងចង់បន្តឱ្យមានអាកប្បកិរិយាជាក់លាក់ប្រសិនបើផលវិបាករបស់វាបង្កឱ្យមានភាពរីករាយ។ ឪពុកម្តាយ និងគ្រូបង្រៀនធ្វើឱ្យកុមាររៀនសូត្រតាមរយៈការលើកទឹកចិត្ត ការសរសើរ និងការផ្តល់រង្វាន់។ ទាំងអស់នេះហៅថា ការផ្តល់រង្វាន់។ គេកំណត់ការផ្តល់រង្វាន់ថាជាព្រឹត្តិការណ៍មួយដែលកើតឡើងបន្ទាប់ពីមានអាកប្បកិរិយាមួយ។ ការផ្តល់រង្វាន់មិនមែនមានន័យថាទាល់តែជា«វត្ថុល្អ» ឬ«ភាពរីករាយ»ជានិច្ចនោះទេ។ វា គឺជាអ្វីមួយដែលអាចបង្កើនភាពដែលអាចកើតមាននូវអាកប្បកិរិយាជាក់លាក់មួយ។

**រង្វាន់មាន៣ប្រភេទ៖**

១. រង្វាន់ទី១ មានសារៈសំខាន់សម្រាប់ ជីវិត។ ឧទាហរណ៍ ម្ហូបអាហារ ទឹក ដំណេក ។ល។

២. រង្វាន់ទី២ ជាព្រឹត្តិការណ៍ ឬវត្ថុដែលជារង្វាន់ ព្រោះវាជាគូជាមួយនឹងរង្វាន់ទី១។ ឧទាហរណ៍ លុយ ពិន្ទុ ។ល។

៣.រង្វាន់ផ្នែកសង្គមៈគឺជាព្រឹត្តិការណ៍ ឬវត្ថុដែលមានសារៈសំខាន់សម្រាប់អារម្មណ៍។ ឧទាហរណ៍ ការយកចិត្តទុកដាក់ ការសរសើរ ការញញឹម ការឱប ។ល។

រង្វាន់ទី២ ឬរង្វាន់ផ្នែកសង្គម មានភាពងាយស្រួលជាង អាចរកបានដោយស្រួល អាចទទួលយកបាន និងមានលក្ខណៈកម្មវត្ថុតិចតួច ដើម្បីឱ្យមានភាពស្កប់ស្កល់ បើប្រៀបធៀបទៅនឹងរង្វាន់ទី១។ ក្នុងករណី ដែលកុមារខ្សោយសតិបញ្ញាធ្ងន់ធ្ងរ រង្វាន់បឋមមានប្រសិទ្ធភាពជាងរង្វាន់ផ្សេងៗទៀត។

### វិធីជ្រើសរើសការផ្តល់រង្វាន់៖

១. សួរកុមារដោយផ្ទាល់

២. សួរឪពុកម្តាយ បងប្អូន ឬអ្នកមើលថែ

៣. ប្រសិនបើវិធីទាំង២ខាងលើមិនមានប្រយោជន៍ទេ ការផ្តល់ឱ្យនូវរង្វាន់ផ្សេងៗជាច្រើនដូចជាម្ហូបអាហារ ឬភេសជ្ជៈឱ្យកុមារ ហើយពិនិត្យមើលតើគេជ្រើសរើសយកមួយណាញឹកញាប់ជាង។ (វិធីទាក់ទងនឹងការពេញចិត្តដោយផ្ទាល់)។

៤. ចំពោះកុមារដែលពុំមានការពេញចិត្តរបស់អ្វីមួយជាក់លាក់ ចូរសង្កេតមើលថាតើកុមារធ្វើអ្វីញឹកញាប់ជាងគេបំផុត។ បន្ទាប់មកប្រើប្រាស់ការពេញចិត្តនេះដោយយកសកម្មភាពដែលញឹកញាប់ជាងគេធ្វើជារង្វាន់មួយ ឧទាហរណ៍ អាកប្បកិរិយាដើរជុំវិញ«កន្លែងអង្គុយ» ឬអាកប្បកិរិយាបុរេនិច្ច័យ។

## ការបង្ហាញរង្វាន់៖

គេត្រូវអនុវត្តតាមចំណុចសំខាន់ចំនួន ៤ នៅពេលបង្ហាញរង្វាន់។

១. ការបម្រុងទុក៖ ការផ្តល់រង្វាន់គួរត្រូវបានគេផ្តល់ឱ្យនៅពេលណាដែលវិបត្តិអាកប្បកិរិយាកើតឡើងប៉ុណ្ណោះ។
២. ភ្លាមៗ៖ ការផ្តល់រង្វាន់គួរត្រូវបានគេផ្តល់ឱ្យភ្លាមៗបន្ទាប់ពីអាកប្បកិរិយាវិជ្ជមានកើតឡើង។
៣.ភាពស៊ីសង្វាក់គ្នា៖ គេត្រូវពង្រឹងអាកប្បកិរិយាបន្ថែមនៅរាល់ពេលដែលវាកើតឡើងជាពិសេសនៅដំណាក់កាលដំបូងក្នុងកម្មវិធីបណ្តុះបណ្តាល។
៤. ការបញ្ជាក់៖ កុមារត្រូវដឹងឱ្យបានច្បាស់ពីហេតុផល ដែលត្រូវបានរង្វាន់។

កម្មវិធីសម្រាប់ការផ្តល់រង្វាន់៖

គេអាចផ្តល់រង្វាន់បន្ទាប់ពីការឆ្លើយតបបានត្រឹមត្រូវនូវចំណុចនីមួយៗខាងក្រោម។ ចំណុចទាំងនេះគឺជាកម្មវិធីបន្តបន្ទាប់មួយនៃការផ្តល់រង្វាន់។ ចំពោះកម្មវិធីចន្លោះៗ រង្វាន់នឹងផ្តល់ឱ្យនូវការឆ្លើយតបជាក់លាក់ខាងក្រោមនេះប៉ុណ្ណោះ។ ប្រភេទទី១គឺមានប្រសិទ្ធភាពចំពោះការបង្កើតអាកប្បកិរិយាថ្មីៗ។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទទី២មានលក្ខណៈទូទៅ និងស៊ាំទៅនឹងការលុបបំបាត់ច្រើនជាង។ គេត្រូវតែរៀបចំផែនការសម្រាប់កម្មវិធីផ្តល់រង្វាន់ជាមុន និងឱ្យបានហ្មត់ចត់សម្រាប់លទ្ធផលដែលគេចង់បាន។

## ប្រភេទនៃកម្មវិធី៖

មានប្រភេទកម្មវិធីចំនួន ៤ សម្រាប់ការផ្តល់រង្វាន់ចោះៗ។

១. រង្វាន់អាចផ្តល់ឱ្យបន្ទាប់ពីមានការឆ្លើយតបនូវចំនួនជាក់លាក់មួយ។ កម្មវិធីប្រភេទនេះ ជាកម្មវិធីសមាមាត្រកំណត់ជាក់លាក់។

២. រង្វាន់អាចផ្តល់ឱ្យបន្ទាប់ពីមានការឆ្លើយតបចំនួនពីរបីលើកដែលអាចមានភាពខុសគ្នា។ នេះជាកម្មវិធីសមាមាត្រដែលមានការប្រែប្រួល។

៣. រង្វាន់អាចផ្តល់ឱ្យបន្ទាប់ពីមានចន្លោះពេលជាក់លាក់រៀងរាល់១៥វិនាទីម្តង។ កម្មវិធីនេះ គឺជាកម្មវិធីដែលមានចន្លោះពេលជាក់លាក់។

៤. រង្វាន់អាចផ្តល់ឱ្យនៅតាមចន្លោះពេលខុសៗគ្នានៃរយៈពេល១៥វិនាទី ឬ ២០វិនាទី ឬ១០វិនាទីចុងក្រោយ។ កម្មវិធីនេះគឺជាកម្មវិធីដែលមានចន្លោះពេលខុសៗគ្នា។

ការប្រើប្រាស់នូវកម្មវិធីខុសៗគ្នាធ្វើឱ្យមានការឆ្លើយតបខុសៗគ្នាដែរ។ កម្មវិធីសមមាត្រដែលមានការប្រែប្រួល និងចន្លោះពេលដែលមានការប្រែប្រួលផ្តល់នូវភាពស៊ាំចំពោះការលុបបំបាត់ច្រើនជាងកម្មវិធីដែលគ្មានការប្រែប្រួល ប៉ុន្តែវាមានការលំបាកជាងក្នុងការផ្តល់លក្ខណៈជាប្រព័ន្ធ និងត្រឹមត្រូវ។

ជំហានក្នុងការអនុវត្តកម្មវិធីផ្តល់រង្វាន់៖

**១. មានគោលបំណងជាក់លាក់៖** ឧទាហរណ៍ តារានឹងមើលមុខរបស់អ្នកព្យាបាលចលនា និងមានការទាក់ទងគ្នាដោយប្រើក្រសែភ្នែក នៅពេលអ្នកព្យាបាលចលនាហៅឈ្មោះរបស់គេ និងនិយាយជាមួយគេ។

**២. កំណត់ការផ្តល់រង្វាន់៖** ឧទាហរណ៍ តារាចូលចិត្តសូកូឡា គេសជ្ជៈដែលត្រជាក់ ប្រដាប់ក្មេងលេង និងចង់ឱ្យគេថើប។

**៣. បង្រៀនពីអាកប្បកិរិយា៖** ឧទាហរណ៍ នៅពេលដែលគ្រូហៅតារា ប្រសិនបើគេមើលមុខអ្នកព្យាបាលចលនា ឬ ក្រសែភ្នែកទាក់ទងគ្នាសូម្បី១វិនាទីក៏ដោយ គ្រូត្រូវផ្តល់សូកូឡាឱ្យគាត់ជាបន្ទាន់ ឬថើបថ្ពាសរបស់គាត់ជារង្វាន់។

**៤. បន្ថយការផ្តល់រង្វាន់៖** ឧទាហរណ៍ ប្រសិនបើកុមាររៀនមើលភ្នែករបស់អ្នកព្យាបាលចលនាកាន់តែជាប់លាប់មែនទែនហើយ គ្រូត្រូវកាត់បន្ថយជាបន្តបន្ទាប់នូវការផ្តល់រង្វាន់ដែលជាចំណីអាហារ ហើយប្រើប្រាស់ការសរសើរ និងការថើបជាការលើកទឹកចិត្តជំនួសវិញ។

វាជាការប្រសើរក្នុងការចាប់ផ្តើមមេរៀនខ្លីៗដែលមានរយៈពេលពី៥-១០នាទី ដោយមានការសាកល្បង សម្រាប់រយៈពេលពី១០-២០នាទីក្នុង១មេរៀន។ មេរៀនខ្លីៗជាច្រើនអាចចំណាយពេលរហូតដល់១ថ្ងៃ។

គេក៏ត្រូវប្រើប្រាស់ការផ្តល់រង្វាន់ចម្រុះដែរសម្រាប់ការដកចេញនូវរង្វាន់ចោះៗដើម្បីទប់ស្កាត់ភាពជិនណាយ ប្រសិនបើកុមារចាប់ផ្តើមធុញទ្រាន់នឹងរង្វាន់ ឬការលើកទឹកចិត្តដដែលៗ។ នៅក្នុង

ដំណើរការនៃការព្យាបាល គេអាចកែសម្រួលកម្មវិធីចន្លោះៗសម្រាប់ការផ្ដល់រង្វាន់(កម្មវិធីសមមាត្រដែលមានការប្រែប្រួល ឬចន្លោះពេលដែលមានការប្រែប្រួល)បាន ដើម្បីជៀសវាងការលុបបំបាត់អាកប្បកិរិយានៃការរៀនសូត្រ។

# មេរៀនទី១២
# វិធីក្នុងការវាយតម្លៃ និងការឱ្យសិស្សឡើងថ្នាក់

**វត្ថុបំណង៖** វត្ថុបំណងរបស់មេរៀននេះគឺ ដើម្បីយល់ និងរៀនសូត្រពីវិធីនៃការវាយតម្លៃ និង លក្ខណៈ វិនិច្ឆ័យនៃការឱ្យសិស្សឡើងថ្នាក់នៅថ្នាក់មត្តេយ្យសិក្សា និងថ្នាក់បឋមសិក្សា។

## វិធីនៃការវាយតម្លៃ៖

កុមារពិការអាចត្រូវបានបង្រៀននៅកម្រិតមត្តេយ្យ និងបឋមសិក្សា ដោយប្រើប្រាស់កម្មវិធីសិក្សាទូទៅដែលមានស្រាប់ ប្រសិនបើមានការសម្របសម្រួល និងការកែលម្អដ៏សមស្រប។

ដោយផ្អែកលើកម្រិតនៃដំណើរការបច្ចុប្បន្នរបស់កុមារផងដែរ បញ្ជីវាយតម្លៃតម្រូវការរបស់កុមារអាចដំណើរការសម្រាប់ការរៀបចំកម្មវិធី ប្រហែលជាត្រូវបានគេប្រើប្រាស់សម្រាប់កុមារនៅក្នុងសាលារៀនអប់រំពិសេស។ គ្រូបង្រៀនត្រូវអានចំណុចនីមួយៗដោយប្រុងប្រយ័ត្ន ហើយតាមរយៈកម្រិតនៃ ការអនុវត្ត ចូរជ្រើសរើសសញ្ញាសម្គាល់ដែលសមស្រប ដូចជា មាន(+) មានន័យថាកុមារអាចអនុវត្តកិច្ចការដោយពុំមានជំនួយ ការផ្តល់តម្រុយម្តងម្កាល មានន័យថាគេត្រូវការផ្តល់ឱ្យកុមារនូវតម្រុយ ផ្សេងៗដែលកុមារត្រូវ«ការគិត»ដើម្បីអនុវត្តការកិច្ចដែលគេផ្តល់ឱ្យ ការនិយាយប្រាប់ ការធ្វើកាយវិការបង្ហាញ "ទេ"(-)មានន័យថាគេត្រូវជួយកុមារទាំងស្រុងដើម្បីបំពេញកិច្ចការ ការមិនអាចអនុវត្តបាន និងមិនយល់ មានន័យថាខ្វះឱកាសក្នុងការរៀនសូត្រ។

## ការដាក់ពិន្ទុ៖

ចំណុចនានាដែលដាក់សញ្ញាសម្គាល់ថា មាន ឬ(+) ឬការផ្តល់តម្រុយម្តងម្កាល ត្រូវបានគេរាប់ថាជាពិន្ទុ ចំណែកឯចំណុចផ្សេងៗទៀត ដូចជា ការធ្វើកាយវិការបង្ហាញ ការនិយាយប្រាប់ មិនយល់ ត្រូវបានគេកត់ត្រាទុក ប៉ុន្តែមិនរាប់ថាជាពិន្ទុនៅក្នុងផ្នែកនានានៃការរស់នៅឬសកម្មភាពប្រចាំថ្ងៃផ្ទាល់ខ្លួន ផ្នែកសង្គម អប់រំ និងមុខរបរទេ។ ដោយសារតែគោលបំណងចុងក្រោយគឺត្រូវសម្រេចឱ្យបាននូវឯករាជ្យភាពចំពោះផ្នែកមួយនៃសកម្មភាពដែលគេផ្តល់ឱ្យ សកម្មភាពទាំងឡាយណាដែលកុមារបំពេញដោយឯករាជ្យ ឬមានការផ្តល់តម្រុយយូរៗម្តង ប៉ុណ្ណោះដែលគេនឹងគិតជាលេខសម្រាប់ដាក់ពិន្ទុ។

## ការដាក់ពិន្ទុទៅលើសកម្មភាពកម្សាន្ត៖

ចំណុចនានាដែលស្ថិតនៅក្រោមការកម្សាន្តមិនចាំបាច់គិតជាគុណសម្បត្តិ និងការគិតឱ្យសិស្សឡើងថ្នាក់ទេ ដោយសារចំណុចទាំងនេះជាមូលដ្ឋាននាំឱ្យមានការចាប់អារម្មណ៍។ កម្រិតផ្សេងៗដែលកត់សម្គាល់ដូចខាងក្រោមបង្ហាញពីការចូលរួមនៅក្នុងសកម្មភាពកម្សាន្តសម្រាប់កុមារ។

A = ផ្តួចផ្តើមគំនិត និងចូលរួមប្រកបដោយប្រសិទ្ធភាព

B = ចូលរួមនៅពេលអ្នកផ្សេងទៀតផ្តួចផ្តើមគំនិត

C = ចូលរួមដោយខ្លួនឯង ប៉ុន្តែមិនយល់ពីក្បួននៃការលេងល្បែងទេ

D = មើលគេលេងដោយការចាប់អារម្មណ៍

E = មិនចាប់អារម្មណ៍ (មិនអើពើ)

NE = មិនយល់

## លក្ខណៈវិនិច្ឆ័យសម្រាប់ឱ្យសិស្សឡើងថ្នាក់៖

ដោយមានការសម្របសម្រួល និងការកែលម្អសមស្រប លក្ខណៈវិនិច្ឆ័យនៃការឱ្យសិស្សឡើងថ្នាក់ដែលមានស្រាប់នឹងត្រូវបានគេអនុវត្តសម្រាប់កុមារពិការនៅសាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សា។ហើយសម្រាប់កុមារដែលគេបង្រៀនដោយប្រើបញ្ជីវាយតម្លៃពីតម្រូវការ សម្រាប់ដំណើរការរៀបចំកម្មវិធី ការសម្រេចបាន៨០%នៃចំណុចនានានៅក្នុងបញ្ជីវាយតម្លៃពីតម្រូវការនឹងត្រូវបានគេពិចារណាដើម្បីឱ្យសិស្សឡើងថ្នាក់ពីកម្រិតមួយទៅកម្រិតមួយទៀតដែលខ្ពស់ជាងមុន។ ឧទាហរណ៍ កុមារដែលសម្រេចបាន ៨០% នៃចំណុចនានានៃបញ្ជីវាយតម្លៃពីតម្រូវការនៅកម្រិតសាលាមត្តេយ្យសិក្សានឹងត្រូវបានឱ្យឡើងថ្នាក់ទី១នៃសាលាបឋមសិក្សា។

# ឈ្មោះក្រុមការងាររៀបចំឯកសារ

| ល.រ | ឈ្មោះ | អង្គភាព | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|
| 1. | Dr. Surendra Singh | International Consultant, Australia | +61425784678 | surendra@y7mail.com |
| 2. | Mr. Sok Boreth/ លោក សុខ បូរ៉េត | MoEYS (SED) | 011 625 244 | |
| 3. | លោក អួក សុខា | នាយកដ្ឋានធានាគុណភាពអប់រំ | 012 521 053 | |
| 4. | លោកស្រី វ៉ាន់ សុភី | នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា | 012 997 386 | |
| 5. | លោក អ៊ូ សារឿន | នាយកដ្ឋានបឋមសិក្សា | 092 899 712 | |
| 6. | លោក ឈឹម ឌីណា | នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ | 011 714 709 | |
| 7. | Mr. Sarang OUT អ៊ុត សារ៉ង | Save the Children | 012 46 16 39 | sarang.out@savethechildren.org |
| 8. | Mr. El Lep អែល ឡឹប | Save the Children | 012 51 99 09 | lep.el@savethechildren.org |
| 9. | Mr. Hak Sokly ហាក់ សុខលី | Operations Enfants du Cambodge (OEC) | 077 77 22 43 | oec_alya@yahoo.com |
| 10. | Mr. Hun Touch/ ហ៊ុន ទូច | Rabbit School Organization | 0123693760 | huntouch40@gmail.com |
| 11. | Mr. Vong Vuthy/ វង្ស វុទ្ធី | Rabbit School Organization | 093851047 | vuty_info@email.com |
| 12. | Ms. Srey Kalyan/ ស្រី កល្យាណ | Rabbit School Organization | 017710058 | tn.rabbitschool@gmail.com |
| 13. | Mr. Chan Sarin/ លោក ចាន់ សារិន | Hands of Hope Community (HHC) | 012 777 042 | chan.sarin9@gmail.com/ hhc.edirector@gmail.com |
| 14. | Mr Hout Puthy លោក ហួត ពុទ្ធី | Hands of Hope Community (HHC) | 017 351 396 | huot.puthy@hhccambodia.org |
| 15. | Mr Sdeng Chinda លោក ស្តើង ចិន្តា | Hands of Hope Community (HHC) | 016 550 022 | sdeng.chenda@hhccambodia.org |
| 16. | Mrs. Kim Phalla/ គឹម ផល្លា | Jesuit Service Cambodia (JSC) | 089 283-285/ 081 37 11 25 | Phall.samnob@gmail.com |
| 17. | Togni Cristina | Jesuit Service Cambodia (JSC) | 012 983 460 | togni_cristina@yahoo.it |
| 18. | Mrs. Ly Sophea/ លី សោភា | Pour un Sourire d'Enfant (PSE) | 0116 58 939 | sophea.ly@pse.ngo |
| 19. | Mr. Kim Chhorn | Krousar Thmey | 012 841 047 | kimchhorn@yahoo.com |

# ឈ្មោះក្រុមការងារពិគ្រោះយោបល់

| ល.រ | ឈ្មោះ | អង្គភាព | ទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|
| 1. | ឯកឧត្តម ពុត សាមិត | MoEYS | 012 914 297 | putsamith@yahoo.com |
| 2. | លោក ថោង រិទ្ធី | MoEYS (SED) | 012 728 070 | |
| 3. | លោក ភុំ សារិទ្ធ | MoEYS (SED) | 012 823 617 | phum.sarith@moeys.gov.kh |
| 4. | លោកស្រី ប៉ែន ថាវី | MoEYS (SED) | 012 387 279 | |
| 5. | លោក លាង សុខខេង | MoEYS (SED) | 012 675 806 | sokkheng134@yahoo.com |
| 6. | លោក នី ពុត | MoEYS (SED) | 093 331 286 | |
| 7. | លោក ស្រី កុម្ភារ៉ា | MoEYS (SED) | 012 229 933 | sreykompheara@gmail.com |
| 8. | Mr. Sean Kosal/ លោក សៀន កុសល | CRS | 012 906 756 | kosal.sean@crs.org |
| 9. | Mr. Soeurn Savath/ លោក សឿន សាវ៉ាត | KPF | 012 603 877 | savath.soeun@komarpikar.org |
| 10. | Mr. Nhork Kimhor/ លោក ញ៉ក់ គឹមហោ | CAMYOD | 012 581 841 | nhorkkimhor@yahoo.com |
| 11. | Mr. Heang Sarym/ លោក ហៀង សារីម | AEA | 092 768 992 | sarym.heang@aide-et-action.org |
| 12. | Mr. Ann Kimheng/ លោក អាន់ គឹមហេង | Sun Rise | 092 545 452 | kimheng@sunrisecambodia.org.kh |
| 13. | Dr. Hong Chea/ លោកវេជ្ជបណ្ឌិត ហុង ជា | CCAMH | 011 633 773 | chea.hong@caritascambodia.org |
| 14. | Ms. Thai Soda (ថៃ សុដា) Shannon Meehan | NEP | 061 777091<br>092 233550 | pc@nepcambodia.org<br>advisor@nepcambodia.org |
| 15. | Vincent Stange | MCC | 095 719 363 | vincentstange@mcc.org |
| 16. | Lam Socheat/ ឡាំ សុជាតិ | AEA | 012 718 611 | socheat.lam@aide-et-action.org |
| 17. | Ms. Tomoko Sonoda | AAR | 097 9 051 263 | cambodia@aarjapan.gr.jp |
| 18. | Ms. Mam Lay/ កញ្ញា ម៉ម ឡៃ | CCAMH | 089 824 316 | ccamh-admin@caritascambodia.org |

# ឯកសារឧបសម្ព័ន្ធ

## ១. សេចក្តីណែនាំ សម្រាប់គ្រូសម្របសម្រួល

- *ផែនការសម្រាប់បណ្តុះបណ្តាល*
- *កិច្ចតែងការសម្រាប់បណ្តុះបណ្តាល*

## ២. លំហូរ វិធី គន្លឹះ និងល្បិចបង្រៀនបំណិនអំណានភាសាខ្មែរ

*ឯកសារជំនួយសម្រាប់គ្រូ ក្នុងការបង្រៀនបំណិនអំណានភាសាខ្មែរ នៅបឋមសិក្សាពិសេសថ្នាក់ទី១*

## ៣. ឯកសារប្រតបត្ត

*សម្រាប់បង្រៀនមេរៀនភាសាខ្មែរ ថ្នាក់ទី១ មានចំនួន១០មេរៀន*

# ក្រសួងអប់រំ យុវជន និងកីឡា

និង

# អង្គការសង្គ្រោះកុមារ

## សូមថ្លែងអំណរគុណ

ចំពោះអង្គការដៃគូក្នុងដំណើរការចងក្រងឯកសារជំនួយការអប់រំកុមារពិការសតិបញ្ញាដូចជា៖